# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

# និង

# បរមត្ថមញ្ជូសាមហាដីកា

# សមាធិនិទ្ទេស

# ភាគទី ២

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៤

# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

# និង

# បរមត្ថមញ្ជូសាមហាដីកា

# សមាធិនិទ្ទេស

# ភាគទី ២

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ ៨ កើត ខែពិសាខ ពុទ្ធសករាជ ២៥៥៤

*ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុជាត*



ឧបាសិកា ហុង គឹមសែ ឧបាសក ឆាយ អ៊ីវស៊ាង

ម្ចាស់ធម្មទាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ២២៤ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១០

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ពិតថេរដីកា
## ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ*០១/១០ស.ធ.អ.យ.ផ* ចុះថ្ងៃទី*២៣* ខែ*តុលា* ឆ្នាំ*២០០៩* ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

***ចម្លងជូន :***
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តបាត់ដំបង
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# និទានវចនៈ

**វិសុទ្ធិមគ្គ** ជាបករណ៍វិសេស ដែលព្រះថេរៈ **អ្នកស្រុកជម្ពូទ្វីប** មានឈ្មោះ បោះសំឡេងមួយរូប បានរចនាឡើង កាលព្រះពុទ្ធសាសនាកន្លងទៅហើយបាន ប្រមាណ ១.០០០ ឆ្នាំ **នៅកោះលង្កាទ្វីប** ព្រះថេរៈរូបនេះ គឺព្រះពុទ្ធឃោសៈ ឯលោកក៏បានរចនាគម្ពីរទុកជាច្រើន នៅក្នុងបវរនៃព្រះពុទ្ធសាសនា ជាការងារ ដ៏ធំ និងជាមរតក រហូតមកដល់សព្វថ្ងៃ ។ ការប្រែ **គម្ពីរព្រះត្រៃបិដក អដ្ឋកថា** ពី **ភាសាសីហឡៈ** មកជា **ភាសាមគធៈ** ឬ **ភាសាបាលី** ព្រះពុទ្ធឃោសៈបាន ប្រមូលធម៌នៅក្នុងព្រះត្រៃបិដក មកសម្ដែងទុកជាពួកៗ តាំងពី **សីល សមាធិ** និង **បញ្ញា** តាមលំដាប់ ។

ឯការរៀបរៀងជាការតែងសំណួរ ឬលំដាប់នៃការឆ្លើយសំណួរធម៌ក្នុង បច្ចុប្បន្ន គឺអធិប្បាយសេចក្ដីសង្ខេបឲ្យពិស្ដារ បទសំណួររបស់ **វិសុទ្ធិមគ្គ** ពោលដោយត្រៃសិក្ខា ដែលជាមាតិកាធំក្នុងព្រះពុទ្ធសាសនា បទសំណួរទាំង អស់ គឺជាបេះដូងនៃការបដិបត្តិតែម្យ៉ាង ព្រោះព្រះពុទ្ធឃោសៈ បានអធិប្បាយ ដោយវិចិត្រពិស្ដារ និងមានរបៀបរៀបរយ បានអាងព្រះពុទ្ធវចនៈជាអាគតដ្ឋាន ទុកក្នុងទីនោះៗ ទូទៅ នេះសម្ដែងឲ្យដឹងថា លោកមានការបែកធ្លាយក្នុងព្រះ ត្រៃបិដក អាចលើកយកធម៌ ដែលពោលដោយសីល មករួបរួមទុកក្នុងពួក សីល លើកយកធម៌ដែលទាក់ទងជាមួយសមាធិ មករួបរួមទុកក្នុងពួកសមាធិ លើកយកធម៌ដែលទាក់ទងជាមួយបញ្ញា មករួមទុកជាមួយពួកបញ្ញា ដោយ

បែកជានិទ្ទេសៗ រួមទាំងអស់មាន **២៣ និទ្ទេស**, រីឯប្រវត្តិនៃការតែងវិសុទ្ធិមគ្គ ក៏បានក្លាយជាការប្រឡូងដេញដោល, ព្រោះព្រះថេរៈ ជាអ្នកស្រុកសីហឡៈ បានផ្ដើមបញ្ហាឲ្យលោកតែងជាមុន កាលបើលោកធ្វើបានជាទីពេញចិត្ត នឹងលើក **គម្ពីរអដ្ឋកថាភាសាសីហឡៈ** ឲ្យលោកប្រែជាភាសាមគធៈតទៅ ព្រះពុទ្ធឃោសាចារ្យបានធ្វើយ៉ាងរហ័ស និងល្អក្រៃលែង ជាទីពេញចិត្តរបស់ព្រះថេរៈអ្នកស្រុកសីហឡៈទាំងពួង, ដូច្នោះ **គម្ពីរវិសុទ្ធិមគ្គនេះ** ជាវិជ្ជានិពន្ធ ដើម្បីសាកល្បងចំណេះដឹងរបស់ព្រះពុទ្ធឃោសៈ ។

ព្រះពុទ្ធឃោសៈ មានដើមកំណើតនៅ **ប្រទេសឥណ្ឌា នាតំបន់ពុទ្ធគយា** បានសិក្សាជំនាញនៅក្នុងព្រះពុទ្ធវចនៈ ទ្រទ្រង់ព្រះត្រៃបិដក មានបញ្ញាដ៏ក្រៃលែង លោកបានធ្វើដំណើរទៅ **លង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ហើយបានរចនាគម្ពីរវិសុទ្ធិមគ្គនៅទីនោះ និងប្រែ **ព្រះបាលីអដ្ឋកថា** ពីភាសាសីហឡៈមកជាភាសាមគធៈ ( ភាសាបាលី ) ។

ព្រះថេរៈ មានឈ្មោះដែលគ្រូទាំងឡាយកាន់យកហើយថា **ពុទ្ធឃោសៈ** ជាអ្នកមានភាពបរិសុទ្ធបរិបូណ៌ ប្រដាប់ដោយសទ្ធា វិជ្ជា និងសេចក្ដីព្យាយាមដ៏បរិសុទ្ធយ៉ាងក្រៃលែង ជាបុគ្គលរុងរឿងដោយធម៌ ជាហេតុកើតនៃសេចក្ដីល្អ មានសីលាចារៈទៀងត្រង់ និងការឱនលំទោនជាដើម អាចឈោងចុះកាន់ជដៈ គឺលទ្ធិរបស់ខ្លួន និងលទ្ធិរបស់បុគ្គលដទៃ ប្រកបដោយការមុតស្រួចនៃបញ្ញា មានចំណេះដឹង មិនទើសទាក់ក្នុងសត្ថុសាសនៈ ដោយបរិយត្តិផ្សេងៗ គឺព្រះ

ត្រៃបិដក ព្រមទាំង **អដ្ឋកថា** ជា **មហាវេយ្យាករណ៍** ប្រកបដោយភាពវិចិត្រ នៃពាក្យសម្ដី ទាំងទន់ភ្លន់ទូលំទូលាយ បន្ទឹចេញបានស្អាត់ជំនាញ សទ្ទឲ្យកើត ករណសម្បត្តិ មានវាទៈប្រសើរត្រឹមត្រូវ បុគ្គលដទៃយល់បានងាយ ជាមហា កវី ហៃហាមដោយបដិសម្ភិទាដែលបែកធ្លាយ ជាអលង្ការនៃវង្ស ព្រះថេរៈដែល នៅក្នុងមហាវិហារទាំងឡាយ ដែលជាប្រទីបនៃថេរវង្ស មានការដឹងតាំងមាំល្អ ហើយ ក្នុង **ឧត្តរិមនុស្សធម្ម** ដែលប្រដាប់ដោយគុណផ្សេងៗ មាន **អភិញ្ញា ៦** ជាដើម ហៃហាមដោយ **បដិសម្ភិទា** បានរចនាវិសុទ្ធិមគ្គនេះចប់ហើយ ។

វិសុទ្ធិមគ្គនេះ តាំងនៅក្នុងលោក សម្ដែងន័យដល់កុលបុត្រទាំងឡាយ ដែលស្វែងរកធម៌ ជាគ្រឿងដកចេញនូវលោក ដរាបប៉ុនដែលព្រះនាមថា **ពុទ្ធោ** របស់ព្រះលោកជេដ្ឋៈ ដែលស្វែងរកគុណដ៏ធំ មានព្រះទ័យដ៏បរិសុទ្ធ ជាតាទិ-បុគ្គលប្រព្រឹត្តទៅក្នុងលោក ។

គម្ពីរវិសុទ្ធិមគ្គនេះបានរចនាដោយ

ព្រះពុទ្ធឃោសាចារ្យ

# ព្រះធម្មបាលត្ថេរ

## ព្រះថេរៈជាអ្នករចនា

## ព្រះគម្ពីរបរមត្ថមញ្ជូសាមហាដីកាវិសុទ្ធិមគ្គ

ខ្ញុំម្ចាស់ ( ព្រះធម្មបាលត្ថេរ ) ដែលព្រះទាឋានាគត្ថេរ ជាអ្នកមានសីល និងអាចារៈដល់ព្រមហើយ មានបញ្ញាជាគ្រឿងទ្រទ្រង់ មានការប្រព្រឹត្តបរិសុទ្ធ មានចិត្តតាំងមាំ អារាធនាហើយ ។ សូមថ្វាយវន្ទា ព្រះពុទ្ធជាម្ចាស់ប្រៀបដូចជាព្រះអាទិត្យ ទ្រង់មានព្រះសទ្ធម្មដូចជាភួងរស្មី ទ្រង់កម្ចាត់ងងឹត គឺមោហៈធំអស់ហើយ ទ្រង់ញុំាងពួកវេនេយ្យសត្វ ដែលប្រៀបដូចជាផ្កាឈូកឲ្យជីងវិសេស ទ្រង់មានព្រះបញ្ញាគុណដ៏វិសេស ដូចដួងព្រះអាទិត្យ មានព្រះវិសុទ្ធិគុណ និងព្រះករុណាគុណ ដូចជាពន្លឺអរុណដែលមិនមានភាពសៅហ្មងរះឡើងក្នុងលោក គួរដល់ការបូជា សូមថ្វាយវន្ទាព្រះធម៌ដែលបំភ្លឺដល់លោករុងរឿងដោយរស្មី គឺព្រះគុណ និងសូមនមស្ការព្រះអរិយសង្ឃ ដែលដូចជាផ្កាឈូកបរិសុទ្ធហើយ ដោយតេជះនៃបុណ្យ ចំពោះការថ្វាយវន្ទាព្រះរតនត្រ័យដែលកើតឡើងហើយ ដោយប្រការនោះៗ សូមប្រាសចាកអន្តរាយក្នុងទីគ្រប់ស្ថាន ខ្ញុំម្ចាស់នឹងអាស្រ័យបោរាណកថាមគ្គ ដើម្បីពណ៌នាខ្លឹមសារនៃបករណ៍វិសេស ឈ្មោះ **វិសុទ្ធិមគ្គ** ដែលប្រដាប់ដោយន័យដ៏បរិសុទ្ធ មានលំដាប់បទយ៉ាងប្រណីត ដែលព្រះអាចារ្យពុទ្ធឃោសៈបានពោលដើម្បីជាឧបាយក្នុងការសម្រេចភាពបរិសុទ្ធិដែលលោកជា **នាថ** មានព្រះចរិយាបរិសុទ្ធ មានហឫទ័យ

ដែលព្រះករុណាឲ្យឧស្សាហ៍ហើយ លោកបានសម្រេចហើយ សម្តែងទុកមិនឲ្យខុសពីលទ្ធិរបស់ព្រះថេរៈឯសម្នាក់មហាវិហារ ឲ្យបរិសុទ្ធយ៉ាងល្អ មិនរាត់រាយ មានវិនិច្ឆ័យសេចក្តីដ៏សុខុម ឲ្យបរិសុទ្ធ និងប្រកបដោយរបៀបរៀបរយ ។

សូមសាធុជនទាំងឡាយ តាំងចិត្តសិក្សានូវខ្លឹមសារនៃព្រះវិសុទ្ធិមគ្គនេះឲ្យបានល្អ ខ្ញុំប្រាថ្នាឲ្យព្រះសទ្ធម្មតាំងនៅអស់កាលយូរ ដោយប្រការដូច្នេះចុះ ។

**ព្រះធម្មបាលត្ថេរ** ជាជនជាតិស្រីលង្កា លោកបានសិក្សានៅក្នុងសំណាក់ **មហាវិហារ** នាក្រុង **អនុរាធបុរៈ** ក្នុង **លង្កាទ្វីប** បានចូលរួមរចនា **គម្ពីរអដ្ឋកថា** ជាមួយព្រះពុទ្ធឃោសាចារ្យដែរ, លោកបានរចនាអដ្ឋកថា និងមហាដីកា ទើបបានទទួលការលើកសរសើរថាជា ព្រះអដ្ឋកថាចារ្យ និង ព្រះដីកាចារ្យ នៅ **កោះលង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ។

គម្ពីរបរមត្ថមញ្ជូសាមហាដីកានេះរចនាដោយ

ព្រះធម្មបាលត្ថេរ

# អារម្ភកថា

ការបកប្រែរៀបរៀងឡើងនូវ **គម្ពីរវិសុទ្ធិមគ្គ** និង **បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស ភាគ ២ នេះ** យើងខ្ញុំបានរៀបរៀងដោយល្អមកជាខេមរភាសា និងរៀបរៀងទៅតាមលំដាប់នៃមាតិកានីមួយៗ យ៉ាងផ្ចិតផ្ចង់បំផុត មិនឲ្យឃ្លៀងឃ្លាតពីច្បាប់ដើម ដើម្បីជាប្រយោជន៍ដល់កុលបុត្តអ្នកជ្រះថ្លា ក្នុងព្រះរតនត្រ័យ និងជាពិសេសដើម្បីជាប្រយោជន៍ដល់ការសិក្សាផងខ្លួន ។

សូមសាធុជនទាំងឡាយ ដែលមានចិត្តកក្តីចំពោះព្រះរតនត្រ័យនោះ **អនុមោទនា** នូវបុណ្យរបស់ខ្ញុំ ដែលសម្រេចហើយដោយប្រការយ៉ាងនេះ ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាម **ខេត្ត ក្រុង** ជាច្រើននៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណា អាត្មាភាពបានសម្តែងព្រះធម៌នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗកន្លែង ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥០** ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ **រៀល ( ១៨ លាន ៤ សែន ៩ ម៉ឺន ៥ ពាន់រៀល )** និងប្រាក់ដុល្លារ **៦៤៥ ដុល្លារសហរដ្ឋអាមេរិក** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា** ដែលមានពុទ្ធបរិស័ទទៅ **ប្រមាណ ៦៥ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ១០** ព្រះអង្គផងដែរ ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុង

ការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅថ្វាយបង្គំបាន ៥១ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសិកា ឱម លក្ខណា នៅក្នុង ព.ស. ២៥៥០ ( ១០.០២.២០០៧ ) ។

## នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា
សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា
ជ្រះថ្លាក្រៃលែង ។
៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង
នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក
ក្នុង ព.ស. ២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥០ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់ រៀល ) និងប្រាក់ដុល្លារ ៤៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺ បុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានា នៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ

១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង បានការជួយជ្រោមជ្រែងឧបត្ថម្ភអំពីឧបាសក ឡាយ សុខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ិប វណ្ណា នៅក្នុង ព.ស. ២៥៥១ ( ០៤.០៤.២០០៨ ) ។

## នឹកឃើញលង្កា

នឹកឃើញលង្កា　នឹកឃើញកាលណា　ជ្រះថ្លាក្រៃលែង
នៅពុទ្ធស្ថាន　១៩ កន្លែង　ដែលខ្ញុំបានស្វែង
ទៅថ្វាយបង្គំ ។
១២១ អង្គា　គាល់ព្រះបាទា　ទាស្ថានមនោរម
លើសុមនកូដ　ជេស្ថាឧត្តម　ជាកំពូលភ្នំ
ក្នុងប្រវត្តិពុទ្ធ ។
ទឹកដីលង្កា　ទឹកដីអស្ចារ្យ　ពេញពោរដោយឫទ្ធិ
នឹកឃើញកាលណា　ជ្រះថ្លាក្រៃពិត　ធម្មយាត្រាប្រណីត
ក្នុង ព.ស. ២៥៥១ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥២ ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥១ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល ( ២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់

វៀល ) និងប្រាក់ដុល្លារ **១៩៥** ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺ បុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានា នៅក្នុង **ប្រទេសឥណ្ឌាជាលើកទីពីរ** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** មានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **អឿ សៅ** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៧** នាក់ ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥** ព្រះអង្គផងដែរ បានការឧបត្ថម្ភមកអំពីឧបាសក **ឃើត សូណាត** ឧបាសិកា **ហ៊ុន ម៉ារ៉ានី** M.SUSOKUNORAetMmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា **អ៊ឹង វិទ្ធារី** ឧបាសិកា **សួន កល្យាណ** ឧបាសិកា **សួន ចរណៃ** នៅក្នុង ព.ស. ២៥៥២ ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសកករាជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ ! ព្រះសាសនា ។
នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នាទស្សនា
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្ចង់ថ្វា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាជាលើកទី ២** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៣៦ នាក់** នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ៣** ព្រះអង្គផងដែរ បានការឧបត្ថម្ភមកអំពីឧបាសក **ឆាយ អ៊ីវស៊ាង** ឧបាសិកា **ហុង គឹមសែ** ក្រោមការជ្រោមជ្រែងរបស់ឧបាសក **យន្ត សួន** នៅក្នុង **ព.ស. ២៥៥២** ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥៣** ផ្នែកខាងសម្ដែងព្រះធម៌ដូចគ្នានឹង **ព.ស. ២៥៥២** ដែរ ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥៣** ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល ( **១៣ លាន ០ សែន ៨ ម៉ឺន** ) និងប្រាក់ដុល្លារ **២០៨ ដុល្លារ** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាជាលើកទី ៣** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១១១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៦** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **៩៦ កន្លែង** បានការជ្រោមជ្រែងអំពីឧបាសក **ឡាយ សុខុម** នៅក្នុង **ព.ស. ២៥៥៣** ( ២៥.០១.២០១០ ) ។

# ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ញប់ស្ញែងអស្ចារ្យ
ឱះ ឱ ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គ ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន
២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៤ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥៣ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល ( ៣១ លាន ៩ សែន ៩ មុឺន ) និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសឥណ្ឌាជាលើកទី ៤ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងមកពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៤ ( ២៧.០២.២០១១ ) ។

# គួរឱ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែប្រាន
ប្រៀបបានព្រៃស្ងាត់ ។
២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់
បូជនីយដ្ឋាន ១២ នាដែនពុទ្ធរដ្ឋ ធម្មយាត្រាកំណត់
ក្នុងពុទ្ធសករាជ ២៥៥៤ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. **២៥៥៥** ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. **២៥៥៤** ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥៥** ប្រាក់ខ្មែរបាន ៣៥,២៨២០០០ រៀល ( **៣៥ លាន ២ សែន ៨ ម៉ឺន ២ ពាន់រៀល** ) និងប្រាក់ដុល្លារ **២៧៥៨ ដុល្លារ** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា** ជាលើកទី ៥ ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៦៨ នាក់ ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥ ព្រះអង្គ**ផងដែរ ដោយទៅថ្វាយបង្គំបាន **១៤ កន្លែងធំៗ** បានការជ្រោមជ្រែងមកពីឧបាសិកា **អ៊ឹង វិទ្ធារី** នៅក្នុង ព.ស. **២៥៥៥** ( ០២.០២.២០១២ ) ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណាអាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាជាលើកទី ៣** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១៤០ នាក់** នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ៥ ព្រះអង្គ**ផងដែរ ដោយទៅថ្វាយបង្គំបាន **៩ កន្លែង**ធំៗ បានការឧបត្ថម្ភមកអំពីឧបាសិកា **អ៊ុង រិទ្ធារី** នៅក្នុង **ព.ស. ២៥៥៥** ( ២៧.០៣.២០១២ ) ។

## បានយល់ស្រុកព្រះ

| | | |
|---|---|---|
| ជ្រះថ្លាខ្លាំងណាស់ | បានយល់ស្រុកព្រះ | ជាតិភូមិសាស្ដា |
| ១៤ កន្លែង | ៦៨ អង្គា | បានក្រាបវន្ទា |
| | បូជាគ្រប់ប្រាណ ។ | |
| សិរីលង្កា | ១៤០ អង្គា | ៩ ពុទ្ធស្ថាន |
| ជ្រះថ្លាខ្លាំងណាស់ | ដែលពួកខ្ញុំបាន | នមស្ការពុទ្ធស្ថាន |
| | ក្នុងពុទ្ធសករាជ ២៥៥៥ ។ | |

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស **យង់ សុង** ( ស្លាប់ ) និងញោមស្រី **ឈឹម ហយ** ( ស្លាប់ ) ម្យ៉ាងទៀត ញាតិកានៅក្នុងសង្សារវដ្ដ ជាពិសេស

នោះ សូមលើកមហាកុសលទាំងអស់នេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **គាំ អ៊ីវ** ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះស្មើនឹងអាត្មាភាពផងដែរ សូម **អនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗគ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគត កុំបីអាក់ខានឡើយ ( **សូមឲ្យបានជាសាវកបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណាទីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១** ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៤

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿង កុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គីម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន ប៊ូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ឹម សុជាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន វណ្ណា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម វ៉ៃយ៉ា ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក ជិម ជំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ប៊ូ ស៊ីផូ ជួយពិនិត្យអក្ខរាវិរុទ្ធ

# សមាជិកសមាគមធម្មទានអរិយវង្សយ៉ំស៊ុផាត

សម្ដេចព្រះសង្ឃរាជគណមហានិកាយ នន្ទ ង៉ែត ជាប្រធានកិត្តិយស

ភិក្ខុ អគ្គបណ្ឌិតោ យ៉ំ ស៊ុផាត ជាប្រធានសមាគម

លោកអភិបាលស្រុក ស្រេង ស្រ៊ាង ជាទីប្រឹក្សាសមាគម

ឧបាសក អ៊ុម វ៉ែយ៉ោ ជាអនុប្រធានសមាគម

ឧបាសិកា ង៉ែត យូអេង ជាអនុប្រធានសមាគម

សាមណេរ ម៉ី សាលួន ជាលេខាធិការ

ឧបាសក ឡាន សុខុម ជាលេខាធិការរង

ឧបាសិកា តាំង ប៉េងជីង ជាហេរញ្ញិក

ឧបាសិកា ជា នាង ជាបេឡា

លោកគ្រូធម្មបណ្ឌិត អៀ សៅ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ឡាយ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា អ៊ុង រិទ្ធារី សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហោ ភាព សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា គួ ប៊ុនគាង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឈុំ គីមហួយ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ប៉ែន រមណីយ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឱម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អ៊ឹង ប៊ុនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា បួ ម៉ាឡា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ប៊ុន ហេង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ជុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មាស ម៉ូនីកា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឡឹក ពេញចិត្ត សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា សៀក ឆាយគីម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក បញ្ញោ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា កែវ កល្យាណ ជាសមាជិកសកម្ម

ឧបាសិកា ឡេង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហេង ចន្ទបុញ្ញាវតី ជាសមាជិកសកម្ម

ឧបាសក ហុង សុវណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហុង សុវណ្ណារ៉េត ជាសមាជិកសកម្ម

# មាតិកាធម៌


| មាតិកា | លេខទំព័រ |
|---|---|
| ១ – អសុភកម្មដ្ឋាននិទ្ទេស | ១ |
| – ឧទ្ទុមាតកអសុភកម្មដ្ឋាន | ៧ |
| – វិធីតាមមើលអសុភ | ៩ |
| – វត្តក្នុងការមើលអសុភ | ១១ |
| – ការកាន់យកនិមិត្ត ៦ ប្រការ | ១៤ |
| – វិនិច្ឆ័យឧគ្គហនិមិត្តជាដើម | ២៩ |
| – និមិត្ត ២ យ៉ាង ផ្សេងគ្នា | ៣៥ |
| – វិនីលកអសុភកម្មដ្ឋាន ... អដ្ឋិកអសុភ | ៤៩ |
| – បកិណ្ណកកថាអំពីអសុភ | ៦២ |
| ២ – ឆអនុស្សតិនិទ្ទេស | ៧៥ |
| – ពុទ្ធានុស្សតិ | ៧៧ |
| – បទថា អរហំ | ៧៨ |
| – បទថា សម្មាសម្ពុទ្ធោ | ១១១ |
| – បទថា វិជ្ជាចរណសម្បន្នោ | ១២៣ |
| – បទថា សុគតោ | ១២៩ |
| – បទថា លោកវិទូ | ១៣៨ |
| – ខ្នាតរបស់ចក្កវាឡជាដើម | ១៤០ |

- បទថា អនុត្តរោ ........ ១៥៩
- បទថា បុរិសទម្មសារថិ ........ ១៦៤
- បទថា អនុត្តរោ បុរិសទម្មសារថិ ........ ១៦៧
- បទថា សត្ថា ទេវមនុស្សានំ ........ ១៦៩
- បទថា ពុទ្ធោ ........ ១៧៧
- បទថា ភគវា និង នាម ៤ យ៉ាង ........ ១៨២
- ពុទ្ធានុស្សតិជ្ឈាន ........ ២២៣
- អានិសង្សនៃការចម្រើនពុទ្ធានុស្សតិ ........ ២២៩

៣ – ធម្មានុស្សតិ ........ ២៣២
- បទថា ស្វាក្ខាតោ ........ ២៣២
- បទថា សន្ទិដ្ឋិកោ ........ ២៦០
- បទថា អកាលិកោ ........ ២៦៣
- បទថា ឯហិបស្សិកោ ........ ២៦៥
- បទថា ឱបនយិកោ ........ ២៦៦
- បទថា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ........ ២៦៨
- ធម្មានុស្សតិជ្ឈាន ........ ២៧០
- អានិសង្សនៃការចម្រើនធម្មានុស្សតិ ........ ២៧១

៤ – សង្ឃានុស្សតិ ........ ២៧៣
- បទថា សុបដិបន្នោ ........ ២៧៣

- បទថា ឧជុ..ញាយ..សាមីចិបដិបន្នោ.................................. ២៧៤
- បទថា យទិទំ ជាដើម....................................................... ២៨០
- បទថា អាហុនេយ្យោ........................................................ ២៨១
- បទថា បាហុនេយ្យោ......................................................... ២៨៣
- បទថា ទក្ខិណេយ្យោ......................................................... ២៨៤
- បទថា អញ្ជលិករណីយោ.................................................... ២៨៤
- បទថា អនុត្តរំ..បុញ្ញក្ខេត្តំ..លោកស្ស................................... ២៨៧
- សង្ឃានុស្សតិដ្ឋាន........................................................... ២៨៧
- អានិសង្សនៃសង្ឃានុស្សតិដ្ឋាន........................................... ២៨៨

៥ – សីលានុស្សតិ.................................................................. ២៩០
- សីលានុស្សតិដ្ឋាន............................................................. ២៩១
- អានិសង្សនៃសីលានុស្សតិ.................................................. ២៩២

៦ – ចាគានុស្សតិ.................................................................. ២៩៦
- ចាគានុស្សតិដ្ឋាន និង អានិសង្ស........................................ ២៩៩

៧ – ទេវតានុស្សតិ................................................................ ៣០៤
- ទេវតានុស្សតិដ្ឋាន និង អានិសង្ស....................................... ៣០៥
- អនុស្សតិ ៦ សម្រេចដល់អរិយសាវក................................ ៣១០
- អនុស្សតិ ៦ សម្រាប់បុថុជ្ជន............................................. ៣១២

៨ –មរណស្សតិ................................................................... ៣១៧

- វិធីចម្រើនមរណស្សតិ.............................................................. ៣១៨
- មរណស្សតិដ្ឋាន................................................................... ៣៣៥
- អានិសង្សនៃមរណស្សតិ.......................................................... ៣៣៦

៩ –កាយគតាសតិ................................................................... ៣៦០

- ភាវនានៃកាយគតាសតិ.......................................................... ៣៦៣
- ឧគ្គហកោសល្យ.................................................................... ៣៦៤
- វិធីស្វាធ្យាយ......................................................................... ៣៦៥
- មនសិការកោសល្យ................................................................ ៣៦៩
- ការកំណត់កោដ្ឋាស ៣២.......................................................... ៣៩៥
- និមិត្ត និង អប្បនា................................................................ ៤២៥
- អានិសង្សនៃការចម្រើនកាយគតាសតិ.......................................... ៤២៦

# អសុភកម្មដ្ឋាននិទ្ទេស

------◎------

ក្នុងអសុភដែលមិនមានវិញ្ញាណ ១០ គឺ **ឧទ្ធុមាតក វិនីលក វិបុព្វក វិច្ឆិទ្ទក វិក្ខាយិតក វិក្ខិត្តក ហតវិក្ខិត្តក លោហិតក បុឡុវក អដ្ឋិក** នេះ ទ្រង់សម្តែងទុកក្នុងលំដាប់នៃកសិណ ។

## ឧទ្ធុមាតកអសុភ

**អសុភ** ដែលឈ្មោះថា **ឧទ្ធុមាត** ព្រោះជាសាកសពដែលហើមប៉ោង ដោយភាពដែលអសុភនោះ ហើមប៉ោងឡើងតាមលំដាប់តាំងអំពីអស់ជីវិតទៅ ដូចបាល់ដែលប៉ោងដោយខ្យល់ **ឧទ្ធុមាត** នោះឯងជា **ឧទ្ធុមាតក** ។ ន័យម្យ៉ាងទៀត **ឧទ្ធុមាត-អសុភ** ចាត់ថាជារបស់គួរខ្ពើម ព្រោះជាវត្ថុបដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា **ឧទ្ធុមាត** ។ ពាក្យថា **ឧទ្ធុមាតក** នោះ ជាពាក្យហៅសាកសពដែលមានសភាពដូច្នោះ ។

## វិនីលកអសុភ

**អសុភ** ដែលមានពណ៌ខៀវចាស់ លាយដោយពណ៌ផ្សេងៗ ហៅថា **វិនីល** , **វិនីល** នោះឯងជា **វិនីលក** ។ ន័យម្យ៉ាងទៀត **វិនីលអសុភ** ចាត់ជារបស់គួរខ្ពើម ព្រោះជាវត្ថុបដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា **វិនីលក** ។ ពាក្យថា **វិនីលក** នោះ ជាពាក្យហៅសាកសព ដែលមានពណ៌ក្រហម ក្នុងទីដែលមានសាច់ក្រាស់ មានពណ៌សក្នុងទីដែលមានខ្ទុះ តែដោយច្រើនមានពណ៌ខៀវជាំ ក្នុងទីដែលខៀវដូចជាដណ្តប់ទៅដោយសំពត់ពណ៌ខៀវ ។

## វិបុព្វកអសុភ

*អសុភ ដែលមានទឹកលឿង ហូរសើមនៅក្នុងទីដែលបែកធ្លាយទាំងឡាយ ឈ្មោះថា **វិបុព្វ** , **វិបុព្វ** នោះឯងជា **វិបុព្វក** ។ ម្យ៉ាងទៀត **វិបុព្វអសុភ** ចាត់ជារបស់គួរខ្ពើម ព្រោះជាវត្ថុបដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា **វិបុព្វក** ។ ពាក្យថា **វិបុព្វក** នោះឯង ជាពាក្យហៅសាកសព ដែលមានសភាពយ៉ាងនោះ ។*

## វិច្ឆិទ្ទកអសុភ

*អសុភ ដែលដាច់ចេញអំពីគ្នា ដោយដាច់ជាពីរកំណាត់ ហៅថា **វិច្ឆិទ្ទ** , **វិច្ឆិទ្ទ** នោះឯងជា **វិច្ឆិទ្ទក** ។ ន័យម្យ៉ាងទៀត **វិច្ឆិទ្ទអសុភ** ចាត់ថាជារបស់គួរខ្ពើម ព្រោះជាវត្ថុបដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា **វិច្ឆិទ្ទក** ។ ពាក្យថា **វិច្ឆិទ្ទក** នោះជាពាក្យហៅសាកសពដែលត្រូវដាច់ពាក់កណ្ដាលខ្លួន ។*

## វិក្ខាយិតកអសុភ

*អសុភ ដែលឈ្មោះថា **វិក្ខាយិត** ព្រោះត្រូវសត្វទាំងឡាយ មានឆ្កែស្រុក និង ឆ្កែព្រៃជាដើម ហែកស៊ីដោយអាការផ្សេងៗ ត្រង់នេះខ្លះត្រង់នោះខ្លះ **វិក្ខាយិត** នោះឯងជា **វិក្ខាយិតក** ។ ន័យម្យ៉ាងទៀត **វិក្ខាយិតអសុភ** ចាត់ថាជារបស់គួរខ្ពើម ព្រោះជាវត្ថុបដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា **វិក្ខាយិតក** ។ ពាក្យថា **វិក្ខាយិតក** នោះ ជាពាក្យហៅសាកសពដែលមានសភាពដូច្នោះ ។*

## វិក្ខិត្តកអសុភ

*អសុភ ដែលខ្ចាត់ខ្ចាយរាត់រាយ ទៅទីផ្សេងៗ ហៅថា **វិក្ខិត្ត** , **វិក្ខិត្ត** នោះឯងជា **វិក្ខិត្តក** ។ ន័យម្យ៉ាងទៀត **វិក្ខិត្តអសុភ** ចាត់ជារបស់គួរខ្ពើម ព្រោះជាវត្ថុបដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា **វិក្ខិត្តក** ។ ពាក្យថា **វិក្ខិត្តក** នោះ ជាពាក្យហៅសាកសពដែលខ្ចាត់ខ្ចាយរាត់រាយទៅកាន់ទីនោះៗ គឺ ដៃទៅម្ខាង ជើងទៅម្ខាង ក្បាលទៅម្ខាង ដូច្នេះជាដើម ។*

## ហតវិក្ខិត្តកអសុភ

*អសុភ ដែលឈ្មោះថា **ហតវិក្ខិត្តក** ព្រោះអសុភនោះត្រូវប្រហារ ឲ្យខ្ចាត់-ខ្ចាយរាត់រាយ តាមន័យមុននោះឯង ។ ពាក្យថា **ហតវិក្ខិត្ត** នោះ ជាពាក្យហៅសាកសពដែលត្រូវមនុស្សកាប់ចិញ្ច្រាំ ត្រង់អវយវៈតូចធំ ដោយអាការ ( ដូចជាកំនួចស្មៅ ) ហើយបោះចោលទៅ តាមន័យដែលបានពោលហើយនោះ ។*

## លោហិតកអសុភ

*អសុភ ដែលឈ្មោះថា **លោហិតក** ព្រោះមាន លោហិតហូរចេញមកអំពីត្រង់នោះខ្លះ ត្រង់នេះខ្លះ ។ ពាក្យថា **លោហិតក** នេះ ជាពាក្យហៅសាកសពដែលមានឈាមហូរចេញ ។*

## បុឡុវកអសុភ

*ជន្តុវទាំងឡាយ ហៅថា **បុឡុវ** , បុឡុវៈទាំងឡាយរួងជញ្ជក់ ក្នុងអសុភនោះ*

ព្រោះហេតុនោះ អសុភនោះ ទើបឈ្មោះថា **បុឡុវក** ។ ពាក្យថា **បុឡុវក** នោះ ជាពាក្យហៅសាកសព ដែលពេញទៅដោយដង្កូវ ។

## អដ្ឋិកអសុភ

ឆ្អឹងនោះឯង ឈ្មោះថា **អដ្ឋិក** ។ ន័យម្យ៉ាងទៀត **ឆ្អឹង** ចាត់ថាជារបស់គួរខ្ពើម ព្រោះជាវត្ថុបដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា **អដ្ឋិក** ។ ពាក្យថា **អដ្ឋិក** នោះ ជាពាក្យហៅ គ្រោងឆ្អឹងក៏បាន ឆ្អឹងមួយកំណាត់ក៏បាន ។

ពាក្យទាំងឡាយ មានពាក្យថា **ឧទ្ធុមាតក** ជាដើម ទាំងនោះឯង ជាឈ្មោះនៃនិមិត្តដែលអាស្រ័យអសុភ មានឧទ្ធុមាតកអសុភជាដើមទាំងនេះ កើតឡើងក៏បាន ជាឈ្មោះនៃឈាន ដែលព្រះយោគាវចរបានក្នុងនិមិត្តទាំងឡាយ ក៏បាន ។

## មហាដីកា

## អសុភកម្មដ្ឋាននិទ្ទេស

( អធិប្បាយអត្ថនៃបទថា **ឧទ្ធុមាតក** ជាដើម )

ពាក្យថា **ក្នុងបណ្តាអសុភដែលមិនមានវិញ្ញាណ** នេះ លោកពោលទុកដោយទាក់ទងនឹងពាក្យសម្តែងនូវសភាពនៃអសុភដែលហើមប៉ោងជាដើម ។ ព្រោះដូច្នោះ ទើបគប្បីឃើញថា ត្រឹមតែជាពាក្យដែលពោលដល់សភាវៈ ( នៃអសុភ ) ដែលប្រាកដច្បាស់ប៉ុណ្ណោះ នឹងបានពោលទុក ព្រោះអសុភដែលមានវិញ្ញាណក៏ទេ ព្រោះមិនមែនជាកម្មដ្ឋាន ពិតយ៉ាងនោះ លោកនឹងពោលទុកថា “ អសុភនេះ នោះ ” នឹងប្រាកដតែក្នុងសរីរៈរបស់អ្នកស្លាប់តែម្យ៉ាង ក៏ទេ ជាដើម ។

ពាក្យថា **ឧទ្ធំជីវិតបរិយាទានា** ប្រែថា បន្ទាប់អំពីការអស់ជីវិតទៅ គឺ ក្រោយអំពីស្លាប់ ។ ពាក្យថា **ដោយភាពដែលហើមប៉ោង** គឺ តាំងឡើង ។ ពាក្យថា **ព្រោះភាពដែលអសុភនោះប៉ោងឡើង** មានន័យថា ព្រោះហើមប៉ោងឡើងសន្សឹម ៗ ។ ពាក្យថា **ឧទ្ធុមាត** នោះឯងជា **ឧទ្ធុមាតក** លោកពោលបន្ថែមបទដោយ " ក " អក្សរ ក៏មិនមានន័យដទៃ ដូចពាក្យថា **បីតក លោហិតក** ( គឺ **បីត លោហិត** នោះឯង ) ។ ពាក្យថា **ព្រោះភាពជារបស់បដិកូល** គឺ ព្រោះភាពជារបស់ដែលគួររង្កៀស ។ ម្យ៉ាងទៀត លោកពោលថា អសុភនេះហើមប៉ោង គួរខ្ពើម ឈ្មោះថា **ឧទ្ធុមាតក** ដូច្នេះដើម្បីសម្ដែងថា " ក " អក្សរនេះ ប្រព្រឹត្តទៅក្នុងអត្ថថា គួរខ្ពើម ដូចពាក្យថា **បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិសព្ទដ៏លាមក គួរខ្ពើម រមែងផ្សាយទៅ ដូច្នេះ ។ ពាក្យថា ( ជាឈ្មោះរបស់សាកសព ) **ដែលមានសភាពដូច្នោះ** មានន័យថា លោកពោលដល់សាកសពដែលជាដូច្នោះ ទុកដោយពាក្យថា ដូចជាបាល់ដែលប៉ោងឡើងដោយខ្យល់ដូច្នោះជាដើម ក៏ជាឈ្មោះរបស់សាកសព ដែលមានសភាពដូច្នោះ ។

អសុភដែលមានពណ៌ខៀវលាយឡំ គឺ លាយដោយពណ៌ស និង ពណ៌ក្រហម ឈ្មោះថា **វិនីល** , ម្យ៉ាងទៀត អសុភមានពណ៌ខៀវ ដែលជាការប្រែប្រួលនៃពណ៌ដើម ឈ្មោះថា **វិនីល** ។ ឈ្មោះថា **ត្រង់ទីដែលបែកដោយជុំវិញ** គឺត្រង់ទីដែលបែកទៅ ព្រោះក្អែក ឬ ស្វាំងជាដើម ។ បទថា **វិស្សន្ទមានបុព្វំ** ប្រែថា មានខ្ទុះកំពុងហូរចេញ មានន័យថា មានខ្ទុះហូរចេញទូទៅត្រង់ទីនោះៗ ។ បទថា **អបធារិតំ** ប្រែថា បើកចំហ បានដល់ បើកចេញ ។ បទថា **ខិត្តំ** ប្រែថា ត្រូវបោល គឺ ត្រូវសត្វ មានឆ្កែចចកជាដើម ធ្វើឲ្យផុតចាកសរីរៈដោយការដែលខាំដាច់

ជាចំណែក ៗ នៅក្នុងទីនោះ ៗ ។ ឈ្មោះថា **វិក្ខិត្ត** ព្រោះអត្ថថា ត្រូវចោលដោយប្រការផ្សេងៗ ។ ពាក្យថា **តាមន័យមុន** គឺ តាមន័យដែលលោកបានពោលទុកក្នុងកាលមុន ដោយពាក្យថា **ត្រូវចោល** មានប្រការផ្សេងៗ ជាដើម ។ ពាក្យថា **ត្រូវមនុស្សកាប់ចិញ្ច្រាំ** គឺ បុគ្គលដែលមានពៀរនឹងគ្នា ប្រើសស្ត្រាវុធ មានដាវ ករវាល ( សស្ត្រាពិសេសម្យ៉ាង ) ជាដើម ប្រហារ ។ ពាក្យថា **តាមន័យដែលបានពោលហើយ** គឺ តាមន័យដែលពោលហើយក្នុងកាលមុន ដោយពាក្យថា កាលត្រូវចោលតាមផ្លូវជាដើម ។

អសុភដែលរើករើកដោយដង្កូវ រុកទូទៅ ព្រោះហេតុ ដែលដង្កូវចេញអំពីខាងក្នុង ក៏ឈ្មោះថា **បុឡុវក** ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ដែលពេញដោយដង្កូវ ។ ឈ្មោះថា **ឧទ្ធុមាតកជាដើម** បានដល់ អសុភដែលគេចោលក្នុងស្ថានទី មានព្រៃខ្មោចស្រស់ជាដើម ។ បទថា **និស្សាយ** ប្រែថា អាស្រ័យ គឺ ប្រារព្ធយកអសុភទាំងនោះ ។ ពាក្យថា **នៃនិមិត្តទាំងឡាយ** គឺ នៃឧគ្គហនិមិត្ត និងបដិភាគនិមិត្ត ។ ពាក្យថា **ឧទ្ធុមាតក** ជាដើមទាំងនេះ នោះឯងចាត់ជាឈ្មោះ ។

( ចប់ មហាដីកា )

## ១. ឧទ្ធុមាតកអសុភកម្មដ្ឋាន

## វិធីរៀនយកឧទ្ធុមាតកអសុភកម្មដ្ឋាន

ក្នុងអសុភ ១០ នោះ ព្រះយោគី ដែលប្រាថ្នានឹងញុំាងឧទ្ធុមាតកនិមិត្តក្នុងសាកសពដែលហើមប៉ោង ឲ្យកើត ហើយញុំាងឈានឈ្មោះ ឧទ្ធុមាតកៈ ឲ្យកើតឡើង គប្បីចូលទៅរកអាចារ្យ មានប្រការដូចពោលហើយ រៀនយកព្រះកម្មដ្ឋានតាមន័យដែលពោលហើយ ក្នុងបឋវីកសិណនោះឯង អាចារ្យនោះ កាលនឹងប្រាប់កម្មដ្ឋានដល់ព្រះយោគាវចរ គប្បីប្រាប់វិធីការគ្រប់យ៉ាង គឺ វិធីទៅដើម្បីអសុភនិមិត្ត ការកំណត់និមិត្តដោយជុំវិញ ការកាន់យកនិមិត្តដោយអាការ ១១ យ៉ាង ការពិចារណាផ្លូវទៅមក ដូច្នេះរហូតដល់អប្បនាវិធី ។ ចំណែកព្រះយោគីនោះ រៀនយកវិធីទាំងពួងឲ្យល្អហើយ គប្បីចូលទៅកាន់សេនាសនៈ មានប្រការដូចដែលបានពោលហើយខាងដើម ហើយស្វែងរកឧទ្ធុមាតកនិមិត្តចុះ ។

កាលលោកនៅយ៉ាងនោះ សូម្បីបានឮពាក្យមនុស្សទាំងឡាយនិយាយគ្នាថា សាកសពឧទ្ធុមាតកៈ គេចោលត្រង់ច្រកផ្លូវចូលភូមិឈ្មោះនោះ ឬ ត្រង់មាត់ព្រៃ មាត់ផ្លូវ ត្រង់ជើងភ្នំ ត្រង់គល់ឈើ ឬត្រង់ទីស្មសានឈ្មោះនោះ ដូច្នេះក៏មិនគួរទៅភ្លាមៗឡើយ គឺជាការត្រាច់ទៅខុសទំនង សួរថា ហេតុអ្វី ? ឆ្លើយថា ព្រោះអសុភនោះ អាចជាសាកសពដែលត្រូវសត្វសាហាវហួងហែងខ្លះ អមនុស្សហួងហែងទុកខ្លះ អន្តរាយនៃជីវិតអាចនឹងមានដល់លោកព្រោះអសុភនោះក៏បាន ។ ឬម្យ៉ាងទៀត ផ្លូវទៅទីនោះអាចជាផ្លូវឆ្លងកាត់ច្រកចូលភូមិខ្លះ ឆ្លងកំពង់ទឹកខ្លះ ឆ្លងចុងស្រែខ្លះ រូបដែលជាវិសភាគៈក្នុងទីទាំងឡាយនោះ នឹងមកកាន់គន្លង ( ចក្ខុ ) ឬ បើមិនដូច្នោះ

សាកសពនោះឯងអាចជាវិសភាគៈ ពិតណាស់ សាកសពស្ត្រី រមែងជាវិសភាគៈនៃបុរស សាកសពបុរសរមែងជាវិសភាគៈនៃស្ត្រី សាកសពនោះៗដែលស្លាប់ទៅថ្មីៗ នឹងប្រាកដនៅមានរាងស្អាតក៏បាន អន្តរាយព្រហ្មចរិយៈនឹងគប្បីមានដល់លោកព្រោះអសុភនោះ ក៏បាន ។ តែបើលោកដឹងច្បាស់ខ្លួនឯងថា វាមិនជារបស់អស្ចារ្យសម្រាប់ភិក្ខុដូចអាត្មាអញ ដូច្នេះសោត លោកទុកចិត្តខ្លួនឯងបានយ៉ាងនោះ ក៏គប្បីទៅចុះ ។ ឯវេលានឹងទៅ គប្បីប្រាប់ព្រះសង្ឃត្ថេរ ឬអភិញ្ញាតភិក្ខុ ( ភិក្ខុដែលមានឈ្មោះបោះសំឡេង ) ហើយសឹមទៅ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះបើលោកត្រូវអនិដ្ឋារម្មណ៍ ដូចជារូបរាង និង សំឡេងនៃសត្វសាហាវ មានអមនុស្សសីហៈ និង ខ្លា ជាដើម ក្នុងព្រៃស្មសានគ្របសង្កត់ រហូតអង្គអវយវៈញ័រចំប្រប់ក្តីរបស់ដែលបរិភោគហើយតាំងនៅមិនបានក្តី អាពាធដទៃក្តី កាលបើដូច្នោះ ព្រះថេរៈដែលលោកបានប្រាប់ហើយនោះ នឹងទុកដាក់បាត្រចីវររបស់លោក ឲ្យយ៉ាងល្អក្នុងវិហារ ហើយបញ្ជូនពួកភិក្ខុកំលោះខ្លះ សាមណេរខ្លះ ទៅជួយប្រណិបត្តិភិក្ខុនោះ ។ ប្រការមួយទៀត ពួកចោរសម្គាល់ថា ព្រៃខ្មោចជាកន្លែងរួចភ័យ ( គ្មានគេឃើញ ) វាបានធ្វើការហើយក្តី មិនទាន់បានធ្វើការក្តី ក៏មកប្រជុំគ្នា បើពួកមនុស្សទាំងឡាយតាមមកទាន់ វាអាចចោលរបស់របរនៅជិតៗភិក្ខុនោះ ហើយគេចចេញទៅ មនុស្សទាំងឡាយនឹងសម្គាល់ថា “ ពួកយើងឃើញចោរព្រមទាំងកស្តុតាង ” ហើយចាប់ភិក្ខុនោះធ្វើទារុណកម្ម ពេលនោះព្រះថេរៈដែលលោកបានប្រាប់ នឹងជួយអង្វរថា អ្នកទាំងឡាយកុំធ្វើទារុណកម្មភិក្ខុនេះឡើយ លោកប្រាប់យើងហើយ ទើបទៅធ្វើការងារបែបនេះ ឲ្យមនុស្សទាំងនោះយល់ត្រូវ ហើយធ្វើនូវសួស្តីឲ្យកើតដល់លោកបាន នេះជាអានិសង្សក្នុងការប្រាប់ហើយ ទើបទៅ ។

## វិធីតាមមើលអសុភតាមន័យអដ្ឋកថា

ព្រោះហេតុនោះ ព្រះយោគាវចរបានប្រាប់ដល់ភិក្ខុ មានប្រការដូចបានពោលហើយ កើតចំណង់យ៉ាងក្រៃលែង ក្នុងការដែលនឹងត្រូវមើលអសុភនិមិត្ត គប្បីញុំាងបីតិ សោមនស្សឲ្យកើតឡើង តាមវិធីដែលលោកពោលទុកក្នុងអដ្ឋកថាទាំង-ឡាយ ដូចក្សត្រកើតបីតិសោមនស្ស យាងទៅកាន់ទីអភិសេក ដូចអ្នកនឹងបូជាយញ្ញកើតបីតិសោមនស្ស ទៅកាន់រោងបូជាយញ្ញ ឬម្យ៉ាងទៀត ដូចមនុស្សមិនមានទ្រព្យ កើតបីតិសោមនស្សទៅកាន់ទីកប់កំណប់ដូច្នោះ ពិតណាស់ ពាក្យនេះលោកពោលទុកថា ភិក្ខុកាលនឹងកាន់យកអសុភនិមិត្ត ប្រភេទឧទ្ធុមាតកៈ រមែងទៅម្នាក់ឯង មិនមានសំឡាញ់ មានសតិតាំងមាំ មិនវង្វេង ជាអ្នកប្រកបព្រមដោយឥន្ទ្រិយទាំងឡាយ ពិចារណាមើលផ្លូវទៅមក អសុភនិមិត្តប្រភេទឧទ្ធុមាតកៈមាននៅត្រង់ទីកន្លែងណា លោករមែងធ្វើដុំថ្មក្តី ដំបូកក្តី ដើមឈើក្តី គុម្ពឈើក្តី វល្លិក្តី ក្នុងទីកន្លែងនោះៗ ឲ្យជានិមិត្តរួម ឲ្យជាអារម្មណ៍ កាលធ្វើឲ្យជានិមិត្តរួមហើយ ឲ្យជាអារម្មណ៍រួមហើយ ទើបចូលទៅកំណត់ ឧទ្ធុមាតកៈអសុភនិមិត្តនោះទៅតាមសភាពជាក់ស្តែងរបស់វា ( ដោយអាការ ១១ ) គឺ ដោយពណ៌កាយខ្លះដោយភេទខ្លះ ដោយសណ្ឋានខ្លះ ដោយទិសខ្លះ ដោយឱកាសខ្លះ ដោយបរិច្ឆេទ ( ទីខណ្ឌ )ខ្លះ និង ដោយទី-ត ដោយប្រហោង ដោយកន្លែងផត ដោយកន្លែងប៉ោងខ្លះ ដោយជុំវិញខ្លួន លោករមែងធ្វើនិមិត្តនោះ ឲ្យជាវត្ថុដែលកាន់យកបានយ៉ាងល្អហើយ រមែងកំណត់យកនិមិត្តនោះឲ្យជាវត្ថុដែលកំណត់ទុកយ៉ាងល្អ ហើយកាលធ្វើនិមិត្តនោះ ។ល។ ឲ្យជាវត្ថុដែលកំណត់ទុកបានយ៉ាងល្អហើយ លោកក៏ទៅតែម្នាក់ឯង មិនមានសំឡាញ់ មានសតិតាំងមាំ មិនវង្វេង ប្រកបដោយឥន្ទ្រិយទាំង-

ឡាយ មានគំនិតមិនក្រៅខ្លួន ពិចារណាមើលផ្លូវទៅមក សូម្បីនឹងចង្ក្រម លោកក៏អធិដ្ឋានចង្ក្រម ឲ្យជាការឧបត្ថម្ភដល់អសុភនិមិត្តតែម្យ៉ាង សូម្បីនឹងអង្គុយ ក៏ក្រាលអាសនៈឲ្យអំណោយផលដល់អសុភនិមិត្តនោះដែរ ។ សួរថា ការចំណាំនិមិត្តដែលនៅជុំវិញ មានប្រយោជន៍ដូចម្ដេច? មានអានិសង្សដូចម្ដេច? ឆ្លើយថា ការចំណាំនិមិត្តនៅជុំវិញ មានការមិនវង្វេងជាប្រយោជន៍ មានការមិនវង្វេងជាអានិសង្ស ។

សួរថា ការកាន់យកនិមិត្តដោយអាការ ១១ មានប្រយោជន៍ដូចម្ដេច ? មានអានិសង្សដូចម្ដេច ? ឆ្លើយថា ការកាន់យកនិមិត្តដោយអាការ ១១ មានការនាំ ( កម្មដ្ឋាន ) ចូលទៅចងទុក ជាប្រយោជន៍ ជាអានិសង្ស ។

សួរថា ការពិចារណាមើលផ្លូវទៅ-មក មានប្រយោជន៍ដូចម្ដេច ? មានអានិសង្សដូចម្ដេច ? ឆ្លើយថា ការពិចារណាមើលផ្លូវទៅ-មក មានការញ៉ាំងកម្មដ្ឋាន ( ដែលវិនាស ) ឲ្យឡើងកាន់វិថីបានវិញ ជាប្រយោជន៍ ជាអានិសង្ស ។

ព្រះយោគាវចរនោះ ជាអ្នកឃើញអានិសង្ស នៅដោយប្រក្រតី មានការសំគាល់( ក្នុងអសុភ )ថា ជាដួងកែវ ចូលទៅតាំងសេចក្ដីកោតក្រែងទុក ប្រព្រឹត្តដូចជាថា ជាទីស្រឡាញ់ នាំចិត្តទៅតម្កល់ទុកក្នុងអារម្មណ៍នោះ ដោយរំពឹងក្នុងចិត្តថា **យើងនឹងត្រូវផុតទៅអំពី ជរានិងមរណៈ ដោយបដិបទានេះដោយពិត** លោកក៏ស្ងាត់ចាកកាមទាំងឡាយ ។ ល ។ ចូលដល់ឈានទី ១ បឋមជ្ឈានជារូបាវចរៈ គឺលោកបានសម្រេចហើយ , វិហារធម៌ដ៏ជាទិព្វ គឺ លោកបានសម្រេចហើយ និងបុញ្ញកិរិយាវត្ថុ ផ្នែកភាវនាមយៈ ក៏លោកបានសម្រេចហើយដែរ ។

## វត្តក្នុងការទៅមើលអសុភ

ព្រោះហេតុនោះ ភិក្ខុណាទឹងទៅកាន់ព្រៃខ្មោច ដើម្បីជាប្រយោជន៍ដល់ការសង្រួមចិត្ត ភិក្ខុនោះចូរគោះគោរតាំងញ៉ាំងគណៈឲ្យប្រជុំប្រាប់គ្នាឲ្យជ្រាបជាមុន ហើយសឹមទៅ កាលទៅដោយកម្មដ្ឋានជាសំខាន់ គប្បីជាអ្នកតែម្នាក់ឯង មិនមានសំឡាញ់ជាអ្នកមិនលះបង់ចោលមូលកម្មដ្ឋាន មនសិការមូលកម្មដ្ឋាននោះរឿយៗ កាន់ឈើប្រត់ ឬឈើធម្មតា ដើម្បីការពារអន្តរាយ មានថ្កៃជាដើមនៅក្នុងព្រៃខ្មោចនោះ ធ្វើសតិទុកមិនឲ្យវង្វេងភ្លេច ដោយញ៉ាំងភាពជាអ្នកមាំទាំ ( ក្នុងកម្មដ្ឋាន ) ឲ្យដល់ព្រម ជាអ្នកមានចិត្តមិនទៅក្រៅខ្លួន ដោយការធ្វើនូវឥន្ទ្រិយទាំងឡាយ ដែលមានចិត្តជាទី ៦ នៅក្នុងខ្លួន ឲ្យដល់ព្រម ហើយទៅចុះ ។ កាលចេញអំពីវិហារ គប្បីចំណាំទ្វារទុកថា យើងចេញតាមទ្វារនោះ ក្នុងទិសនោះ តអំពីនោះ លោកទៅតាមផ្លូវណា គប្បីចំណាំផ្លូវនោះទុកថា ផ្លូវនេះត្រង់ទៅតាមទិសខាងកើត ឬថា ត្រង់ទៅទិសខាងលិច ទិសខាងជើង ទិសខាងត្បូង ឬថាត្រង់ទៅទិសឆៀង ។ម្យ៉ាងវិញទៀត ព្រះយោគាវចរ គប្បីកំណត់ផ្លូវដែលទៅ ថា ត្រង់នេះបត់ខាងឆ្វេង ត្រង់នេះបត់ខាងស្តាំ ឯក្នុងទីនៃអសុភនោះ ត្រង់នេះមានដុំថ្ម ត្រង់នេះមានដំបូក ត្រង់នេះមានដើមឈើ ត្រង់នេះមានគុម្ពឈើ ត្រង់នេះមានវល្លិ ដូច្នេះ រហូតដល់ស្ថានទីនៃនិមិត្តតាំងនៅ ។ ម្យ៉ាងវិញទៀត មិនគួរទៅច្រាស់ខ្យល់ ព្រោះថា កាលទៅច្រាស់ខ្យល់ ក្លិនសពនឹងប៉ះខួប់ច្រមុះ ធ្វើឲ្យស្រោមខួរក្បាលហើមរលាកក៏បាន ធ្វើឲ្យ ( អាហារដែលបរិភោគចូលហើយ ចេញមកវិញ ) ក៏បាន ធ្វើឲ្យកើតការខូចចិត្តថា **ពុទ្ធោអើយ យើងមកកន្លែងចោលសាកសពដូច្នេះទៅវិញ** ក៏បាន ព្រោះដូច្នោះ គប្បីវៀរផ្លូវច្រាស់ខ្យល់ទៅបណ្តោយខ្យល់ចុះ បើមិនអាចទៅតាមផ្លូវបណ្តោយខ្យល់បាន ព្រោះមានភ្នំ ជ្រោះ

ដុំថ្ម របង ព្រៃបន្ទា ទឹក ឬ រណ្ដៅ ក្នុងរវាងទីនោះសោត ក៏គប្បីបិទប្រមុះ ដោយជាយចីវរ ទៅចុះ នេះជាវត្តក្នុងការទៅនៃព្រះយោគាវចរនោះ ។

## វត្តកាលនៅដល់កន្លែងអសុភហើយ

ព្រះយោគាវចរ ទៅដល់កន្លែង ( អសុភ ) យ៉ាងនេះហើយ កុំទាន់មើលអសុភនិមិត្ត គប្បីកំណត់ទិសជាមុនសិន ពីព្រោះ កាលលោកឈរត្រង់ទិសណាមួយ អារម្មណ៍មិនប្រាកដច្បាស់ ចិត្តក៏មិនជាកម្មនីយៈ ( គួរដល់ភាវនា ) ព្រោះហេតុនោះ គប្បីវៀរទិសនោះចេញ ហើយឈរត្រង់ទិសណាដែលកាលឈរហើយអារម្មណ៍នឹងប្រាកដច្បាស់ ហើយចិត្តក៏ជាកម្មនីយៈផង នោះចុះ ។ម្យ៉ាងទៀត គប្បីលះបង់ការឈរក្រោមខ្យល់ និង លើខ្យល់ចេញ ព្រោះកាលឈរក្រោមខ្យល់ត្រូវក្លិនសពរំខាន ចិត្តនឹងរាយមាយ កាលឈរលើខ្យល់ បើមានអមនុស្សនៅក្នុងសពនោះ វានឹងក្រោធ ហើយធ្វើសេចក្ដីមិនចម្រើនឲ្យ ព្រោះហេតុនោះ គប្បីងាកបញ្ចិតបន្តិច ឈរកុំឲ្យចំពីលើខ្យល់ពេក ។ សូម្បីកាលឈរយ៉ាងនេះ គប្បីឈរក្នុងទីមិនឆ្ងាយពេក មិនជិតពេក មិនងាកទៅខាងចុងជើង មិនងាកទៅខាងក្បាល ព្រោះថា កាលឈរនៅឆ្ងាយពេក អារម្មណ៍នឹងមិនច្បាស់ ក្នុងទីជិតពេក ការភ័យខ្លាចនឹងកើតឡើង កាលឈរងាកទៅខាងចុងជើងក្ដី ខាងក្បាលក្ដី អសុភទាំងមូលនឹងមិនប្រាកដប៉ុនគ្នា ព្រោះហេតុនោះ គប្បីឈរក្នុងទីចំពាក់កណ្ដាលខ្លួន មិនឆ្ងាយពេក មិនជិតពេក ដែលជាផាសុកសម្រាប់អ្នកមើល ។

## វិធីចំណាំនិមិត្តផ្សេងៗនៅជុំវិញអសុភ

ព្រះយោគាវចរ ដែលឈរនៅយ៉ាងនោះហើយ គប្បីកំណត់ចំណាំនូវនិមិត្ត

ទាំងឡាយដោយជុំវិញ ដែលពោលមកហើយថា **លោករមែងធ្វើ ដុំថ្មក្តី ។ ល ។ វល្លិក្តី ក្នុងទីកន្លែងនោះ ឲ្យជានិមិត្តរួម** ដូច្នេះ នេះជាវិធីចំណាំក្នុងសេចក្តីនោះ ។ បើនៅជុំវិញនិមិត្តនោះ ដុំថ្មប្រាកដដល់គន្លងចក្ខុសោត គប្បីកំណត់មើលដុំថ្មនោះថា ដុំថ្មនេះខ្ពស់ឬទាប តូចឬធំ ខ្មៅឬស ទ្រវែងឬមូល បន្ទាប់ពីនោះទើបចំណាំទុកថា ក្នុងឱកាសត្រង់នេះ នោះជាដុំថ្ម នេះជាអសុភនិមិត្ត នេះអសុភនិមិត្ត នោះដុំថ្ម ។ ប្រសិនបើមានដំបូក សូម្បីដំបូកនោះ ក៏គប្បីកំណត់ថា ខ្ពស់ឬទាប តូចឬធំ ក្រហម ខ្មៅ ឬ ស វែងឬខ្លី ឬមូល ។ បន្ទាប់អំពីនោះ ទើបសង្កេតទុកថា ក្នុងឱកាសត្រង់នេះ នោះជាដំបូក នេះជាអសុភនិមិត្ត ។ បើមានដើមឈើ សូម្បីដើមឈើនោះ ក៏គប្បីកំណត់ថា ជាដើមពោធិ ឬដើមជ្រៃ ដើមទន្សែ ឬដើមខ្វិត ខ្ពស់ឬទាប តូចឬធំ សឬខ្មៅ បន្ទាប់អំពីនោះ ទើបចំណាំទុកថា ក្នុងឱកាសត្រង់នេះ នោះជាដើមឈើ នេះជាអសុភនិមិត្ត ។ បើមានគុម្ពឈើ សូម្បីគុម្ពឈើនោះ ក៏គប្បីកំណត់ថា នេះជាគុម្ពភ្នំភ្លៀង ឬគុម្ពក្រចកស្វាំង ឬគុម្ពស្មាយ ឬគុម្ពប្រទាលកន្ទុយដំរី គុម្ពខ្ពស់ឬទាប គុម្ពធំឬតូច តអំពីនោះទើបចំណាំទុកថា ក្នុងឱកាសត្រង់នេះ នេះជាគុម្ពឈើ នោះជាអសុភនិមិត្ត ។ បើមានវល្លិ សូម្បីវល្លិនោះក៏គប្បីកំណត់ថា ជាវល្លិឃ្លោក ឬ វល្លិល្ពៅ ឬ វល្លិយោង ឬ វល្លិផ្ទោម តអំពីនោះ ទើបចំណាំទុកថា ក្នុងឱកាសត្រង់នេះ នេះជាវល្លិ នោះជាអសុភនិមិត្ត ។

ចំណែកពាក្យដែលពោលថា ធ្វើ ... ឲ្យជានិមិត្តរួម ឲ្យជាអារម្មណ៍រួម ពាក្យនោះក៏រួមនៅក្នុងសេចក្តីនេះឯង ព្រោះថា កាលកំណត់ហើយ ទន្ទេញទៅមកៗ ក៏ឈ្មោះថា ធ្វើឲ្យជានិមិត្តរួម កាលកំណត់រួមនិមិត្ត ២ យ៉ាង ចូលជាមួយគ្នាថា នោះដុំថ្ម នេះអសុភនិមិត្ត នេះអសុភនិមិត្ត នោះដុំថ្ម ដូច្នោះក៏ឈ្មោះថា ធ្វើឲ្យជាអារម្មណ៍

រួម កាលធ្វើឲ្យជានិមិត្តរួម និងធ្វើឲ្យជាអារម្មណ៍រួមយ៉ាងនេះហើយ ព្រោះការដែលពោលទុកថា **សភាវភាវតោ វវត្ថបេតិ** កំណត់មើល តាមភាពដែលវាជារបស់ចំពោះខ្លួន គឺ ភាវៈណាដែលជាសភាពជាក់ស្តែងនៃសាកសព ជាភាវៈដែលមិនទូទៅដល់វត្ថុដទៃ ជាភាវៈរបស់ខ្លួនវា គឺ ភាពដែលវាជាសាកសពហើមប៉ោង គប្បីធ្វើទុកក្នុងចិត្តដោយភាវៈនោះ មានន័យថា ឲ្យកំណត់មើល តាមការប្រាកដរបស់វាតាមរស ( កិច្ច ) របស់វា យ៉ាងនេះថា **វណិតំ ឧទ្ធុមាតកំ** អសុភហើមប៉ោងគួរខ្ពើម ។

## ការកាន់យកនិមិត្ត ៦ ប្រការ

កាលកំណត់បានយ៉ាងនេះហើយ គប្បីកាន់យកនិមិត្ត ៦ ប្រការ គឺ ដោយពណ៌សម្បុរកាយខ្លះ ដោយភេទខ្លះ ដោយសណ្ឋានខ្លះ ដោយទិសខ្លះ ដោយឱកាសខ្លះ ដោយទីខណ្ឌ ( បរិច្ឆេទតោ ) ខ្លះ ។

សួរថា តើកាន់យកដូចម្តេច ? ឆ្លើយថា ព្រះយោគីនោះ គប្បីកំណត់មើល **ដោយសម្បុរកាយ** ថា នេះជាសាកសពរបស់មនុស្សសម្បុរខ្មៅ ឬ របស់មនុស្សសម្បុរ-ស របស់មនុស្សសម្បុរពីរ ។ **ចំណែកដោយភេទ** កុំកំណត់ថា ជាភេទស្រី ឬ ជាភេទប្រុស គប្បីកំណត់ថា ( នេះជាសាកសពរបស់មនុស្ស តាំងនៅក្នុងបឋមវ័យ ឬ ក្នុងមជ្ឈិមវ័យ ឬ ក្នុងបច្ឆិមវ័យ ។ **ចំណែកដោយសណ្ឋាន** ក៏គប្បីកំណត់ដោយអសុភនេះ ហើមប៉ោងប៉ុណ្ណោះថា នេះសណ្ឋានក្បាល នេះសណ្ឋានក នេះសណ្ឋានដៃ នេះសណ្ឋានពោះ នេះសណ្ឋានផ្ចិត នេះសណ្ឋានចង្កេះ នេះសណ្ឋានទ្រូង នេះសណ្ឋានស្មង នេះសណ្ឋានជើងរបស់សាកសពនោះ ។

ចំណែកដោយ **ទិស** គប្បីកំណត់ថា ក្នុងសាកសពនេះ មានទិស ២ គឺ ក្រោមផ្ចិតចុះទៅ ជាទិសខាងក្រោម លើផ្ចិតឡើងមក ជាទិសខាងលើ , ម្យ៉ាងទៀត គប្បីកំណត់ថា យើងឈរនៅក្នុងទិសនេះ អសុភនិមិត្តតាំងនៅក្នុងទិសនោះ ។

ចំណែកដោយ **ឱកាស** គប្បីកំណត់ថា ដៃនៅក្នុងឱកាសត្រង់នេះ ជើងនៅក្នុងឱកាសត្រង់នេះ ក្បាលនៅត្រង់នេះ កាយកំណាត់កណ្តាលនៅត្រង់នេះ , ម្យ៉ាងទៀត គប្បីកំណត់ថា យើងឈរនៅក្នុងឱកាសនេះ អសុភនិមិត្តតាំងនៅក្នុងឱកាសនោះ ។

ដោយ **បរិច្ឆេទ** គប្បីកំណត់ថា សាកសពនេះ ខាងក្រោមខណ្ឌដោយបាតជើង ខាងលើខណ្ឌដោយចុងសក់ ជុំវិញខណ្ឌដោយស្បែក ហើយក្នុងទីខណ្ឌនោះៗ វាពេញទៅដោយសាកសព ៣២ តែម្យ៉ាង ។ ន័យម្យ៉ាងទៀត គប្បីកំណត់ថា " នោះជាទីខណ្ឌនៃដៃ នោះជាទីខណ្ឌនៃជើង នោះជាទីខណ្ឌនៃសីសៈ នោះជាទីខណ្ឌនៃកាយកំណាត់កណ្តាល ឬមួយវិញទៀត កាន់យកទី ( នៃអវយវៈ ) បានត្រឹមណា គប្បីខណ្ឌយកទីត្រឹមនោះឯងថា នេះឧទ្ធុមាតកអសុភ " តែថា សរីរៈរបស់ស្ត្រី រមែងមិនគួរដល់បុរស សរីរៈរបស់បុរសក៏មិនគួរដល់ស្ត្រី អារម្មណ៍នៃសរីរៈដែលជាវិសភាគៈ រមែងមិនប្រាកដ ( អាការបដិកូល ) រមែងជាបច្ច័យនៃការរាយមាយផ្សេងៗ ព្រោះលោកពោលទុកក្នុងអដ្ឋកថាមជ្ឈិមនិកាយថា " ស្ត្រីសូម្បី ( ស្លាប់ ) ហើមហើយ ក៏គង់ចងចិត្តបុរសទុកបាន " ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីកាន់យកនិមិត្តដោយអាការទាំង ៦ តែក្នុងសរីរៈដែលជាសភាគៈចុះ ។

## ការកាន់យកដោយអាការ ៥ បន្ថែម

ចំណែកកុលបុត្តណា សេពកម្មដ្ឋាន រក្សាធុតង្គ ញ៉ាំញីមហាភូត ( ដោយ

ចតុធាតុវវដ្ឋាន ) ចាប់សង្ខារ ( ដោយលក្ខណញ្ញាណ ) កំណត់នាមរូប ដកចេញនូវសត្តសញ្ញា ធ្វើសមណធម៌ អប់រំវាសនា បំពេញការនាមកហើយក្នុងសំណាក់ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ជាអ្នកមានពូជ ( គឺ កុសលដែលជាឧបនិស្ស័យនៃវិវដ្ដ: ) ជាអ្នកមានញាណចាស់ក្លា មានកិលេសតិច បដិភាគនិមិត្ត រមែងប្រាកដដល់កុលបុត្តនោះបានគ្រប់កន្លែងដែលលោកបានមើល ប្រសិនបើមិនប្រាកដយ៉ាងនោះ ពេលលោកកាន់យកនិមិត្តដោយអាការ ៦ ដែលពោលមកហើយនោះ នឹងអាចប្រាកដបាន តែសូម្បី ( កាន់យកអាការ ៦ ) យ៉ាងនោះហើយ បើនៅមិនទាន់ប្រាកដដល់កុលបុត្តណា កុលបុត្តនោះ ទើបគួរកាន់យកអាការ ៥ ទៀត គឺ ដោយទី-ត ដោយប្រហោង ដោយទីផត ដោយទីប៉ោង ដោយទីជុំវិញខ្លួន ។

## ដោយទី-ត

ក្នុងមាតិកាទាំងនោះ មាតិកាថា **ដោយទី-ត** បានដល់ ដោយទី-ត ១៨០ កន្លែង តែថាព្រះយោគាវចរនឹងកំណត់មើលទី-ត ១៨០ កន្លែង ក្នុងឧទ្ធុមាតកអសុភដូចម្ដេចបាន ព្រោះដូច្នោះ ទើបកំណត់ដោយទី-ត តែតាមទិសធំ ៗ ១៤ កន្លែងយ៉ាងនេះ គឺ ទី-តដៃខាងស្ដាំ ៣ , ទី-តដៃខាងឆ្វេង ៣ , ទី-តជើងខាងស្ដាំ ៣ , ទី-តជើងខាងឆ្វេង ៣ , ទី-តត្រង់ក ១ , ទី-តត្រង់ចង្កេះ ១ ។

## ដោយទីប្រហោង

មាតិកាថា **ដោយទីប្រហោង** គឺ ចន្លោះដៃ ចន្លោះជើង ប្រហោងពោះ ប្រហោងត្រចៀកជាដើម ឈ្មោះថា ប្រហោង , ព្រះយោគាវចរ គប្បីកំណត់មើលដោយទីចន្លោះ យ៉ាងនោះចុះ សូម្បីក្នុងពេលដែលភ្នែកបើកក្ដី ភ្នែកបិទក្ដី សូម្បីមាត់បិទក្ដី

ហារក្តី ក៏គប្បីកំណត់ដែរ ។

## ដោយទីផត

មាតិកាថា **គឺ កន្លែងណាដែលផត ៗ ក្នុងសរីរៈ** បានដល់ រណ្តៅភ្នែកក្តី ប្រហោងមាត់ក្តី រណ្តៅកក្តី គប្បីកំណត់មើលទីនោះ ន័យម្យ៉ាងទៀត គឺថា យើងឈរនៅត្រង់ទីទំនាប សាកសពនៅត្រង់ទីទួល ។

## ដោយទីប៉ោង

មាតិកាថា **ដោយទីប៉ោង** គឺ ក្នុងទីណាដែលជាទីទួលប៉ោងឡើងក្នុងសរីរៈ បានដល់ ក្បាលជង្គង់ក្តី ទ្រូងក្តី ថ្ងាសក្តី គប្បីកំណត់មើលទីនោះ ។ ន័យម្យ៉ាងទៀត គប្បីកំណត់ថា យើងឈរនៅត្រង់ទីទួល សាកសពនៅត្រង់ទីទំនាប ។

## ដោយទីជុំវិញខ្លួន

មាតិកាថា **ដោយទីជុំវិញខ្លួន** មានសេចក្តីថា គប្បីកំណត់មើលរូបរាងទាំងអស់ដោយជុំវិញ គឺ គប្បីញ៉ាំងញាណឲ្យត្រាច់ទៅកាន់រាងកាយទាំងមូល កន្លែងណាប្រាកដជាឧទ្ធុមាតកៈច្បាស់ ក៏តាំងចិត្តបរិកម្មថា **ឧទ្ធុមាតកំ ឧទ្ធុមាតកំ** ត្រង់កន្លែងនោះ ។ សូម្បីថា កំណត់មើលយ៉ាងនោះហើយ ឧទ្ធុមាតកភាវៈ ក៏នៅមិនប្រាកដសោត រូបរាងកំណាត់ខាងលើមិនសូវហើម បើត្រង់ពោះហើមខ្លាំងជាង គប្បីតាំងចិត្តបរិកម្ម ថា **ឧទ្ធុមាតកំ ឧទ្ធុមាតកំ** ត្រង់កំណាត់ពោះនោះ ក៏បាន ។

# មហាដីកា

## ឧទ្ធុមាតកកម្មដ្ឋាន

បទថា **ភាវេតុកាមេន** ប្រែថា អ្នកប្រាថ្នានឹង ( ធ្វើឈានដែលឈ្មោះថាឧទ្ធុមាតកៈ ) ឲ្យកើតឡើង ។ បទថា **តេន** ប្រែថា ដែលអាចារ្យនោះ ។ បទថា **អស្ស** គឺ ដល់ព្រះយោគាវចរនោះ ។ ពាក្យថា **ដើម្បីប្រយោជន៍ដល់អសុភនិមិត្ត** គឺដើម្បីប្រយោជន៍ដល់ការរៀនយកអសុភនិមិត្ត ឬដើម្បីប្រយោជន៍ដល់ឧគ្គហនិមិត្តក្នុងអសុភ ។ បទថា **គមនវិធានំ** ប្រែថា វិធីទៅ គឺ ព្រះយោគាវចរគប្បីទៅដោយវិធីណា បានដល់ វិធីនោះ ។ លោកអាចារ្យពោលថា ដែលមានអប្បនាវិថីជាទីបំផុត ដូច្នេះ សំដៅយកវិធីបដិបត្តិដែលលោកពោលទុកក្នុងបឋវីកសិណ ចាប់តាំងអំពីកាលដែលឧគ្គហនិមិត្តកើតឡើងហើយ ។ បទថា **តាវទេវ** ( ត្រាច់ទៅ ) គឺក្នុងខណៈដែលបានឮនោះឯង ។ ហាក់ដូចជារសាត់ទៅ គឺដូចជាចូលទៅកាន់ស្ទឹងបុណ្ណៈជាដើម ខុសទំនង ដូច្នោះ ។ ពាក្យថា **ជាផ្លូវចុងស្រែ** គឺ ផ្លូវព្រំដែនស្រែ ។ ពាក្យថា **រូបជាវិសភាគៈ** គឺ រូបដែលជាវិសភាគៈវត្ថុ មានស្ត្រីចាំស្រែជាដើម ។ ពាក្យថា **សាកសព** បានដល់ សាកសពហើមប៉ោង ។ បទថា **អធុនាមតំ** ប្រែថា ដែលទើបតែស្លាប់ថ្មីៗ បានដល់ នៅមិនទាន់ដល់ភាពជាសាកសពហើមប៉ោង ។ ពាក្យថា **ដឹងច្បាស់** គឺ លើកសរសើរ ( ខ្ទបាន ) មិនសម្គាល់ថាការៈធ្ងន់ ។ ក្នុងពាក្យថា ( អារម្មណ៍ដែលមិនគួរប្រាថ្នា ) **មានរូបនិងសំឡេងជាដើម** នេះគប្បីប្រកបសេចក្តីតាមសមគួរថា សម្រាប់ពួកអមនុស្ស បានដល់ រូបទាំងឡាយ , សម្រាប់សីហៈ ឬខ្លាធំជាដើម បានដល់ សំឡេងជាដើម , ម្យ៉ាងទៀត សូម្បីសម្រាប់ពួកអមនុស្ស

បានដល់ ទាំងរូបទាំងសំឡេងជាដើម ។ សម្រាប់សីហៈ ឬខ្លាធំជាដើម ក៏យ៉ាងនោះដូចគ្នា ។ ពាក្យថា **ត្រូវអារម្មណ៍ដែលមិនគួរប្រាថ្នាគ្របសង្កត់** គឺត្រូវអារម្មណ៍ដែលមិនគួរប្រាថ្នា ព្រោះភាពជាអារម្មណ៍ដែលគួរខ្លាចជាដើមគ្របសង្កត់ គឺ គម្រាម ។ ពាក្យថា **តាំងនៅមិនបាន** គឺ នឹងតាំងនៅក្នុងទីអាស្រ័យ ទាក់ទងនឹងការរំលាយអាហារមិនបាន មានន័យថា នឹងនាំឲ្យក្អួតចេញមក ។ ពាក្យថា **អាពាធដទៃ** គឺ នឹងកើតជំងឺជង្គាត់ដទៃអំពីប្រការដែលពោលហើយ ដោយអំណាចនៃពួកអមនុស្សជាដើម ឬដោយប្រការដទៃ ។ បទថា **សោ** បានដល់ ព្រះសង្ឃត្ថេរ ឬភិក្ខុដែលមនុស្សស្គាល់ច្រើន ។ ជាអ្នកដែលព្រះយោគាវចរនេះ បានប្រាប់ការទៅ(របស់ខ្លួន) ទុកហើយ ។ ពាក្យថា **ដែលបានធ្វើការ** គឺ ដែលបានបួន់ ។ ពាក្យថា **ដែលមិនទាន់បានធ្វើការ** គឺ ដែលមានបំណងនឹងបួន់ ។ តែក្នុងទីនេះ គឺ សំដៅយកពួកចោរដែលបានបួន់រួចហើយ ។ ព្រោះដូច្នោះ ពាក្យថា **ពួកចោរទាំងនោះ** បានដល់ ពួកចោរដែលបានបួន់រួចមកហើយ ។ ឈ្មោះថា **សហោឍំ** ព្រោះអត្ថថា ប្រព្រឹត្តទៅព្រមជាមួយកស្តុតាង មានន័យថា ព្រមទាំងរបស់ដែលបួន់យកមក ។ បទថា **យជមានោ** ប្រែថា មនុស្សដែលនឹងបូជាយញ្ញ គឺ ជាម្ចាស់យញ្ញ ។ ឈ្មោះថា **ធ្វើបីតិសោមនស្សឲ្យកើតឡើង** ព្រោះគិតថា យើងនឹងរួចផុតចាកជរាមរណៈបាន ដោយបដិបទានេះយ៉ាងពិត ដូច្នេះ ។

លោកអាចារ្យកាលពោលវិធីទៅ តែម្យ៉ាង យ៉ាងនេះហើយ ឥឡូវនេះបំណងនឹងសម្តែងវិធីទៅនោះ តាមន័យដែលបានពោលហើយក្នុងអដ្ឋកថាទាំងឡាយ ទើបពោលថា **តាមវិធីដែលលោកពោលទុកក្នុងអដ្ឋកថាទាំងឡាយ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ពាក្យថា **កាលនឹងរៀនយក** គឺ ព្រោះការរៀនយកជាហេតុ ។

បទថា **ឯកោ** មានន័យថា **ឯក** ស័ព្ទនេះ មានអត្ថថា មិនមានសំឡាញ់ មិនមែនមាន អត្ថថា ជាបុគ្គលម្នាក់ឯងជាដើម ព្រោះហេតុនោះ លោកទើបពោលថា មិនមានបុគ្គលទីពីរ ដូច្នោះ ។ **បិ** ស័ព្ទ ដែលមានអត្ថថា រួបរួម ( ទើបប្រែថា ទាំង ) លោកកាន់យកក្នុងឋានៈ ៦ ( មិនយកទាំង ១១ ឋានៈ ) ដោយពាក្យថា **វណ្ណតោបិ** ទាំងពណ៌ជាដើម ដើម្បីសម្តែងថា ការកំណត់ដោយពណ៌ជាដើម ដែលព្រះយោគីធ្វើឲ្យកើតឡើងបានដោយពិតប្រាកដ ជាកិច្ចដែលគប្បីត្រូវការ ព្រោះជាកិច្ចដែលគួរប្រាថ្នាក្នុងអសុភទាំងពួង យ៉ាងណា ការកំណត់ដោយទី.តជាដើម នឹងដូច្នោះក៏ទេ ។ លោកពោលថា **ជាបុគ្គលម្នាក់ឯង មិនមានអ្នកទីពីរជាដើមទៀត** សំដៅយកព្រះយោគីដែលកាន់យកនិមិត្តបានហើយ ត្រឡប់ទៅកាន់លំ-នៅវិញ ។ ពាក្យថា **ឲ្យមានចំណែកនៃអសុភនិមិត្តនោះ ៗ ឯង** បានដល់ ឲ្យមានចំណែកនៃអសុភនិមិត្តនោះឯង គឺឲ្យប្រព្រឹត្តទៅរួមជាមួយការមនសិការអសុភនិមិត្តនោះឯង ។ ពាក្យថា **ក្រាលអាសនៈ** គឺ ត្រៀមការអង្គុយ ។ ការដែលលោកពោលថា ពាក្យថា **ក្នុងទីកន្លែងដែលបែរមុខត្រង់ទិសនៃអសុភនិមិត្ត** ដូច្នេះ ឯណាទុក សូម្បីពាក្យនោះ លោកក៏ពោលទុក សំដៅយកការអធិប្បាយនេះ នោះឯង ។ ព្រោះថា ព្រះយោគីនឹងសម្រេចគុណណា ៗ ដោយការៈដែលបែរមុខត្រង់ទិសតែមួយ ក៏ទេ ។ ពាក្យថា **ការកំណត់និមិត្តដោយជុំវិញ** បានដល់ ការកំណត់និមិត្តមានដុំថ្មជាដើម ជុំវិញឧទ្ធុមាតកអសុភ ។ ពាក្យថា **មានការមិនវង្វេងភ្លេច ជាផល** គឺ កាលឧគ្គហនិមិត្តប្រាកដហើយ ក៏មានការប្រាសចាកសេចក្តីវង្វេង ដែលកើតឡើងជាផល ។ ពាក្យថា **ដោយអាការ ១១ យ៉ាង** គឺ ដោយអាការ ១១ យ៉ាង ដោយទាក់ទងជាមួយពណ៌ជាដើម ។ ពាក្យថា **មានការចូលទៅចងទុក ជាផល** គឺ

មានការនាំចិត្តចូលទៅចងទុកក្នុងអសុភារម្មណ៍ ជាផល ។ ពាក្យថា **ឲ្យឡើងកាន់វិថីជាប្រយោជន៍** គឺ មានការញុំាងវិថីនៃកម្មដ្ឋាន ឲ្យដំណើរទៅដោយប្រពៃនោះឯង ជាផល ។ ភ្ជាប់សេចក្តីថា **បុញ្ញកិរិយាវត្ថុ អធិគតំ ហោតិ** ។

ពាក្យថា **ព្រោះដូច្នោះ** មានន័យថា ព្រោះហេតុដែលការរៀនយកអសុភនិមិត្ត ជាឧបាយឲ្យសម្រេចបឋមជ្ឈានដែលជាបទដ្ឋាននៃអរិយមគ្គ ឬ ព្រោះហេតុដែលព្រះអដ្ឋកថាចារ្យពោលទុកថា កាលនឹងរៀនយកនូវអសុភនិមិត្ត រមែងជាបុគ្គលម្នាក់ឯង មិនមានបុគ្គលទី ២ រួមដំណើរ ។ ពាក្យថា **ដើម្បីប្រយោជន៍ ដល់ការសង្រួមចិត្ត** បានដល់ ដើម្បីសេចក្តីសង្រួម គឺ ដើម្បីធ្វើចិត្តរបស់ខ្លួនឲ្យសង្រួម ដោយការកំណត់សភាពរបស់សាកសព និង ដោយការធ្វើសេចក្តីសង្វេគ ឲ្យកើតឡើង ។ ឬថា បាឋៈនឹងជា **ចិត្តសញ្ញត្តាយ** ដូច្នេះក៏បាន មានន័យថា ដើម្បីការសង្រួម គឺ ដើម្បីទូន្មានចិត្ត ដែលមិនសង្រួមដោយអំណាចនៃកិលេស បានដល់ ដើម្បីជាកម្មដ្ឋាន ។ បទថា **កម្មដ្ឋានសីសេន** ប្រែថា ព្រោះកម្មដ្ឋានដែលជាប្រធាន , ធ្វើកម្មដ្ឋាននោះឲ្យជាអគ្គដ៏ប្រសើរ គឺ ឲ្យជាហេតុដែលជាប្រធាន ។ ពាក្យថា **មូលកម្មដ្ឋាន** គឺ សព្វត្ថកម្មដ្ឋាន មានពុទ្ធានុស្សតិជាដើម ដែលខ្លួនបរិហារ តាមប្រក្រតី តាមកាលដ៏គួរ ។ ព្រះយោគី មិនលះមូលកម្មដ្ឋាននោះ ដោយគិតថា យើងនឹងទៅព្រោះកម្មដ្ឋាន ( អសុភកម្មដ្ឋាន ) ដែលជាប្រធាន ។ ព្រោះហេតុនោះ ទើបលោកពោលថា មនសិការមូលកម្មដ្ឋាននោះ ។ ពាក្យថា **ដោយការធ្វើភាវៈដែលសតិចូលទៅតាំងទុកដោយល្អ ឲ្យដល់ព្រម** គឺ ដោយការធ្វើភាវៈដែលសតិចូលទៅតាំងទុកដោយល្អ ក្នុងមូលកម្មដ្ឋានឲ្យដល់ព្រម ។ ព្រោះថា **សតិ** នឹងឈ្មោះថា មិនវង្វេង ក៏ដោយប្រការយ៉ាងនេះ ។ ចិត្តដែលមិនប្រព្រឹត្តទៅក្នុងអារម្មណ៍ ដ៏

ច្រើនខាងក្រៅ ប្រព្រឹត្តទៅចំពោះក្នុងកម្មដ្ឋាន ឈ្មោះថា មិនស្ទុះទៅខាងក្រៅ ។ ព្រះយោគីនោះ នឹងធ្វើឥន្ទ្រិយដែលជារូបទាំងឡាយ ឲ្យមានកិច្ចឈប់ប្រព្រឹត្តទៅបាន ក៏ដោយចិត្តដែលជាយ៉ាងនោះ ព្រោះហេតុនោះ ទើបលោកពោលថា **ដោយការធ្វើភាវៈដែលឥន្ទ្រិយទាំងឡាយ មានចិត្តជាទី ៦ ។ ល ។ ហើយទៅចុះ** ដូច្នេះ ។ ពាក្យថា **គួរចំណាំទ្វារទុក** គឺ គួរតែចងចាំទ្វារក្នុងទិសទាំងឡាយ មានទិសខាងកើតជាដើម ក្នុងវិហារទុកថា ទ្វារនេះនៅក្នុងទិសនោះ យើងចេញអំពីវិហារនោះឯង ទ្វារនោះបានកំណត់ទុកហើយក្នុងផ្លូវទិសនោះដូច្នេះ ។ ពាក្យថា **តអំពីនោះទៅ** គឺ បន្ទាប់អំពីការចំណាំទ្វារ ។ ឈ្មោះថា **ទៅតាមផ្លូវណា** គឺ ខ្លួនឯងនឹងទៅតាមផ្លូវណា ។ ពាក្យថា **ស្ថានទីនៃនិមិត្តតាំងនៅ** គឺ ស្ថានទីដែលនឹងកាន់យកអសុភនិមិត្ត ។ ពាក្យថា **ធ្វើឲ្យអាហារដែលបរិភោគហើយ ចេញមកវិញ** គឺ នឹងធ្វើឲ្យក្អួត ។ ពាក្យថា **កណ្ឌកដ្ឋានំ** បានដល់ ស្ថានទីដែលមានបន្លា ។

លោកអាចារ្យបំណងនឹងបើកផ្ទារអត្ថន័យ ដែលបានពោលទុកដោយសង្ខេបថា **គួរកំណត់ទិសទាំងឡាយទុក** ដូច្នេះ ទើបពោលថា ព្រោះថា ( កាលលោកឈរនៅត្រង់ទិសណាមួយហើយ ) ដូច្នេះជាដើម ។ បទថា **ខាយតិ** ប្រែថា ប្រាកដ ។ ពាក្យថា **គួរដល់ការឆ្ងារ** គឺ គួរដល់ការឆ្ងារនៃភាវនា ។ ពាក្យថា **ឧព្វាឡ្ហស្ស** ប្រែថា ដែលត្រូវ ( ក្លិនសព ) រំខាន ។ ពាក្យថា **រមែងស្ទុះទៅ** គឺ រមែងត្រាច់ទៅក្នុងអារម្មណ៍ផ្សេងៗ ។ ពាក្យថា **ឆាកបញ្ចិត** គឺ បញ្ចិតចេញអំពីទិសចំពីលើខ្យល់ ។ សាកសពមនុស្សស្លាប់ ដោយច្រើន រមែងប្រាកដថា គួរខ្លាចសម្រាប់អ្នកដែលជាបុថុជ្ជន ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ក្នុងទីជិតពេក ការភ័យខ្លាចនឹងកើតឡើង** ដូច្នេះ ។ ពាក្យថា **ឆាកទៅខាងចុងជើង** គឺ ជិតជើង ។ កាលព្រះយោគី

ឈរនៅក្នុងទីណា អាចនឹងមើលបានដោយងាយ ទីនោះ ឈ្មោះថា ទីដែលស្រួលសម្រាប់លោកអ្នកមើល ។ បទថា **សមន្តា** ប្រែថា ដោយជុំវិញ ។ បទថា **សមន្តា** បទមួយទៀត គឺ **សាមន្តា** ប្រែថា ក្នុងទីជិត ។ បទថា **កច្ឆកោ** បានដល់ ដើមទន្ទ្រខ្មៅ ។ អាចារ្យពួកខ្លះពោលថា បានដល់ ដើមលៀប ដូច្នេះ ក៏មាន ។ ពាក្យថា **គុម្ពឈើ** ( ម្យ៉ាង ) បានដល់ គុម្ពឈើតូច ៗ ។ ឈ្មោះថា **គុម្ពក្រចកស្មាំង ជាដើម** មានន័យច្បាស់ហើយ ។ បទថា **សាមា** បានដល់ វល្លិប្រេងខ្មៅ ។ បទថា **កាឡវល្លិ** បានដល់ វល្លិមួយប្រភេទមានពណ៌ខ្មៅ មិនមានស្លឹក ។

ពាក្យថា **វល្លិផោម** បានដល់ វល្លិម្យ៉ាងដែលធ្លាប់ហៅថា វល្លិកឡោចិ ។

ការធ្វើឲ្យជានិមិត្តជាដើម នោះក៏រួមចុះ គឺ រូបរួមចូលក្នុងខនេះ គឺ ក្នុងប្រការធ្វើដុំថ្មជាដើម ឲ្យជានិមិត្តតាមដែលពោលហើយនោះឯង ។ ពាក្យថា **សនិមិត្តំ ករោតិ** ប្រែថា ធ្វើឲ្យជានិមិត្តរួមគ្នា បានដល់ ធ្វើ គឺ កំណត់អសុភ ព្រមជាមួយនឹងនិមិត្តមានដុំថ្មជាដើម ។ ន័យម្យ៉ាងទៀត កាលធ្វើ គឺ កាលកំណត់អសុភនិមិត្ត និងនិមិត្ត មានដុំថ្មជាដើម ព្រមគ្នា គឺ ពេលជាមួយគ្នា ក៏ហៅថា ធ្វើឲ្យជានិមិត្តរួមគ្នា ដូច្នេះ ។ ព្រោះថា នេះជាពាក្យសមាសជាមួយ **សហ** សព្ទ ដែលសម្តែងដល់ការមានកាលព្រមគ្នា ( ដូចជាពាក្យថា **សចក្កនេ្ទហិ** ចូរឲ្យព្រមទាំងកង់ ) ដូច្នោះ ការធ្វើឲ្យជានិមិត្តនេះនោះ រមែងមានបានដោយការសង្កេតរឿយៗ មិនមែនមានត្រឹមតែមួយគ្រានោះឡើយ ព្រោះហេតុនោះ ទើបលោកពោលថា កាលកំណត់រឿយ ៗ ក៏ឈ្មោះថា ធ្វើឲ្យជានិមិត្តរួមគ្នា ។ ពាក្យថា **នូវនិមិត្តទាំង ២** បានដល់ និមិត្ត គឺ ដុំថ្ម និងនិមិត្ត គឺ អសុភ ។ ពាក្យថា **រួមគ្នា** បានដល់ សង្គ្រោះ គឺ ធ្វើឲ្យរួមគ្នាតែមួយ ។ ពាក្យថា **ជាអារម្មណ៍រួមគ្នា** មានន័យថា ធ្វើដុំថ្មជាដើម ឲ្យជាអារម្មណ៍

ស្មើគ្នា ព្រមជាមួយនឹងអារម្មណ៍ គឺ អសុភ , ន័យម្យ៉ាងទៀត បានដល់ ធ្វើឲ្យជាអារម្មណ៍ព្រមគ្នា គឺ ធ្វើនិមិត្តទាំង ២ ឲ្យជាអារម្មណ៍ ហាក់បីដូចជា ជាអារម្មណ៍តែមួយ និងកាលសង្កេតរឿយ ៗ ក៏ឈ្មោះថា ធ្វើវត្ថុទាំង ២ គឺ ដុំថ្ម ជាដើម និងអសុភនិមិត្តឲ្យជាអារម្មណ៍ ដូចជារួមអារម្មណ៍តែមួយ ។ បទថា **អត្តនិយោ** ប្រែថា ជារបស់ខ្លួន ។ បទថា **វណិតំ** ប្រែថា គួរខ្ពើម ។ ពាក្យថា **តាមសភាវៈ តាមរសរបស់ខ្លួន** បានដល់ តាមលក្ខណៈរបស់ខ្លួន ពោលគឺ ភាពជាអសុភហើមប៉ោង និងតាមកិច្ចរបស់ខ្លួន ពោលគឺ ការធ្វើសេចក្តីរង្កៀសឲ្យកើតឡើង ដល់មនុស្សដទៃម្យ៉ាងទៀត សភាវៈនោះឯង លោកហៅថា **រស** ព្រោះសម្រេចយ៉ាងនោះ ។

ពាក្យថា **គប្បីកាន់យកនិមិត្ត ៦ ប្រការ** គឺ គប្បីកាន់យកឧទ្ធុមាតកអសុភ-និមិត្ត ៦ ប្រការ មានពណ៌ជាដើម ។ អាចារ្យពួកខ្លះពោលថា គប្បីកាន់យក **៧ ប្រការ** ព្រមទាំងទំហំ វែងឬខ្លីជាដើម របស់សាកសព ដូច្នេះ ពាក្យនោះមិនមានក្នុងអដ្ឋកថា ។ លោកអាចារ្យកាលនឹងសម្តែងថា ឈ្មោះថា **ភេទ** ក្នុងពាក្យថា ដោយភេទនេះ បានដល់ ភេទ គឺ វ័យ មិនមែនគ្រឿងសំគាល់ភេទស្រី ឬ ប្រុស មានដោះ ឬ ពុកមាត់ជាដើមទេ ដូច្នេះ ទើបពោលថា ឬកុំកំណត់ថា ជាភេទស្រី ដូច្នេះ ជាដើម ។ ក្នុងសេចក្តីថា **បិតស្ស សត្តស្ស ឥទំ សរីរំ** ។ ឈ្មោះថា ( គប្បីកំណត់ ) **ដោយសម្ពន្ធជាមួយសណ្ឋានដែលហើមប៉ោងនោះឯង** គឺ មិនគប្បីកំណត់ទាក់ទងនឹងសណ្ឋានដែលមានតាមប្រក្រតី ។ ដោយពាក្យនេះ លោកសម្តែងថា ប្រសិនបើក្នុងសរីរៈនោះ មានចំណែកណា ៗ ដែលមិនទាន់ដល់នូវភាពហើមប៉ោង ព្រះយោគី មិនគប្បីកាន់យកចំណែកនោះឡើយ នេះជាការកំណត់សណ្ឋានដែលទាក់ទងនឹងអវយវៈដែលគ្រោតគ្រាត គឺ ( ឃើញច្បាស់ ) មិនមែនទាក់ទងនឹង

អវយវៈដែលល្អិតទេ ព្រោះហេតុនោះ ទើបលោកកាន់យកសណ្ឋាន ៩ យ៉ាង មានសណ្ឋានសីសៈជាដើមប៉ុណ្ណោះ ។ ពាក្យថា **ទិសនេះ** ប្រកបសេចក្ដីថា យើងឈរនៅទិសខាងកើត ទិសខាងត្បូង ទិសខាងលិច ទិសខាងជើង ឬទិសតូចៗ ។ ពាក្យថា **ដៃតាំងនៅក្នុងឱកាសឈ្មោះនេះ** ប្រកបសេចក្ដីថា គប្បីកំណត់ថា ដៃរបស់សាកសពនេះ តាំងនៅក្នុងភូមិប្រទេស ឈ្មោះនេះ ។ ពាក្យថា **ខាងក្រោមខណ្ឌដោយបាតជើងជាដើម** លោកពោលទុក ដោយទាក់ទងនឹងប្រការកំណត់ខនេះថា ក្រោមផ្ចិតចុះមក ឈ្មោះថា ខាងក្រោម លើផ្ចិតឡើងទៅ ឈ្មោះថា ខាងលើដូច្នេះ ។ ឈ្មោះថា **បរិច្ឆេទនៃដៃ** គប្បីកាន់យកខាងក្រោមដោយចុងម្រាម ខាងលើដោយទី.តនៃចង្កួយស្មា ខាងៗត្រឹមស្បែកជាទីបំផុត ។ សូម្បីក្នុងបរិច្ឆេទនៃជើងជាដើម ក៏មានន័យដូច្នេះដែរ ។ ពាក្យថា **ឬព្រះយោគី រមែងកាន់យកបានត្រឹមតែប៉ុន្មានចំណែក** មានន័យថា ប្រសិនបើព្រះយោគី មិនអាចកំណត់កាន់យកគ្រប់សរីរៈទាំងអស់បាន ចំណែកដែលហើមរបស់សរីរៈនោះមាន ព្រះយោគីនោះ អាចកំណត់កាន់យក ចំណែកនៃសរីរៈបានត្រឹមប៉ុណ្ណា ដោយការដឹងថា វាជាចំណែកដែលហើមប៉ោង ក៏គប្បីខណ្ឌយកចំណែកប៉ុណ្ណោះនោះឯង គឺ ប៉ុនទីកំណត់កាន់យកបាននោះចុះ ។ ពាក្យថា **ដែលដូច្នេះនេះ** មានន័យថា គប្បីខណ្ឌយក ដោយសភាវៈតាមភាពពិតថា ដែលជាដូច្នេះនេះ មានដៃជាដើមនេះ គឺ ដែលមានអាការយ៉ាងនេះ ហើមប៉ោង ។ ពាក្យថា **ក្នុងសរីរៈដែលជាវិសភាគារម្មណ៍នឹងមិនប្រាកដ** គឺ កម្មដ្ឋាន ដែលបានដល់អាការដែលជាបដិកូល នឹងមិនប្រាកដ , **ន ឧបដ្ឋាតិ** សេចក្ដីប៉ុនគ្នាជាមួយ **ន ខាយតិ** ប្រែថា រមែងមិនប្រាកដ គឺ អាចប្រាកដជាស្អាតបាន ព្រោះហេតុនោះ ទើបលោកពោលថា រមែងជាបច្ច័យដល់ការរាយមាយចិត្តទៅផ្សេងៗ ប៉ុណ្ណោះ ។

សេចក្តីថា និមិត្តនឹងជាបច្ច័យដល់ការរាយមាយចិត្តទៅជុំវិញ គឺ កិលេស នោះឯង ។ ពាក្យថា **សូម្បីហើមប៉ោងហើយ** គឺ សូម្បីដល់ភាពជាឧទ្ធុមាតកអសុភ ឬ មានន័យថា សូម្បីជាសរីរៈដែលល្អយហើយ ដោយប្រការទាំងពួង ។ ន័យ នេះនោះ បណ្ឌិតគប្បីសម្តែងទុកដោយរឿងទាំងឡាយ ដែលលោកណែនាំទុកក្នុង អាបត្តិបារាជិកខជំបូង ។ ពាក្យថា **ធ្លាប់សេពកម្មដ្ឋានរឿយ ៗ** គឺ បានធ្វើសេចក្តី ស្និទ្ធស្នាលទុកក្នុងអសុភកម្មដ្ឋាន ។ ឈ្មោះថា **ធ្លាប់បរិហារធុតង្គ** ក៏ដោយទាក់ទង ជាមួយសោសានិកង្គៈ ( អង្គនៃភិក្ខុដែលនៅព្រៃខ្មោច ) ជាដើម ។ ឈ្មោះថា **ធ្លាប់ ញាំញីមហាភូតបាន** ក៏ទាក់ទងដោយការកំណត់ធាតុ ៤ ។ ឈ្មោះថា **ធ្លាប់កំណត់ សង្ខារ** ក៏ជាការកំណត់ដោយញាណ ។ ឈ្មោះថា **ធ្លាប់កំណត់នាមរូប** ក៏ទាក់ទង ដោយការកំណត់បច្ច័យ ។ ឈ្មោះថា **ធ្លាប់ដកសត្តសញ្ញាបាន** ក៏ដោយកម្លាំងនៃ សុញ្ញតានុបស្សនាដ៏ខ្ពង់ខ្ពស់ នៃវិបស្សនាដែលមានធម៌ព្រមទាំងលក្ខណៈជាអារម្មណ៍ៗ ឈ្មោះថា **ធ្លាប់ធ្វើសមណធម៌** ក៏ដោយការធ្វើវិបស្សនាឲ្យសម្រេចដល់បដិបទា-ញាណទស្សនវិសុទ្ធិបាន ព្រោះហេតុនោះ ទើបឈ្មោះថា **ធ្លាប់អប់រំវាសនា ធ្លាប់ ចម្រើនភាវនា** ដោយធ្វើកុសលវាសនា និងកុសលភាវនា ឲ្យពេញបានដោយប្រការ ទាំងពួង ។ ឈ្មោះថា **មានពូជ** ក៏ដោយពូជ គឺ កុសលដែលជាឧបនិស្ស័យនៃ វិវដ្តៈ។ ឈ្មោះថា **ក្រៃលែងដោយញាណ** ព្រោះភាវៈដែលបានបន្ទុំញាណទុកហើយ។ ឈ្មោះថា **មានកិលេសតិច** ក៏ដោយការធ្វើកិលេសទាំងឡាយ ឲ្យស្រាលស្តើង ដោយឧបដិបត្តិតាមដែលបានពោលហើយ ។ ពាក្យថា **ក្នុងស្ថានទីដែលលោកសម្លឹង មើលហើយ ក្រឡេកមើលហើយនោះឯង** គឺ ក្នុងស្ថានទីណានីមួយនៃអសុភ មាន ឧទ្ធុមាតកអសុភជាដើម ដែលលោកសម្លឹងមើលហើយ ក្រឡេកមើលហើយនោះ

ឯង ។ សេចក្ដីថា សម្រាប់ព្រះយោគីដែលមានសភាពដូច្នោះ មិនសំដៅដល់វេលាពិសេស ឬស្ថានទីពិសេសនៃអសុភ ( អ្វីឡើយ ) ។ ពាក្យថា **ប្រសិនបើមិនប្រាកដយ៉ាងនោះសោត** មានសេចក្ដីថា ប្រសិនបើបដិភាគនិមិត្តមិនប្រាកដ ដូចដែលប្រាកដដល់បុរសពិសេសតាមដែលពោលហើយ យ៉ាងនេះសោត ។ ពាក្យថា **ដោយ ៦ ប្រការយ៉ាងនេះ** គឺ ដោយ ៦ ប្រការ ទាក់ទងនឹងពណ៌ជាដើម ដែលមានអាការតាមដែលពោលហើយយ៉ាងនេះ ។ សព្ទថា **បុនបិ** ( សូម្បីទៀត ) សេចក្ដីថា **បិ** សព្ទ ( ប្រែថា សូម្បី ) មានអត្ថថា រួបរួម ។ ដោយ **បិ** សព្ទនោះ លោករួមយកវិធីកាន់យកនិមិត្ត មិនមែនរួមយកសេចក្ដី ៥ ប្រការ ព្រោះថា ការកាន់យកនិមិត្តក្នុងខាងដើម លោកចាត់ចែងទុក មាន ៦ ប្រការ ។

លោកអាចារ្យពោលថា ដោយ ទី-ត ១៨០ កន្លែង ដូច្នេះ ដើម្បីសម្ដែងថា សូម្បីទី-តទាំងអស់ មានហើយ សូម្បីក្នុងពេលនោះឯង បំណងសម្ដែងថា ទី-តទាំងឡាយ ដោយច្រើនមិនប្រាកដ ព្រោះភាពជាអសុភហើមប៉ោង ។ ចំណែកទី-តពួកណាប្រាកដបាន ក៏គួរកំណត់ទី-តទាំងនោះ ដូច្នេះ ទើបពោលថា **តែថា ក្នុងឧទ្ធុមាតកអសុភ** ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ទី-តដៃស្ដាំ ៣ កន្លែង** បានដល់ ទី-តដៃស្ដាំ ៣ កន្លែង គឺ ស្មា កែងដៃ និង កដៃ ។ ទី-តដៃឆ្វេងក៏យ៉ាងនោះ ។ ឈ្មោះថា **ទី-តជើងស្ដាំង ៣ កន្លែង** គឺ ចង្កេះ ជង្គង់ និង កជើង ។ ឈ្មោះថា **ទី-តជើងឆ្វេង ៣ កន្លែង** ក៏យ៉ាងនោះដូចគ្នា ។ លោកពោលថា **ទី-តចង្កេះ ១ កន្លែង** សំដៅដល់ទី-តរវាង ឆ្អឹងខ្នង និង ចង្កេះ ។ ពាក្យថា **ចន្លោះដៃ** គឺ ជាចន្លោះរវាងដៃស្ដាំ និង ដៃឆ្វេង ។ ពាក្យថា **ចន្លោះជើង** គឺ ត្រង់រវាងកណ្ដាលនៃជើងទាំង ២

ខាង ។ ពាក្យថា **ចន្លោះពោះ** គឺ ត្រង់កណ្តាលពោះ ដែលតែងហៅថា ជាទីតាំងផ្ចិត ឬថាខាងក្នុងពោះ ។ ពាក្យថា **ចន្លោះត្រចៀក** បានដល់ រន្ធត្រចៀក ។ **ឥតិ** ស័ព្ទ មានអត្ថថា **អាទិ** ( ជាដើម ) ។ ដោយ **ឥតិ** ស័ព្ទនោះ គប្បីឃើញថា សង្គ្រោះយក សូម្បីរន្ធច្រមុះជាដើម ។ ដើម្បីសម្តែងថា យកទាំងទីដែលជាប្រហោង សូម្បីទាក់ទងដោយភ្នែកនិងមាត់នោះឯង ទើបលោកអាចារ្យពោលថា " ភាវៈដែលបិទភ្នែក ទោះជាភ្នែកទាំង ២ " ដូច្នេះជាដើម ។

ពាក្យថា **ដោយជុំវិញខ្លួន** មានសេចក្តីថា លោកអាចារ្យបំណាងនឹងសម្តែងវិធីកំណត់ថា ប្រសិនបើ កាលព្រះយោគីកំណត់ឧទ្ធុមាតកអសុភដោយទី-តជាដើម តាមប្រការដូចពោលមកនេះ និមិត្តប្រាកដបានសោត យ៉ាងនេះ នេះក៏ជាការល្អ ។ ប្រសិនបើប្រាកដមិនបាន ក៏គួរកំណត់ដោយជុំវិញខ្លួន ដូច្នេះទើបពោលថា " ( គប្បីធ្វើញាណឲ្យត្រាច់ទៅ ) **ក្នុងសរីរៈទាំងមូល** " ដូច្នេះ ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ធ្វើញាណឲ្យត្រាច់ទៅ** គឺ នឹកដល់សរីរៈទូទៅគ្រប់ចំណែកនោះឯង ហើយធ្វើភាវនាញាណឲ្យប្រព្រឹត្តទៅមិនដាច់ខ្សែ ប្រារព្ធដល់ភាវៈដែលហើមប៉ោង ដែលប្រព្រឹត្តទៅព្រមជាមួយអាការដែលជាបដិកូលក្នុងសរីរៈនោះ ។ ពាក្យថា **ត្រង់ចំណែកណា** មានន័យថា កាលព្រះយោគីធ្វើញាណឲ្យត្រាច់ទៅយ៉ាងនេះ ចំណែកណាក្នុងសរីរៈនោះ ស្តែងឡើងជាចំណែកដែលប្រាកដច្បាស់ គឺ ដោយភាវៈដែលស្តែងចេញនូវអាការដែលហើមប៉ោង ។ ឈ្មោះថា **ចំណែកទីបំផុតត្រឹមពោះ** បានដល់សរីរៈកំណាត់លើ ។

( ចប់ មហាដីកា )

# វិនិច្ឆ័យឧគ្គហនិមិត្តជាដើម

តទៅនេះជាពាក្យវិនិច្ឆ័យ ក្នុងអដ្ឋកថាបាឋៈ មានពាក្យថា លោករមែងធ្វើនិមិត្តនោះឲ្យជាវត្ថុដែលកាន់យកបាន យ៉ាងនេះហើយ ដូច្នេះជាដើម ដែលព្រះយោគីនោះ គប្បីកាន់យកនិមិត្តក្នុងសាកសពនោះ ឲ្យល្អដោយ ( វិធី ) កាន់យកនិមិត្តតាមដែលពោលហើយ គប្បីធ្វើសតិឲ្យមាំទាំល្អហើយ នឹករំពឹងទៅ លោកកាលធ្វើយ៉ាងនោះរឿយៗ បរិកម្មរឿយៗ គប្បីកំណត់ចំណាំ និងកំណត់យកទុកឲ្យស្មាត់ ទោះលោកឈរក្តី អង្គុយក្តី ក្នុងទីមិនឆ្ងាយពេក មិនជិតពេកអំពីសាកសព បើកភ្នែកសម្លឹងមើលកាន់យកនិមិត្ត គប្បីបរិកម្មថា **ឧទ្ធុមាតកំ បដិកូលំ ឧទ្ធុមាតកំ បដិកូលំ** បើកភ្នែកមើល បិទភ្នែកនឹកសញ្ជឹងទៅ ១០០ ដង ១០០០ ដង ... កាលធ្វើយ៉ាងនោះរឿយៗទៅ **ឧគ្គហនិមិត្ត** នឹងជាវត្ថុដែលលោកបានកាន់យកដោយល្អហើយ ។

សួរថា ឧគ្គហនិមិត្ត ជាវត្ថុដែលលោកបានកាន់យកដោយល្អហើយ ក្នុងពេលណា ? ឆ្លើយថា ក្នុងកាលណាលោកបើកភ្នែកមើលក្តី បិទភ្នែកសញ្ជឹងគិតក្តី និមិត្តប្រាកដ ដូចជាមកកាន់គន្លង( ចក្ខុ ) ក្នុងកាលនោះ ឧគ្គហនិមិត្តឈ្មោះថា ជាវត្ថុដែលលោកកាន់យកបានយ៉ាងល្អហើយ ។ ព្រះយោគាវចរនោះ កាលធ្វើនិមិត្តនោះ ឲ្យជាវត្ថុដែលកាន់យកដោយល្អ កំណត់ចាំទុកយ៉ាងល្អ សម្គាល់ទុកយ៉ាងល្អដូច្នេះហើយ បើមិនអាចដល់ទីបំផុតនៃភាវនាក្នុងទីនោះសោត លោកតែម្នាក់ឯង មិនមានសំឡាញ់មនសិការកម្មដ្ឋាននោះឯងបណ្តើរ ធ្វើសតិឲ្យតាំងមាំល្អ មានឥន្ទ្រិយទាំងឡាយជាប់ខ្លួន ( គឺ សង្រួម ) មានការគិតមិនទៅក្រៅខ្លួន តាមន័យដែលបានពោលហើយក្នុងកាលមុននោះឯង ទៅកាន់សេនាសនៈរបស់ខ្លួនចុះ ។

ម្យ៉ាងវិញទៀត កាលចេញអំពីព្រៃខ្មោចនោះ គប្បីកំណត់មើលផ្លូវដែលមកផងថា យើងចេញផ្លូវណា ផ្លូវនេះត្រង់ទៅទិសខាងកើត ឬត្រង់ទៅទិសខាងលិចជើង ត្បូង ឬទៅត្រង់ទិសតូច ឬមួយវិញទៀត ត្រង់នេះទៅខាងឆ្វេង ត្រង់នេះទៅខាងស្តាំ ត្រង់នេះមានដុំថ្ម ត្រង់នេះដំបូក ត្រង់នេះមានដើមឈើ ត្រង់នេះមានគុម្ពឈើ ត្រង់នេះមានវល្លិ លោកកាលកំណត់មើលផ្លូវមកយ៉ាងនេះហើយ មក ( ដល់សេនាសនៈរបស់ខ្លួន ) ហើយ កាលនឹងចង្រ្កមគប្បីអធិដ្ឋានចង្ក្រមដែលជាឧបការៈដល់ចំណែកអសុភនោះប៉ុណ្ណោះ មានន័យថា គប្បីចង្ក្រមក្នុងភូមិប្រទេសដែលបែរមុខទៅរកទិសនៃអសុភនិមិត្ត សូម្បីអង្គុយ ក៏គួរក្រាលអាសនៈដែលឧបការៈដល់អសុភនោះដូចគ្នា តែបើក្នុងទិសនោះ មានអណ្តូងក្តី ជ្រោះក្តី ដើមឈើក្តី របងក្តី រណ្តៅក្តី លោកមិនអាចចង្ក្រមក្នុងភូមិប្រទេសដែលបែរមុខទៅទិសនោះបាន សូម្បីអាសនៈក៏មិនអាចក្រាលបាន ព្រោះមិនមានឱកាស ក៏មិនគួរបែរទៅទិសនោះ គួរចង្ក្រមនិងអង្គុយ ក្នុងកន្លែងដែលគួរដល់ឱកាសក៏បាន តែគប្បីធ្វើចិត្តឲ្យឆ្ពោះទៅកាន់ទិសនោះប៉ុណ្ណោះ ។

## អធិប្បាយពាក្យឆ្លើយ

### ការកំណត់ចំណាំនិមិត្តដោយជុំវិញ មានប្រយោជន៍អ្វី ?

ពាក្យតទៅនេះ ជាពាក្យអធិប្បាយដោះស្រាយថា **មានការមិនវង្វេង ជាប្រយោជន៍ជាដើម** នៃបញ្ហាទាំងឡាយថា ការកំណត់និមិត្ត ដោយជុំវិញមានប្រយោជន៍អ្វី ជាដើម ។

កាលព្រះយោគាវចរអង្គណា ទៅកាន់ទីតាំងឧទ្ធុមាតកនិមិត្តក្នុងពេលមិនសម

គួរ ធ្វើការកំណត់និមិត្តសូម្បីដោយជុំវិញហើយ បើកភ្នែកមើលដើម្បីកាន់យកនិមិត្ត នោះឯង បើសាកសពនោះប្រាកដដូចជាក្រោកឡើងឈរ ដូចជាចង់ចាប់ ដូចជាចង់ដេញ , ព្រះយោគាវចរនោះ ឃើញសាកសពនោះ ជាអារម្មណ៍គួរខ្លាចខ្លាំងហើយ ក៏បាត់ស្មារតី ទៅជាឆ្កួត ដល់នូវការតក់ស្លុត ការស្រយុត ការព្រឺរោម ពិតណាស់ ក្នុងអារម្មណ៍ ៣៨ ដែលទ្រង់ចែកទុកក្នុងបាលី អារម្មណ៍ដទៃដែលចាត់ជាអារម្មណ៍គួរខ្លាចយ៉ាងនេះ មិនមាន ព្រោះក្នុងកម្មដ្ឋាននេះ ព្រះយោគាវចរ ឈ្មោះថា **ឈានវិកន្តក** ( វិនាសចាកឈាន ) ក៏មាន ព្រោះហេតុអ្វី ព្រោះកម្មដ្ឋាន ជាកម្មដ្ឋានគួរខ្លាចក្រៃលែង ព្រោះហេតុនោះ ព្រះយោគីនោះ គប្បីពង្រឹងចិត្ត ធ្វើសតិឲ្យតាំងមាំដោយល្អ ដាក់ចិត្តចុះថា រាងកាយដែលស្លាប់ហើយ នឹងក្រោកឡើងដេញបាន មិនមាន ប្រសិនបើ ដុំថ្ម....វល្លិ ដែលនៅជិតៗសពនោះ វានឹងរំកិលមកបានសោត សាកសពក៏នឹងមកបានខ្លះ តែដុំថ្មនិងវល្លិនោះ មកមិនបានយ៉ាងណា សូម្បីសាកសព ក៏មកមិនបានដូច្នោះ អាការដែលប្រាកដដល់លោកនេះ ជាអាការដែលកើតពីសញ្ញា កើតឡើងព្រោះសញ្ញាទេ កម្មដ្ឋាននឹងប្រាកដដល់អ្នកក្នុងថ្ងៃនេះហើយ អ្នកកុំខ្លាចឡើយណាភិក្ខុ ដូច្នេះហើយ បន្ទោបង់ **តាស** ( ការស្រៀវខ្លាច ) ញុំាង **ហាស** ( សេចក្ដីត្រេកអរ ) ឲ្យកើតឡើង ញុំាងចិត្តឲ្យត្រាច់ទៅក្នុងនិមិត្តនោះ យ៉ាងនេះ លោកក៏នឹងបានសម្រេចនូវធម្មវិសេស ។ ប្រការថា ការកំណត់ចំណាំនិមិត្តដោយជុំវិញ មានការមិនវង្វេងជាប្រយោជន៍នោះ ព្រះអដ្ឋកថាចារ្យពោលសំដៅយកពាក្យនេះឯង ។

## អធិប្បាយ ពាក្យឆ្លើយបញ្ហាថា

## ការកាន់យកនិមិត្តដោយអាការ ១១ មានប្រយោជន៍ដូចម្ដេច ?

ព្រះយោគាវចរ សូម្បីញ៉ាំងការកាន់យកនិមិត្តដោយអាការ ១១ ឲ្យសម្រេច ឈ្មោះថា នាំកម្មដ្ឋានចូលទៅចងទុកបាន ព្រោះថា ឧគ្គហនិមិត្តរមែងកើតឡើងដល់លោក ព្រោះការបើកភ្នែកមើល( និមិត្ត )ជាបច្ច័យ លោកកាលញ៉ាំង **មានស្ស** ( ភាវនាចិត្ត ) ឲ្យត្រាច់ទៅក្នុងឧគ្គហនិមិត្តនោះ បដិភាគនិមិត្តទើបកើតឡើង , ញ៉ាំងភាវនាចិត្តឲ្យត្រាច់ទៅក្នុងបដិភាគនិមិត្តនោះ ទើបដល់អប្បនា , តាំងនៅក្នុងអប្បនា ញ៉ាំងវិបស្សនាឲ្យចម្រើនហើយ ទើបធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបាន ព្រោះហេតុនោះ ទើបលោកពោលថា ការកាន់យកនិមិត្តដោយអាការ ១១ មានការនាំ ( កម្មដ្ឋាន ) ចូលទៅចងទុក ជាប្រយោជន៍ ។

## អធិប្បាយ ពាក្យឆ្លើយបញ្ហាថា
## *ការពិចារណាមើលផ្លូវទៅមក មានប្រយោជន៍ដូចម្ដេច ?*

ចំណែកប្រការថា ការពិចារណាមើលផ្លូវទៅមក ដែលញ៉ាំងកម្មដ្ឋានឲ្យឡើងកាន់វិថីជាប្រយោជន៍នោះ មានន័យថា ការពិចារណាមើលផ្លូវទៅផង ផ្លូវមកផង ដែលពោលហើយឯណា ការពិចារណានោះ មានប្រយោជន៍ គឺ ញ៉ាំងកម្មដ្ឋាន ( ដែលវិនាស ) ឲ្យឡើងកាន់វិថីនៃកម្មដ្ឋានវិញបាន មានន័យថា បើគេសួរថ្ងៃចំពោះភិក្ខុដែលកាន់យកកម្មដ្ឋានបានហើយ មកវិញថា “ លោកម្ចាស់ ថ្ងៃនេះតិថីទីប៉ុន្មាន ” ក្ដី សួរបញ្ហាក្ដី ធ្វើបដិសណ្ឋារៈក្ដី ក្នុងរវាងផ្លូវសោត បើសិនជាលោកនៅស្ងៀមដោយសំគាល់ខ្លួនថា ខ្លួនកើតព្រះកម្មដ្ឋាន ដើរទៅ ក៏មិនគួរ ចាំបាច់ត្រូវប្រាប់ថ្ងៃឆ្លើយបញ្ហា ប្រសិនបើមិនដឹង ក៏ត្រូវឆ្លើយថា អាត្មាមិនដឹង ត្រូវធ្វើបដិសណ្ឋារៈដោយប្រពៃតាមធម៌ កាលលោករវល់ធ្វើយ៉ាងនោះ និមិត្តថ្មី ៗ ដែលទើបតែបានមក

ក៏វិនាស សូម្បីកាលនិមិត្តកំពុងវិនាស លោកត្រូវគេសួរថ្ងៃ ក៏ត្រូវប្រាប់ មិនដឹងបញ្ហា ក៏ត្រូវឆ្លើយថា អាត្មាមិនដឹង សូម្បីដឹងក៏ប្រពៃ ចាំបាច់ត្រូវឆ្លើយយ៉ាងណាមួយឯបដិសណ្ឋារៈវិញ ចាំបាច់ត្រូវធ្វើ ។ ម្យ៉ាងវិញទៀត បើជួបភិក្ខុអាគន្តុកៈ ក៏ចាំបាច់ត្រូវធ្វើ អាគន្តុកបដិសណ្ឋារៈផងដែរ សូម្បីវត្តដ៏សេស គឺ វត្តដែលមកក្នុងខន្ធកៈវិន័យទាំងឡាយ ទាំងពួង មានចេតិយង្គណវត្ត ( វត្តដែលត្រូវធ្វើត្រង់លានព្រះចេតិយ ) ពោធិយង្គណវត្ត( វត្តដែលត្រូវធ្វើត្រង់ទីលានព្រះពោធិ ) ឧបោសថាគារវត្ត( វត្តត្រូវបំពេញត្រង់រោងឧបោសថ ) ភោជនសាលាវត្ត( វត្តដែលត្រូវបំពេញត្រង់សាលាឆាន់ ) ជន្តាឃរវត្ត( វត្តត្រូវបំពេញក្នុងរោងភ្លើង ) អាចរិយវត្ត( វត្តត្រូវបំពេញចំពោះអាចារ្យ ) ឧបជ្ឈាយវត្ត( វត្តដែលត្រូវបំពេញចំពោះឧបជ្ឈាយ៍ ) អាគន្តុកវត្ត( វត្តដែលត្រូវបំពេញចំពោះអាគន្តុកៈ ) គមិកវត្ត( វត្តដែលត្រូវបំពេញចំពោះភិក្ខុដែលបម្រុងនឹងទៅ ) ជាដើម ចាំបាច់ត្រូវធ្វើទាំងអស់ កាលលោករវល់តែបំពេញវត្តទាំងនោះហើយ និមិត្តថ្មីនោះអាចនឹងវិនាសទៅ កាលលោកគិតថានឹងទៅកាន់យកនិមិត្តទៀត សូម្បីជាអ្នកប្រាថ្នានឹងទៅ ក៏មិនអាច សូម្បីត្រឹមតែការចូលទៅកាន់ព្រៃខ្មោច ព្រោះអមនុស្ស ឬ សត្វសាហាវរារាំង ( ឬបើចូលព្រៃបាន ) និមិត្តក៏ប្រែប្រួលខូចអស់ ពិតណាស់ ឧទ្ធុមាតកអសុភស្ថិតនៅត្រឹម ១-២ ថ្ងៃប៉ុណ្ណោះ ក៏ដល់នូវសភាពជាអសុភដទៃ មានវិនីលកអសុភជាដើម ។ ក្នុងកម្មដ្ឋានទាំងអស់កម្មដ្ឋានឈ្មោះថា ដែលរកបានដោយកម្រ ស្មើដោយឧទ្ធុមាតកអសុភ មិនមាន ព្រោះហេតុនោះ កាលនិមិត្តវិនាសទៅហើយយ៉ាងនោះ ភិក្ខុនោះ គប្បីអង្គុយនៅត្រង់ទីដែលសម្រាកពេលយប់ ឬក្នុងទីសម្រាកពេលថ្ងៃក៏ដោយ ហើយពិចារណាដល់ផ្លូវទៅ ផ្លូវមក រហូតដល់កន្លែងដែលខ្លួនអង្គុយពែនភ្នែន យ៉ាងនេះថា “ យើងចេញអំពី

វិហារដោយទ្វារឈ្មោះនេះ ដើរតាមផ្លូវត្រង់ទៅទិសនោះ ផាកឆ្វេងត្រង់នេះ ផាកស្តាំត្រង់នោះ នៅត្រង់កន្លែងអសុភនោះ ជុំថ្មនៅត្រង់នោះ ឬជំបូក ដើមឈើ គុម្ពឈើ វល្លិ យ៉ាងណាមួយ នៅត្រង់ទីនោះៗ អាត្មាអញទៅតាមផ្លូវនោះ ទើបបានឃើញអសុភក្នុងទីឈ្មោះនោះ នៅទីនោះ ហើយឈរបែរមុខទៅទិសនោះ សម្គាល់និមិត្តទាំងឡាយដោយជុំវិញយ៉ាងនោះ កាន់យកអសុភនិមិត្តបានយ៉ាងនោះ ហើយចេញអំពីព្រៃខ្មោចតាមទិសនោះ ធ្វើកិច្ចនេះៗ តាមផ្លូវនោះៗ ជាលំដាប់តមករហូតដល់កំពុងអង្គុយនៅទីនេះ ” ។ កាលលោកពិចារណាយ៉ាងនេះ និមិត្តនោះនឹងប្រាកដឡើង គឺ ចូលមកប្រាកដ ដូចនៅចំពោះមុខ កម្មដ្ឋាននឹងឡើងកាន់វិថីដោយអាការដូចគ្រាដំបូង ព្រោះហេតុនោះ ទើបលោកពោលថា ការពិចារណាផ្លូវទៅមក មានប្រយោជន៍ គឺ ញ៉ាំងកម្មដ្ឋាន ( ដែលវិនាស ) ឲ្យឡើងកាន់វិថីវិញបាន ។

## អធិប្បាយសេចក្តីថា
## អានិសំសទស្សាវី ។ បេ ។ ចិត្តំ ឧបនិពន្ធតិ

ឥឡូវនេះបណ្ឌិត គប្បីជ្រាបអធិប្បាយក្នុងអដ្ឋកថា បាឋមាតិកាថា “ ព្រះយោគាវចរនោះ ជាអ្នកឃើញអានិសង្សនៅដោយប្រក្រតី មានសេចក្តីសម្គាល់( ក្នុងអសុភ )ដូចដួងកែវ ចូលទៅតាំងសេចក្តីកោតក្រែង( ក្នុងអសុភនោះ ) ប្រព្រឹត្តដូចថា ជាទីស្រឡាញ់ នាំចិត្តចូលទៅតម្កល់ទុកក្នុងអារម្មណ៍នោះ ” ។ ព្រះយោគាវចរញ៉ាំង **មានស្ស**( ការនាចិត្ត ) ឲ្យត្រាច់ទៅក្នុងឧទ្ធុមាតកអសុភដែលជាបដិកូល ញ៉ាំងឈានឲ្យកើតឡើង ចម្រើនវិបស្សនា ដែលមានឈានជាបទដ្ឋាន ជាអ្នកឃើញអានិសង្សយ៉ាងនេះថា “ យើងនឹងរួចផុតចាកជរា-មរណៈ តាមបដិបទានេះ ដោយ

ពិត ” ដូចជាអ្នកក្រ បានកែវមណីមានតម្លៃច្រើន ហើយត្រេកអរថា ខ្លួនបានរបស់ដែលរកបានដោយកម្រ នឹងគប្បីជាអ្នកមានសេចក្តីសម្គាល់ក្នុងកែវមណីនោះ ថាជារតនៈ ញុំាងគារវៈ ( សេចក្តីគោរព ) ឲ្យកើតឡើង ជ្រួតជ្រាបទៅដោយសេចក្តីស្រឡាញ់ដ៏ក្រៃលែង រក្សាកែវមណីនោះទុកយ៉ាងណា ព្រះយោគាវចរ ក៏ដូច្នោះដូចគ្នា ត្រេកអរថា ខ្លួនបានកម្មដ្ឋាននេះ ជាកម្មដ្ឋានបានដោយកម្រ ដូចគ្នានឹងកែវមណីមានតម្លៃច្រើនរបស់មនុស្សទុគ៌ត ព្រោះថា លោកអ្នកដែលបំពេញចតុធាតុកម្មដ្ឋាន ក៏កំណត់យកមហាភូតរូប ៤ របស់ខ្លួន អ្នកបំពេញអានាបានកម្មដ្ឋាន ក៏កំណត់យកខ្យល់ត្រង់ច្រមុះរបស់ខ្លួន អ្នកបំពេញកសិណកម្មដ្ឋានក៏ធ្វើកសិណ បំពេញទៅតាមសប្បាយ ។ កម្មដ្ឋានទាំងឡាយក្រៅអំពីនេះ ក៏រកបានងាយដូចគ្នា តែឧទ្ធុមាតកអសុភកម្មដ្ឋាននេះ ស្ថិតនៅបាន ១-២ ថ្ងៃ ប៉ុណ្ណោះ បន្ទាប់អំពីនោះទៅ ក៏ដល់នូវភាពជាអសុភដទៃ មានវិនីលកអសុភជាដើមទៅហើយ ព្រោះហេតុនោះ កម្មដ្ឋានដែលរកបានដោយលំបាកក្រៃលែងជាងឧទ្ធុមាតកកម្មដ្ឋាននោះ មិនមាន ដូច្នេះនឹងគប្បីជាអ្នកមានសេចក្តីសម្គាល់ក្នុងឧទ្ធុមាតកអសុភនោះថា ដូចជារតនៈ ចូលទៅតាំងសេចក្តីកោតក្រែងទុក ( ក្នុងអសុភនោះ ) ប្រព្រឹត្តដូចថា ជាទីស្រឡាញ់ រក្សានិមិត្តនោះទុក នាំចិត្តចូលទៅចងទុកក្នុងអសុភនោះរឿយ ៗ ដោយបរិកម្មថា **ឧទ្ធុមាតកំ បដិកូលំ ឧទ្ធុមាតកំ បដិកូលំ** គប្បីនឹករំពឹងចំពោះ( ឧគ្គហៈ )និមិត្តនោះទុក ធ្វើនិមិត្តនោះទុកក្នុងចិត្តរឿយៗ បរិកម្មរឿយៗ ធ្វើរហូតឲ្យជាវត្ថុនឹកមកបានៗ កាលលោកធ្វើយ៉ាងនោះ បដិភាគនិមិត្ត រមែងកើតឡើង ។

## និមិត្ត ២ យ៉ាង ផ្សេងគ្នា

នេះជាសេចក្តីផ្សេងគ្នានៃនិមិត្តទាំង ២ ក្នុងឧទ្ធុមាតកអសុភនោះ គឺឧគ្គហនិមិត្ត

ប្រាកដជារូបវិកល គួរខ្ពើមពន្លឹក ចំណែកបដិភាគនិមិត្ត ប្រាកដដូចជាអ្នកមានអង្គអវយវៈធំតូច ធាត់ ស្តើង បរិភោគអាហារហូតឆ្អែតស្កប់ស្កល់ ហើយដេកលក់ ។

## ចានបដិភាគនិមិត្ត លះនីវរណៈចាន
## អង្គឈានកើតឡើង

ព្រមគ្នានឹងពេលដែលបានបដិភាគនិមិត្តនោះឯង ព្រោះមិនដាក់ចិត្តដល់កាមទាំងឡាយក្នុងខាងក្រៅ , **កាមច្ឆន្ទៈ** ព្រះយោគាវចរនោះលះបង់បានដោយអំណាចវិក្ខម្ភនប្បហាន និងព្រោះលះសេចក្តីត្រេកអរបាននោះឯង , **ព្យាបាទ** លោកក៏លះបានផងដែរ ប្រៀបដូច ព្រោះលះបង់លោហិតបាន ខ្ទុះក៏លះបានផងដែរ ដូច្នោះដោយន័យដូចគ្នា , ព្រោះជាអ្នកមានសេចក្តីព្យាយាមដែលប្រារព្ធហើយ **ថីនមិទ្ធៈ**ក៏លះបង់បាន , **ឧទ្ធច្ចកុក្កុច្ចៈ** ក៏លះបង់បានផងដែរ ដោយអំណាចការតាមប្រកបធម៌ដែលស្ងប់ ដែលធ្វើការមិនក្តៅក្រហាយចិត្ត ( ក្នុងពេលក្រោយ ) ព្រោះធម្មវិសេសខ្លួនបានសម្រេចហើយ ជាគុណដែលប្រចក្ស ( ចំពោះខ្លួន ) វិចិកិច្ឆាក្នុងអង្គព្រះសាស្តាដែលទ្រង់សម្តែងគោលបដិបត្តិក្តី ក្នុងតួគោលបដិបត្តិក្តី ក្នុងផលនៃការបដិបត្តិក្តី ក៏លះបង់បាន , នីវរណធម៌ទាំង ៥ ព្រះយោគាវចរលះបង់បានដូច្នេះ ។

ម្យ៉ាងវិញទៀត អង្គឈានទាំងឡាយ គឺ **វិតក្កៈ** មានការលើកចិត្តឡើងកាន់អារម្មណ៍ក្នុងនិមិត្តនោះឯង ជាលក្ខណៈ , **វិចារៈ** មានការញ៉ាំងកិច្ច គឺ ការតាមប្រកបនូវនិមិត្តឲ្យសម្រេច , **បីតិ** មានវិសេសាធិគម ( **អធិគម** គឺ ធម្មវិសេស ) ដែលបានហើយជាបច្ច័យ , **សុខ** ចាត់ថាមានបស្សទ្ធិជានិមិត្ត( ហេតុ ) ព្រោះបស្សទ្ធិកើតឡើងដល់ព្រះយោគាវចរដែលមានចិត្តប្រកបដោយបីតិ និងឯកគ្គតា ដែលចាត់

ថា មានសុខជានិមិត្ត(ហេតុ) ព្រោះការតាំងមាំនូវចិត្ត កើតមានដល់ព្រះយោគាវចរ ដែលដល់នូវសេចក្តីសុខ ( ៥ នេះ ) រមែងប្រាកដឡើងដោយន័យដូច្នេះ ។ សូម្បីឧបចារឈានដែលជារូបប្រៀបផ្ទឹមនៃបឋមជ្ឈាន ក៏កើតដល់លោក ក្នុងខណៈនោះដូចគ្នា ។ តទៅនេះ ពាក្យពណ៌នាទាំងពួងរហូតដល់ អប្បនា នឹងដល់នូវភាពវសីនៃបឋមជ្ឈាន បណ្ឌិតគប្បីជ្រាបតាមន័យដែលបានពោលហើយ ក្នុងបឋវីកសិណនោះចុះ ។

# មហាដីកា

# ពណ៌នា វិនិច្ឆ័យកថា

------◎------

## វិនិច្ឆ័យ ឧគ្គហនិមិត្ត

ពាក្យថា **វិនិច្ឆ័យកថា** បានដល់ ពាក្យពណ៌នាសេចក្តីប្រកបការវិនិច្ឆ័យ ។ ពាក្យថា **ដោយទាក់ទងជាមួយនឹងការកាន់យកនិមិត្តតាមដែលពោលហើយ** គឺដោយទាក់ទងជាមួយនឹងការកាន់យកឧទ្ធុមាតកនិមិត្តដែលមានប្រការ ដូចបានពោលហើយ ដោយពណ៌ជាដើម និងដោយទី-តជាដើម ។ ពាក្យថា **គប្បីកាន់យកនិមិត្តទុកដោយល្អ** គឺ គប្បីកាន់យកអសុភនិមិត្តដោយប្រពៃនោះឯង តាមប្រការដែលឧគ្គហនិមិត្តនឹងប្រាកដបាន ។ ឥឡូវនេះ លោកអាចារ្យដើម្បីនឹងបង្ហាញដល់អាការដែលកាន់យកទុកដោយល្អ នូវនិមិត្តនោះឯង ទើបពោលថា **ធ្វើសតិឲ្យចូលទៅតាំងទុកដោយល្អ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ការធ្វើដដែលៗ រឿយៗយ៉ាងនេះ** មានន័យថា ព្រះយោគីដែលមានការជឿជាក់ថា “ យើងនឹងផុតចាកនូវ

ជរាមរណៈបានដោយបដិបទានេះ " ដូច្នេះ ចូលទៅតាំងសតិ និង សម្បជញ្ញៈទុកដោយល្អ ហើយរំពឹងដល់ឧទ្ធុមាតកអសុភគ្រាដំបូង ដោយអាការណា ក៏ធ្វើការនឹកទៅក្នុងឧទ្ធុមាតកអសុភនោះ ដដែលៗ រឿយៗ ដោយអាការនោះ ។ ពាក្យថា **នឹងគប្បីចងចាំទុក** នឹងគប្បីកំណត់ទុកដោយល្អ គឺ នឹងគប្បីកំណត់ទុកដោយសតិ និងគប្បីចាក់ធ្លុះដោយបញ្ញា យ៉ាងគោរព ។ ពិតណាស់ លោកសម្ដែងខែសតិ ទុកថា " ជាការទ្រទ្រង់ចាំ " ហើយ " ការទ្រទ្រង់ចាំក្នុងទីនេះ " បានដល់ ការចំណាំទុកបាន ។ លោកសម្ដែងខែបញ្ញាទុកថា " ជាការកំណត់ " ហើយការកំណត់ក្នុងទីនេះ បានដល់ ការចាក់ធ្លុះ ។ ន័យម្យ៉ាងទៀត ពាក្យថា **គប្បីទ្រទ្រង់ចាំទុក** បានដល់ គប្បីចូលទៅដៅទុកដោយបញ្ញា ដែលមានសតិជាប្រធាន ។ ព្រោះបញ្ញាវៀរចាកសតិក្នុងកាលណា ៗ មិនមាន ។ ពាក្យថា **គប្បីកំណត់ទុក** គឺ គប្បីកំណត់ដោយសតិដែលមានបញ្ញាជាប្រធាន ។ ព្រោះថា ក្នុងទីនេះបំណងយកសតិដែលប្រព្រឹត្តទៅព្រមជាមួយបញ្ញាប៉ុណ្ណោះ មិនបានបំណងយកសតិដែលវៀរបញ្ញានោះទេ ។ ការសម្លឹងមើលគប្បីមានបាន អាស្រ័យដោយទំនាក់ទំនងជាមួយនឹងការប្រើទ្វារភ្នែកជាដើម ព្រោះហេតុនោះ ទើបលោកពោលថា បើកភ្នែកមើល ដូច្នេះ ដោយពាក្យថា បើកភ្នែកមើលនោះ លោកសំដៅដល់ការមើលឃើញច្បាស់នោះឯង ។ ពាក្យថា **កាលធ្វើដដែលៗ រឿយៗ យ៉ាងនេះ** មានសេចក្ដីថា កាលព្រះយោគីធ្វើការបើកភ្នែកមើល និងការបិទភ្នែកនឹកគិតអស់ច្រើនវារៈ ជាប់តគ្នាទៅតាមប្រការដែលបានពោលហើយ ។ ពាក្យថា **ឧគ្គហនិមិត្ត** បានដល់ ឧគ្គហនិមិត្តក្នុងឧទ្ធុមាតកអសុភ ។ បទថា **សុគ្គហិតំ** ប្រែថា គឺ លោកកាន់យកបានដោយល្អ គឺលោកកាន់យកដោយប្រការដែលវាមិនវិនាស មិនវង្វេងភ្លេច ។ បទថា **ឯកសទិសំ**

( ដូចគ្នា ) ។ ព្រោះ ឯក ស័ព្ទនេះ មានអត្ថថា **ស្មើ** ដូចជាពាក្យថា “ **អរិយ-វិនយេតិ វា សប្បុរិសវិនយេតិ វា ឯកសេសេ ឯកេកជ្ជេ សមេ សភាគេ តជ្ជាតេ ហាញ្ញេវ** ” ពាក្យថា ក្នុងវិន័យរបស់ព្រះអរិយៈក្តី ពាក្យថា ក្នុងវិន័យរបស់សប្បុរសក្តី នេះនោះ មានអត្ថដូចគ្នា ស្មើគ្នា មានចំណែកស្មើគ្នា យ៉ាងនេះឯង ។ ពាក្យថា **ក្នុងវេលាមក** គឺ ក្នុងវេលាមកអំពីវិហារឆ្ពោះទៅកាន់ព្រៃខ្មោច ។ ពាក្យថា **តាមន័យដូចបានពោលហើយនោះឯង** លោកសម្តែងអត្ថដែលបានពោលទុកហើយ ដោយទាក់ទងជាមួយនឹងពាក្យចង្អុលបង្ហាញ ដោយសរុប ដោយពាក្យថា “ គប្បីជាបុគ្គលម្នាក់ឯង ” ជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា ( មនសិការ ) **កម្មដ្ឋាននោះៗឯង** គឺ មនសិការឧទ្ធុមាតកកម្មដ្ឋាន ។ អាចារ្យពួកមួយពោលថា “ មនសិការមូលកម្មដ្ឋាន ពាក្យនោះ មិនត្រឹមត្រូវ ” ។ ព្រោះថា ព្រះយោគីលះបង់ចោលកម្មដ្ឋានដែលមាននិមិត្តប្រាកដ ហើយទៅមនសិការកម្មដ្ឋានដទៃ ក៏ដូចនឹងព្រះរាជាទ្រង់លះបង់រាជសម្បត្តិយាងទៅកាន់ប្រទេសផ្សេង ដូច្នោះឯង ។ ពាក្យថា ( ព្រះយោគីដែល.... ) **មកដល់** គឺ មកដល់ស្ថានទីលំនៅរបស់ខ្លួន ។ បទថា **អវេលាយំ** គឺ ក្នុងវេលាដែលមិនសមគួរ មានពេលព្រលប់ជាដើម ។ បទថា **វិភច្ឆំ** ប្រែថា គួរខ្ពើម ។ ពាក្យថា អារម្មណ៍ដែលគួរខ្លាច គឺ អារម្មណ៍ដែលគួរខ្លាច ដូចជាវេតាល ( ខ្មោចព្រាយមួយប្រភេទ ) ។

ពាក្យថា **មានចិត្តរាយមាយ** គឺ ដល់នូវភាពរាយមាយទៅនៃចិត្ត ដូចបុគ្គលតក់ស្លុត ( កាល ) ឃើញបិសាចដូច្នោះ ។ ពាក្យថា **ទៅជាឆ្កួត** គឺ បុគ្គលខ្លះដូចជាយក្សឆ្កួត ។ បទថា **ឈានវិគ្គុតោ** បានដល់ ឃ្លាតចាកឈាន ដូចបុគ្គលដែល

ឈ្មោះថា **សីលវិព្ពន្ទក** ( ឃ្លាតចាកសីល ) **មន្តវិព្ពន្ទក** ( ឃ្លាតចាកមន្ត ) ដូច្នោះ ។ ពាក្យថា **ចិត្តរឹង** គឺជាអ្នកមិនញាប់ញ័រ ព្រោះប្រាសចាកការញាប់ញ័រ ដោយការស្ងប់ការភ័យខ្លាចដែលកើតឡើងហើយ លះបង់ចេញបាន ។ ពាក្យថា **ធ្វើសតិឲ្យចូលទៅតាំងទុកបានល្អ** ជាដើម លោកពោលទុកដើម្បីសម្តែងឧបាយពង្រឹងចិត្ត ។ កាលមិនមានការព្យាយាមក្នុងការដឹកនាំ( ទូន្មាន )ខ្លួន ដូចជា( រំលឹក )ថា សរីរៈរបស់មនុស្សស្លាប់ ដែលអាចក្រោកឡើងដេញតាមនរណាបាន មិនមាន ។ អាការដែលក្រោកឡើងដេញមកនោះ រមែងសម្រេចក្នុងរូបដែលមិនទាន់វិនាស គឺ មិនទាន់ដល់ភាពជាអសុភហើមប៉ោងជាដើមនោះឯង អធិប្បាយថា ក្នុងរាងកាយដែលមានសភាពយ៉ាងនេះ ( គឺហើមប៉ោង ) នឹងមានអាការនោះ ដូចជាសរីរៈរបស់ទេវតាបានក៏ទេ ។ ពាក្យថា **ដែលកើតអំពីសញ្ញា** គឺ កើតអំពីសញ្ញាក្នុងបរិកម្មនៃភាវនា ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា **កើតព្រោះសញ្ញា** គឺ មានសញ្ញាជាសមុដ្ឋាន ។ ពាក្យថា **បន្ទោបង់ការភ័យខ្លាចទាំងនោះ** គឺ បន្ទោបង់ បានដល់ ស្ងប់ការស្រៀវខ្លាចនៃចិត្តដែលកើតឡើង ដែលមានការប្រាកដនៃនិមិត្តជាហេតុ តាមប្រការដែលបានពោលហើយ ។ **ធ្វើសេចក្តីក្បៀវក្លាវីករាយ** គឺ ( ញុំាង ) បីតិ បាមោជ្ជឲ្យកើតឡើង ដោយគិតថា “ ឥឡូវនេះ សេចក្តីព្យាយាមរបស់អ្នក កើតមានផលឡើងហើយ ” ដូច្នេះ ។ ពាក្យថា **គប្បីធ្វើចិត្តឲ្យត្រាច់ទៅ** បានដល់ គប្បីធ្វើភាវនាចិត្តឲ្យប្រព្រឹត្តទៅ គឺ គប្បីមនសិការ ។

ពាក្យថា **ការកាន់យកនិមិត្ត** គឺ ការរៀនយកនិមិត្ត បានដល់ ឧគ្គហនិមិត្ត ។ ពាក្យថា **កាលធ្វើឲ្យដល់ព្រម** គឺ កាលធ្វើឲ្យសម្រេច បានដល់ កាលធ្វើឲ្យបានផល ។ ពាក្យថា **ចូលទៅចងកម្មដ្ឋានទុក** គឺ នាំភាវនាចូលទៅចងទុកក្នុងនិមិត្តតាម

ដែលបានពោលហើយ ។ ការបំពេញព្យាយាម លោកបំណងថា **កម្មដ្ឋាន** ព្រោះភាពជាហេតុនៃសុខវិសេសរបស់ព្រះយោគី ម្យ៉ាងទៀត និមិត្តតាមដែលប្រាកដហើយ ក៏ឈ្មោះថា **កម្មដ្ឋាន** ព្រោះជាទីតាំងនៃការប្រព្រឹត្តទៅក្នុងការបំពេញសេចក្តីព្យាយាម ព្រះយោគី រមែងចូលទៅចងកម្មដ្ឋាន គឺ និមិត្តនោះទុកក្នុងភាវនាចិត្ត ។

លោកអាចារ្យ កាលនឹងសម្តែងថា ពាក្យថា **ធ្វើចិត្តឲ្យត្រាច់ទៅ** ។ លោកនឹងសម្រេចគុណវិសេសបាន ក៏ដោយប្រការយ៉ាងនេះ ព្រះអដ្ឋកថាចារ្យពោលសំដៅយក ការចូលទៅចងទុកនូវនិមិត្តនោះឯង ដូច្នេះ ទើបពោលថា **តស្ស ហិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **តស្ស** ប្រែថា ដល់ព្រះយោគី ឬប្រែថា នៃឧទ្ធុមាតក-អសុភនោះ ។ ពាក្យថា **ដល់អ្នកដែលធ្វើចិត្តឲ្យត្រាច់ទៅ** គឺ ដល់អ្នកដែលធ្វើភាវនាចិត្តឲ្យប្រព្រឹត្តទៅជាប់តគ្នា មានន័យថា ដល់អ្នកដែលមនសិការរឿយៗនូវឧគ្គហនិមិត្តនោះ ។

ចំពោះបទថា **វីថិសម្បដិបាទនត្ថា** លោកអាចារ្យ កាលប្រាប់អត្ថន័យទុកថា “ បានដល់ មានការញ៉ាំងវិថីនៃកម្មដ្ឋាន ឲ្យដំណើរទៅដោយប្រពៃ ជាផល ” ដូច្នេះហើយ តែដើម្បីនឹងសម្តែងវិថីនៃកម្មដ្ឋាននោះ និងវិធីញ៉ាំងវិថីនៃកម្មដ្ឋាននោះឲ្យដំណើរទៅដោយប្រពៃ ដោយពិស្តារ ទើបពោលថា “ ពិតណាស់ ប្រសិនបើ ” ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ជាតិបីទីប៉ុន្មាន** មានន័យថា ជាតិបីទីប៉ុន្មាននៃបក្ខ ទី ២ ឬ ទី ៣ ជាដើម យ៉ាងណាមួយ ។

ឈ្មោះថា **ការដែលភិក្ខុជាអ្នកនៅស្ងៀម ដើរទៅ រមែងមិនគួរ** ក៏ដើម្បីការពារចិត្តរបស់បុគ្គលដទៃ ដែលសួរប្រការដទៃ ( ការពារចិត្តរបស់អ្នកសួរ នឹងយល់ខុសជាយ៉ាងដទៃ ) ។ ជាការពិតណាស់ ថា ការប្រតិបត្តិប្រពៃ នៅក្នុងព្រះ

សាសនា រមែងប្រព្រឹត្តទៅដើម្បីធ្វើបុគ្គលដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លា និងដើម្បីធ្វើបុគ្គលដែលជ្រះថ្លាហើយ ឲ្យជ្រះថ្លាក្រៃលែងឡើងទៅ ។ ពាក្យថា **នឹងវិនាសទៅ** គឺ នឹងមិនឃើញ មានន័យថា នឹងមិនប្រាកដ ។ ពាក្យថា **ត្រូវធ្វើអាគន្តុកបដិសណ្ឋារៈ** នេះលោកសម្ដែងដល់អាគន្តុកវត្ត តែម្យ៉ាង ព្រោះហេតុនោះ លោកពោលថា សូម្បីវត្តដ៏សេស ដូច្នេះហើយ ក៏នៅធ្វើស័ព្ទថា អាគន្តុកៈទៀត ដើម្បីនឹងកាន់យកអាគន្តុកវត្តឲ្យបរិបូរណ៍ ។

ក្នុងបទថា **គមិកវត្តាទីនិ** ( គមិកវត្តជាដើម ) ដោយ **អាទិ** ស័ព្ទ ( ដែលប្រែថា ជាដើម ) គប្បីឃើញថា សង្គ្រោះយកអាវាសិកវត្ត ( វត្តរបស់ភិក្ខុដែលនៅប្រចាំអាវាស ) , អនុមោទនវត្ត ( វត្ត គឺ ការអនុមោទនា ) , បិណ្ឌចារិកវត្ត ( វត្តរបស់ភិក្ខុដែលត្រាច់បិណ្ឌបាត ) , អារញ្ញិកវត្ត ( វត្តរបស់ភិក្ខុដែលនៅព្រៃ ) , សេនាសនវត្ត ( វត្តដែលត្រូវធ្វើ ទាក់ទងនឹងសេនាសនៈ ) , វច្ចកុដិវត្ត ( វត្តដែលត្រូវធ្វើទាក់ទងនឹងវច្ចកុដិ ) ជាដើម ។ ក៏វត្តធំៗដែលមកហើយក្នុងខន្ធកវត្ត លោកហៅក្នុងទីនេះថា **ខន្ធកវត្ត** ។ ចំណែកវត្ត ដែលត្រូវប្រព្រឹត្ត ក្នុងវេលាដែលធ្វើតជ្ជនីយកម្ម( ការទិតៀន )ជាដើម។ និងក្នុងវេលាដែលជាភិក្ខុអ្នកនៅបរិវាសជាដើម។ លោកមិនបានបំណងយកក្នុងទីនេះ ព្រោះមិនមានដល់ភិក្ខុរូបនេះ ។ ពាក្យថា **ឬនិមិត្តប្រែប្រួលទៅ** មានន័យថា និមិត្ត គឺ អសុភ ដែលនៅក្នុងទីស្មសាន រមែងប្រែប្រួលទៅដោយការអស់ភាពជាអសុភហើម ព្រោះហេតុនោះ ទើបលោកពោលថា **ឧទ្ធុមាតកអសុភ** ដូច្នេះជាដើម ។ បទថា **តស្មា** ប្រែថា ព្រោះហេតុនោះ មានន័យថា ព្រោះកម្មដ្ឋាននេះ រកបានដោយលំបាក ។ ភ្ជាប់សេចក្ដីថា **និសីទិត្វា បច្ចវេក្ខិតព្វោ** ។

ការពិចារណាទិសជាដើម តាមដែលបានសង្កេតទុកហើយ សូម្បីក្នុងគ្រាដែលកាន់យកនិមិត្តបាន ហើយត្រឡប់មក ក៏ដូចជាក្នុងកាលទៅ ដើម្បីនឹងកាន់យកនិមិត្ត រមែងមានដើម្បីប្រយោជន៍ដល់ការចាំបាន ដោយមិនកាត់ផ្តាច់នូវកិរិយាដែលធ្វើឲ្យប្រព្រឹត្តទៅ រហូតដល់កាលនិមិត្តវិនាស ។ ពិតណាស់ កាលមានការចាំបានជាប់តគ្នា អាការដែលកម្មដ្ឋានប្រាកដ ក្នុងវេលាដែលភិក្ខុនោះ ចូលទៅកាន់វិហារហើយអង្គុយ គប្បីប្រាកដបានជាក់ច្បាស់ ដូចជាអាការដែលចិត្តតាំងមាំ ក្នុងគ្រាកាន់យកសមថនិមិត្ត ដូច្នោះឯង ។ ព្រោះហេតុនោះ ទើបលោកពោលថា កាលលោកនោះពិចារណាទៅ យ៉ាងនេះ ។ ល ។ កម្មដ្ឋាន រមែងដំណើរទៅកាន់វិថីដោយអាការ ដូចជាអាការដំបូងនោះឯង មានន័យថា ការមនសិការកម្មដ្ឋានរមែងឡើងកាន់វិថីនៃភាវនាដោយអាការដំបូងនោះឯង ព្រោះក្នុងអាការដំបូង និមិត្តប្រាកដដោយភាវៈដែលជាក់ច្បាស់ ។

លោកអាចារ្យបំណងសម្តែងថា ដែលបានឈ្មោះថា អសុភហើមប៉ោងមិនស្អាត មានក្លិនស្អុយ គួរខ្ពើម ជាបដិកូល គួរស្បើម និងគួរខ្លាចដ៏ពន្លឹក ក្នុងអារម្មណ៍ដែលជាដូច្នោះ ចំពោះព្រះយោគីដែលប្រកបភាវនារឿយ ៗ ដែលជាអ្នកមាំទាំចំពោះបរិកម្ម ដែលបានតម្កល់មាំប៉ុណ្ណោះ ទើបនឹងសម្រេចនូវសេចក្តីប្រាថ្នាបាន យ៉ាងនេះ ដូច្នោះ ទើបលោកពោលថា ជាអ្នកសម្លឹងឃើញអានិសង្ស ដូច្នេះជាដើម ។ ពាក្យថា (សម្លឹងឃើញអានិសង្ស) យ៉ាងនេះ គឺ ជាអ្នកសម្លឹងឃើញអានិសង្សយ៉ាងនេះនោះឯង គឺ តាមអាការដែលបានពោលហើយនោះឯង ។

ពាក្យថា **រក្សាកែវមណីនោះទុក** មានន័យថា ព្រោះគិតថា “ យើងនឹងនៅជាសុខបាន អាស្រ័យវត្ថុនេះដោយពិត ” ដូច្នេះទើបរក្សាកែវមណីនោះទុក ដូចរក្សា

ជីវិតរបស់ខ្លួន ។ ពាក្យថា **ព្រះយោគីដែលបំពេញចតុធាតុកម្មដ្ឋាន** ជាដើម ជាពាក្យសម្តែងដល់កម្មដ្ឋានទាំងនោះរកបានដោយងាយ ។ ក្នុងពាក្យទាំងនោះ **ព្រះយោគីដែលមានធាតុ ៤ ជាកម្មដ្ឋាន ឬ ប្រកបក្នុងចតុធាតុកម្មដ្ឋាន ឬ បរិហារចតុធាតុកម្មដ្ឋាន** ឈ្មោះថា អ្នកបំពេញចតុធាតុកម្មដ្ឋាន ។ ពាក្យថា **កម្មដ្ឋានក្រៅពីនេះ** បានដល់ កម្មដ្ឋាន មានពួកអនុស្សតិ ព្រហ្មវិហារជាដើម ដ៏សេសអំពីពោលហើយ។ ពាក្យថា ( រក្សា ) **និមិត្តនោះ** គឺ ឧគ្គហនិមិត្តតាមដែលបានពោលហើយ ។ លោកអាចារ្យ កាលនឹងពោលថា **គប្បីរក្សា** ដូច្នេះហើយ បំណងនឹងសម្តែងវិធីរក្សាទៀត ទើបពោលថា **ក្នុងស្ថានទីសម្រាកពេលយប់** ដូច្នេះជាដើម ។

ឈ្មោះថា **នានាករណំ** ព្រោះអត្ថថា គ្រឿងធ្វើឲ្យផ្សេងគ្នា បានដល់ ភាពផ្សេងគ្នា ។ ឈ្មោះថា ប្រាកដជាសរីរៈគួរស្ញើម សម្តែងសេចក្តីគួរខ្លាច ក៏ព្រោះការដែលមនសិការ រកការសរសើរមិនបាន និងព្រោះអារម្មណ៍មិនស្ងប់ ។ គប្បីនាំពាក្យមកភ្ជាប់គ្នាថា “ បដិភាគនិមិត្ត ប្រាកដដូចជាបុរសដែលមានអវយវៈធំតូចហើមប៉ោង ដូច្នេះ ដោយបរិយាយផ្ទុយគ្នានឹងឧគ្គហនិមិត្តនោះចុះ ។ ពាក្យថា **ខាងក្រៅ** គឺ ខាងក្រៅអំពីអារម្មណ៍ខាងក្នុង ។ ពាក្យថា **ព្រោះមិនមនសិការ នូវកាមទាំងឡាយ** គឺ ព្រោះមិនមានការធ្វើទុកក្នុងចិត្ត ប្រារព្ធកាមគុណទាំងឡាយ ព្រោះកាមសញ្ញាត្រូវប្រានចេញឲ្យនៅក្នុងទីឆ្ងាយ ដោយអានុភាពនៃអសុភភាវនានោះឯង ។ ម្យ៉ាងទៀត ពាក្យថា **ព្រោះមិនមនសិការ** គឺ ព្រោះហេតុ ជាបដិបក្ខចំពោះការមនសិការ ។ ពិតណាស់ សត្វទាំងឡាយ រមែងមនសិការ ក្នុងកាមទាំងឡាយ ដោយអំណាចនៃកាមសញ្ញាណា អសុភសញ្ញាដែលជាបដិបក្ខចំពោះសញ្ញានោះ ឈ្មោះថា **អមនសិការ** ( គឺ ជាបដិបក្ខចំពោះមនសិការ ) **នៃកាម**

**ទាំងឡាយ** មានន័យថា មានអមនសិការនោះជាហេតុ ។ ព្រោះហេតុនោះ ទើបលោកពោលថា កាមច្ឆន្ទៈ ត្រូវលះបង់ទៅដោយអំណាចវិក្ខម្ភនប្បហាន ។ ពិតណាស់ សមាធិដែលមានកម្លាំង ដែលកំពុងកើតឡើងព្រមជាមួយអសុភសញ្ញា ដែលមានបដិភាគនិមិត្តជាអារម្មណ៍នោះឯង រមែងគ្របសង្កត់កាមច្ឆន្ទៈបាន ក្នុងកាលដែលគ្របសង្កត់ហេតុបានហើយ ក៏អាចនឹងគ្របសង្កត់ភាពអាឃាត ដែលមានការមិនត្រេកអរ ជាមូលបាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា និង ព្រោះលះសេចក្ដីត្រេកអរបាននោះឯង..... ព្យាបាទ ទើបត្រូវព្រះយោគីលះបង់បានដែរ ។ ពិតណាស់ **ព្យាបាទ** រមែងមិនកើតឡើងដល់អ្នកដែលលះបង់សេចក្ដីត្រេកអរបានហើយនោះទេ ។ **បីតិ** ដែលសហគតដោយអសុភសញ្ញា តាមដែលពោលហើយ កំពុងប្រព្រឹត្តទៅយ៉ាងប្រពៃនោះឯង រមែងគ្របសង្កត់ព្យាបាទបាន ។ ពាក្យថា **ព្រោះបានប្រារព្ធសេចក្ដីព្យាយាម ដោយប្រការនោះហើយ** មានន័យថា ព្រោះការដែលបានផ្ដងសេចក្ដីព្យាយាមទុក ដោយអំណាចការតម្កល់ចិត្តក្នុងកម្មដ្ឋានតាមសភាពដែលឧបចារជ្ឈាន អាចនឹងកើតឡើងបាន ។ ពិតណាស់ សម្រាប់ព្រះយោគីដែលផ្ដងសេចក្ដីព្យាយាម សម្មាសង្កប្បៈ រមែងកើតឡើងគ្របសង្កត់នូវថីនមិទ្ធៈបាន ព្រោះភាវៈដែលមានការផ្សាយទៅ ដូចគ្របសង្កត់មិច្ឆាសង្កប្បៈដូច្នោះ។

ឈ្មោះថា **វិប្បដិសារ** បានដល់ ការក្ដៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយ , ឈ្មោះថា **អវិប្បដិសារ** ក៏ព្រោះ ជាបដិបក្ខចំពោះវិប្បដិសារៈនោះ បានដល់ ភាវៈដែលចិត្តរលត់ត្រជាក់ហើយ ព្រោះមិនមានការក្ដៅក្រហាយ គឺ សេចក្ដីខ្វល់ខ្វាយ ។ **សីល** ជាបច្ច័យដល់អវិប្បដិសារៈនោះ ធម៌ទាំងឡាយមានបីតិ បស្សទ្ធិ សុខជាដើម ដែលសហគតៈដោយសីលនោះ និង មានសីលនោះ ជាឧបនិស្ស័យ

មានភាពស្ងប់ដោយសភាវៈ និងដោយហេតុ ឧទ្ធច្ចកុក្កុច្ចៈដែលមានសភាពមិនស្ងប់ ទើបត្រូវលះទៅ ព្រោះការប្រកបរឿយៗនូវធម៌ទាំងនោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ឧទ្ធច្ចកុក្កុច្ចៈ ក៏ត្រូវលះបង់ទៅ ដោយអំណាចនៃការប្រកបរឿយៗ នូវធម៌ដែលស្ងប់ ដែលបង្កើតឡើងនូវអវិប្បដិសារៈ ។

ពិតណាស់ កាលភាវនានាំមកនូវគុណវិសេសជាប់តគ្នាទៅ ព្រះយោគីរមែងបានសុខដ៏ក្រៃលែងណា សុខនោះ រមែងកើតឡើងគ្របសង្កត់នូវឧទ្ធច្ចកុក្កុច្ចៈ ដែលមានសភាវៈមិនស្ងប់ នោះឯង ។ ពាក្យថា **នូវគុណវិសេសដែលបានសម្រេចហើយ** គឺ នូវភាវនាពិសេសតាមដែលបានសម្រេចហើយ ។ ពាក្យថា **ព្រោះភាវៈដែលឃើញប្រចក្ស** គឺ ព្រោះភាវៈដែលប្រចក្សដល់ព្រះយោគីដែលកំពុងបដិបត្តិ ។

វិចិកិច្ឆាក្នុងព្រះសាស្តា ដែលទ្រង់សម្តែងគោលបដិបត្តិ ត្រូវលះទៅដោយន័យថា “ បុគ្គលដែលសម្តែងសម្មាបដិបត្តិឲ្យឃើញដូច្នេះបាន ត្រូវតែជាព្រះដ៏មានព្រះភាគសម្មាសម្ពុទ្ធជាម្ចាស់ ហ្ន៎ ! ” ។ ពាក្យថា **ក្នុងការបដិបត្តិ** គឺ ក្នុងការបដិបត្តិឈាន ដែលកំពុងបដិបត្តិ ។ ពាក្យថា **ក្នុងផលនៃការបដិបត្តិ** គឺ ក្នុងលោកិយផល និង លោកុត្តរផល ដែលគប្បីធ្វើឲ្យសម្រេចបានដោយការបដិបត្តិនោះ ។ ឈ្មោះថា **វិចិកិច្ឆាត្រូវលះបង់ទៅ** ក៏ដោយកម្លាំងនៃវិចារៈ គឺ ដោយកម្លាំងនៃវិចារៈដែលអនុលោមតាមធម៌ នាំមក ។ ពាក្យថា **នីវរណៈ ៥ ត្រូវលះបង់ទៅយ៉ាងនេះ** មានន័យថា នីវរណៈ ៥ មានកាមច្ឆន្ទៈជាដើម ត្រូវព្រះយោគីលះបង់ទៅដោយទាក់ទងនឹងការគ្របសង្កត់ដោយធម៌ មានសមាធិជាដើម ដែលសម្រេចដោយអានុភាពនៃភាវនា ដែលប្រព្រឹត្តទៅអស់កាលក្នុងខាងដើម ព្រមគ្នានឹងការបាននូវបដិភាគនិមិត្តនោះឯង យ៉ាងនេះ ។ ពិតណាស់ វៀរធម៌ដែលជាបដិបក្ខចេញហើយ

រមែងមិនមានការលះបង់ធម៌ដែលគួរលះឡើយ ធម៌មានសមាធិជាដើម ជាបដិបក្ខចំពោះធម៌ មានកាមច្ឆន្ទៈជាដើម ។ ដូចដែលលោកពោលទុកក្នុងបករណ៍បេដកថា “ សមាធិជាបដិបក្ខចំពោះកាមច្ឆន្ទៈ ” ជាដើម ។

ព្រោះហេតុនោះ នោះឯង លោកអាចារ្យបំណាងសម្តែងអង្គឈានទាំងឡាយ ដោយតួសភាវៈដែលមានប្រាកដ ដោយសម្តែងការលះបង់ជាគន្លង ជាហេតុ ថា **ការលះបង់នីវរណៈទាំងនោះ រមែងមានបានដោយអង្គឈានទាំងនោះ** ដូច្នេះ ទើបពោលថា **តស្មីយេវ ច** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា ( មានការលើកចិត្តទុក ) ក្នុងនិមិត្តនោះៗឯង គឺ ក្នុងនិមិត្តដែលជាបដិភាគនិមិត្ត ដែលប្រាកដដូចជ្រែកឧគ្គហនិមិត្ត ប្រាកដចេញមក ជានិមិត្តដែលជាស្រមោលនៃឧគ្គហនិមិត្តនោះៗឯង ។ ពាក្យថា **ចិត្ត** បានដល់ ចិត្តដែលសម្បយុត្តនឹងខ្លួន ។ បទថា **អភិនិរោបនលក្ខណោ** ប្រែថា មានការលើកទុកជាលក្ខណៈ មានន័យថា មានការធ្វើឲ្យដល់( នូវនិមិត្ត ) ជាសភាវៈ ។ ឈ្មោះថា **ការតាមអង្អែលនិមិត្ត** គឺ ការត្រាច់ទៅរឿយៗ ក្នុងបដិភាគនិមិត្ត ។ ការប្រព្រឹត្តទៅដោយអាការដែលត្រាច់ទៅរឿយៗក្នុងអារម្មណ៍នៃវិចារៈ ដូចការហើរថ្លែលរឿយៗលើផ្កាឈូកនៃសត្វកន្លង់ ឈ្មោះថា កិច្ច គឺ ការតាមបបោសអង្អែល ។ គុណវិសេសនោះឯង ឈ្មោះថា **អធិគមវិសេស** ព្រោះព្រះយោគីគប្បីសម្រេច , ឈ្មោះថា **បដិលទ្ធវិសេសាធិគម** ព្រោះអត្ថថា ជាអធិគមវិសេសដែលព្រះយោគីបានមក , **បីតិ** មានអធិគមវិសេសដែលព្រះយោគីបានមកនោះ ជាបច្ច័យ គឺ មានអធិគមវិសេសដែលបានមកនោះ ជាហេតុ ឈ្មោះថា **បដិលទ្ធវិសេសាធិគម បច្ចយា បីតិ** ។ ពាក្យថា **ព្រះយោគីដែលមានបីតិចិត្ត** គឺព្រះយោគីដែលមានចិត្តសហគតដោយបីតិ ។ ពាក្យថា **កើតបស្សទ្ធិ** គឺ

សម្រេចកាយបស្សទ្ធិនិងចិត្តបស្សទ្ធិ ។ សមដូចដែលទ្រង់ត្រាស់ទុកថា **បីតិមនស្ស កាយោ បស្សម្ភតិ** កាយរបស់ភិក្ខុដែលមានចិត្តប្រកបដោយបីតិ រមែងស្ងប់រំងាប់ ដូច្នេះ ។ **សុខ** ដែលមានបស្សទ្ធិជាហេតុ ឈ្មោះថា **បស្សទ្ធិនិមិត្តំ** តាមពាក្យដែលទ្រង់ត្រាស់ទុកថា **បស្សទ្ធកាយោ សុខំ វេទយតិ** ភិក្ខុដែលមានកាយស្ងប់រំងាប់ហើយ រមែងសោយសុខ ដូច្នេះ ។ **ឯកគ្គតា** ដែលមានសុខជាបច្ច័យ ឈ្មោះថា មានសុខជាហេតុ ។ សមដូចដែលទ្រង់ត្រាស់ទុកថា **សុខិនោ ចិត្តំ សមាធិយតិ** ចិត្តរបស់ភិក្ខុដែលមានសុខ រមែងតាំងមាំ ដូច្នេះ ។ ពាក្យថា **អង្គឈានទាំងឡាយរមែងប្រាកដយ៉ាងនេះ** មានន័យថា អង្គឈានទាំងឡាយ មានវិតក្កៈជាដើមទាំងនេះ រមែងកើតឡើងក្នុងនិមិត្តនោះៗឯង យ៉ាងនេះ ។ ពាក្យថា **ដែលជារូបប្រៀបរបស់បឋមជ្ឈាន** គឺ ដែលជាគន្លងនៃបឋមជ្ឈាន អធិប្បាយថា សូម្បីឧបចារឈាន ក៏រមែងកើតឡើងក្នុងខណៈនោះៗឯង គឺ ក្នុងកាលព្រមគ្នានឹងការបានមកនូវបដិភាគ-និមិត្តនោះឯង មិនមែនចំពោះតែការលះបង់នីវរណៈប៉ុណ្ណោះទេ ។

( ចប់ មហាដីកា )

## ២.វិនីលកអសុភកម្មដ្ឋាន

សូម្បីក្នុងកម្មដ្ឋានទាំងឡាយ( ដ៏សេស ) មានវិនីលកអសុភកម្មដ្ឋានជាដើម ត អំពីនេះទៅ លក្ខណៈ( ការកាន់យកនិមិត្ត ) ចាប់តាំងពីការទៅ( មើលអសុភ ) ជាដើម ទៅ ដែលលោកពោលទុកដោយន័យថា **ឧទ្ធុមាតកំ អសុភនិមិត្តំ ឧគ្គណ្ហន្តោ ឯកោ អទុតិយោ គច្ឆតិ ឧបដ្ឋិតាយ សតិយា** កិច្ចកាលនឹងរៀនយកអសុភនិមិត្ត ប្រភេទ ឧទ្ធុមាតកៈ គប្បីទៅម្នាក់ឯង មិនត្រូវមានសំឡាញ់ មានសតិតាំងមាំ ដូច្នេះជាដើម នោះ យ៉ាងណា លក្ខណៈនោះទាំងពួង ព្រមទាំងវិនិច្ឆ័យ និងអធិប្បាយ បណ្ឌិត គប្បីជ្រាបតាមន័យដែលលោកពោលហើយនោះឯង ប្លែកតែឧទ្ធុមាតកៈក្នុងទីនោះៗ តាមអសុភនោះៗ ដូចយ៉ាងនេះថា “ **វិនីលកំ អសុភនិមិត្តំ ឧគ្គណ្ហន្តោ វិបុព្វកំ អសុភនិមិត្តំ ឧគ្គណ្ហន្តោ** កិច្ចកាលនឹងរៀនយកអសុភនិមិត្ត ប្រភេទ វិនីលកៈ .... កិច្ចកាលនឹងរៀនយកអសុភនិមិត្តប្រភេទវិបុព្វកៈ....” ( ដូច្នេះ ជាឧទាហរណ៍ ) ចំណែកសេចក្ដី ( តទៅ ) នេះ ជាសេចក្ដីផ្សេងគ្នា...។

ក្នុងវិនីលកអសុភ ព្រះយោគាវចរ គប្បីញុំាងមនសិការឲ្យប្រព្រឹត្តទៅថា **វិនីលកំ បដិកូលំ , វិនីលកំ បដិកូលំ** ( វិនីលកអសុភ ជាបដិកូលៗ ) ។

ម្យ៉ាងវិញទៀត ឧគ្គហនិមិត្តក្នុងកម្មដ្ឋាននេះ ប្រាកដជាសរីរៈដែលមានពណ៌ ផ្សេង ៗ លាយឡំគ្នា ចំណែកបដិភាគនិមិត្ត រមែងប្រាកដដោយអំណាចនៃពណ៌ ដែលក្រាស់ច្រើន ( ជាងពណ៌ដទៃ ) ។

## ៣.វិបុព្វកអសុភកម្មដ្ឋាន

ក្នុងវិបុព្វកអសុភ គប្បីញុំាងមនសិការឲ្យប្រព្រឹត្តទៅថា **វិបុព្វកំ បដិកូលំ**

**វិបុព្វកំ បដិកូលំ** ( វិបុព្វកអសុភ ជាបដិកូល ៗ ) ។ ចំណែកឧគ្គហនិមិត្តក្នុងកម្មដ្ឋាននោះ ប្រាកដជា (សរីរៈ) ដូចជាមានខ្ទុះនៅហូរ បដិភាគនិមិត្តប្រាកដដូចជាសរីរៈស្ងៀមឈឹង ។

## ៤.វិច្ឆិទ្ទកអសុភកម្មដ្ឋាន

វិច្ឆិទ្ទកអសុភ រមែងមាននៅក្នុងទីលានចម្បាំងខ្លះ ក្នុងព្រៃចោរខ្លះ ក្នុងទីស្មសានដែលព្រះរាជាទាំងឡាយ បញ្ជាឲ្យ (ប្រហារដោយវិធី) កាត់ (សរីរៈ) ពួកចោរជា (កំណាត់ៗ) ខ្លះ ឬក្នុងព្រៃត្រង់ទីដែលមានមនុស្សត្រូវសីហៈ ឬខ្លាខាំ (រហូតដាច់ខ្លួនចេញអំពីគ្នា ) ខ្លះ ។ ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីចូលទៅកាន់ស្ថានទីបែបនោះ ។ បើអសុភនោះ (ដាច់ជាកំណាត់) ធ្លាក់ (រាយប៉ាយ) នៅផ្សេងទិសគ្នា តែមកកាន់គន្លង ( ដូចគ្នា ) បាន ដោយអាវជ្ជនជាមួយគ្នាសោត មកបានយ៉ាងនេះ នោះជាការល្អ ប្រសិនបើមិនមក ក៏កុំចាប់ពាល់ (យកមករួមគ្នា) ដោយដៃខ្លួនឯង ព្រោះតែការចាប់ពាល់ លោកនឹងមានភាពស្និទ្ធស្នាល ព្រោះហេតុនោះ ទើបគួររកគ្រោមវត្ត ឬ សាមណុទ្ទេស ឬនរណាៗដទៃក៏បាន ឲ្យធ្វើ ប្រមូលទុកក្នុងកន្លែងតែមួយ ។ ប្រសិនបើរកមិនបាន គប្បីប្រើឈើចង្កៀស ឬឈើប្រត់ធ្មៀស ប្រមូលទុកចន្លោះ ( ឃ្លាតពីគ្នាត្រឹម ) ១ អង្គុលី កាលធ្មៀសប្រមូលយ៉ាងនោះហើយ ទើបញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅថា **វិច្ឆិទ្ទកំ បដិកូលំ , វិច្ឆិទ្ទកំ បដិកូលំ** ( វិច្ឆិទ្ទកអសុភ ជាបដិកូល ៗ ) ។

ឧគ្គហនិមិត្តក្នុងកម្មដ្ឋាននេះ ប្រាកដជាសរីរៈ ហាក់ដូចជាដាច់ពាក់កណ្ដាលនៅឡើយ លុះដល់បដិភាគនិមិត្ត ទើបប្រាកដជាសរីរៈពេញលេញ ។

## ៥.វិក្ខាយិតកអសុភកម្មដ្ឋាន

ក្នុងវិក្ខាយិតកអសុភ គប្បីញុំាងមនសិការឲ្យប្រព្រឹត្តទៅ ថា **វិក្ខាយិតកំ បដិកូលំ , វិក្ខាយិតកំ បដិកូលំ** ( វិក្ខាយិតកអសុភ ជាបដិកូលៗ ) ។

ចំណែកឧគ្គហនិមិត្តក្នុងកម្មដ្ឋាននេះ ប្រាកដជាសរីរៈដូចសរីរៈដែលត្រូវសត្វកកេរកញ្ឆក់អន្ទើៗ បដិភាគនិមិត្តទើបប្រាកដជាសរីរៈពេញលេញ ។

## ៦.វិក្ខិត្តកអសុភកម្មដ្ឋាន

ព្រះយោគាវចរ គប្បីប្រើមនុស្សឲ្យធ្វើ( ការប្រមូល ) ឬធ្វើខ្លួនឯង( ដោយប្រើឈើច្រត់ឆ្កៀសប្រមូលនូវវិក្ខិត្តកអសុភ ឲ្យមានរវាងចន្លោះ ( ពីគ្នា ) ១ អង្គុលី ៗ តាមន័យដែលពោលក្នុងវិច្ឆិទ្ទកអសុភនោះឯង ហើយញុំាងមនសិការឲ្យប្រព្រឹត្តទៅថា **វិក្ខិត្តកំ បដិកូលំ , វិក្ខិត្តកំ បដិកូលំ ( វិក្ខិត្តកអសុភ ជាបដិកូលៗ )** ។

ឧគ្គហនិមិត្តក្នុងកម្មដ្ឋាននេះ ប្រាកដជាសរីរៈ មានស្នាមបែក ( ប្រេះ ៗ ) បដិភាគនិមិត្ត ទើបប្រាកដជាសរីរៈពេញលេញ ។

## ៧. ហតវិក្ខិត្តកអសុភកម្មដ្ឋាន

សូម្បីហតវិក្ខិត្តកអសុភ ក៏រកបានតាមទីទាំងឡាយដែលមានប្រការដូចពោលក្នុងវិច្ឆិទ្ទកអសុភ ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីទៅក្នុងទីទាំងនោះ ប្រើមនុស្សឲ្យធ្វើ ឬ ធ្វើខ្លួនឯង ឲ្យមានចន្លោះពីគ្នា ១ អង្គុលីៗ តាមន័យដែលបានពោលហើយនោះ ហើយញុំាងមនសិការឲ្យប្រព្រឹត្តទៅថា **ហតវិក្ខិត្តកំ បដិកូលំ ហតវិក្ខិត្តកំ បដិកូលំ** ( ហតវិក្ខិត្តកអសុភ ជាបដិកូលៗ ) ។

ចំណែក ឧគ្គហនិមិត្ត ក្នុងកម្មដ្ឋាននេះ ដូចជាសរីរៈដែលមានមុខដំបៅត្រូវប្រហារ បដិភាគនិមិត្ត ទើបប្រាកដជាសរីរៈពេញលេញ ។

## ៨.លោហិតកអសុភកម្មដ្ឋាន

លោហិតកអសុភ រមែងបានក្នុងកាលដែលអវយវៈទាំងឡាយ មានដៃនិងជើងជាដើម របស់បុគ្គលដែលត្រូវប្រហារក្នុងទីផ្សេងៗ មានទីលានចម្បាំងជាដើមរបួស ហើយឈាមកំពុងហូរ ឬ ក្នុងកាលដែលលោហិតកំពុងហូរចេញអំពីមុខដំបៅរបស់សាកសព ដែលមានបូស ឬ ពងបែកជាដើម ព្រោះដូច្នោះ ព្រះយោគាវចរឃើញលោហិតនោះហើយ គប្បីញុំាងមនសិការឲ្យប្រព្រឹត្តទៅ ថា **លោហិតកំ បដិកូលំ , លោហិតកំ បដិកូលំ ( លោហិតកអសុភ ជាបដិកូលៗ )** ។

ឧគ្គហនិមិត្តក្នុងកម្មដ្ឋាននោះ ប្រាកដជាសរីរៈមានអាការញ័រ ដូចទង់សំពត់ក្រហមត្រូវខ្យល់ តែបដិភាគនិមិត្តប្រាកដជាសរីរៈស្ងៀមឈឹង ។

## ៩.បុឡុវកអសុភកម្មដ្ឋាន

បុឡុវកអសុភ រមែងកើតក្នុងកាលដែលហ្វូងដង្កូវ រុកចេញតាមមុខដំបៅទាំង ៩ របស់សាកសព កាលកន្លងទៅបាន ២-៣ ថ្ងៃ ។ ម្យ៉ាងទៀត បុឡុវកអសុភនោះ រមែងមានទំហំប៉ុនសាកសពផ្សេងៗ ដូចជាឆ្កែស្រុក ឆ្កែព្រៃ មនុស្ស គោ ក្របី ដំរី សេះ និង ពស់ថ្លាន់ តាំងនៅបីដូចគំនរបាយស្រូវសាលី ។ ព្រះយោគីគប្បីញុំាងមនសិការឲ្យប្រព្រឹត្តទៅក្នុងសាកសពទាំងនោះ យ៉ាងណាមួយថា **បុឡុវកំ បដិកូលំ , បុឡុវកំ បដិកូលំ ( បុឡុវកអសុភ ជាបដិកូលៗ )** ។ ពិតណាស់ និមិត្តក្នុងសាកសពដំរីក្នុងបឹងកាឡទីយវាបី ក៏បានប្រាកដដល់ព្រះចូឡបិណ្ឌបាតិកតិស្សត្ថេរ ។

ចំណែកឧគ្គហនិមិត្តក្នុងកម្មដ្ឋាននេះ ប្រាកដដូចជាសរីរៈញ័រនៅឡើយ បដិ-ភាគនិមិត្ត ទើបប្រាកដជាសរីរៈស្ងៀមឈឹង ដូចគំនរបាយនៃស្រូវសាលី ។

## ១០. អដ្ឋិកអសុភកម្មដ្ឋាន

អដ្ឋិកអសុភ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ក្នុង ( មហាសតិប្បដ្ឋានសូត្រ ) ដោយប្រការផ្សេងៗ ដោយន័យថា " ភិក្ខុនោះគប្បីសម្លឹងមើលសាកសព ដែលគេបោលក្នុងព្រៃស្មសាន ជាពង្អឹងនៅមានសាច់និងឈាម ( ជាប់ខ្លះ ) នៅមានសរសៃជាគ្រឿងចង " ដូច្នេះជាដើម ព្រោះហេតុនោះ សរីរៈនោះគេបោលក្នុងទីណា ព្រះយោគាវចរគប្បីទៅក្នុងទីនោះ តាមន័យដែលបានពោលមកហើយនោះឯង ធ្វើនិមិត្តរូប អារម្មណ៍រូបតាមតែវត្ថុ ( ដែលមានប្រាកដ ) ដោយជុំវិញ មានដុំថ្មជាដើម ហើយសង្កេតឲ្យច្បាស់តាមសភាពដែលវាមាន ថា នេះឆ្អឹង ហើយទើបកាន់យកនិមិត្ត ( ឲ្យកើតឧគ្គហនិមិត្តឡើង ) ដោយអាការ ១១ យ៉ាង មានពណ៌ជាដើម ។ តែអដ្ឋិកអសុភនោះ បើមើលដោយពណ៌ថា ស រមែងមិនប្រាកដ ព្រោះលាយឡំនឹងឱទាត-កសិណ ព្រោះដូច្នោះ ត្រូវមើលថា ជាឆ្អឹង ដោយផ្លូវជារបស់បដិកូលប៉ុណ្ណោះ ។

ពាក្យថា **ភេទ** ក្នុងអសុភនេះ ជាឈ្មោះនៃអវយវៈទាំងឡាយ មានដៃជាដើម ព្រោះដូច្នោះ **ដោយភេទ** គប្បីកំណត់តាម ប្រអប់ដៃ ប្រអប់ជើង ក្បាលទ្រូង ដៃ ចង្កេះ ជើង ស្មង បុះ ។ ចំណែកការពោល **ដោយសណ្ឋាន** គប្បីកំណត់ដោយ ភាពវែងនិងខ្លី មូលនិងបួនជ្រុង តូចនិងធំ ទិសនិងឱកាស មានន័យដូចពោលហើយ ចំណែកដោយទីខណ្ឌ គប្បីកំណត់ដោយព្រំដែននៃឆ្អឹងនោះ ៗ ។ ក្នុងឆ្អឹងទាំងពួងនោះ និមិត្តនៃឆ្អឹងកំណាត់ណាប្រាកដច្បាស់ គប្បីកាន់យកនិមិត្តនោះ

( រហូតដល់ ) អប្បនាចុះ ។ ចំណែកដោយ **ទីផត** និង **ទីប៉ោង** គប្បីកំណត់តាមទីផត និង ទីប៉ោង នៃឆ្អឹងនោះ ៗ ។ម្យ៉ាងទៀត គប្បីកំណត់ដោយស្ថានទី ថា យើងឈរនៅត្រង់ទីទំនាប ឆ្អឹងនៅត្រង់ទីទួល ឬថា យើងឈរនៅទីទួល ឆ្អឹងនៅទីទំនាប ដូច្នេះក៏បាន ។ ចំណែកដោយ **ទី-ត** គប្បីកំណត់យកតាមដែលឆ្អឹងពីរកំណាត់ទល់គ្នា ។ ដោយ **ប្រហោង** គប្បីកំណត់យកតាមចន្លោះនៃឆ្អឹងទាំងឡាយនោះឯង ។ ចំណែកដោយ **ជុំវិញខ្លួន** គប្បីញុំាងញាណឲ្យប្រព្រឹត្តទៅក្នុងឆ្អឹងទូទៅកំណត់ថា ត្រង់នេះ ឆ្អឹងនេះ ។ បើនិមិត្តមិនប្រាកដដោយការនោះវិធីយ៉ាងនេះ គប្បីបញ្ឈប់ចិត្តទុកត្រង់ឆ្អឹងថ្ងាសចុះ ការកាន់យកនិមិត្តដោយអាការ ១១ យ៉ាងនេះ ក្នុងអដ្ឋិកអសុភនេះ យ៉ាងណា សូម្បីក្នុងអសុភមុនៗ មានបុឡុវកអសុភជាដើម គប្បីសង្កេតកាន់យកតាមអាការដែលសមគួរចុះ ។ ក៏ព្រោះក្នុងកម្មដ្ឋានប្រការនេះ រមែងសម្រេចបានក្នុងរាងឆ្អឹងទាំងមូលក៏បាន ក្នុងឆ្អឹងមួយកំណាត់ក៏បាន ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីកាន់យកនិមិត្តដោយអាការ ១១ ក្នុងរាងឆ្អឹង ឬ កំណាត់ឆ្អឹងនោះ ណាមួយ ឡើងហើយ ញុំាងមនសិការឲ្យប្រព្រឹត្តទៅថា **អដ្ឋិកំ បដិកូលំ , អដ្ឋិកំ បដិកូលំ** ( អដ្ឋិកអសុភ ជាបដិកូលៗ ) ចុះ ។

## លក្ខណនិមិត្តទាំង ២ ក្នុងអដ្ឋិកអសុភ

លោកពោលទុកក្នុងអដ្ឋកថា ថា “ **ឧគ្គហនិមិត្តក្តី បដិភាគនិមិត្តក្តី ក្នុងកម្មដ្ឋាននេះ ដូចគ្នាតែម្យ៉ាង** ” ពាក្យនោះ ( សម្រាប់ ) ឆ្អឹងតែមួយកំណាត់ ជាការត្រឹមត្រូវ តែក្នុងរាងឆ្អឹងទាំងមូល ( ក៏ជា ) សរីរៈដែលមានប្រហោង ( ប្រាកដ ) ក្នុងឧគ្គហនិមិត្ត ភាពជាសរីរៈពេញលេញប្រាកដក្នុងបដិភាគនិមិត្ត ទើបគួរ , ម្យ៉ាងវិញ

ទៀត សូម្បីក្នុងដីកាមួយកំណាត់ ក្នុងឧគ្គហនិមិត្តក៏គួរជារូបវិកលគួរខ្លាច តែក្នុងបដិភាគនិមិត្ត គួរជារូបដែលធ្វើបីតិសោមនស្សឲ្យកើត ព្រោះជានិមិត្តដែលនាំមកនូវឧបចារៈ តែក្នុងឱកាសនេះ ពាក្យដែលពោលទុកក្នុងអដ្ឋកថាទាំងឡាយ លោកក៏ពោលឲ្យបន្ទោះទុកដូចគ្នា ពិតហើយ ក្នុងអដ្ឋកថានោះ សូម្បីទីងបានពោលថា " ក្នុងព្រហ្មវិហារ ៤ និង ក្នុងអសុភ ១០ បដិភាគនិមិត្តមិនមាន ព្រោះក្នុងព្រហ្មវិហារ **សីមសម្ភេទ** ( ដែនទល់គ្នា ) ប៉ុណ្ណោះ ជានិមិត្ត និងក្នុងអសុភ ១០ កាលឃើញភាពជាបដិកូលរហូតមិនមានវិកប្ប ត្រឹមប៉ុណ្ណោះ ក៏រាប់ថាជានិមិត្ត ដូច្នេះហើយ ក៏ពោលជាប់តទៅទៀតថា " និមិត្តក្នុងអសុភនេះមាន ២ យ៉ាង គឺ ឧគ្គហនិមិត្ត និង បដិភាគនិមិត្ត - ឧគ្គហនិមិត្តប្រាកដជារូបវិកលពន្លឹក ជាអារម្មណ៍គួរខ្លាច " ដូច្នេះជាដើម ព្រោះហេតុនោះ ខ្ញុំព្រះករុណាទាំងឡាយ បានវិចារហើយពោលពាក្យណាទុក ពាក្យនោះឯងប្រពៃហើយក្នុងឱកាសដែលពោលដល់និមិត្តទាំង ២ ក្នុងអដ្ឋិកអសុភនេះ ឯរឿងផ្សេង ៗ មានរឿងដែលកំណាត់កាយរបស់ស្ត្រីម្នាក់ប្រាកដជារាងឆ្អឹង ដល់ព្រះមហាតិស្សត្ថេរ ព្រោះគ្រាន់តែឃើញត្រឹមតែធ្មេញជាដើមជានិទស្សនៈ ( បង្ហាញភាពផ្សេងគ្នានៃនិមិត្តទាំង ២ ) ក្នុងអដ្ឋិកកម្មដ្ឋាននេះ បានផងដែរ ។

## អវសានគាថា ក្នុងអសុភកម្មដ្ឋាន

ព្រះទសពលដ៏មានព្រះកិត្តិគុណ ដែលស្តេចទសសតលោចនៈលើក
សរសើរហើយ ទ្រង់ព្រះសុភគុណ បានត្រាស់អសុភទាំងឡាយណា
ដែលជាហេតុនៃឈាន ដោយប្រការដូច្នេះ បណ្ឌិតបានជ្រាបនូវអសុភ

ទាំងឡាយនោះ និងការនាន័យនេះ នៃអសុភទាំងឡាយនោះផង យ៉ាងនេះហើយ គួរជ្រាបបកិណ្ណកកថា ក្នុងអសុភទាំងឡាយនោះទៀត ដូចតទៅនេះ... ។

# មហាដីកា

## ពណ៌នាកម្មដ្ឋាន

## មានវិធីលកអសុភកម្មដ្ឋានជាដើម

ក្នុងកម្មដ្ឋាន មានវិធីលកអសុភកម្មដ្ឋានជាដើម ។ ពាក្យថា **លក្ខណៈដែលលោកពោលទុក** គឺ លក្ខណៈនៃការកាន់យកនិមិត្តដែលលោកពោលទុកនោះឯង ។ ពាក្យថា **តាមន័យដែលបានពោលហើយនោះឯង** គឺ តាមន័យដែលបានពោលហើយក្នុងឧទ្ធុមាតកអសុភកម្មដ្ឋាននោះឯង ។ លក្ខណៈ ឈ្មោះថា **សវិនិច្ឆយាធិប្បាយំ** ព្រោះអត្ថថា ប្រព្រឹត្តទៅព្រមជាមួយពាក្យវិនិច្ឆ័យ និងពាក្យអធិប្បាយ។ ភ្ជាប់សេចក្ដីថា **តំ សព្វំ លក្ខណំ វេទិតព្វំ** ។

ពាក្យថា ( ប្រាកដជា )**ពណ៌ផ្សេងៗ** គឺ ពណ៌ចម្រុះគ្នាដោយច្រើន ។ ពាក្យថា **ដោយអំណាចនៃពណ៌ដែលច្រើន** គឺ ក្នុងបណ្ដាពណ៌ក្រហម ពណ៌ស និង ពណ៌ខៀវ ប្រាកដដោយអំណាចពណ៌ដែលក្រាស់ ។

ពាក្យថា **ស្ងៀមឈឹង** គឺ ដល់នូវភាពនឹងថ្កល់ដោយប្រការទាំងពួង ព្រោះការដែលមិនញាប់ញ័រនោះឯង ។ ពាក្យថា **ក្នុងព្រៃចោរ** គឺ ក្នុងព្រៃដែលពួកចោរប្រជុំគ្នាលាក់ខ្លួន ។ ពាក្យថា **ក្នុងស្ថានទីដែល** ( ព្រះរាជាឲ្យប្រហារពួកចោរ ) គឺ ក្នុងស្ថានទីដែលជាផ្លូវបែកជាបួន ។ ពាក្យថា **ត្រង់ទីដែលមនុស្សត្រូវសីហៈ ឬ ខ្លាធំ**

**ខាំដាច់ខ្លួន** គឺ ត្រង់ស្ថានទីដែលមនុស្សត្រូវសីហៈជាដើម ខាំដាច់ខ្លួន ។ ពាក្យថា ដែលធ្លាក់ទៅកាន់ទិសផ្សេងៗ គឺ សរីរៈដែលដាច់ជា ២ កំណាត់ រត់រាយទៅកាន់ទិសទាំងឡាយនីមួយ ៗ ។ ពាក្យថា **ដោយអាវុធនៈដូចគ្នា** គឺ ដោយការបង្អោនមកក្នុងខណៈជាមួយគ្នា ។ ពាក្យថា **មកកាន់គន្លង** គឺ មកកាន់គន្លង (ទ្វារ) ព្រមគ្នា ។

ពាក្យថា **នឹងមានភាពស្និទ្ធស្នាល** គឺ នឹងគប្បីចូលដល់ភាពជាវត្ថុមិនគួររង្កៀស ដូចអ្នកជុតខ្មោចដូច្នោះ ។ សេចក្ដីរង្កៀសរមែងមានបាន ក៏ព្រោះការមិនប៉ះពាល់ដោយដៃរបស់ខ្លួននោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា គួរប្រើឈើចង្កៀស ឬ ឈើច្រត់ផ្ទៀសប្រមូល ។ ការធ្វើឲ្យមានចន្លោះឃ្លាតពីគ្នា ១ អង្គុលី ក៏ដើម្បីធ្វើឲ្យវិច្ឆិទ្ទកអសុភប្រាកដ ។ បទថា **ឧបនាមេតព្វំ** ប្រែថា គួរផ្ទៀសប្រមូល ។ ពាក្យថា **ដូចសរីរៈដែលត្រូវខាំស៊ីនោះឯង** គឺ ដូចជាអសុភដែលត្រូវខាំស៊ីនោះឯង ។ ពាក្យថា **ឲ្យមានចន្លោះ ឲ្យឃ្លាតពីគ្នានីមួយៗ ១ អង្គុលី** គឺ ឲ្យចំណែកនៃសរីរៈដែលបោះចោល មានប្រការផ្សេងៗ មានចន្លោះឃ្លាតពីគ្នា ពីមួយទៅមួយ ១ អង្គុលី ។ បទថា **កត្វា វា** បានដល់ ប្រើឈើចង្កៀស ឬ ឈើច្រត់ដោយខ្លួនឯង ។ បទថា **លទ្ធប្បហារំ** ភ្ជាប់សេចក្ដីថា **លទ្ធាវុធប្បហារំ មុខតោ** ប្រែថា មុខដំបៅនៃសរីរៈដែលបានទទួលការប្រហារដោយអាវុធ ។ បទថា **មុខតោ** ប្រែថា មុខដំបៅនៃសរីរៈដែលបានទទួលការប្រហារជាដើម ។ ពាក្យថា **លោហិតហូរចេញមក** ប្រកបសេចក្ដីថា លោហិតកអសុភ រមែងមានក្នុងវេលាដែលលោហិតហូរចេញមក ។

បទថា **តំ** បានដល់ បុឡុវកអសុភនោះ ។ បទថា **តេសុ** បានដល់ ក្នុងសរីរៈរបស់ឆ្កែស្រុកជាដើមទាំងនោះ ។ បទថា **អដ្ឋិកំ** ភ្ជាប់សេចក្ដីថា អដ្ឋិកអសុភ

ទ្រង់ត្រាស់ទុកដោយប្រការផ្សេងៗ ។ ពាក្យថា **តាមន័យមុននោះឯង** គឺតាមន័យដែលបានពោលហើយ ក្នុងឧទ្ធុមាតកអសុភខាងដើមនោះឯង ។

បទថា **តំ** បានដល់ អដ្ឋិកអសុភ ។ ពាក្យថា **នឹងមិនប្រាកដ** គឺ នឹងមិនជាសភាវៈ មានន័យថា មិនប្រាកដដោយភាពជាបដិកូល ។ ព្រោះហេតុនោះ ទើបលោកពោលថា នឹងមានការលាយឡំជាមួយឱទាតកសិណ ។ ព្រះយោគាវចរមិនអាចកំណត់ភេទ មានបឋមវ័យជាដើម ក្នុងដុំឆ្អឹងបាន ព្រោះហេតុនោះ ទើបលោកពោលថា ពាក្យថា **ភេទ** ក្នុងអដ្ឋិកអសុភនេះ ជាឈ្មោះនៃអវយវៈ មានដៃជាដើមៗ តែបើឆ្អឹងទាំងមូល អាចកំណត់ដោយអំណាចនៃអវយវៈ ចំណែកឆ្អឹងតូច ៗ ដែលរួមគ្នាជាសរីរៈ យ៉ាងនេះថា នេះជាឆ្អឹងក្មេង នេះជាឆ្អឹងមនុស្សតាំងនៅក្នុងវ័យកំលោះក្រមុំ នេះជាឆ្អឹងរបស់អ្នកដែលដល់នូវភាពចំណាស់ ដោយអវយវៈទាំងឡាយ ដូច្នេះបានសោត គប្បីជ្រាបថា ជាការកាន់យក ( ដោយភេទ គឺ វ័យ ) មិនបាន ព្រោះវាមិនតជាប់គ្នាបានយូរ ។ ព្រះយោគាវចរ រមែងបាននូវការកំណត់ដោយទី-ត ក្នុងសរីរៈឆ្អឹង ក៏ពិត តែមិនបានក្នុងកំណាត់ឆ្អឹង ( តែ ១ កំណាត់ ) ព្រោះហេតុនោះ លោកអាចារ្យបំណង សម្តែងនូវអដ្ឋិកអសុភនោះ ជារបស់មិនពិតប្រាកដ ( ទាក់ទងដោយការកំណត់ទី-ត ) ទើបធ្វើការឆ្លាស់លំដាប់គ្នា ពោលថា “ ចំណែកដោយទីផតនិងទីប៉ោង គប្បីកំណត់តាមទំនងនៃកំណាត់ឆ្អឹងនោះ ៗ មានចំណែកដែលផតនិងចំណែកដែលប៉ោងចុះ ” ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ចំណែកដែលផត** គឺ ផ្នែកដែលក្រហូងនៃឆ្អឹង ។ ឈ្មោះថា **ចំណែកទីប៉ោង** បានដល់បរិវេណដែលពក ។ ពាក្យថា **ដែលទាក់ទងនឹងទី-ត ដែលឆ្អឹង ២ កំណាត់តគ្នា** គឺ ទាក់ទងនឹងទីដែលរាងឆ្អឹងនៅមិនទាន់ប្រាសចាកសរសៃចងរឹត និងឆ្អឹងដទៃៗ នៅ

ជាប់គ្នានិងគ្នា ។ ពាក្យថា **ទាក់ទងនឹងទីចន្លោះ** គឺទាក់ទងនឹងចន្លោះឆ្អឹងពី ១ កំណាត់ទៅ ១ កំណាត់ និងទាក់ទងនឹងទីដែលជាប្រហោង ។ ពាក្យថា ( **គប្បីធ្វើញាណឲ្យត្រាច់ទៅ** ) **ក្នុងឆ្អឹងទាំងអស់នោះឯង** គឺ ក្នុងរាងឆ្អឹងទាំងមូល ឬ ក្នុងកំណាត់ឆ្អឹងគ្រប់កំណាត់ ។ បទថា **ឯត្ថ** ប្រែថា ក្នុងអដ្ឋិកអសុភនោះ ។ ពាក្យថា **គប្បីសង្កេត ទាក់ទងដោយការកាន់យកក្នុងអវយវៈត្រង់ចំណែកដែលសមគួរ** មានន័យថា ការកាន់យកនិមិត្តណារមែងសមគួរក្នុងអវយវៈចំណែកណា ក៏គប្បីសង្កេតការកាន់យកនិមិត្តនោះ ដោយទាក់ទងនឹងការកាន់យកនិមិត្ត ដើម្បីនឹងរៀនយកក្នុងអវយវៈចំណែកនោះ ។ ពាក្យថា ( **រមែងសម្រេចក្នុងរាងឆ្អឹង** ) **ទាំងមូល** គឺ ដែលមិនមានចំណែកសល់ បានដល់ មានអវយវៈគ្រប់ ។ ឈ្មោះថា **រមែងសម្រេច** ក៏ទាក់ទងដោយការប្រាកដនៃនិមិត្ត ។ ពាក្យថា **ក្នុងឆ្អឹងទាំងនោះ** គឺក្នុងគ្រោងឆ្អឹង និងកំណាត់ឆ្អឹង ។ ឈ្មោះថា ពាក្យដែលលោកពោលក្នុងអដ្ឋកថា ។ ពាក្យថា **ពាក្យនោះ** គឺ ពាក្យថា ដូចគ្នាតែមួយ ។ ពាក្យថា **ប្រើបានក្នុងឆ្អឹង ១ កំណាត់** នេះលោកពោលទុក ព្រោះបានធ្វើទុកក្នុងចិត្តថា និមិត្តទាំង ២ ក្នុងវិនីលកអសុភជាដើមរមែងបានភាពផ្សេងគ្នា ដោយពណ៌ដែលផ្សេងគ្នា ដោយជាសរីរៈពេញលេញ និងជាសរីរៈមិនពេញលេញ , ដោយជាសរីរៈដែលមានចន្លោះឃ្លាតពីគ្នា និងជាសរីរៈដែលមានចន្លោះមិនឃ្លាតពីគ្នា , ដោយជាសរីរៈដែលញាប់ញ័រ និង ជាសរីរៈមិនញាប់ញ័រ តាមសមគួរយ៉ាងណា ក្នុងអដ្ឋិកអសុភ ១ កំណាត់នេះ រមែងមានការផ្សេងគ្នា ក៏ទេដែរ តែថា មិនមានការផ្សេងគ្នា ព្រោះមិនផ្សេងគ្នាដោយប្រការទាំងពួង ព្រោះហេតុនោះឯង ទើបលោកពោលថា ម្យ៉ាងវិញទៀត សូម្បីឆ្អឹង ១ កំណាត់ ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **គួររង្កៀស** គឺ គួរខ្ពើមដោយ

ភាពជាធ្មេញនោះឯង ព្រោះជារូបធ្មេញសុទ្ធសាធ ។ ពាក្យថា **គួរខ្លាច** គឺ ព្រោះហេតុនោះឯង ទើបជាហេតុនាំមកនូវការភ័យខ្លាចដល់សត្វទាំងឡាយតាមប្រក្រតី ។ ពាក្យថា **ដែលឲ្យកើតបីតិសោមនស្សបាន** គឺ ដែលធ្វើបីតិ និងសោមនស្សឲ្យកើតឡើងបាន ព្រោះប្រាកដដោយភាពជានិមិត្តដែលល្អិតល្អន់ និង ដែលរៀបរយ និង ព្រោះភាវនាមានភាពវិសេស ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រោះជាហេតុនាំមកនូវឧបចារៈ ។

ពាក្យថា **ក្នុងឱកាសនេះ** គឺ ក្នុងឋានៈដែលពោលដល់ ឧគ្គហនិមិត្ត និង បដិភាគនិមិត្ត ។ ពាក្យថា **ឲ្យប្រហោង(ចន្លោះ)ទុកហើយ** គឺ លោកមិនឈប់ត្រឹមតែពាក្យថា “ ឈ្មោះថា និមិត្ត រមែងមាន កាលបានឃើញដោយភាពជាបដិកូលហើយនោះឯង ” ដូច្នេះ ត្រឹមនេះប៉ុណ្ណោះ នៅពោលឲ្យប្រហោងសម្រាប់ការញែកនិមិត្តតាមដែលពោលហើយ តទៅទៀត ដោយការពោលចែក ឧគ្គហនិមិត្ត និង បដិភាគនិមិត្តទុកថា “ និមិត្តក្នុងអសុភនេះ មាន ២ យ៉ាង ” ដូច្នេះជាដើម ។ ពាក្យថា **មិនមានវិកប្ប** គឺ អស់គោលកំណត់ដោយការកំណត់ថា ស្អាត មានន័យថា មិនស្អាតនោះឯង ។ ពាក្យថា **យើងបានវិចារ** គឺ យើងបានពិចារណាទុកដោយពាក្យថា “ ពាក្យនោះប្រើបានក្នុងធ្មេញមួយកំណាត់ ” ដូច្នេះជាដើម ។

ពាក្យថា **ព្រះមហាតិស្សត្ថេរ** បានដល់ ព្រះមហាតិស្សត្ថេរដែលអាស្រ័យនៅក្នុងចេតិយបព៌តវិហារ ។ ពាក្យថា **ជានិទស្សនៈ** មានន័យថា រឿងដែលសរីរៈរបស់ស្ត្រីនោះទាំងមូល មានការប្រាកដជាគ្រោងធ្មេញសុទ្ធ ដោយការឃើញត្រឹមតែធ្មេញធ្មេញជាដើម ជាឧទាហរណ៍ដែលបង្ហាញដល់ភាពផ្សេងគ្នានៃឧគ្គហនិមិត្ត និង បដិភាគនិមិត្ត ក្នុងអដ្ឋិកកម្មដ្ឋាននេះ ។ ពាក្យថា **ដ៏មានព្រះកិត្តិគុណ** គឺ ដែលមាន

ព្រះគុណដ៏បរិសុទ្ធ ព្រោះទ្រង់លះបង់កិលេសទាំងឡាយ ព្រមទាំងវាសនាបាន ហើយ ។ បទថា **ទសសតលោចនេន** ប្រែថា ទេវសហស្សនេត្រ បានដល់ ព្រះឥន្ទដែលធំជាងទេវតា ។ ពិតណាស់ ព្រះឥន្ទដែលជាចមទេពនោះ ហៅថា ទេវសហស្សនេត្រ ព្រោះដល់ព្រមដោយចក្ខុ គឺ បញ្ញាដែលអាចពិចារណាអត្ថទាំងពាន់ ដោយការអង្គុយត្រឹមតែ ១ ភ្លែត ប៉ុណ្ណោះ ។ ពាក្យថា **មានព្រះកិត្តិគុណដែលព្រះសហស្សនេត្រទ្រង់សរសើរ** គឺ មានព្រះកិត្តិស័ព្ទដែលស្តេចសហស្សនេត្រសរសើរក្រៃលែងហើយ ដោយពាក្យថា “ **យោ ធីរោ សព្វធិ ទន្តោ** ” ព្រះដ៏មានព្រះភាគអង្គណា ដែលទ្រង់ជាអ្នកប្រាជ្ញ ទូន្មានហើយក្នុងធម៌ទាំងពួងជាដើម ។

( ចប់ មហាដីកា )

# បកិណ្ណកកថា

ពិតណាស់ ព្រះយោគាវចរដែលបានសម្រេចឈាន ក្នុងអសុភកម្មដ្ឋានទាំងនោះ ណាមួយ ក៏ជាអ្នកមិនមានការប្រព្រឹត្តល្មោភ មើលទៅដូចជាអ្នកប្រាសចាករាគៈ ព្រោះរាគៈត្រូវគ្របសង្កត់ទុកដោយប្រពៃហើយ សូម្បីដូច្នោះ ប្រភេទអសុភដែលពោលទុកនេះ ក៏គប្បីជ្រាបថា លោកពោលទុកតាមការដល់នូវភាព ( ប្រាកដ ) នៃសាកសព ១ តាមការផ្សេងគ្នានៃបុគ្គលរាគចរិត ១ ។ ព្រោះថា សាកសពកាលដល់នូវភាពជាបដិកូល ត្រូវជាសាកសពដែលដល់នូវសភាពជា ឧទ្ធុមាតកអសុភខ្លះ ដល់នូវសភាពនៃអសុភដ៏សេស មានវិនីលកអសុភជាដើម យ៉ាងណាមួយខ្លះ ព្រោះហេតុនោះ ព្រះយោគាវចរ អាចរកអសុភប្រភេទណាៗបាន ក៏ត្រូវកាន់យកនិមិត្តក្នុងអសុភប្រភេទនោះ ៗ ដោយមនសិការថា **ឧទ្ធុមាតកំ បដិកូលំ , វិនីលកំ បដិកូលំ** ដូច្នេះជាដើមនោះឯង ។ ប្រភេទនៃអសុភគប្បីជ្រាបថា លោកពោលទុកជា ១០ ប្រភេទ ការដល់សភាពជាសាកសព ដូច្នេះឯង , រីឯការពោលដោយភាពផ្សេងគ្នា ក្នុងអសុភទាំងនេះ គប្បីជ្រាបថា លោកពោលប្រភេទនៃអសុភទុកដល់ទៅ ១០ ប្រភេទ តាមការផ្សេងគ្នានៃបុគ្គលរាគចរិត ដោយន័យម្យ៉ាងទៀតដូច្នេះ គឺ ៖

| | |
|---|---|
| ១. ឧទ្ធុមាតកអសុភ | ជាសប្បាយនៃបុគ្គលច្រើនដោយតម្រេក ក្នុងទ្រង់ទ្រាយសណ្ឋាន ព្រោះប្រាកដនូវការខូចទ្រង់ទ្រាយ នៃរាងកាយ ។ |
| ២. វិនីលកអសុភ | ជាសប្បាយនៃបុគ្គលដែលច្រើនដោយតម្រេកក្នុងសម្បុរ |

កាយ ព្រោះប្រាកដនូវការខូចពណ៌នៃស្បែក ។

៣. វិបុព្វកអសុភ — ជាសប្បាយនៃបុគ្គលដែលច្រើនដោយតម្រេក ក្នុងក្លិនកាយ ដែលតាំងឡើងដោយអំណាចគ្រឿងអប់ក្លិន មានផ្កាកម្រង និងគ្រឿងក្រអូបជាដើម ព្រោះប្រាកដនូវភាពជាវត្ថុដែលជាប់ទាក់ទងដោយកាយ និង ពណ៌សម្បុរស្បែក ដែលមានក្លិនស្អុយ ។

៤. វិច្ឆិទ្ទកអសុភ — ជាសប្បាយនៃបុគ្គលដែលច្រើនដោយតម្រេក ក្នុងភាពមាំមួននៃរាងកាយ ព្រោះប្រាកដនូវភាពប្រហោង ខាងក្នុង ។

៥. វិក្ខាយិតកអសុភ — ជាសប្បាយនៃបុគ្គលដែលច្រើនដោយតម្រេក ក្នុងសាច់ដុំ ក្នុងទីតាំងនៃសរីរៈផ្សេង ៗ មានដោះជាដើម ព្រោះប្រាកដនូវភាពសាបសូន្យនៃសម្បត្តិសាច់ដុំ ។

៦. វិក្ខិត្តកអសុភ — ជាសប្បាយនៃបុគ្គលដែលច្រើនដោយតម្រេក ក្នុងការលីលា ( ដំណើរល្អតល្មៃ ) នៃអង្គអវយវៈតូចធំ ព្រោះប្រាកដឲ្យឃើញនូវភាពខ្ចាត់ខ្ចាយនៃអង្គាវយវៈតូចធំ ។

៧. ហតវិក្ខិត្តកអសុភ — ជាសប្បាយនៃបុគ្គលដែលច្រើនដោយតម្រេក ក្នុងសម្បត្តិនៃរូបរាង ព្រោះប្រកាសនូវភាពខុសប្រក្រតីដោយរូបរាងដាច់ចេញពីគ្នា ។

៨. លោហិតកអសុភ — ជាសប្បាយនៃបុគ្គលដែលច្រើនទៅដោយតម្រេក ក្នុងភាពស្អាតនៃគ្រឿងប្រដាប់ ព្រោះប្រកាសនូវភាពជារូប

| | |
|---|---|
| | បដិកូលដោយមានលោហិតប្រឡាក់ ។ |
| ៩. បុឡុវកអសុភ | ជាសប្បាយនៃបុគ្គលដែលច្រើនដោយតម្រេក ក្នុងកាយ ដោយការសម្គាល់ថា របស់យើង ព្រោះប្រាកដភាពជាកាយ ដែលជាសាធារណៈដល់ពពួកដង្កូវច្រើនប្រភេទ ។ |
| ១០. អដ្ឋិកអសុភ | ជាសប្បាយនៃបុគ្គលដែលច្រើនទៅដោយតម្រេក ក្នុងសម្បត្តិនៃធ្មេញ ព្រោះប្រាកដនូវភាពដែលឆ្អឹងក្នុងសរីរៈទាំងឡាយ ជារបស់បដិកូល ។ |

## អសុភ សម្រេចឈាន ចានត្រឹមបឋមជ្ឈាន

ម្យ៉ាងវិញទៀត ព្រោះហេតុថា ក្នុងអសុភទាំង ១០ យ៉ាងនោះ ចិត្តតាំងមាំបាន ក៏ដោយកម្លាំងនៃវិតក្កៈប៉ុណ្ណោះ វៀរវិតក្កៈចេញ អាចតាំងមាំបានមិនមាន ព្រោះអារម្មណ៍មានកម្លាំងទុព្វល ប្រៀបដូចក្នុងស្ទឹងដែលទឹកមិនស្ងៀមនឹង មានក្រសែហូរ ទូក កាលឈប់នៅស្ងៀមបានក៏ដោយកម្លាំងច្នៅលប៉ុណ្ណោះ វៀរច្នៅលចេញហើយ អាចឈប់នៅស្ងៀមបានមិនមាន ដូច្នោះ ព្រោះហេតុនោះ ក្នុងអសុភកម្មដ្ឋាននេះ ទើបមានត្រឹមបឋមជ្ឈានប៉ុណ្ណោះ ឈានក្រៅពីនេះ មានទុតិយជ្ឈានជាដើម មិនមាន ។ ម្យ៉ាងវិញទៀត ព្រោះក្នុងអារម្មណ៍នោះ សូម្បីជាបដិកូល បីតិសោមនស្ស ក៏កើតឡើងបាន ព្រះយោគាវចរឃើញអានិសង្សយ៉ាងនេះថា " យើងផុតចាក ជរា មរណៈ បានដោយបដិបទានេះ ដោយពិត " និងព្រោះលះនូវគ្រឿងក្តៅ គឺ នីវរណៈចេញបាន ដូចក្នុងគំនរលាមក បីតិសោមនស្សក៏កើតឡើងបាន ដល់

អ្នកស៊ីឈ្នួលចាក់សំរាម ដោយឃើញអានិសង្សថា “ យើងនឹងបានថ្លៃឈ្នួលច្រើនជាប្រាកដ ” និងព្រោះដូចជា កម្ពុត ឬការបន្ទោបង់ចេញមក បីតិសោមនស្សអាចកើតឡើងបានដល់អ្នកដែលឈឺធ្ងន់ ដូច្នោះ ។

## អសុភ ១០ មានលក្ខណៈ ១

ម្យ៉ាងទៀត អសុភទាំង ១០ យ៉ាងនោះ បើពោលដោយលក្ខណៈ ក៏មានតែមួយប៉ុណ្ណោះ , មែនពិត ភាពជាបដិកូល គឺ មិនស្អាត ស្អុយ និង គួរខ្ពើមប៉ុណ្ណោះជាលក្ខណៈរបស់អសុភទាំង ១០ យ៉ាងនោះ អសុភនេះនោះ មិនមែនប្រាកដដោយលក្ខណៈនេះ ចំពោះសរីរៈរបស់មនុស្សស្លាប់តែម្យ៉ាងនោះទេ តែរមែងប្រាកដសូម្បីក្នុងសរីរៈរបស់មនុស្សរស់ ដូចដែលប្រាកដដល់ព្រះមហាតិស្សត្ថេរ ដែលគង់នៅឯចេតិយបព៌តវិហារ ដែលបានឃើញធ្មេញ ( របស់ស្ត្រីម្នាក់ ) និងដូចដែលប្រាកដដល់សាមណេរជាឧបដ្ឋាករបស់ព្រះសង្ឃរក្ខិតត្ថេរ ដែលបានក្រឡេកមើលព្រះរាជាដែលប្រថាប់នៅលើ-កដំរី , ដោយសរីរៈរបស់អ្នកស្លាប់ជាអសុភយ៉ាងណា សូម្បីសរីរៈរបស់មនុស្សរស់ក៏ជាអសុភដូច្នោះដូចគ្នា ប៉ុន្តែលក្ខណៈរបស់អសុភក្នុងសរីរៈរបស់មនុស្សរស់នោះមិនប្រាកដ ព្រោះគ្រឿងតុបតែងកាយដែលជាអាគន្តុកៈ បិទបាំងទុកជាប្រក្រតីហើយ ដែលសរីរៈនេះមានឆ្អឹង ៣០០ កំណាត់ តៗ ជាគ្រោងឆ្អឹង ទល់ជាប់គ្នាដោយអំណាចតំណ ១៨០ កន្លែង ចងរឹតដោយសរសៃ ៩០០ សរសៃ បូកលាបដោយសាច់ ៩០០ ដុំ ហុំដោយស្បែក និងបិទបាំងដោយស្បែកសម្បុរថ្លៃ ដែលមានរន្ធតូចៗ មានខ្លាញ់ជ្រាបចេញទាំងខាងលើនិងខាងក្រោម ដូចថង់ខ្លាញ់ខាប់ ជាទីអាស្រ័យរបស់ពពួកដង្កូវ ជាអណ្តូងកើតនៃរោគទាំងឡាយ ជា

ឬសគល់នៃទុក្ខធម៌ទាំងឡាយ ជាទីហូរចេញរឿយ ៗ នូវរបស់មិនស្អាត តាមមុខ ដំបៅទាំង ៩ ដូចឫសដែលបែកហើយ ជាសរីរៈដែលមានអាចម៍ភ្នែកចេញតាមភ្នែកទាំង ២ មានអាចម៍ត្រចៀកចេញតាមរន្ធត្រចៀក អាចម៍ច្រមុះចេញតាមរន្ធច្រមុះ អាហារ ( ក៏ ) ទឹកប្រមាត់ ស្លេស្ម ឈាម ចេញតាមមាត់ ឧច្ចារបស្សាវៈចេញតាមទ្វារក្រោម តំណក់ញើសដែលមិនស្អាតចេញតាមរណ្ដៅរោម ៩៩.០០០ រណ្ដៅ សត្វល្អិតទាំងឡាយ មានរុយក្បាលខៀវជាដើមចោមរោម បុគ្គលមិនប្រណិបត្តិសរីរៈ ដោយសរីរៈកិច្ច មានដុសធ្មេញ ខ្ពុរមាត់ កក់ក្បាល ងូតទឹក ស្លៀកដណ្ដប់ សំពត់ជាដើម ជាបុគ្គលតាមកំណើត មានសក់ស៊ើងទ្រើង ត្រាច់ទៅតាមភូមិស្រុក ជាព្រះរាជាក្ដី ជាមនុស្សថ្នាក់ទាបក្ដី មានអ្នកស៊ីឈ្នួលកើបសំរាម និង មនុស្សចណ្ឌាលជាដើម មិនមាននរណាមួយប្លែកគ្នាឡើយ ព្រោះភាពដែលមានសរីរៈបដិកូលស្មើគ្នា ឈ្មោះថា ភាពផ្សេងគ្នាក្នុងសរីរៈរបស់ព្រះរាជាក៏ដោយ របស់ចណ្ឌាលក៏ដោយ មិនមាន ព្រោះសរីរៈជារបស់បដិកូល គឺ មិនស្អាត ស្អុយ និងគួរខ្ពើម ដូច្នេះ ។ ប៉ុន្តែបុគ្គលទាំងឡាយសម្អាតមន្ទិលទាំងឡាយ មានមន្ទិលនៃធ្មេញជាដើម ក្នុងសរីរៈនេះ ដោយកិច្ច មានដុសធ្មេញ ខ្ពុរមាត់ជាដើម , បិទបាំងអវយវៈដែលនាំឲ្យមានសេចក្ដីអៀនខ្មាស ដោយសំពត់ពណ៌ផ្សេង ៗ លាបលនដោយគ្រឿងក្រអូប ប្រដាប់តាក់តែងដោយគ្រឿងប្រដាប់ មានផ្កាកម្រង និងគ្រឿងអាភរណៈជាដើម ធ្វើឲ្យមានអាការល្មមកាន់យកបាន ថាខ្ញុំ ថារបស់ខ្ញុំ បន្ទាប់អំពីនោះទៅ គេទាំងឡាយក៏ចាំលក្ខណៈអសុភដែលជាសភាពពិតយ៉ាងណា របស់វានោះមិនបាន ព្រោះវាត្រូវបិទបាំងដោយគ្រឿងអលង្ការដែលជាអាគន្តុកៈនេះ ពពួកបុរស ទើបធ្វើការត្រេកត្រអាលក្នុងស្ត្រីទាំងឡាយ ពួកស្ត្រីទើបធ្វើការត្រេកត្រអាល

ក្នុងបុរសទាំងឡាយ តែដោយបរមត្ថហើយ ឈ្មោះថា កន្លែងដែលគួរដល់សេចក្តីប្រាថ្នាក្នុងសរីរៈនេះ សូម្បីបន្តិចក៏មិនមាន ពិតហើយ សត្វទាំងឡាយរមែង មិនប្រាថ្នាសូម្បីតែនឹងពាល់ត្រូវដោយដៃ រមែងខ្ពើមឆ្អើម ស្អប់ខ្ពើមដល់កោដ្ឋាស ក្នុងបណ្តាកោដ្ឋាសទាំងឡាយ មាន សក់ រោម ក្រចក ធ្មេញ និង ទឹកមាត់ ទឹក-សំបោរ ឧច្ចារបស្សាវៈជាដើម នូវកោដ្ឋាសណាមួយ ដែលជ្រុះចាកកាយហើយ តែកោដ្ឋាសណាៗ ដ៏សេសដែលនៅជាប់កាយនោះ គេទាំងឡាយត្រូវសេចក្តីងងឹត គឺ អវិជ្ជាបិទបាំងហើយ ត្រូវគ្រឿងលាបចិត្ត ពោលគឺ សេចក្តីស្រឡាញ់លាបលនហើយ ក៏កាន់យកនូវកោដ្ឋាសនោះ សូម្បីជារបស់បដិកូល យ៉ាងនេះថា ជារបស់គួរប្រាថ្នា គួរស្រឡាញ់ ជារបស់ទៀង ជាសុខ ជាតួខ្លួន គេទាំងឡាយកាន់យកយ៉ាងនោះ ក៏រាប់បានថា ដល់នូវភាពស្មើគ្នានឹងចចកចាស់ដែលឃើញដើមចាក្នុងព្រៃហើយអន្ទះសាចិត្ត ដោយសម្គាល់ផ្កាចា ដែលមិនទាន់ជ្រុះអំពីដើម ថា នោះដុំសាច់ នោះដុំសាច់ នោះឯង ព្រោះហេតុនោះ ៖

អ្នកប្រាជ្ញមិនគប្បីកាន់យកកោដ្ឋាស ដែលដាច់( ចាកកាយ )ប៉ុណ្ណោះ នោះថាជាអសុភ ដូចសត្វឆ្កែចចកឃើញផ្កាចារីកក្នុងព្រៃ សម្គាល់ថាខ្លួនបានដុំសាច់ ហើយប្រញាប់ចូលទៅប្រមូលយកនូវផ្កាដែលជ្រុះៗ ទោះដឹងថា នេះមិនមែនជាដុំសាច់ ក៏នៅប្រកាន់ថា ដែលនៅលើដើមឈើនោះជាដុំសាច់ ដូច្នោះហើយ គប្បីសម្គាល់នូវកោដ្ឋាសសូម្បីនៅជាប់នឹងសរីរៈថា ជាអសុភដូចគ្នាចុះ ព្រោះបុគ្គលល្ងង់ទាំងឡាយប្រកាន់រាងកាយនេះថា ជារបស់ស្អាត ហើយលិចចុះនៅក្នុងរាងកាយនោះ រវល់ធ្វើនូវបាប រមែងមិនរួចផុតចាកទុក្ខបានឡើយ ព្រោះហេតុនោះ អ្នកមានបញ្ញា គប្បីឃើញនូវសភាពនៃកាយស្អុយ ដែលនៅរស់ ឬ ស្លាប់ហើយក៏ដោយ ថា ជារបស់

ប្រាសចាកនូវភាពស្អាតចុះ ។

ពិតហើយ ព្រះបោរាណាចារ្យបានពោលពាក្យនេះទុកថា ៖

កាយនេះមិនស្អាត មានក្លិនស្អុយ ប្រៀបដូចជាសាកសព ប្រៀបដូចរណ្តៅលាមក ជាកាយដែលអ្នកមាន( បញ្ញា )ចក្ខុទាំងឡាយតិះដៀលហើយ ឯបុគ្គលល្ងង់ខ្លៅសរសើរ កាយនេះគ្របដណ្តប់ដោយស្បែក មានវន្ធ ៩ ស្មោកគ្រោក មានក្លិនស្អុយហូរចេញមកក្រៅ បើខាងក្នុងនៃកាយនេះ( ត្រឡប់ )ជាខាងក្រៅសោត បុគ្គលប្រាកដជាកាន់ដំបងចាំការពារក្អែក និង ឆ្កែ ដោយពិត ។

ព្រោះហេតុនោះ ភិក្ខុដែលជាទព្វជាតិ ( មានជាតិប្រកបដោយបញ្ញា ) សរីរៈនៅរស់ ឬ ស្លាប់ហើយ ក៏ដោយ អាការនៃអសុភប្រាកដក្នុងសរីរៈណា ៗ គប្បីកាន់យកនិមិត្តក្នុងសរីរៈនោះៗ ធ្វើកម្មដ្ឋានឲ្យដល់អប្បនាចុះ ។

## មហាដីកា
## ពណ៌នា បកិណ្ណកកថា

លោកអាចារ្យសំដៅយកការៈដែលលះបង់បានដោយធម៌ ដែលជាបដិបក្ខដោយត្រង់ ទើបពោលថា ព្រោះការដែលលោកគ្របសង្កត់នូវកាមរាគៈបានដោយល្អ ។ ពាក្យថា **ប្រភេទនៃអសុភ** គឺ ការបែកអសុភ មានឧទ្ធុមាតកអសុភជាដើម ។ ពាក្យថា **ទាក់ទងនឹងរាងកាយ** គឺ ទាក់ទងនឹងសរីរៈដែលចូលដល់នូវសភាពរបស់ខ្មូន ។ ពិតណាស់ រាងកាយកាលនឹងវិនាស រមែងវិនាសទៅដោយទាក់ទងនឹងការដល់ភាពជា( សរីរៈហើមប៉ោង ) នោះឯង ដូចរាងកាយនៃអារក្សទឹកដែលស្ថិតនៅក្នុង

រូបសត្វដទៃ ។ ពាក្យថា **ទាក់ទងនឹងភាពផ្សេងគ្នានៃបុគ្គលរាគចរិត គឺ** ទាក់ទងនឹងការចែកបុគ្គលរាគចរិត ។ ប្រសិនបើប្រភេទនៃអសុភនេះ ទ្រង់ត្រាស់ទុកថា ទាក់-ទងនឹងការដល់សភាពនៃរាងកាយសោត ប្រភេទនៃអសុភ ៩ យ៉ាង ក្នុងមហាសតិប្បដ្ឋានសូត្រជាដើម ទ្រង់ត្រាស់ទុកដូចម្តេចទៅវិញ ? ឆ្លើយថា នេះជាប្រការផ្សេងគ្នា ដែលប្រាកដ គឺ ប្រភេទនៃអសុភ ៩ យ៉ាងនោះ ទ្រង់ត្រាស់ទាក់ទងនឹងការដល់សភាវៈតាមកិច្ចរបស់ខ្លួនតែម្យ៉ាង ។ ចំណែកប្រភេទនៃអសុភ ១០ យ៉ាងនេះ ទ្រង់ត្រាស់ទុក ទាក់ទងនឹងការដល់សភាព ព្រោះសេចក្តីព្យាយាមរបស់អ្នកដទៃ ។ ម្យ៉ាងវិញទៀត ក្នុងបណ្តាអសុភ ១០ ដែលមកហើយក្នុងទីនេះ អសុភខ្លះប៉ុណ្ណោះ ដែលទ្រង់កាន់យកក្នុងមហាសតិប្បដ្ឋានសូត្រជាដើមនោះ ហើយអដ្ឋិកអសុភ ក៏ទ្រង់ចែកទុកជា ៥ យ៉ាង ។ ម្យ៉ាងវិញទៀត អសុភ ៩ ទាំងនោះ ទ្រង់ត្រាស់ទុកដោយអំណាចនៃវិបស្សនា ចំណែកអសុភទាំង ១០ នេះ ទ្រង់ត្រាស់ទុកដោយអំណាចនៃសមថៈ ។

កាលអសុភទាំង ១០ នេះ សូម្បីមានភាពជាសប្បាយដល់ បុគ្គលរាគចរិតទាំងឡាយ ដោយមិនផ្សេងគ្នា ព្រោះភាពជាអសុភដូចគ្នា លោកអាចារ្យក៏នៅមានបំណងសម្តែងចែកពាក្យដែលពោលទុកថា នឹងទាក់ទងជាមួយភាពផ្សេងគ្នានៃបុគ្គលរាគចរិត ទើបពោលពាក្យថា **ដោយផ្សេងគ្នា** ដូច្នេះជាដើម ។ លោកអាចារ្យសម្តែងសេចក្តីវិបត្តិនៃទ្រង់ទ្រាយ ជាខាងក្រោយដែលហើមប៉ោងថា រាងកាយសូម្បីនៅទ្រង់ទ្រាយល្អ ក៏ជាការមិនល្អ ព្រោះភាវៈដែលហើមប៉ោងនោះឯង ព្រោះហេតុនោះ ទើបលោកពោលថា ព្រោះប្រកាសភាពវិបត្តិនៃទ្រង់ទ្រាយរបស់រាងកាយ ។ បុគ្គលដែលត្រេកត្រអាលក្នុងការដល់ព្រមនៃទ្រង់ទ្រាយ ឈ្មោះថា **សណ្ឋានរាគី** ។

ឈ្មោះថា **ជាសប្បាយ** សម្រាប់បុគ្គលដែលមានតម្រេកក្នុងទ្រព្យទ្រាយ ព្រោះភាពជាឧបាយ គ្របសង្កត់ការត្រេកត្រអាលក្នុងទ្រព្យទ្រាយ ។ កាយនោះឯង ឈ្មោះថា **កាយវណ្ណ** បានដល់ ជាវត្ថុដែលទំនាក់ទំនងគ្នា គឺ ដែលអាស្រ័យក្នុងកាយនោះ ។ ពាក្យថា **ព្រោះប្រកាសដល់ភាពប្រហោង** ព្រោះប្រកាសដល់ភាពដែលជាព្រង់ គឺ ប្រហោងទទេ មានហើយ ។ ពាក្យថា **សម្រាប់បុគ្គលដែលច្រើនដោយតម្រេកក្នុងភាពមាំមួននៃរាងកាយ** គឺ សម្រាប់បុគ្គលដែលមានសេចក្ដីត្រេកអរដែលអាស្រ័យភាពរឹងប៉ឹងនៃអវយវៈតូចធំក្នុងរាងកាយកើតឡើង ។ ពាក្យថា **ព្រោះប្រាកដភាពខ្ចត់ខ្ចាយ** គឺ ព្រោះប្រាកដភាពខ្ចត់ខ្ចាយទៅខាងនេះ ខាងនោះ ព្រោះហេតុផ្ដែស្រុកផ្ដែចចកជាដើម ។ ពាក្យថា **ជាសប្បាយសម្រាប់បុគ្គលដែលច្រើនដោយតម្រេកក្នុងការលីលានៃអវយវៈតូចធំ ព្រោះមិននាំឲ្យកើតតម្រេក** មានន័យថា អវយវៈដែលកំណត់រូបរាងមិនបាន នឹងមានលីលា គឺ ដំណើរល្វតល្វន់ កែក្រាយ ដូចម្ដេចទៅ ។ ពាក្យថា **ព្រោះប្រកាសភាពវិការ** គឺ ការបែកខ្ញែកគ្នានៃរាងកាយដែលជាប់គ្នា មានន័យថា ភាពវិការ គឺ ការបែកខ្ញែកគ្នានៃតំណយ៉ាងល្អនៃរាងកាយ ដែលជាប់គ្នា គឺ នៃអវយវៈតូចធំដែលជាប់គ្នា ឈ្មោះថា **សង្ឃដភេទ វិការោ** បានដល់ ព្រោះប្រកាសភាពវិការ គឺ ការបែកខ្ញែកគ្នានៃរាងកាយ ដែលជាប់គ្នានោះ ។ បទថា **លោហិតមក្ខិតបដិកូលភាវប្បកាសនតោ** មានន័យថា ភាពជាបដិកូល ព្រោះជារាងកាយដែលប្រឡាក់ឈាម បានដល់ ព្រោះប្រកាសនូវបដិកូល ដោយជារាងកាយដែលមានឈាមប្រឡាក់នោះ ។ ពាក្យថា **បុគ្គលដែលច្រើនដោយតម្រេកក្នុងភាពជារបស់ខ្លួន** គឺ បុគ្គលដែលមានសេចក្ដីត្រេកត្រអាល កើតឡើងថា “ នេះរបស់យើង ” ។ ពាក្យថា **បុគ្គលដែលច្រើនដោយតម្រេកក្នុងសម្បត្តិនៃធ្មេញ** គឺ បុគ្គល

ដែលមានប្រក្រតីត្រេកអរក្នុងការដល់ព្រមនៃធ្មេញ ។

លោកអាចារ្យធ្វើពាក្យដេញដោលសាកសួរទុកក្នុងចិត្តថា ក្នុងអសុភទាំង ១០ មានឧទ្ធុមាតកអសុភជាដើមនេះ ព្រោះហេតុអ្វី ទើបកើតឡើងបានត្រឹមតែបឋមជ្ឈាន ប៉ុណ្ណោះ មិនកើតដល់ទុតិយជ្ឈានជាដើម ទើបពោលថា **ម្យ៉ាងវិញទៀត ព្រោះហេតុដែល** ដូច្នេះជាដើម ។ ពាក្យថា **ទឹកមិនស្ងៀមនឹង** គឺ មានទឹកហូរមិនឈប់ ព្រោះហូរទៅដោយទាក់ទងនឹងក្រសែទឹក បានដល់ មានទឹកមិនឈប់ស្ងៀម ។ បទថា **អវិត្តពលេន** ប្រែថា កម្លាំងខ្សោយ ។ ពាក្យថា **ព្រោះអារម្មណ៍មានកម្លាំងខ្សោយ** មានន័យថា ភាវៈដែលមិនអាចនឹងញ៉ាំងចិត្តទុកក្នុងខ្លួន ( គឺ ក្នុងអារម្មណ៍ ) នោះឯង ព្រោះភាពជាបដិកូល ឈ្មោះថា ហេតុនៃការខ្សោយកម្លាំងនៃអារម្មណ៍ ។ ពិតណាស់ ក្នុងអារម្មណ៍ដែលជាបដិកូល ចិត្តរមែងមិនអាចនឹងប្រព្រឹត្តទៅតាមសភាវៈរបស់ខ្លួនបាន តែចិត្តត្រូវវិតក្កៈដែលមានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈលើកឡើងកាន់អារម្មណ៍នោះឯង ទើបបាននូវឯកគ្គៈ ( ភាពមានអារម្មណ៍តែ១ ) ។ ពាក្យថា **វៀរវិតក្កៈចេញក៏ទេ** មានន័យថា ឈានទាំងឡាយ មានទុតិយជ្ឈានជាដើម ដែលវៀរវិតក្កៈ រមែងមិនបានការតាំងមាំក្នុងអារម្មណ៍នោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ដោយកម្លាំងរបស់វិតក្កៈប៉ុណ្ណោះ ដូច្នេះជាដើម ។

លោកអាចារ្យសំដៅយកពាក្យទាក់ទងដែលថា ប្រសិនបើទុតិយជ្ឈានជាដើម រមែងមិនប្រព្រឹត្តទៅក្នុងអារម្មណ៍ មានឧទ្ធុមាតកអសុភជាដើម ព្រោះភាពជារបស់បដិកូលសោត កាលបើយ៉ាងនេះ សូម្បីបឋមជ្ឈាន ក៏មិនគួរកើតឡើងក្នុងអារម្មណ៍នោះបាន , ព្រោះថា ក្នុងអារម្មណ៍នោះ មិនសមគួរកើតបីតិសោមនស្ស ដូច្នេះ ទើបពោលថា ក្នុងអារម្មណ៍សូម្បីដែលជាបដិកូលនេះ ដូច្នេះជាដើម ។ ក្នុងពាក្យ

ទាំងនោះ គប្បីប្រកបពាក្យឧបមា មានអ្នកចាក់សំរាមនិងកម្ពូត និង ការបន្ទោបង់ចូលទុកជាមួយនឹងភាពជាអ្នកសម្លឹងឃើញអានិសង្ស ក្នុងការជាពេក គឺ ការជុតកម្តៅនូវនីវរណៈតាមលំដាប់ចុះ ។

លោកអាចារ្យ ដើម្បីនឹងសម្តែងថា អសុកសូម្បីកំណត់ទុកជា ១០ យ៉ាងដោយហេតុ តាមដែលពោលហើយ ក៏ចាត់ថា មានតែមួយ៉ាងប៉ុណ្ណោះដោយសភាវៈ ដូច្នេះ ទើបពោលថា មួយ៉ាងវិញទៀត អសុកទាំង ១០ យ៉ាងនោះ ដូច្នេះជាដើម ។ កាលនឹងសម្តែងថា សភាវៈនេះនោះ រមែងបាន សូម្បីក្នុងសរីរៈដែលមានវិញ្ញាណដូចក្នុងសរីរៈដែលគ្មានវិញ្ញាណដែរ ព្រោះដូច្នោះ អ្នកមានយោនិសោមនសិការៈរមែងសម្រេចការនាបាន សូម្បីក្នុងសរីរៈដែលមានវិញ្ញាណនោះឯង ដូច្នោះទើបលោកពោលថា ដោយលក្ខណៈនេះ អសុកនេះនោះ ដូច្នេះជាដើម ។ បទថា **ឯត្ថ** ប្រែថា ក្នុងសរីរៈរបស់អ្នករស់នេះ ។ ពាក្យថា **គ្រឿងតែងខ្លួន** គឺ គ្រឿងតែងខ្លួនមានគ្រឿងជម្រះកាយជាសំខាន់ , អធិប្បាយថា មិនប្រាកដដល់ពពួកជនភាគច្រើន ។ ឈ្មោះថា ជាគ្រោងនៃឆ្អឹងជាង ៣០០ កំណាត់ ដោយការរាប់ព្រមជាមួយនឹងឆ្អឹងធ្មេញទាំងឡាយ តែលោកពោលទុកក្នុងកាយគតាសតិថា " ឆ្អឹងមានប្រមាណ ៣០០ កំណាត់ " ដូច្នេះ វៀរឆ្អឹងធ្មេញទាំងនោះ ។ បទថា **ធិន្នាវធិន្នំ** ប្រែថា មានប្រហោងធំ ប្រហោងតូច ។ ពាក្យថា **ថង់ខ្ទាញ់ខាប់** គឺ ភាជនៈដែលពេញដោយខ្ទាញ់ខាប់ ។ បទថា **និច្ចុគ្ឃរិតបគ្ឃរិតំ** ប្រែថា មានខ្ទាញ់ជ្រាបសើមទាំងខាងលើ និងខាងក្រោមអស់កាលជានិច្ច ។ បទថា **វេមត្តំ** ប្រែថា ភាពផ្សេងគ្នា ។ ពាក្យថា **សំពត់ផ្សេង ៗ** គឺ សំពត់មានពណ៌ផ្សេងៗ ។ **ឧច្ចារមគ្គ បស្សាវមគ្គ** ឈ្មោះថា **ហិរិកោបន** ព្រោះធ្វើ ហិរិ គឺ ការខ្មាសឲ្យកម្រើក គឺ ធ្វើឲ្យ

វិនាស ។ ពាក្យថា **ដែលមានរសរបស់ខ្លួនតាមសេចក្ដីពិត** គឺ ដែលមានសភាវៈតាមសេចក្ដីពិត ។ ពិតណាស់ សភាវៈឈ្មោះថា **រស** ព្រោះអត្ថថា ដែលបណ្ឌិតរមែងត្រេកអរ គឺ ដឹងបានតាមសេចក្ដីពិត ។ ពាក្យថា **រមែងត្រេកអរ** គឺ ត្រេកអរក្រៃលែង ពេញចិត្តក្រៃលែង បុគ្គលកាលត្រេកអរហើយដោយរាគៈ ពោលគឺសេចក្ដីស្នេហាក្នុងខ្លួន ឈ្មោះថា **អត្តសិនេហរាគរត្តា** ។ ពាក្យថា **ក្ដៅក្រហាយ** គឺ ដល់នូវភាពក្ដៅក្រហាយ ព្រោះមិនបានវត្តតាមដែលខ្លួនប្រាថ្នា ។ បទថា **កឹសុកំ** ប្រែថា **ដើមចា** អាចារ្យពួកខ្លះ ប្រែថា **ដើមរលួសផ្អុង** មួយពួកទៀតថា **ដើមរកា** ។ ពាក្យថា **មានការល្មោភហួសប្រមាណ** គឺ មានសេចក្ដីល្មោភជាសភាវៈហួសនឹងប្រៀបបាន ។ បទថា **អទុំ** ប្រែថា នោះ ។ ពាក្យថា **កោដ្ឋាសសូម្បីដែលតាំងនៅក្នុងរាងកាយនោះ** គឺ កោដ្ឋាសក្នុងរាងកាយ មានសក់ជាដើម ។ ពាក្យថា **សញ្ជប់សញ្ជឹង** គឺ លិចចុះ ឬថា ដល់នូវភាពសោកសៅ ដោយអំណាចនៃតណ្ហាដែលធ្វើឲ្យដល់នូវភាពសោកសៅ ។ ពាក្យថា **សភាព** គឺ សភាពដែលជាបដិកូល ។ ពាក្យថា **មានឧបមាដូចរណ្ដៅលាមក** គឺ ស្មើដោយស្ថានទីបន្ទោបង់ឧច្ចារបស្សាវៈ ឬថា ស្មើដោយរណ្ដៅលាមក ។ បទថា **ចក្ខុភូតេហិ** ប្រែថា លោកអ្នកដល់នូវចក្ខុ គឺ លោកអ្នកបាននូវបញ្ញាចក្ខុ ឬប្រែថា អ្នកដែលមានបញ្ញាចក្ខុឃើញនូវលោក ។ ពាក្យថា **បិទបាំងទុកដោយស្បែកស្រស់** គឺ ដណ្ដប់ទុកដោយស្បែកស្រស់ ។ ពាក្យថា **ជាអ្នកទព្វជាតិ** គឺ បុគ្គលគួរបានទទួលឧត្តរិមនុស្សធម៌ ជាសភាវៈ ។ បទថា **យត្ថ យត្ថ** ប្រែថា ក្នុងសរីរៈ គឺ ក្នុង កោដ្ឋាសណាៗនៃរាងកាយ ។ ពាក្យថា **កាន់យកនិមិត្ត** បានដល់ កាន់យកនិមិត្ត គឺ ធ្វើឧគ្គហនិមិត្តឲ្យកើតឡើង ដោយទាក់ទងនឹងការរៀនយក តាមប្រការដែលឧគ្គហនិមិត្តអាចនឹងកើតឡើងបាន ដោយ

អំណាចនៃការកំណត់ទុកបានយ៉ាងល្អនូវអាការ ដែលមិនស្អាត ។ ពាក្យថា **ញ៉ាំង កម្មដ្ឋានឲ្យសម្រេចដល់អប្បនា** មានន័យថា កិច្ចដែលបរិកម្មក្នុងឧគ្គហនិមិត្ត តាមដែលបានធ្វើបដិភាគនិមិត្តឲ្យកើតឡើងហើយ តាំងនៅក្នុងឧបចារឈាន កាលធ្វើការនានោះៗឯងឲ្យចម្រើនឡើង ក៏នឹងញ៉ាំងអសុភកម្មដ្ឋាននោះ ឲ្យសម្រេចដល់អប្បនាបាន ។ កិច្ចដែលសម្រេចអប្បនាហើយ តាំងនៅក្នុងបឋមជ្ឈាន កាលធ្វើឈានទាំងនោះឲ្យជាបាទ ប្រារព្ធវិបស្សនា ពិចារណាសង្ខារ រមែងធ្វើអាសវៈទាំងពួងឲ្យអស់ទៅបាន ក្នុងកាលមិនយូរឡើយ ដូច្នេះ ។

បរិច្ឆេទទី ៦

ឈ្មោះ អសុភកម្មដ្ឋាននិទ្ទេស

ក្នុងអធិការនៃសមាធិនិទ្ទេសភាវនា ក្នុងបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គ

ដែលខ្ញុំព្រះករុណាធ្វើដើម្បីជាប្រយោជន៍ដល់ បាមោជ្ជនៃសាធុជន ដូច្នេះឯង ។

# ៩អនុស្សតិនិទ្ទេស

ក្នុងអនុស្សតិ ១០ ដែលលោកសម្តែងទុកក្នុងលំដាប់នៃអសុភ សតិនោះឯង ឈ្មោះថា **អនុស្សតិ** ព្រោះកើតឡើងរឿយ ៗ , ម្យ៉ាងវិញទៀត **សតិ** ឈ្មោះថា **អនុស្សតិ** ព្រោះហេតុ ជាការរលឹកដែលរាប់ថា សមគួរដល់កុលបុត្តដែលបួសដោយសទ្ធា ព្រោះឲ្យប្រព្រឹត្តទៅក្នុងឋានៈដែលគួរប្រព្រឹត្តទៅប៉ុណ្ណោះ ដូច្នេះក៏បាន ។

១. អនុស្សតិ ដែលប្រារព្ធព្រះពុទ្ធជាម្ចាស់ កើតឡើង ឈ្មោះថា **ពុទ្ធានុស្សតិ** ពាក្យថា **ពុទ្ធានុស្សតិ** នោះ ជាពាក្យហៅ **សតិ** ដែលមានព្រះពុទ្ធគុណជាអារម្មណ៍ ។

២. អនុស្សតិ ដែលប្រារព្ធព្រះធម៌កើតឡើង ឈ្មោះថា **ធម្មានុស្សតិ** ពាក្យថា **ធម្មានុស្សតិ** នោះ ជាពាក្យហៅ **សតិ** ដែលមានព្រះធម្មគុណមានភាពជា **ស្វាក្ខាតធម្ម** ជាដើម ជាអារម្មណ៍ ។

៣. អនុស្សតិ ដែលប្រារព្ធព្រះសង្ឃ កើតឡើង ឈ្មោះថា **សង្ឃានុស្សតិ** ពាក្យថា **សង្ឃានុស្សតិ** នោះ ជាពាក្យហៅ **សតិ** ដែលមានព្រះសង្ឃគុណ មានភាពជាអ្នកបដិបត្តិល្អជាដើម ជាអារម្មណ៍ ។

៤. អនុស្សតិ ដែលប្រារព្ធសីល កើតឡើង ឈ្មោះថា **សីលានុស្សតិ** ពាក្យថា **សីលានុស្សតិ** នោះ ជាពាក្យហៅ **សតិ** ដែលមានសីលគុណ មានភាពជាសីលមិនដាច់ជាដើម ជាអារម្មណ៍ ។

៥. អនុស្សតិ ដែលប្រារព្ធដល់ការលះបង់ កើតឡើង ឈ្មោះថា **ចាគានុស្សតិ** ពាក្យថា **ចាគានុស្សតិ** នោះ ជាពាក្យហៅ **សតិ** ដែលមាន

ចាគគុណ គឺ ជាអ្នកលះបង់ដាច់ស្រឡះជាដើម ជាអារម្មណ៍ ។

៦. អនុស្សតិ ដែលប្រារព្ធទេវតា កើតឡើង ឈ្មោះថា **ទេវតានុស្សតិ** ពាក្យថា **ទេវតានុស្សតិ** នោះ ជាពាក្យហៅ **សតិ** ដែលមានគុណមានសទ្ធាជាដើមរបស់ខ្លួន តាំងទេវតាទុកនៅក្នុងឋានៈ ជាបន្ទាល់ ( សាក្សី ) ជាអារម្មណ៍ ។

៧. អនុស្សតិ ដែលប្រារព្ធសេចក្តីស្លាប់ កើតឡើង ឈ្មោះថា **មរណានុស្ស-តិ** ពាក្យថា **មរណានុស្សតិ** នោះ ជាពាក្យហៅ **សតិ** ដែលមានការដាច់នៃជីវិតិន្ទ្រិយ ជាអារម្មណ៍ ។

៨. អនុស្សតិ ឈ្មោះថា **កាយគតា** ព្រោះទៅកាន់រូបកាយដែលផ្សេងដោយកោដ្ឋាស មានសក់ជាដើម ឬថា ព្រោះទៅក្នុងកាយ កាលគួរនឹងពោល ( វិគ្រោះ ) ថា **កាយគតា ច សា សតិ ចាតិ កាយគតាសតិ** “ សតិនោះផង គ្រាប់ទៅក្នុងកាយផង ព្រោះហេតុនោះ ទើបឈ្មោះថា **កាយគតាសតិ** ” តែលោកមិនធ្វើរស្សៈ ពោលថា **កាយគតាសតិ** , ពាក្យថា **កាយគតាសតិ** នោះ ជាពាក្យហៅ **សតិ** ដែលមាន ( បដិកូល ) និមិត្តក្នុងកោដ្ឋាសនៃកាយ មានសក់ជាដើម ជាអារម្មណ៍ ។

៩. អនុស្សតិ ដែលប្រារព្ធខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ កើតឡើង ឈ្មោះថា **អានាបានស្សតិ** ពាក្យថា **អានាបានស្សតិ** នោះ ជាពាក្យហៅ **សតិ** ដែលមាននិមិត្តក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ជាអារម្មណ៍ ។

១០. អនុស្សតិ ដែលប្រារព្ធឧបសមៈ កើតឡើង ឈ្មោះថា **ឧបសមានុស្សតិ** ពាក្យថា **ឧបសមានុស្សតិ** នោះ ជាពាក្យហៅ **សតិ** ដែលមានព្រះនិព្វាន ដែលជាទីរំងាប់នៃសព្វទុក្ខ ជាអារម្មណ៍ ។

## ពុទ្ធានុស្សតិ

ក្នុងអនុស្សតិ ១០ មានប្រការដូចពោលមកនេះ ព្រះយោគាវចរដែលប្រកប ដោយសេចក្តីជ្រះថ្លាមាំទាំ ប្រាថ្នានឹងចម្រើនពុទ្ធានុស្សតិដែលជាលំដាប់ដំបូង គប្បីជាអ្នកគេចចេញទៅក្នុងទីស្ងាត់ សម្រាកនៅក្នុងសេនាសនៈដែលសមគួរហើយ រឭកដល់ព្រះពុទ្ធគុណរបស់ព្រះដ៏មានព្រះភាគ ដោយអនុស្សរណបាឋៈ យ៉ាងនេះថា ៖

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ។

នេះជាន័យ ក្នុងការរឭកក្នុងព្រះពុទ្ធគុណទាំងនោះ គឺ ( រឭកប្រកប **ឥតិបិ** ទុកគ្រប់បទ ) ថា **សោ ភគវា ឥតិបិ អរហំ** ( សូម្បីព្រោះហេតុយ៉ាងនេះ ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ ជាព្រះអរហន្ត ) ។បេ។ **សោ ភគវា ឥតិបិ ភគវា** ( សូម្បីព្រោះហេតុយ៉ាងនេះ ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ ជា **ព្រះភគវា** ) ។ ( ពាក្យ **ឥតិបិ** នោះ មានអធិប្បាយថា ព្រោះហេតុនេះ ៗ ។

## បទថា អរហំ ៥ ន័យ

បណ្ឌិតរមែងរឭកថា ក្នុងបទទាំងនោះព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ បាន

ព្រះនាមថា **អរហំ** ព្រោះហេតុ ៥ន័យ នេះសិនគឺ ៖

| | |
|---|---|
| -អារកត្តា | ព្រោះភាពជាអារកៈ ( អ្នកឆ្ងាយ ) ១ ។ |
| -អរីនំ អរានញ្ច ហតត្តា | ព្រោះទ្រង់កម្ចាត់អរិ ( សត្រូវ ) ទាំងឡាយចេញបាន ១ និងព្រោះទ្រង់ទម្លាយអរៈ( កាំ )ទាំងឡាយចេញបាន ១ ។ |
| -បច្ចយាទីនំ អរហត្តា | ព្រោះភាពជាអរហៈ( អ្នកគួរ )ដល់ទក្ខិណាវត្ថុទាំងឡាយ មានបច្ច័យជាដើម ១ ។ |
| -បាបករណេ រហាភាវា | ព្រោះភាពមិនមានរហៈ ( ទីកំបាំង ) ក្នុងការធ្វើបាប ១ ។ |

## ន័យទី ១ អ្នកឆ្ងាយ

ពិតណាស់ ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ ឈ្មោះថា **អារក** គឺ ទ្រង់ស្ថិតនៅក្នុងទីឆ្ងាយអំពីសព្វកិលេស ព្រោះកិលេសទាំងឡាយ ព្រមទាំងវាសនា ព្រះអង្គទ្រង់កម្ចាត់ចោលបានហើយ ព្រោះភាពជា **អារក** ( អ្នកឆ្ងាយ ) ដូច្នេះ ហើយទើបបានព្រះនាមថា **អរហំ** ។

## សរុបគាថា សម្រាប់ន័យទី ១

ព្រះមានព្រះភាគជាម្ចាស់ជា នាថ ទ្រង់មិនមានការជាប់ជំពាក់ដោយកិលេសណា ព្រះអង្គទ្រង់មិនប្រកបដោយវត្ថុដែលជាទោសទាំងឡាយណា ក៏ឈ្មោះថាទ្រង់ជាអ្នកឆ្ងាយចាកកិលេស និងទោសនោះ ព្រោះហេតុនោះ ទើបទ្រង់ប្រាកដព្រះនាមថា អរហំ ( អ្នកឆ្ងាយ ) ដូច្នេះ ។

## ន័យទី ២ អ្នកកម្ចាត់ អរិ

ម្យ៉ាងវិញទៀត **អរិ** គឺ កិលេសទាំងឡាយនោះ ព្រះអង្គទ្រង់កម្ចាត់ចេញបាន ហើយដោយមគ្គ គឺ ទ្រង់កម្ចាត់អរិទាំងឡាយចេញបានដូច្នេះ ទើបទ្រង់ព្រះនាមថា **អរហំ** ប្រការ ១ ។

## សរុបគាថា សម្រាប់ន័យទី ២

ព្រោះហេតុដែល **អរិ** ទាំងឡាយ ពោលគឺ កិលេស មានរាគៈជាដើម សូម្បីទាំងអស់ ព្រះមានព្រះភាគជាម្ចាស់ជា **នាថ** ទ្រង់កម្ចាត់ហើយដោយសស្ត្រា គឺ ព្រះបញ្ញា ព្រោះហេតុនោះ ទើបទ្រង់ប្រាកដព្រះនាមថា **អរហំ** ( អ្នកកម្ចាត់សត្រូវ ) ប្រការ ១ ដូច្នេះ ។

## ន័យទី ៣ អ្នកទម្លាយកាំសង្សារចក្រ

ម្យ៉ាងវិញទៀត សង្សារចក្រ ( កង់ គឺ សង្សារ ) ដែលមានដុំ គឺ អវិជ្ជា និង ភវតណ្ហា , អភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម ជាកាំ , ជរាមរណៈជាខ្នងកង់ ស៊កដោយភ្លៅ គឺ អាសវសមុទយ ប្រកបចូលទុកក្នុងតួរថ គឺ ត្រៃភព , វិលទៅអស់កាលរកខាងដើមមិនមាននោះណា កាំទាំងឡាយនៃសង្សារចក្រនោះ ព្រះអង្គទ្រង់ប្រតិស្ឋាននៅនាផែនដី គឺ សីល ដោយព្រះយុគលបាទ គឺ វីរិយៈ ហើយទ្រង់កាន់យកពូថៅ គឺ ព្រះញាណ ដែលទ្រង់កម្ចាត់នូវកម្មដោយព្រះហស្ត គឺ សទ្ធា ឲ្យខ្ចាត់ខ្ចាយអស់ហើយ ព្រោះទ្រង់ទម្លាយនូវអរៈ គឺ សង្សារចេញបាន ដូច្នេះទ្រង់ទើបព្រះនាមថា **អរហំ** ប្រការ ១ ។

ឬបើមិនដូច្នោះ សង្សារវដ្តដែលមិនប្រាកដទីបំផុត ហៅថា សង្សារចក្រ ឯអវិជ្ជារាប់ថាជាដុំនៃសង្សារចក្រនោះ ព្រោះជាខាងដើម , ជរាមរណៈរាប់ថាជា ខ្នងកង់ ព្រោះជាខាងចុង , ធម៌ដ៏សេស ១០ ប្រការ រាប់ថា កាំ ព្រោះមានអវិជ្ជាជាខាងដើម និងព្រោះមានជរាមរណៈជាខាងចុង , ក្នុងធម៌ទាំងនោះ ការមិនដឹងក្នុងអរិយសច្ច មានទុក្ខជាដើម ឈ្មោះថា **អវិជ្ជា** ។

***អវិជ្ជាក្នុងកាមភព*** រមែងជាបច្ច័យនៃសង្ខារទាំងឡាយក្នុងកាមភព , អវិជ្ជាក្នុងរូបភព រមែងជាបច្ច័យនៃសង្ខារទាំងឡាយក្នុងរូបភព , អវិជ្ជាក្នុងអរូបភព រមែងជាបច្ច័យនៃសង្ខារទាំងឡាយ ក្នុងអរូបភព ។

***សង្ខារទាំងឡាយក្នុងកាមភព*** រមែងជាបច្ច័យនៃបដិសន្ធិវិញ្ញាណក្នុងកាមភពក្នុងភព ក្រៅអំពីនេះ ក៏មានន័យដូច្នោះ ។

***បដិសន្ធិវិញ្ញាណក្នុងកាមភព*** រមែងជាបច្ច័យនៃនាមរូបក្នុងកាមភព , ក្នុងរូបភពក៏យ៉ាងនោះ , ក្នុងអរូបភព ( បដិសន្ធិវិញ្ញាណ ) ជាបច្ច័យដល់នាមតែម្យ៉ាង ។

***នាមរូបក្នុងកាមភព*** ជាបច្ច័យនៃអាយតនៈគ្រប់ទាំង ៦ ក្នុងកាមភព , នាមរូបក្នុងរូបភព ជាបច្ច័យនៃអាយតនៈ ៣ ក្នុងរូបភព , នាមក្នុងអរូបភពជាបច្ច័យនៃអាយតនៈ ១ ក្នុងអរូបភព ។

***អាយតនៈ ៦ ក្នុងកាមភព*** រមែងជាបច្ច័យនៃផស្សៈទាំង ៦ ក្នុងកាមភព , អាយតនៈក្នុងរូបភពជាបច្ច័យដល់ផស្សៈ ៣ ក្នុងរូបភព , អាយតនៈ ១ ក្នុងអរូបភពជាបច្ច័យដល់ផស្សៈ ១ ក្នុងអរូបភព ។

***ផស្សៈ ៦ ក្នុងកាមភព*** ជាបច្ច័យនៃវេទនា ៦ ក្នុងកាមភព , ផស្សៈ ៣ ក្នុងរូបភពជាបច្ច័យដល់វេទនា ៣ ក្នុងរូបភព , ផស្សៈ ១ ក្នុងអរូបភពជាបច្ច័យ

នៃវេទនា ១ ក្នុងអរូបភព ។

**វេទនា ៦ ក្នុងកាមភព** ជាបច្ច័យនៃតណ្ហា ៦ ក្នុងកាមភព , វេទនា ៣ ក្នុងរូបភពជាបច្ច័យនៃតណ្ហា ៣ ក្នុងរូបភព , វេទនា ១ ក្នុងអរូបភពជាបច្ច័យនៃតណ្ហា ១ ក្នុងអរូបភព ។

**តណ្ហានោះៗ ក្នុងភពនោះៗ** ជាបច្ច័យនៃឧបាទាននោះៗ ធម៌ដ៏សេស មានឧបាទានជាដើម ជាបច្ច័យនៃធម៌ទាំងឡាយមានភពជាដើម ។

សួរថា សេចក្តីនេះ ដូចម្តេច ? ឆ្លើយថា “ បុគ្គលខ្លះក្នុងលោកនេះ ប្រាថ្នា ( ដោយអំណាចកាមតណ្ហា ថា ) យើងនឹងបរិភោគកាម ហើយប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ព្រោះកាមុបាទានជាបច្ច័យ កាលចម្រើនទៅដោយទុច្ចរិត គេ ( ស្លាប់ទៅ ) ក៏កើតក្នុងអបាយ , កម្មដែលជាហេតុនៃឧប្បត្តិក្នុងអបាយនោះ របស់គេ ជាកម្មភព ខន្ធទាំងឡាយដែលកើតព្រោះកម្ម ជាឧប្បត្តិភព ការកើតនៃខន្ធទាំងឡាយជាជាតិ ការចាស់ ( នៃខន្ធ ) ជាជរា ការបែកធ្លាយទៅ ( នៃខន្ធទាំងនោះ ) ជាមរណៈ ។

បុគ្គលខ្លះទៀត ប្រាថ្នាថា យើងនឹងសោយសម្បត្តិក្នុងស្ថានសួគ៌ ហើយប្រព្រឹត្តសុចរិតព្រោះកាមុបាទានជាបច្ច័យ ន័យដូចគ្នា កាលពេញប្រៀបទៅដោយសុចរិត គេ( ស្លាប់ទៅ )ក៏កើតក្នុងស្ថានសួគ៌ ។ សេចក្តីតទៅនេះ ក៏មានន័យដូច្នោះ គឺ កម្មដែលជាហេតុនៃការឧប្បត្តិក្នុងសួគ៌នោះរបស់គេ ជាកម្មភព ដូច្នេះជាដើម ។

ចំណែកបុគ្គលខ្លះទៀត ប្រាថ្នាថា យើងនឹងសោយសម្បត្តិក្នុងព្រហ្មលោក ហើយចម្រើនមេត្តា ចម្រើនករុណា មុទិតា ឧបេក្ខា ព្រោះកាមុបាទានជាបច្ច័យ ដូចគ្នាដែរ កាលពេញទៅដោយភាវនា គេ ( ស្លាប់ទៅ ) ក៏ទៅកើតក្នុងព្រហ្មលោក ន័យ

( តទៅ ) ក៏មានន័យដូចគ្នា គឺ កម្មដែលជាហេតុនៃឧប្បត្តិក្នុងព្រហ្មលោកនោះ របស់គេជាកម្មភព ដូច្នេះជាដើម ។

បុគ្គលខ្លះទៀត ប្រាថ្នាថា យើងនឹងសោយសម្បត្តិក្នុងអរូបភព ហើយចម្រើនសមាបត្តិ មានអាកាសានញ្ចាយតនៈជាដើម ព្រោះឧបាទានជាបច្ច័យ , ដូចគ្នាដែរ កាលបរិបូរទៅដោយភាវនា គេ ( ស្លាប់ទៅ ) ក៏កើតក្នុងអរូបភពនោះៗ កម្មដែលជាហេតុនៃឧប្បត្តិក្នុងអរូបភពនោះរបស់គេ ជាកម្មភព , ខន្ធទាំងឡាយដែលកើតព្រោះកម្ម ជាឧប្បត្តិភព , ការកើតនៃខន្ធទាំងឡាយជា ជាតិ , ការចាស់ទៅ (នៃខន្ធ) ជាជរា , ការបែកធ្លាយទៅ ( នៃខន្ធ ) ជាមរណៈ ( កាមុបាទាន ជាបច្ច័យនៃភពជាដើម ដូច្នេះឯង ) ។ ន័យ សូម្បីក្នុងការប្រកប ( សេចក្តី ) ដែលមានឧបាទានដ៏សេស ក៏មានន័យដូច្នេះ ។

តទៅនេះ លោកដកយកបាលីក្នុងបដិសម្ភិទាមគ្គមកពោលបញ្ជាក់សេចក្តីក្នុងរឿងធម៌ទាំងនេះ ជាបច្ច័យទាក់ទងគ្នា ដោយហៅការកំណត់ដឹងក្នុងរឿងនេះថា **ធម្មដ្ឋិតិញ្ញាណ** ហើយសរុបជាសង្ខេបជាដើមដូច្នេះ ដោយន័យដូច្នេះ បញ្ញាក្នុងការកំណត់បច្ច័យថា “ អវិជ្ជាជាហេតុ សង្ខារជាហេតុសមុប្បន្ន , អវិជ្ជានិងសង្ខារទាំងពីរនេះ ក៏ជាហេតុសមុប្បន្នដែរ នេះឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** បញ្ញាក្នុងការកំណត់បច្ច័យថា “ អវិជ្ជាជាហេតុ សង្ខារជាហេតុសមុប្បន្ន អវិជ្ជានិងសង្ខារ ទាំង ២ នេះ ក៏ជាហេតុសមុប្បន្នផងដែរ ទាំងក្នុងអតីតកាល ទាំងក្នុងអនាគតកាល ” ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** យ៉ាងនេះឯង ( ឧបរិបណ្ណាសកៈ លេខ ៣១ ) ។ បទទាំងពួង បណ្ឌិតគប្បីពោលដោយពិស្តារ តាមន័យនេះចុះ ។

ក្នុងធម៌ទាំងនោះ អវិជ្ជា និង សង្ខារ ជាសង្ខេប ១ , វិញ្ញាណ នាមរូប

សឡាយតនៈ ផស្សៈ វេទនា ជាសង្ខេប ១ , តណ្ហា ឧបាទាន ភព ជាសង្ខេប ១, ជាតិ ជរា មរណៈ ជាសង្ខេប ១ ។ម្យ៉ាងទៀត ក្នុងសង្ខេបទាំង ៤ នោះ សង្ខេបដំបូងជាអតីតអទ្ធា ( អតីតកាល ) , សង្ខេបកណ្ដាល ២ ជាបច្ចុប្បន្នអទ្ធា , ជាតិ ជរា មរណៈ ជាអនាគតអទ្ធា ។ ម្យ៉ាងវិញទៀត ក្នុងធម៌ទាំងនោះ ការកាន់យក ( គឺ ពោលដល់ ) អវិជ្ជា សង្ខារ ក៏ជាការកាន់យកនូវ តណ្ហា ឧបាទាន ភព ( ដែលជាហេតុ គឺ ជាកិលេសនិងកម្ម ) ផងដែរ ព្រោះដូច្នោះ ធម៌ ៥ ប្រការនេះ ទើបចាត់ជាកម្មវដ្ដៈក្នុងអតីត ។ ធម៌ ៥ ប្រការ មានវិញ្ញាណជាដើម ( គឺ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ) ចាត់ជាវិបាកវដ្ដៈក្នុងបច្ចុប្បន្ន ។ ការកាន់យក តណ្ហា ឧបាទាន ភព ក៏កាន់យក អវិជ្ជា សង្ខារ ផងដែរ ព្រោះដូច្នោះ ធម៌ ៥ ប្រការ នេះ ទើបជាកម្មវដ្ដៈក្នុងបច្ចុប្បន្ន ។ ធម៌ ៥ ប្រការ នេះ ( គឺ វិញ្ញាណ ។ល។ វេទនា ) ចាត់ជាវិបាកវដ្ដៈក្នុងអនាគត ព្រោះដោយការពោលដល់ ជាតិ ជរា មរណៈ ជាការចង្អុលដល់ធម៌ ៥ ប្រការ មានវិញ្ញាណជាដើម ( ដែលជាធម៌មាន ជាតិ ជរា មរណៈ ) ជាសភាវៈ ធម៌ទាំងនោះដោយអាការទើបមាន ២០ ។ ម្យ៉ាងវិញទៀត ក្នុងធម៌ទាំងនោះ ក្នុងរវាងសង្ខារនិងវិញ្ញាណ មានសន្ធិ ១ , រវាងវេទនានិងតណ្ហា មានសន្ធិ ១ , រវាងភពនិងជាតិ មានសន្ធិ ១ ដូច្នេះឯង ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ដឹង ទ្រង់ឃើញ គឺ ទ្រង់ដឹងដ៏ក្រៃលែង ឃើញពិតនូវបដិច្ចសមុប្បាទដែលមាន សង្ខេប ៤ , អទ្ធា( កាល ) ៣ , អាការ ២០ , សន្ធិ ៣ នោះ ដោយអាការទាំងពួង តាមន័យដូចដែលពោលមកដូច្នេះឯង ។

ការដឹងនោះ ឈ្មោះថា **ញាណ** ព្រោះអត្ថថា ដឹង , ឈ្មោះថា **បញ្ញា** ព្រោះ

អត្ថថា ប្រចក្សច្បាស់ ព្រោះហេតុនោះ ទើបលោកពោលថា បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់ត្រាស់ដឹងនូវធម៌ទាំងនោះតាមសេចក្តីពិត ដោយធម្មដ្ឋិតិញ្ញាណនេះហើយ ទ្រង់នឿយ-ណាយក្នុងធម៌ទាំងនោះ ទ្រង់ប្រាសចាកសេចក្តីត្រេកអរ រួចផុតស្រឡះ ឈ្មោះថាទ្រង់កម្ចាត់ ឬ ទម្លាយនូវកាំទាំងឡាយនៃសង្សារចក្រ ដែលមានប្រការដូចដែលពោលហើយ ព្រោះទ្រង់កាច់បំបាក់កាំទាំងឡាយ ( នៃសង្សារចក្រ ) ចេញបានយ៉ាងនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបទ្រង់ព្រះនាមថា **អរហំ** ប្រការ ១ ។

## គាថាសរុបសម្រាប់ន័យទី៣

ព្រោះហេតុដែល អរ ( កាំ ) ទាំងឡាយនៃសង្សារចក្រ ព្រះលោកនាថជាម្ចាស់ទ្រង់ទម្លាយចោលហើយ ដោយដាវ គឺ ព្រះញាណ ព្រោះហេតុនោះ ព្រះអង្គទើបព្រះនាមថា អរហំ ( អ្នកទម្លាយកាំ ) ។

## ន័យទី៤ អ្នកគួរ

ន័យម្យ៉ាងទៀត ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ គួរទទួលនូវបច្ច័យមានចីវរជាដើម និងការបូជាយ៉ាងពិសេស ព្រោះព្រះអង្គជាអគ្គទក្ខិណេយ្យបុគ្គល ព្រោះហេតុនោះឯង កាលព្រះតថាគតជាម្ចាស់កើតឡើងហើយ ជនគ្រប់ពួកក្រុមដែលជាមហេសក្ខ ( ពួកជនលើកតម្កើងថា ជាម្ចាស់ ជាធំ ) ទាំងទេវតា ទាំងមនុស្ស លោកទាំងនោះធ្វើការបូជាក្នុងទីដទៃក៏ទេ ពិតហើយ ទេវសហម្បតិព្រហ្មបានបូជាព្រះតថាគត ដោយកម្រងរតនៈប៉ុនភ្នំសិនេរុ ម្យ៉ាងវិញទៀត ទេវតាដទៃ ៗ និងមនុស្សទាំងឡាយ ដូចជាព្រះបាទពិម្ពិសារ និង ព្រះបាទកោសល្យរាជ ក៏បានបូជា

តាមកម្លាំង ម្យ៉ាងវិញទៀត ព្រះបាទអសោកមហារាជ ទ្រង់ក៏បានលះបង់ទ្រព្យ ប្រមាណ ៩៦ កោដិ ប្រទានឲ្យសាងវិហារដល់ទៅ ៨៤.០០០ កន្លែង ឧទ្ទិស ចំពោះព្រះមានព្រះភាគ សូម្បីទ្រង់បរិនិព្វានហើយ នឹងពោលថ្វីដល់ការបូជាយ៉ាង វិសេសដទៃៗ ដែលទេវតា និងមនុស្សដែលមិនមែនជាមហេសក្ខ ធ្វើថ្វាយនោះ ។

ព្រោះទ្រង់ជា **អរហ** ( អ្នកគួរ ) ដល់ទក្ខិណាវត្ថុទាំងឡាយ មានបច្ច័យជាដើម ដូច្នេះ ទើបទ្រង់ព្រះនាមថា **អរហំ** ប្រការ ១ ។

## គាថាសរុបសម្រាប់ន័យទី៤

ព្រោះហេតុដែលព្រះលោកនាថ អង្គនោះ ទ្រង់គួរដល់នូវការបូជាយ៉ាង ពិសេស ព្រមទាំងបច្ច័យទាំងឡាយ ព្រោះហេតុនោះ ព្រះអង្គក៏ជាព្រះជិនៈ ទើប ទ្រង់គួរដល់ព្រះនាមនោះ គឺ **អរហំ** ក្នុងលោក ដែលជាព្រះនាមមានអត្ថដ៏សមគួរ ដល់អត្ថ ( នៃ **អរហ សទ្ទ** ) ។

## ន័យទី៥ អ្នកមិនមានទីកំបាំង

ម្យ៉ាងវិញទៀត បុគ្គលពាលដែលទុកខ្លួនថាជា បណ្ឌិត គ្រប់ជំពូកក្នុងលោក រមែងធ្វើបាបក្នុងទីស្ងាត់ ព្រោះខ្លាចខូចឈ្មោះ យ៉ាងណា ព្រះដ៏មានព្រះភាគជា ម្ចាស់អង្គនោះ ទ្រង់ធ្វើដូច្នោះក្នុងកាលណាៗ មិនមាន ព្រោះការមិនមានទីកំបាំងក្នុង ការធ្វើបាបដូច្នោះ ទើបទ្រង់បានព្រះនាមថា **អរហំ** ប្រការ ១ ។

## គាថាសរុបសម្រាប់ន័យទី៥

ព្រោះហេតុដែលបានឈ្មោះថា ទីកំបាំង ក្នុងការធ្វើបាបទាំងឡាយ រមែងមិន

មានដល់ព្រះតាទីតថាគតជាម្ចាស់ ព្រោះហេតុនោះ ព្រះអង្គទើបប្រាកដព្រះនាមថា អរហំ ព្រោះមិនមានទីកំបាំង ។

## គាថាសរុបសម្រាប់គ្រប់ន័យ

ព្រះមុនីជាម្ចាស់អង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះទ្រង់ឆ្ងាយចាកកិលេស ១ , ព្រោះទ្រង់កម្ចាត់ អរិ គឺ កិលេសទាំងឡាយចេញ ១ , ព្រះអង្គទ្រង់ជាអ្នកទម្លាយកាំនៃសង្សារចក្រ ១ , ជាអ្នកគួរដល់ទក្ខិណាវត្ថុទាំងឡាយ មានបច្ច័យជាដើម ១ , ទ្រង់មិនធ្វើបាបទាំងឡាយក្នុងទីកំបាំង ១ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហំ ដោយប្រការទាំងពួង ដូចពណ៌នាមកដូច្នេះឯង ។

# មហាដីកា

## ពណ៌នា ឆអនុស្សតិនិទ្ទេស

------◎------

## ពុទ្ធានុស្សតិ

បទថា **អសុភានន្តរំ** គឺ ក្នុងលំដាប់នៃអសុភកម្មដ្ឋាន ។ ពាក្យថា **ក្នុងបណ្តាអនុស្សតិ** គឺ ក្នុងបណ្តាអនុស្សតិកម្មដ្ឋាន ។ លោកអាចារ្យបំណាងសម្តែងអត្ថន័យនោះថា “ ការរឭករឿយៗ ឈ្មោះថា **អនុស្សតិ** ” ដូច្នេះ ទើបពោលថា ព្រោះកើតឡើងរឿយៗ ហើយបំណាងសម្តែងថា **សតិ** សព្ទ ដែលមានការប្រកបចូលជាមួយ **អនុ** សព្ទ ក្នុងពាក្យអនុស្សតិនេះ មិនបានជាសព្ទដែលប្រាប់អត្ថន័យដទៃ ទើបពោលថា **សតិ** នោះឯង ឈ្មោះថា **អនុស្សតិ** ។ ដោយពាក្យថា **សតិ** នោះ

ឯង ឈ្មោះថា អនុស្សតិនោះ លោកសម្ដែងថា **អនុ** ស័ព្ទនេះ ជាស័ព្ទដែលមិនមានអត្ថដទៃ ដូចគ្នានឹង **ឧប** ស័ព្ទ ក្នុងពាក្យថា **ឧបលព្ភតិ** ជាដើម ហើយនឹងជាស័ព្ទដែលប្រាប់អត្ថន័យ ដូចគ្នានឹង **សំ** ស័ព្ទ ជាដើម ក្នុងពាក្យថា **សញ្ញានំ** ការដឹងព្រម **បជានំ** ការដឹងដោយប្រការផ្សេងៗ ជាដើម ក៏ទេ ។ ពាក្យថា **ព្រោះការដែលប្រព្រឹត្តទៅ ក្នុងឋានៈដែលគួរធ្វើឲ្យប្រព្រឹត្តទៅនោះឯង** នេះលោកពោលដល់ភាពដែលអនុស្សតិសមគួរដល់ឋានៈដែលគួររឭកដល់ ព្រោះហេតុនោះដើម្បីសម្ដែងភាវៈដែលសមគួរដល់កុលបុត្ត ដែលគប្បីធ្វើឲ្យប្រព្រឹត្តទៅនោះឯង , លោកទើបពោលថា ( ជាសតិ )ដែលសមគួរដល់កុលបុត្តនោះ , ម្យ៉ាងទៀត ឈ្មោះថា ភាពជាសតិសមគួរដល់កុលបុត្តដែលបួសដោយសទ្ធា ។ រមែងមានបាន ព្រោះភាពជាសតិដែលសមគួរដល់ឋានៈ ដែលគួរធ្វើឲ្យប្រព្រឹត្តទៅនោះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលដល់ភាពជាសតិដែលសមគួរដល់កុលបុត្ត ដែលធ្វើឲ្យប្រព្រឹត្តទៅ តែមួយចំណែក មិនមែនដល់ទាំង ២ ចំណែក ( គឺ ទាំងកុលបុត្តដែលធ្វើឲ្យប្រព្រឹត្តទៅ ទាំងឋានៈដែលគួរធ្វើឲ្យប្រព្រឹត្តទៅ ) ។ ពាក្យថា **សមគួរ** មានន័យថា សមរម្យ ។ បញ្ញត្តិថា **ព្រះពុទ្ធ** ចំពោះព្រះដ៏មានព្រះភាគ ប្រព្រឹត្តទៅអាស្រ័យដោយគុណពួកណា លោកអាចារ្យរួមយកព្រះគុណទាំងនោះ ចូលជាមួយគ្នា ពោលថា **ព្រះពុទ្ធ** ព្រោះហេតុនោះ ទើបលោកពោលថា ពាក្យថា **ពុទ្ធានុស្សតិ** នេះ ជាឈ្មោះនៃសតិដែលមានព្រះពុទ្ធគុណជាអារម្មណ៍ ។ ពាក្យថា **ប្រារព្ធ** គឺ ផ្គងទុក ។ ពាក្យថា **ព្រះធម៌** គឺ លោកុត្តរធម៌ទាំង ៩ យ៉ាង ព្រមទាំងព្រះបរិយត្តិធម៌ ។ សួរថា លោកពោលព្រះនិព្វានទុកដោយភាពជាកម្មដ្ឋានម្យ៉ាងដាច់ដោយឡែក មិនមែនឬ ? ឆ្លើយថា លោកពោលព្រះនិព្វានទុកដោយភាពជា

កម្មដ្ឋានមយ៉ាង ដាច់ដោយឡែកក៏ពិត សូម្បីយ៉ាងនោះ ក៏គប្បីឃើញថា ការដែលលោកកាន់យកព្រះនិព្វាននោះ ចូលទុកក្នុងធម្មានុស្សតិកម្មដ្ឋាន ក៏ព្រោះព្រះនិព្វានព្រមទាំង មគ្គ និង ផល លោកសង្គ្រោះចូលក្នុងធម្មានុស្សតិកម្មដ្ឋាននេះបាន ដោយព្រះបាលីថា ដោយការស្មើគ្នាក្នុងភាពជាព្រះធម៌ ចំណែកការដែលលោកធ្វើការកាន់យកព្រះនិព្វាននោះ ដោយភាពជាកម្មដ្ឋានមយ៉ាងដទៃទៀត ក៏ព្រោះភាវៈដែលព្រះនិព្វាននោះ ផ្សេងពីមគ្គនិងផល ដោយភាពជាអសង្ខតធម៌ ជាអមតធម៌ ជាដើម ។ មយ៉ាងវិញទៀត ការដែលលោកកាន់យកអនុស្សតិ ៣ មានសីលានុស្សតិជាដើម ដោយភាពជាកម្មដ្ឋានតែមយ៉ាង ក៏ព្រោះ សីល ចាគៈ និងគុណទាំងឡាយមានសទ្ធាជាដើម ជារបស់ខ្លួនប៉ុណ្ណោះ ដែលព្រះយោគីគួរនឹងកាន់យកដោយភាពជាទីតាំងនៃអនុស្សតិបាន ។ ពាក្យថា **ទៅកាន់រូបកាយ** គឺ ប្រព្រឹត្តទៅ ប្រារព្ធករជកាយរបស់ខ្លួន ដោយទាក់ទងក្នុងការធ្វើឲ្យជាអារម្មណ៍ ។ ពាក្យថា **ក្នុងកាយ** បានដល់ ក្នុងកាយដែលជាអារម្មណ៍ ។ ពាក្យថា **ដែលមាននិមិត្តក្នុងកោដ្ឋាសជាអារម្មណ៍** គឺ ដែលមានបដិកូលនិមិត្តក្នុងកោដ្ឋាសទាំងឡាយ មានសក់ជាដើម ជាអារម្មណ៍ ។ លោកប្រើសព្ទថា **និមិត្ត** ក៏ដើម្បីសម្តែងថា ក្នុងអនុស្សតិ ៧ មុនកាយគតាសតិនេះ មិនមានការកើតឡើងនៃនិមិត្ត , ក្នុងកាយគតាសតិនេះ មានការកើតឡើងនៃនិមិត្ត ។ សូម្បីក្នុងពាក្យថា ដែលមាននិមិត្តក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ជាអារម្មណ៍ ក៏យ៉ាងនោះដូចគ្នា ។ ពាក្យថា **ឧបសមធម៌** មានន័យថា ព្រះនិព្វាន ដែលមានការចូលទៅស្ងប់សង្ខារទាំងពួង ។

សេចក្តីជ្រះថ្លាមិនកម្រើក ដែលកើតឡើង ព្រោះជ្រាបនូវព្រះពុទ្ធគុណទាំង-ឡាយតាមសេចក្តីពិត ឈ្មោះថា **អវេច្ចប្បសាទោ** ប្រែថា មានសេចក្តីជ្រះថ្លាមិន

ញាប់ញ័រ បានដល់ សេចក្ដីជ្រះថ្លាដែលមកហើយដោយព្រះអរិយមគ្គ ឬសូម្បីដែលដូចគ្នានឹងសេចក្ដីជ្រះថ្លាដែលមកហើយដោយអរិយមគ្គនោះ ជាសេចក្ដីជ្រះថ្លាដែលមិនញាប់ញ័រព្រោះវាទៈនៃមិច្ឆាទិដ្ឋិទាំងឡាយ ដែលវាទៈនៃមិច្ឆាទិដ្ឋិទាំងឡាយមិនអាចធ្វើឲ្យកម្រើកញាប់ញ័របាន បានដល់ ព្រះយោគាវចរដែលដល់ព្រមដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រនោះ ។ ការចម្រើននូវពុទ្ធានុស្សតិ នឹងសម្រេចបានសម្រាប់ព្រះយោគាវចរដែលមានសភាពដូច្នោះ មិនមែនសម្រាប់ព្រះយោគីក្រៅពីនេះឡើយ ។ ពាក្យថា **ក្នុងសេនាសនៈដែលសមរម្យ** គឺ ក្នុងសេនាសនៈដែលប្រកបដោយអង្គ ៥ វៀរចាកទោស ១៨ យ៉ាង តាមដែលបានពោលហើយ ( ក្នុងបឋវីកសិណនិទ្ទេស ) ។

បទថា **រហោគតេន** ប្រែថា ទៅក្នុងទីកំបាំង ។ ពាក្យថា **រហោគតេន** នោះលោកសម្ដែងដល់កាយវិវេក ។ ពាក្យថា **គេចចេញ** បានដល់ ពួនសម្ងំអំពីអារម្មណ៍ផ្សេង ៗ គឺ ចៀសចេញអំពីអារម្មណ៍ដែលមានសភាពអ៊ូអែក្នុងខាងក្រៅ ហើយសម្ងំនៅក្នុងកម្មដ្ឋាន មានន័យថា ជាអ្នកមានចិត្តប្រមូលទុកដោយល្អ ។ ស័ព្ទថា **ឯវំ** បានដល់ តាមន័យដែលពោលមកហើយក្នុងព្រះបាលីនោះ ។ ក្នុងពាក្យថា **សោ ភគវា** ( ព្រះដ៏មានព្រះភាគអង្គនោះ ) នេះមានវិនិច្ឆ័យដូច្នេះ បទថា **សោ** ( អង្គនោះ ) បានដល់ ព្រះអង្គទ្រង់បានបំពេញព្រះបារមី ៣០ គ្រប់ចំនួនបរិបូរណ៍ហើយ កាច់បំបាក់កិលេសទាំងពួងបានហើយ ត្រាស់ដឹងនូវព្រះសម្មាសម្ពោធិដ៏កំពូល ទ្រង់ជាទេពក្រៃលែងជាងពួកទេព ជាព្រហ្មក្រៃលែងជាងពួកព្រហ្ម ជាទីពឹងរបស់សត្វលោក ទ្រង់ជាអ្នកមានព្រះកិត្តិស័ព្ទដែលផ្សាយទូទៅថា **ព្រះភគវា** ក្នុងលោក ព្រមទាំងទេវលោកដោយហេតុទាំងឡាយ មានភាពជាព្រះភាគ្យជាដើម ។ បទថា **ភគវា** ( ព្រះដ៏មាន

ព្រះភាគ ) នេះជាពាក្យសរសើរព្រះសាស្តាដោយព្រះនាម ។ ពិតយ៉ាងនោះ ព្រះសារីបុត្តត្ថេរបានពោលទុកថា " **ភគវាតិ នេតំ នាមំ មាតរា កតំ** " ពាក្យថា **ភគវា** នេះ មិនមែនព្រះនាមដែលព្រះជននីទ្រង់តាំងឲ្យ ដូច្នេះជាដើម ។ ចំណែកបទថា **ភគវា** តទៅខាងមុខ ជាពាក្យសរសើរព្រះសាស្តា ដោយគុណ ។ លោកអាចារ្យកាលនឹងសម្តែងថា ក្នុងឋានទាំង ៩ មានបទថា **អរហំ** ជាដើម គប្បីរឭករឿយៗដល់ព្រះពុទ្ធគុណដោយប្រកប **ឥតិ** ស័ព្ទ ចូលទុកតែមួយឋាន , ដូច្នេះទើបពោលថា " រមែងរឭករឿយៗថា " ( **សោ ភគវា** ) **ឥតិបិ អរហំ ។បេ។ ឥតិបិ ភគវា** ដូច្នេះ ។ **ឥតិ** ស័ព្ទ មានអត្ថថា ជាហេតុជិត ឃើញបានប្រចក្ស ដូចក្នុងប្រយោគថា " **ឥតិបេតំ ភូតំ ឥតិបេតំ តច្ឆំ** " ដូច្នេះ ជាដើម ។ **បិ** ស័ព្ទ មានអត្ថថា រួបរួម ។ ដោយ **បិ** ស័ព្ទនោះ ជាការសម្តែងដល់ភាវៈដែលព្រះគុណទាំងនោះ មានច្រើនសន្ធឹកសន្ធាប់ និងសម្តែងដល់ហេតុនៃការកំណត់ព្រះគុណទាំងនោះ លោកអាចារ្យ កាលនឹងសម្តែងថា ព្រះយោគាវចរដែលចម្រើនគួរធ្វើព្រះគុណទាំងឡាយ ឲ្យប្រាកដចំពោះមុខ ទើបពោលថា ជាការពោលអធិប្បាយបានថា ព្រោះហេតុនេះ និង ព្រោះហេតុនេះ ដូច្នេះ ។

ដែលឈ្មោះថា **នៅទីឆ្ងាយ** លោកពោលប្រៀបធៀបគ្នា ដូចគ្នានឹងទីជិត ព្រោះហេតុនោះ កាលនឹងសម្តែងការនៅទីឆ្ងាយដែលដល់នូវភាពខ្ពង់ខ្ពស់ក្រៃលែង ទើបលោកអាចារ្យពោលថា **ក្នុងទីឆ្ងាយ** ដូច្នេះ មានន័យថា **ក្នុងទីឆ្ងាយ** ដោយភាពជាទីឆ្ងាយនោះឯង ។ លោកអាចារ្យកាលនឹងសម្តែងថា ព្រោះព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់នៅក្នុងទីឆ្ងាយអំពីកិលេសនោះ ព្រោះទ្រង់លះបង់កិលេសទាំងនោះបានដោយប្រការទាំងពួងហើយ ទើបពោលថា **ព្រោះព្រះអង្គទ្រង់ញ៉ាំញីកិលេស**

**ទាំងឡាយ ( ព្រមទាំងវាសនា ) បានហើយដោយមគ្គ** ។ លោកអាចារ្យជណ្តឹងសួរក្នុងចិត្តថា កិលេសទាំងនោះ សូម្បីព្រះខីណាស្រពទាំងឡាយដទៃ ៗ ក៏លះបង់បានដូចគ្នា មិនមែនឬ ? ដូច្នេះហើយទើបពោលថា ព្រមទាំងវាសនា ។ ពិតណាស់ វៀរព្រះដ៏មានព្រះភាគចេញ ព្រះខីណាស្រពដទៃមិនអាចនឹងលះបង់កិលេស ព្រមទាំងវាសនាបានឡើយ ដោយពាក្យថា ព្រមទាំងវាសនានេះ លោកពោលសំដៅដល់ ព្រះអរហត្ត ( ភាពជាព្រះអរហន្ត ) របស់ព្រះដ៏មានព្រះភាគ មិនមែនជាសាធារណៈដល់ព្រះខីណាស្រពដទៃ ។ ដែលឈ្មោះថា វាសនានោះ គឺអ្វី ? គឺអំណាចពិសេសដែលតាំងចុះព្រោះកិលេស ដែលជាហេតុនៃប្រយោគ ( ការប្រព្រឹត្តផ្លូវកាយនិងវាចា ) ដូចគ្នានិងប្រយោគរបស់បុគ្គលដែលនៅលះបង់កិលេសមិនទាន់បាន នៃព្រះខីណាស្រពដែលជាអ្នកលះបង់កិលេសបានហើយ ដូចជាហេតុនៃការបន្ទឺវាចាថា បុគ្គលថោកទាប របស់ព្រះបិលិន្ទវច្ឆ ដូច្នោះ ។

សួរថា កាលពោលពាក្យថា " **ព្រោះភាពជាអ្នកឆ្ងាយ** " ដូច្នេះហើយ នឹងបានសេចក្តីថា " **ចាកកិលេសទាំងឡាយ** " នេះ បានដូចម្តេច ?

ឆ្លើយថា ព្រោះពាក្យនិយាយដែលជាសាមញ្ញជោតនា ( ចុះបញ្ជាំងអត្ថន័យសាមញ្ញ ) តាំងចុះបានក្នុងអត្ថន័យពិសេស និង ដែលត្រូវការអត្ថន័យពិសេស គប្បីសាកសួរដល់អត្ថន័យពិសេស, បទទាំងឡាយក្នុងព្រះសូត្រដែលថា " អកុសលធម៌ទាំងឡាយដ៏លាមក រមែងជាធម្មជាតិនៅក្នុងទីឆ្ងាយអំពីភិក្ខុនេះ " ដូច្នេះជាដើម គប្បីលើកឡើងជាឧទាហរណ៍ក្នុងរឿងទាំងនេះបាន ។

ក៏ក្នុងបទថា **អារកា** ( អ្នកឆ្ងាយ ) នេះ គប្បីជ្រាបថា ព្រោះលោកធ្វើ **អា** អក្សរ ឲ្យជា រស្សៈ គឺ **អ** , និងធ្វើ **ក** អក្សរ ឲ្យជា **ហ** អក្សរ មាននិគ្គហិត ទើបសម្រេចបទថា **អរហំ** បានដោយនិរុត្តិន័យ ។ ដើម្បីកាន់យកដោយងាយនូវអត្ថន័យដែលបានពោលហើយនោះឯង លោកអាចារ្យទើបពោលប្រព័ន្ធគាថា ថា **សោ តតោ អារកា នាម** ជាដើម ។ ក្នុងបទទាំងនោះ បទថា បុគ្គលមានប្រក្រតីដល់ព្រម ឈ្មោះថា **សមង្គី** ព្រោះហេតុនោះ ភាពមិនជាអ្នកមានប្រក្រតីព្រមព្រៀង គឺការមិនប្រកបព្រម ការមិនប្រព្រឹត្តទៅព្រមគ្នា ( នឹងកិលេស ) ។ កិលេសនោះឯង ឈ្មោះថា **អរិ** ព្រោះនាំទៅកាន់ភាពវិនាស ព្រោះហេតុនោះ ទើបឈ្មោះថា **កិលេសារិ** ( **អរិ** គឺ កិលេស ) ។ កាលគួរនឹងពោលថា “ **អរិហា** ” ព្រោះកម្ចាត់អរិទាំងឡាយបាន លោកក៏ត្រឡប់ពោលថា **អរហំ** ដោយនិរុត្តិន័យ ។

ភ្ជាប់សេចក្ដីថា **យទេតំ សំសារចក្កំ** ( សង្សារចក្កនេះបាន ) ។

ធម្មជាតិទាំង ២ គឺ អវិជ្ជា និង ភវតណ្ហាដែលជាអង្គប្រកប ដែលជាមូលដែលប្រជុំចុះព្រមគ្នា ទាំងខាងក្នុង និងខាងក្រៅ ប្រៀបដូចដុំរទេះ ព្រោះហេតុនោះ ទើបលោកពោលថា ដែលមានដុំ គឺ អវិជ្ជា និង ភវតណ្ហា ដូច្នេះ , អភិសង្ខារ មាន បុញ្ញាភិសង្ខារជាដើម ដែលមានអវិជ្ជានិងតណ្ហាជាបច្ច័យ រួមនឹង ជរា និង មរណៈជាផល ដូចជាកាំដែលភ្ជាប់ដុំទៅនឹងខ្នងកង់ ព្រោះហេតុនោះ ទើបលោកពោលថា អភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម ជាកាំ ។ ជរានិងមរណៈ ប្រាកដភាពជាទីបំផុតជុំវិញ ក្នុងភពនោះៗ ព្រោះហេតុនោះ លោកទើបឧបមា ជរាមរណៈនោះ ឲ្យឋិតនៅក្នុងឋានៈជាខ្នងកង់ ហើយពោលថា មានជរាមរណៈជាខ្នងកង់ ។ ឯភ្លៅជាហេតុ ជាប្រធានក្នុងការវិលទៅនៃកង់រថយ៉ាងណា អាសវសមុទយៈ ក៏ជា

ហេតុ ជាប្រធាននៃការវិលទៅនៃកង់ គឺ សង្សារវដ្ត ដូច្នោះដែរ ព្រោះហេតុនោះ ទើបលោកពោលថា **ដែលប្រើភ្លៅធ្វើដោយអាសវសមុទយៈ ស៊កចូលហើយ** ។ អាសវៈនោះឯង ឈ្មោះថា **អាសវសមុទយៈ** ព្រោះជាហេតុនៃធម៌ទាំងឡាយ មាន អវិជ្ជាជាដើម ។ ដូចដែលទ្រង់ត្រាស់ទុកថា **អាសវសមុទយា អវិជ្ជាសមុទយោ** ព្រោះមានអាសវៈជាហេតុ អវិជ្ជាទើបកើតឡើង ។ ភពទាំង ៣ មានកាមភពជាដើម ដែលផ្សេងដោយវិបាក និងកដត្តារូប ( កម្មជរូប ) នោះឯង ឈ្មោះថា **រថ** បានដល់ **រថ** គឺ ភពទាំង ៣ នោះ ។ ឈ្មោះថា **សមា យោជិតំ** ( ប្រកបទុក ) ព្រោះអត្ថថា ប្រកបស្មើគ្នា ឬ ដោយប្រការទាំងពួង មកតាំងអំពីដើមដោយបច្ច័យទាំងឡាយ របស់ខ្លួន ។ ឈ្មោះថា **អនាទិកាលប្បវត្តំ** ព្រោះធ្វើវចនត្ថៈថា **អាទិរហិតំ កាលំ បវត្តិ** ប្រព្រឹត្តទៅមិនមានទីបំផុតខាងដើម ។

សង្សារវដ្ត ដែលលោកពោលទុកយ៉ាងនេះថា ៖

លំដាប់ដែលប្រព្រឹត្តទៅមិនដាច់ខ្សែនៃ ខន្ធ ធាតុ និង អាយតនៈ ទាំងឡាយ ហៅថា **សង្សារវដ្ត** ។

ដូច្នោះ ឈ្មោះថា **សង្សារចក្រ** “ កង់ គឺ សង្សារវដ្ត ” ។

បទថា **អនេន** បានដល់ ព្រះដ៏មានព្រះភាគអង្គនោះ ។ បទថា **ពោធិមណ្ឌេ** បានដល់ ក្នុងស្ថានទី ឬវេលាដែលដល់នូវភាពជាដែននៃព្រះញាណ ដែលហៅថា ការត្រាស់ដឹង ។ ពាក្យថា **ព្រះបាទ** គឺ វិរិយៈ បានដល់ ព្រះបាទ គឺ វិរិយៈរបស់ ព្រះអង្គដែលប្រព្រឹត្តទៅដោយអាការ ២ ព្រោះការដែលមានកិច្ចការពារធម៌ទាំង-ឡាយ ដែលជាបក្ខពួកនៃសេចក្តីសៅហ្មង និងប្រជុំចុះក្នុងធម៌ទាំងឡាយដែលជា ចំណែកនៃសេចក្តីផូរផង់ ។ ពាក្យថា **លើផែនដី គឺ សីល** មានន័យថា សីលនោះ

ឯង ឈ្មោះថា ផែនដី ដោយន័យថា ជាទីតាំង បានដល់ លើផែនដី គឺ សីល នោះ ។ ពាក្យថា **ឈរ** មានន័យថា ឈ្មោះថា **ឈរ** ក៏ទាក់ទងនឹងការធ្វើឲ្យដល់ព្រម ។ ពាក្យថា **ព្រះហស្ត** គឺ សទ្ធា មានន័យថា សទ្ធានោះឯង ឈ្មោះថា **ព្រះហស្ត** ព្រោះឲ្យសម្រេចនូវការកាន់យកធម៌ដែលមិនមានទោស បានដល់ ព្រះហស្ត គឺ សទ្ធានោះ ។ ពាក្យថា **ដែលធ្វើឲ្យអស់ទៅនូវកម្ម** បានដល់ ដែលធ្វើកម្មឲ្យអស់ទៅ ព្រោះរំលត់កម្ម ដែលផ្សេងដោយកាយកម្មជាដើម ទាំងពួង ។ ពាក្យថា **ចាប់ពូថៅ** គឺ ព្រះញាណ បានដល់ ចាប់ពូថៅ គឺ ព្រះមគ្គញ្ញាណដែលសំលៀងល្អហើយដោយថ្ម គឺ សមាធិ ។

ក្នុងការទម្លាយកម្មដែលលោកពោលទុកក្នុងពាក្យថា " **ព្រោះការដែលទ្រង់កម្ចាត់អរៈ**( កាំ ) " នេះ លោកអាចារ្យកាលធ្វើពាក្យប្រកបសេចក្តីដោយកាន់យកថា សង្សារវដ្ត ដូចជាចក្រ ទើបឈ្មោះថា **ចក្រ** ដូច្នេះ យ៉ាងនេះហើយ ឥឡូវនេះ បំណងសម្តែងសង្សារចក្រនោះ សូម្បីដោយលំដាប់នៃទេសនាក្នុងបដិច្ចសមុប្បាទ ទើបពោលថា **ន័យម្យ៉ាងទៀត** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **សង្សារវដ្តដែលមានទីបំផុតបុគ្គលដឹងមិនបាន** គឺ វដ្តសង្សារ មានទីបំផុតដែលនរណាៗតាមដឹងមិនបាន ។ ឈ្មោះថា ធម៌ ១០ ដ៏សេស បានដល់ ធម៌ទាំងឡាយមានសង្ខារជាដើម មានជាតិជាទីបំផុត ចាត់ជាកាំ ។ តើដូចម្តេច ? លោកអាចារ្យកាលនឹងសម្តែងធម៌ ១០ ដ៏សេស ចាត់ជា កម្ម , ព្រោះ ដុំ ទាក់ទងជាមួយអវិជ្ជាដោយជាមូល ខ្នងកង់ទាក់ទងជាមួយនឹងជរាមរណៈជាទីបំផុត ទើបពោលថា **ព្រោះមានអវិជ្ជាជាមូល និង ជរាមរណៈជាទីបំផុត** ។ ពាក្យថា **ក្នុងសច្ចៈ ៤ មានទុក្ខជាដើម** គឺ ក្នុង ទុក្ខ សមុទយៈ និរោធ និង មគ្គ ។ ក្នុងសច្ចៈ ៤ ទាំងនោះ **អវិជ្ជា**

ឈ្មោះថា ការមិនដឹងក្នុងទុក្ខ ព្រោះជាសភាវៈដែលឈានចុះកាន់សេចក្ដីទុក្ខនោះ និង ព្រោះជាការបិទបាំងទុក្ខនោះ , **អវិជ្ជា** ឈ្មោះថា ការមិនដឹងក្នុងសច្ចៈដ៏សេស ក៏ ព្រោះជាការបិទបាំងតែម្យ៉ាង ។ ពាក្យថា **ទុក្ខ** ក្នុងទីនេះបំណងយកទុក្ខអរិយសច្ច ព្រោះហេតុនោះ លោកអាចារ្យ កាលនឹងចែកទុក្ខនោះចេញជា ៣ យ៉ាង ដោយ ទាក់ទងនឹងភព មានកាមភពជាដើម ហើយសម្ដែងអវិជ្ជាដែលជាតួបិទបាំងទុក្ខនោះ ដោយអាការនោះ និងធម៌ មានសង្ខារជាដើមក្នុងភព ៣ ដែលមានអវិជ្ជាជាដើម ជាបច្ច័យទៅតាមលំដាប់ ទើបលោកពោលថា **អវិជ្ជាក្នុងកាមភព** ជាដើម ។ ក្នុង ពាក្យទាំងនោះ ពាក្យថា **អវិជ្ជាក្នុងកាមភព** គឺ អវិជ្ជាដែលជាតួបិទបាំងទោសក្នុង កាមភព ។ សូម្បីក្នុងពាក្យនេះ ដែលថា **អវិជ្ជាក្នុងរូបភព អរូបភព** ក៏មានន័យ ដូច្នេះឯង ។ ពាក្យថា **ដល់សង្ខារទាំងឡាយក្នុងកាមភព** គឺ ដល់សង្ខារទាំងឡាយ ដែលទាក់ទងក្នុងកាមភូមិ , ម្យ៉ាងទៀត មានន័យថា សង្ខារពួកណា ដែលបុគ្គល គប្បីធ្វើឲ្យសម្រេចក្នុងកាមភព ក៏បានដល់សង្ខារដែលជាតួធ្វើការឧប្បត្តិក្នុងកាមភព ឲ្យកើតឡើងទាំងនោះ ។ ពាក្យថា **រមែងជាបច្ច័យមុនគេ** រមែងជាបច្ច័យដល់បុញ្ញា-ភិសង្ខារដោយអាការ ២ គឺ ដោយអារម្មណប្បច្ច័យ និងដោយឧបនិស្សយប្បច្ច័យ ។ ក្នុងបណ្ដាអបុញ្ញាភិសង្ខារទាំងឡាយ រមែងជាបច្ច័យដល់អបុញ្ញាភិសង្ខារដែលកើត ព្រមគ្នា ដោយអំណាចសហជាតប្បច្ច័យជាដើម ដល់អបុញ្ញាភិសង្ខារដែលមិនបាន កើតព្រមគ្នា ដោយអំណាចអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យជាដើម តែថា រមែងជា បច្ច័យដល់សង្ខារដែលមិនមានក្នុងលំដាប់ ( គឺ មិនបានកើតក្នុងលំដាប់បន្ទាប់ពីការ រលត់ទៅរបស់ខ្លួន ) ដោយអំណាចអារម្មណប្បច្ច័យ និង ឧបនិស្សយប្បច្ច័យ ។ ពាក្យថា **ដល់សង្ខារទាំងឡាយក្នុងអរូបភព** គឺ ដល់អនេញ្ជាភិសង្ខារទាំងឡាយ

ឈ្មោះថា **រមែងជាបច្ច័យ** ក៏ដោយអំណាចឧបនិស្សយប្បច្ច័យតែម្យ៉ាង ។ ក៏ក្នុងទីនេះ កាលនឹងពង្រីកសេចក្តីនេះឲ្យពិស្តារ ការឃើតយូរនឹងមានបាន តែថា អត្ថន័យពិស្តារនោះ នឹងមានមកដល់ក្នុងខាងមុខ ព្រោះដូច្នោះ ខ្ញុំព្រះករុណា មិនពង្រីកសេចក្តីឲ្យពិស្តារទេ ។

ពាក្យថា **ដល់អាយតនៈ ៣** គឺដល់ ចក្ខាយតនៈ សោតាយតនៈ និងមនាយតនៈ ។ ពាក្យថា **ដល់អាយតនៈ ១** គឺ មនាយតនៈ ។ ការចែកធម៌ទាំងឡាយមានផស្សៈជាដើម ក៏គប្បីជ្រាបដោយន័យនេះចុះ ។ ពាក្យថា **តណ្ហានោះៗ ក្នុងភពនោះៗ** បានដល់ តណ្ហាដែលមានប្រភេទជារូបតណ្ហាជាដើម ដែលកើតឡើងក្នុងភពនោះៗ មានកាមភពជាដើម ។ ពាក្យពោលដែលមានតណ្ហាជាដើម ជាមូលដោយសង្ខេប ព្រោះហេតុនោះ លោកអាចារ្យបំណងសម្តែងពាក្យពោលនោះផងឧបាទាននិងភពផង ចែកឲ្យពិស្តារ ទើបពោលថា “ គឺ យ៉ាងដូចម្តេច ” ជាដើម ។ ក្នុងពាក្យទាំងនោះ ដោយពាក្យថា **យើងនឹងបរិភោគកាម** នេះ លោកពោលដល់ការប្រព្រឹត្តទៅនៃកាមតណ្ហា ។ ពាក្យថា **យើងនឹងសោយសម្បត្តិសួគ៌** ជាដើម ក៏ដូច្នោះ ក៏ព្រោះហេតុដែលតណ្ហាប្រព្រឹត្តទៅដោយអំណាចការប្រកាន់មាំ ទើបឈ្មោះថា ជាកាមុបាទាន ដូច្នោះ ទើបលោកពោលថា ព្រោះកាមុបាទានជាបច្ច័យ ។ បទថា **តថេវ** គឺ ព្រោះកាមុបាទានជាបច្ច័យនោះឯង ។ ពាក្យថា **សម្បត្តិក្នុងព្រហ្មលោក** គឺ សម្បត្តិក្នុងលោកជាន់រូបព្រហ្ម ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា សូម្បីភវរាគៈក៏ជាកាមុបាទានដែរ ព្រោះមានពាក្យពោលថា ធម៌ដែលមានក្នុងភូមិ ៣ ទាំងអស់ឈ្មោះថា **កាម** ព្រោះមានអត្ថថា ដែលសត្វទាំងឡាយ គប្បីប្រាថ្នា , ហើយទើបពោលថា ព្រោះកាមុបាទានជាបច្ច័យនោះឯង ទើបចម្រើនមេត្តាជាដើម ។

តទៅនេះ ជាពាក្យប្រកបសេចក្តី ក្នុងពាក្យថា ក្នុងពាក្យប្រកបសេចក្តី សូម្បីដែលមានឧបាទានដ៏សេសជាមូលនេះ គឺ គប្បីប្រកបពាក្យពោលតាមន័យដែលបានពោលហើយថា មនុស្សខ្លះក្នុងលោកនេះ ប្រកាន់ដោយនត្ថិកទិដ្ឋិថា " លោកខាងមុខមិនមាន " គេ ព្រោះទិដ្ឋុបាទានជាបច្ច័យ ទើបប្រព្រឹត្តទុច្ចរិតដោយកាយជាដើម។

គប្បីប្រកបពាក្យពោលតាមន័យដែលបានពោលហើយ នោះៗឯងថា ៖

បុគ្គលពួកមួយទៀត រមែងប្រកាន់ដោយឧច្ឆេទទិដ្ឋិ ថា " អត្តានឹងដាច់សូន្យក្នុងសម្បត្តិភពនោះ " គេរមែងប្រព្រឹត្តសុចរិតដោយកាយ ដើម្បីការចូលដល់ក្នុងភពនោះ ដូច្នេះជាដើម ។

បុគ្គលមួយពួកទៀតគិតថា " អត្តាជារបស់មាន រូបសម្រេចដោយចិត្តរមែងដាច់សូន្យ " ហើយរមែងចម្រើនមគ្គដើម្បីការចូលដល់រូបភព ។

ពាក្យទាំងអស់ដែលថា ព្រោះការបរិបូរណ៍នៃភាវនាជាដើម គប្បីជ្រាបតាមន័យដែលបានពោលហើយនោះចុះ ។

បុគ្គលមួយពួកទៀតគិតថា " អត្តាកើតឡើងក្នុងអរូបភពហើយ រមែងដាច់សូន្យ " ដូច្នេះហើយ រមែងចម្រើនមគ្គដើម្បីចូលដល់អរូបភព ។ ពាក្យទាំងអស់ដែលថា **ព្រោះការបរិបូរណ៍នៃភាវនាជាដើម** គប្បីជ្រាបតាមន័យដែលពោលហើយនោះចុះ ។

គប្បីឃើញថា ជាការដែលលោកពណ៌នាពាក្យប្រកបសេចក្តី ដែលមានអត្តវាទុបាទានជាមូល ទុកដោយទិដ្ឋិទាំងនោះឯង ។

គប្បីជ្រាបពាក្យប្រកបសេចក្តី សូម្បីទាក់ទងនឹងទិដ្ឋធម្មនិព្វានវាទតាមប្រការដែលបានពោលមកនេះចុះ ។

គប្បីប្រកបសេចក្តីនៃពាក្យពោលទាំងអស់ តាមន័យដែលបានពោលហើយនោះឯងថា បុគ្គលមួយពួកទៀត កាលប្រកាន់វត្តបដិបត្តិដែលមិនមែនជាផ្លូវបរិសុទ្ធថាជា "ផ្លូវបរិសុទ្ធ" ដោយន័យថា "**សេចក្តីបរិសុទ្ធិមានបានដោយសីល**" ជាដើម ព្រោះមានសីលព្វតុបាទានជាបច្ច័យ ទើបប្រព្រឹត្តទុច្ចរិតដោយកាយដូច្នេះ ជាដើម ។

ការៈដែលធម៌ទាំងឡាយ មានអវិជ្ជាជាដើម ជាបច្ច័យ និង ការៈដែលធម៌ទាំងឡាយ មានសង្ខារជាដើមជាបច្ចយុប្បន្នៈ ដែលលោកអាចារ្យសម្តែងនូវសង្សារចក្រ បានសម្តែងទុកដោយពាក្យថា អវិជ្ជាក្នុងកាមភព រមែងជាបច្ច័យដល់សង្ខារទាំងឡាយក្នុងកាមភព ដូច្នេះជាដើម នេះឯណា ឥឡូវនេះលោកអាចារ្យ កាលនឹងនាំយកព្រះបាលី បដិសម្ភិទាមគ្គ មកសម្តែងដល់ការៈដែលជាបច្ច័យ និងការៈដែលជាបច្ចយុប្បន្នៈនោះឯង ដោយទាក់ទងនឹងពាក្យពោលបញ្ចាក់ លោកទើបពោលថា **ឯវមយំ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ សេចក្តីថា សង្ខារទាំងឡាយកើតឡើងព្រោះហេតុឯណា សូម្បីអវិជ្ជាក៏ជាធម៌ដែលមានហេតុ ដោយហេតុ មានកាមាសវៈជាដើមនោះឯង ព្រោះហេតុនោះ ទើបលោកពោលថា ធម៌ទាំង ២ នេះ កើតឡើងព្រោះហេតុ ។ ពាក្យថា **ក្នុងការកំណត់កាន់យកបច្ច័យ** គឺ ក្នុងការកំណត់កាន់យកនូវធម៌ទាំងឡាយ មានអវិជ្ជាជាដើម ដែលជាបច្ច័យនៃនាមរូប ជាសត្តមីវិភត្តិក្នុងអត្ថថា គប្បីធ្វើឲ្យសម្រេច ។ ពាក្យថា **បញ្ញា** បានដល់ ការដឹងដោយប្រការទាំងពួង ដែលហៅថា **កង្ខាវិតរណវិសុទ្ធិ** ។ ពាក្យថា **ធម្មដ្ឋិតិញ្ញាណ** បានដល់ការដឹងបដិច្ចសមុប្បាទធម៌ , ធម្មដ្ឋិតិញ្ញាណនេះ ព្រោះហេតុដែលប្រព្រឹត្តទៅ ដោយទាក់ទងជាមួយការឆ្លងនូវមន្ទិល គឺ សេចក្តីសង្ស័យក្នុងកាលទាំង ៣ ដូច្នោះ ទើបលោកពោលថា សូម្បីក្នុងអតីតកាល ដូច្នេះជាដើម ។ ពាក្យថា **ដោយន័យនេះ** គឺ

ដោយន័យដែលពោលទុកក្នុងអវិជ្ជា ដោយពាក្យថា “ អវិជ្ជាជាហេតុ ” ជាដើមនេះ ។ ក្នុងបទទាំងពួង គប្បីអធិប្បាយឲ្យពិស្តារ ក្នុងន័យថា “ សង្ខារទាំងឡាយជាហេតុ វិញ្ញាណកើតឡើងព្រោះហេតុ ” ដូច្នេះជាដើមចុះ ។ ហេតុ និង វិបាក ឈ្មោះថា “ **សង្ខេប** ” ព្រោះអត្ថថា ជាទីបំព្រួញយកធម៌ មានអវិជ្ជាជាដើម និងធម៌មាន វិញ្ញាណជាដើមទុក ។ ម្យ៉ាងទៀត **ធម៌** មានអវិជ្ជាជាដើម និង **ធម៌** មានវិញ្ញាណ ជាដើម ឈ្មោះថា “ **សង្ខេប** ” ព្រោះអត្ថថា ត្រូវបំព្រួញថា ជាហេតុនិងវិបាក ។ តែគប្បីឃើញថា លោកធ្វើទុកជាឯកវចនៈ “ **សង្ខេបោ** ” ក៏ព្រោះ ការដែលធម៌ មានអវិជ្ជាជាដើមទាំងនោះ មានសង្ខេបស្មើគ្នា ។ ម្យ៉ាងវិញទៀត សង្ខេបទាំងនោះ មាន ៤ ក៏ដោយចែកតាមកាលយ៉ាងនេះ គឺ ហេតុក្នុងអតីត ១ វិបាកក្នុងបច្ចុប្បន្ន ១ ហេតុក្នុងបច្ចុប្បន្ន ១ វិបាកក្នុងអនាគត ១ ។ ព្រោះហេតុនោះ ទើបលោកពោលថា ម្យ៉ាងទៀត ក្នុងសង្ខេប ៤ នេះ សង្ខេបដំបូងជាអតីតអទ្ធា ដូច្នេះជាដើម ។ ស័ព្ទ ថា **សង្ខេប** ជាពាក្យហៅចំណែក ព្រោះហេតុនោះ ចំណែកនៃហេតុដែលជាអតីត ទើបចាត់ជាសង្ខេបដំបូង ។ សូម្បីក្នុងសង្ខេបដ៏សេស ក៏មានន័យដូច្នេះ ។ ឈ្មោះ ថា ជាការកាន់យក តណ្ហា ឧបាទាន និង ភព តែមួយ ព្រោះធម៌ ៥ មានអវិជ្ជា ជាដើមទាំងនេះ មានភាពជាកិលេសនិងកម្មស្មើដូចគ្នា និងព្រោះវៀរធម៌ ៣ មាន តណ្ហា ជាដើមទាំងនោះហើយ អវិជ្ជា និង សង្ខារ ក៏ធ្វើកិច្ចរបស់ខ្លួនបាន ។ កម្ម និង តណ្ហា ជាហេតុសាងនូវវដ្តៈនោះរួមគ្នា ទើបឈ្មោះថា **កម្មវដ្ត** ដោយអត្ថថា ធ្វើឲ្យប្រព្រឹត្តទៅ ។

ការតាំងចុះនៃកំណើត ការចាស់គ្រាំគ្រា និងការបែកធ្លាយនៃវិញ្ញាណ នាមរូប សឡាយតនៈ ផស្ស និង វេទនា ហៅថា “ **ជាតិ** និង **ជរាមរណៈ** ” ព្រោះហេតុ

នោះ ទើបលោកពោលថា " ព្រោះធម៌ ៥ មានវិញ្ញាណជាដើម ទ្រង់សម្ដែងខែទុកហើយ ដោយទ្រង់ចង្អុលបង្ហាញដល់ ជាតិ ជរា និង មរណៈ " ដូច្នេះពាក្យថា ធម៌ ៥ នេះ ( ចាត់ជាវិបាកវដ្ដៈ ក្នុងអនាគត ) បានដល់ ធម៌ ៥ មានវិញ្ញាណជាដើម ។ ឈ្មោះថា **ចាត់ជាវិបាកក្នុងអនាគត** ព្រោះធម៌ដែលជាអនាគត ត្រូវមានប្រក្រតី ដែលសត្វកាន់យកបានដោយហេតុបច្ចុប្បន្ន ។ ពាក្យថា **ធម៌ពួកនោះ** ( មាន ២០ យ៉ាង ដោយអាការ ) បានដល់ ធម៌ មានអវិជ្ជាជាដើម ។ ពាក្យថា **ដោយអាការ** គឺ ដោយសភាវៈមាននៅនៃធម៌ទាំងឡាយ រួមទាំងធម៌ដែលមិនទាន់បានពោលទុក ឈ្មោះថា **អាការ** ព្រោះអត្ថថា បណ្ឌិតអធិប្បាយ គឺ ប្រកាសទុកដោយស័ព្ទថា អវិជ្ជា សង្ខារជាដើម ក្នុងការសង្គ្រោះនោះៗ ,ម្យ៉ាងទៀត ប្រការទាំងឡាយនៃធម៌ដែលជាអតីតហេតុជាដើម ឈ្មោះថា **អាការ** បានដល់ ដោយអាការនោះ ។ ឈ្មោះថា **មាន ២០ យ៉ាង** ដោយភាពផ្សេងគ្នានៃពួកធម៌ មានពួកអតីតហេតុ ៥ ជាដើម។

ពាក្យថា **រវាងសង្ខារនិងវិញ្ញាណ ចាត់ជាសន្ធិ ១** គឺ ចាត់ជាសន្ធិ ១ ដែលជាការភ្ជាប់គ្នានៃហេតុនិងផល ព្រោះផល មានការប្រព្រឹត្តទៅមិនដាច់ខ្សែបាន ក៏ដោយហេតុ ។ រវាង ភព និង ជាតិ ក៏យ៉ាងនោះដូចគ្នា ។ ចំណែក រវាងវេទនា និង តណ្ហា ចាត់ជាសន្ធិ ១ ដែលជាការភ្ជាប់គ្នានៃផលនិងហេតុ ព្រោះហេតុ មានការប្រព្រឹត្តទៅមិនដាច់ខ្សែបាន ក៏ដោយផល ។ ពិតណាស់ ធម៌សូម្បីជាផលក៏ជាបច្ច័យដល់ធម៌ដែលមានសភាវៈជាហេតុបានដែរ ។ ស័ព្ទថា **ឥតិ** ជាពាក្យដែលដកយកនូវអត្ថន័យដែលមានប្រការដូចបានពោលហើយ ។ ព្រោះហេតុនោះ ទើបលោកពោលថា ដែលមានសង្ខេប ៤ ជាដើម ។ ពាក្យថា **ដោយអាការទាំងពួង** គឺ ដោយអាការទាំងពួង ដែលបានពោលហើយក្នុងទីនេះ និង ដែលនៅមិនទាន់បានពោលទុក

ដែលមកហើយក្នុងបដិច្ចសមុប្បាទវិភង្គ និង ក្នុងសម្មប្បដ្ឋានអនន្តន័យជាដើម ។ ពាក្យថា **ទ្រង់ដឹង** គឺ ទ្រង់ត្រាស់ដឹង ។ ពាក្យថា **ទ្រង់ឃើញ** គឺ ទ្រង់ឃើញដោយប្រចក្ស ដោយព្រះញាណចក្ខុដែលជាគ្រឿងឃើញ ។ ពាក្យថា **ទ្រង់ជ្រាប ទ្រង់ចាក់ធ្លុះ** ក៏ជាពាក្យវេវចនៈនៃពាក្យថា ទ្រង់ដឹងជាដើមនោះឯង ។ បទថា **តំ** បាន ដល់ ការដឹងនោះ ។ ពាក្យថា **ដោយអត្ថថា ដឹង** គឺ ដោយអត្ថថា ដឹងសភាវៈតាមសេចក្ដីពិត ។ ពាក្យថា **ដោយអត្ថថា ដឹងដោយប្រការទាំងពួង** គឺ ដោយអត្ថថា ចាក់ធ្លុះដោយប្រការទាំងពួង មាន **អនិច្ចំ** ជាដើម ។

លោកអាចារ្យ នាំកវចក្រនោះមក ( ពោល ) ក្នុងទីនេះដើម្បីប្រយោជន៍ណា ឥឡូវនេះដើម្បីនឹងសម្ដែងប្រយោជន៍នោះ ទើបលោកពោលថា **ឥមិនា** ជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ធម៌ពួកនោះ** បានដល់ ធម៌ទាំងឡាយ មាន អវិជ្ជាជាដើម ។ ពាក្យថា **កាលទ្រង់ជ្រាបតាមសេចក្ដីពិត** គឺកាលទ្រង់ដឹងតាមសេចក្ដីពិតដោយព្រះញាណដ៏ថ្លៃថ្លា ។ ប្រកបសេចក្ដីថា កាលទ្រង់នឿយណាយប្រាសចាកតម្រេក រួចផុតដោយវិបស្សនាដែលមានកំលាំង ទ្រង់ក៏កាច់បំបាក់កាំបានដោយព្រះអរិយមគ្គទាំងឡាយ ។ ក្នុងពាក្យទាំងនោះ មានអត្ថន័យថា ក្នុងវេលាណា ព្រះដ៏មានព្រះភាគទ្រង់ប្រាសចាកតម្រេក ផុតស្រឡះ ក្នុងវេលានោះ ឈ្មោះថា ទ្រង់កម្ចាត់កាំទាំងឡាយបានហើយ ។ បន្ទាប់អំពីនោះទៅ លោកកាន់យកខណៈដែលទ្រង់ត្រាស់ដឹងដោយប្រពៃហើយ ពោលថា កម្ចាត់ ទម្លាយ ញាំញី ។ លោកអាចារ្យកាលនឹងសម្ដែងថា កាលចក្រកែវដែលមិនមានចេតនា កើតឡើងដល់ព្រះចៅចក្រពត្តិនោះប៉ុណ្ណោះ មនុស្សលោក ក៏រមែងធ្វើការបូជាចំពោះព្រះចៅចក្រពត្តិនោះប៉ុណ្ណោះ រមែងលះបង់ការបូជាពិសេសក្នុងបុគ្គលដទៃចេញ ចាំបាច់និយាយថ្វី

ដល់កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ឧប្បត្តិឡើងនោះ ដូច្នេះទើបពោលថា កាលព្រះតថាគតទ្រង់ឧប្បត្តិឡើងហើយដូច្នេះជាដើម ។ ពាក្យថា **នឹងពោលទៅថ្វីដល់ការបូជាពិសេសដទៃ ៗ នោះ** មានន័យថា ក្នុងភាពជាអ្នកគួរដល់ការបូជាវិសេសដ៏ឧឡារិក ដោយឡែកអំពីដែលពោលហើយ ដែលពួកទេវតា និង មនុស្សមិនមានស័ក្តិយសបានធ្វើហើយ នឹងត្រូវនិយាយអ្វីទៀត ។ ពាក្យថា **ដែលសមគួរដល់អត្ថ** គឺ ដែលសមគួរដល់អត្ថនៃភាពជា **អរហំ** បានដល់ ស្របតាមអត្ថនោះ ។

ពាក្យថា **ព្រោះខ្វាចខ្វូចឈ្មោះ ខូចនាម** គឺ ព្រោះខ្លាចមិនមានកិត្តិយស ។ ឈ្មោះថា រមែងធ្វើបាបនៅក្នុងទីស្ងាត់ ដោយគិតថា " នរណាៗ នឹងមិនបានដឹងឃើញ " ឈ្មោះថា ព្រះដ៏មានព្រះភាគ " នេះ " ទ្រង់ធ្វើបាបក្នុងគ្រាខ្លះក៏ទេ ព្រោះធម៌ដែលជាហេតុនៃបាបទាំងឡាយ ត្រូវព្រះអង្គលះបង់ចោលបានដោយប្រពៃហើយ ក្នុងទីត្រាស់ដឹងនោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា **ទ្រង់ជាព្រះអរហន្ត ព្រោះភាវៈដែលទ្រង់ជាអ្នកឆ្ងាយ** មានន័យថា ព្រោះភាវៈដែលទ្រង់នៅក្នុងទីដ៏សែនឆ្ងាយនោះឯង ។

**សួរថា** ទ្រង់ជាព្រះអរហន្ត ព្រោះភាវៈដែលទ្រង់នៅក្នុងទីដ៏សែនឆ្ងាយ តើឆ្ងាយអំពីនរណា ?

**ឆ្លើយថា** ព្រោះទ្រង់ជាអ្នកឆ្ងាយ គឺ ឆ្ងាយអំពីបុគ្គលដែលមិនអប់រំកាយ មិនចម្រើនសីល មិនចម្រើនចិត្ត មិនចម្រើនបញ្ញានោះឯង និងទ្រង់ជាអ្នកឆ្ងាយអំពីបុគ្គលដែលលះបង់ រាគៈ ទោសៈ មោហៈ មិនទាន់បាន មិនឈ្លាសក្នុងធម៌របស់ព្រះអរិយៈជាម្ចាស់ មិនបានទទួលការអប់រំក្នុងធម៌របស់ព្រះអរិយៈជាម្ចាស់ មិនឃើញធម៌របស់ព្រះអរិយៈជាម្ចាស់ មិនបដិបត្តិ និង បដិបត្តិខុស , សេចក្តីនេះសមដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ សូម្បីថា ភិក្ខុជាអ្នកចាប់ជាយសង្ឃាដីរបស់តថាគត ជាប់តាមទៅអំពីខាងក្រោយ គ្រប់ជំហាន តែគេនោះ ជាអ្នកច្រើនដោយអភិជ្ឈា មានរាគៈខ្លាំងក្លា ក្នុងកាមទាំងឡាយ មានចិត្តព្យាបាទ មានវិហិង្សាវិតក្កៈ មិនមានសតិ មិនមានសម្បជញ្ញៈ មានចិត្តរាយមាយ មិនតាំងមាំ មានឥន្ទ្រិយប្រាកដ ( គឺ ក្រឡេមក្រឡឹម មិនសង្រួម ) ។ កាលបើដូច្នោះ ភិក្ខុរូបនោះ ក៏ឈ្មោះថា ជាអ្នកឆ្ងាយអំពីតថាគត ហើយតថាគតក៏ឈ្មោះថា ជាអ្នកឆ្ងាយអំពីភិក្ខុនោះ សេចក្ដីនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះ មិនឃើញធម៌ កាលមិនឃើញធម៌ ក៏ឈ្មោះថា មិនឃើញតថាគត ។

ពិតណាស់ បុគ្គលទាំងឡាយ តាមដែលពោលហើយ សូម្បីថា ជាអ្នកត្រាច់ទៅក្នុងទីជិតព្រះសាស្ដា គ្រប់ពេលវេលា ព្រឹក ល្ងាច ក៏មិនគួរពោលដល់គេទាំងនោះថា " ជាអ្នកនៅជិតព្រះសាស្ដា " ដោយហេតុត្រឹមប៉ុណ្ណោះឡើយ ដូចគ្នានេះដែរ មិនគួរពោល សូម្បីព្រះសាស្ដាថា ប្រថាប់នៅជិតបុគ្គលទាំងនោះ ។ ទ្រង់ជាព្រះអរហន្ត ព្រោះអត្ថថា ទ្រង់ជាអ្នកឆ្ងាយ គឺ គង់នៅក្នុងទីឆ្ងាយចំពោះពួកដែលមិនមែនសប្បុរសទាំងឡាយ យ៉ាងនេះ ។

នរជនពួកណា មានអធ្យាស្រ័យថោកទាប មិនបដិបត្តិប្រពៃ ព្រះដ៏មានព្រះ-ភាគ ទ្រង់ជាអ្នកឆ្ងាយ គឺ ប្រថាប់នៅក្នុងទីឆ្ងាយអំពីនរជនទាំងនោះ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយ ទើបថ្វាយព្រះនាមព្រះអង្គថា អរហំ ដូច្នេះ ។

យ៉ាងនោះដូចគ្នាដែរ ឈ្មោះថា ទ្រង់ជាព្រះអរហន្ត ព្រោះអត្ថថា ទ្រង់ជាអ្នកជិត មានន័យថា ព្រោះភាវៈដែលទ្រង់ប្រថាប់នៅក្នុងទីជិត ។

សួរថា ព្រះដ៏មានព្រះភាគ ព្រះនាមថា ទ្រង់ជាព្រះអរហន្ត ព្រោះភាវៈដែល

ទ្រង់នៅក្នុងទីជិតនរណា ?

ឆ្លើយថា ព្រោះទ្រង់ជាអ្នកជិតបុគ្គលដែលអប់រំកាយ ចម្រើនសីល ចម្រើនចិត្ត ចម្រើនបញ្ញា នោះឯង ទ្រង់ជាអ្នកជិតបុគ្គលដែលលះបង់ រាគៈ ទោសៈ និងមោហៈបានហើយ ឈ្លាសក្នុងធម៌របស់ព្រះអរិយៈ ទទួលការអប់រំក្នុងធម៌របស់ព្រះអរិយៈ ឃើញធម៌របស់ព្រះអរិយៈ បដិបត្តិត្រូវ សមដូចព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលនៅឆ្ងាយអំពីតថាគតដល់ទៅ ១០០ យោជន៍ តែបុគ្គលនោះ មិនបានជាអ្នកច្រើនដោយអភិជ្ឈា មិនមានរាគៈខ្លាំងក្លា ក្នុងកាមទាំងឡាយ មិនមានចិត្តព្យាបាទ មិនមានវិហិង្សាវិតក្កៈ មានសតិ មានសម្បជញ្ញៈ មានចិត្តតាំងមាំជាឯកគ្គៈ សង្រួមឥន្ទ្រិយ ។ កាលបើដូច្នោះ ភិក្ខុនោះ ឈ្មោះថានៅក្នុងទីជិតតថាគត ហើយតថាគតក៏ឈ្មោះថា នៅក្នុងទីជិតបុគ្គលនោះ ។ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះឃើញធម៌ កាលឃើញធម៌ ក៏ឈ្មោះថា ឃើញតថាគត ។

ពិតណាស់ បុគ្គលទាំងឡាយដែលមានលក្ខណៈដូចពោលនោះ សូម្បីជាអ្នកនៅឆ្ងាយពីព្រះសាស្ដាដល់ទៅ ១០០ យោជន៍ ក៏មិនគួរពោលចំពោះបុគ្គលនោះថា " ត្រាច់ទៅឆ្ងាយពីព្រះសាស្ដា " ដោយហេតុត្រឹមប៉ុណ្ណោះឡើយ ដូចគ្នានេះដែរ ក៏មិនគួរពោលថា ព្រះសាស្ដា " ទ្រង់ត្រាច់ទៅឆ្ងាយពីបុគ្គលទាំងនោះ " ។ ទ្រង់ជាព្រះអរហន្ត ព្រោះអត្ថថា ទ្រង់ជាអ្នកជិត គឺ ប្រថាប់នៅក្នុងទីជិតសប្បុរសទាំង-ឡាយ យ៉ាងនេះ ។

បុគ្គលពួកណា មានអធិមុត្តិដ៏ប្រណីតល្អ បដិបត្តិត្រូវ ព្រះជិនៈ ទ្រង់ជាអ្នក

ជិត គឺ ប្រថាប់នៅក្នុងទីជិតបុគ្គលពួកនោះ សូម្បីព្រោះហេតុនោះ ទើបទ្រង់ព្រះនាម ថា **អរហំ** ។

បាបធម៌ទាំងឡាយ មានរាគៈជាដើម ទាំងនេះ កើតឡើងក្នុងសន្តានណា រមែងនាំមកតែអនត្ថៈ ( សេចក្តីវិនាស ) ទាំងដែលមានជាបច្ចុប្បន្ន ទាំងដែលនឹងមានក្នុងកាលខាងមុខ ដល់សន្តាននោះ ។ នឹងជាសឹកសត្រូវដោយត្រង់នៃបដិបទាដែលជាហេតុដល់ព្រះនិព្វាន ដោយពិតប្រាកដនោះឯង បាបធម៌ទាំងនោះ ឈ្មោះថា **រហ** ព្រោះអត្ថថា សាធុជនទាំងឡាយដែលបដិបត្តិត្រូវ ដើម្បីនឹងធ្វើប្រយោជន៍ខ្លួននិង ប្រយោជន៍អ្នកដទៃឲ្យបរិបូរណ៍ គប្បីវៀរ គឺ គប្បីលះបង់ គប្បីលះចោលឲ្យឆ្ងាយ ក៏ព្រោះហេតុ បាបធម៌ ដែលឈ្មោះថា **រហ** ទាំងនោះ ព្រះដ៏មានព្រះភាគ ទ្រង់លះបង់ គឺ ទ្រង់កាត់ផ្តាច់បានហើយដោយប្រការទាំងពួង ដោយព្រះអរិយមគ្គ នាគល់ពោធិព្រឹក្សនោះឯង ។ ដូចដែលទ្រង់ត្រាស់ទុកថា ៖

**ម្នាលព្រាហ្មណ៍ រាគៈ ទោសៈ មោហៈ តថាគតលះបង់បានហើយ អកុសលធម៌ដែលជាបាបធម៌ទាំងអស់ តថាគតលះបង់បានហើយ កាត់ឫសដាច់ហើយ ធ្វើមិនឲ្យមានទីតាំងអាស្រ័យ ដូចដើមត្នោតដែលត្រូវដកទាំងឫស សល់តែដី ដល់នូវភាពមិនមាន រកការកើតឡើងតទៅទៀតមិនបាន ជាធម្មតា ។**

ព្រោះដូច្នោះ កាលគួរនឹងពោលថា ទ្រង់ព្រះនាមថា **អរហោ** ព្រោះអត្ថថា មិនមាន **រហ** ( បាបធម៌ ) ដោយប្រការទាំងពួង លោកក៏ធ្វើការផ្លាស់ ឱ អក្សរឲ្យជា **អ** អក្សរ ព្រមទាំងចុះនិគ្គហិតអាគម ហើយពោលថា **អរហំ** ដូច្នេះ ។

បាបធម៌ទាំងឡាយ ឈ្មោះថា **រហ** ព្រោះសាធុជនទាំងឡាយ គប្បីលះបង់ , ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះនាមថា **អរហំ** ព្រោះទ្រង់លះបង់នូវបាបធម៌ ដែល

ឈ្មោះថា **រហ** ទាំងនោះបានយ៉ាងល្អ ។

ព្រះអរហន្តខីណាស្រពទាំងឡាយ ដែលកំណត់ដឹងខន្ធហើយ លះបង់កិលេសបានហើយ ចម្រើនមគ្គហើយ ធ្វើនិរោធឲ្យជាក់ច្បាស់ហើយ ដោយប្រការទាំងពួងទាំងនោះឯណា ព្រះសេក្ខៈទាំងឡាយ ដែលមានចិត្តនៅមិនទាន់រួចស្រឡះ ប្រាថ្នានូវភាពក្សេមចាកយោគៈ ដ៏កំពូលពួកណា និងបុគ្គលទាំងឡាយដែលមានបយោគ-បរិសុទ្ធ មានអធ្យាស្រ័យល្អ ដល់ព្រមដោយគុណ មាន សទ្ធា សីលៈ សុតៈ ជាដើមឯណា ព្រះដ៏មានព្រះភាគ ទ្រង់ជាអ្នកដែលព្រះអរហន្តខីណាស្រពជាដើមទាំងនោះ មិនគប្បីវៀរ មិនគប្បីលះបង់ចោល ឯព្រះអង្គ ក៏ទ្រង់មិនលះបង់ចោលបុគ្គលទាំងនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អរហំ** ។

ពិតហើយ ព្រះអរិយបុគ្គលទាំងឡាយ ព្រោះធ្វើឲ្យជាក់ច្បាស់នូវព្រះធម៌ដែលព្រះសាស្តាទ្រង់ឃើញហើយ ទើបចាត់ជាអ្នកដែលមិនឃ្លាតឆ្ងាយអំពីព្រះសរីរៈ គឺ ធម៌ ( ធម្មកាយ ) របស់ព្រះសាស្តានោះឯង ដូចដែលព្រះបិង្គិយៈពោលទុកថា ៖

ម្នាលព្រាហ្មណ៍ អាត្មាមិនប្រមាទ រមែងឃើញព្រះពុទ្ធជាម្ចាស់អង្គនោះដោយចិត្ត ដូចឃើញដោយភ្នែក អស់ទាំងយប់ទាំងថ្ងៃ តែងនមស្ការអស់យប់ និង ថ្ងៃ អាត្មាសម្គាល់ដឹងជានិច្ចថា មិនមានការឃ្លាតអំពីព្រះពុទ្ធជាម្ចាស់អង្គនោះឡើយ ។ សទ្ធា បីតិ ចិត្ត និង សតិ របស់អាត្មា ក៏មិនរំកិលឃ្លាតទៅអំពីសាសនារបស់ព្រះគោតមឡើយ ព្រះអង្គមានបញ្ញាដូចផែនដី ស្តេចយាងទៅកាន់ទិសណាៗ អាត្មាក៏ជាអ្នកបង្អោនទៅកាន់ទិសនោះៗ ដែរ ។

ព្រោះហេតុនោះឯង ព្រះអរិយបុគ្គលទាំងឡាយ ទើបមិនឧទ្ទិសខ្លួនចំពោះសាសនាដទៃ ។ ដូចដែលទ្រង់ត្រាស់ទុកថា ៖

**ម្នាលភិក្ខុទាំងឡាយ នេះមិនមែនជាឋានៈ មិនមែនជាឱកាស គឺឋានៈនៃបុគ្គលដែលដល់ព្រមដោយទិដ្ឋិ នឹងគប្បីឱទ្ទិសខ្ទួនចំពោះសាស្តាដទៃ មិនមានឡើយ ។**

សូម្បីពួកកល្យាណបុថុជ្ជនដោយច្រើន ក៏ជាអ្នកមានសទ្ធាមិនញាប់ញ័រ ក្នុងព្រះសាស្តាដូចគ្នា ។ ដោយប្រការដូចដែលពោលមកហើយនេះ ព្រះដ៏មានព្រះភាគអង្គនោះ ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះអត្ថថា បុគ្គលដែលនឹងត្រូវព្រះអង្គលះបង់ គឺ គប្បីទ្រង់លះបង់ មិនមាន ឬ ព្រោះអត្ថថា ការដែលព្រះអង្គនឹងទ្រង់ត្រូវបុគ្គលល្អវៀរចាក ព្រោះទ្រង់ជាបុគ្គលដែលគួរគេលះបង់ មិនមាន ព្រោះទ្រង់ជាអ្នកដែលពួកបុរសពិសេសដែលបដិបត្តិល្អ មិនគប្បីវៀរ និង ព្រោះទ្រង់មិនលះបង់បុរសពិសេស ដែលបដិបត្តិល្អទាំងនោះ ។

ព្រះអរិយៈទាំងឡាយ ដែលមានព្រះសទ្ធម្មធ្វើឲ្យជាក់ច្បាស់ហើយ មានគោចរដ៏បរិសុទ្ធពួកណា ព្រះលោកនាថ ទ្រង់នឹងមិនជាអ្នកវៀរចាកព្រះអរិយៈជាម្ចាស់ទាំងនោះឡើយ ព្រោះហេតុនោះ បណ្ឌិតទើបថ្វាយព្រះនាមព្រះអង្គថា **អរហំ** ។

ម្យ៉ាងវិញទៀត **ការទៅ** ហៅថា **រហ** , ឯការទៅក្នុងសង្សារវដ្ត ពោលគឺការវិលវល់ទៅក្នុងគតិផ្សេងៗ រមែងមិនមានដល់ព្រះដ៏មានព្រះភាគ ព្រោះការដែលកម្មវដ្តៈ ព្រមទាំងគ្រឿងប្រកប ត្រូវព្រះអង្គទ្រង់ប្រើអរិយមគ្គដែលធ្វើឲ្យអស់ទៅនូវកម្ម កម្ចាត់ចោលបានហើយ ដោយប្រការទាំងពួង ត្រង់គល់ពោធិព្រឹក្សនោះឯង ។ ដូចដែលទ្រង់ត្រាស់ទុកថា ៖

**ការចូលដល់ភាពជាទេវតា ឬគន្ធព្វដែលត្រាច់ទៅក្នុងអាកាស គប្បីមានដល់តថាគតដោយអាសវៈណា តថាគតគប្បីដល់នូវភាពជាយក្ស និង គប្បីដល់នូវភាពជាមនុស្ស ព្រោះអាសវៈណា អាសវៈរបស់តថាគតទាំងនោះ អស់ទៅហើយ**

តថាគតកម្ចាត់ចោលបានហើយ ធ្វើឲ្យប្រាសចាកកពជាគ្រឿងចងបានហើយ ។

ដោយប្រការដូចពោលមកនេះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **អរហំ** ព្រោះអត្ថថា ទ្រង់មិនមាន **រហ** គឺ ការទៅ បានដល់ ការកើតក្នុងកាលខាងមុខ ក្នុងគតិទាំងឡាយ ។

ម្យ៉ាងទៀត **រហ** គឺ ការទៅក្នុងសង្សារវដ្ត មិនមានដល់ព្រះដ៏មានព្រះភាគអង្គណា ដោយប្រការទាំងពួង ។ បណ្ឌិតទើបថ្វាយព្រះនាម ព្រះសុគតជាសាស្តា ថា **អរហំ** ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **អរហំ** ព្រោះទ្រង់ជាអ្នកគួរសរសើរ ។ អ្នកត្រិះរិះអក្ខរៈទាំងឡាយពណ៌នា **អរហ** សព្ទ ទុកក្នុងអត្ថន័យថា សរសើរ ។ ការដែលភាពជាបុគ្គលគួរសរសើរ នៃព្រះដ៏មានព្រះភាគ មិនជារបស់សាធារណៈដល់បុគ្គលដទៃ ទ្រង់បានសម្រេចដោយព្រះគុណតាមសេចក្តីពិត តាំងមាំល្អហើយក្នុងលោក ព្រមទាំងទេវលោក ។ ពិតហើយ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះលក្ខណៈ ដែលបុរសជាបណ្ឌិត ទេវតា ព្រហ្ម ឬ ព្រះដ៏មានព្រះភាគអង្គដទៃ កាលនឹងថែក ពោលដល់ព្រះគុណទាំងឡាយនោះៗ យ៉ាងនេះថា ទ្រង់ជាអ្នករកបុគ្គលណាស្មើគ្មាន ទ្រង់ស្មើដោយបុគ្គលដែលរកបុគ្គលស្មើគ្មាន ទ្រង់រកបុគ្គលប្រៀបស្មើគ្មាន ទ្រង់រកបុគ្គលដែលមានចំណែកប្រៀបស្មើមិនបាន ទ្រង់ជាបុគ្គលដែលនរណាៗប្រៀបស្មើមិនបាន ដោយសីលដ៏កំពូល ដោយសមាធិដ៏កំពូល ដោយបញ្ញាដ៏កំពូល ដោយវិមុត្តិដ៏កំពូលជាដើម មិនគប្បីអាចនឹងពណ៌នាឲ្យសព្វគ្រប់បាន ។ ដោយប្រការដូចដែលបានពោលហើយនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះទ្រង់ជាបុគ្គលគួរសរសើរ ។ ព្រោះហេតុដែលបុគ្គលស្មើ

ដូចគ្នាន ដោយគុណទាំងឡាយ មិនមាននៅក្នុងលោក ព្រមទាំងទេវលោក ដូច្នោះ ព្រះដ៏មានព្រះភាគប្រសើរឧត្តមជាងសត្វជើង ២ ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះទ្រង់ជាបុគ្គលគួរសរសើរ ។ ដោយប្រការទាំងពួងដូចដែលបាន ពោលមកហើយនេះ ។

ព្រះជិនៈជាម្ចាស់ ទ្រង់ព្រះនាមថា **អរហំ** ព្រោះទ្រង់ជាអ្នកឆ្ងាយអំពីបុរសដែលមិនមានបញ្ញា ទ្រង់ជាអ្នកជិតចំពោះបុរសដែលមានបញ្ញា ព្រោះភាវៈដែលបាបធម៌ទាំងឡាយ ឈ្មោះថា **រហ** ត្រូវព្រះអង្គលះបង់ចោលបានហើយដោយប្រពៃ ព្រោះអ្នកប្រាជ្ញទាំងឡាយ មិនគួរវៀរ ព្រោះទ្រង់មិនមានការទៅក្នុងភពទាំងឡាយ និង ព្រោះទ្រង់ជាបុគ្គលគួរសរសើរ ។

( ចប់ មហាដីកា )

## បទថា សម្មាសម្ពុទ្ធោ

វីឯព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ក៏ព្រោះទ្រង់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ពិតហើយ ព្រះអង្គទ្រង់ត្រាស់ដឹងដោយប្រពៃផង ដោយព្រះអង្គឯងផង នូវធម៌ទាំងពួង គឺ ទ្រង់ត្រាស់ដឹងធម៌ទាំងឡាយដែលជាអភិញ្ញេយ្យ ជាធម៌ដែលគប្បីដឹងដ៏ក្រៃលែង ទ្រង់ត្រាស់ដឹងធម៌ទាំងឡាយដែលជាបរិញ្ញេយ្យ ជាធម៌ដែលគប្បីកំណត់ដឹង ទ្រង់ត្រាស់ដឹងនូវធម៌ទាំងឡាយដែលជាបហាតព្វៈ ជាធម៌ដែលគប្បីលះបង់ ទ្រង់ត្រាស់ដឹងនូវធម៌ទាំងឡាយដែលជាសច្ឆិកាតព្វៈ ជាធម៌ដែលគប្បីធ្វើឲ្យជាក់ច្បាស់ ទ្រង់ត្រាស់ដឹងធម៌ទាំងឡាយដែលជាភាវេតព្វៈ ជាធម៌ដែលគប្បីចម្រើន ព្រោះហេតុនោះឯង ព្រះអង្គ ទើបទ្រង់ត្រាស់ ( ដល់សេលព្រាហ្មណ៍ជាគាថា ) ថា ៖

**វត្ថុដែលគួរកំណត់ដឹងក្រៃលែង តថាគតបានត្រាស់ដឹងហើយ និង វត្ថុគួរចម្រើន តថាគតបានចម្រើនហើយ វត្ថុដែលគួរលះបង់ តថាគតបានលះបង់ហើយ ព្រោះហេតុនោះ តថាគតទើបជា ព្រះពុទ្ធ ។**

ន័យម្យ៉ាងទៀត ព្រះអង្គត្រាស់ដឹងដោយប្រពៃ និងដោយព្រះអង្គឯង នូវធម៌ទាំងពួង ដោយលើកឡើងត្រង់បទមួយដូច្នេះក៏បាន ថា **ចក្ខុជាទុក្ខសច្ច** តណ្ហាដែលមានមកអំពីភពមុន ដែលជាហេតុឲ្យកើតឡើង ដោយភាពជាតួហេតុ ដែលជាមូលនៃចក្ខុនោះជា **សមុទយសច្ច** ការមិនកើតឡើងនៃចក្ខុ និងចក្ខុសមុទយៈទាំងពីរជា **និរោធសច្ច** បដិបទាដែលជាហេតុត្រាស់ដឹងនូវនិរោធ ជា **មគ្គសច្ច** ក្នុងសោតៈ ឃានៈ ជិវ្ហា កាយ និង មនៈ ក៏មានន័យដូច្នេះ ។ អាយតនៈ ៦ មានរូបជាដើម ពួកវិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើម ផស្ស ៦ មានចក្ខុសម្ផស្សជាដើម

វេទនា ៦ មានចក្ខុសម្ផស្សវេទនាជាដើម សញ្ញា ៦ មានរូបសញ្ញាជាដើម ចេតនា ៦ មានរូបសញ្ចេតនាជាដើម ពួកតណ្ហា ៦ មានរូបតណ្ហាជាដើម វិតក្ក ៦ មានរូបវិតក្កជាដើម វិចារ ៦ មានរូបវិចារជាដើម ខន្ធ ៥ មានរូបក្ខន្ធជាដើម កសិណ ១០ អនុស្សតិ ១០ សញ្ញា ១០ មានឧទ្ធុមាតកសញ្ញាជាដើម អាការ ៣២ មានសក់ជាដើម អាយតនៈ ១២ ធាតុ ១៨ ភព ៩ មានកាមភពជាដើម ឈាន ៤ មានបឋមជ្ឈានជាដើម អប្បមញ្ញា ៤ មានមេត្តាភាវនាជាដើម អរូបសមាបត្តិ ៤ និងអង្គនៃបដិច្ចសមុប្បាទដោយបដិលោម មានជរាមរណៈជាដើម ដោយអនុលោមមានអវិជ្ជាជាដើម ( ទាំងនេះ គប្បីប្រកបសេចក្តី ) ចូលតាមន័យនោះឯង ។ នេះជាការប្រកបបទ ១ ក្នុងធម៌ទាំងនោះ ( គឺ ព្រះដ៏មានព្រះភាគ ជាម្ចាស់ទ្រង់ត្រាស់ដឹង គឺ ទ្រង់ត្រាស់ដឹងដោយអនុលោម ទ្រង់ត្រាស់ដឹងដោយបដិលោមដោយប្រពៃ និងដោយព្រះអង្គឯង នូវធម៌ទាំងពួង ដោយលើកឡើងបទ ១ យ៉ាងនេះថា " ជរា-មរណៈជាទុក្ខសច្ច ជាតិជាសមុទយសច្ច ការរលត់នៃទុក្ខនិងសមុទយៈ ទាំងពីរនោះ ជានិរោធសច្ច បដិបទាដែលជាហេតុត្រាស់ដឹងនូវនិរោធ ជាមគ្គសច្ច " ដូច្នេះជាតួយ៉ាង ព្រោះហេតុនោះ ខ្ញុំព្រះករុណាទើបពោលថា ព្រះដ៏មានព្រះភាគ ជាម្ចាស់អង្គនោះ ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ក៏ព្រោះទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឯង ។

## មហាដីកា

បទថា **សម្មា** ( ដោយប្រពៃ ) គឺ មិនវិបរិត ។ បទថា **សាមំ** ស្មើគ្នានឹង

**សយំ** ( ដោយព្រះអង្គឯង ) នោះឯង ។ ក៏ **សំ** ស័ព្ទ ក្នុងបទថា **សម្ពុទ្ធោ** នេះ គប្បីឃើញថា ប្រាប់ឲ្យដឹងអត្ថថា **សយំ** នេះ ។ ពាក្យថា **ធម៌ទាំងពួង** បានដល់ញេយ្យធម៌ ( ធម៌ដែលគួរដឹង ) ទាំងពួង មិនមានសល់ ។

**សួរថា** ក្នុងពាក្យថា សម្មាសម្ពុទ្ធោនេះ នឹងបានន័យថា ជាការត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដូចម្ដេច ?

**ឆ្លើយថា** ព្រោះគ្មានការប្រើស័ព្ទថា ចំណែកខ្លះ ។ ពិតណាស់ កាលមិនមានការប្រើស័ព្ទថា ចំណែកខ្លះ បណ្ឌិតរមែងជ្រាបបានថា ធម៌ដែលទ្រង់កាន់យក រកចំណែកសល់មិនបាន ដូចពាក្យថា មិនមែនឲ្យដល់ចំពោះតែមនុស្សឧស្សាហ៍ទេ ( គឺ ឲ្យដល់មនុស្សគ្រប់គ្នា ) ។

ព្រោះធ្វើអធិប្បាយយ៉ាងនេះ គួរជ្រាបសេចក្ដីសម្រេចនៃ **ពុទ្ធ** ស័ព្ទ ដែលមិនមានការសម្លឹងដល់អត្ថន័យពិសេស ក្នុងអត្ថថា ជាកត្តុ ( អ្នកធ្វើ គឺ អ្នកដឹង ) នោះឯង ព្រោះមិនមានសេចក្ដីត្រូវការដោយពាក្យពោល ដែលជាកម្ម ( គឺ ត្រូវដឹង ) ។ ពិតណាស់ រមែងបានពាក្យពោលដោយស័ព្ទក្នុងទីនេះ ត្រឹមនេះថា ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះត្រាស់ដឹងដោយប្រពៃ និង ដោយព្រះអង្គឯង ប៉ុណ្ណោះ ចំណែកពាក្យថា **ធម៌ទាំងឡាយទាំងពួង** លោកពោលកាន់យកពាក្យពោលបានដោយអត្ថ ព្រោះថា កិរិយាដែលដឹង បើមិនមានអារម្មណ៍ រមែងមិនត្រឹមត្រូវ ។

ឥឡូវនេះ លោកអាចារ្យបំណាងចែក សម្ដែងអារម្មណ៍ដែលពោលទុកដោយពាក្យសាមញ្ញថា “ **ធម៌ទាំងឡាយទាំងពួង** ” នៃកិរិយាដែលដឹងនោះ ទើបពោល

ថា “ (គឺត្រាស់ដឹង) **អភិញ្ញេយ្យធម៌ទាំងឡាយ** ” ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **អភិញ្ញេយ្យធម៌ទាំងឡាយ** បានដល់ ធម៌ដែលគួរដឹងដោយញាណដ៏វិសេសក្រៃលែងទាំងឡាយ ។

អភិញ្ញេយ្យធម៌ទាំងឡាយនោះ គឺ អ្វី ? គឺ **សច្ចៈ ៤** ។

២បទថា **អភិញ្ញេយ្យតោ ពុទ្ធោ** ប្រែថា ត្រាស់ដឹងដោយភាពជាអភិញ្ញេយ្យធម៌ មានន័យថា ក្នុងពេលខាងដើម ទ្រង់ជ្រាបដោយវិបស្សនាញាណទាំងឡាយ ក្នុងខណៈចាក់ធ្លុះ ទ្រង់ជ្រាបដោយមគ្គប្បញ្ញា ក្នុងពេលក្រោយទ្រង់ជ្រាបដោយព្រះញាណទាំងឡាយ មានព្រះសព្វញ្ញុតញ្ញាណជាដើម ។ សូម្បីក្នុងធម៌ដទៃក្រៅពីនេះក៏ដូច្នេះដែរ ។ ពាក្យថា **បរិញ្ញេយ្យធម៌ទាំងឡាយ** លោកពោលដល់ទុក្ខអរិយសច្ច ។ ពាក្យថា **បហាតព្វធម៌ទាំងឡាយ** លោកពោលដល់ធម៌ទាំងឡាយ ដែលជាចំណែកនៃសមុទយៈ ។ ពាក្យថា **សច្ឆិកាតព្វធម៌ទាំងឡាយ** លោកពោលសំដៅយកព្រះនិព្វាន ។ តែលោកធ្វើពាក្យនិទ្ទេស ជាពហុវចនៈទុក ព្រោះកាន់យកប្រភេទ មានសឧបាទិសេសនិព្វានជាដើម ដែលសម្រេចដោយបរិយាយឧទ្ទេស ក៏គឺ សច្ចធម៌ ៤ នោះឯង ។ ពិតហើយ លោកនឹងពោលថា “ **ចក្ខុជាទុក្ខសច្ច** ” ដូច្នេះជាដើម ។ ឧទ្ទេស លោកធ្វើទុកដោយទាក់ទងនឹងធម៌ ដែលមិនទាន់មានការកំណត់តួសភាវៈ ( គឺ អង្គធម៌ ) ដែលបានវិនិច្ឆ័យទុក ។

ពិតណាស់ ដោយឧទ្ទេស លោកពោលត្រឹមតែការមាននៅនៃធម៌ដែលលើកឡើងសម្តែង នៅមិនទាន់ពោលការកំណត់ ( អង្គធម៌ ) ព្រោះហេតុនោះ ព្រោះមិនទាន់មានការកំណត់ ( អង្គធម៌ ) ទើបលោកពោលទុកជាពហុវចនៈ ដូចជាពាក្យថា **អបច្ចយា ធម្មា អសង្ខតា ធម្មា** ធម៌ដែលមិនមានបច្ច័យទាំងឡាយ អសង្ខតធម៌

ទាំងឡាយ ។

នយម្យ៉ាងទៀត ពាក្យថា **សច្ចិកាតព្វធម៌ទាំងឡាយ** លោកកាន់យកផល វិមុត្តិផងដែរ ។ មិនមែនកាន់យកចំពោះតែព្រះនិព្វាននោះឡើយ ព្រោះដូច្នោះ ទើបធ្វើនិទ្ទេស ( ពាក្យអធិប្បាយ ) ជាពហុវចនៈ ។ ហើយក្នុងពាក្យថា **ភាវេតព្វធម៌ទាំងឡាយ** ក៏យ៉ាងនេះដូចគ្នា ។ គប្បីជ្រាបថា លោកកាន់យកឈានទាំងឡាយផងដែរ ។

ក្នុងគាថា **ច** សព្ទ ក្នុងបទថា **ភាវេតព្វញ្ច** នេះ មានអត្ថថា រួបរួមយកធម៌ដែលទ្រង់មិនបានត្រាស់ទុកដោយ **ច** សព្ទនោះ គប្បីជ្រាបថា កាន់យកវត្ថុដែលគួរធ្វើឲ្យជាក់ច្បាស់ ។ ពាក្យថា **ព្រោះហេតុនោះតថាគត ទើបជា ពុទ្ធ** មានន័យថា ព្រោះហេតុដែលតថាគតត្រាស់ដឹងសច្ចធម៌ ៤ ហើយវត្ថុដែលគួរដឹងណា ៗ ដែលផុតទៅអំពីសច្ចៈ មិនមាន ព្រោះហេតុនោះ តថាគតទើបជា **ពុទ្ធ** ដឹងហើយនូវវត្ថុដែល គួរដឹងគ្រប់ប្រការ ។

លោកអាចារ្យបំណងនឹងចែក សម្តែងអត្ថន័យដែលពោលទុក ដោយទាក់-ទងនឹងសច្ចៈ ដោយពាក្យពោលសាមញ្ញយ៉ាងនេះ ដោយទាក់ទងនឹងសច្ចៈនោះឯង ព្រមទាំង ទ្វារនិងអារម្មណ៍ និងធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងទ្វារ និងព្រមទាំងធម៌ទាំងឡាយ មានខន្ធជាដើម ទើបផ្តើមពាក្យថា នយម្យ៉ាងទៀត ដូច្នេះជាដើម។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **ដោយភាពជាមូល** គឺ ដោយភាពជាហេតុ គឺដោយភាពជាហេតុដែលជាមូលនៃទុក្ខទាំងនោះ សូម្បីហេតុដទៃ មានអវិជ្ជាជាដើមមានហើយ ។ សេចក្តីពិត តណ្ហាជាហេតុ ជាប្រធានក្នុងការវិចិត្រនៃទុក្ខ ព្រោះហេតុនៃការវិចិត្ររបស់កម្ម និង ព្រោះការចូលដល់ភាពជាសំឡាញ់របស់កម្ម ។ ពាក្យថា

**ដែលធ្វើ ( ចក្ខុនោះ ) ឲ្យតាំងឡើង** គឺ ដែលធ្វើចក្ខុនោះឲ្យកើតឡើង ។ ពាក្យថា **តណ្ហាចាស់** គឺ តណ្ហាដែលសម្រេចហើយក្នុងភពមុន ។ ពាក្យថា **នៃធម៌ទាំងពីរ** គឺ នៃចក្ខុ និង តណ្ហាដែលជាហេតុឲ្យកើតឡើងនៃចក្ខុនោះ ។ ពាក្យថា **ការមិនប្រព្រឹត្តទៅ** គឺ ធម៌ដែលជាហេតុនៃការមិនប្រព្រឹត្តទៅ ។ ពាក្យថា **ដែលជាគ្រឿងដឹងច្បាស់នូវនិរោធ** គឺ ដែលជាគ្រឿងចាក់ធ្លុះនូវនិរោធដោយអំណាចការត្រាស់ដឹង គឺ ធ្វើឲ្យជាក់ច្បាស់ ។ ពាក្យថា **ដោយការលើកឡើងត្រង់បទ ១** គឺ ដោយការដកចេញមកមួយចំណែក ដោយន័យថា **ចក្ខុ ចក្ខុសមុទយ** ជាដើម ។

លោកអាចារ្យពោលថា **គំនរតណ្ហា ៦ មានរូបតណ្ហាជាដើម** ដើម្បីសម្តែងថា សូម្បីតណ្ហាក៏មានការសង្គ្រោះចូលក្នុងទុក្ខសច្ចបាន ព្រោះតណ្ហាក៏មានភាពជាធម៌ដែលគួរកំណត់ដឹង និងព្រោះប្រជុំចុះក្នុងឧបាទានក្ខន្ធ ។

ពាក្យថា **កសិណ** បានដល់ កសិណឈាន ។ ពាក្យថា **អាការ ៣២** បានដល់ កោដ្ឋាស ៣២ និង ឈានដែលមានកោដ្ឋាស ៣២ នោះជាអារម្មណ៍ ។ ពាក្យថា **ភព ៩** បានដល់ ភព ៩ គឺ ភព ៣ មានកាមភពជាដើម ភព ៣ មានសញ្ញីភពជាដើម ភព ៣ មានឯកវោការភពជាដើម ។ ពាក្យថា **ឈាន ៤** បានដល់ រូបាវចរឈាន ៤ ដែលមានភាពផ្សេងគ្នាទៅដោយអារម្មណ៍ ដែលមិនទាន់បានកាន់យក ឬថា ពាក្យនេះ លោកកាន់យកឈានដែលជាវិបាកទាំងឡាយ ។ ក្នុងធម៌ទាំងនេះ សម្រាប់កុសលធម៌ទាំងឡាយ តណ្ហាដែលជាឧបនិស្សយប្បច្ច័យ គប្បីជ្រាបថា តណ្ហាចាស់ដែលធ្វើឲ្យកើតឡើង ។ ចំណែកកិរិយាធម៌ទាំងឡាយ តណ្ហាដែលជាហេតុនៃអត្តភាព ដែលជាកិរិយាញុំាងធម៌ទាំងនោះឲ្យកើតឡើង គប្បីជ្រាបថា តណ្ហាចាស់ដែលធ្វើឲ្យកើតឡើង ។ បទថា **អនុពុទ្ធោ** គឺ ត្រាស់ដឹង តាមសម

គួរនូវធម៌ដែលគួរត្រាស់ដឹង ។ បទថា **តេន** ប្រែថា ព្រោះហេតុនោះ មានន័យថា ព្រោះហេតុដែលព្រះអង្គ ទ្រង់ត្រាស់ដឹងនូវធម៌ទាំងឡាយទាំងពួងដោយសាមញ្ញ និង ដោយពិសេស ដោយការលើកឡើងត្រង់បទ ១ ដូច្នោះ ទើបខ្ញុំម្ចាស់ពោលទុក ។ ពោលទុកថា ដូចម្ដេច ? ពោលទុកថា **ព្រោះទ្រង់ត្រាស់ដឹងធម៌ទាំងឡាយទាំងពួងដោយប្រពៃ និងដោយព្រះអង្គ**ឯង មានន័យថា ព្រោះព្រះអង្គ ទ្រង់ត្រាស់ដឹង ដោយប្រពៃនូវធម៌គួរដឹងទាំងអស់ មិនភ្លាំងភ្លាត់ដោយអាការទាំងពួង ដោយព្រះអង្គ ឯង ដោយពាក្យថា ព្រោះទ្រង់ត្រាស់ដឹង... និងដោយព្រះអង្គឯង នេះលោកសម្ដែង ចំពោះការសម្រេចនូវព្រះសព្វញ្ញុតញ្ញាណ ដែលហៅថា ព្រះអនាវរណញ្ញាណដែល អាចដឹងច្បាស់នូវធម៌ទាំងពួងបាន ដោយអាការទាំងពួង ប្រព្រឹត្តទៅដោយទាក់ទង ដល់ព្រះបំណងនៃព្រះមានព្រះភាគ ដែលទ្រង់ប្រាសចាកការណែនាំអំពីបុគ្គលដទៃ ។

ប្រសិនបើមានពាក្យសួរថា ព្រះអនាវរណញ្ញាណ ផ្សេងអំពីព្រះសព្វញ្ញុត-ញ្ញាណ ឬ ? កាលកាន់យកសេចក្ដីដោយប្រការដទៃ ពាក្យថា **ឆ សាធារណ-ញ្ញាណានិ ពុទ្ធញ្ញាណានិ** ញាណដែលមិនជាសាធារណៈដល់សាវ័ក ៦ ញាណ ជា ពុទ្ធញ្ញាណដូច្នេះ ក៏ខុសឬ ? ឆ្លើយថា មិនខុសទេ ព្រោះលោកពោលថា ញាណ មួយនោះឯង បែកជាពីរញ្ញាណ ដោយអំណាចភាពផ្សេងគ្នានៃការប្រព្រឹត្តទៅក្នុង អារម្មណ៍ ដើម្បីសម្ដែងការមិនជាសាធារណៈដល់បុគ្គលដទៃ ។

ពិតណាស់ ញាណដូចគ្នានោះឯង ហៅថា **ព្រះសព្វញ្ញុតញ្ញាណ** ព្រោះមាន សង្ខតធម៌ អសង្ខតធម៌ និង សម្មតិធម៌ ជាអារម្មណ៍មិនមានសល់ និងហៅថា **ព្រះ អនាវរណញ្ញាណ** ព្រោះសំដៅដល់ការត្រាច់ទៅមិនទើសទាក់ ព្រោះមិនមានគ្រឿង រារាំងក្នុងអារម្មណ៍នោះ ដូចដែលព្រះសារីបុត្តត្ថេរ ពោលទុកក្នុងបដិសម្ភិទាមគ្គថា

“ ឈ្មោះថា **ព្រះសព្វញ្ញុតញ្ញាណ** ព្រោះអត្ថថា ដឹងសង្ខតធម៌ អសង្ខតធម៌ទាំងអស់មិនមានសល់ , ឈ្មោះថា **ព្រះអនាវរណញ្ញាណ** ព្រោះអត្ថថា មិនមានគ្រឿងរារាំងក្នុងធម៌ទាំងនោះ ” ដូច្នេះជាដើម ។ ព្រោះហេតុនោះ ញាណទាំង ២ នេះ ទើបមិនមានភាពផ្សេងគ្នាដោយសភាវៈ បណ្ឌិតគប្បីត្រូវការពាក្យអធិប្បាយយ៉ាងនេះៗ ដោយចំណែកមួយចុះ ។ កាលនឹងកាន់យកសេចក្ដីដោយប្រការដទៃ ព្រះសព្វញ្ញុតញ្ញាណ និង ព្រះអនាវរណញ្ញាណ នឹងគប្បីដល់នូវភាពជាញាណដែលជាសាធារណៈ និងភាពជាញាណដែលមិនមានធម៌ទាំងអស់ជាអារម្មណ៍ ។ ពិតហើយ គ្រឿងរារាំងព្រះញាណនៃព្រះមានព្រះភាគ សូម្បីត្រឹមតែអណូមិនមាន ។ កាលព្រះអនាវរណញ្ញាណមានភាពជាញាណដែលមិនមានធម៌ទាំងអស់ជាអារម្មណ៍ ព្រះអនាវរណញ្ញាណនោះប្រព្រឹត្តទៅក្នុងអារម្មណ៍មិនបាន ព្រោះមានការរារាំងក្នុងអារម្មណ៍នោះ ក៏រកភាពជាព្រះអនាវរណញ្ញាណមិនបានដែរ ឬ ព្រះអនាវរណញ្ញាណជាញាណដែលមានហេតុដទៃអំពីព្រះសព្វញ្ញុតញ្ញាណ តែជាក្នុងទីនេះ លោកបំណងយកព្រះសព្វញ្ញុតញ្ញាណនោះឯងថាជាព្រះអនាវរណញ្ញាណ ព្រោះប្រព្រឹត្តទៅមិនទើសទាក់ក្នុងធម៌ទាំងពួងៗ ព្រោះទ្រង់សម្រេចនូវព្រះញាណនោះ បណ្ឌិតទើបថ្វាយព្រះនាមព្រះដ៏មានព្រះភាគថា “ **សព្វញ្ញូ** ( អ្នកដឹងវត្ថុគ្រប់យ៉ាង ) **សព្វវិទូ** ( អ្នកឃើញច្បាស់វត្ថុគ្រប់យ៉ាងនិងថា **សម្មាសម្ពុទ្ធោ** ( អ្នកត្រាស់ដឹងដោយប្រពៃ និង ដោយព្រះអង្គឯង ) ” មិនមែនជាការដឹងធម៌ទាំងអស់ក្នុងគ្រាតែមួយឡើយ ។ ពិតហើយ លោកពោលទុកក្នុងបដិសម្ភិទាមគ្គថា “ ពាក្យថា **ពុទ្ធោ** នេះ មានក្នុងទីបំផុតនៃវិមោក្ខនៃព្រះមានព្រះភាគជាសច្ឆិកាបញ្ញត្តិ ( ឈ្មោះដែលបាន ព្រោះការធ្វើឲ្យជាក់ច្បាស់ ) ដែលបានមកព្រមជាមួយព្រះសព្វញ្ញុតញ្ញាណ នាគល់ពោធិព្រឹក្ស ” ។ ពិតណាស់ ព្រោះទ្រង់

សម្រេចព្រះញាណដែលអាចដឹងនូវធម៌ទាំងពួងបាន ព្រះមានព្រះភាគ ទើបទ្រង់មាន សមត្ថភាពដែលនឹងអាចដឹងនូវធម៌ទាំងពួងមិនមានសល់ ក្នុងសន្តានព្រះអង្គ ។

ក្នុងអធិការនេះ សួរថា ព្រះញាណនេះ កាលនឹងប្រព្រឹត្តទៅ រមែងប្រព្រឹត្ត ទៅក្នុងអារម្មណ៍ទាំងអស់ ក្នុងគ្រាជាមួយគ្នាឬ ឬថា តាមលំដាប់ ?

ឆ្លើយថា ក្នុងរឿងនេះ ខ្ញុំម្ចាស់សូមពោលបន្តិច ដំបូង ប្រសិនបើប្រព្រឹត្តទៅ ក្នុងអារម្មណ៍ទាំងពួង ក្នុងគ្រាមួយប៉ុណ្ណោះ ក៏រមែងសម្រេចសេចក្តីថា ក្នុងការដែល សង្ខតធម៌ទាំងឡាយ ដែលផ្សេងគ្នាដោយប្រភេទ ជាអតីត អនាគត បច្ចុប្បន្ន ខាង ក្នុង ខាងក្រៅជាដើម អសង្ខតធម៌ និង សម្មតិធម៌ទាំងឡាយ ប្រាកដព្រមគ្នា , ការ ដឹងតែមួយចំណែក នឹងមានមិនបាន ដូចមនុស្សដែលសម្លឹងមើលសំពត់ដែលវិចិត្រ ច្រើនយ៉ាងអំពីចម្ងាយដូច្នោះ ហើយបើយ៉ាងដូច្នោះបាន ធម៌ទាំងឡាយទាំងពួង ក៏ជា អារម្មណ៍នៃព្រះញាណរបស់ព្រះមានព្រះភាគ ដោយសភាវៈដែលទ្រង់មិនត្រូវត្រិះរិះ ( ដើម្បីទ្រង់ជ្រាប ) ដូចជាអារម្មណ៍ដោយអាការជាអនត្តា មានដល់ព្រះយោគីដែល ពិចារណាឃើញថា “ ធម៌ទាំងឡាយទាំងពួងជាអនត្តា ” ដូច្នោះ ។ សូម្បីអាចារ្យ ពួកណានឹងពោលថា “ ព្រះញាណរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ មានលក្ខណៈ ដែលតាំងនៅនៃញេយ្យធម៌ទាំងពួងជាអារម្មណ៍ ប្រាសចាកវិកប្ប ( មិនមានគំនូស ចំណាំ កំណត់ ) ប្រព្រឹត្តទៅអស់កាលទាំងពួង ព្រោះហេតុនោះ បណ្ឌិតទើបថ្វាយ ព្រះនាមព្រះពុទ្ធជាម្ចាស់ទាំងនោះថា **សព្វវិទូ** ដឹងវត្ថុអស់កាលទាំងពួង ។ ពាក្យថា **ទ្រង់ជានាគ កាលនឹងត្រាច់ទៅ ក៏ជាអ្នកមានចិត្តតាំងមាំ កាលនឹងឋិតនៅក៏ជាអ្នក មានចិត្តតាំងមាំ** សូម្បីដូច្នេះ ក៏ជាការពោលទុកល្អហើយ ក៏ព្រោះធ្វើអធិប្បាយទុក យ៉ាងនេះ ដូច្នេះ សូម្បីការពោលរបស់អាចារ្យពួកនោះ ក៏មិនខុសដែរ ត្រង់ន័យថា

ព្រះញាណរបស់ព្រះមានព្រះភាគ មានធម៌ចំណែកមួយៗជាអារម្មណ៍ប៉ុណ្ណោះ ព្រោះដូច្នោះ ទើបប្រព្រឹត្តទៅតែមួយគ្រា មិនត្រឹមត្រូវ ព្រោះមានលក្ខណៈប្រាកដជាអារម្មណ៍តែធម៌ដែលជាអតីត អនាគត និង សម្បតិ មិនមានលក្ខណៈដែលប្រាកដនោះទេ ។ សួរថា បើដូច្នោះ ព្រះញាណ ក៏រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងពួងតាមលំដាប់ ( គឺ មិនព្រមគ្នា ) ឬ ? ឆ្លើយថា សូម្បីពោលមកយ៉ាងនេះ ក៏មិនត្រឹមត្រូវ ព្រោះថា កាលនឹងទ្រង់កាន់យកញេយ្យធម៌ ដែលផ្សេងគ្នាដោយប្រភេទជាច្រើន ដោយទាក់ទងនឹង ជាតិ ភូមិ សភាវៈ ជាដើម និងទាក់ទងនឹង ទិស ទេសៈ កាលៈ ជាដើម ទៅតាមលំដាប់ការចាក់ធ្លុះញេយ្យធម៌នោះ ដោយមិនមានសល់ ក៏រមែងមានមិនបាន ព្រោះតែញេយ្យធម៌រកទីបំផុតមិនបាន ។ រីឯអាចារ្យពួកណា នឹងពោលថា “ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **សព្វញ្ញូ** ព្រោះទ្រង់ធ្វើញេយ្យធម៌ចំណែកមួយ ឲ្យឃើញប្រចក្ស ព្រោះទ្រង់ធ្វើអត្ថមិនឲ្យឃ្លៀងឃ្លាត ហើយទ្រង់សម្រេចព្រះទ័យកំណត់ថា សូម្បីញេយ្យធម៌ដ៏សេសក៏យ៉ាងនេះ ព្រះញាណនោះ មិនជាព្រះញាណប្រកបដោយការអនុមាន ព្រោះមិនមានសេចក្ដីសង្ស័យ ។ ព្រោះថា ក្នុងផ្លូវលោក ញាណទាក់ទងដោយសេចក្ដីសង្ស័យ ទើបឈ្មោះថា “ **អនុមានញាណ** ” ដូច្នេះ ពាក្យនោះឯងរបស់អាចារ្យពួកនោះ មិនត្រឹមត្រូវ ។ ក៏ព្រោះកាលនៅមិនមានការឃើញប្រចក្សនូវញេយ្យធម៌ទាំងអស់ ការធ្វើញេយ្យធម៌មួយចំណែកឲ្យឃើញប្រចក្ស ដោយមិនធ្វើសភាវៈឲ្យឃ្លៀងឃ្លាត ហើយសម្រេចចិត្ត កំណត់ចុះទៅថា “ សូម្បីធម៌ដ៏សេសក៏យ៉ាងនេះ ” ដូច្នេះក៏ទេ ។ ដោយថា វត្ថុដ៏សេសនោះឯណា វត្ថុនោះ ឈ្មោះថានៅមិនទាន់ឃើញប្រចក្ស , បើវត្ថុនោះ ឈ្មោះថា ឃើញប្រចក្ស វត្ថុនោះមិនគួរមានភាពជាវត្ថុដ៏សេសនោះទេ ព្រោះហេតុនោះ ពាក្យទាំងអស់នេះទើបមិនមានហេតុ ។

ព្រោះហេតុអ្វី ព្រោះជាការពិចារណាវិស័យដែលមិនគួរពិចារណា ។ សេចក្ដីនេះសមដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា **ម្នាលភិក្ខុទាំងឡាយ ពុទ្ធវិស័យជាអចិន្តេយ្យ គឺ មិនគួរគិត បុគ្គលណាគិត បុគ្គលនោះគប្បីជាអ្នកមានចំណែកនៃការឆ្កួត នៃការក្ដៅក្រហាយ** ។ ក្នុងរឿងនេះ មានខសន្និដ្ឋានដូច្នេះ វត្ថុណាមួយដែលព្រះដ៏មានព្រះភាគទ្រង់បំណងនឹងជ្រាប ទោះបីទាំងអស់ ឬ មួយចំណែកក៏ដោយ ព្រះញាណ រមែងប្រព្រឹត្តទៅ ឃើញប្រចក្សក្នុងវត្ថុនោះ ដោយការប្រព្រឹត្តទៅបានមិនទើសទាក់ និង ស្ទាត់ជំនាញជានិច្ច ព្រោះមិនមានការរាយមាយ ។ កាលវត្ថុដែលទ្រង់បំណងនឹងជ្រាបទាំងអស់ ជាអារម្មណ៍មិនបាន តែវត្ថុទាំងអស់នោះ នឹងប្រព្រឹត្តទៅផុតចាកព្រះបំណងក៏ទេ ភាវៈដែលវត្ថុទាំងអស់ប្រព្រឹត្តទៅទាក់ទងនឹងព្រះបំណងនោះ បណ្ឌិតគប្បីកាន់យកបានដោយចំណែកមួយៗ ព្រោះមានពាក្យពោលទុកថា **ធម៌ទាំងឡាយទាំងពួង ទាក់ទងនឹងការនឹកភាវរក ទាក់ទងនឹងព្រះបំណង ទាក់ទងនឹងមនសិការ ទាក់ទងនឹងចិត្តុប្បាទ ( ការគិតដែលកើតឡើង ) នៃព្រះដ៏មានព្រះភាគជាម្ចាស់** ។ ព្រះញាណនៃព្រះដ៏មានព្រះភាគ សូម្បីថា មានធម៌ដែលជាអតីត ឬ អនាគតជាអារម្មណ៍ ក៏ឈ្មោះថា ឃើញប្រចក្សដែរ ព្រោះវៀរចាកការកាន់យកដោយអនុមាន ( តាម ) ការរៀន និង ការគិតយក ។

សួរថា ក្នុងចំណែកនេះ ក្នុងវេលាណាទ្រង់បំណងនឹងជ្រាបធម្មជាតិទាំងអស់ ក្នុងវេលានោះ ព្រះញាណរបស់ព្រះដ៏មានព្រះភាគ នឹងគប្បីប្រព្រឹត្តទៅដោយសភាវៈដែលទ្រង់មិនត្រូវព្រះតម្រិះ ព្រោះទ្រង់មានធម្មជាតិទាំងអស់ជាអារម្មណ៍ ក្នុងគ្រាតែមួយជាមួយគ្នានោះឯង ព្រោះហេតុនោះ ក៏មិនខុសក្លាត់ពីខដែលពោលហើយនោះដែរ មិនមែនឬ ? ឆ្លើយថា មិនមែនទេ ព្រោះទ្រង់ជម្រះនូវព្រះញាណទាំងអស់ឲ្យ

បរិសុទ្ធបាន ។ ក៏ពុទ្ធវិស័យដែលទ្រង់ជម្រះបានបរិសុទ្ធនោះ ជាអចិន្តេយ្យ ។ កាលកាន់យកសេចក្តីដោយប្រការដទៃ ព្រះញាណរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ទាំងឡាយ នឹងគប្បីរកភាពជាអចិន្តេយ្យមិនបាន ព្រោះប្រព្រឹត្តទៅស្មើគ្នានឹងញាណរបស់ជនទូទៅ , ព្រោះដូច្នោះ ព្រះញាណនោះ សូម្បីថា មានធម៌ទាំងអស់ជាអារម្មណ៍ ក៏រមែងប្រព្រឹត្តទៅធ្វើធម៌ទាំងនោះ ដែលទ្រង់កំណត់ទុកបានល្អហើយនោះឯង ឲ្យជាអារម្មណ៍ ដូចធ្វើធម៌មួយៗឲ្យជាអារម្មណ៍ សេចក្តីដែលពោលមកយ៉ាងនេះ នេះឈ្មោះថា អចិន្តេយ្យក្នុងទីនេះ ។ សេចក្តីនេះសមដូចដែលព្រះសារីបុត្តពោលទុកថា " **វត្ថុដែលគួរដឹងមានប្រមាណប៉ុណ្ណា ព្រះញាណក៏មានប្រមាណត្រឹមនោះ ព្រះញាណមានប្រមាណប៉ុណ្ណា វត្ថុដែលគួរដឹងក៏មានត្រឹមប៉ុណ្ណោះ ព្រះញាណមានវត្ថុដែលគួរដឹងជាព្រំដែន វត្ថុដែលគួរដឹងមានព្រះញាណជាព្រំដែន** " ។ ព្រះដ៏មាន-ព្រះភាគទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធ** ព្រោះព្រះអង្គត្រាស់ដឹងធម៌ទាំងពួង រួមគ្នា ឬបែកគ្នា ក្នុងគ្រាជាមួយគ្នា ឬតាមលំដាប់ តាមសមគួរដល់ព្រះបំណងដោយប្រពៃនិងដោយព្រះអង្គឯង តាមន័យដូចដែលបានពោលមកដូច្នេះឯង ។

( ចប់ មហាដីកា )

## បទថា វិជ្ជាចរណសម្បន្នោ

ចំណែកដែលទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ក៏ព្រោះទ្រង់ដល់ព្រម ដោយវិជ្ជាទាំងឡាយ និង ចរណៈផង ។ ក្នុង២បទនោះ បទថា **វិជ្ជា** សំដៅយក ទាំងវិជ្ជា ៣ ទាំងវិជ្ជា ៨ ។ **វិជ្ជា ៣** គប្បីជ្រាបតាមន័យដែលពោលក្នុងភយភេរវ-សូត្រ , **វិជ្ជា ៨** គប្បីជ្រាបតាមន័យដែលពោលក្នុងអម្ពដ្ឋសូត្រចុះ អម្ពដ្ឋសូត្រនោះ ព្រះដ៏មានព្រះភាគ ជាម្ចាស់ទ្រង់កំណត់យកអភិញ្ញា ៦ និង វិបស្សនាញាណ និង មនោមយិទ្ធិ ត្រាស់ថា វិជ្ជា ៨ ។

ធម៌ **១៥** ប្រការ នេះគឺ ( ចរណៈ ១៥ ) បានដល់ ៖

- សីលសំវរៈ ១
- ឥន្ទ្រិយេសុគុត្តទ្វារតា ១ ( ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ )
- ភោជនេមត្តញ្ញុតា ១
- ជាគរិយានុយោគ ១
- ព្រះសទ្ធម្ម ៧ ( សទ្ធា ហិរិ ឱត្តប្បៈ ពាហុសច្ចៈ វីរិយៈ សតិ បញ្ញា )
- រូបាវចរឈាន ៤

ទាំងនេះឯងគប្បីជ្រាបថា ឈ្មោះថា **ចរណៈ** មែនពិត ធម៌ **១៥** ប្រការ នេះ លោកហៅថា **ចរណៈ** ព្រោះជាផ្លូវធ្វើដំណើរទៅកាន់ទិសអមតៈនៃព្រះអរិយ-សាវក ដូចព្រះអានន្ទត្ថេរពោល ( ដល់ព្រះបាទមហានាមសក្យ ) ថា “ បពិត្រមហា នាម អរិយសាវកក្នុងព្រះធម្មវិន័យនេះ ជាអ្នកមានសីល ” ដូច្នេះជាដើម ពាក្យរបស់ ព្រះអានន្ទទាំងពួង បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលក្នុង ( សេក្ខបដិបទាសូត្រ

មជ្ឈិមនិកាយ ) មជ្ឈិមបណ្ណាសកៈ នោះចុះ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយវិជ្ជាទាំងនេះ និងចរណៈនេះផង ព្រោះហេតុនោះ ទើបបានព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ដល់ព្រមដោយវិជ្ជា និងចរណៈ ។

ក្នុងការដល់ព្រម ២ យ៉ាងនោះ ការដល់ព្រមដោយវិជ្ជា សាងភាពជាព្រះសព្វញ្ញូនៃព្រះដ៏មានព្រះភាគឡើង ហើយតាំងនៅ ការដល់ព្រមដោយចរណៈ សាងភាពជាអ្នកប្រកបដោយព្រះមហាករុណា នៃព្រះដ៏មានព្រះភាគជាម្ចាស់ឡើង ហើយតាំងនៅ ព្រះអង្គទ្រង់ដឹងវត្ថុដែលជាប្រយោជន៍ និងវត្ថុដែលមិនជាប្រយោជន៍ ដោយភាពជាព្រះសព្វញ្ញូហើយ ទ្រង់វៀរចាកវត្ថុដែលមិនជាប្រយោជន៍ចេញ ទ្រង់ណែនាំតែក្នុងវត្ថុដែលជាប្រយោជន៍ ព្រោះជាអ្នកប្រកបដោយព្រះមហាករុណា ដល់សត្វទាំងពួង ជាគំរូដល់លោកអ្នកដែលដល់ព្រមដោយ វិជ្ជា និង ចរណៈ ព្រោះហេតុនោះ សាវកទាំងឡាយរបស់ព្រះអង្គ ទើបជាអ្នកបដិបត្តិល្អ មិនជាអ្នកបដិបត្តិអាក្រក់ ដូចពួកសាវករបស់ម្ចាស់លទ្ធិទាំងឡាយដែលគ្មានវិជ្ជានិងចរណៈ ដែលជាបុគ្គលជំពូកធ្វើខ្លួនឲ្យក្តៅ ( ធ្វើខ្លួនឯងឲ្យលំបាក ) ជាដើម ដូច្នោះ ។

## មហាដីកា

ក្នុងពាក្យថា **ដោយវិជ្ជាទាំងឡាយ** នេះ មានវិនិច្ឆ័យថា ឈ្មោះថា **វិជ្ជា** ព្រោះបានវត្ថុដែលគួរបាន មានន័យថា បានតាមសេចក្តីពិត ។

ម្យ៉ាងទៀត ឈ្មោះថា **វិជ្ជា** ព្រោះមានន័យថា ចាក់ធ្លុះនូវធម៌ដែលជាបដិបក្ខ

នឹងខ្លួន មានន័យថា ទម្លាយកាពង់នឹតជាដើម ព្រោះទម្លាយគំនរងងឹត នោះឯង ទើបឈ្មោះថា **វិជ្ជា** ព្រោះមានន័យថា ធ្វើអារម្មណ៍របស់ខ្លួនឲ្យប្រាកដ ។

ពាក្យថា **ព្រោះទ្រង់ដល់ព្រម** គឺ ព្រោះទ្រង់ប្រកបព្រម ឬ ព្រោះទ្រង់បរិបូរណ៍ មានន័យថា ព្រោះទ្រង់មិនខុសឆ្គង ។ គប្បីឃើញថា ទ្រង់កាន់យកវិជ្ជា ៣ និង វិជ្ជា ៨ ក្នុងសូត្រនោះ ៗ ក៏ដោយទាក់ទងនឹងអធ្យាស្រ័យនៃ វេនេយ្យសត្វ ។ ឈ្មោះថា **ព្រះសទ្ធម្ម ៧** បានដល់ **សទ្ធា ហិរិ ឱត្តប្ប ពាហុសច្ច វិរិយ សតិ** និង **បញ្ញា** ជាព្រះសទ្ធម្មដែលទ្រង់សំដៅយកត្រាស់ទុកថា " ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា " ដូច្នេះជាដើម ។ ពាក្យថា **ឈាន ៤** គឺ រូបាវចរឈាន ៤ ពួកណាមួយ ។

លោកអាចារ្យសំដៅយកពាក្យដែលសួរថា ក៏ព្រោះហេតុអ្វី ក្នុងពាក្យថាដល់ព្រមដោយវិជ្ជានិងចរណៈនេះ ទ្រង់ត្រាស់ចំពោះធម៌ ១៥ យ៉ាង មានសីលជាដើម ប៉ុណ្ណោះថា " **ចរណៈ** " ទៅវិញ ដូច្នេះពោលថា **ឥមេយេវ ហិ** ដូច្នេះ ជាដើម ។ ដោយពាក្យនោះ លោកពោលដល់ធម៌ទាំងនោះ ឲ្យសម្រេចក្នុងការចូលដល់ព្រះនិព្វានបានដោយពិតប្រាកដ ព្រោះសង្គ្រោះចូលក្នុងសិក្ខា ៣ បាន ។ ឥឡូវនេះ ដើម្បីនឹងធ្វើអត្ថាធិប្បាយនោះឲ្យសម្រេច ទើបលោកសម្ដែងល័ក្ខឋានដែលមានមក ពោលថា " ដូចដែលទ្រង់ត្រាស់ទុកថា " ដូច្នេះជាដើម ។

ពាក្យថា **ព្រះដ៏មានព្រះភាគ** ជាដើម លោកពោលទុកដោយទាក់ទងជាពាក្យបញ្ជាក់ដល់អត្ថន័យដែលបានពោលហើយនោះឯង ។

សួរថា ការដល់ព្រមនៃវិជ្ជា និង ចរណៈ មានបាន សូម្បីក្នុងសាវកទាំងពួងមិនមែនឬ ?

លោកអាចារ្យបំណាងសម្ដែងថា មានពិតមែនហើយ តែមិនដូចជារបស់ព្រះដ៏មានព្រះភាគទេ ដូច្នេះទើបលោកពោលថា " ក្នុងការដល់ព្រម ២ យ៉ាងនោះ ការដល់ព្រមនៃវិជ្ជា ដូច្នេះជាដើម " ។ ព្រោះករុណាព្រហ្មវិហារនោះ រាប់បញ្ចូលក្នុងចរណធម៌ ហើយក្នុងចរណធម៌ទាំងឡាយនេះ ករុណាព្រហ្មវិហារនោះ មានសភាវៈជាសាធារណៈ ( គឺ មានសត្វទាំងឡាយទូទៅជាអារម្មណ៍ ) ព្រោះដល់នូវភាពជាមហគ្គតៈ ព្រោះហេតុនោះ ទើបលោកពោលថា ការដល់ព្រមនៃចរណៈ ធ្វើភាពជាអ្នកមានព្រះមហាករុណាដ៏ពេញប្រៀបតាំងនៅ ដូច្នេះ ។ ដូចជាកាលទ្រង់ញុំាងសត្វទាំងឡាយឲ្យចេញចាកហាយនវត្ថុ ហើយប្រកបក្នុងប្រយោជន៍ វៀរព្រះបញ្ញាចេញមិនបាន យ៉ាងណា កាលទ្រង់ញុំាងសត្វទាំងឡាយនោះ ឲ្យស្គាល់ប្រយោជន៍ និងហាយនវត្ថុ វៀរព្រះករុណារបស់ព្រះសាស្ដាចេញ ក៏មិនបានដូចគ្នា ព្រោះហេតុនោះ ធម្មជាតិ សូម្បីទាំង ២ ( គឺ ព្រះបញ្ញានិងព្រះករុណា ) គប្បីមានកិច្ចរួមគ្នាតែម្យ៉ាងក្នុងកិច្ចទាំង ២ ។ តែថា ធម្មជាតិទាំង ២ នោះ ធម្មជាតិណាមានភាពជាប្រធាន ដើម្បីសម្ដែងធម្មជាតិនោះ ទើបលោកពោលថា **ព្រះដ៏មានព្រះភាគនោះ ដោយភាពជាសព្វញ្ញូជាដើម** ។ ក្នុងពាក្យទាំងនោះ ពាក្យថា **យថាតំ វិជ្ជាចរណសម្បន្នោ** គឺប្រសើរជាងលោកអ្នកដែលដល់ព្រមដោយវិជ្ជានិងចរណៈដទៃ ។ ដោយពាក្យនោះ លោកសម្ដែងថា នេះជាឧបដិបត្តិមួយផ្នែករបស់លោកអ្នកដល់ព្រមដោយ វិជ្ជា និងចរណៈហើយ ។ លោកអាចារ្យបំណាងសម្ដែងថា ការដល់ព្រមនៃវិជ្ជានិងចរណៈរបស់ព្រះសាស្ដា ជាហេតុដ៏ប្រាកដនៃសម្មាបដិបត្តិរបស់សាវកទាំងឡាយ ដោយពាក្យទូន្មាននាំចេញចាកទុក្ខដូច្នេះ ទើបពោលថា ព្រោះហេតុនោះ សាវកទាំងឡាយរបស់ព្រះអង្គនេះ ដូច្នេះជាដើម , ពាក្យនោះ បណ្ឌិតដឹងបានដោយងាយហើយ ។

ម្យ៉ាងវិញទៀត ក្នុងការដល់ព្រម ២ យ៉ាងនេះ ដោយការដល់ព្រមនៃវិជ្ជា ជាការប្រកាសភាពអស្ចារ្យនៃព្រះបញ្ញារបស់ព្រះសាស្តា ដោយការដល់ព្រមនៃចរណៈជាការប្រកាសភាពអស្ចារ្យនៃព្រះករុណា ។ ក្នុងធម៌ ២ យ៉ាងនោះ ព្រះដ៏មានព្រះភាគ ទ្រង់ដល់នូវភាពជាព្រះធម្មរាជាដោយព្រះបញ្ញា ទ្រង់ចែកធម៌ដោយព្រះករុណា ទ្រង់នឿយណាយក្នុងសង្សារទុក្ខដោយព្រះបញ្ញា ទ្រង់អត់ធន់ក្នុងសង្សារទុក្ខដោយព្រះករុណា ទ្រង់កំណត់ដឹងទុក្ខរបស់អ្នកដទៃដោយព្រះបញ្ញា ទ្រង់ប្រារព្ធការបំបាត់ទុក្ខរបស់អ្នកដទៃដោយព្រះករុណា ។ ទ្រង់ឆ្ពោះព្រះភក្ត្រទៅកាន់ការបរិនិព្វានដោយព្រះបញ្ញា ទ្រង់សម្រេចព្រះនិព្វាននោះដោយព្រះករុណា ទ្រង់ឆ្លងព្រះអង្គឯងដោយព្រះបញ្ញា ទ្រង់ញុំាងសត្វដទៃឲ្យឆ្លងដោយព្រះករុណា ។ ទ្រង់សម្រេចភាពជាព្រះពុទ្ធដោយព្រះបញ្ញា ទ្រង់សម្រេចព្រះពុទ្ធកិច្ចដោយព្រះករុណា ។ ក្នុងភូមិនៃព្រះពោធិសត្វ ( ក្នុងសម័យដែលទ្រង់នៅជាព្រះពោធិសត្វ ) ទ្រង់ឆ្ពោះទៅកាន់សង្សារវដ្តដោយព្រះករុណា ទ្រង់រកការត្រេកអរក្នុងសង្សារវដ្តនោះមិនបាន ដោយព្រះបញ្ញា ។ យ៉ាងនោះដូចគ្នាដែរ ទ្រង់ញុំាងសត្វដទៃឲ្យអស់ភ័យដោយព្រះករុណា ទ្រង់អស់ភ័យព្រះអង្គឯងអំពីសត្វដទៃដោយព្រះបញ្ញា ។ ទ្រង់រក្សាអ្នកដទៃដោយព្រះករុណា ទ្រង់រក្សាព្រះអង្គឯងដោយព្រះបញ្ញា កាលទ្រង់រក្សាព្រះអង្គឯងដោយព្រះបញ្ញា ក៏ទ្រង់រក្សាអ្នកដទៃទុកបាន ។ យ៉ាងនោះដូចគ្នាដែរ ទ្រង់មិនធ្វើសត្វដទៃឲ្យក្តៅក្រហាយដោយព្រះករុណា ទ្រង់មិនធ្វើព្រះអង្គឯងឲ្យក្តៅក្រហាយដោយព្រះបញ្ញា ។ ព្រោះហេតុនោះ ទើបទ្រង់ជាអ្នកសម្រេចភាពជាបុគ្គលទី ៤ ( គឺ បដិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងដើម្បីប្រយោជន៍អ្នកដទៃ ) ក្នុងបណ្តាបុគ្គល ៤ ជំពូក ដែលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនជាដើម ។ យ៉ាងនោះដូចគ្នាដែរ ទ្រង់មានភាពជាព្រះលោកនាថ ( ទី

ពឹងរបស់លោក ) ដោយព្រះករុណា ទ្រង់មានភាពជាអត្តនាថ ( ទីពឹងនៃខ្លួនឯង ) ដោយព្រះបញ្ញា ។

ម្យ៉ាងវិញទៀត ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់មានភាពទន់ភ្លន់ដោយ ព្រះមហាករុណា ទ្រង់លើកព្រះអង្គឯងដោយព្រះបញ្ញា ។ យ៉ាងនោះ ដូចគ្នាដែរ ទ្រង់មានសេចក្ដីអនុគ្រោះក្នុងសត្វទាំងឡាយដោយព្រះករុណា តែព្រោះទ្រង់បណ្ដោយតាមព្រះបញ្ញា ទើបទ្រង់ជាអ្នកមានចិត្តប្រាសចាកតម្រេកក្នុងសត្វទាំងពួង ទ្រង់ជាអ្នកមានចិត្តប្រាសចាកតម្រេកក្នុងធម៌ទាំងពួងដោយព្រះបញ្ញា តែព្រោះ ទ្រង់បណ្ដោយតាមព្រះករុណា ទើបទ្រង់មិនយាងទៅ ដើម្បីប្រោសសត្វទាំងពួង ក៏ទេ ។ ដូចជាព្រះករុណារបស់ព្រះដ៏មានព្រះភាគ ជាធម្មជាតិដែលវៀរចាកសេចក្ដីស្នេហា និងសេចក្ដីសោក យ៉ាងណា ព្រះបញ្ញា ក៏ជាធម្មជាតិដែលរួចផុតអំពីអហង្ការ ( ការយល់ឃើញថា ជាយើង ) និង មមង្ការ ( ការយល់ឃើញថា ជារបស់យើង ) ក៏ដូច្នោះ ព្រោះហេតុនោះ ទើបគួរឃើញថា គុណវិសេសដែលបរិសុទ្ធយ៉ាងក្រៃលែងសូម្បីតែម្យ៉ាង ក៏ជម្រះគ្នានិងគ្នាឲ្យបរិសុទ្ធ លោកបានប្រកាសហើយដោយការដល់ព្រមនៃ វិជ្ជា និង ចរណៈ ដូច្នេះឯង ។

( ចប់ មហាដីកា )

# បទថា សុគតោ ៤ ន័យ

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ព្រះនាមថា **សុគតោ** ព្រោះទ្រង់មានផ្លូវយាងទៅល្អ ១ ព្រោះទ្រង់យាងទៅកាន់សុន្ទរស្ថាន ១ ព្រោះទ្រង់មានដំណើរល្អ ១ ព្រោះទ្រង់ត្រាស់ដោយល្អ ១ ។

## ន័យទី១ ទ្រង់មានផ្លូវយាងទៅល្អ

ព្រោះថា សូម្បី **គមន** ( ផ្លូវទៅ ) ក៏ហៅថា **គត** បាន ឯផ្លូវទៅនោះរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ជាផ្លូវស្អាត គឺជាផ្លូវបរិសុទ្ធ មិនមានទោស។ សួរថា ផ្លូវទៅនោះ គឺអ្វី ? ឆ្លើយថា គឺ **អរិយមគ្គ** ។ ពិតណាស់ ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ យាងទៅកាន់ទិសដ៏ក្សេម មិនទើសទាក់បាន ក៏ដោយផ្លូវបែបនោះ ហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះទ្រង់មានផ្លូវយាងទៅល្អ ។

## ន័យទី ២ ទ្រង់យាងទៅកាន់សុន្ទរស្ថាន

ម្យ៉ាងវិញទៀត ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ ទ្រង់យាងទៅកាន់សុន្ទរស្ថាន គឺ អមតៈ មហានិព្វាន ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះស្តេចយាងទៅកាន់សុន្ទរស្ថានហើយ ប្រការ ១ ។

## ន័យទី ៣ ទ្រង់មានដំណើរល្អ

ម្យ៉ាងវិញទៀត ព្រះអង្គយាងទៅហើយដោយប្រពៃ គឺ មិនត្រឡប់មកកាន់កិលេសទាំងឡាយដែលទ្រង់លះបង់បានហើយ ដោយមគ្គនោះៗ ទៀតឡើយ សមដូចពាក្យដែលពោល ( ក្នុងបដិសម្ភិទាមគ្គ ) ថា កិលេសពួកណាដែលលះបង់ហើយ

ដោយសោតាបត្តិមគ្គ ព្រះអង្គទ្រង់មិនបែរមក ទ្រង់មិនវិលមក ទ្រង់មិនត្រឡប់មកកាន់កិលេសទាំងនោះទៀតឡើយ ព្រោះដូច្នោះ ព្រះអង្គទើបព្រះនាមថា **សុគតោ** ។ ល ។ កិលេសពួកណាដែលទ្រង់លះបង់បានហើយដោយអរហត្តមគ្គ ព្រះអង្គមិនបែរមក ទ្រង់មិនវិលមក ទ្រង់មិនត្រឡប់មកកាន់កិលេសទាំងឡាយនោះទៀតឡើយ ព្រោះហេតុនោះ ព្រះអង្គទើបព្រះនាមថា **សុគតោ** ដូច្នេះ ។

ម្យ៉ាងទៀត ស្ដេចយាងទៅដោយប្រពៃ គឺ ទ្រង់ធ្វើតែប្រយោជន៍ និងសេចក្ដីសុខដល់លោកទាំងពួង ដោយព្រះសម្មាបដិបត្តិ ព្រោះទ្រង់បំពេញព្រះសមតឹង្ស-បារមី ចាប់ផ្ដើមអំពី ( កាលដែលតាំងព្រះបណិធាន ) ទៀបបាទមូលព្រះពុទ្ធទីបង្ករ ដ៏រាបដល់កាលដែលព្រះពោធិញ្ញាណចាស់ក្លា និងព្រោះទ្រង់យាងទៅ ( ជាមជ្ឈិមា ) មិនចូលជិតអន្ត: ( ២ គូ ) គឺ **សស្សត-ឧច្ឆេទ** ( គូ១ ) **កាមសុខ-អត្តកិលមថ** (គូ១) ហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះស្ដេចយាងទៅដោយប្រពៃប្រការ ១ ។

## ន័យទី ៤ ទ្រង់ត្រាស់ដោយល្អ

ម្យ៉ាងវិញទៀត ព្រះអង្គរមែងត្រាស់ដោយប្រពៃ គឺ ទ្រង់ពោលវាចាដែលគួរក្នុងឋានៈដែលគួរ ហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះទ្រង់ត្រាស់ដោយប្រពៃប្រការ ១ ( សេចក្ដីក្នុងអភ័យរាជកុមារសូត្រតទៅ ) នេះជាសូត្រសាធកៈក្នុងសេចក្ដីនោះ គឺ ៖

១- តថាគតដឹងវាចាណាថា ជាវាចាមិនពិត មិនមែន មិនប្រកបដោយប្រយោជន៍ , ហើយវាចានោះមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់បុគ្គលដទៃ តថាគតរមែងមិនពោលវាចានោះឡើយ ។

២- សុម្បីវាចាណា ដែលតថាគតដឹងថា ជាវាចាពិត តែមិនប្រកបដោយប្រយោជន៍ ហើយវាចានោះមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អ្នកដទៃផង សុម្បីវាចានោះ តថាគតក៏មិនពោល ។

៣- ចំណែកវាចាណា តថាគតដឹងថា ជាវាចាពិត ប្រកបដោយប្រយោជន៍ សុម្បីវាចានោះមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អ្នកដទៃ ក្នុងសេចក្តីនោះ តថាគតរមែងជាអ្នកស្គាល់កាលដែលនឹងគួរពោលវាចានោះ ។

៤- តថាគតដឹងវាចាណាថា ជាវាចាមិនពិត មិនមែន មិនប្រកបដោយប្រយោជន៍ សុម្បីវាចានោះជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អ្នកដទៃ តថាគតក៏មិនពោលវាចានោះ ។

៥- សុម្បីវាចាណា ដែលតថាគតដឹងថា ជាវាចាពិត តែមិនប្រកបដោយប្រយោជន៍ សុម្បីវាចានោះជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មនុស្សដទៃ សុម្បីវាចានោះ តថាគតក៏មិនពោល ។

៦- ចំណែកវាចាណា តថាគតដឹងថា ជាវាចាពិត ប្រកបដោយប្រយោជន៍ ហើយវាចានោះ ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អ្នកដទៃផង ក្នុងសេចក្តីនោះ តថាគតរមែងជាអ្នកស្គាល់កាល ដែលនឹងគួរពោលវាចានោះ ។

ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ បណ្ឌិតគប្បីជ្រាបថា ទ្រង់ព្រះនាមថា **សុគតោ** ព្រោះទ្រង់ត្រាស់ដោយប្រពៃ ដូចពោលមកដូច្នេះ ប្រការ ១ ។

# មហាដីកា

សូម្បីការដើរទៅ លោកក៏ហៅថា **គត** បាន ដូចក្នុងពាក្យថា **គតេ ឋិតេ** ក្នុងការដើរ ក្នុងការឈរ ដូច្នេះជាដើម ( ឲ្យឃើញថា ពាក្យថា **គត** ប្រើជាពាក្យនាមបានប៉ុណ្ណោះ ) ។ បទថា **សោភណំ** ប្រែថា ល្អស្អាត ។ ភាពល្អស្អាតមានព្រោះសេចក្តីបរិសុទ្ធិ សេចក្តីបរិសុទ្ធិមានបានព្រោះការប្រាសចាកទោស ព្រោះហេតុនោះ ទើបលោកពោលទុកថា " **បរិសុទ្ធិ មិនមានទោស** " ។

ម្យ៉ាងវិញទៀត ដែលបានឈ្មោះថា **ផ្លូវទៅ** មានច្រើនយ៉ាង ព្រោះហេតុនោះលោកអាចារ្យកាលនឹងសម្តែងផ្លូវទៅ ដែលបំណងយកក្នុងទីនេះ ទើបពោលថា គឺ **ព្រះអរិយមគ្គ** ។ ពិតណាស់ ព្រះអរិយមគ្គនោះ ហៅថា " **គត** និងថា **គមន** " ព្រោះធ្វើវចនត្ថៈថា ជាផ្លូវទៅ គឺ ជាឧបាយសម្រេចព្រះនិព្វាន ។ ឥឡូវនេះ លោកបំណងសម្តែងហេតុនៃការកាន់យកព្រះអរិយមគ្គនោះឯង ទើបពោលថា " ពិតណាស់ ព្រះដ៏មានព្រះភាគអង្គនោះ ដោយផ្លូវទៅនោះ " ដូច្នេះជាដើម ។ ពាក្យថា **ទិសដ៏ក្សេម** បានដល់ ព្រះនិព្វាន ។ ពាក្យថា **មិនជាប់ជំពាក់** បានដល់ មិនជាប់ជំពាក់ គឺ មិនធ្វើការជាប់ជំពាក់ សូម្បីក្នុងផ្លូវទៅកាន់សុគតិ ព្រោះមិនមានអន្តរាយ ចាំបាច់និយាយថ្វីដល់ផ្លូវទៅក្រៅអំពីនេះនោះ ។

ន័យម្យ៉ាងទៀត ព្រះអង្គទ្រង់គង់លើអាសនៈមួយហើយ អំពីនេះទៅ ក៏យាងទៅ មិនជាប់ជំពាក់ ដោយទ្រង់បានមគ្គទាំង ៤ ដោយអំណាចនៃវិប្បាកិញ្ញា ( ត្រាស់ដឹងដោយឆាប់រហ័ស ) នោះឯង ព្រះដ៏មានព្រះភាគ ស្តេចយាងទៅផ្លូវណា

ក៏ទ្រង់កម្ចាត់អនត្ថៈ(សេចក្តីវិនាស)ទាំងពួង ហើយទ្រង់នាំមកនូវសម្បត្តិដ៏កំពូលទាំងពួង ផ្លូវនោះឯងឈ្មោះថា ល្អ , ដែលជាហេតុឲ្យព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **សុគត** ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា " **ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា សុគត ព្រោះទ្រង់មានផ្លូវយាងទៅដ៏ល្អ** " ព្រោះធ្វើអធិប្បាយថា **សុ** ស័ព្ទ ( ក្នុងពាក្យថា **សុគត** ) មានអត្ថន័យថា ល្អ ។ **អសង្ខតធាតុ** ឈ្មោះថា ល្អ តែម្យ៉ាង ព្រោះជាសុខដ៏លើសលប់ ព្រោះមិនមានការប្រព្រឹត្តទៅនៃសង្ខារដែលមិនស្អាត គឺ ជាទុក្ខ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ម្យ៉ាងវិញទៀត ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់យាងទៅកាន់សុន្ទរស្ថាន គឺ អមតៈមហានិព្វាន ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទើបទ្រង់ត្រាស់ទុកថា " **និព្វានំ បរមំ សុខំ** " ព្រះនិព្វានជាសុខដ៏ក្រៃលែង ។ បទថា **សម្មា** ប្រែថា ល្អ ។ ឈ្មោះថា **មានដំណើរល្អ** ជាការទៅនៃលោកអ្នកមិនត្រូវធម៌ដែលជាបដិបក្ខគ្របសង្កត់ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលទុកថា **ទ្រង់មិនវិលត្រឡប់មកកាន់កិលេសទាំងឡាយដែលទ្រង់លះបង់បានហើយ ( ដោយមគ្គនោះៗ ) ទៀតឡើយ** ។ លោកអាចារ្យបំណាងសម្តែងថា គឺ ស្តេចមានដំណើរល្អ ដល់នូវភាពជាកំពូលនេះ សម្រេចហើយដោយបដិបទាដែលជាហេតុមកឯណា បដិបទានោះ ក៏ឈ្មោះថា ទ្រង់យាងទៅដោយប្រពៃដូចគ្នា ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ព្រះនាមថា **សុគត** ដោយប្រការយ៉ាងនេះ ដូច្នេះ ទើបពោលថា ម្យ៉ាងទៀត ព្រះអង្គមានដំណើរល្អ ដូច្នេះជាដើមៗ ពាក្យថា **ដោយព្រះសម្មាបដិបត្តិ** គឺ ដោយការបដិបត្តិ ដែលមិនវិបរិតក្នុងការសម្រេចនូវសម្មាសម្ពោធិញ្ញាណ ។ ដោយពាក្យថា **ធ្វើតែប្រយោជន៍ និង សេចក្តីសុខដល់លោកទាំងពួង** នេះលោកសម្តែងថា បដិបទាដើម្បីការត្រាស់ដឹងដ៏ប្រពៃ

រមែងប្រព្រឹត្តទៅដោយការៈដែលនាំមកនូវប្រយោជន៍សុខដល់សត្វទាំងពួង ដោយមិនមានការបែងចែកអស់កាលទាំងពួង ។ ដោយពាក្យថា **ស្តេចយាងទៅមិនចូលជិតអន្តៈ ( ២ គូ )** គឺ សស្សតៈ ( ការឋិតថេរ ) ឧច្ឆេទៈ ( ការដាច់សូន្យ ) នេះលោកសំដៅដល់គតិនៃបដិច្ចសមុប្បាទ ដោយពាក្យថា ស្តេចយាងទៅមិនចូលជិតចំណែកទាំងនេះ គឺ កាមសុខ និង ការធ្វើខ្លួនឲ្យលំបាក នេះ លោកសម្តែងដល់គតិនៃព្រះអរិយមគ្គ ។ បទថា **តត្រ** គឺ ក្នុងការត្រាស់វាចា ដែលសមគួរក្នុងឋានៈដែលសមគួរប៉ុណ្ណោះ ក៏ពាក្យនេះជាសត្តមីវិភត្តិប្រើក្នុងអត្ថថា គប្បីធ្វើឲ្យកើតឡើង គឺ គប្បីធ្វើឲ្យសម្រេច ។ ពាក្យថា **មិនពិត** គឺ រកខ្លឹមសារដែលពិតមិនបាន ។ ដោយវាចាមានភាពមិនពិត ឬមានភាពពិត ក៏ដោយអាស្រ័យអត្ថន័យជាសំខាន់ ។ ពាក្យថា **មិនមែន** ក៏ជាពាក្យវេវចនស័ព្ទនៃពាក្យថា **មិនពិត** នោះឯង ។ម្យ៉ាងទៀត បទថា **អភូតំ** កែជា **អសន្តំ** ប្រែថា មិនមានប្រាកដ ។

បទថា **អតច្ឆំ** បានដល់ មានអាការដែលមិនមែន គឺ មាននៅដោយអាការដទៃ ។ ពាក្យថា **ប្រកបដោយអនត្ថៈ** គឺ ប្រកបដោយអនត្ថៈ ( វត្ថុដែលមិនជាប្រយោជន៍ វត្ថុដែលជាបដិបក្ខចំពោះប្រយោជន៍ ) ក្នុងបច្ចុប្បន្ន និង ខាងមុខ បានដល់ ជាហេតុនាំមកនូវអនត្ថៈ ។ ឈ្មោះថា **អនត្ថ** ព្រោះអត្ថថា មិនមែនប្រយោជន៍ បានដល់ វត្ថុជាបដិបក្ខចំពោះប្រយោជន៍ និងការមិនមាននៃប្រយោជន៍ ។ សេចក្តីថា ( មិនត្រាស់ ) វាចាដែលប្រកបដោយអនត្ថៈនោះ គឺ បិសុណាវាចា និង សម្ផប្បលាបៈ ។ គប្បីឃើញថា ក្នុងពាក្យនេះសង្គ្រោះយកវចីទុច្ចរិតទាំង ៤ យ៉ាង តាមប្រការដែលពោលមកនេះ ។ ម្យ៉ាងវិញទៀត ក្នុងវាចាទាំង ៦ យ៉ាងនេះ កាលពោលដល់បុគ្គលអ្នកមានសីល ដោយពាក្យថា **បុគ្គលទ្រុស្តសីល** កាលពោលដល់បុគ្គល

ដែលមិនមែនចណ្ឌាលជាដើមនោះឯង ដោយពាក្យថា **មនុស្សចណ្ឌាល** ជាដើម គប្បីជ្រាបថា ជាវាចាប្រការទី ១ ( **មិនពិត មិនមែន** ប្រកបដោយអនត្ថៈ មិនជាទីស្រឡាញ់ ។ល។ ) កាលពោលដល់បុគ្គលទ្រុស្តសីល ដោយពាក្យថា **បុគ្គលទ្រុស្តសីល** កាលពោលដល់បុគ្គលចណ្ឌាលជាដើមនោះឯង ដោយពាក្យថា **បុគ្គលចណ្ឌាល** ជាដើម រកន័យពិសេសមិនបាន ក៏គប្បីឃើញថា ជាវាចាប្រការទី ២ ( **ពិត** ប្រកបដោយអនត្ថៈ មិនជាទីស្រឡាញ់ ។ ល ។ ) ។

ពាក្យនិយាយចំហរ ដល់នូវភាពជាសត្វនរកជាដើម នៃសត្វនរកជាដើម ដូចជាពាក្យនិយាយថា " **ភិក្ខុទេវទត្តកើតក្នុងអបាយ ជាសត្វនរក** " ដូច្នេះជាដើម គប្បីឃើញថា ជាវាចាប្រការទី ៣ ( **ពិត** ហើយប្រកបដោយប្រយោជន៍ មិនជាទីពេញចិត្ត ។ ល ។ ) ។

ពាក្យពោលដោយភាពវង្វេងការពិតរបស់សត្វលោក យ៉ាងនេះថា " ការសម្លាប់សត្វជាដើម ដែលបុគ្គលធ្វើដោយយញ្ញវិធី ដែលផ្សេងគ្នាដោយវេទ រមែងនាំមកនូវសុគតិ " ដូច្នេះ គប្បីឃើញថា ជាវាចាប្រការទី ៤ ( **មិនពិត មិនមែន** ប្រកបដោយអនត្ថៈ ជាទីពេញចិត្ត ។ ល ។ ) ។

ពាក្យពោលដែលបន្លំនទៅ ដើម្បីការបែកគ្នាជាដើម ដោយរឿងមិនពិត គប្បីឃើញថា ជាវាចាទី ៥ , ពិត ប្រកបដោយអនត្ថៈ ជាទីស្រឡាញ់ ។ ល ។

ពាក្យពោលដល់ ទាន សីល ជាដើម ដែលធ្វើឲ្យប្រព្រឹត្តទៅក្នុងឋានៈដែលដល់នូវភាពជាវាចាដែលសមគួរ គប្បីជ្រាបថា ជាវាចាប្រការទី ៦ ( **ពិត មែន** ប្រកបដោយប្រយោជន៍ ជាទីពេញចិត្ត ។ ល ។ ) ។

ពាក្យថា **ព្រោះត្រាស់ដោយល្អ** ដោយប្រការដូចដែលពោលទុកយ៉ាងនេះ

បានដល់ ព្រោះត្រាស់ដោយប្រពៃ គឺដោយល្អនូវវាចាដែល **ពិត មែន** ប្រកបដោយប្រយោជន៍ គួរស្រឡាញ់ គួរពេញចិត្ត វៀរចាកវាចាដែលមិនពិតជាដើម តាមដែលពោលហើយនោះឯង ទើបទ្រង់ព្រះនាមថា **សុគត** ព្រោះធ្វើ **ទ** អក្សរ ឲ្យជា **ត** អក្សរ ។ ពិតណាស់ ព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ សូម្បីថា មិនជាទីស្រឡាញ់សម្រាប់មនុស្សខ្លះ ដោយគ្រាន់តែមកដល់គន្លង ( សោតទ្វារ ) ក៏ឈ្មោះថា គួរស្រឡាញ់ គួរពេញចិត្តដែរ ព្រោះជាហេតុឲ្យសម្រេចប្រយោជន៍ គឺព្រោះនាំមកនូវប្រយោជន៍សុខដល់សត្វលោក ។

ន័យម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **សុគត** ព្រោះអត្ថថា ទ្រង់មាន **គត** គឺ មានដំណើរល្អ ។ ពិតណាស់ ការចូលទៅរកវេនេយ្យជននៃព្រះដ៏មានព្រះភាគ ជាកិរិយាដែលល្អ គឺ ចម្រើន ព្រោះឲ្យសម្រេចប្រយោជន៍សុខដល់ជនទាំងនោះ តែម្យ៉ាង ។ ម្យ៉ាងវិញទៀត ព្រោះទ្រង់មានព្រះរូបកាយប្រដាប់ហើយ ដោយព្រះមហាបុរិសលក្ខណៈ និងព្រះអនុព្យញ្ជនៈ ការយាងទៅដោយព្រះកាយ ទើបជាការយាងទៅដូចព្រះរាជា ស្តេចហង្ស ស្តេចគោ ស្តេចដំរី ស្តេចម្រឹគ , យាងយាសប្រាសចាកទោស មានការដើរទប់កាយ ( ដោយឈើច្រត់ ) ដើរវាស ដើរជំទើតចុងជើង ដើរធ្ងន់កែងជើង ដើរខ្ញុំចុងម្រាម ដើរពើងខ្លួន ដើររលះរលាំង ជាដើមដែលគួរស្អប់ , ទើបជាដំណើរល្អ និង ការទៅដោយព្រះញាណដែលប្រកបដោយគុណវិសេស មានព្រះករុណា ព្រះសតិ ព្រះវិរិយៈជាដើម ដែលរុងរឿងចាកមន្ទិល ក៏ជាកិរិយាដែលល្អនោះឯង ព្រោះប្រាសចាកទោស និងព្រោះនាំមកនូវប្រយោជន៍សុខដល់សត្វទាំងឡាយ រាប់តាំងពីទ្រង់បង្អោនព្រះទ័យទៅរហូតដល់ការត្រាស់ដឹងដ៏អស្ចារ្យ ( ជាទីបំផុត ) ។

ន័យម្យ៉ាងទៀត កាលទ្រង់កំណត់ដឹងនូវលោក សូម្បីទាំងមូលដោយព្រះសយម្ភូញាណ ដោយអំណាចនៃបរិញ្ញាភិសម័យ ( ការត្រាស់ដឹង គឺ ការកំណត់ដឹង ) ឈ្មោះថា **យាងទៅ** គឺ ទ្រង់ត្រាស់ដឹងដោយប្រពៃ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគត** ។ យ៉ាងនោះដូចគ្នា កាលទ្រង់លះបង់ហេតុកើតឡើងនៃលោកដោយអំណាចនៃបហានាភិសម័យ ( ការត្រាស់ដឹង គឺ លះបង់ ) ធ្វើឲ្យដល់នូវភាពមិនកើតឡើងជាធម្មតា ក៏ឈ្មោះថា **យាងទៅ** គឺ ទ្រង់កន្លងបង់បានដោយប្រពៃ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគត** ។ ព្រះអង្គយាងទៅ គឺ ទ្រង់សម្រេចដោយប្រពៃនូវការរំលត់នៃលោក គឺ ព្រះនិព្វាន ដោយអំណាចនៃសច្ឆិកិរិយាភិ-សម័យ ( ការត្រាស់ដឹង គឺ ធ្វើឲ្យជាក់ច្បាស់ ) ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគត** ។ ព្រះអង្គយាងទៅ គឺ ទ្រង់បដិបត្តិដោយប្រពៃនូវបដិបទាដែលឲ្យដល់នូវភាពរំលត់នៃលោកដោយអំណាចនៃភាវនាភិសម័យ ( ការត្រាស់ដឹង គឺ ចម្រើន ) ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគត** ។ ម្យ៉ាងទៀត វត្ថុណានៃលោកព្រមទាំងទេវលោកនេះ ដែលជាវត្ថុគួរឃើញបាន ឮបាន ប៉ះពាល់បាន ដឹងបាន ប្រព្រឹត្តទៅបាន ស្វែងរកបាន សត្វប្រើចិត្តត្រាច់តាមទៅបាន ព្រះអង្គយាងទៅ គឺ ដឹងក្រៃលែងនូវវត្ថុនោះ ទាំងអស់ដោយប្រពៃ គឺ ដោយប្រចក្ស ដូចបុគ្គលសម្លឹងមើលផ្លែកន្ទួតព្រៃលើបាតដៃដូច្នោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគត** ។

( ចប់ មហាដីកា )

# បទថា លោកវិទូ

## "លោកយាវថា "

រីឯទ្រង់ព្រះនាមថា *លោកវិទូ* ក៏ព្រោះទ្រង់ត្រាស់ដឹងនូវលោក ដោយប្រការទាំងពួង ពិតណាស់ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បានត្រាស់ដឹង គឺ ជ្រាបសព្វគ្រប់នូវលោកដោយប្រការទាំងពួង គឺ ដោយសភាវៈ ដោយសមុទយៈ ដោយនិរោធ ដោយនិរោធគាមិនីបដិបទា ដូចទ្រង់ត្រាស់ទីង ( រោហិតស្សទេវបុត្ត ) ថា " ម្នាលអាវុសោ ក្នុងទីបំផុតនៃលោកឯណា សត្វមិនកើត មិនចាស់ មិនស្លាប់ មិនចុតិ មិនឧប្បត្តិ តថាគតមិនពោលនូវទីបំផុតនៃលោកនោះថា ជាទីកន្លែងគួរដឹង គួរឃើញ គួរទៅដល់ដោយដំណើរជើងឡើយ តែតថាគតក៏មិនពោលថា បើមិនទាន់ដល់ទីបំផុតនៃលោក នឹងធ្វើទីបំផុតនៃទុក្ខបាននោះក៏ទេ តថាគតបញ្ញត្តលោក និងលោកសមុទយ លោកនិរោធ លោកនិរោធគាមិនីបដិបទា (ចុះក្នុង ) រាងកាយដែលមានប្រវែងប្រមាណ ១ ព្យាម មានសញ្ញា មានចិត្ត ឯណោះទេ ។

ទីបំផុតនៃលោកបុគ្គលមិនគប្បីទៅដល់បាន ដោយជើងឡើយ តែថា បើមិនទាន់ដល់ទីបំផុតនៃលោកទេ នឹងរួចផុតចាកទុក្ខបាន ក៏ទេ ព្រោះហេតុនោះ អ្នកមានបញ្ញាល្អដែលដល់ទីបំផុតនៃលោក មានព្រហ្មចរិយៈចប់ហើយ ស្ងប់ហើយ ដឹងទីបំផុតនៃលោកហើយ ទើបមិនប្រាថ្នាទាំងលោកនេះ និងលោកខាងមុខ ។

### លោក ៣

ន័យម្យ៉ាងទៀត លោកមាន ៣ គឺ សង្ខារលោក សត្វលោក ឱកាសលោក

ក្នុងលោក ៣ នោះ ៖

១- សង្ខារលោក គប្បីជ្រាបក្នុងអាគតដ្ឋាន ( បាលី ) ថា “ លោក ១ គឺ សត្វទាំងឡាយរស់នៅបានដោយអាហារ ” ។

២- សត្វលោក គប្បីជ្រាបក្នុងអាគតដ្ឋាន ( បាលី ) ថា “ (ឃើញ) ថា លោកទៀងខ្លះ លោកមិនទៀងខ្លះ ” ។

៣- ឱកាសលោក គប្បីឃើញក្នុងអាគតដ្ឋាន ( បាលី ព្រហ្មនិមន្តនិកសូត្រ ) ថា “ ព្រះចន្ទនិងព្រះអាទិត្យ អណ្តែតទៅជុំវិញ ( ចក្កវាឡ ) ធ្វើឲ្យទិសទាំងឡាយភ្លឺស្វាង ដោយទីមានប្រមាណប៉ុណ្ណា លោកក្នុងទីមានប្រមាណប៉ុណ្ណោះ មាន ១.០០០ ចំណែក ( ក្នុង ) អំណាចនៃអ្នកផ្សព្វផ្សាយទៅក្នុងលោកទាំងនោះ ” ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានត្រាស់ដឹងនូវលោកទាំង ៣ នោះ ដោយប្រការទាំងពួង , ពិតហើយ សូម្បីសង្ខារលោក គឺ ៖

| | | |
|---|---|---|
| - លោក ១ | គឺ សត្វទាំងពួង រស់នៅបានដោយសារអាហារ | |
| - លោក ២ | គឺ នាម ១ រូប ១ | |
| - លោក ៣ | គឺ វេទនា | ៣ |
| - លោក ៤ | គឺ អាហារ | ៤ |
| - លោក ៥ | គឺ ឧបាទានក្ខន្ធ | ៥ |
| - លោក ៦ | គឺ អាយតនៈខាងក្នុង | ៦ |
| - លោក ៧ | គឺ វិញ្ញាណដ្ឋិតិ | ៧ |

- លោក ៨ គឺ លោកធម៌ ៨
- លោក ៩ គឺ សត្តាវាស ៩
- លោក ១០ គឺ អាយតនៈ ១០
- លោក ១២ គឺ អាយតនៈ ១២
- លោក ១៨ គឺ ធាតុ ១៨

នេះព្រះអង្គក៏ទ្រង់ត្រាស់ដឹងដោយប្រការទាំងពួង ។ ម្យ៉ាងវិញទៀត ព្រោះហេតុដែលព្រះអង្គ ទ្រង់ដឹងនូវ **អាសយ** ( ទីអាស្រ័យនៃចិត្ត ) , ទ្រង់ដឹង **អនុសយ** ( កិលេសដែលដេកត្រាំក្នុងសន្តាន ) , ទ្រង់ដឹង **ចរិត** ( ប្រក្រតីរបស់ចិត្ត ) , ទ្រង់ដឹង **អធិមុត្តិ** ( ការបង្អោនទៅនៃចិត្ត ) របស់សត្វទាំងពួង ទ្រង់ដឹងសត្វទាំងឡាយដែលមានកិលេសដូចធូលីក្នុងភ្នែកតិច មានធូលីក្នុងភ្នែកច្រើន មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ខ្សោយ មានអាការល្អ មានអាការថោកទាប មានអាការគ្រោតគ្រាត នឹងគប្បីឲ្យត្រាស់ដឹងបានងាយ ឲ្យត្រាស់ដឹងបានដោយលំបាក ជាភព្វសត្វ ជាអភព្វសត្វ ព្រោះហេតុនោះ សូម្បីសត្វលោក ក៏ទ្រង់ដឹងដោយប្រការទាំងពួង ។

ម្យ៉ាងទៀត សត្វលោកព្រះអង្គទ្រង់ដឹងយ៉ាងណា សូម្បីឱកាសលោក ក៏ទ្រង់ដឹងពិតដូច្នោះដូចគ្នា.... ។

## ខ្នាតរបស់ចក្រវាល

ចក្កវាឡទីមួយៗ មានបណ្តោយនិងទទឹង ប្រមាណ ១.២០៣.៤៥០ យោជន៍ ដោយជុំវិញ ។

បរិមណ្ឌលទាំងមូល ប្រមាណ ៣.៦១០.៣៥០ យោជន៍ ។

## ខ្នាតរបស់ផែនដី

ក្នុងចក្កវាឡនោះ ផែនដីនេះពោលដោយកម្រាស់ មានប្រមាណដល់ប៉ុណ្ណេះ គឺ ២៤០.០០០ យោជន៍ ។

## ខ្នាតរបស់ទឹកទ្រផែនដី

វត្ថុដែលទ្រផែនដីនោះ គឺ ទឹកដែលតាំងនៅលើខ្យល់ ដោយកម្រាស់ មានប្រមាណប៉ុណ្ណេះ គឺ ៤៨០.០០០ យោជន៍ ។

## ខ្នាតរបស់ខ្យល់ទ្រទឹក

ខ្យល់ដែលផាត់ឡើងលើ ដោយកម្រាស់ មានប្រមាណ ៩៦០.០០០ យោជន៍ នេះជាការតាំងនៅបាតនៃលោក ។

## ខ្នាតភ្នំសិនេរុ និង ដើមឈើប្រចាំទ្វីប

ម្យ៉ាងវិញទៀត ក្នុងចក្រវាលដែលតាំងនៅ ព្រមដោយឫសយ៉ាងនេះនោះ មានភ្នំព្រះសិនេរុ ដែលជាភ្នំខ្ពស់បំផុតចាក់ ( ឫស ) ចុះទៅក្នុងមហាសមុទ្រ ៨៤.០០០ យោជន៍ ខ្ពស់ឡើងទៅ ( ក្នុងលំហរ ) ក៏មានប្រមាណស្មើគ្នា ។ ភ្នំធំទាំងឡាយ គឺ ភ្នំយុគន្ធរ ភ្នំឥសិន្ធរ ភ្នំករវីកៈ ភ្នំសុទស្សនៈ ភ្នំនេមិន្ធរ ភ្នំវិនតកៈ ភ្នំអស្សកណ្ណ ដែលលម្អទៅដោយរតនៈផ្សេងៗ ប្រៀបដូចភ្នំទិព្វ ចាក់ឫស ( ជម្រៅ ) ចុះទៅ ( ក្នុងមហាសមុទ្រ ) និង កម្ពស់ឡើងទៅ ( ក្នុងលំហរ ) ដោយប្រមាណពាក់កណ្ដាលៗ អំពីប្រមាណនៃភ្នំសិនេរុ ទៅតាមលំដាប់ ភ្នំធំទាំង ៧ នោះ ( តាំងនៅ ) ដោយជុំវិញភ្នំសិនេរុ ជាទីលំនៅរបស់ ( ចតុ ) មហារាជ ជាទីដែលទេវតា

និងយក្សអាស្រ័យនៅ ។ ភ្នំហិមពាន្តកម្ពស់ ៥០០ យោជន៍ បណ្ដោយ និងទទឹង ៣០០០ យោជន៍ ( ប៉ុនគ្នា ) ប្រដាប់ទៅដោយកំពូលដល់ទៅ ៨៤.០០០ កំពូល ។ ដើមជម្ពូ ( ព្រីង ) ឈ្មោះ **នគ** វាស់ជុំវិញដើមបាន ១៥ យោជន៍ ដើមកម្ពស់ ៥០ យោជន៍ និងមែក ( មែក ១ ) ក៏ប្រវែង ៥០ យោជន៍ ផ្សាយចេញទៅវាស់បាន ១០០ យោជន៍ ដោយជុំវិញ និងកម្ពស់ឡើងទៅក៏ប៉ុនគ្នានោះ ដោយអានុភាពរបស់ដើមជម្ពូនេះ ទ្វីបនេះ ទើបត្រូវប្រកាសឈ្មោះថា **ជម្ពូទ្វីប** ។

ក៏ឯខ្នាតរបស់ដើមជម្ពូនេះយ៉ាងណា ខ្នាតនោះ នុ៎ះឯងជាខ្នាតរបស់ដើម ចិត្របាដលី ( ដើមល្ងៀង ) របស់ពួកអសុរ ដើមសិម្ពលី ( រកា ) របស់ពួកគ្រុឌ ដើមខ្ទុមក្នុងអមរគោយានទ្វីប ដើមកប្បៈក្នុងឧត្តរកុរុទ្វីប ដើមសិរីសៈ ( ដើមច្រេស ) ក្នុងបុព្វវិទេហទ្វីប ដើមបារិច្ឆត្តកៈ ក្នុងស្ថានតាវត្តិង្ស ព្រោះហេតុនោះឯង បុរាណាចារ្យទើបពោលទុកថា ( ដើមប្រចាំភពនិងទ្វីប ) គឺ ដើមបាដលី ដើមសិម្ពលី ដើមជម្ពូ ដើមបារិច្ឆត្តកៈរបស់ពួកទេវតា ដើមខ្ទុម ដើមកប្បៈ និង ទី ៧ គឺ សិរីសៈដូច្នេះ ។

## ខ្នាតភ្នំចក្រវាល

ភ្នំចក្កវាឡចាក់ឫស ( ជម្រៅ ) ចុះទៅក្នុងមហាសមុទ្រ ៨២០០០ យោជន៍ កម្ពស់ឡើងទៅ ( ក្នុងលំហរ ) ក៏ប៉ុនគ្នាដែរ ភ្នំចក្រវាលនេះ ហ៊ុំព័ទ្ធលោកធាតុទាំងមូលតាំងនៅ ។

## ខ្នាតរបស់ភពនិងទ្វីប

ក្នុងលោកធាតុនោះ មានព្រះចន្ទ ( វាស់ជុំវិញ ? ) ប្រមាណ ៤៩ យោជន៍ ព្រះអាទិត្យប្រមាណ ៥០ យោជន៍ ភពតាវត្តិង្ស ១០០០ យោជន៍ ភពអសុរ មហា

នរកអវិចីនិងជម្ពូទ្វីបក៏ប៉ុនគ្នា អមរគោយានទ្វីប ៧០០០ យោជន៍ បុព្វវិទេហទ្វីប ក៏ប៉ុននោះ ឧត្តរកុរុទ្វីប ៨០០០ យោជន៍ ម្យ៉ាងវិញទៀត ក្នុងលោកធាតុនោះ ទ្វីបធំមួយទ្វីបៗ មានទ្វីបតូចជាបរិវារ មួយទ្វីប ៥០០ ។

វត្ថុទាំងពួង ( ដែលពោលមកនេះ ) នោះ ( រួម ) ជាចក្កវាឡមួយ ឈ្មោះថា លោកធាតុ ១ ក្នុងចន្លោះនៃលោកធាតុទាំងឡាយ មានលោកន្តរនរក ( មួយចន្លោះ ១ ? ) ។

ព្រះមានព្រះភាគជាម្ចាស់អង្គនោះ ទ្រង់យល់ដឹង គឺ ដឹងសព្វគ្រប់នូវអនន្តចក្កវាឡ អនន្តលោកធាតុ មានប្រការដូចពោលមកដូច្នេះ ដោយព្រះអនន្តពុទ្ធញាណ សូម្បីឱកាសលោក ព្រះអង្គក៏ទ្រង់ដឹងដោយប្រការទាំងពួង ដោយន័យដែលពោលមក ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះទ្រង់ដឹងលោកដោយប្រការទាំងពួង ដូច្នេះ ជាប្រការ ១ ។

## មហាដីកា

បទថា **សព្វថា** ប្រែថា ដោយប្រការទាំងពួង ។ លោកណាៗ គប្បីជ្រាបបានដោយប្រការណាៗ ព្រះសម្ពុទ្ធទ្រង់ជ្រាបដោយប្រការនោះៗ ។ ចំណែកលោកអាចារ្យបំណងសម្តែងប្រការនោះៗ ទើបពោលថា **ដោយសភាវៈ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ដោយសភាវៈ** គឺ ដោយសភាវៈនៃទុក្ខ ។ ពិតណាស់ លោកទាំងអស់ជាសភាវៈនៃទុក្ខ ។ ដូចទ្រង់ត្រាស់ទុកថា " ដោយសង្ខេប ឧបាទានក្ខន្ធ ៥ ជាទុក្ខ " ដូច្នេះ ។ ពាក្យថា **ដោយសមុទយ** គឺ ដោយហេតុតាំងឡើងនៃលោកនោះ គឺដោយហេតុមានតណ្ហាជាដើម ពាក្យថា **ដោយនិរោធ** គឺដោយទីរំលត់

នៃលោកនោះ បានដល់ វិសង្ខារធម៌ ។ ពាក្យថា **ដោយឧបាយចាក់ធ្លុះនិរោធ** គឺ ដោយវិធីដែលចាក់ធ្លុះនិរោធនោះ បានដល់ អរិយមគ្គ ព្រោះមិនមានប្រការដទៃអំពីនេះ ។

លោកអាចារ្យកាលពោលថា " ទ្រង់បានដឹងនូវលោកហើយដោយប្រការទាំងពួង " ដូច្នេះ យ៉ាងនេះហើយ កាលនឹងសម្ដែងព្រះសូត្រ ដែលជាសាធកៈក្នុងប្រការនោះ ទើបពោលថា **ម្នាលលោកដ៏មានអាយុ ក្នុងទីណា** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ទ្រង់បដិសេធការកើតជាដើមដោយត្រង់ ដោយបទថា **នជាយតិ** មិនកើតជាដើម ហើយទ្រង់បដិសេធការឃ្លាត និងការឧប្បត្តិ តៗទៅ ដោយពីរបទថា **ន ច វតិ នឧប្បជ្ជតិ** មិនឃ្លាត មិនឧប្បត្តិដូច្នេះ ។

ចំណែកអាចារ្យពួកខ្លះពោលថា បទថា " មិនកើតជាដើម ត្រាស់ទុកដោយទាក់ទងដល់សត្វដែលជាគព្ភសេយ្យកៈ បទក្រៅពីនេះ ត្រាស់ទុកទាក់ទងដល់សត្វដែលជាឱបបាតិកៈ " ដូច្នេះ ។ ពាក្យថា **ទីនោះ** បានដល់ ទីដែលវៀរការកើតជាដើម ពាក្យថា **ដោយការទៅ** គឺ ដោយការទៅដោយជើង ។ បទថា **ញាតេយ្យំ** ប្រែថា គប្បីដឹង ។ បាឋៈថា " **ញាតាយំ** " ដូច្នេះក៏មាន កាត់បទជា **ញាតា អយំ** អធិប្បាយថា លោកដែលត្រូវការព្រះនិញ្វាននេះដឹង ដូច្នេះ ។

ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងថា នរណាៗ មិនអាចនឹងទៅ ដោយការទៅដោយជើង ហើយឃើញ , ឬថា ដល់ទីបំផុតនៃលោកបានក៏ពិត តែថា តថាគតនឹងបញ្ញត្តសម្ដែងទីបំផុតនៃលោកនេះទុក ក្នុងទីដែលបានប្រមាណទុកដោយកំណាត់ទុកដូច្នេះ ទើបត្រាស់ថា **ក៏តែថា** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ព្រមទាំងសញ្ញា** គឺ ប្រព្រឹត្តព្រមនឹងសញ្ញា ។ ឈ្មោះថា **ព្រមទាំងចិត្ត** គឺ ព្រម

ទាំងវិញ្ញាណ ក៏ដោយអាការដែលប្រព្រឹត្តទៅព្រមគ្នានោះឯង ។ ចំណែកថា ក្នុងកឡេវរៈដែលមិនមានវិញ្ញាណ ដែលមានត្រឹមតែការប្រជុំនៃរូប មានឧតុជាសមុដ្ឋាន មិនអាចនឹងបញ្ញត្តទីបំផុតនៃលោកបាន ។ ពាក្យថា **លោក** បានដល់ លោកមានខន្ធជាដើម ។ ពាក្យថា **លោកនិរោធ** ( ទីរំលត់លោក ) គឺ រំលត់លោក មានខន្ធជាដើមនោះ ឬថា បានដល់ ព្រះនិព្វាននោះឯង ។ ពិតណាស់ ព្រះនិព្វាននោះសូម្បីថា មិនមែនស្ថានទី ក៏ទ្រង់សម្ដែងឲ្យប្លែកទៅដោយឧបចារវោហារ ( ថាទីរំលត់ ) ដែលទាក់ទងនឹងធម៌ទាំងឡាយ ដែលមានការរលត់ ដូចទ្រង់ត្រាស់ទុកថា ចក្ខុជាសភាវៈដែលគួរស្រឡាញ់ ជាសភាវៈដែលគួរត្រេកអរក្នុងលោក តណ្ហានេះកាលនឹងត្រូវលះទៅ រមែងត្រូវលះទៅក្នុងចក្ខុនេះ កាលនឹងរលត់ទៅ រមែងរលត់ទៅក្នុងចក្ខុនេះ ដូច្នេះ ។

ពាក្យថា **ដោយការទៅ** គឺ ដោយការទៅដែលមានតាមប្រក្រតី ។ ពាក្យថា **ទីបំផុតនៃលោក** គឺ ទីបំផុតនៃសង្ខារលោក បានដល់ ព្រះនិព្វានដែលជាហេតុធ្វើនូវទីបំផុត ។ បទថា **កុទាចនំ** គឺ ក្នុងកាលសូម្បីណាៗ ។ ពាក្យថា ( តែគេ ) **មិនដល់** គឺ មិនចាក់ធ្លុះដោយមគ្គជាន់ខ្ពស់ ។ ពាក្យថា **បមោចនំ** ប្រែថា ការផុត គឺ ការរលាស់ទៅ ។ ពាក្យថា **ព្រោះហេតុនោះ** គឺ ព្រោះហេតុដែលមិនដល់ទីបំផុតនៃលោកហើយ ក៏មិនមានការផុតចាកវដ្តទុក្ខដូច្នោះ ។ ស័ព្ទថា **ហវេ** ត្រឹមតែជានិបាត។ ពាក្យថា **ដែលអ្នកស្គាល់លោក** គឺ លោកអ្នកដែលស្គាល់លោកទាំងពួងដោយប្រការទាំងឡាយ មានសភាវៈជាដើម ។ បទថា **សុមេធោ** ប្រែថា មានបញ្ញាល្អ ។ ពាក្យថា **ដល់ទីបំផុតនៃលោក** គឺ ស្គាល់លោកដោយបរិញ្ញាភិសម័យ ( ការត្រាស់ដឹង គឺ ការកំណត់ដឹង ) ហើយក៏ជាអ្នកដល់ទីបំផុតនៃលោកបាន ដោយបហាន-

កិលេសម័យ ( ការត្រាស់ដឹង គឺ លះ ) ។ ឈ្មោះថា **នៅចប់ព្រហ្មចារ្យ** ក៏ព្រោះចប់ការនៅ ( ការអប់រំ ) មគ្គព្រហ្មចារ្យហើយ ។ ឈ្មោះថា **សមិតាវី** ( ស្ងប់ហើយ ) ព្រោះស្ងប់កិលេសទាំងពួងបានហើយ ឬព្រោះត្រាស់ដឹងសច្ចធម៌ទាំង ៤ បានហើយ។ ឈ្មោះថា **មិនសង្ឃឹម** គឺ មិនប្រាថ្នាលោកដទៃ ដូចគ្នានឹងលោកនេះដែរ ព្រោះភាពជាអ្នកមានបដិសន្ធិទៅប្រាសហើយ ។

តាមប្រការដែលពោលមកនេះ លោកអាចារ្យបានសម្ដែងភាពជាលោកវិទូដោយមិនមានសេសសល់ ព្រោះបានសម្ដែងដោយសភាវៈហើយក៏ពិត សូម្បីដូច្នោះហើយ លោកក៏ពោលដល់លោកទុកដោយចំណែកៗ ប៉ុណ្ណោះ ព្រោះហេតុនោះកាលសម្ដែងលោកនោះដោយមិនមានសល់ លោកទើបពោលថា **ម្យ៉ាងទៀត លោកមាន ៣** ដូច្នេះជាដើម ។ ក្នុងលោក ៣ នោះ មានអធិប្បាយថា ប្រជុំ និងការបន្តនៃខន្ធទាំងឡាយ ដែលទាក់ទងដោយឥន្ទ្រិយ ឈ្មោះថា **សត្តលោក** ( លោក គឺ សត្វ ) ។ ឈ្មោះថា **សត្ត** ( សត្វ ) ព្រោះភាពដែលជាប់ជំពាក់ក្នុងខន្ធទាំងឡាយមានរូបជាដើម ឈ្មោះថា **លោក** ក៏ព្រោះអត្ថថា ដែលបុគ្គលមើលឃើញកុសល អកុសល និង វិបាករបស់កុសល អកុសលនោះ ។ ការប្រជុំ និង ការបន្តនៃខន្ធទាំងឡាយ មានរូបជាដើម ដែលមិនទាក់ទងដោយឥន្ទ្រិយ ឈ្មោះថា “ **ឱកាសលោក** ” ព្រោះអត្ថថា ជាទីដែលបុគ្គលមើលឃើញវត្ថុដែលឃ្លាតចាកទីបាន និងឃ្លាតចាកទីមិនបាន និង ជាឱកាស ( ទីតាំង ) នៃវត្ថុទាំងនោះ ។ ក៏ឱកាសលោកនេះ ព្រោះជាទីទទួលទ្រទ្រង់វត្ថុទាំងនោះ នឹងហៅថា **ភាជនៈលោក** ដូច្នេះក៏បាន ។ ខន្ធទាំងពីរចំណែក ( ទាំងដែលទាក់ទងដោយឥន្ទ្រិយ ទាំងដែលមិនទាក់ទងដោយឥន្ទ្រិយ ) ឈ្មោះថា **សង្ខារលោក** ព្រោះអត្ថថា ដែលបច្ច័យទាំងឡាយ តាក់តែង

និងប្រែប្រួលបែកធ្លាយទៅ ។ ពាក្យថា **មានការតាំងនៅបានព្រោះអាហារ** គឺ ការតាំងនៅបានព្រោះបច្ច័យ មានសេចក្តីថា មានការប្រព្រឹត្តទៅទាក់ទងដោយបច្ច័យ ។ ព្រោះថា **អាហារ** ស័ព្ទ ក្នុងពាក្យថា **អាហារដ្ឋិតិកា** នេះ មានអត្ថថា បច្ច័យដូចក្នុងប្រយោគថា " នេះជាអាហារ ( ជាបច្ច័យ ) ដើម្បីការកើតឡើងនៃកាមច្ឆន្ទៈដែលនៅមិនទាន់កើតឡើង " ដូច្នេះជាដើម ក៏ដោយពាក្យថា "សត្វទាំងពួង" តាមប្រការដែលពោលមកនេះ នេះជាការកាន់យកពួកអសញ្ញីសត្វផងដែរ ។ ម្យ៉ាងវិញទៀត ភាពជាអ្នកមានការតាំងនៅបានដោយអាហារនេះនោះ ដោយនិប្បរិយាយបានដល់ សង្ខារធម៌ មិនមែនសត្តធម៌ ព្រោះហេតុនោះ លោកទើបពោលថា **គប្បីជ្រាបសង្ខារលោកក្នុងសេចក្តីពិតដែលមកថា ( លោក ១ គឺ ) សត្វទាំងពួង មានការតាំងនៅបានដោយអាហារ ដូច្នេះ** ។

សួរថា ប្រសិនបើយ៉ាងដូច្នេះ នឹងប្រើពាក្យថា **សត្វទាំងពួង** នេះបានយ៉ាងដូចម្តេច ? ឆ្លើយថា ជាទេសនាបុគ្គលាធិដ្ឋាន ព្រោះដូច្នោះ សេចក្តីនេះទើបមិនមែនខុសទេ ដូចទ្រង់ត្រាស់ទុកសូម្បីក្នុងទីដទៃថា " ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកនឿយណាយនៅដោយប្រពៃ ប្រាសចាកតម្រេកនៅដោយប្រពៃ រួចផុតនៅដោយប្រពៃ សម្លឹងឃើញទីបំផុតនៅដោយប្រពៃក្នុងធម៌តែមួយ រមែងជាអ្នកចាក់ធ្លុះដោយប្រពៃ ( គឺ អរិយមគ្គមានអង្គ ៨ ) ធ្វើទីបំផុតនៃទុក្ខក្នុងអត្តភាពនេះឯងបាន ។ ក្នុងធម៌តែមួយដូចម្តេច ? ក្នុងធម៌តែមួយ គឺ សត្វទាំងពួងមានការតាំងនៅបានដោយអាហារ " ដូច្នេះ ។ គំនិតយល់ឃើញថា " អត្តា និងថា លោក " ដោយទាក់ទងជារបស់ឋិតថេរជាដើម នៃពួកមិច្ឆាទិដ្ឋិទាំងឡាយ ដោយច្រើនមានសត្វជាអារម្មណ៍ មិនមែនមានសង្ខារជាអារម្មណ៍ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **គប្បី**

ជ្រាបសត្វលោកក្នុងសេចក្ដីពិតដែលមកថា ( ប្រសិនបើព្រះមានជោគ ទ្រង់នឹងមិនព្យាករថា ) លោកឋិតថេរក្ដី លោកមិនឋិតថេរក្ដី ដូច្នេះ ។

ពាក្យថា **ព្រះចន្ទ និងព្រះអាទិត្យគោចរទៅជុំវិញ ក្នុងទីមានប្រមាណត្រឹមណា** គឺព្រះចន្ទ និងព្រះអាទិត្យរំកិលទៅជុំវិញ វិលទៅជុំវិញក្នុងទីមានប្រមាណត្រឹមណា ។ ពាក្យថា **ទិសទាំងឡាយក៏ភ្លឺរុងរឿង** គឺ ទិសទាំងនោះ ក៏ជាការភ្លឺផ្សាយទៅរុងរឿង ព្រោះការវិលទៅជុំវិញនៃព្រះចន្ទ និងព្រះអាទិត្យទាំងនោះឯង ។ ពាក្យថា **អស់ទីមានប្រមាណប៉ុណ្ណោះ មានលោកនៅ ១០០០ ចំណែក** មានសេចក្ដីថា អស់ទីមានប្រមាណប៉ុនណា មានឱកាសលោកនៅ ១០០០ ប្រការ គឺ មានលោកធាតុ ១០០០ ។ បាឋៈថា **តាវសហស្សធា** ដូច្នេះក៏មាន ។

បទថា **តម្បិ** គឺ លោកទាំង ៣ យ៉ាងនោះ ។ ភ្ជាប់សេចក្ដីថា ពិតយ៉ាងនោះសង្ខារលោកនេះ ព្រះលោកនាថ ក៏ទ្រង់បានស្គាល់ហើយ សូម្បីដោយប្រការទាំងពួង ។ ទ្រង់ពោលចំពោះសង្ខារទាំងពួងដែលប្រព្រឹត្តទៅទាក់ទងដោយបច្ច័យ ទុកដោយពាក្យពោលដែលជាបុគ្គលាធិដ្ឋាន ( មានបុគ្គលជាទីតាំង ) ថា **លោក ១** “ គឺសត្វទាំងពួងមានការតាំងនៅបានដោយអាហារ ” ដូច្នេះឯង ដោយពាក្យពោលដែលជាបុគ្គលាធិដ្ឋាននោះ សង្ខារលោកទាំងពួងទើបមាន ១ គឺ តែម្យ៉ាង ព្រោះមិនមានប្រការដទៃ ។ សូម្បីក្នុងពាក្យថា **លោក ២** ជាដើម ក៏គប្បីជ្រាបអត្ថន័យ ដោយន័យនេះ ។ ម្យ៉ាងវិញទៀត ដោយស័ព្ទថា **នាម** ក្នុងទីនេះ លោកមិនកាន់យកព្រះនិព្វាន ព្រោះព្រះនិព្វាននោះ រកសភាវៈដែលជាលោកមិនបាន សួរថា ក៏ក្នុងពាក្យថា “ មានការតាំងនៅបានដោយអាហារ ” នេះ សូម្បីមគ្គធម៌ និងផលធម៌ក៏រមែងដល់នូវភាពជាលោក ព្រោះការប្រព្រឹត្តទៅទាក់ទងដោយបច្ច័យ មិនមែនឬ?

ឆ្លើយថា មិនដល់ទេ ព្រោះពាក្យថា **លោក** ក្នុងទីនេះ ទ្រង់បំណងយកធម៌ គឺទុក្ខសច្ច ដែលគួរកំណត់ដឹង ។ ន័យម្យ៉ាងទៀត បុគ្គលប្រកាន់ធម៌ណា ថា " មិនប្រែប្រួល មិនបែកធ្លាយ " ដូច្នេះហើយ មិនប្រព្រឹត្តទៅតាមដែលប្រកាន់នោះ ធម៌នោះ ឈ្មោះថា **លោក** ព្រោះហេតុនោះ លោកុត្តរធម៌ទាំងឡាយដែលទទេវៀរចាកការប្រកាន់នោះ ទើបមិនមានសភាពជាលោក ។ ខន្ធដែលជាអារម្មណ៍របស់ឧបាទាន ឈ្មោះថា **ឧបាទានក្ខន្ធ** ។ ពាក្យថា **អាយតនៈ ១០** បានដល់ អាយតនៈដែលជារូប ១០ ។

មួយវិញទៀត ក្នុងរឿងនេះដោយពាក្យពោល ដែលពោលដល់ការប្រព្រឹត្តទៅទាក់ទងដោយបច្ច័យថា " មានការតាំងនៅបានដោយអាហារ " ដូច្នេះ ជាការដែលទ្រង់ប្រកាសសេចក្តីដែលសង្ខារទាំងឡាយជារបស់មិនទៀង ។ តែព្រោះមានព្រះបាលីថា " វត្ថុដែលមិនទៀងឯណា វត្ថុនោះជាទុក្ខ , វត្ថុដែលជាទុក្ខឯណា វត្ថុនោះជាអនត្តា " ដូច្នេះ ទើបទ្រង់ប្រកាសចំពោះភាវៈនោះជាទុក្ខ ជាអនត្តាផងដែរ ព្រោះហេតុនោះ ក៏ជាការកាន់យកសាមញ្ញលក្ខណៈសូម្បីទាំង ៣ ។ ពាក្យថា **នាម** បានដល់ នាមក្ខន្ធ ៤ ក៏នាមក្ខន្ធ ៤ ទាំងនោះ ដោយសភាវៈក៏បានដល់ធម៌ទាំងឡាយមានផស្សៈជាដើម ។ ពាក្យថា **រូប** បានដល់ មហាភូតរូប និង ឧបាទាយរូបទាំងឡាយ ក៏រូបទាំងនោះដោយសភាវៈ បានដល់ ធម៌ទាំងឡាយ មានបឋវីជាដើម ព្រោះហេតុនោះ ជាការដែលលោកកាន់យកសង្ខារទាំងឡាយ ដោយលក្ខណៈរបស់ខ្លួន ដោយមិនប្លែកគ្នានោះឯង ។ សង្ខារទាំងនោះ មានភាពផ្សេងគ្នា មានកុសលជាដើម និង មានហេតុជាដើមពួកណា សូម្បីភាពផ្សេងគ្នាទាំងនោះ គឺ លោកកាន់យកហើយដោយស័ព្ទថា **នាមនិងរូប** នោះឯង ព្រោះហេតុនោះ លោកអាចារ្យទើប

ពោលថា **សូម្បីសង្ខារលោកនេះ គឺ ដូច្នេះ** ព្រះមានព្រះភាគអង្គនេះ " ក៏ទ្រង់បានស្គាល់ហើយដោយប្រការទាំងពួង " ដូច្នេះ ។

ឈ្មោះថា **អាស្រ័យ** ព្រោះអត្ថថា ជាទីចិត្តមកអាស្រ័យ សំដៅយកសេចក្ដីថា ជាទីមកនៅរបស់ចិត្ត ដូចជាការអាស្រ័យ ( ដែលមាននៅ ) របស់ម្រឹគ ដូច្នេះ ។ ប្រៀបដូចជាម្រឹគទៅកាន់ទីរកស៊ី ហើយត្រឡប់មកនៅក្នុងព្រៃក្រាស់នោះប៉ុណ្ណោះ ព្រោះហេតុនោះ ទីនោះ ( គឺ ព្រៃក្រាស់នោះ ) ទើបឈ្មោះថា **អាស្រ័យ** ( ទីមកនៅ ) របស់ម្រឹគនោះយ៉ាងណា ចិត្តសូម្បីប្រព្រឹត្តទៅក្នុងទីដទៃហើយ មកនៅក្នុងទីណា ទីនោះក៏ហៅថា **អាស្រ័យ** ( ទីសម្រាក ) របស់ចិត្តនោះ ដូច្នោះ ។ ក៏ព្រោះអាស្រ័យនោះមាន ៤ យ៉ាង គឺ មានសស្សតទិដ្ឋិជាដើម សមដូចដែលលោកពោលទុកថា ៖

**សស្សតទិដ្ឋិ ១ ឧច្ឆេទទិដ្ឋិ ១ អនុលោមិកខន្តិញ្ញាណ ( ញាណដែលឃើញដោយប្រពៃ ដែលអនុលោមចំពោះលោកុត្តរធម៌ ) នោះឯង ១ , យថាភូតញ្ញាណ ( ញាណដែលដឹងទៅតាមសេចក្ដីពិត ) ១ ធម៌ ៤ យ៉ាង មានសស្សតទិដ្ឋិជាដើមនេះហៅថា អាស្រ័យ-ទីនៅ ដូច្នេះ ។**

ក្នុងអាស្រ័យ ៤ យ៉ាងនោះ ព្រោះភាពដែលទិដ្ឋិទាំងអស់សង្គ្រោះចូលដោយសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ សត្វទាំងឡាយដែលមានទិដ្ឋិ សូម្បីទាំងអស់ ទើបចាត់ជាអ្នកអាស្រ័យទិដ្ឋិ ២ យ៉ាង ទាំងនេះប៉ុណ្ណោះ ។ ដូចទ្រង់ត្រាស់ទុកថា ម្នាលកច្ចានៈ លោកនេះ ដោយច្រើនអាស្រ័យភាវៈពីរយ៉ាង គឺ **ភាវៈមាន** និង**ភាវៈមិនមាន** ។ ពាក្យថា **ភាវៈមាន** ទ្រង់សំដៅយក **សស្សតគាហ** ការប្រកាន់ថា ឋិតថេរ , ពាក្យថា **ភាវៈមិនមាន** ទ្រង់សំដៅយក **ឧច្ឆេទគាហ** ការប្រកាន់ថា ដាច់សូន្យ ។

នេះចាត់ជាទីអាស្រ័យរបស់បុថុជ្ជន ដែលអាស្រ័យវដ្តៈមុន ។ រីឯសម្រាប់សត្វដែលបរិសុទ្ធដែលអាស្រ័យវិវដ្តៈ មានអាស្រ័យពីរយ៉ាង គឺ **អនុលោមិកខន្តិញ្ញាណ** និង **យថាភូតញ្ញាណ** ។

ពាក្យថា **ទ្រង់ដឹងអាស្រ័យ** គឺ ទ្រង់ដឹងអាស្រ័យទាំង ៤ យ៉ាងរបស់សត្វទាំងឡាយ និងកាលទ្រង់ចង់ដឹង ក៏ទ្រង់ដឹងបាន សូម្បីក្នុងទិដ្ឋិទាំងនោះ និងញាណទាំងនោះមិនទាន់ប្រព្រឹត្តទៅ សេចក្ដីនេះសមពិតដូចព្រះសារីបុត្តពោលទុកថា ៖

**ទ្រង់ដឹងបុគ្គលដែលកំពុងសេពកាមនោះឯងថា “ បុគ្គលនេះធ្ងន់ក្នុងកាម មានកាមជាទីអាស្រ័យ មានចិត្តបង្អោនទៅក្នុងកាម ” ដូច្នេះ ទ្រង់ដឹងបុគ្គលដែលកំពុងសេពកាមនោះឯងថា “ បុគ្គលនេះធ្ងន់ក្នុងនេក្ខម្មៈ មាននេក្ខម្មៈជាទីអាស្រ័យ មានចិត្តបង្អោនទៅក្នុងនេក្ខម្មៈ ” ដូច្នេះជាដើម ។**

កិលេសទាំងឡាយឈ្មោះថា **អនុស័យ** ព្រោះអត្ថថា ដេកត្រាំនៅក្នុងសន្ដានព្រោះភាពដែលនៅមិនទាន់បានលះ មានសេចក្ដីថា បានហេតុដែលសមគួរហើយក៏នឹងកើតឡើង ។ ដោយអត្ថន័យនេះ រមែងសម្ដែងដល់ភាពដែលកិលេសទាំងនោះគួរកើតឡើងក្នុងកាលមានការបានហេតុ ។ ពិតណាស់ កិលេសទាំងឡាយដែលលះមិនទាន់បាន នឹងកើតឡើងបាន ក៏ក្នុងកាលមានការបានហេតុ ។

សួរថា កិលេសទាំងនោះ បានដល់ កិលេសអ្វី ? ឆ្លើយថា បានដល់កិលេស ៧ យ៉ាង មានរាគៈជាដើម ដែលជាអនាគត កិលេសអតីត និងកិលេសបច្ចុប្បន្នក៏ហៅយ៉ាងនោះ ( គឺ ហៅថា អនុស័យ ) បាន ព្រោះមានសភាវៈនោះ ។ ពិតណាស់ ធម៌ទាំងឡាយនឹងមានភាពផ្សេងគ្នាដោយសភាវៈ ព្រោះមានភាពផ្សេងគ្នានៃកាលក៏ទេ ។ ទ្រង់ដឹងអនុស័យ ៧ យ៉ាងនោះ ដែលកំពុងប្រព្រឹត្តទៅដោយ

សភាវៈដែលជាប់តាមទៅក្នុងសន្តានរបស់សត្វនោះៗ ។

ពាក្យថា **ចរិត** បានដល់ ការប្រព្រឹត្តល្អ ប្រព្រឹត្តអាក្រក់ ។ ក៏ចរិតនោះ ទ្រង់សម្តែងទុកក្នុងចរិតនិទ្ទេស **ក្នុងបករណវិភង្គ** ហើយ ។ ន័យម្យ៉ាងទៀត ពាក្យថា **ចរិត** គប្បីជ្រាបថា បានដល់ ចរិយា ។ ក៏ចរិយានោះ បានដល់ ចរិយាដែលជាមូល ៦ គឺ រាគចរិយា ១ ទោសចរិយា ១ មោហចរិយា ១ សទ្ធាចរិយា ១ ពុទ្ធិចរិយា ១ វិតក្កចរិយា ១ ប្រភេទនៃចរិយាទាំងនោះដោយត្រឹមតែម្យ៉ាងរកទីបំផុតមិនមាន ចំណែកប្រភេទដែលលាយឡំគ្នាមាន ៦៣ យ៉ាង ។ ទ្រង់ដឹងចរិតនោះដោយប្រការយ៉ាងនេះ គឺ ដោយសភាវៈ ដោយសេចក្តីសៅហ្មង និងដោយភាពផូរផង់ ដោយសមុដ្ឋាន ដោយផល ដោយអានិសង្សជាដើម ។

ពាក្យថា **អធិមុត្តិ** បានដល់ ធាតុ គឺ អជ្ឈាសយៈ ។ អធិមុត្តិនោះមាន ២ យ៉ាង គឺ អធិមុត្តិថោកទាប និងអធិមុត្តិប្រណីត មានសេចក្តីថា សត្វទាំងឡាយដែលមានអធិមុត្តិថោកទាប រមែងគប់រកសត្វទាំងឡាយ ដែលមានអធិមុត្តិថោកទាបប៉ុណ្ណោះ ហើយសត្វទាំងឡាយដែលមានអធិមុត្តិប្រណីត ក៏រមែងគប់រកនឹងសត្វទាំងឡាយដែលមានអធិមុត្តិប្រណីតប៉ុណ្ណោះ ដោយធាតុ គឺ អជ្ឈាសយៈណា ។ **ធាតុ** គឺ អធ្យាស្រ័យ , **សភាវៈ** គឺ អធ្យាស្រ័យនោះ ហៅថា **អធិមុត្តិ** ។ **ទ្រង់ដឹងអធិមុត្តិនោះ** ដោយន័យថា សត្វនេះមានអធិមុត្តិថោកទាប សត្វពួកនេះមានអធិមុត្តិប្រណីត សូម្បីយ៉ាងនោះថា សត្វពួកនេះមានអធិមុត្តិទន់ខ្សោយ សត្វពួកនេះមានអធិមុត្តិទន់ខ្សោយជាង សត្វពួកនេះមានអធិមុត្តិទន់ខ្សោយជាទីបំផុតដូច្នេះជាដើម ។ ក៏បណ្ឌិតគប្បីជ្រាបភាពរឹងមាំ និងភាពទន់ខ្សោយនៃអធិមុត្តិជាដើម បានតាមសមគួរតាមភាពចាស់ក្លា ឬ ភាពទន់ខ្សោយនៃឥន្ទ្រិយទាំងឡាយជាដើម ។ ពិតយ៉ាងនោះ

លោកពោលទុកក្នុងសម្មោហវិនោទនីថា អធិមុត្តិ សូម្បីថាទ្រង់កាន់យកក្នុងខាងដើម ហើយ ទ្រង់នៅកាន់យកក្នុងទីនេះទៀត ក៏គប្បីសម្តែងចំពោះសត្វទាំងឡាយដែលមានឥន្ទ្រិយចាស់ក្លា ឬ មានឥន្ទ្រិយទន់ខ្វី ដូច្នេះ ។

សត្វទាំងឡាយ ឈ្មោះថា **អប្បរជក្ខា** ព្រោះអត្ថថា មានភ្នែកដែលមានកិលេសដូចជាធូលីតិច ម្យ៉ាងទៀត សត្វទាំងឡាយឈ្មោះ **អប្បរជក្ខា** ព្រោះអត្ថថា មានកិលេសដូចជាធូលីតិចក្នុងកែវភ្នែក គឺ បញ្ញា បានដល់ សត្វដែលមានធូលី គឺរាគៈជាដើមមិនក្រាស់ ។ ទ្រង់ស្គាល់សត្វដែលមានកិលេសដូចជាធូលីក្នុងភ្នែកតិចទាំងនោះ ។ សូម្បីក្នុងពាក្យថា ទ្រង់ស្គាល់សត្វដែលមានកិលេសដូចជាធូលីក្នុងភ្នែកច្រើន ក៏មានន័យនេះឯង សត្វដែលមានធូលី មានរាគៈជាដើមក្រាស់ឈ្មោះថា សត្វមានកិលេសដូចជាធូលីក្នុងភ្នែកច្រើន ។ ពាក្យថា **អ្នកមានឥន្ទ្រិយចាស់ក្លា** គឺ អ្នកដល់ព្រមដោយឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើមដែលចាស់ក្លា ។ ឈ្មោះថា អ្នកមានឥន្ទ្រិយទន់ខ្វី បានដល់ អ្នកដែលដល់ព្រមដោយឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើមទន់ខ្វី ។ ឥន្ទ្រិយដែលទ្រង់បំណងយកក្នុងទីនេះ ឈ្មោះថា ឥន្ទ្រិយដែលជាឧបនិស្ស័យ ។ បទថា **ស្វាការេ** ប្រែថា មានអាការល្អ គឺ មានប្រក្រតីល្អស្អាត មានសេចក្តីថា មានអធ្យាស្រ័យក្នុងវិវដ្ដៈ ។ ពាក្យថា **អ្នកដែលទ្រង់ ប្រោសឲ្យដឹងបានងាយ** គឺ អ្នកមានសទ្ធា និងមានបញ្ញាដែលទ្រង់ធ្វើឲ្យដឹងសម្មត្តនិយាមធម៌ ( អរិយមគ្គមានអង្គ ៨ ) បានងាយ ។ ក្នុងពាក្យថា **អ្នកគួរ អ្នកមិនគួរ** នេះ មានសេចក្តីថា ពាក្យថា **អ្នកគួរ** បានដល់ អ្នកវៀរចាកកម្មាវរណៈ ( គ្រឿងរាំង គឺ កម្ម ) កិលេសាវរណៈ ( គ្រឿងរាំង គឺ កិលេស ) និង វិបាកាវរណៈ ( គ្រឿងរាំង គឺ វិបាក ) ។ គប្បីជ្រាបដល់ **អ្នកមានអាការមិនល្អ** ដែលទ្រង់

**ប្រោសឲ្យដឹងដោយលំបាក និង អ្នកមិនគួរ** ដោយបរិយាយផ្ទុយគ្នាដែលពោលហើយនោះ ។ ម្យ៉ាងទៀត ក្នុងបណ្ដាសត្វទាំងនោះ គប្បីជ្រាបការដឹងរបស់ព្រះលោកនាថ ក្នុងសត្វដែលមានកិលេសដូចជាធូលីក្នុងភ្នែកតិច ដោយន័យថា " ដែលមានធូលី គឺ រាគៈតិច ដែលមានធូលី គឺ ទោសៈតិច " ដូច្នេះជាដើមចុះ ។ សូម្បីក្នុងសត្វដ៏សេស ក៏មានន័យនេះឯង ។ ពាក្យថា **ព្រោះដូច្នោះ** មានសេចក្ដីថា ព្រោះហេតុដែលព្រះមានព្រះភាគអង្គនេះ ទ្រង់ជ្រាបសត្វលោក ដោយប្រការទាំងពួង រកប្រមាណមិនបាន ដោយអាស្រ័យជាដើម ដូច្នោះព្រះមានព្រះភាគ ទ្រង់ដឹងច្បាស់នូវសត្វលោកទាំងពួង ។ សួរថា ក៏សូម្បីប្រមាណ ( ចំនួន ) ជាដើម ក្នុងសត្វទាំងឡាយដែលព្រះអង្គទ្រង់ដឹងបាន ក៏មាន មិនមែនឬ ? ឆ្លើយថា មាន , តែការដឹងប្រមាណជាដើមនោះ មិនបានប្រព្រឹត្តទៅដើម្បីការនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់តណ្ហា ព្រោះហេតុនោះ ក្នុងទីនេះ ទ្រង់ទើបមិនកាន់យកប្រមាណជាដើមនោះ ព្រះមានព្រះភាគ ទ្រង់បានជ្រាបយ៉ាងច្បាស់ ទ្រង់កំណត់ចែកបានយ៉ាងល្អផងដែរ តែព្រោះគ្មានប្រយោជន៍ ទើបទ្រង់មិនលើកឡើងកាន់ទេសនា ព្រោះហេតុនោះ ព្រះអានន្ទត្ថេរ ទើបបានពោលទុកថា ៖

**កាលនោះឯង ព្រះមានព្រះភាគ ទ្រង់ប្រើចុងព្រះនខាធ្លីះធូលីដីបន្តិច ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនឹងសម្គាល់សេចក្ដីនោះដូចម្ដេច មួយណាមានច្រើនជាងហ្ន៎ ធូលីដែលតថាគតប្រើចុងក្រចកធ្លីះឡើងមក ត្រឹមតែបន្តិចនេះ ឬថា ផែនដីធំជាង ដូច្នេះជាដើម ។**

ភ្ជាប់សេចក្ដីថា ទ្រង់ជ្រាប សូម្បីឱកាសលោកដោយប្រការទាំងពួង ។ ពាក្យថា ចក្រវាល បានដល់ លោកធាតុ ។ ពិតណាស់ លោកធាតុ លោកហៅថា

ចក្កវាឡ ព្រោះត្រូវភ្នំចក្រវាលដែលដូចជាកង់រថ ហ៊ុំព័ទ្ធដោយជុំវិញ ។ បទថា **ចតុត្តឹសសតានិ ច** គឺ ៣០០០ លើស ៤០០ មានសេចក្ដីថា ៣០០០ + ៤០០ ។ បទថា **អឌ្ឍុឌ្ឍានិ** ប្រែថា ៣៥០ មានសេចក្ដីថា ៣០០ + ៥០ ។ បទថា **នហុត្តានិ** ប្រែថា ១០.០០០ ។ បទថា **សង្ខាតា** ប្រែថា ពោល ។ ពាក្យថា **ការតាំងមាំនៅបាន** បានដល់ ការតាំងនៅបានដោយឱកាសទាំងពួង គឺ ទាំងខាងក្រោម និងខាងលើ ។

បទថា **ឯវំ សណ្ឋិតេ** បានដល់ ដែលតាំងនៅយ៉ាងនេះឯង ។ បទថា **ឯត្ថ** ប្រែថា ក្នុងចក្រវាល ។ ពាក្យថា **កម្ពស់ក៏ប៉ុណ្ណោះដូចគ្នា** បានដល់ កម្ពស់ក៏ប៉ុណ្ណោះដូចគ្នា គឺ ៨៤.០០០ យោជន៍ ដូចគ្នា ។ ក៏ក្នុងសេចក្ដីនេះ មិនមែនចំពោះកម្ពស់តែម្យ៉ាងប៉ុណ្ណោះ សូម្បីតែបណ្ដោយ និងទទឹង ក៏ប៉ុណ្ណោះដូចគ្នា សេចក្ដីនេះសមដូចដែលទ្រង់ត្រាស់ទុកថា “ ម្នាលភិក្ខុទាំងឡាយ ភ្នំសិនេរុ ស្ដេចនៃភ្នំបណ្ដោយ ៨៤.០០០ យោជន៍ ទទឹង ៨៤.០០០ យោជន៍ ” ដូច្នេះ ។

ពាក្យថា **រាប់អំពីខាតនៃភ្នំសិនេរុនោះទៅ** គឺ រាប់អំពីខាតដែលបានពោលទុកទាំងខាងក្រោមទាំងខាងលើនៃភ្នំសិនេរុនោះ ។ បទថា **ឧបឌ្ឍុឧឌ្ឍេន** កាត់ជា **ឧបឌ្ឍេន ឧបឌ្ឍេន** ( ពាក់កណ្ដាល ពាក់កណ្ដាល ) ។ សេចក្ដីនេះ គឺ ទ្រង់ត្រាស់អធិប្បាយថា ភ្នំយុគន្ធរ ជម្រៅចុះទៅក្នុងមហាសមុទ្រ ៤២.០០០ យោជន៍ និងកម្ពស់ឡើងទៅខាងលើ ក៏ប៉ុណ្ណោះដូចគ្នា ភ្នំឦសធរ ( ឥសិន្ធរ ) ជម្រៅចុះទៅក្នុងមហាសមុទ្រ ២១.០០០ យោជន៍ និងកម្ពស់ឡើងទៅខាងលើ ក៏ប៉ុណ្ណោះដូចគ្នា ដូច្នេះ ។ គប្បីជ្រាបការមានខាតពាក់កណ្ដាល ថយចុះពាក់កណ្ដាល សូម្បីក្នុងភ្នំដ៏សេសតាមន័យនេះ ។ មហាសមុទ្រមានជម្រៅសន្សឹមៗទៅ រហូតដល់ជើងភ្នំសិនេរុ

ដូចជម្រេលទៅជើងភ្នំចក្រវាល ព្រោះហេតុនោះ គួរឃើញថា ភ្នំយុគន្ធរ មានខ្នាត ត្រឹមតែពាក់កណ្ដាលនៃខ្នាតរបស់ភ្នំសិនេរុ ផ្នែកខាងក្រោមតាំងមាំលើផ្ទៃដីយ៉ាងស៊ប់ (គឺ មិនអណ្ដែតនៅក្នុងទឹក ដោយហេតុដែលជម្រៅត្រឹមពាក់កណ្ដាលរបស់ភ្នំសិនេរុនោះទេ) សូម្បីភ្នំឦសធរជាដើម ក៏យ៉ាងនោះដូចគ្នា ។ សេចក្ដីនេះ សមដូចដែលទ្រង់ត្រាស់ទុកថា “ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រជ្រៅទៅសន្សឹមៗ លាតទៅសន្សឹមៗ ឱនទៅសន្សឹមៗ ” ដូច្នេះ ។ អាចារ្យជាច្រើនពោលថា សមុទ្រ ឈ្មោះថា **សីទន្តរសមុទ្រ** នៅចន្លោះភ្នំសិនេរុ និងភ្នំយុគន្ធរជាដើម - ទាំងនោះ មានខ្នាតប្រវែងប៉ុនគ្នានឹងកម្ពស់របស់ភ្នំសិនេរុជាដើម តាមលំដាប់ ។ បទថា **ព្រហា** ប្រែថាធំ ។ ពាក្យថា **ដោយជុំវិញភ្នំសិនេរុ** គឺ ស្ថិតនៅដោយជុំវិញ ព័ទ្ធជុំវិញភ្នំសិនេរុ ផ្ដើមអំពីភ្នំយុគន្ធរព័ទ្ធជុំវិញភ្នំសិនេរុ ភ្នំឦសធរព័ទ្ធភ្នំយុគន្ធរនោះ ទ្រង់ត្រាស់ដល់ភ្នំទាំងឡាយដែលព័ទ្ធជុំវិញភ្នំនោះៗ (ជាស្រទាប់ៗ) យ៉ាងនេះថា ដោយជុំវិញភ្នំសិនេរុ ដូច្នេះ ។

ច្រើនបទថា **យោជនានំសតានុច្ចោ ហិមវា បញ្ច បព្វតោ** ប្រែថា មានភ្នំហិមពាន្តកម្ពស់ ៥០០ យោជន៍ ពាក្យថា **ឈ្មោះថា នគ** គឺ ដែលមានឈ្មោះដើមឈើធ្លាប់ហៅដោយសំឡេងថា **នគ** ។ បទថា **បញ្ញាសយោជនក្ខន្ធ សាខាយាមា** គឺ មានប្រវែងកម្ពស់មែកទៅលើ ៥០ យោជន៍ , ប្រវែងមែកសាខា ៥០ យោជន៍ ។ ព្រោះហេតុនោះឯង ទើបបែកមែកចេញទៅដោយជុំវិញ ១០០ យោជន៍ និងកម្ពស់ដើមពីដីឡើងទៅ ក៏ប៉ុណ្ណោះដូចគ្នា ។ ពាក្យថា **ជាដើមព្រីងដែលមានអានុភាព ជាហេតុ** (ឲ្យប្រកាសជម្ពូទ្វីប) មានសេចក្ដីថា ជាដើមព្រីងដែលមានអានុភាព មានប្រការផ្សេងៗ គឺ ជាដើមឈើដែលតាំងនៅបានអស់កប្បជាដើម ព្រោះជាដើមធំ (ជា

ហេតុឲ្យប្រកាសថា ជម្ពូទ្វីប ) ។ **ដើមសិម្ពលីរបស់ពួកគ្រុឌ** តាំងនៅលើជាន់ទី ២ នៃភ្នំសិនេរុ ។

បទថា **សិរីសេន** ( ក្នុងវិសុទ្ធិមគ្គជា សិរីសោ ) ជាតតិយាវិភត្តិក្នុងអត្ថនៃបឋមាវិភត្តិ ។ បទថា **សត្តមំ** ( ទី ៧ ) លោកពោលទុកដោយលិង្គវិបល្លាស មានអត្ថន័យថា **សិរីសោភវតិសត្តមោ** ( ប្រែថា ដើមសិរីសៈ ជាដើមទី ៧ ) ។

ក្នុងលោកធាតុនោះ **ព្រះចន្ទ** នៅក្រោម , **ព្រះអាទិត្យ** នៅខាងលើ ។ ព្រះចន្ទប្រាកដដោយភាវៈដែលឆាយារបស់ខ្លួនវិកល ( គឺ មិនជាក់ច្បាស់ណាស់ទេ ) ព្រោះភាពដែលនៅជិតព្រះអាទិត្យ , ព្រះចន្ទ និងព្រះអាទិត្យគោចរទៅក្នុងអាកាស កម្ពស់ប្រមាណស្មើកំពូលភ្នំយុគន្ធរ ចន្លោះទីច្រើនយោជន៍ ។ ឈ្មោះថា **ទីលំនៅរបស់ពួកអសុរ** បានដល់ ខាងក្រោមភ្នំសិនេរុ ។ ឈ្មោះថា **អវេចី** បានដល់ ខាងក្រោមជម្ពូទ្វីប , ជម្ពូទ្វីបមានសណ្ឋានដូចរទេះ ។ **អបរគោយានទ្វីប** ( ក្នុងវិសុទ្ធិមគ្គជាអមរគោយានទ្វីប ) មានសណ្ឋានដូចចិញ្ចៀន ។ **បុព្វវិទេហទ្វីប** មានសណ្ឋានដូចព្រះចន្ទពាក់កណ្តាល ។ **ឧត្តរកុរុទ្វីប** មានសណ្ឋានដូចតាំង ។ អាចារ្យច្រើននាក់ពោលថា សូម្បីទម្រង់មុខរបស់មនុស្សទាំងឡាយ ដែលនៅអាស្រ័យក្នុងទ្វីបនោះៗ និងទីនៅអាស្រ័យក្នុងទ្វីបបរិវារនោះ ក៏មានសណ្ឋានដូចទ្វីប ឬទ្វីបបរិវារនោះៗ ។ បទថា **តទន្តរេសុ** ប្រែថា ក្នុងរវាងចន្លោះចក្រវាលទាំងនោះ ពិតហើយចក្រវាល ៣ ប្រជុំគ្នា បានចន្លោះចក្រវាល ១ ដូចបាត្រ ៣ ប្រជុំគ្នា , រមែងមានលោកន្តរនរក ១ រណ្តៅ ។

ពាក្យថា **ដែលរកទីបំផុតមិនបាន** គឺ ដែលរកប្រមាណមិនបាន បានដល់ ជាចក្រវាលដែលមនុស្សដទៃៗ មិនអាចនឹងរាប់បានថា **មានប៉ុណ្ណេះ** ដូច្នេះ ។ ឈ្មោះ

ថា ព្រះមានព្រះភាគទ្រង់បានស្គាល់ដោយព្រះពុទ្ធញ្ញាណ ដែលរកទីបំផុតមិនបាន មានសេចក្តីថា ព្រះពុទ្ធញ្ញាណរមែងកំណត់បាននូវវត្ថុដែលរកទីបំផុតមិនបានទាំងបីយ៉ាង គឺ អាកាសដែលរកទីបំផុតមិនបាន សត្តនិកាយ ( ពពួកសត្វ ) ដែលរកទីបំផុតមិនបាន ចក្កវាឡដែលរកទីបំផុតមិនបាន ព្រោះសូម្បីព្រះញាណព្រះអង្គក៏រកទីបំផុតមិនបាន ។ ពិតណាស់ វត្ថុដែលអាចដឹងបាន មានប្រមាណត្រឹមណា ព្រះ-ញាណក៏មានប្រមាណប៉ុណ្ណោះ ព្រះញាណមានប្រមាណត្រឹមណា វត្ថុដែលអាចដឹងបាន ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ។ ព្រះញាណមានវត្ថុដែលអាចដឹងបានជាព្រំដែន វត្ថុក៏មានព្រះញាណជាព្រំដែនដូច្នេះ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា " ទ្រង់បានស្គាល់ដោយព្រះពុទ្ធញ្ញាណដែលរកទីបំផុតមិនបាន " ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបសេចក្តីដែលព្រះពុទ្ធញ្ញាណនេះ រកទីបំផុតមិនបាន ក៏ដោយការចាក់ធ្លុះវត្ថុដែលអាចដឹងបាន ដែលរកទីបំផុតមិនបាននោះឯង ព្រោះការដែលត្រាច់ទៅបានមិនទើសទាក់ក្នុងវត្ថុដែលអាចដឹងបាននោះ ។ សួរថា ក្នុងរឿងនេះ សូម្បីជាអ្នកដឹងធម៌ មានវិវដ្ដៈជាដើម ក៏គួរពោលដល់ មិនមែនឬ ? ឆ្លើយថា គួរពោលដល់ក៏ពិត តែភាពជាអ្នកស្គាល់ធម៌ មានវិវដ្ដៈជាដើមនោះ នឹងមកក្នុងអភិញ្ញាកថា ខាងមុខ ព្រោះហេតុនោះ ក្នុងទីនេះ លោកទើបមិនកាន់យក ។

( ចប់ មហាដីកា )

## បទថា អនុត្តរោ

*បុគ្គលដែលក្រៃលែងជាងព្រះមានព្រះភាគជាម្ចាស់ មិនមាន ព្រោះមិនមាននរណាត្រឹមតែម្នាក់ ដែលវិសេសជាងព្រះអង្គដោយគុណទាំងឡាយ ហេតុនោះទើបទ្រង់ព្រះនាមថា* ***អនុត្តរោ*** *ពិតហើយ ព្រះមានព្រះភាគ ទ្រង់រមែងគ្របសង្កត់នូវលោកទាំងពួងដោយសីលគុណក្តី សមាធិគុណ បញ្ញាគុណ វិមុត្តិគុណ និងដោយវិមុត្តិញ្ញាណទស្សនគុណក្តី ព្រះអង្គទ្រង់មិនមានអ្នកណាស្មើ ទ្រង់ស្មើនឹងអ្នកដែលមិនមានអ្នកស្មើ មិនមានអ្នកប្រៀប មិនមានអ្នកប្រដូច មិនមានអ្នកស្មើដោយសីលគុណក្តី ។ ល ។ ដោយវិមុត្តិញ្ញាណទស្សនៈក្តី ដូចទ្រង់ត្រាស់ទុកថា “ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញ ( សមណៈ ឬ ព្រាហ្មណ៍ដទៃ ) ដែលដល់ព្រមដោយសីល ក្រៃលែងជាងតថាគតឡើយ ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ។ ល ។ ក្នុងប្រជាជន ទាំងដែលជាទេវតា និងមនុស្ស ដូច្នេះជាដើម សេចក្តីពិស្តារបណ្ឌិតគប្បីពោល ( តាមន័យ ព្រះសូត្រនេះ ) សូត្រទាំងឡាយ មានអគប្បសាទសូត្រជាដើម និងគាថាទាំងឡាយ ដូចគាថា មានពាក្យជាដើមថា “* ***ន មេ អាចរិយោ អត្ថិ*** *អាចារ្យរបស់តថាគតមិនមាន ” បណ្ឌិតគប្បី ( នាំមកពោល ) ឲ្យពិស្តារចុះ ។*

## មហាដីកា

*ពាក្យថា* ***អត្តនា*** *នេះ ជាបញ្ចមីវិភត្តិ ( ប្រែថា ក្រៃលែងជាងព្រះអង្គ ) ។ ភ្ជាប់សេចក្តីថា* ***គុណេហិ អត្តនា វិសិដ្ឋតរស្ស*** *។ ក៏សព្ទថា* ***តរ*** *( ដែលប្រែថា ក្រៃលែង ) ក្នុងពាក្យថា* ***វិសិដ្ឋតរស្ស*** *នេះ លោកធ្វើទុកដើម្បីសម្តែងនូវអត្ថន័យ*

នៃបទថា **អនុត្តរោ** , មិនធ្វើទុក ក្រែងតែ នរណាៗ ដែលវិសេសជាងមានប្រាកដ , ពិតណាស់ ក្នុងលោក ព្រមទាំងទេវលោក នរណាៗ ឈ្មោះថា ល្មមនឹងប្រៀបបានថា ស្មើដូចព្រះតថាគត ក៏មិនមាន , អ្នកស្មើដូច ( ពិត ៗ ) នឹងមានបានអំពីណា ។ ចំណែកក្នុងបុគ្គលដែលវិសេសជាង នឹងមានអ្វីត្រូវនិយាយនោះ ។ បទថា **កស្សចិ** កែថា **កស្សចិបិ** ( សូម្បីនរណា ៗ ) ពាក្យថា **ទ្រង់គ្របសង្កត់** មានសេចក្តីថា សីលគុណរបស់ព្រះសាស្តា ដែលមិនជាសាធារណៈដល់បុគ្គលដទៃ ដល់នូវភាពជាបារមីដ៏ខ្ពង់ខ្ពស់ ព្រោះទ្រង់លះធម៌ដែលជាបដិបក្ខ ព្រមទាំងវាសនាបាន រាប់តាំងអំពីកាលដែល ហិរិ ឱត្តប្បៈ មេត្តា ករុណា ដែលជាឧបនិស្ស័យនៃសីលសម្បទា និង សទ្ធា សតិ វីរិយៈ បញ្ញា ដែលជាបច្ច័យពិសេសប្រជុំព្រមគ្នាដើម្បីសម្រេចភាពខ្ពង់ខ្ពស់ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបឈ្មោះថា ទ្រង់ប្រព្រឹត្តទៅគ្របសង្កត់លោក ព្រមទាំងទេវលោកបានដោយពិត អធិប្បាយថា ព្រះអង្គទ្រង់មិនត្រូវនរណាៗ គ្របសង្កត់បាន ។ សូម្បីក្នុងសមាធិគុណជាដើម ក៏គប្បីពោលតាមសមគួរយ៉ាងនេះ ម្យ៉ាងវិញទៀត គប្បីជ្រាបថា ព្រះគុណ មានសីលជាដើមទាំងនេះ មានទាំងដែលជាលោកិយ ទាំងដែលជាលោកុត្តរលាយឡំគ្នា ។ ចំណែក **វិមុត្តិញ្ញាណទស្សនៈ** ជាលោកិយ គឺជាកាមាវចរៈតែម្យ៉ាង ។

មានពាក្យសួរថា ប្រសិនបើយ៉ាងនេះ ព្រះពុទ្ធអង្គទ្រង់គ្របសង្កត់លោក ព្រមទាំងទេវលោកដោយវិមុត្តិញ្ញាណទស្សនៈនោះបានដូចម្តេច ( ព្រោះវិមុត្តិញ្ញាណទស្សនៈនោះជាលោកិយប៉ុណ្ណោះ ) ឆ្លើយថា ទ្រង់គ្របសង្កត់លោក ព្រមទាំងទេវលោកដោយវិមុត្តិញ្ញាណទស្សនៈនោះបាន ព្រោះវិមុត្តិញ្ញាណទស្សនៈនោះ រកវិមុត្តិញ្ញាណទស្សនៈ ( របស់បុគ្គលដទៃប្រៀបស្មើមិនបានដោយអានុភាព ) ។ ព្រោះវិមុត្តិ-

ញ្ញាណទស្សនៈនោះ ឈ្មោះថា ប្រសើរវិសេសជាង ដោយអារម្មណ៍ ដោយការប្រព្រឹត្តទៅ និងដោយអាការដែលប្រព្រឹត្តទៅនោះឯង ។ ពិតណាស់ វិមុត្តិញ្ញាណទស្សនៈនោះ មិនសាធារណៈដល់បុគ្គលដទៃ រមែងប្រព្រឹត្តទៅប្រារព្ធវិមុត្តិញ្ញាណទស្សនៈរបស់ព្រះសាស្ដា ( ជាអារម្មណ៍ ) ហើយកាលប្រព្រឹត្តទៅ រមែងប្រព្រឹត្តធ្វើអារម្មណ៍របស់ខ្លួនដែលមិនជាទីត្រាច់ទៅនៃការនឹកគិត ( គឺ ផុតវិស័យនៃការនឹកគិត ) ដែលជ្រាលជ្រៅយ៉ាងក្រៃលែង ដែលល្អិតយ៉ាងក្រៃលែង ឲ្យប្រាកដច្បាស់យ៉ាងល្អ ក្រៃលែង ព្រោះទ្រង់លះបង់ធម៌ដែលជាបដិបក្ខទាំងឡាយបានយ៉ាងល្អហើយ និងរមែងប្រព្រឹត្តទៅរហ័សរហួន ព្រោះដល់នូវភាពជាវសីបានដោយប្រពៃ និង ព្រោះមានការធ្លាក់ចុះកាន់ភវង្គ តិចបំផុតផងដែរ ។

លោកអាចារ្យ កាលសម្ដែងភាពមិនមានបុគ្គល ដែលលើសជាងព្រះសម្ពុទ្ធដោយព្រះគុណទាំងឡាយ មានសីលជាដើម យ៉ាងនេះហើយ ឥឡូវនេះបំណងនឹងសម្ដែងភាពដែលមិនមានបុគ្គលស្មើដូច ទើបពោលថា **ទ្រង់ជាអ្នកដែលរកបុគ្គលស្មើមិនបាន** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ទ្រង់ជាអ្នកដែលរកបុគ្គលស្មើមិនបាន** មានសេចក្ដីថា ព្រះមានព្រះភាគឈ្មោះថា ទ្រង់ជាអ្នកដែលរកបុគ្គលស្មើមិនបាន ព្រោះអត្ថថា ក្នុងកាលតែមួយ ទ្រង់មិនមានបុគ្គលដែលស្មើគ្នា គឺ ដូចគ្នាដោយគុណ មានសីលជាដើម ។ យ៉ាងនោះដូចគ្នា ឈ្មោះថា **ទ្រង់ជាអ្នកដែលស្មើដោយបុគ្គល ដែលរកអ្នកស្មើមិនបាន** ព្រោះអត្ថថា ទ្រង់ជាអ្នកដែលស្មើគ្នានឹងព្រះជាម្ចាស់ក្នុងអតីត និងក្នុងអនាគត ដែលជាបុគ្គលរកអ្នកស្មើមិនបាន ឬ ទ្រង់មានបុគ្គលដែលរកបុគ្គលស្មើមិនបាន ជាអ្នកស្មើគ្នា ( នឹងព្រះអង្គ ) ។ ឈ្មោះថា **ទ្រង់រកបុគ្គលប្រៀបមិនបាន** ព្រោះអត្ថថា ទ្រង់គ្មានអ្នកប្រៀបគ្នាបាន ដោយព្រះគុណ

មានសីលជាដើម ។ សូម្បីក្នុង២បទដ៏សេស ក៏មានន័យដូច្នេះដែរ ។ ក្នុងបទទាំង នោះ គ្រាន់តែប្រៀបធៀបគ្នាបាន ក៏ឈ្មោះថា **បដិមា** ( អ្នកប្រៀបគ្នាបាន ) ការប្រៀបធៀបគ្នាបាន ដោយជាបុគ្គលស្មើគ្នា ឈ្មោះថា **បដិភាគោ** ( ប្រែថា អ្នកមានចំណែកប្រៀបគ្នាបាន ) គប្បីជ្រាបថា បានដល់ ចំពោះបុគ្គលដែលតាំងនៅ ដោយទាក់ទងនឹងការចាប់គូគ្នា ( គឺ បុគ្គលម្នាក់ប្រៀបនឹងម្នាក់ទៀត ជាគូៗ ) ។

ពាក្យថា **ក៏ឯតថាគតមើលមិនឃើញ** ( នរណាមួយក្នុងលោក ) ជាដើម មានអធិប្បាយថា តថាគតសូម្បីកាលក្រឡេកមើលលោកទាំងពួង ដូចក្រឡេកមើលផ្លែកន្ទួតព្រៃក្នុងបាតដៃ ដោយសមន្តចក្ខុរបស់តថាគត ក៏មិនឃើញបុគ្គលណាៗ ក្នុងទីនោះ គឺ ក្នុងលោក ព្រមទាំងទេវលោក ។ល។ ក្នុងពពួកបជា ព្រមទាំងទេវតា និងមនុស្សដែលជាអ្នកដល់ព្រមដោយសីលដ៏ក្រៃលែងជាង គឺ មានសីលដែលដល់ព្រមក្រៃលែងជាងខ្លួន គឺ ជាងតថាគត ព្រោះបុគ្គលដែលមានសភាពដូច្នោះ មិនមានដូច្នេះ ។ ក្នុងពាក្យថា **អគប្បសាទសូត្រ** ជាដើមនេះ ពាក្យថា ៖

**ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយដែលមិនមានជើងក្តី មានជើងពីរក្តី មានជើង ៤ ក្តី មានជើងច្រើនក្តី មានរូបក្តី មិនមានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី មានប្រមាណត្រឹមណា ពោលបានថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ជាកំពូលនៃបណ្តាសត្វទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកណាជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ បុគ្គលទាំងនោះ ឈ្មោះថា ជ្រះថ្លាក្នុងបុគ្គលដ៏កំពូល ។ រីឯ ផលបុណ្យដែលជាកំពូល រមែងមានដល់បុគ្គល ដែលជ្រះថ្លាក្នុងបុគ្គលដ៏កំពូលនោះ ។ នេះជាអគប្បសាទសូត្រ ។**

ដោយ **អាទិ** ស័ព្ទ គប្បីជ្រាបដល់បទនៃព្រះសូត្រជាដើម យ៉ាងនេះថា ៖

ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកគ្របសង្កត់ នរណាៗ គ្របសង្កត់មិនបាន ជាអ្នកឃើញពិត ជាអ្នកធ្វើអំណាចឲ្យប្រព្រឹត្តទៅក្នុងលោក ព្រមទាំងទេវលោក ។ល។ ក្នុងពពួកប្រជា ព្រមទាំងទេវតា និងមនុស្ស ព្រោះហេតុនោះ ទើបហៅថា " តថាគត " ដូច្នេះ ។

ក្នុងពាក្យថា ព្រះគាថាដែលពោល ..... ជាដើមនេះ មានសេចក្ដីថា គប្បីពង្រីកព្រះគាថា មានយ៉ាងនេះថា ៖

តថាគត ជាអរហន្តក្នុងលោក តថាគតជាសាស្ដាដ៏កំពូល តថាគតតែមួយប៉ុណ្ណោះជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ជាបុគ្គលត្រជាក់ និព្វានហើយ ។ ព្រះតថាគតជាអ្នកទូន្មានខ្លួន ដ៏ប្រសើរបំផុត ក្នុងបណ្ដាអ្នកទូន្មានខ្លួនទាំងឡាយ ជាអ្នកស្វែងរកនូវគុណដ៏ស្ងប់ ក្នុងបណ្ដាអ្នកស្ងប់ទាំងឡាយ ជាអ្នករួចផុត ជាបុគ្គលកំពូលក្នុងបណ្ដាអ្នករួចផុតទាំងឡាយ ជាអ្នកឆ្លងនូវឱឃៈ ( ឱឃៈ គឺ កិលេស ) ដ៏ប្រសើរ ក្នុងបណ្ដាអ្នកដែលឆ្លងទាំងឡាយ ) ក៏បុគ្គលដែលប្រសើរជាងព្រះពុទ្ធជាម្ចាស់ និងស្មើដូចគ្នាក្នុងលោកនេះ ឬ ក្នុងលោកដទៃមិនមាន ។ ព្រះអង្គយាងទៅកាន់ភាពជាកំពូល ដែលបុគ្គលជាអ្នកប្រាជ្ញពោលថា ជាទក្ខិណេយ្យបុគ្គលសម្រាប់មនុស្សទាំងឡាយដែលត្រូវការបុណ្យ ស្វែងរកផលបុណ្យដ៏ធំ ។ ដូច្នេះជាដើមឲ្យពិស្ដារចុះ ។

( ចប់ មហាដីកា )

# បទថា បុរិសទម្មសារថិ

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះទ្រង់បង្ហឹក អធិប្បាយថា ទ្រង់ទូន្មាន ទ្រង់នាំទៅនូវបុរសដែលគប្បីទូន្មានបានទាំងឡាយ បុរសទាំងឡាយដែលនៅមិនទាន់ទូន្មាន ( តែថា ) គួរទូន្មានបាន ជាតិរច្ឆានបុរសក្តី ជាមនុស្សបុរសក្តី ជាអមនុស្សបុរសក្តី ឈ្មោះថា **បុរិសទម្មា** បុរសដែលគប្បីទូន្មានបានទាំងឡាយ ( ពាក្យថា បុរសក្នុងទីនេះ លោកមិនបានសំដៅដល់ភេទ តែសំដៅដល់អ្នកណាក៏ដោយដែលអាចទទួលការទូន្មានបាន ) ក្នុងបទ **បុរិសទម្មសារថិ** នោះ ពិតយ៉ាងនោះ សូម្បីតិរច្ឆានបុរសទាំងឡាយ ដូចជា អបលាលនាគរាជ ចូឡូទរ-នាគរាជ មហោទរនាគរាជ អគ្គិសិខនាគរាជ ធូមសិខនាគរាជ អាលវាឡនាគរាជ ធនបាលកៈ ព្រះមានព្រះភាគជាម្ចាស់ ក៏ទ្រង់ទូន្មានបាន គឺ ទ្រង់ធ្វើឲ្យអស់ពិស ( អស់កាចកាច ) ឲ្យតាំងនៅក្នុងសរណៈ និងសីលបាន សូម្បីមនុស្សទាំងឡាយ ដូចជាសច្ចកនិគន្ថបុត្រ អម្ពដ្ឋមាណព បោក្ខរសាតិព្រាហ្មណ៍ សោណទណ្ឌព្រាហ្មណ៍ កូដទន្តព្រាហ្មណ៍ សូម្បីអមនុស្សទាំងឡាយ ដូចជា អាឡវកយក្ខ សូចិលោមយក្ខ ខរលោមយក្ខ និងសក្កទេវរាជ ព្រះអង្គក៏ទ្រង់ទូន្មានបាន គឺ ទ្រង់នាំទៅបានដោយ វិនយុបាយ ( វិធីនាំ ) ផ្សេង ៗ យ៉ាងវិញទៀត ក្នុងសេចក្តីប្រការនេះ ព្រះសូត្រនេះ ( ទ្រង់ត្រាស់ ) ថា " **ម្នាលកេសី តថាគតក៏នាំបុរសដែលគប្បីទូន្មានបានទាំង-ឡាយទៅ ដោយវិធីកណ្តាលខ្លះ ... វិធីគ្រោតគ្រាតខ្លះ វិធីទាំងកណ្តាល ទាំងគ្រោតគ្រាត លាយគ្នាខ្លះ** " ដូច្នេះជាដើម បណ្ឌិតគប្បី ( នាំមកពោល ) ឲ្យពិស្តារ ។ ប្រការ១ទៀត ព្រះមានព្រះភាគ កាលត្រាស់ប្រាប់គុណវិសេស ( ដែល

ក្រៃលែងឡើងទៅ ) មានបឋមជ្ឈានជាដើមដល់ការកបុគ្គលទាំងឡាយ មានបុគ្គលដែលមានសីលបរិសុទ្ធហើយជាដើម និង ត្រាស់ប្រាប់មគ្គបដិបទាដ៏ក្រៃលែងឡើងទៅ ដល់អរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម ក៏ឈ្មោះថា ទ្រង់ទូន្មានអ្នកដែលបានទូន្មានហើយដោយពិត ( ដូច្នេះជាដើមថា អ្នកដែលនៅមិនទាន់បានទូន្មាន តែគួរដល់ការទូន្មានក្តី អ្នកដែលបានទូន្មានហើយ តែនៅមិនទាន់ដល់ទីបំផុតក្តី ក៏ជាបុរិសទម្មទាំងអស់ ) ។

## មហាដីកា

ពាក្យថា **ទ្រង់ទូន្មាន** គឺ ទ្រង់ធ្វើឲ្យស្ងប់រម្ងាប់បាន មានសេចក្តីថា ទ្រង់ឲ្យប្រកបដោយការស្ងប់កាយជាដើម ។ ក៏ការឲ្យប្រកបដោយការស្ងប់កាយជាដើមនោះ ជាការធ្វើឲ្យតាំងមាំក្នុងវិន័យ ( គ្រឿងអប់រំ ) មានតទង្គវិន័យជាដើម តាមសមគួរ ព្រោះហេតុនោះ លោកទើបពោលថា មានអត្ថាធិប្បាយថា គឺ ទ្រង់ទូន្មានដូច្នេះ ។ ពាក្យថា **គួរទូន្មានបាន** គឺជាអ្នកគួរដល់ការទូន្មាន ។ ក្នុងពាក្យថា **អមនុស្សបុរស** នេះ មានសេចក្តីថា ឈ្មោះថា អមនុស្ស ព្រោះអត្ថថា ដូចមនុស្ស ។

ភាពដូចគ្នានឹងមនុស្សរមែងប្រាកដក្នុងអមនុស្សនេះ ព្រោះហេតុនោះ ត្រឹមតែភាពជាមនុស្សប៉ុណ្ណោះមិនមាន ចំណែកដទៃមានដូចគ្នា ព្រោះហេតុនោះ លោកទើបបំណងយកសត្វទាំងឡាយ មានយក្ខជាដើមថា “ អមនុស្ស ” មិនបានបំណងយកសត្វពួកណានីមួយ ដែលដទៃអំពីមនុស្សទេ ។ ពិតហើយ លោកបានធ្វើការកាន់យកពួកតិរច្ឆានបុរសជាចំណែកមួយដទៃទៀត និង បានសម្តែងខែចំពោះបុគ្គលទាំងឡាយ មានទេវសក្កៈជាដើមប៉ុណ្ណោះ ( ថាជា អមនុស្ស ) ។ **អបលាលនាគរាជ**

អាស្រ័យនៅភ្នំហិមពាន្ត ។ **ចូឡោទរនាគរាជ** និង **មហោទរនាគរាជ** អាស្រ័យនៅឯនាគទ្វីប ។ **អគ្គិសិខនាគរាជ** និង **ធូមសិខនាគរាជ** អាស្រ័យនៅឯសីហឡ-ទ្វីប ។ ឈ្មោះថា ទ្រង់ធ្វើឲ្យអស់ពិសកំណាច ក៏ព្រោះទ្រង់បន្ទោបង់ពិសកំណាច គឺ ទោសៈបាន ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ឲ្យតាំងនៅក្នុងសរណៈ និងក្នុងសីលបាន** ដូច្នេះ ។ **គោទត្តព្រាហ្មណ៍ជាដើម** ដោយ **អាទិ** ស័ព្ទ ( ដែលប្រែថា ជាដើម ) គប្បីឃើញថា រួមយកបុគ្គលទាំងឡាយ មានឃោរមុខ-គហបតី ឧបាលិគហបតីជាដើម។ ពាក្យថា **សក្កទេវរាជជាដើម** ដោយ **អាទិ** ស័ព្ទ ( ដែលប្រែថា ជាដើម ) គប្បីឃើញថា សង្គ្រោះយកបុគ្គលទាំងឡាយ មានអជ-កលាបយក្ខ ពកព្រហ្មជាដើម ។ ពាក្យថា **ក៏រឿងនេះ គួរពង្រីកព្រះសូត្រនេះ** បានដល់ គួរពង្រីកកេសីសូត្រនេះឲ្យពិស្ដារក្នុងអត្ថថា គឺ ទ្រង់ទូន្មានដោយឧបាយទូន្មានដ៏វិចិត្រច្រើនប្រការនេះ ព្រោះមានការសម្ដែងការទូន្មានដោយឧបាយទាំងឡាយ មានឧបាយដែលទន់ភ្លន់ជាដើម តាមសមគួរ ។

ពាក្យថា ( **កាលទឹងត្រាស់ប្រាប់គុណវិសេស មានបឋមជ្ឈានជាដើម ដល់កល្យាណបុថុជ្ជនដែលមានសីលបរិសុទ្ធជាដើម** ភ្ជាប់សេចក្ដីថា កាលទឹងត្រាស់ប្រាប់គុណវិសេសដែលខ្ពង់ខ្ពស់ឡើងទៅដល់កល្យាណបុថុជ្ជននោះៗ ដោយន័យថា " ត្រាស់ប្រាប់បឋមជ្ឈានដល់អ្នកមានសីលបរិសុទ្ធ ត្រាស់ប្រាប់ទុតិយជ្ឈានដល់អ្នកបានបឋមជ្ឈាន " ដូច្នេះជាដើម ។ សូម្បីក្នុងពាក្យនេះថា **ដល់ព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម** ក៏មានន័យនេះឯង ។ លោកពោលពាក្យថា **ក៏ឈ្មោះថាទ្រង់ទូន្មានបុគ្គលសូម្បីដែលជាអ្នកទូន្មានហើយនោះឯង** ដូច្នេះនេះទុកខាងដើម ព្រោះធ្វើអធិប្បាយថា " បុគ្គលដែលចូលដល់ការទូន្មានតាមលំដាប់ ឈ្មោះថា **បុរិសទម្ម**

ទាំងអស់ ដោយប្រការទាំងពួង ” ដូច្នេះ ។ ក៏បុគ្គលពួកណា ព្រោះបានធ្វើភាពជាបុគ្គលគួរទូន្មាន ទុកដោយប្រការផ្សេងៗ ទើបមិនកន្លងផុតភាពជាបុគ្គលគួរទូន្មានដោយប្រការទាំងពួង លោកអាចារ្យសំដៅយកបុគ្គលទាំងនោះ ពោលថា “ ឈ្មោះថា ទ្រង់ទូន្មានបុគ្គល សូម្បីជាអ្នកទូន្មានហើយនោះឯង ” ដូច្នេះ ។ ពិតណាស់បុគ្គលទាំងនោះ ក៏ឈ្មោះថា **បុរិសទម្ម** ផងដែរ ព្រោះហេតុ គឺ ព្រះសាស្តា ទ្រង់ទូន្មានពួកគេ ។

( ចប់ មហាដីកា )

## បទថា អនុត្តរោ បុរិសទម្មសារថិ

ន័យម្យ៉ាងទៀត ពីរបទថា **អនុត្តរោ បុរិសទម្មសារថិ** នេះជាអត្ថបទ ( បទសម្តែងសេចក្តី ) ដែលដូចគ្នា ព្រោះព្រះមានព្រះភាគជាម្ចាស់ ទ្រង់ទូន្មានបុរសទាំងឡាយដែលគប្បីទូន្មានបាន ដូចដែលលោកទាំងឡាយអង្គុយធ្វើសមាធិនៅមួយកន្លែងនោះឯង ( តែ ) ត្រាច់ទៅបានទាំង ៨ ទិស មិនជាប់ជំពាក់ ព្រោះហេតុនោះ បណ្ឌិតទើបថ្វាយព្រះនាមថា **អនុត្តរោ បុរិសទម្មសារថិ** ទ្រង់ដឹកនាំបុរសដែលគប្បីទូន្មានបាន មិនមានអ្នកដទៃក្រៃលែងជាង ។ ម្យ៉ាងវិញទៀត ក្នុងសេចក្តីនេះ ព្រះសូត្រនេះ ( ដែលត្រាស់ ) ថា “ **ម្នាលភិក្ខុទាំងឡាយ ដំរីដែលគប្បីទូន្មាន ត្រូវគ្រូទូន្មានដំរី ទូន្មានហើយ រមែងឲ្យត្រាច់ទៅក្នុងទិសតែមួយបាន** ” ដូច្នេះជាដើម បណ្ឌិត គប្បី ( នាំមកពោល ) ឲ្យពិស្តារចុះ ។

# មហាដីកា

ពាក្យថា **អត្ថបទ** បានដល់ **អត្ថ អភិព្យញ្ជនបទ** ( បទដែលធ្វើខ្លឹមសារឲ្យជាក់ច្បាស់ ) មានសេចក្ដីថា ពាក្យ ។ ដោយការធ្វើអត្ថន័យឲ្យជាក់ច្បាស់សម្រេចបានដោយពាក្យ មិនមែនមានដោយហេតុត្រឹមតែបទ មាននាមបទជាដើមប៉ុណ្ណោះឡើយ គឺជាការដែលលោកអាចារ្យ សម្ដែងភាពជានាយសារថី ទូន្មានបុរសដែលគួរទូន្មាននៃព្រះសាស្ដា ដែលមិនជាសាធារណៈដល់បុគ្គលដទៃ ទុកដោយសភាពជាបទដូចគ្នា ។ ព្រោះហេតុនោះ លោកទើបពោលថា ក៏ព្រះមានព្រះភាគដូច្នេះជាដើម ។ ពាក្យថា **ទិសទាំង ៨** បានដល់ សមាបត្តិ ៨ ពិតណាស់ សមាបត្តិ ៨ នោះ សូម្បីថា សម្ព័ន្ធគ្នានិងគ្នាក៏ឈ្មោះថា **ទិស** ព្រោះអត្ថថា ប្រាកដ គឺ បណ្ឌិតចង្អុលបង្ហាញទុក ព្រោះជាធម៌ដែលមិនលាយគ្នា ម្យ៉ាងទៀត សមាបត្តិ ៨ ឈ្មោះថា **ទិស** ព្រោះអត្ថថា ដូចជាទិស ។ បទថា **អសជ្ជមានា** ប្រែថា មិនទើសទាក់ គឺ ត្រាច់ទៅបានមិនជាប់ជំពាក់ ព្រោះដល់ភាពជាវសី ។ ឈ្មោះថា **ស្ទុះទៅ** ព្រោះប្រកបក្នុងការប្រព្រឹត្តទៅនៃជវ័ន អធិប្បាយថា នៅមិនទាន់បានផ្លាស់ប្ដូរាងកាយ ( ផ្លាស់ប្ដូរឥរិយាបថ ) របស់ខ្លួន ក៏បុរសដែលគួរទូន្មានបានដែលព្រះសាស្ដាទ្រង់ទូន្មានហើយ រមែងត្រាច់ទៅកាន់ទិសទាំង ៨ បាន ដោយឥរិយាបថមួយប៉ុណ្ណោះ ។ ព្រោះហេតុនោះ លោកទើបពោលថា **អង្គុយដោយបល្ល័ង្កមួយប៉ុណ្ណោះ** ដូច្នេះ ។ ក៏ពាក្យថា “ ទិសទាំង ៨ នេះ ” ត្រឹមតែជានិទស្សនៈ ព្រោះនៅមានការត្រាច់ទៅកាន់ទិស គឺ និរោធសមាបត្តិនិងអមតទិស ( ព្រះនិព្វាន ) ដែលលោកិយជនទាំងឡាយមិនទាន់ធ្លាប់ទៅ ។ ( ចប់ មហាដីកា )

## បទថា សត្ថា ទេវមនុស្សានំ

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **សត្ថា** ( សាស្តា ) ព្រោះទ្រង់ប្រៀនប្រដៅ ( វេនេយ្យសត្វ ) ដោយប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ និងប្រយោជន៍យ៉ាងក្រៃលែង ( គឺ ព្រះនិព្វាន ) តាមសមគួរ ។ ន័យម្យ៉ាងទៀត ព្រះនាមថា **សត្ថា** ( នោះ ) សំដៅយកសេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ជា **សត្ថវាហ** ( អ្នកដឹកនាំពួកក្រុម ដូចមេកងរទេះ ) អធិប្បាយក្នុងសេចក្តីនេះ បណ្ឌិតគប្បីជ្រាបតាមន័យនៃព្រះបាលីនិទ្ទេសក៏បានថា " **សត្ថវាហ** " ( មេក្រុមរទេះ ) រមែងនាំពួករទេះឲ្យឆ្លងកន្តារ គឺ ឲ្យឆ្លងចោរកន្តារ ឲ្យឆ្លងវាលកន្តារ ឲ្យឆ្លងទុព្ភិក្ខកន្តារ ឲ្យឆ្លងនិរោទកកន្តារ រហូតចេញក្រៅផុត ( ដែនកន្តារ ) ទៅដល់ដែនដី ដែលជាដែនក្សេម ( ផុតភ័យ ) យ៉ាងណា ព្រះមានព្រះភាគក៏ដូច្នោះឯង ទ្រង់ជា **សត្ថា** គឺជា **សត្ថវាហ** ញុំាងសត្វទាំងឡាយឲ្យឆ្លងភវកន្តារ ឲ្យឆ្លងជាតិកន្តារ.... ដូច្នេះ ជាដើម ។

ពាក្យថា **ទេវមនុស្សានំ** មានសេចក្តីថា របស់ទេវតាទាំងឡាយផង របស់មនុស្សទាំងឡាយផង, ពាក្យថា ( **ទេវមនុស្សានំ** ) នេះ ទ្រង់ត្រាស់ដោយការកំណត់យកវេនេយ្យសត្វថ្នាក់ឧក្រិដ្ឋ និងដោយកំណត់យកវេនេយ្យសត្វដែលជាភព្វបុគ្គល ( សំដៅយកសេចក្តីថា ទេវតា និងមនុស្សប៉ុណ្ណោះ រាប់ជាសត្វជាន់ខ្ពស់ នៅក្នុងឋានៈជាភព្វបុគ្គល គឺ បុគ្គលគួរធ្វើដំណើរទៅកាន់ធម៌ដែលត្រឹមត្រូវបាន សត្វតិរច្ឆានមិននៅក្នុងឋានៈនោះទេ ) តែសេចក្តីពិត ព្រះមានព្រះភាគជាម្ចាស់ ជាសាស្តារបស់សត្វតិរច្ឆានទាំងឡាយផងដែរ ដោយប្រទានព្រះអនុសាសនីដល់សត្វតិរច្ឆានទាំងនោះឲ្យបានឧបនិស្ស័យសម្បត្តិ ដោយការស្តាប់ធម៌អំពីព្រះមានព្រះភាគ ហើយដោយ

ឧបនិស្ស័យសម្បត្តិនោះឯង និង ជាអ្នកមានចំណែកនៃមគ្គផល ក្នុងអត្តភាពទី ២ ឬ ទី ៣ ពិតណាស់ អ្នកបានឧបនិស្ស័យសម្បត្តិដោយការស្តាប់ធម៌ទាំង ឡាយ មានមណ្ឌូកទេវបុត្រជាដើម ជានិទស្សនៈក្នុងសេចក្តីនេះ ។

## រឿងមណ្ឌូកទេវបុត្រ

មានរឿងពោលថា កាលព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងធម៌ដល់អ្នកក្រុងចម្ប៉ានៅមាត់ស្រះបោក្ខរណី ឈ្មោះ **គគ្គរា** មានកង្កែបមួយកាន់យកនិមិត្តក្នុងព្រះសូរសៀងរបស់ព្រះមានព្រះភាគបាន ( ជាទ្រង់សម្តែងធម៌ មានចិត្តជ្រះថ្លាឡើងមកក្រាបស្ងៀម ស្តាប់ព្រះធម៌នៅលើគោក ខាងក្រោយបរិស័ទ ) ។ គ្រានោះអ្នកកង្វាលគោម្នាក់ដើរចូលទៅមើលគេស្តាប់ធម៌ បានទៅឈរនៅជិតកង្កែប តែកង្កែបកំពុងតែជ្រះថ្លាដោយយកចិត្តទុកដាក់ក្នុងព្រះសូរសៀងរបស់ព្រះអង្គ ទើបមិនលោតគេចទៅណា ចំណែកអ្នកកង្វាលគោនោះ ក៏មិនបានឃើញកង្កែបនោះដែរ បានយកឈើប្រត់ៗ ចុះទៅ ( ចៃដន្យ ) ចំកង្កែបត្រង់ក្បាល ហើយកង្កែបនោះបានស្លាប់ទៅមួយរំពេចក្នុងពេលនោះឯង ក្រោយអំពីស្លាប់ បានទៅកើតក្នុងវិមានមាសដែលមានកម្ពស់ ១២ យោជន៍ នាស្ថានតាវត្តិង្ស ដូចជាដេកលក់ទៅ ហើយភ្ញាក់ឡើងវិញ ឃើញខ្លួន មានទេពអប្សរហោមរោមនៅក្នុងវិមាននោះ គិតពិចារណាមើលថា អើ ! ខ្លួនយើងក៏មកកើតក្នុងទីនេះដែរហ្ន៎ យើងបានធ្វើកម្មដូចម្តេចហ្ន៎ ក៏មិនបានឃើញកម្មដទៃឯណានីមួយ ក្រៅអំពីការកាន់យកនិមិត្តក្នុងព្រះសូរសៀងរបស់ព្រះមានព្រះភាគជាម្ចាស់ រំពេចនោះ ទេវបុត្រនោះ ក៏មកគាល់ព្រះសម្ពុទ្ធទាំងវិមាន លុះមកដល់ ក៏បានចូលទៅថ្វាយបង្គំព្រះយុគលបាទរបស់ព្រះមានព្រះភាគ ព្រះមានព្រះ

កាគ ទ្រង់ជ្រាបហើយ ទ្រង់ត្រាស់សួរដើម្បីឲ្យមនុស្សទាំងឡាយ ឃើញប្រចក្សក្នុងផលកម្ម និង ពុទ្ធានុភាព ថា ៖

“ ***នរណាហ្នឹង រុងរឿងដោយឫទ្ធិ ដោយយស ( បរិវារ ) មានសម្បុរកាយស្រស់ល្អ ញុំាងទិសទាំងពួងឲ្យភ្លឺស្វាង មកថ្វាយបង្គំបាទារបស់តថាគត*** ” ។

គ្រានោះ ទេវបុត្រនោះ បានក្រាបទូលតបចំពោះព្រះអង្គវិញថា ក្នុងជាតិមុន ខ្ញុំព្រះអង្គជាកង្កែប ដែលជាសត្វជំពូកវារីគោចរ ( រកស៊ីតាមទឹក ) កាលខ្ញុំព្រះអង្គកំពុងស្តាប់ព្រះសូរសៀងសម្តែងធម៌របស់ព្រះអង្គ អ្នកកង្វាលគោបានធ្វើឲ្យខ្ញុំព្រះអង្គស្លាប់ ។

លំដាប់នោះ ព្រះមានព្រះភាគ សម្តែងធម៌ដល់ទេវបុត្រនោះ ធម្មាភិសម័យបានកើតមានដល់សត្វ ៨៤.០០០ ឯទេវបុត្រនោះ បានតាំងនៅក្នុងសោតាបត្តិផល រួចបានធ្វើការញញឹមញញែម ត្រឡប់ទៅវិញ ។

## មហាដីកា

អត្តភាពដែលឃើញប្រចក្ស ហៅថា **ទិដ្ឋធម៌** ប្រយោជន៍ឈ្មោះថា **ទិដ្ឋធម្មិក** ព្រោះអត្ថថា ប្រកបក្នុងទិដ្ឋធម៌នោះ បានដល់ ប្រយោជន៍ក្នុងលោកនេះ ។ លោកខាងមុខ ឈ្មោះថា **សម្បរាយ** ព្រោះដែលបុគ្គលគប្បីដល់ខាងមុខ គឺ គប្បីដល់ដោយប្រពៃ ដោយអំណាចនៃកម្មនិងកិលេស ប្រយោជន៍ ឈ្មោះថា **សម្បរាយិក** ព្រោះអត្ថថា ប្រកបក្នុងសម្បរាយ ( គឺ ក្នុងលោកខាងមុខ ) នោះ បានដល់ប្រយោជន៍ក្នុងលោកខាងមុខ ។ ប្រយោជន៍យ៉ាងក្រៃលែង គឺ ឧត្តម ឈ្មោះថា បរមត្ថ បានដល់ ព្រះនិព្វាន ។ សេចក្តីថា **ដោយទិដ្ឋធម្មិកប្រយោជន៍ សម្បរាយិក**

**ប្រយោជន៍** **និងបរមត្ថប្រយោជន៍** ទាំងនោះ ។ បទថា **យថារហំ** ប្រែថា តាមសមគួរ ។ មានសេចក្តីថា ក្នុងបណ្តាប្រយោជន៍ទាំងឡាយទាំងនោះ បុគ្គលណាៗ រមែងគួរដល់ប្រយោជន៍ណាៗ ព្រះមានព្រះភាគក៏ទ្រង់អនុសាសន៍ បុគ្គលនោះៗ តាមសមគួរដល់ប្រយោជន៍នោះៗ ។ ពាក្យថា **ទ្រង់អនុសាសន៍** គឺ ទ្រង់ដឹកនាំបានដល់ ទ្រង់ឲ្យតាំងនៅក្នុងប្រយោជន៍នោះៗ ។ **ពពួកជន** ឈ្មោះថា **សត្ថ** ព្រោះអត្ថថា ប្រព្រឹត្តទៅព្រមជាមួយប្រយោជន៍ បានដល់ ពពួកជនដែលទៅកាន់ប្រទេសដទៃ ដើម្បីធ្វើការលក់ដូរ ដោយមុខទំនិញដែលជាដើមទុន , **មេគណៈ** ឈ្មោះថា **សត្ថា** ព្រោះអត្ថថា មានពពួកជនដែលឈ្មោះថា **សត្ថ** នោះ ដែលខ្ទួនគប្បីបរិបាល គឺ គប្បីប្រៀនប្រដៅដោយការទាក់ទង និងការចង្អុលបង្ហាញដល់វត្ថុដែលជាប្រយោជន៍ជាដើម ។ ព្រះមានព្រះភាគទ្រង់ដូចជាមេគណៈនោះ ព្រោះហេតុនោះ លោកទើបពោលថា **ព្រះមានព្រះភាគទ្រង់ព្រះនាមថា សត្ថា** គឺ ទ្រង់ជាអ្នកនាំពពួកជន ដូចមេគណៈ ដូច្នេះ ។

ឥឡូវនេះ លោកបំណាងសម្តែងសេចក្តីនោះតាមន័យព្រះបាលី គម្ពីរនិទ្ទេស ទើបពោលថា **មេគណៈយ៉ាងណា** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សត្ថេ** ប្រែថា ពពួកជន ។ ឈ្មោះថា **ផ្លូវកន្តារ** ព្រោះអត្ថថា ជាទីដែលបុគ្គលមានទឹក ទើបឆ្លងទៅបាន បានដល់ ស្ថានទីជាព្រៃប្រាសចាកទឹក ស្ថានទីសូម្បីក្រៅអំពីនេះ គេក៏ហៅយ៉ាងនោះបាន ដោយទាក់ទឹងស័ព្ទដែលនិយមប្រើ ។ បទថា **ចោរកន្តារំ** ប្រែថា ផ្លូវកន្តារដែលពួកចោរគ្រប់គ្រង ។ ឈ្មោះថា **វាលកន្តារំ** ក៏ដោយន័យដូចគ្នានោះ ( គឺ ផ្លូវកន្តារ ដែលសត្វសាហាវនៅគ្រប់គ្រង ) ។ បទថា **ទុព្ភិក្ខកន្តារំ** ប្រែថា ផ្លូវកន្តារដែលរកអាហារបានដោយលំបាក ។ ពាក្យថា **ឲ្យឆ្លង** គឺ ឲ្យឈាន

កន្លងស្ថានទីដែលរកសេចក្ដីក្សេមមិនបាន ។ បទថា **ឧត្តារេតិ** ( ឲ្យឆ្លងឡើង ) ជាដើម លោកពោលបន្ថែមបទទុក ដោយពាក្យឧបសគ្គ ។ ន័យម្យ៉ាងទៀត បទថា **ឧត្តារេតិ** បានដល់ ឲ្យឆ្លងចូលទៅកាន់ភូមិប្រទេសដែលក្សេម ។ បទថា **និត្ថារេតិ** បានដល់ ឲ្យឆ្លងចេញទៅអំពីស្ថានទីដែលរកសេចក្ដីក្សេមមិនបាន ។ បទថា **បត្តា-រេតិ** បានដល់ ចាប់ឲ្យឆ្លងទៅ មានសេចក្ដីថា ឲ្យឆ្លងទៅដូចប្រើដៃចាប់ឲ្យឆ្លងទៅ ។ ការឲ្យឆ្លង ឲ្យឆ្លងទៅជាដើម ទាំងអស់នេះ ត្រឹមតែជាការឲ្យតាំងនៅក្នុងស្ថានទីក្សេមប៉ុណ្ណោះ ព្រោះហេតុនោះ លោកទើបពោលថា **ឲ្យដល់ភូមិប្រទេសដែលក្សេម** ដូច្នេះ ។ ពាក្យថា **សត្ថ** បានដល់ វេនេយ្យសត្វ ។ ផ្លូវកន្តារ គឺ ជាតិ ឈ្មោះថា ជាតិកន្តារ ព្រោះជាព្រៃក្រាស់ធំ ព្រោះមានសេចក្ដីវិនាសធំ និងព្រោះមានការឆ្លងផុតបានដោយលំបាក មានសេចក្ដីថា ទ្រង់ញ៉ាំងឲ្យឆ្លង **ជាតិកន្តារ** នោះ ។

បទថា **ឧកដ្ឋបរិច្ឆេទវសេន** ប្រែថា ដោយអំណាចការកំណត់យកសត្វជាន់ខ្ពស់ ។ ពិតណាស់ ទេវតានិងមនុស្សប៉ុណ្ណោះ ឈ្មោះថា សត្វជាន់ខ្ពស់ មិនមែនសត្វតិរច្ឆានជាដើម ។ ពាក្យថា **ទាក់ទងដោយការកំណត់ដល់ភព្វបុគ្គល** គឺទាក់ទងនឹងការកំណត់ដល់បុគ្គល ដែលសមគួរដល់ការឈានចុះកាន់សម្មត្តនិយាម ( ការកំណត់នូវសភាវៈដ៏ប្រពៃ គឺ អរិយមគ្គមានអង្គ ៨ ) ។ បទថា **ឯតំ** បានដល់ពាក្យថា **ទេវមនុស្សានំ** នេះ ។ បទថា **ភគវតោ** ជាបញ្ចមីវិភត្តិ ( ប្រែថា អំពីព្រះមានព្រះភាគ ) ដូចពាក្យថា “ **ឧបជ្ឈាយតោអជ្ឈេតិ** ” ( រមែងបានទទួលអំពីព្រះឧបជ្ឈាយ៍ ) ដូច្នេះ ឬមានអត្ថន័យថា ក្នុងសម្នាក់របស់ព្រះមានព្រះភាគ ។ ពាក្យ ថា **ឧបនិស្សយសម្បត្តិ** បានដល់ ហេតុមានកម្លាំងនៃការសម្រេចមគ្គផលមានតិហេតុកបដិសន្ធិ ( បដិសន្ធិដែលប្រកបដោយហេតុ ៣ ) ជាដើម ។

ពាក្យថា **ឈ្មោះថា គគ្គរា** គឺ ហៅថា **គគ្គរា** តាមព្រះនាមអគ្គមហេសី ឬថា ដែលបានឈ្មោះថា " **គគ្គរា** " ព្រោះព្រះមហេសីព្រះនាមថា ព្រះនាង គគ្គរានោះ ទ្រង់ឲ្យកសាងឡើង ។ ពាក្យថា **បានកាន់យកនិមិត្តក្នុងព្រះសូរសៀង** គឺបានកាន់យកហើយនូវនិមិត្តក្នុងព្រះសូរសៀង ដោយការសម្គាល់ថា ជាធម៌យ៉ាង នេះថា " នេះឯងហៅថា **ធម៌** " ដូច្នេះ ហើយកាលកំពុងកាន់យក ក៏ជាអ្នកមានចិត្ត ជ្រះថ្លា ក្រាបនៅក្រោយបរិស័ទ ។ ពាក្យថា **ឈរច្រត់** មានសេចក្តីថា កាលមិន ឃើញឈើច្រត់សង្កត់នៅលើក្បាលកង្កែប ទើបឈរច្រត់នៅត្រង់ទីនោះ ។ សូម្បី កង្កែប កាលឈើច្រត់សង្កត់ក្បាលហើយ ក៏មិនរើបម្រះឡើយ រហូតស្លាប់ទៅទាំង សេចក្តីជ្រះថ្លា ដែលប្រព្រឹត្តទៅក្នុងព្រះធម៌ ។ ការនឹកគិតថា " យើងមកពីទីណា កើតឡើងហើយ ក្នុងទីនេះ ក្នុងទីដែលយើងមកនោះ យើងបានធ្វើកម្មអ្វីទុក " ដូច្នេះ នេះជាធម្មតា របស់សត្វទាំងឡាយដែលកើតក្នុងទេវលោក ។ ព្រោះដូច្នោះ ដោយ បានឃើញកពចាស់របស់ខ្លួនហើយ ទើបបានពោលថា " **អើហ្ន៎ យើងឈ្មោះថា សូម្បីតែយើងក៏កើតក្នុងទីនេះបាន** " ដូច្នេះ ។ ទេវបុត្របានក្រាបថ្វាយបង្គំព្រះបាទា ព្រះមានព្រះភាគ ដោយសេចក្តីស្រឡាញ់ សេចក្តីគោរព និង សេចក្តីរាប់អានដ៏ ជ្រាលជ្រៅ ដែលទាក់ទងដោយភាពជាអ្នកកតញ្ញូ ។

ព្រះមានព្រះភាគ កាលទ្រង់កំពុងជ្រាបនោះឯង ទ្រង់បំណងនឹងធ្វើផល របស់កម្ម និងពុទ្ធានុភាពឲ្យប្រាកដដល់មហាជន ទើបត្រាស់សួរដោយព្រះគាថាថា " **កោ មេ វន្ទតិ** " ( នរណាហ្ន៎ កំពុងថ្វាយបង្គំបាទារបស់តថាគត ) ជាដើម ។ ក្នុងបាឋព្រះគាថាទាំងនោះ ពាក្យថា **នរណា** មានសេចក្តីថា ក្នុងបណ្តាបុគ្គលទាំង ឡាយ មានទេវតា នាគ យក្ខ គន្ធព្វ ជាដើម ជានរណា អ្នកណា ។ បទថា **មេ**

ប្រែថា របស់យើង ។ បទថា **បាទានិ** កែជា **បាទេ** ( ប្រែថា ជើងទាំងពីរ ) ។ ពាក្យថា **ដោយឫទ្ធិ** គឺ ដោយឫទ្ធិបែបនេះ ។ ពាក្យថា **ដោយយស** គឺ ដោយបរិវារ និងដោយខេត្តដែន ដូច្នេះ ។ បទថា **ផលំ** ប្រែថា រុងរឿង ។ ពាក្យថា **ដែលគួរពេញចិត្តយ៉ាងក្រៃលែង** បានដល់ ដែលគួរពេញចិត្ត គឺដែលគួរប្រាថ្នា ស្រស់ស្អាតហួសទីងប្រៀបបាន ។ ពាក្យថា **ដោយវណ្ណៈ** បានដល់ ដោយឆវីវណ្ណ គឺ ដោយភាពផូរផង់នៃសម្បុរកាយ ។ ពាក្យថា **ញ៉ាំងទិសទាំងពួងឲ្យភ្លឺស្វាង** មានសេចក្ដីថា ញ៉ាំងទិសទាំងពួង គឺ ទាំង ១០ ឲ្យភ្លឺ គឺ ធ្វើឲ្យមានឱកាសតែមួយដូចគ្នា គឺ ឲ្យមានពន្លឺភ្លឺតែមួយដូចគ្នានឹងព្រះចន្ទ និងព្រះអាទិត្យ ។

ចំណែកទេវបុត្រ ត្រូវព្រះមានព្រះភាគត្រាស់សួរហើយយ៉ាងនេះ កាលនឹងប្រកាសខ្លួនឲ្យព្រះអង្គជ្រាប ទើបពោលពាក្យជាគាថាថា **មណ្ឌូកោហំ បុរេអាសឹ** ក្នុងជាតិមុន ខ្ញុំព្រះអង្គជាកង្កែប ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **បុរេ** ប្រែថា ក្នុងជាតិមុន ។ ពាក្យថា **ក្នុងទឹក** នេះ ជាពាក្យសម្ដែងស្ថានទីឧប្បត្តិរបស់ខ្លួនក្នុងពេលនោះ ។ ដោយពាក្យថា **ជាកង្កែបនៅក្នុងទឹក** នេះ ជាការធ្វើការបដិសេធកង្កែបដែលនៅលើគោក មានកង្កែបដែលបំប៉ោងខ្លួនបាន ( ហ៊ឹង ) ជាដើម ។ ឈ្មោះថា **គោចរ** ព្រោះអត្ថថា ជាទីដែលគោទាំងឡាយត្រាច់ទៅ បានដល់ ស្ថានទីរកស៊ីរបស់គោទាំងឡាយ តែក្នុងទីនេះ ឈ្មោះថា **គោចរ** ព្រោះអត្ថថា ដូចគោចរ , កង្កែបនេះ ឈ្មោះថា **វារិគោចរ** ព្រោះអត្ថថា មានវារិ គឺ ទឹកជាគោចរ ។ ក៏សត្វពួកខ្លះ មានអណ្ដើកជាដើម សូម្បីថាត្រាច់ទៅក្នុងទឹក តែឈ្មោះថា មានទឹកជាទីគោចរដែរ ក៏ទេ ( ព្រោះជួនកាលរកស៊ីលើគោក ) ព្រោះដូច្នោះ ទេវបុត្រទើបពោលឲ្យពិសេសទៅថា **មានទឹកជាទីគោចរ** ដូច្នេះ ។ ពាក្យថា **កាលកំពុងស្ដាប់ព្រះធម៌**

**របស់ព្រះអង្គ** គឺកាលកំពុងស្តាប់ព្រះធម៌របស់ព្រះអង្គសម្តែង ដោយព្រះសូរសៀង ដូចជាសំឡេងព្រហ្ម សំឡេងពីរោះដូចជាការវិក ដោយអំណាចការកាន់យកនិមិត្ត ក្នុងព្រះសូរសៀងថា **នេះឯងហៅថា ធម៌** ដូច្នេះ ។ ក៏ពាក្យថា **សណន្តស្ស** នេះ ជាឆដ្ឋីវិភត្តិក្នុងអត្ថថា **អនាទរ** ( គឺ ឲ្យប្រែថា កាលកំពុងស្តាប់ ) ។ ពាក្យថា **អ្នកកង្វាលគោក៏សម្លាប់** មានសេចក្តីថា អ្នកកង្វាលគោ ដែលមកកាន់ទីជិតខ្ញុំព្រះអង្គ ហើយយកឈើច្រត់ៗ ចុះទៅ សង្កត់ចំលើក្បាលរបស់ខ្ញុំព្រះអង្គឲ្យស្លាប់ដូច្នេះ ។

ពាក្យថា **ធ្វើការញញឹមញញែម** មានសេចក្តីថា លុះគិតថា " ដោយអានុភាពនៃបុណ្យសូម្បីត្រឹមតែបន្តិចបន្តួចយ៉ាងនោះ យើងក៏បានទទួលសម្បត្តិទាំងដែលជាលោកិយ ទាំងដែលជាលោកុត្តរ ដែលប្រសើរហួសនឹងប្រៀបយ៉ាងនេះបានហ្ន៎ " ដូច្នេះហើយ ក៏កើតបីតិសោមនស្ស ធ្វើការញញឹមញុំាងស្ថានទីនោះឲ្យភ្លឺស្វាងដោយប្រមាណក្រៃលែង ដោយរស្មីនៃក្រចកទាំង ១០ ដែលចាំងចែងជាពន្លឺពណ៌ស ។ ក៏ដោយអំណាចនៃបីតិ និងសោមនស្ស ទេវបុត្រនោះពោលគាថាពីរនេះថា ៖

*សូមព្រះអង្គទតព្រះនេត្រមើលឫទ្ធិ និង យសរបស់ខ្ញុំព្រះអង្គ ដែលមានចិត្តជ្រះថ្លាមួយជួរខណៈ និង សូមទតព្រះនេត្រមើលអានុភាពរបស់ខ្ញុំព្រះអង្គ សូមទតព្រះនេត្រមើលវណ្ណៈ និង ភាពរុងរឿងរបស់ខ្ញុំព្រះអង្គ បពិត្រព្រះគោតម ក៏អស់កាលដ៏យូរមកហើយ បុគ្គលពួកណា បានស្តាប់ធម៌របស់ព្រះអង្គ បុគ្គលទាំងនោះដល់ហើយនូវឋានៈដែលមិនញាប់ញ័រ ទៅក្នុងទីណាហើយ រមែងមិនសោយសោក ។*

ដូច្នេះហើយ ក៏ចៀសចេញទៅ ។

( ចប់ មហាដីកា )

## បទថា ពុទ្ធោ

ចំណែកដែលទ្រង់ព្រះនាមថា **ពុទ្ធោ** ក៏ព្រោះវត្ថុគ្រប់យ៉ាង ដែលឈ្មោះថា ជាវត្ថុដែលគួរដឹងមានហើយ ទ្រង់ដឹងវត្ថុដែលគួរដឹងនោះទាំងអស់ ដោយអំណាច វិមោក្ខន្តិកញ្ញាណ ( ព្រះញាណដែលកើតឡើងក្នុងទីបំផុតនៃវិមោក្ខ ) ន័យម្យ៉ាង ទៀត ព្រោះហេតុដែលបានត្រាស់ដឹងសច្ចៈ ៤ ដោយព្រះអង្គឯងខ្លះ ទ្រង់ញ៉ាំង សត្វដទៃៗ ឲ្យដឹងផងខ្លះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ពុទ្ធោ** ដោយហេតុ ដូចពោលមកដូច្នេះជាដើមក៏បាន ក៏ដើម្បីឲ្យដឹងសេចក្តីនេះច្បាស់ ន័យនៃបាលី និទ្ទេសក្តី ន័យនៃបាលីបដិសម្ភិទាក្តី ទាំងអស់ដែលប្រព្រឹត្តទៅដោយន័យថា **ពុជ្ឈិតា សច្ចានីតិ ពុទ្ធោ** ព្រះមានព្រះភាគទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវ សច្ចៈទាំងឡាយ **ពោធេតា បជាយាតិ ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះ អង្គញ៉ាំងពពួកជនឲ្យត្រាស់ដឹងផង ដូច្នេះជាដើម បណ្ឌិតគប្បី ( នាំមកពោល ) ឲ្យ ពិស្តារផងចុះ ។

## មហាដីកា

ក្នុងពាក្យថា **យំ បន កិញ្ចិ** ( វត្ថុណានីមួយ ) នេះ បទថា **យំ** ជាពាក្យ ពោលដែលមិនកំណត់ពិតប្រាកដ ។ បទថា **កិញ្ចិ** ក៏យ៉ាងនោះ ដូចគ្នា ។ ស័ព្ទថា **បន** គ្រាន់តែជាគ្រឿងលម្អពាក្យពោល ។ ព្រោះដូច្នោះ ទើបលោកអាចារ្យធ្វើការ គ្របដណ្តប់វត្ថុដែលគួរដឹង មិនមានសល់ទុកដោយបទថា **យំ កិញ្ចិ** ម្យ៉ាងទៀត ស័ព្ទថា **បន** ជានិបាត ដែលសម្តែងអត្ថថា ផ្សេងគ្នា ( គឺ ឲ្យប្រែថា ចំណែក , ចំណែកថា ) ។ ព្រោះហេតុនោះ ដោយបទថា **សម្មាសម្ពុទ្ធោ** នេះ គឺ លោកពោល

ដល់ការត្រាស់ដឹងសច្ចៈ ៤ របស់ព្រះសាស្ដាដោយសង្ខេប និង ដោយពិស្ដារ ។ ចំណែកដោយបទថា **ពុទ្ធោ** នេះ គឺ លោកពោលដោយការត្រាស់ដឹងវត្ថុដែលគួរដឹង សូម្បីដទៃអំពីសច្ចៈ ៤ នោះ ។ មយ៉ាងទៀត ដោយបទដំបូង (**សម្មាសម្ពុទ្ធោ**) គឺ លោកពោលដល់អានុភាពនៃបដិវេធញ្ញាណ របស់ព្រះសាស្ដា ដោយបទក្រោយ ( **ពុទ្ធោ** ) គឺ លោកពោលដល់ដោយអានុភាពនៃទេសនាញាណ ។ ដោយស័ព្ទថា **ឫ** លោកប្រកាសដល់ការផ្សេងគ្នា ដែលនឹងពោលតទៅ ។ ព្រះអរហត្តមគ្គឈ្មោះថា **វិមោក្ខ** ព្រោះអត្ថថា រួចផុតអំពីធម៌ ដែលជាបដិបក្ខទាំងឡាយបានដោយអស់ជើង ។ ព្រះអរហត្តផល ឈ្មោះថា **ទីបំផុតនៃវិមោក្ខនោះ** ញាណមានក្នុងទីបំផុតនៃវិមោក្ខនោះ ឈ្មោះថា **វិមោក្ខន្តិកញ្ញាណ** ព្រោះនឹងគប្បីបាន ក៏ក្នុងកាលបានទីបំផុតនៃវិមោក្ខនោះហើយ បានដល់ ព្រះពុទ្ធញ្ញាណសូម្បីទាំងអស់ ព្រមទាំងសព្វញ្ញុតញ្ញាណ ។ ក្នុងពាក្យនេះថា **ដែលប្រព្រឹត្តទៅ** បានដល់ នៃព្រះបាលីគម្ពីរនិទ្ទេសនេះថា ៖

ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះទ្រង់ជាអ្នកដឹងវត្ថុទាំងពួង ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះទ្រង់ជាអ្នកឃើញវត្ថុទាំងពួង ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះទ្រង់មិនបានត្រូវអ្នកដទៃដឹកនាំ ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះទ្រង់ជាអ្នករីក ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះការរាប់ថា ទ្រង់ជាព្រះខីណាស្រព ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះការរាប់ថា ទ្រង់ជាអ្នកប្រាសចាកកិលេស ជាគ្រឿងធ្វើឲ្យសៅហ្មង ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះអត្ថថា ទ្រង់ជាអ្នកប្រាសចាករាគៈពិតប្រាកដ ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះអត្ថថា ទ្រង់ជាអ្នកប្រាសចាកទោសៈពិតប្រាកដ ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះអត្ថថា ទ្រង់ជាអ្នកប្រាសចាកមោហៈពិតប្រាកដ ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះអត្ថថា ទ្រង់ជាអ្នក

មិនមានកិលេសពិតប្រាកដ ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះអត្ថថា ទ្រង់យាងទៅកាន់មគ្គដែលជាផ្លូវតែមួយ ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះអត្ថថា ទ្រង់ជាបុគ្គលម្នាក់ឯងដែលត្រាស់ដឹងក្រៃលែងនូវសម្មាសម្ពោធិដ៏កំពូល ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះទ្រង់បានមកនូវពុទ្ធិ ( ការត្រាស់ដឹង ) ព្រោះទ្រង់កម្ចាត់ការមិនដឹងបានហើយ ។ ពាក្យ ពុទ្ធ នេះ មិនមែនឈ្មោះដែលមាតាតែងតាំង មិនមែនឈ្មោះដែលបិតាតែងតាំង មិនមែនឈ្មោះដែលបងប្អូនប្រុសតែងតាំង មិនមែនឈ្មោះដែលបងប្អូនស្រីតែងតាំង មិនមែនឈ្មោះដែលមិត្តជិតស្និទ្ធតែងតាំង មិនមែនឈ្មោះដែលពួកសាលោហិតតែងតាំង មិនមែនឈ្មោះដែលពួកសមណៈ និងព្រាហ្មណ៍តែងតាំង មិនមែនឈ្មោះដែលពួកទេវតាតែងតាំង តែថា ពុទ្ធ នេះ មានក្នុងទីបំផុតនៃវិមោក្ខ ជាសច្ឆិកាបញ្ញត្តិ ( ឈ្មោះដែលមានព្រោះការធ្វើឲ្យជាក់ច្បាស់ជាហេតុ ) ព្រមជាមួយនឹងការបានមកនូវសព្វញ្ញុតញ្ញាណត្រង់គល់ពោធិព្រឹក្ស នៃព្រះមានព្រះភាគជាម្ចាស់ទាំងឡាយ ។

ម្យ៉ាងទៀត ក្នុងសេចក្ដីនេះ ព្រោះហេតុដែលព្រះបាលីគម្ពីរនិទ្ទេស នោះមិនមានសេចក្ដីប្លែកគ្នានឹងព្រះបាលីគម្ពីរបដិសម្ភិទាមគ្គ ដូច្នោះ ដើម្បីសម្ដែងថា ក្នុងន័យនៃព្រះបាលីគម្ពីរទាំងពីរ សេចក្ដីសម្រេចប្រយោជន៍រមែងមានបាន សូម្បីដោយន័យនៃព្រះបាលីគម្ពីរមួយដូច្នេះ លោកអាចារ្យទើបពោលថា ស័ព្ទដែលមាន អត្ថថា មិនកំណត់ពិតប្រាកដថា **បដិសម្ភិទានយោ វា** ដូច្នេះ ។

ក្នុងពាក្យទាំងនោះ មានអធិប្បាយថា ប្រៀបដូចក្នុងផ្លូវលោក មនុស្សដែលចុះទៅ គេហៅថា **អវគតោ** យ៉ាងណា ក៏ថ្វាយព្រះនាមព្រះមានព្រះភាគ ដោយអំណាច ពាក្យពោលជាសុទ្ធកត្តុសាធនៈថា **ពុទ្ធ** ព្រោះអត្ថថា ទ្រង់ជាអ្នកត្រាស់ដឹងសច្ចៈទាំងឡាយ ដូច្នេះ ។ ប្រៀបដូចខ្យល់ដែលធ្វើស្លឹកឈើឲ្យហួតហែង ដែលគេ

ហៅថា **បណ្ណសុសា** យ៉ាងណា ក៏ថ្វាយព្រះនាមព្រះមានព្រះភាគដោយពាក្យពោល ជាហេតុកត្តុសាធនៈថា **ពុទ្ធ** ព្រោះអត្ថថា ទ្រង់ជាអ្នកប្រោសពពួកសត្វឲ្យត្រាស់ដឹង ដូច្នោះ លោកនាំអត្ថថា ហេតុទៅខាងក្នុង ក្នុងពាក្យថា **ពុទ្ធ** នេះ ។

ពាក្យថា **ទ្រង់ព្រះនាមថា ពុទ្ធ** ព្រោះទ្រង់ជាអ្នកដឹងវត្ថុទាំងពួង មានសេចក្តីថា ទ្រង់ព្រះនាមថា **ពុទ្ធ** ព្រោះទ្រង់មានការដឹង ដែលអាចដឹងធម៌ទាំងពួង ។ ពាក្យថា **ទ្រង់ព្រះនាមថា ពុទ្ធ** ព្រោះទ្រង់ជាអ្នកឃើញវត្ថុទាំងពួង មានសេចក្តីថា ទ្រង់ព្រះនាមថា **ពុទ្ធ** ព្រោះទ្រង់ឃើញធម៌ទាំងពួងដោយញាណចក្ខុ ។ ពាក្យថា **ទ្រង់ព្រះនាមថា ពុទ្ធ** ព្រោះទ្រង់មិនបានត្រូវអ្នកដទៃដឹកនាំ មានសេចក្តីថា ទ្រង់ព្រះនាមថា **ពុទ្ធ** ព្រោះត្រាស់ដឹងឯងនោះឯង មិនបានត្រូវអ្នកដទៃធ្វើឲ្យត្រាស់ដឹង ។ ពាក្យថា **ទ្រង់ព្រះនាមថា ពុទ្ធ** ព្រោះទ្រង់ជាអ្នករីក មានសេចក្តីថា ទ្រង់ព្រះនាមថា **ពុទ្ធ** ព្រោះអត្ថថា ទ្រង់រីកដូចផ្កាបទុម ព្រោះទ្រង់មានការរីកដោយព្រះគុណផ្សេងៗ ។ ដោយ ៦ បទ មានពាក្យថា **ទ្រង់ព្រះនាម ពុទ្ធ** ព្រោះការរាប់ថា ទ្រង់ជាព្រះខីណាស្រពយ៉ាងនេះជាដើម គឺ លោកអធិប្បាយថា ទ្រង់ព្រះនាមថា **ពុទ្ធ** ព្រោះទ្រង់ជាអ្នកភ្ញាក់ ព្រោះអស់កាពដេកលក់ គឺ កិលេសទាំងពួង ដូចបុរសដែលភ្ញាក់ ព្រោះអស់កាពងងុយដូច្នេះ ។ ពាក្យថា **ទ្រង់ព្រះនាមថា ពុទ្ធ** ព្រោះអត្ថថា ស្តេចយាងទៅដល់មគ្គដែលជាផ្លូវតែមួយ មានសេចក្តីថា ព្រោះសព្ទ ដែលមានអត្ថថា **ទៅ** រមែងបានអត្ថថា **ដឹង** សូម្បីសព្ទដែលមានអត្ថថា **ដឹង** ក៏រមែងបានអត្ថថា **ទៅ** ព្រោះហេតុនោះ ទើបមានន័យថា បណ្ឌិតថ្វាយព្រះនាមថា **ពុទ្ធ** ព្រោះភាវៈដែលស្តេចយាងទៅដល់មគ្គដែលជាផ្លូវតែមួយ ។ ពាក្យថា **ទ្រង់ព្រះនាមថា ពុទ្ធ** ព្រោះអត្ថថា ទ្រង់ជាបុគ្គលម្នាក់ឯង ដែលត្រាស់ដឹងក្រៃលែងនូវព្រះសម្មាសម្ពោធិ

ដ៏កំពូល មានសេចក្តីថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **ពុទ្ធ** ព្រោះត្រាស់ដឹងដោយសារអ្នកដទៃក៏ទេ តែថា ទ្រង់ព្រះនាមថា **ពុទ្ធ** ព្រោះត្រាស់ដឹងដោយប្រពៃក្រៃលែងនូវសម្មាសម្ពោធិដ៏កំពូលដោយព្រះអង្គឯង នោះឯង ។ ពាក្យថា **ទ្រង់ព្រះនាមថា ពុទ្ធ** ព្រោះទ្រង់បានមកនូវពុទ្ធិ ( ការដឹង ) ព្រោះទ្រង់កម្ចាត់ការមិនដឹងបានហើយ មានសេចក្តីថា ពាក្យថា **ពុទ្ធិ ពុទ្ធំ ពោធិ ពោធោ** មិនបានមានអត្ថដទៃ ( គឺ មានអត្ថតែមួយដូចគ្នា ) ។ ក្នុងបទទាំងនោះ លោកពោលទុកដើម្បីឲ្យជ្រាបថា **ទ្រង់ព្រះនាមថា ពុទ្ធ** ព្រោះទ្រង់ប្រកបដោយព្រះពុទ្ធគុណ ដូចសំពត់ដែលឈ្មោះថា សំពត់ក្រហម ព្រោះប្រកបដោយគុណ គឺ ពណ៌ក្រហមដូច្នោះ ។ តអំពីនោះទៅ បទថា **ពាក្យថា ពុទ្ធ** នេះ មិនមែនឈ្មោះដែលមាតាតែងតាំងជាដើម លោកពោលទុកដើម្បីឲ្យជ្រាបថា នេះជាបញ្ញត្តិដែលប្រព្រឹត្តទៅអនុលោមតាមសភាវៈ ទើបគប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **ពុទ្ធ** ព្រោះហេតុនេះ សូម្បីក្នុងបណ្តាហេតុទាំងឡាយទាំងពួង ក៏ដូចប្រការដែលបានពោលមក យ៉ាងនេះឯង ។

( ចប់ មហាដីកា )

## បទថា ភគវា

ចំណែកពាក្យថា **ភគវា** នេះ ជាពាក្យដែលហៅព្រះមានព្រះភាគជាម្ចាស់អង្គនោះ ដែលវិសេសដោយព្រះគុណ ( ទាំងឡាយ ) ដ៏ឧត្តមជាងសត្វទាំងឡាយ និងដែលជាគ្រូដោយសេចក្ដីគោរព ព្រោះហេតុនោះ លោកបោរាណាចារ្យទាំងឡាយ ទើបពោលទុកថា ៖

**ពាក្យថា ភគវា ជាពាក្យប្រសើរ ពាក្យថា ភគវា ជាពាក្យឧត្តម ព្រះមានព្រះភាគជាម្ចាស់អង្គនោះ ទ្រង់ជាគ្រូ ទ្រង់ប្រកបដោយគុណធម៌របស់គ្រូ ព្រោះហេតុនោះ អ្នកប្រាជ្ញទើបថ្វាយព្រះនាមថា ភគវា ។**

## នាម ៤ យ៉ាង

ន័យម្យ៉ាងទៀត ឈ្មោះមាន ៤ យ៉ាង គឺ **អាវត្ថិកនាម** ( ឈ្មោះដែលហៅតាមស្រុករ ) ( **អាវត្ថា** ប្រែថា វេលា សម័យក៏បាន ក្នុងទីនេះប្រែថា ស្រុករ ដើម្បីឲ្យស៊ីសេចក្ដីនឹងពាក្យខែរបស់លោកតទៅនោះ ) **លិង្គិកនាម** ( ឈ្មោះដែលហៅតាមភេទ គឺ គ្រឿងសម្គាល់ប្រចាំខ្លួន ) **នេមិត្តិកនាម** ( ឈ្មោះដែលមកតាមគុណដែលជានិមិត្ត ) **អធិច្ចសមុប្បន្ននាម** ( ឈ្មោះដែលគេតាំងឲ្យ ) មានពាក្យអធិប្បាយថា “ ឈ្មោះដែលតាំង តាមការប្រាថ្នា ដោយវោហាររបស់អ្នកស្រុក ឈ្មោះថា ការតាំងឲ្យ ” ។

ក្នុងឈ្មោះ ៤ យ៉ាងនោះ ឈ្មោះដូចជា **វច្ឆោ** ( កូនគោ ) **ទម្មោ** ( គោស្ទាវ ) **ពលិពទ្ទោ** ( គោប្រើ ) ដូច្នេះជាដើម ឈ្មោះថា **អាវត្ថិកនាម** ។ ឈ្មោះដូចជា **ទណ្ឌី** ( អ្នកកាន់ឈើច្រត់ - មនុស្សចាស់ ) **ឆត្តី** ( អ្នកមានឆត្រ = ព្រះ

រាជា ? ) **សិខី** ( សត្វមានសិរ = ក្ងោក ) **ករី** ( សត្វមានប្រមោយ = ដំរី ) ដូច្នេះជាដើម ឈ្មោះថា **លិង្គិកនាម** ។ ឈ្មោះដូចជា **តេវិជ្ជោ** ( អ្នកបានវិជ្ជា ៣ ) **ឆឡភិញ្ញោ** ( អ្នកបានអភិញ្ញា ៦ ) ដូច្នេះជាដើម ឈ្មោះថា **នេមិត្តិកនាម** ។ ឈ្មោះតាំងឲ្យ មិនត្រិះរិះដល់សេចក្ដីរបស់ពាក្យ ដូចជា **សិរិវឌ្ឍកោ** ( អ្នកចម្រើនដោយសិរី ) **ធនវឌ្ឍកោ** ( អ្នកចម្រើនដោយទ្រព្យ ) ដូច្នេះជាដើម ឈ្មោះ **អធិច្ចសមុប្បន្ននាម** ។

ចំណែកព្រះនាមថា **ភគវា** នេះ ជានេមិត្តិកនាម ព្រះនាងមហាមាយាមិនបានទ្រង់ថ្វាយឲ្យ ព្រះបាទសុទ្ធោទនមហារាជក៏មិនបានទ្រង់ថ្វាយឲ្យ ព្រះញាតិ ៨៤.០០០ ក៏មិនបានថ្វាយ ទេវតាដែលវិសេសទាំងឡាយ មានសក្កទេវរាជ និងស្ដេចសន្តុសិតជាដើម ក៏មិនបានប្រទានថ្វាយ ពិតណាស់ សេចក្ដីនេះ សូម្បីព្រះធម្មសេនាបតី ក៏បានពោលទុកថា ព្រះនាមថា **ភគវា** នោះ ព្រះមាតាមិនបានទ្រង់ថ្វាយឲ្យ ។ល។ ព្រះនាមនោះជា **វិមោក្ខន្តិកនាម** ( នាមដែលកើតក្នុងទីបំផុតនៃវិមោក្ខ ) កើតឡើងព្រមជាមួយនឹងការបានព្រះសព្វញ្ញុតញ្ញាណ ត្រង់គល់ពោធិព្រឹក្សនៃព្រះមានព្រះភាគជាម្ចាស់ទាំងឡាយ ព្រះនាមនោះជា **សច្ឆិកាបញ្ញត្តិ** ( តាំងឡើង ព្រោះដឹងច្បាស់នូវធម៌ជានិមិត្ត ) ព្រះនាមនេះគឺអ្វី ព្រះនាមនេះ គឺ **ភគវា** ដូច្នេះ ។

ក៏ឯព្រះនាមនោះ មានគុណឯណាជានិមិត្តដើម្បីប្រកាសគុណទាំងនោះ ព្រះសង្គីតិកាចារ្យ ទើបពោលជាគាថានេះទុកថា ៖

ព្រះមានព្រះភាគជាម្ចាស់អង្គនោះ ព្រះនាមថា **ភគវា** ព្រោះទ្រង់ជា ( ភគី ) អ្នកមានភគៈ ( គឺ ជោគ ) ព្រោះជា ( ភជី ) អ្នកសេព ( ទីស្ងាត់ ) ព្រោះជា ( ភាគី ) អ្នកមាន **ភាគ** ( គឺ មានចំណែក ) គួរបានទទួលនូវចតុប្បច្ច័យ ឬ មាន

ចំណែកនៃធម៌ ព្រោះជា ( **វិភត្តវា** ) អ្នកចែក ( ធម៌ ) ព្រោះទ្រង់បានធ្វើភគៈ ( គឺ ការកាច់បំបាក់កិលេសបាបធម៌ ) ព្រោះទ្រង់ជាគ្រូ ព្រោះទ្រង់មានភាគ្យ ( គឺ បុញ្ញបារមី ) ព្រោះទ្រង់ជា ( **សុភាវិតត្ត** អ្នកអប់រំខ្លួនល្អហើយ ដោយញាយធម៌ជាច្រើន ព្រោះជា ( **ភវន្តគ** ) អ្នកដល់ទីបំផុតនៃភព ។

ក៏ឯអធិប្បាយនៃបទនោះៗ ក្នុងព្រះគាថានោះ បណ្ឌិតគប្បីឃើញតាមន័យនៃព្រះបាលីដែលពោលក្នុងនិទ្ទេសនោះចុះ ចំណែកន័យ ( តទៅ ) នេះ ជាន័យម្យ៉ាងទៀត គឺ ៖

ព្រះមានព្រះភាគទ្រង់ជា ( **ភាគ្យវា** ) អ្នកមានភាគ្យ , ជា ( **ភគវា** ) អ្នកកាច់ និងជា ( **ភគេហិ យុត្តោ** ) អ្នកប្រកបដោយភគធម៌ទាំងឡាយ , ជា ( **វិភត្តវា** ) អ្នកដែលចែក , ជា ( **ភត្តវា** ) អ្នកគប់ ( **ភគ្គវា វិភត្តវា ភត្តវា** ៣ សព្ទនេះចុះ **ភវន្តុ** បច្ច័យកិរិយាកិតក៍ មិនមែន **វន្តុ** បច្ច័យតទធិត ) , ជា ( **ភវេសុ វន្តគមន** ) ទ្រង់មានដំណើរទៅកាន់ភពទាំងឡាយខ្ជាក់ចោលហើយ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ។

## អធិប្បាយ ភាគ្យវា

ក្នុងបទទាំងនោះ បណ្ឌិតគប្បីជ្រាបថា លោកកាន់យកនិរុត្តិលក្ខណៈ ( គឺ លក្ខណៈភាសាដែលនឹងបន្លឺចេញមក ឲ្យពីរោះស្តាប់ និង ស្រួលមាត់ផង ) មានលក្ខណៈថា “ **វណ្ណាគមោ វណ្ណវិបរិយាយោ** ចុះអក្សរថ្មី ផ្លាស់អក្សរ ” ជាដើម ឬកាន់យកលក្ខណៈ គឺ ការរួមចូលក្នុង **ជុត** សព្ទ មាន **បិសោទរ** សព្ទជាដើម ( គឺ ធ្វើដូច **បិសោទរ** សព្ទជាដើម ) តាមន័យនៃសទ្ទសាស្ត្រ កាលគួរនឹងហៅថា **ព្រះ**

*ភាគ្យវា ព្រោះព្រះអង្គទ្រង់មានព្រះភាគ្យ គឺ ព្រះបារមី មានទាន និងសីលជាដើម យ៉ាងកំពូល ដែលអាចញ៉ាំងសេចក្ដីសុខទាំងដែលជាលោកិយ ទាំងដែលជាលោកុត្តរ ឲ្យកើតបាន តែហៅថា ព្រះភគវា ។*

## អធិប្បាយ ភគ្គវា

*ម្យ៉ាងវិញទៀត ព្រោះហេតុដែល ព្រះអង្គបានកាច់បំបាក់ហើយនូវកិលេស ដែលធ្វើសេចក្ដីក្រវល់ក្រវាយ និងការក្ដៅក្រហាយ ( ដល់សត្វទាំងឡាយ ) ទាំងអស់ រាប់ដោយសែនប្រភេទ គឺ ប្រភេទលោភៈ ប្រភេទទោសៈ ប្រភេទមោហៈ ប្រភេទវិបរិតមនសិការ ( ការគិតខុសផ្លូវ ) ប្រភេទអហិរីនិងអនោត្តប្បៈ ប្រភេទក្រោធៈនិងឧបនាហៈ ប្រភេទមក្ខៈនិងបលាសៈ ប្រភេទឥស្សានិងមច្ឆរិយៈ ប្រភេទមាយានិងសាថេយ្យៈ ប្រភេទថម្ភៈនិងសារម្ភៈ ប្រភេទមានៈនិងអតិមានៈ ប្រភេទមទៈនិងបមាទៈ និង ប្រភេទតណ្ហានិងអវិជ្ជា ប្រភេទអកុសលមូល ៣ ប្រភេទទុច្ចរិត ៣ ប្រភេទសង្កិលេស ៣ ប្រភេទមលៈ ( មន្ទិល ៣ ) ប្រភេទវិសមៈ ( ការមិនស្ងប់ ) ៣ ប្រភេទសញ្ញា ៣ ប្រភេទវិតក្កៈ ៣ និង ប្រភេទបបញ្ចៈ ( គ្រឿងយឺតយូរ ) ៣ ប្រភេទវិបរិយេសៈ ( ការសម្គាល់ខុស ) ៤ ប្រភេទអាសវៈ ៤ ប្រភេទគន្ថៈ ( គ្រឿងចងរឹត ) ៤ ប្រភេទឱឃៈ ៤ ប្រភេទយោគៈ ៤ ប្រភេទអគតិ ៤ និង ប្រភេទតណ្ហុប្បាទៈ ( ទីកើតនៃតណ្ហា ) ៤ ប្រភេទចេតោខីលៈ ( គ្រឿងដោតចិត្ត ) ៥ ប្រភេទវិនិពន្ធៈ ( គ្រឿងចងចិត្ត ៥ ) ប្រភេទនីវរណៈ ៥ និង ប្រភេទអភិនន្ទនៈ ( គ្រឿងភ្លើតភ្លើន ) ៥ ប្រភេទវិវាទ-មូល ( មូលនៃការវិវាទ ) ៦ និងប្រភេទតណ្ហាកាយ ( ពពួកតណ្ហា ) ៦ ប្រភេទ*

អនុស័យ ៧ ប្រភេទមិច្ឆត្តៈ ៨ ប្រភេទតណ្ហាមូលកៈ ( ទោសមានតណ្ហាជាមូល ) ៩ ប្រភេទអកុសលកម្មបថ ១០ ប្រភេទទិដ្ឋិគតៈ ( ការយល់ឃើញ ) ៦២ ប្រភេទតណ្ហាវិចរិត ( ការនឹកទៅផ្សេងៗ ដោយអំណាចតណ្ហា ) ១០៨ ( ជាឧទាហរណ៍ ) ឬ ពោលដោយសង្ខេបនូវមារ ៥ គឺ កិលេសមារ ខន្ធមារ អភិសង្ខារមារ ទេវបុត្រមារ និងមច្ចុមារ ព្រោះហេតុនោះ កាលគួរនឹងហៅថា **ព្រះភគ្គវា** ព្រោះទ្រង់កាច់បំបាក់ ( កិលេសដែលធ្វើ ) អន្តរាយទាំងឡាយទាំងនោះចោលបាន តែហៅថា ព្រះភគវា ពិតណាស់ ក្នុងសេចក្ដីនេះ លោកពោលជាគាថាទុកថា ៖

ព្រះមានព្រះភាគជា ( **ភគ្គរាគោ** ) ទ្រង់ជាអ្នកកាច់បំបាក់រាគៈ ( **ភគ្គទោសោ** ) ទ្រង់ជាអ្នកកាច់បំបាក់ទោសៈ ( **ភគ្គមោហោ** ) ទ្រង់ជាអ្នកកាច់បំបាក់មោហៈ ទ្រង់ជាអ្នកមិនមានអាសវៈ បាបធម៌ទាំងឡាយ ព្រះអង្គទ្រង់កាច់បំបាក់អស់ហើយ ព្រោះហេតុនោះ បណ្ឌិតទើបថ្វាយព្រះនាមថា **ព្រះភគវា** ។

ក៏ឯការដល់ព្រមនៃព្រះរូបកាយរបស់ព្រះអង្គ ដែលទ្រទ្រង់ទុកនូវព្រះបុញ្ញលក្ខណៈ ( លក្ខណៈដែលកើតព្រោះបុណ្យ ) រាប់ដោយ ១០០ គឺ លោកសម្ដែងហើយព្រោះទ្រង់ជាអ្នកមានព្រះភាគ្យ ( គឺ បុញ្ញបារមី ) ការដល់ព្រមនៃព្រះធម្មកាយជាការសម្ដែងដោយភាពដែលទ្រង់ជា ( ភគ្គទោស ) អ្នកកាច់បំបាក់ទោស ភាពជាអ្នកដែលអ្នកស្រុក និងអ្នកស្និទ្ធស្នាលទាំងឡាយស្គាល់ច្រើនក្ដី ភាពជាអ្នកដែលគ្រហស្ថនិងបព្វជិតទាំងឡាយ គប្បីទៅមករកក្ដី ភាពជាអ្នកអាចក្នុងការជួយកម្ចាត់ទុក្ខកាយ ទុក្ខចិត្តឲ្យដល់ជនទាំងឡាយ ដែលទៅរកក្ដី ភាពជាអ្នកធ្វើឧបការៈដល់ជនទាំងនោះដោយអាមិសទាន និងធម្មទានក្ដី ភាពជាអ្នកអាចក្នុងការញ៉ាំងជន ឲ្យប្រកបព្រមទៅដោយ លោកិយសុខ និង លោកុត្តរសុខក្ដី គឺ លោកសម្ដែងហើយ

ដោយព្រះគុណសម្បត្តិ ២ យ៉ាងនោះ ។

# អធិប្បាយ ភគេហិ យុត្តោ

ម្យ៉ាងវិញទៀត ព្រោះហេតុដែលសត្វ ភគ ក្នុងលោក រមែងប្រព្រឹត្តទៅក្នុងធម៌ ៦ យ៉ាង គឺ ភាពជាធំ ( ឥស្សរិយៈ ) ធម្មៈ យស សិរី ការបានដូចប្រាថ្នា ( កាមៈ ) និង ការព្យាយាម ( បយត្ត ) ក៏ភាពជាធំក្នុងចិត្តរបស់ព្រះអង្គឯណា យ៉ាងកំពូលមានប្រាកដ ឬ ភាពជាធំដែលលោកសន្មតគ្នា ( ៨ យ៉ាង ) មានធ្វើរាងកាយឲ្យតូច ( អណិមា ) និងធ្វើរាងកាយឲ្យស្រាល ដើរលើអាកាសបាន ( លឃិមា ) ជាដើម ដែលបរិបូណ៌ដោយអាការទាំងពួងរបស់ព្រះអង្គក៏មានហើយ ដោយន័យដូចគ្នានោះ ព្រះធម៌ដែលជាលោកុត្តររបស់ព្រះអង្គក៏មានហើយ ព្រះយសរបស់ព្រះអង្គ ប្រាកដទូទៅពេញលោកទាំង ៣ ជាព្រះយសដែលទ្រង់បានដោយព្រះគុណតាមសេចក្ដីពិត ជាព្រះយសដែលបរិសុទ្ធក្រៃលែងក៏មានហើយ ព្រះសិរី ( ភាពស្រស់ស្អាត ) នៃព្រះអង្គាវយវៈធំតូចទាំងពួង បរិបូណ៌ដោយអាការគ្រប់យ៉ាង អាចឲ្យកើតការគាប់ភ្នែក គាប់ចិត្តដល់ជនដែលខ្នះខ្នែងក្នុងការគាល់សរសើរព្រះរូបកាយក៏មានហើយ ព្រោះការសំដៅដល់ការសម្រេចនៃប្រយោជន៍ ដែលទ្រង់ព្រះបំណងក៏មានហើយ ព្រោះប្រយោជន៍ណាៗ ដែលព្រះអង្គមានព្រះបំណងហើយ ទ្រង់ប្រាថ្នាហើយ ទោះជាប្រយោជន៍ខ្លួនក៏ដោយ ប្រយោជន៍អ្នកដទៃក៏ដោយ ប្រយោជន៍នោះៗ ក៏សម្រេចសមតាមព្រះបំណងទាំងអស់ និងព្រះបយត្តៈ ពោលគឺ **សម្មាវាយាមៈ** ដែលជាហេតុឲ្យកើតឡើងនៃភាពជាគ្រូរបស់លោកទាំងពួង ក៏មាន ព្រោះហេតុនោះ បណ្ឌិតទើបថ្វាយព្រះនាមថា **ភគវា** ដោយអត្ថនេះថា **ភគ្គាអស្ស សន្តិ**

ទ្រង់មានភគធម៌ ព្រោះទ្រង់ប្រកបដោយភគធម៌ទាំងឡាយ ( ដែលពោលមក ) នេះ ប្រការមួយ ។

## អធិប្បាយ វិភត្តវា

ម្យ៉ាងវិញទៀត ព្រោះហេតុដែលព្រះមានព្រះភាគជា **វិភត្តវា** មានពាក្យអធិប្បាយថា ទ្រង់ចែក ទ្រង់បើកផ្សារ ទ្រង់ប្រកាស នូវធម៌ទាំងពួងដោយប្រភេទទាំងឡាយ មានប្រភេទកុសលជាដើម ឬថា នូវធម៌ មានកុសលធម៌ជាដើម ដោយប្រភេទមានខន្ធ អាយតនៈ ធាតុ សច្ចៈ ឥន្ទ្រិយ និងបដិច្ចសមុប្បាទជាដើម ឬថា ៖

នូវ **អរិយសច្ច** គឺ **ទុក្ខ** ដោយអត្ថ ៤ យ៉ាង គឺ **បីឡន**-បៀតបៀន **សង្ខត**-ដែលបច្ច័យតាក់តែង **សន្តាប**-ដុតកោល **វិបរិណាម**-ប្រែប្រួល ។

នូវ **អរិយសច្ច** គឺ **សមុទយ** ដោយអត្ថ ៤ គឺ **អាយូហន**-ប្រមូលមកនូវទុក្ខ **និទាន**-ជាហេតុនៃទុក្ខ **សំយោគ**-ចងភ្ជាប់ជាមួយទុក្ខ **បលិពោធ**-ទាញទុកមិនឲ្យដល់មគ្គ ។

នូវ **អរិយសច្ច** គឺ **និរោធ** ដោយអត្ថ ៤ យ៉ាង គឺ **និស្សរណ**-ចេញចាកអំពីទុក្ខ **វិវេក**-ស្ងាត់ចាកទុក្ខ **អសង្ខត**-បច្ច័យមិនបានតាក់តែង **អមត**-មិនស្លាប់ ។

នូវ **អរិយសច្ច** គឺ **មគ្គ** ដោយអត្ថ ៤ យ៉ាង គឺ **និយ្យានិក**-នាំចេញចាកទុក្ខ **ហេតុ**-ជាហេតុនៃនិរោធ **ទស្សន**-ឃើញព្រះនិព្វាន **អធិបតេយ្យ**-ជាធំក្នុងការឃើញអរិយសច្ច ព្រោះហេតុនោះ គួរហៅថា **ព្រះវិភត្តវា** តែក៏ហៅថា **ព្រះភគវា** ។

## អធិប្បាយ ភត្តវា

*ម្យ៉ាងវិញទៀត ព្រោះហេតុដែលព្រះមានព្រះភាគអង្គនោះទ្រង់គប់ គឺ ទ្រង់សេព ទ្រង់ធ្វើឲ្យច្រើននូវធម៌ដែលជាទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ (* ***ទិព្វវិហារ*** *បានដល់ រូបាវចរជ្ឈាន ,* ***អរិយវិហារ*** *បានដល់ ផលសមាបត្តិ ) នូវកាយវិវេក ចិត្តវិវេក និងឧបធិវិវេក នូវសុញ្ញតវិមោក្ខ អប្បណិហិតវិមោក្ខ និងអនិមិត្តវិមោក្ខ និងឧត្តរិមនុស្សធម៌ ទាំងដែលជាលោកិយ និងលោកុត្តរដទៃៗ ព្រោះហេតុនោះ គួរនឹងហៅថា* ***ព្រះភត្តវា*** *តែក៏ហៅថា* ***ព្រះភគវា*** *។*

## អធិប្បាយ ភវេសុ វន្តគមន

*ម្យ៉ាងទៀត ព្រោះការទៅ ពោលគឺ តណ្ហាក្នុងភព ៣ ព្រះអង្គទ្រង់ខ្ជាក់ចោលហើយ ព្រោះហេតុនោះ គួរនឹងហៅថា* ***ភវេសុវន្តគមនោ*** *តែលោកកាន់យក* ***ភ*** *អក្សរពី* ***ភវ*** *ស័ព្ទ* ***គ*** *អក្សរពី* ***គមន*** *ស័ព្ទ និង* ***វ*** *អក្សរពី* ***វន្ត*** *ស័ព្ទ ធ្វើ (* ***វ*** *អក្សរ ) ឲ្យជាទីឃៈ ហៅថា* ***ព្រះភគវា*** *ដូចក្នុងផ្លូវលោក កាលគួរហៅ ( ឲ្យពេញ )* ***មេហនស្ស ខស្សមាលា*** *( មាលានៃឱកាសដែលជាទីកំបាំង ? ) តែអ្នកប្រាជ្ញកាន់យក* ***មេ*** *អំពី* ***មេហនស្ស*** *,* ***ខ*** *អំពី* ***ខស្ស*** *,* ***លា*** *អំពី* ***មាលា*** *ហៅថា* ***មេខលា*** *បោរាណាទើបប្រែ* ***មេខលា*** *ថា របៀបគ្រឿងប្រដាប់ ឱកាសដែលកំបាំង ដូច្នេះឯង ។*

## មហាដីកា

*បទថា* ***អស្ស*** *បានដល់ ព្រះមានព្រះភាគ ។ ពាក្យថា* ***ជាពាក្យហៅ ព្រះមានព្រះភាគអង្គនោះ ដែលវិសេសដោយគុណទាំងឡាយ ដែលជាគ្រូដ៏ឧត្តមជាងសត្វ***

**ទាំងឡាយ ដោយអំណាចការគោរព** មានសេចក្ដីថា ពាក្យថា **ភគវា** នេះ ជាពាក្យដែលហៅព្រះមានព្រះភាគ ដែលវិសេសដោយគុណ មានសីលគុណទាំងពួងជាដើម ព្រោះហេតុនោះឯង ទើបទ្រង់ជាគ្រូដ៏ឧត្ដមជាងសត្វទាំងពួង ដោយអំណាចការគោរព ។ ពិតយ៉ាងនោះ ព្រះអង្គទ្រង់ជាទីពឹងរបស់លោក ទ្រង់មានឋានៈគួរគោរពយ៉ាងក្រៃលែងរបស់សត្វទាំងឡាយ ដែលរកប្រមាណមិនបាន ក្នុងលោកធាតុទាំងឡាយ ដែលរកប្រមាណមិនបាន ព្រោះទ្រង់ជាអ្នកដល់ព្រមដោយគុណ-វិសេស មានសីលជាដើម ដែលមានអានុភាពរកប្រមាណមិនបាន ឧបមាមិនបាន និង ទ្រង់មានឧបការក្រៃពេកដល់ពពួកសត្វ ព្រមទាំងទេវតា និង មនុស្សដោយបយោគសម្បត្តិ ( ការដល់ព្រមនៃសេចក្ដីព្យាយាម ) ដ៏ក្រៃលែង ដែលផ្ដើមដោយការចៀសវាងវត្ថុដែលជាអនត្ថៈ ( សេចក្ដីវិនាស ) ទាំងពួង អ្នកប្រាជ្ញតែងតែចាត់ចែងប្រយោជន៍សុខ ទុកខាងមុខដោយមិនមានសេសសល់ ។ ពាក្យថា **ភគវា** ជាពាក្យប្រសើរ គឺ ជាពាក្យហៅបុគ្គលប្រសើរ អធិប្បាយថា ជាពាក្យ**ដែលប្រសើរ** ព្រោះសម្រេចព្រមជាមួយព្រះគុណដ៏ប្រសើរ ។ ន័យម្យ៉ាងទៀត អត្ថន័យឈ្មោះថា **វចនំ** ព្រោះអត្ថថា ត្រូវពោលដល់ , ព្រោះដូច្នោះ ទើបមានអត្ថន័យថា អត្ថន័យដែលគប្បីពោលដល់ដោយពាក្យថា **ភគវា** ឯណា អត្ថន័យនោះប្រសើរដូច្នេះ ។ សូម្បីក្នុងពាក្យថា **ភគវា** ជាពាក្យឧត្ដមនេះក៏មានន័យនេះឯងបទថា **គារវយុត្តោ** ប្រែថា ប្រកបដោយភាពជាគ្រូ គឺ ប្រកបដោយគុណនៃគ្រូ , ម្យ៉ាងទៀត ឈ្មោះថា **គារវយុត្តោ** ព្រោះអត្ថថា គួរល្អក្រៃលែង នូវការៈដែលធ្វើភាពជាគ្រូ ទើបមានអត្ថន័យថា **គារវារហោ** ។

លោកអាចារ្យដែលបំណាងចែកអត្ថន័យ ដែលពោលទុកដោយសង្ខេបថា ៖

ពាក្យថា **ភគវា** នេះ ជាព្រះនាមដែលព្រះមានព្រះភាគមានព្រះគុណវិសេសជាហេតុ ដូច្នេះដោយពិស្តារ កាលនឹងសម្ដែងព្រះនាមនោះឯង ដោយអំណាចការពង្រីកអត្ថមុន ទើបពោលថា ន័យម្យ៉ាងទៀត នាមមាន ៤ យ៉ាង ដូច្នេះជាដើម ។ ក្នុងនាមទាំង ៤ នោះ ពាក្យថា **អាវត្ថិកនាម** បានដល់ នាមដែលដឹងគ្នា ដោយគ្រឿងកំណត់ គឺនាមដែលគេអាស្រ័យគ្រឿងកំណត់នោះៗ បញ្ញត្តិហៅគ្នា ។ ឈ្មោះថា **លិង្គិកនាម** ក៏យ៉ាងនោះ បានដល់ នាមដែលហៅគ្នាដោយលិង្គៈ ( គ្រឿងសម្គាល់ ) នោះៗ ។ ពាក្យថា **នេមិត្តិកនាម** បានដល់ នាមដែលមកដោយនិមិត្ត ( គុណធម៌ជាហេតុ )។ ពាក្យថា **អធិច្ចសមុប្បន្ននាម** បានដល់ នាមដែលប្រព្រឹត្តទៅតាមប្រាថ្នា គឺ មកតាមការប្រាថ្នា តាំងសេចក្ដីប្រាថ្នា ។ ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) ស័ព្ទដំបូង ( ..... **ពលិពទ្ទោតិ ឯវមាទិ** ) សង្គ្រោះយកនាម មានយ៉ាងនេះថា **ពាលោ** ( ក្មេង ) **យុវា** ( មនុស្សកំលោះក្រមុំ ) **វុឌ្ឍោ** ( មនុស្សចាស់ ) ជាដើម ដោយ **អាទិ** ស័ព្ទទី ២ ( .... **ករីតិ ឯវមាទិ** ) សង្គ្រោះយកនាម យ៉ាងនេះថា **មុណ្ឌី** ( មនុស្សកំណោរ ប្រើហៅ មនុស្សក្បាលត្រងោល ) **ជដី** ( មនុស្សមានជដា ប្រើហៅ ឥសី ) ជាដើម ដោយ **អាទិ** ស័ព្ទទី ៣ (...**ធម្មវិញ្ញូតិ ឯវ-មាទិ** ) សង្គ្រោះយកនាម មានយ៉ាងនេះថា **ពហុស្សុតោ** ( អ្នកស្ដាប់ច្រើន ) **ធម្មកថិកោ** ( ព្រះធម្មកថិក ) **ឈាយី** ( អ្នកមានឈាន ) ជាដើម ដោយ **អាទិ** ស័ព្ទទី ៤ (... **ធនវឌ្ឍកោតិ ឯវមាទិ** ) សង្គ្រោះយកនាម មានយ៉ាងនេះថា **អយ-មរិសនំ បាវចនំ** ( ពាក្យសម្ដីដែលជាប្រធាន ដែលមានការសម្ដែងដល់ទុក្ខ ) ជាដើម ។ លោកអាចារ្យបំណងនឹងបញ្ជាក់អត្ថដែលបានពោលហើយថា ( ចំណែកព្រះនាមថា **ភគវា** នេះ ) ជា **នេមិត្តិកនាម** ដូច្នេះ ដោយអំណាចនៃពាក្យបដិសេធ

ទើបពោលថា មិនមែនព្រះនាមដែលព្រះនាងមហាមាយាទ្រង់តាំងឲ្យ ដូច្នេះជាដើម ។ ដោយពាក្យថា មានក្នុងទីបំផុតនៃវិមោក្ខនេះ លោកសម្តែងថា ព្រះនាមនេះកើតក្នុងខណៈដែលជាតិអរិយៈកើតនោះឯង ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ប្រសិនបើជាឈ្មោះដែលមានក្នុងទីបំផុតនៃវិមោក្ខសោត កាលបើដូច្នេះ ព្រោះហេតុអ្វីទើបជាឈ្មោះដែលមិនសាធារណៈដល់ព្រះខីណាស្រពដទៃៗ ផង ដូច្នេះ ទើបពោលថា ព្រមជាមួយការបាននូវព្រះសព្វញ្ញុតញ្ញាណ ដូច្នេះ ។ ពិតណាស់ ព្រះអរហត្តផល ( ដែលបានឈ្មោះថា ទីបំផុតនៃវិមោក្ខ ) របស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ កាលនឹងសម្រេច រមែងសម្រេចព្រមជាមួយព្រះពុទ្ធគុណទាំងពួង មានព្រះសព្វញ្ញុតញ្ញាណជាដើមនោះឯង ។ ព្រោះហេតុនោះ លោកទើបពោលថា ( ព្រះនាមថា **ភគវា** នេះ ) មានក្នុងទីបំផុតនៃវិមោក្ខ ដូច្នេះ ។ ពាក្យថា **ជាសច្ឆិកាបញ្ញត្តិ** គឺ ជាបញ្ញត្តិដែលមានការធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងពួងជាហេតុ ។ ន័យម្យ៉ាងទៀត ពាក្យថា **ជាសច្ឆិកាបញ្ញត្តិ** បានដល់ ជាបញ្ញត្តិដែលសម្រេចហើយដោយប្រចក្ស ។ ពិតណាស់ បញ្ញត្តិនោះ មានព្រះគុណពួកណាជាហេតុ ព្រះគុណទាំងនោះជាវត្ថុដែលព្រះសាស្តាទ្រង់ឃើញប្រចក្ស ព្រោះហេតុនោះ សូម្បីបញ្ញត្តិនោះ ក៏ឈ្មោះថា ទ្រង់ធ្វើឲ្យជាក់ច្បាស់ដូចគ្នានឹងគុណទាំងឡាយនោះឯង អធិប្បាយថា មិនមែនជាបញ្ញត្តិដោយគ្រាន់តែជាឈ្មោះដែលហៅសម្រាប់អ្នកដទៃ ។

លោកអាចារ្យពោលទុកដោយពាក្យ ដែលជាពហុវចនៈថា **វទន្តិ** ( ទើបពោល ) ព្រោះមានសេចក្តីគោរពចំពោះព្រះមហាថេរៈ ឬពោលសំដៅយកអនុវាទដែលព្រះសង្គីតិកាចារ្យទាំងឡាយបានតែងទុក ។ ឈ្មោះថា **ទ្រង់ជាភគ្គី** ព្រោះអត្ថថា ទ្រង់មានភគៈ ដែលមានប្រភេទជាព្រះឥស្សរិយៈជាដើម ។ ពាក្យថា **ទ្រង់បាន**

**ធ្វើកគ:** មានសេចក្ដីថា ទ្រង់បានធ្វើធម៌ដែលជាបាប មានរាគៈជាដើមឲ្យបាក់ខ្ទេច ទើបទ្រង់ព្រះនាមថា **ភគវា** ។ ពាក្យថា **ដោយញ៉ាយធម៌ទាំងឡាយដ៏ច្រើន** គឺ ដោយលំដាប់ការទៅ មានកាយការទៅជាដើមដ៏ច្រើន ពាក្យថា ជា **សុភាវិតត្តន** គឺ ជាអ្នកដែលមានខ្លួនបានអប់រំហើយជាសភាវៈ ដោយប្រពៃនោះឯង ។ ក៏ពាក្យថា **សុភា-វិតត្តនោ** នេះជាឆដ្ឋីវិភត្តិ ក្នុងអត្ថនៃបឋមាវិភត្តិ ។

ក្នុងពាក្យថា តាមន័យដែលលោកពោលទុកក្នុងគម្ពីរនិទ្ទេសនោះឯង តទៅនេះ ជាន័យក្នុងគម្ពីរនិទ្ទេសថា ៖

ពាក្យថា **ភគវា** នេះ ជាពាក្យហៅដោយអំណាចសេចក្ដីគោរព ។ ន័យម្យ៉ាងទៀត ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកកាច់បំបាក់រាគៈ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកកាច់បំបាក់ទោសៈ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកកាច់បំបាក់មោហៈ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកកាច់បំបាក់មានះ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកកាច់បំបាក់ទិដ្ឋិ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកកាច់បំបាក់នូវបន្ទា ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកកាច់បំបាក់កិលេស ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាភជិ គឺ បែងចែក រំលែកជាចំណែកៗ ចែកទៅដោយប្រការផ្សេងៗ នូវព្រះធម្មរតនៈ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ធ្វើទីបំផុតនៃភពទាំងឡាយ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកអប់រំកាយ អប់រំសីល អប់រំចិត្ត អប់រំបញ្ញា ។ ម្យ៉ាងវិញទៀត ព្រះមានព្រះភាគទ្រង់ជាភជិ គឺ អ្នកសេពសេនាសនៈដ៏ស្ងាត់ គឺ ព្រៃ ព្រៃស្តុក ដែលប្រាសចាកសំឡេងជជែកគ្នា ប្រាសចាកសំឡេងអឺងកង វៀរចាកជនសញ្ចរ ជាស្ថានទីលំនៅដែល

គេចចេញអំពីមនុស្សទាំងឡាយ សមគួរចំពោះការសម្រាក ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ។ ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ជា **ភាគី** គឺ អ្នកមានចំណែកនៃ ចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារ គឺ ថ្នាំដែលជាបច្ច័យ សម្រាប់អ្នកជំងឺ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ។ ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ជា **ភាគី** គឺ អ្នកមានការគប់រកជាប្រក្រតីនូវ អត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត អធិបញ្ញា ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ជាភាគី គឺ អ្នកមានការគប់រកជាប្រក្រតីជាមួយឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ជាភាគី គឺ អ្នកមានការគប់រកជាប្រក្រតីជាមួយវិមោក្ខ ៨ ( វិមោក្ខ ៨ ដែលបង្អោនទៅក្នុងអារម្មណ៍ ដែលទ្រង់បានត្រាស់ទុកដោយន័យថា អ្នកមានរូប រមែងឃើញរូបទាំងឡាយជាដើម ) អភិភាយតនៈ ៨ ( ឈាន ៨ ដែលគ្របសង្កត់អាយតនៈបានហើយ ) អនុបុព្វវិហារសមាបត្តិ ៩ ( សមាបត្តិដែលគប្បី ចូលតាមលំដាប់ ៩ យ៉ាង គឺ រូបជ្ឈាន ៤ អរូបជ្ឈាន ៤ និងនិរោធសមាបត្តិ ១ ) ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ជា **ភាគី** គឺ អ្នកមានការគប់រកជាប្រក្រតីជាមួយសញ្ញាភាវនា ១០ ( មានអនិច្ចសញ្ញាជាដើម ដែលមានមកហើយក្នុងគិរីមានន្ទសូត្រ ) កសិណសមាបត្តិ ១០ ( ឈានកសិណ ១០ មានបឋវីកសិណជាដើម ) អានាបានស្សតិសមាធិ អសុភសមាបត្តិ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ជា **ភាគី** គឺ អ្នកដែលមានការសេពជាប្រក្រតីនូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមាន

អដ្ឋ ៨ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ,ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ជា **ភាគី** គឺ អ្នកមានការគប់រកជាប្រក្រតីជាមួយកម្លាំងរបស់ព្រះតថាគត ១០ ( ព្រះញាណដែលជាកម្លាំងរបស់ព្រះតថាគត ១០ មានញាណដែលដឹងហេតុនិងមិនមែនហេតុជាដើម ) វេសារជ្ជ ៤ ( ភាពក្លាហាន ៤ ) បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ព្រះនាមថា **ភគវា** នេះ មិនមែនព្រះនាម ដែលព្រះជននីទ្រង់តាំង ។ល។ តែព្រះនាមថា **ភគវា** នេះ ។ល។ ជាសច្ឆិកាបញ្ញត្តិ ។ល។ នៃព្រះមានព្រះភាគសម្ពុទ្ធជាម្ចាស់ទាំងឡាយ ដូច្នេះ ។

ក៏ក្នុងគម្ពីរនិទ្ទេសនេះ ពាក្យថា **ជាពាក្យហៅដោយអំណាចសេចក្ដីគោរពជាដើម** លោកមិនបានសម្ដែងខែទៅតាមលំដាប់បទ ដែលមកហើយក្នុងគាថាក៏ពិត សូម្បីដូច្នោះ ក៏គប្បីជ្រាបបានតាមពាក្យទាំងនោះ សូម្បីគ្រប់ពាក្យមានក្នុងគម្ពីរនិទ្ទេសតាមសមគួរ ។ ក៏ក្នុងន័យគម្ពីរនិទ្ទេសនោះ ពាក្យថា **ជាពាក្យហៅដោយអំណាចសេចក្ដីគោរព** គឺជាពាក្យពោលដែលពោលដល់គ្រូទាំងឡាយដោយសេចក្ដីគោរព ។ បទថា **ភជិ** អ្នកបែងចែក គឺ ពោលដោយចំណែក ។ ព្រោះហេតុនោះ លោកទើបពោលថា **វិភជិ** ចែករំលែកជាចំណែក ៗ ដូច្នេះ ។ ពាក្យថា **នូវព្រះធម្មរតនៈ** គឺ នូវព្រះធម្មរតនៈរបស់ព្រះអរិយៈ មានមគ្គផលជាដើម ។ បទថា **ភជិ** មួយបទទៀតប្រែថា អ្នកសេព ។ បទថា **ភាគី** ប្រែថា អ្នកមានចំណែក ។ បទថា **ភាគី** មួយបទទៀត ប្រែថា ដែលមានការសេពរកជាប្រក្រតី ។ ពាក្យថា **អត្ថរស** បានដល់ រសដែលមានអត្ថជាទីពឹងអាស្រ័យ ។ ពិតណាស់ បុគ្គលកាលតាំងនៅក្នុងធម៌ ដែលមានវិមុត្តាយតនៈ ( អណ្ដូងកើតនៃការរួចផុត ) ជាប្រធាន

ហើយសម្ដែងធម៌ និង ស្ដាប់ធម៌ បីតិសោមនស្សដែលកើតឡើងប្រារព្ធអត្ថនោះ ឈ្មោះថា **អត្ថរស** , បីតិសោមនស្សដែលកើតឡើងប្រារព្ធធម៌ ឈ្មោះថា **ធម្មរស** , បានដល់ ពាក្យដែលទ្រង់សំដៅយកដោយត្រង់ទុកថា រមែងបានសេចក្ដីរីករាយក្នុងអត្ថ រមែងបានសេចក្ដីរីករាយក្នុងធម៌ដូច្នេះ ។ ពាក្យថា **វិមុត្តិរស** បានដល់ រសដែលជាវិមុត្តិ ឬ ជាទីពឹងអាស្រ័យនៃវិមុត្តិ ។ ពាក្យថា **សញ្ញាភាវនា** បានដល់ សញ្ញាភាវនា ១០ មានអនិច្ចសញ្ញាជាដើម ។ ពាក្យថា **ពុទ្ធធម៌ ៦** លោកពោលសំដៅយកព្រះញាណ ដែលមិនជាសាធារណៈ ( ដល់សាវក ) ៦ ព្រះញាណ ។ រូបសម្រេចនៃសព្ទថា **ភគវា** ក្នុងបទនោះៗ គប្បីជ្រាបតាមន័យនៃនិរុត្តិចុះ ។

**អត្ថ** ( របស់ពាក្យថា **ភគវា** ) ដែលលោកពោលទុកដោយបទថា **ភាគ្យវា** ជាដើម គឺ សង្គ្រោះហើយដោយគាថាសម្ដែងខែថា **ភគី ភជី** ជាដើមនោះឯង ក៏ពិតហើយ , សូម្បីយ៉ាងនោះ ន័យក្នុងសំវណ្ណនាដែលប្រកបដោយរូបសម្រេចនៃបទពាក្យចែកអត្ថ ពាក្យប្រកបអត្ថជាដើម ក៏ជាអាការមួយទៀតក្រៅពីអត្ថ ដែលសង្គ្រោះដោយគាថានោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ចំណែកតទៅនេះជាន័យមួយ ដូច្នេះ ។ ដោយ **អាទិ** សព្ទ ( ដែលប្រែថា ជាដើម ) ក្នុងបទថា **អាទិកំ** ( មានលក្ខណៈថា ជាដើម ) លោករួមយកលក្ខណៈ ( សូត្រ ) ៣ យ៉ាង គឺ **វណ្ណវិការោ** ( ធ្វើអក្សរឲ្យខុសប្លែកទៅ ) **វណ្ណលោបោ** ( លប់អក្សរ ) និង **ធាតុ អត្ថនិយោជនំ** ( ប្រកបទុកក្នុងអត្ថរបស់ធាតុ ) ។ ពាក្យថា **ដោយន័យនៃសទ្ទសាស្ត្រ** គឺ ដោយន័យនៃវេយ្យាករណ៍ ។ លោកអាចារ្យពោលថា កាន់យកលក្ខណៈដែលរួមទុកក្នុង **គណ** សព្ទ មាន **បិសោទរ** សព្ទជាដើម ដូច្នេះ ព្រោះសព្ទទាំងឡាយ មាន **បិសោទរ** សព្ទជាដើម មានមកជាគណៈ ។ ការរួមទុកនោះឯងជា

លក្ខណៈ ( ទើបឈ្មោះថា លក្ខណៈដែលរួមទុក ) ។ ក៏ការធ្វើភាពជាសត្តុ ដែលទាក់ទងក្នុង **គណា** សត្តុ មាន **បិសោទរ** សត្តុជាដើមនោះ ឈ្មោះថា ការរួមទុក ។ បទថា **បារប្បត្តំ** បានដល់ ភាពជាបារមីដ៏ឧត្តមក្រៃលែង ។ ពាក្យថា **ភាគ្យ** បានដល់ កុសល ។ ក្នុងកុសលទាំងនោះ មគ្គកុសល ជាកុសលដែលធ្វើលោកុត្តរសុខឲ្យកើតឡើង កុសលក្រៅអំពីនេះ ជាកុសលដែលធ្វើលោកិយសុខឲ្យកើតឡើង ម្យ៉ាងទៀត កុសលសូម្បីក្រៅអំពីនេះ ជាឧបនិស្ស័យនៃវិវដ្តៈ ក៏ជាកុសលដែលធ្វើលោកុត្តរសុខឲ្យកើតបានដោយបរិយាយ ។

ធម៌ទាំងឡាយ មានលោភៈជាដើម លោកកាន់យកដោយទាក់ទងតែម្យ៉ាង ( ជាប្រភេទលោភៈ ប្រភេទទោសៈ ... ) ដល់វិបរិតមនសិការ ក៏យ៉ាងនោះដូចគ្នា ដោយភាពជាវិបល្លាសដូចគ្នា ទាំងធម៌ទាំងឡាយ មានអហិរិកៈជាដើម លោកកាន់យកដោយទាក់ទងជាធម៌ពួកពីរ ( ប្រភេទអហិរិកៈ និង អនោត្តប្បៈជាដើម ) ។ ម្យ៉ាងវិញទៀត ធម៌ទាំងឡាយ មានលោភៈជាដើម លោកកាន់យកម្តងទៀត ដោយទាក់ទងជាមួយធម៌ពួក ៣ ថា អកុសលមូល ៣ យ៉ាង , ឈ្មោះថា ទុច្ចរិត ៣ យ៉ាងជាដើម គឺ ទុច្ចរិត ៣ មានកាយទុច្ចរិតជាដើម សង្កិលេស ៣ មានសង្កិលេស គឺ តណ្ហាជាដើម មន្ទិល ៣ មានមន្ទិល គឺ រាគៈជាដើម វិសមៈ ៣ មានវិសមៈ គឺ រាគៈជាដើម សញ្ញា ៣ មានកាមសញ្ញាជាដើម វិតក្ក ៣ មានកាមវិតក្កជាដើម បបញ្ចៈ ៣ មានបបញ្ចៈ គឺ តណ្ហាជាដើម ។ ធម៌ទាំងឡាយមានសុភសញ្ញាជាដើម ឈ្មោះថា **វិបរិយេស ៤ យ៉ាង** ។ **ការកើតនៃតណ្ហា ៤ យ៉ាង** មកហើយយ៉ាងនេះថា **តណ្ហា** កាលនឹងកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះចីវរជាហេតុខ្លះ , **តណ្ហា** កាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះបិណ្ឌបាតជាហេតុខ្លះ , **តណ្ហា** កាល

កើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះសេនាសនៈជាហេតុខ្លះ , **តណ្ហា** កាលនឹងកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះការគិតថា ការមិនមានរោគ រមែងមានបានព្រោះអាស្រ័យវត្ថុប្រណីត មានទឹកដោះថ្លាជាដើម ជាហេតុខ្លះ ។ **ចេតោខីល ៥ យ៉ាង** មកហើយយ៉ាងនេះថា រមែងសង្ស័យក្នុងព្រះពុទ្ធ រមែងសង្ស័យក្នុងព្រះធម៌ រមែងសង្ស័យក្នុងព្រះសង្ឃ រមែងសង្ស័យក្នុងសិក្ខា រមែងជាអ្នកក្រោធ មិនពេញចិត្ត មានចិត្តអាក់អន់ កើតភាពរឹងត្អឹងក្នុងមិត្តដែលប្រព្រឹត្តព្រហ្មចរិយធម៌ទាំងឡាយដូច្នេះ ។ **វិនិពន្ធ ៥ យ៉ាង** មកហើយយ៉ាងនេះថា រមែងជាអ្នកមិនប្រាសចាករាគៈក្នុងកាម មិនប្រាសចាករាគៈក្នុងកាយ មិនប្រាសចាករាគៈក្នុងរូប បរិភោគតាមតែដែលត្រូវការរហូតដល់ពេញពោះ ហើយប្រកបនូវសុខក្នុងការដេក សុខក្នុងការទម្រេត សុខក្នុងការដេកលក់ ប្រព្រឹត្តព្រហ្មចរិយៈ ប្រាថ្នាទេវនិកាយណាមួយ ។ **រូបាភិនន្ទនា** ( សេចក្តីត្រេកត្រអាលក្នុងរូប ) ជាដើម ឈ្មោះថា **អភិនន្ទនា ៥ យ៉ាង** ។ ឈ្មោះថា **វិវាទមូល ៦ យ៉ាង** ទាំងនេះ គឺ កោធៈ ( សេចក្តីក្រោធ ) មក្ខៈ ( ការលប់គុណគេ ) ឥស្សា ( ការច្រណែន ) សាថេយ្យ ( អំនួត ) បាបិច្ឆតា ( ការប្រាថ្នាលាមក ) សន្ទិដ្ឋិបរាមាសៈ ( ការប្រកាន់មាំតាមការយល់ឃើញរបស់ខ្លួន ) ដូច្នេះ ។ រូបតណ្ហាជាដើម ឈ្មោះថា **តណ្ហាកាយ ៦ យ៉ាង** ។ កាមរាគៈ បដិឃៈ ទិដ្ឋិ វិចិកិច្ឆា ភវរាគៈ មានៈ អវិជ្ជា ឈ្មោះថា **អនុស័យ ៧** ។ ធម៌ ៨ យ៉ាង មានមិច្ឆាទិដ្ឋិជាដើម ឈ្មោះថា **មិច្ឆត្ត ៨** ។ ឈ្មោះថា **ធម៌មានតណ្ហាជាមូល ៩ យ៉ាង** ទាំងនេះ គឺ អាស្រ័យតណ្ហា ក៏កើតការស្វែងរក អាស្រ័យការស្វែងរកក៏កើតការបាន អាស្រ័យការបានក៏កើតការវិនិច្ឆ័យ អាស្រ័យការវិនិច្ឆ័យក៏កើតឆន្ទរាគៈ អាស្រ័យឆន្ទរាគៈក៏កើតការប្រកាន់មាំ អាស្រ័យការប្រកាន់មាំក៏កើតការ

ហួងហែង អាស្រ័យការហួងហែងក៏កើតសេចក្តីកំណាញ់ អាស្រ័យសេចក្តីកំណាញ់ ក៏កើតការរក្សា ព្រោះការរក្សាជាហេតុ ក៏កើតការចាប់ដំបងជាដើមដូច្នេះ ។ ឈ្មោះថា ទិដ្ឋិ ៦២ ទាំងនេះ គឺ វាទៈថា ទៀង ៤ , វាទៈថា ទៀងដោយចំណែកខ្លះ ៤ វាទៈថា លោកមានទីបំផុតនិងមិនមានទីបំផុត ៤ , វាចាដោះស្រាយទៅបានផ្សេងៗ មិនឲ្យស្ងាប់ខ្ជួន ៤ , វាទៈថា អត្តានិងលោកកើតឡើងឯងៗ ២ , វាទៈថា មានសញ្ញា ១៦ , វាទៈថា មិនមានសញ្ញា ៨ , វាទៈ ថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ៨ , វាទៈថា ដាច់សូន្យ ៧ , វាទៈអះអាងព្រះនិព្វានក្នុងបច្ចុប្បន្ននេះយ៉ាងក្រៃលែង ៥ ដូច្នេះ ។ តណ្ហាវិចរិតអាស្រ័យខន្ធខាងក្នុង ១៨ គឺ តណ្ហាដែលប្រព្រឹត្តទៅថា យើងមាន ១ ដែលប្រព្រឹត្តទៅថា យើងកាលមានក៏ជាយ៉ាងនេះ ( គឺជាក្សត្រជាដើម ) ១ ដែលប្រព្រឹត្តទៅថា យើងដូចជាយ៉ាងនោះ ( គឺ ជាក្សត្រដូចគ្នានឹងគេជាដើម ) ១ ដែលប្រព្រឹត្តទៅថា យើងជាយ៉ាងដទៃ ( គឺ យើងអាក្រក់ជាង ឬល្អជាងជនទាំងឡាយនោះ ) ១ ដែលប្រព្រឹត្តទៅថា យើងនឹងមាន ១ ដែលប្រព្រឹត្តទៅថា យើងនឹងជាយ៉ាងនេះ ១ ដែលប្រព្រឹត្តទៅថា យើងនឹងដូចជាយ៉ាងនោះ ១ ដែលប្រព្រឹត្តទៅថា យើងនឹងជាយ៉ាងដទៃ ១ ដែលប្រព្រឹត្តទៅថា យើងទៀង ១ ដែលប្រព្រឹត្តទៅថា យើងមិនទៀង ១ ដែលប្រព្រឹត្តទៅថា យើងគួរនឹងមាន ១ ដែលប្រព្រឹត្តទៅថា យើងគួរនឹងជាយ៉ាងនេះ ១ ដែលប្រព្រឹត្តទៅថា យើងគួរនឹងដូចជាយ៉ាងនោះ ១ ដែលប្រព្រឹត្តទៅថា យើងគួរនឹងជាយ៉ាងដទៃ ១ ដែលប្រព្រឹត្តទៅថា យើងគប្បីកើតខ្លះ ១ ដែលប្រព្រឹត្តទៅថា យើងគប្បីកើតជាយ៉ាងនេះខ្លះ ១ ដែលប្រព្រឹត្តទៅថា យើងគប្បីដូចជាយ៉ាងនោះខ្លះ ១ ដែលប្រព្រឹត្ត ទៅថា យើងគប្បីជាយ៉ាងដទៃខ្លះ ១ ដូច្នេះ ។ តណ្ហាវិចរិត ១៨ អាស្រ័យខន្ធខាងក្រៅ

ក៏មានន័យដូចបានពោលហើយថា យើងមាននៅដោយខន្ធនេះ ១ យើងកាលមានក៏យ៉ាងនេះ ដោយរបស់នេះ គឺ ជាក្សត្រជាដើម ដោយឆត្រ ឬព្រះខ័នជាដើម ១ យើងដូចជាយ៉ាងនោះ ដោយរបស់នេះ ១ យើងជាយ៉ាងដទៃដោយរបស់នេះ ១ ដូច្នេះជាដើម ទើបរួមជាតណ្ហាវិចរិត៣៦ , ជាអតីត ៣៦ ជាអនាគត ៣៦ ជាបច្ចុប្បន្ន ៣៦ រួមជាតណ្ហា វិចរិត ១០៨ ។

សព្ទថា **បភេទ** ( ប្រភេទ គប្បីភ្ជាប់ចូលតែបទមួយ ) ។ តទៅនេះជាពាក្យប្រកបសេចក្តីក្នុងការភ្ជាប់ចូលតែមួយបទនោះ គឺ ៖

គប្បីភ្ជាប់ចូលដល់បទយ៉ាងនេះថា ប្រភេទលោភៈ ប្រភេទទោសៈ ទៅរហូតដល់ប្រភេទតណ្ហាវិចរិត ១០៨ យ៉ាង ។ ប្រកបសេចក្តីថា ព្រះមានព្រះភាគទ្រង់បានកាច់បំបាក់កិលេសទាំងពួង ដែលបង្កើតនូវភាពក្រវល់ក្រវាយ និង ភាពក្តៅក្រហាយដល់សត្វទាំងឡាយដូច្នេះ ។ តែពោលដោយការចែកដោយអារម្មណ៍ជាដើម និងដោយការចែកដោយអាការដែលប្រព្រឹត្តទៅ កិលេសក៏មានប្រភេទរកទីបំផុតមិនបាន ។ ក្នុងពាក្យថា **ដោយសង្ខេបនេះ** មានសេចក្តីថា ព្រះមានព្រះភាគទ្រង់បានកាច់បំបាក់ គឺ ទ្រង់បានធ្វើកិលេសមារឲ្យបាក់បែក ដោយទ្រង់ធ្វើមិនឲ្យប្រព្រឹត្តទៅដោយប្រការទាំងពួង ដោយអំណាចការលះជាសមុច្ឆេទ ទ្រង់បានកាច់បំបាក់ គឺ ទ្រង់បានធ្វើខន្ធមារឲ្យបាក់ខ្ទេច ដោយអំណាចការកំណត់ដឹង គឺ លះបង់សមុទយៈ , ទ្រង់បានកាច់បំបាក់ គឺ ទ្រង់បានធ្វើអភិសង្ខារមារឲ្យវិនាស ដោយទ្រង់ធ្វើមិនឲ្យប្រព្រឹត្តទៅ ដោយប្រការទាំងពួង ដោយអំណាចការធ្វើកិលេសដែលជាសម្ភារៈឲ្យវិនាសទៅ , ទ្រង់បានកាច់បំបាក់ គឺ ទ្រង់បានធ្វើទេវបុត្តមារ និងមច្ចុមារឲ្យវិនាសដោយអំណាចការញ៉ាំញីកម្លាំងពល និងការឈានកន្លងវិស័យចេញបាន ។

បទថា **បរិស្សយានំ** ប្រែថា អន្តរាយ ។ កិលេសនោះឯងជាមារ ដោយន័យថា ធ្វើឲ្យស្លាប់ មានន័យថា ធ្វើឲ្យក្តៅក្រហាយ ព្រោះជាហេតុនាំមកនូវការវិនាសដល់សត្វទាំងឡាយ ទាំងក្នុងបច្ចុប្បន្ន និងក្នុងអនាគត ព្រោះហេតុនោះ ទើបឈ្មោះថា កិលេសមារ ។ ខន្ធទាំងឡាយនោះឯងជាមារ ដោយន័យថា ជាពេជ្ឈឃាត ( អ្នកសម្លាប់ ) ព្រោះហេតុនោះ ទើបឈ្មោះថា ខន្ធមារ ។ ទ្រង់ត្រាស់ទុកពិតយ៉ាងនោះថា រមែងមិនដឹងច្បាស់ទៅតាមសេចក្តីពិតនូវរូបដែលជាពេជ្ឈឃាតថា រូបជាពេជ្ឈឃាត ដូច្នេះ ជាដើម ។ អភិសង្ខារនោះឯងជាមារ ដោយការធ្វើសេចក្តីវិនាសធំ មានជាតិជរាជាដើមឲ្យកើតឡើង ព្រោះហេតុនោះ ទើបឈ្មោះថា អភិសង្ខារមារ ។ ទេវបុត្តនោះឯងជាមារ ដោយន័យថា ជាហេតុនៃសង្កិលេស ហើយធ្វើគុណ គឺ សេចក្តីល្អឲ្យស្លាប់ ព្រោះហេតុនោះ ទើបឈ្មោះថា ទេវបុត្តមារ ។ សេចក្តីស្លាប់នោះឯងជាមារ ព្រោះដូចជាការឈឺធ្ងន់ ដោយធ្វើសេចក្តីវិនាសដល់ជីវិត និងបរិក្ខារនៃជីវិតរបស់សត្វទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា មច្ចុមារ ។

ពាក្យថា ***ដែលទ្រទ្រង់ទុកនូវព្រះលក្ខណៈដែលកើតឡើងព្រោះបុណ្យជារយភាគ*** គឺ ដែលរុងរឿងដោយមហាបុរិសលក្ខណៈ ដែលកើតឡើងព្រោះបុណ្យច្រើនរយ ឈ្មោះថា ជាការសម្តែងព្រះរូបកាយសម្បត្តិ ក៏ព្រោះភាពជាមូល ព្រោះភាពជាទីតាំងនៃផលសម្បទាទាំងឡាយក្រៅអំពីនេះ ( ព្រះរូបកាយសម្បទា ជាមូល និងជាទីតាំងនៃព្រះញាណសម្បទា បហានសម្បទា និងអានុភាវសម្បទា ) ឈ្មោះថា ជាការសម្តែងព្រះធម្មកាយសម្បត្តិ ក៏ព្រោះព្រះញាណសម្បទាជាដើម មានបហានសម្បទាជាខាងដើម ។ ប្រកបសេចក្តីថា ដោយភាពជាអ្នកមានព្រះភាគ្យ ជាការសម្តែងភាពជាអ្នកដែលលោកិយជន រាប់អានច្រើន ។ ព្រោះជាអ្នកទម្លាយនូវទោស

ជាការសម្ដែងភាពជាអ្នកដែលបុគ្គលមានបញ្ញារាប់អានជាច្រើន ។ សូម្បីក្នុងពាក្យដទៃៗក្រៅពីនេះ ក៏គប្បីប្រកបទៅតាមន័យនេះចុះ ។ ពិតណាស់ ពួកគ្រហស្ថទាំងឡាយ មានក្សត្រជាដើម រមែងគប់រកអ្នកមានបុណ្យ ពួកអ្នកមានបញ្ញាដែលជាបព្វជិត តាបស បរិព្វាជកជាដើម រមែងគប់រកលោកដែលលះបង់ទោសបានហើយ ដោយពាក្យថា ព្រះអង្គនឹងសម្ដែងធម៌ដើម្បីកម្ចាត់ទោស ដូច្នេះ ឈ្មោះថា នឹងសម្ដែងសមត្ថភាពក្នុងការកម្ចាត់ទុក្ខតាមផ្លូវកាយ និង ទុក្ខតាមផ្លូវចិត្តរបស់បុគ្គលដែលគប់រកព្រះអង្គទាំងអស់ ក៏ព្រោះទ្រង់មានព្រះឧបការៈ ដោយអាមិសទាន និង ធម្មទាន ( កម្ចាត់ទុក្ខតាមផ្លូវកាយដោយអាមិសទាន កម្ចាត់ទុក្ខតាមផ្លូវចិត្តដោយធម្មទាន ) ។ ឈ្មោះថា ជាការសម្ដែងភាពជាអ្នកមានឧបការៈ ដោយអាមិសទាន និង ធម្មទានដល់បុគ្គលដែលគប់រកព្រះអង្គទាំងអស់ ក៏ព្រោះការដែលជនទាំងនោះឃើញព្រះរូបកាយដោយបសាទចក្ខុ ឃើញព្រះធម្មកាយដោយបញ្ញាចក្ខុ ហើយរំងាប់ទុក្ខទាំងពីរបាន ឈ្មោះថា ជាការសម្ដែងសមត្ថភាព ក្នុងការឲ្យប្រកបដោយលោកិយសុខនិងលោកុត្តរសុខ ព្រោះទ្រង់ដឹកនាំបុគ្គល ដែលគប់រកព្រះអង្គឲ្យប្រកបក្នុងការបដិបត្តិប្រពៃយ៉ាងនេះ គឺ ភាពជាអ្នកលើសក្នុងលោកដោយអាមិសទាន និងធម្មទាននេះ តថាគតឃើញមុនហើយ ព្រោះដូច្នោះ សូម្បីពួកអ្នក ក៏គប្បីបដិបត្តិយ៉ាងនេះចុះ ដូច្នេះ ។

ឈ្មោះថា **ឥស្សរិយៈក្នុងព្រះទ័យរបស់ព្រះអង្គ** បានដល់ ការដែលទ្រង់ធ្វើចិត្តរបស់ព្រះអង្គឯងឲ្យដល់ភាពជាវសីបាន ដែលជាហេតុសម្រេចវិហារធម៌ មានភាពជាអ្នកសម្គាល់ក្នុងវត្ថុដែលជាបដិកូលជាដើមថា មិនជាបដិកូលជាដើម សូម្បីការសម្ដែងឫទ្ធិ មានអធិដ្ឋានឫទ្ធិជាដើម ក៏ឈ្មោះថា ព្រះឥស្សរិយៈក្នុងចិត្តដូចគ្នា ព្រោះ

ជាការសម្រេចនៃការនាចិត្តដែលដល់ភាពជាវសី ។ ដោយ **អាទិ** ស័ព្ទ ក្នុងពាក្យថា **អណិមាលឃិមាទិកំ** រួមយកឥស្សរិយៈ ៦ ទាំងនេះផង គឺ មហិមា ១ បត្តិ ១ បាកម្ម ១ ឦសិតា ១ វសិតា ១ យត្ថកាមាវសាយិតា ១ ។ ក្នុងឥស្សរិយៈទាំងនោះ ការធ្វើរាងកាយឲ្យតូច ឈ្មោះថា **អណិមា** ។ ការស្រាលនៃកាយ ឈ្មោះថា **លឃិមា** ព្រោះមានការប្រើជើងដើរទៅក្នុងអាកាសបានជាដើម ។ **ភាពធំ** ឈ្មោះថា **មហិមា** បានដល់ ការធ្វើរាងកាយឲ្យធំ ។ ការទៅដល់ប្រទេសតាមប្រាថ្នាបាន ឈ្មោះថា **បត្តិ** ។ ការធ្វើវត្ថុដែលត្រូវការ ឲ្យសម្រេចដោយអំណាចការអធិដ្ឋានជាដើម ឈ្មោះថា **បាកម្ម** ។ ភាវៈដែលខ្លួនឯង ជាអ្នកមានអំណាច គឺ ភាវៈដែលជាធំ ឈ្មោះថា **ឦសិតា** ។ ភាពជំនាញក្នុងការសម្ដែងឫទ្ធិ ឈ្មោះថា **វសិតា** ។ កាលទៅតាមផ្លូវអាកាសក្ដី កាលធ្វើកិច្ចឯណានីមួយក្ដី ការដល់នូវភាពសម្រេចហោះចុះបានក្នុងទីណាមួយ ឈ្មោះថា **យត្ថកាមាវសាយិតា** ។ អាចារ្យជាច្រើនពោលថា បានដល់ ការសម្ដែងរូបជាកុមារជាដើម ដូច្នេះក៏មាន ។ **ឥស្សរិយៈ ៨** យ៉ាងនេះ អ្នកស្រុកគេរាប់អាន ។ ក៏ឥស្សរិយៈរបស់ព្រះទសពលនោះ រួមចុះក្នុងឥទ្ធិវិធ ការសម្ដែងឫទ្ធិ និងមិនសាធារណៈដល់បុគ្គលដទៃ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ទ្រង់មាន ( ព្រះឥស្សរិយៈ ) ដែលបរិបូណ៌ដោយអាការទាំងពួង ដូច្នេះ ។

លោកអាចារ្យបំណាងសម្ដែងថា សម្រាប់បុគ្គលខ្លះ មានការប្រព្រឹត្តក្នុងទីខ្លះ និងមានយសមិនបរិសុទ្ធ ព្រោះអាស្រ័យគុណដែលមិនពិត តែសម្រាប់ព្រះតថាគតនឹងជាដូច្នោះក៏ទេ ដូច្នេះ ទើបពោលថា ( ទ្រង់មានព្រះយស ) ដែលផ្សាយទៅក្នុងលោកទាំង ៣ ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ព្រះយស រមែងជាការប្រាកដ

ដល់បុគ្គលដែលសម្រេចគុណរបស់ព្រះសាស្តាក្នុងលោកនេះ ទៅឧប្បត្តិក្នុងអរូប-លោក ហើយរឭកដល់គុណរបស់ព្រះមានព្រះភាគជារឿយៗ ដោយន័យថា **ឥតិបិ សោ ភគវា** ជាដើម ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ដែលផ្សាយទៅក្នុងលោកទាំង ៣ ដូច្នេះ ។ ឈ្មោះថា **បរិសុទ្ធហួសនឹងប្រៀបបាន** ព្រោះភាពដែលទ្រង់សម្រេចហើយដោយព្រះគុណទៅតាមសេចក្តីពិត ។ ឈ្មោះថា **ទ្រង់មានព្រះសិរីនៃអវយវៈតូចធំទាំងពួង** គឺ ទ្រង់មានភាពស្រស់ស្អាតនៃអវយវៈតូចធំទាំងពួងដោយបរិបូណ៌ដោយអាការទាំងពួង ព្រោះការដល់ព្រមនៃព្រះលក្ខណៈ និង អនុព្យញ្ជនៈជាដើម ដែលរកចំណែកសល់មិនបាន ។ ប្រយោជន៍តែម្យ៉ាង ឈ្មោះថា ព្រះអង្គជាទីពឹងរបស់លោកនេះ ទ្រង់បំណងយកហើយ ក៏ដោយអំណាចនៃមនោបណិធាន និងវចីបណិធាន ដោយន័យថា យើងឆ្លងបានហើយ នឹងគប្បីញុំាងសត្វទាំងឡាយឲ្យឆ្លងដូច្នេះជាដើម ឈ្មោះថា ទ្រង់ប្រាថ្នាហើយ ក៏ដោយអំណាចនៃកាយបណិធាន ។ ពាក្យថា **តាមដែលទ្រង់បំណងនោះឯង** គឺ តាមសមគួរដល់បណិធាននោះឯង ។ ព្រះបយត្តដែលដល់នូវភាពជាវីរិយបារមី និង ទាក់ទងក្នុងអរិយមគ្គ ឈ្មោះថា ព្រះបយត្ត ពោលគឺ សេចក្តីព្យាយាមត្រូវ ។

ពាក្យថា **ដោយប្រភេទទាំងឡាយ មានកុសលជាដើម** គឺ ដោយប្រភេទទាំងឡាយ ដែលសង្គ្រោះដោយតិកៈបទ ( បទដែលមានធម៌ពួក ៣ ) និងទុកៈបទ ( បទដែលមានធម៌ពួក ២ ) ទាំងពួង ។ ពាក្យថា **បដិច្ចសមុប្បាទជាដើម** ដោយ **អាទិ** ស័ព្ទដែលប្រែថា ជាដើម គប្បីជ្រាបថា មិនបានរួមយកធម៌ទាំងឡាយ មានសតិ-ប្បដ្ឋានជាដើម ដែលមកហើយក្នុងព្រះបាលីគម្ពីរវិភង្គតែម្យ៉ាងប៉ុណ្ណោះទេ តែថា រួមយកធម៌ មាន **សង្គហ** ( ធាតុសង្គហៈ ក្នុងធាតុកថា ) ជាដើម, រួមយកបុគ្គល មាន

***សមយវិមុត្តិ*** ( ក្នុងបុគ្គលប្បញ្ញត្តិ ) ជាដើម , រួមយកធម៌ មាន ***បឋម*** ( សមាធិ ) ជាដើម និងរួមយកធម៌ មានតិកប្បដ្ឋាន ( ក្នុងមហាបដ្ឋាន ) ជាដើម ។

***ទុក្ខសច្ច*** ឈ្មោះថា ***មានសភាវៈដែលបៀតបៀន*** គឺ មានការបៀតបៀនសត្វដែលដល់ព្រមដោយទុក្ខនោះ បានដល់ មានការធ្វើឲ្យលំបាក ។ ឈ្មោះថា ***មានសភាវៈដែលជាសង្ខត*** គឺ មានសភាពជាធម្មជាតិ ដែលបច្ច័យទាំងឡាយដល់ព្រមហើយ កើតព្រមហើយ សាងឡើង ។ ឈ្មោះថា ***មានសភាវៈដែលធ្វើឲ្យក្តៅក្រហាយ*** គឺ មានការធ្វើឲ្យក្តៅ បានដល់ ដុតរោលដោយភាពជាទុក្ខទុក្ខជាដើម ។ ឈ្មោះថា ***មានសភាពប្រែប្រួល*** គឺ មានភាពជាធម៌ ដែលគប្បីត្រូវធ្វើឲ្យប្រែប្រួលទៅ ដោយហេតុ ២ ប្រការ គឺ ដោយជរា និង ដោយមរណៈ ។

***សមុទយៈ*** ឈ្មោះថា ***មានសភាវៈ ប្រមូលមក*** គឺ មានការរួបរួមទុកដោយទាក់ទងនឹងការធ្វើទុក្ខឲ្យកើតឡើង ។ ឈ្មោះថា ***មានសភាវៈដែលប្រគល់ឲ្យ*** គឺ មានការធ្វើទុក្ខឲ្យតាំងឡើងដល់សត្វ ដូចប្រគល់ឲ្យទៅថា នេះគឺ ទុក្ខ ដូច្នេះ ។ ឈ្មោះថា ***មានសភាវៈដែលប្រកបទុក*** គឺ មានការប្រកបសត្វចូលទុកក្នុងសង្សារទុក្ខ ។ ឈ្មោះថា ***មានសភាវៈដែលជាគ្រឿងកង្វល់*** គឺ មានការរាំងចំពោះការសម្រេចមគ្គ ។

***និរោធ*** ឈ្មោះថា ***មានសភាវៈដែលរលាស់ចេញទៅ*** គឺ មានភាពជាធម៌ដែលរលាស់ចេញទៅ អំពីឧបធិនោះ ព្រោះមានសភាវៈ ព្រលែងនូវឧបធិទាំងពួង ឬថា បានដល់ មានសភាពជាហេតុនៃការរលាស់ចេញទៅអំពីឧបធិនោះ ។ ឈ្មោះថា ***មានសភាវៈដែលស្ងាត់*** គឺ មានសភាពជាធម៌ដែលចេញចាកសង្ខារទាំងពួង ។ ឈ្មោះថា ***មានសភាវៈដែលជាអសង្ខត*** គឺជាធម៌ដែលបច្ច័យណា ៗ ក៏មិនបាន

សានឡើង ។ ឈ្មោះថា **មានសភាវៈដែលជាអមតៈ** គឺ មិនមានការស្លាប់ ព្រោះជាសភាវៈដែលទៀង ឬ បានដល់ មានភាពជាហេតុ មិនមានការស្លាប់នៃសត្វទាំងឡាយ ។

**មគ្គ** ឈ្មោះថា **មានសភាវៈដែលនាំចេញទៅ** គឺ មានសភាវៈដែលចេញទៅចាកវដ្តទុក្ខ ។ ឈ្មោះថា **មានសភាវៈដែលជាហេតុ** គឺ មានភាពជាហេតុ ក្នុងការសម្រេចព្រះនិព្វាន ។ ឈ្មោះថា **មានសភាវៈដែលឃើញ** គឺ មានការធ្វើព្រះនិព្វានដ៏សុខុមឲ្យជាក់ច្បាស់ ។ ឈ្មោះថា **មានសភាវៈជាធំ** គឺ មានការធ្វើភាពជាធំក្នុងសម្បយុត្តធម៌ទាំងឡាយក្នុងការឃើញសច្ចៈ ៤ ឬ បានដល់ មានភាពជាអារម្មណាធិបតី ដោយពិសេសតាមពាក្យដែលថា មគ្គាធិបតិ ( អធិបតី គឺ មគ្គ ) ។ ក៏ធម៌ទាំងឡាយ មានឈានជាដើម សូម្បីកាលមានភាពជាអារម្មណាធិបតី ក៏មិនបាន ត្រាស់ទុកយ៉ាងនេះថា **ឈានាធិបតិនោ ធម្មា** ធម៌ដែលជាអធិបតី គឺ ឈានដូច្នេះជាដើម ត្រឡប់ជាត្រាស់ថា **មគ្គាធិបតិនោ ធម្មា** ធម៌ដែលជាអធិបតី គឺ មគ្គដូច្នេះ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបបានថា មគ្គមានភាពពិសេស ព្រោះភាពជាអារម្មណាធិបតី ដូច្នេះ ។ ក៏សភាវៈដែលបៀតបៀនជាដើមទាំងនេះ ឈ្មោះថា អាការ ១៦ ។ សួរថា ក៏ក្នុងបណ្តាអាការទាំងនោះ អាការដទៃ មានអាការដែលជារោគ ជាបូស ជាដើមមានហើយ ព្រោះហេតុអ្វី លោកទើបកំណត់យកចំពោះអាការ ១៦ នេះប៉ុណ្ណោះ ? ឆ្លើយថា លោកកំណត់យកចំពោះអាការ ១៦ នេះប៉ុណ្ណោះ ព្រោះជាការបើកផ្សារដោយលក្ខណៈរបស់ខ្លួន ( នៃសច្ចៈមួយ ៗ ) និងដោយការសម្តែងលំដាប់សច្ចៈ ។ អធិប្បាយនេះនឹងមានច្បាស់ក្នុងសច្ចកថាខាងមុខនោះឯង ។

ឈ្មោះថា **ទិព្វវិហារ** បានដល់ រូបាវចរជ្ឈានទាំងឡាយ ដែលមានកសិណជាដើមជាអារម្មណ៍ ។ ឈាន ៤ មានមេត្តាជាដើម ឈ្មោះថា **ព្រហ្មវិហារ** ។ ផលសមាបត្តិ ឈ្មោះថា **អរិយវិហារ** ។ ភាពជាអ្នកនៅម្នាក់ឯង ដោយទាក់ទងនឹងការមានកាយតាំងនៅក្នុងភាពស្ងាត់ចាកកាមទាំងឡាយ ឈ្មោះថា **កាយវិវេក** ។ ភាពជាអ្នកមានចិត្តស្ងាត់ចាកនីវរណធម៌ជាដើម ដោយបឋមជ្ឈានជាដើម ឈ្មោះថា **ចិត្តវិវេក** ។ ឈ្មោះថា **ឧបធិវិវេក** បានដល់ ព្រះនិព្វាន ។ ពាក្យថា **ឧត្តរិមនុស្សធម៌ដទៃៗ** គឺ ឧត្តរិមនុស្សធម៌ទាំងឡាយ មានលោកិយអភិញ្ញាជាដើម ។

ការវិលវល់ទៅក្នុងភពទាំងឡាយ រមែងមានបានដោយអំណាចនៃកិលេស និងអភិសង្ខារ ក៏សភាវៈនោះ មានតណ្ហាជាប្រធាន ព្រោះហេតុនោះ ទើបលោកពោលថា ការទៅ ពោលគឺ តណ្ហា ដូច្នេះ ។ ពាក្យថា **ទ្រង់ខ្ជាក់ចោលបានហើយ** បានដល់ ទ្រង់ប្រើព្រះឱស្ឋ គឺ អរិយមគ្គ ខ្ជាក់ចោលបាន ដោយអំណាចការមិនវិលត្រឡប់មកទៀត ។ លោកអាចារ្យកាលនឹងសម្ដែងថា ពាក្យថា **ភគវា** ហៅតាមន័យនិរុត្តិដូច្នេះ ទើបពោលថា ដូចជាក្នុងលោក ។ ល ។ ក៏ត្រឡប់ហៅថា មេខលាវិញ ដូច្នេះ ។

ន័យម្យ៉ាងទៀត **ភាគវាតិ ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកមានចំណែកនៃគុណ **ភតវាតិ ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកមានធម៌ដែលបម្រុងទុកហើយ **ភាគេ វនីតិ ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់គប់រកចំណែកនៃធម៌ **ភគេ វនីតិ ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់គប់រក **ភគ** ( ធម្មសម្បត្តិ ) **ភត្តវាតិ ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានជនដែលភក្ដី **ភគេ វមីតិ ភគវា** ទ្រង់ព្រះនាមថា **ភគវា**

ព្រោះអត្ថថា ទ្រង់ខ្ជាក់ចោលនូវ ភគ ( ទ្រព្យសម្បត្តិ ) **ភាគេ វមីតិ ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ខ្ជាក់ចោលនូវ ភគ ( ចំណែកនៃសភាវធម៌ ) ។

ព្រះជិនស្រីជាម្ចាស់ទ្រង់ព្រះនាមថា ភគវា ព្រោះអត្ថថា ទ្រង់ជាអ្នកមានចំណែកនៃគុណ ទ្រង់ជាអ្នកមានធម៌ដែលរក្សាទុកហើយ ទ្រង់គប់រកចំណែកនៃធម៌ និងធម្មសម្បត្តិទាំងឡាយ ទ្រង់មានជនដែលភក្តី ទ្រង់ខ្ជាក់ចោលនូវទ្រព្យសម្បត្តិ ម្យ៉ាងវិញទៀត ទ្រង់ខ្ជាក់ចោលចំណែកនៃសភាវធម៌ ។

ក្នុងអត្ថទាំងនោះ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកមានចំណែកនៃគុណដូចម្តេច ? គំនរធម៌ទាំងឡាយ គឺ ចំណែកនៃគុណទាំងឡាយ មានសីលជាដើមទាំងនោះឯង ព្រះតថាគតទ្រង់មាន ទ្រង់បានចំណែកនៃគុណដែលមិនសាធារណៈដល់អ្នកដទៃ ដែលគុណរបស់អ្នកដទៃមិនល្អប្រសើរជាងគុណទាំងនោះ ។ ពិតយ៉ាងនោះ ព្រះតថាគតនេះ ទ្រង់មាន ទ្រង់បានចំណែកនៃធម៌ ពពួកនៃគុណដែលមិនសាធារណៈដល់អ្នកដទៃ ដែលគុណរបស់អ្នកដទៃមិនក្រៃលែងជាង ដែលមានប្រមាណ និងប្រភេទរកទីបំផុតមិនបាន យ៉ាងនេះគឺ សីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ, ហិរិ-ឱត្តប្បៈ សទ្ធា-វិរិយៈ សតិ-សម្បជញ្ញៈ សីលវិសុទ្ធិ-ទិដ្ឋិវិសុទ្ធិ សមថៈ-វិបស្សនា , កុសលមូល ៣ សុចរិត ៣ សម្មាវិតក្ក ៣ អនវជ្ជសញ្ញា ( សេចក្តីសម្គាល់ថា រកទោសមិនបាន ) ៣ ធាតុ ៣ , សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ អរិយមគ្គ ៤ អរិយផល ៤ បដិសម្ភិទា ៤ យោនិបរិច្ឆេទកញ្ញាណ ( ញាណកំណត់ឧបាយ ) ៤ អរិយវង្ស ៤ វេសារជ្ជញ្ញាណ ( សេចក្តីដឹងជាហេតុនៃការក្លៀវក្លា ) ៤ , អង្គនៃសេចក្តីព្យាយាម ៥ សម្មាសមាធិ

មានអង្គ ៥ សម្មាសមាធិមានញាណ ៥ ឥន្ទ្រិយ ៥ ពលៈ ៥ និស្សារណីយធាតុ ៥ ញាណក្នុងវិមុត្តាយតនៈ ៥ , សញ្ញាបន្ទុំវិមុត្តិ ៦ អនុស្សតិដ្ឋាន ៦ គារវធម៌ ៦ និស្សារណីយធាតុ ៦ វិហារគ្រឿងនៅប្រចាំ ៦ អនុត្តរិយៈ ៦ និព្វេធភាគិយសញ្ញា ៦ អភិញ្ញា ៦ ញាណដែលមិនជាសាធារណៈ ៦ , អបរិហានីយធម៌ ៧ អរិយធម៌ ៧ អរិយទ្រព្យ ៧ ពោជ្ឈង្គ ៧ សប្បុរិសធម៌ ៧ និជ្ជរវត្ថុ ៧ សញ្ញា ៧ ទេសនាទក្ខិណេយ្យបុគ្គល ៧ ទេសនាវិញ្ញាណដ្ឋិតិ ៧ ទេសនាកម្លាំងព្រះខីណាស្រព ៧ , ទេសនាហេតុនៃការបានមកនូវបញ្ញា ៨ សម្មត្តធម៌ ៨ ការឈានកន្លងលោកធម៌ ៨ អារម្ភវត្ថុ ៨ អក្ខណទេសនា ៨ មហាបុរិសវិតក្កៈ ៨ ទេសនាអភិភាយតនៈ ៨ វិមោក្ខ ៨ , ធម៌ដែលមានយោនិសោមនសិការជាមូល ៩ អង្គនៃសេចក្តីព្យាយាមបរិសុទ្ធ ៩ ទេសនាសត្តាវាស ៩ ធម៌ជាគ្រឿងកម្ចាត់សេចក្តីអាឃាត ៩ សញ្ញា ៩ នានត្ត ( សភាវៈដែលប្លែកផ្សេងគ្នានៃធម៌ ) ៩ អនុបុព្វវិហារ ៩ , ធម៌ជាគ្រឿងធ្វើទីពឹង ១០ កសិណាយតនៈ ១០ កុសលកម្មបថ ១០ សម្មត្តធម៌ ១០ អរិយវាស ១០ អសេក្ខធម៌ ១០ កម្លាំងរបស់ព្រះតថាគត ១០ , អានិសង្សមេត្តា ១១ អាការនៃធម្មចក្រ ១២ ធុតង្គគុណ ១៣ ព្រះពុទ្ធញាណ ១៤ ធម៌បន្ទុំវិមុត្តិ ១៥ អានាបានស្សតិ ១៦ អាការ អបរន្តបនីយធម៌ ១៦ ពុទ្ធធម៌ ១៨ បច្ចវេក្ខណញាណ ១៩ ញាណវត្ថុ ៤៤ ឧទយព្វយញ្ញាណ ៥០ កុសលធម៌ ៥០ ជាង ញាណវត្ថុ ៧៧ មហាវជិរញ្ញាណដែលសញ្ចរទៅក្នុងសមាបត្តិ ២ លាន ៤ សែនកោដិ ញាណដែលវិនិច្ឆ័យពិចារណា និងទេសនាសម្មន្តបដ្ឋានអនន្តន័យម្យ៉ាងទៀត និងញាណដែលបើកផ្សារអធ្យាស្រ័យជាដើមនៃសត្វទាំងឡាយ ដែលរកទីបំផុតមិនបាន ក្នុងលោកធាតុដែលរកទីបំផុតមិនបានដូច្នេះជាដើម ។ ព្រោះដូច្នោះ កាលគួរនឹងពោលថា

ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានចំណែកនៃធម៌ គឺ ចំណែកនៃគុណ តាមដែលពោលហើយនោះ លោកក៏ធ្វើ **អា** អក្សរឲ្យជា រស្សៈ ហើយពោលថា **ភគវា** ព្រះអង្គសូម្បីជា **ភាគវា** ( អ្នកមានចំណែកនៃគុណ ) ទើបទ្រង់ព្រះនាមថា **ភគវា** តាមប្រការដែលពោលមកនេះ ។

*ព្រោះហេតុ ជាចំណែកនៃគុណទាំងពួង មានសីលជាដើម មាននៅក្នុងព្រះសុគតជាម្ចាស់ ដោយមិនមានសេសសល់ដូច្នេះ បណ្ឌិតទើបថ្វាយព្រះនាមព្រះអង្គថា ភគវា ។*

ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជាអ្នកមានធម៌ដែលរក្សាទុកហើយដូចម្ដេច ? បារមី ១០ គឺ ទានបារមី ១ សីលបារមី ១ នេក្ខម្មបារមី ១ បញ្ញាបារមី ១ វីរិយបារមី ១ ខន្តិបារមី ១ សច្ចបារមី ១ អធិដ្ឋានបារមី ១ មេត្តាបារមី ១ ឧបេក្ខាបារមី ១ ដូច្នេះ ឧបបារមី ១០ បរមត្ថបារមី ១០ រួមជាបារមីចំនួន ៣០ សង្គហវត្ថុ ៤ មានទានជាដើម អធិដ្ឋាន ៤ មានសច្ចាធិដ្ឋានជាដើម ការបរិច្ចាគខ្លួន មហាបរិច្ចាគ ៥ គឺ បរិច្ចាគកែវភ្នែក ១ បរិច្ចាគទ្រព្យ ១ បរិច្ចាគរាជសម្បត្តិ ១ បរិច្ចាគបុត្រ ១ បរិច្ចាគភរិយា ១ ឬ ដោយសង្ខេបបានដល់ធម៌ដែលសាងភាពជាព្រះពុទ្ធជាម្ចាស់ ដែលជាសម្ភារៈនៃបុណ្យ និងសម្ភារៈនៃញាណទាំងពួងយ៉ាងនេះ គឺ បុព្វយោគ ( ការបំពេញសមថៈនិងវិបស្សនាក្នុងកាលមុនៗ ) បុព្វចរិយា ( ការប្រព្រឹត្តល្អក្នុងកាលមុន ៗ ) ធម្មក្ខាន ( ការពោលប្រាប់ធម៌ ) ញាតត្ថចរិយា ( ការបំពេញប្រយោជន៍ដល់ញាតិ ) លោកត្ថចរិយា ( ការបំពេញប្រយោជន៍ដល់លោក ) ពុទ្ធត្ថចរិយា ( ការបំពេញប្រយោជន៍ដល់ភាពជាព្រះពុទ្ធ ) ដូច្នេះជាដើម ដែលជាព្រះមហាពោធិសត្វ ដែលដល់ព្រមដោយការខ្នះខ្នែង ដើម្បី

ប្រយោជន៍ដល់លោកទាំងពួង ដែលបានប្រមូលធម៌ ៨ យ៉ាង មានភាពជាមនុស្ស ជាដើម សាងអភិនីហារដ៏ធំក្រៃលែង ដើម្បីព្រះសម្មាសម្ពោធិញ្ញាណ គប្បីធ្វើឲ្យពេញ បរិបូរណ៍ ។ ធម៌ទាំងនោះដែលព្រះអង្គរក្សាទុកហើយ រក្សាទុកល្អហើយ ដោយ គោរពជាប់ជានិច្ច មិនមានសល់ រហូត ៤ អសង្ខេយ្យ និងមួយសែនកប្ប រាប់ តាំងអំពីកាលអភិនីហារដ៏ធំក្រៃលែង ដោយប្រការដែលមិនជាហានភាគិយៈ ( គឺ មិនមានចំណែកនៃការវិនាស ) មិនជាសង្កិលេសភាគិយៈ ( គឺ មិនមានចំណែកនៃ ការសៅហ្មង ) មិនជាឋិតិភាគិយៈ ( គឺ មិនមានចំណែកនៃការនៅនឹង ) តែជា ជាវិសេសភាគិយៈ ( គឺ មានចំណែកនៃគុណវិសេស ) ក្រៃលែងៗ ឡើងទៅតែ ម្យ៉ាង រមែងមានដល់ព្រះអង្គ ព្រោះហេតុនោះ កាលគួរនឹងថ្វាយព្រះនាមថា **ភគវា** ក៏បែរជាថ្វាយព្រះនាមថា **ភគវា** ព្រោះធ្វើ ត អក្សរឲ្យជា គ អក្សរ ដោយន័យនៃ និរុត្តិ ។ ន័យម្យ៉ាងទៀត បទថា **ភគវា** មានន័យថា ទ្រង់បានរក្សា រក្សាល្អហើយ គឺ ធ្វើឲ្យបរិបូណ៌នូវធម៌ដែលសាងភាពជាព្រះពុទ្ធ តាមដែលពោលហើយទាំងនោះ ឯង តាមន័យដែលពោលហើយ ។ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ជា អ្នកមានធម៌ដែលរក្សាទុកហើយ តាមប្រការដែលពោលមកនេះ ។

*ព្រះមានព្រះភាគជាទីពឹងរបស់លោក ជាអ្នកមានធម៌ ដែលរក្សាទុកហើយ ក្នុងធម៌ដែលជាសម្ភារៈនៃព្រះសម្មាសម្ពោធិញ្ញាណទាំងពួង មានទានបារមីជាដើម ព្រោះហេតុនោះ បណ្ឌិតទើបថ្វាយព្រះនាមព្រះអង្គថា ភគវា ។*

ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់គប់រកចំណែកនៃធម៌ដូចម្តេច ? ចំណែកនៃសមាបត្តិដែលទ្រង់ប្រើប្រាស់រាល់ថ្ងៃ រាប់បាន ២ លាន ៤ សែនកោដិ នុ៎ះឯង ព្រះអង្គទ្រង់គប់រក គឺ ទ្រង់ប្រើប្រាស់ ទ្រង់សេព ទ្រង់ធ្វើឲ្យច្រើនហើយនូវ

ចំណែកនៃសមាបត្តិទាំងនោះ ដោយមិនមានសល់ អស់កប្បជានិច្ច ដើម្បីប្រយោជន៍ដល់សត្វលោក និង ដើម្បីប្រយោជន៍ដល់ការនៅជាសុខក្នុងទិដ្ឋធម៌ ( ក្នុងអត្តភាពនេះ ) របស់ព្រះអង្គឯង ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់គប់រកចំណែកនៃធម៌ ។ ន័យម្យ៉ាងទៀត ក្នុងបណ្ដាធម៌ទាំងឡាយ ដែលគួរដឹងក្រៃលែង មានកុសលជាដើម និងមានខន្ធជាដើម ចំណែកនៃធម៌ដែលត្រាស់ដឹងមាន ៤ យ៉ាង ដោយសង្ខេប ដោយទាក់ទងជាមួយនឹងធម៌ដែលគួរកំណត់ដឹងជាដើម ឬ ពោលដោយពិស្ដារ ចំណែកនៃធម៌ដែលគួរកំណត់ដឹងច្រើនយ៉ាង ដោយន័យថា ចក្ខុជារបស់គួរកំណត់ដឹង សោតៈជារបស់គួរកំណត់ដឹង ។ល។ ជរាមរណៈជារបស់គួរកំណត់ដឹងដូច្នេះជាដើម ចំណែកនៃធម៌ដែលគួរលះ ដោយន័យថា ហេតុកើតឡើងនៃចក្ខុជារបស់គួរលះ ។ ល ។ ហេតុកើតឡើងនៃជរាមរណៈជារបស់គួរលះបង់ដូច្នេះជាដើម ។

ចំណែកនៃធម៌ដែលគប្បីធ្វើឲ្យជាក់ច្បាស់ ដោយន័យថា **ធម៌ដែលរលត់ចក្ខុជារបស់គួរធ្វើឲ្យជាក់ច្បាស់ ។ល។ ធម៌ដែលរលត់ជរាមរណៈជាដើម ជារបស់គួរធ្វើឲ្យជាក់ច្បាស់** ដូច្នេះជាដើម និងធម៌ដែលជាចំណែកគួរចម្រើន ដែលមានប្រភេទជាច្រើន ដោយន័យថា គោលបដិបត្តិឲ្យដល់ធម៌ដែលរលត់ចក្ខុជាដើម និងដោយន័យថា សតិប្បដ្ឋាន ៤ ជាដើមទាំងនោះ ឯណា ព្រះអង្គទ្រង់គប់រក គឺ ទ្រង់ប្រើធម៌ទាំងនោះទាំងអស់ បានដល់ទ្រង់សេពដោយអំណាចនៃគោចរអាសេវនៈ ( សេព គឺ ធ្វើឲ្យជាអារម្មណ៍ ) និងភាវនាអាសេវនៈ ( សេព គឺ ចម្រើន ) តាមសមគួរ ។ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់គប់រកចំណែកនៃធម៌ តាមប្រការដែលពោលមកនេះ ។ ន័យម្យ៉ាងទៀត គំនរធម៌ទាំងឡាយ មានសីលជាដើម គឺ ពួក

នៃគុណ ចំណែកនៃគុណដែលសាធារណៈដល់សាវកទាំងឡាយទាំងនេះ ព្រះអង្គទ្រង់សំណូមពរ ( វនិ ប្រែថា សំណូមពរក៏បាន ) គឺ ទ្រង់ប្រាថ្នាក្រៃលែងហើយដោយព្រះមហាករុណាថា ធ្វើដូចម្ដេចហ្ន៎ ចំណែកនៃគុណទាំងនោះ គប្បីតាំងមាំនៅក្នុងសន្ដានវេនេយ្យសត្វបាន ដូច្នេះ ក៏សេចក្ដីប្រាថ្នាក្រៃលែងរបស់ព្រះអង្គនោះបានជាហេតុនាំមកនូវផល តាមដែលទ្រង់បំណង ។ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់សំណូមពរចំណែកនៃធម៌ តាមប្រការដែលពោលមកនេះ ។

***ព្រោះហេតុដែលព្រះតថាគតគប់រក ចំណែកនៃធម៌ដែលគួរដឹង និងគុណ គឺសមាបត្តិទាំងឡាយ ទ្រង់ប្រាថ្នាហើយដើម្បីប្រយោជន៍ដល់សត្វទាំងឡាយ ដូច្នោះទើបទ្រង់បានទទួលការថ្វាយព្រះនាមថា ភគវា ។***

ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់គប់រក **ភគ** ( ធម្មសម្បត្តិ ) យ៉ាងដូចម្ដេច ? មុនដំបូងពោលដោយរួមគ្នា សម្បត្តិដែលជាលោកិយ និង លោកុត្តរទាំងឡាយ ឈ្មោះថា **ភគ** ព្រោះអត្ថថា អ្នកដែលបានធ្វើបុណ្យទុក មានប្រយោគដល់ព្រម រមែងប្រើប្រាស់តាមសមគួរដល់ទ្រព្យ ។ ក្នុង **ភគ** ទាំងពីរនោះ មុនដំបូង ព្រះតថាគតមុនកាលត្រាស់ដឹង នៅជាព្រះពោធិសត្វនៅឡើយ ទ្រង់គប់រក គឺ ទ្រង់ប្រើប្រាស់ ទ្រង់សេពគគៈដែលជាលោកិយ ដែលដល់នូវភាពឧត្ដមក្រៃលែង សឹងជាគគៈដែលព្រះអង្គអាស្រ័យ ជាទីតាំងមាំ ប្រមូលធម៌ ដែលសាងភាពជាព្រះពុទ្ធ បន្ទុំព្រះពុទ្ធធម៌ទាំងឡាយឲ្យទុំដោយជុំវិញ ដោយមិនមានសេសសល់ ។ ព្រះអង្គទ្រង់ជាព្រះពុទ្ធហើយ ដូច្នោះក៏ទ្រង់នៅគប់រក គឺ ទ្រង់ប្រើប្រាស់ ទ្រង់សេពគគៈដែលជាលោកុត្តរ ដែលប្រកបដោយសេចក្ដីសុខ ដែលប្រាសចាកទោស ដែលមិនជាសាធារណៈដល់ពួកជនដទៃទាំងនោះ ។ ចំណែកពោលដោយពិស្ដារ ព្រះអង្គ

ទ្រង់គប់រក គឺ ទ្រង់ប្រើប្រាស់ ទ្រង់សេពគគ: ដែលមិនជាសាធារណៈដល់ពួកជនដទៃ ដែលមានប្រភេទជាអនេក គឺ រាជសម្បត្តិប្រចាំប្រទេស ភាពជាធំ សម្បត្តិនៃស្តេចចក្រពត្តិ សម្បត្តិ គឺ ភាពជាទេវរាជជាដើម និងឧត្តរិមនុស្សធម៌ មានឈានវិមោក្ខ សមាធិសមាបត្តិ ញាណទស្សនៈ ការចម្រើនមគ្គ ការធ្វើផលឲ្យជាក់ច្បាស់ជាដើម ។ ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់គប់រកភគៈទាំងឡាយ តាមប្រការដែលពោលមកនេះ ។

**សម្បត្តិទាំងឡាយក្នុងលោកទាំងនោះ និងលោកុត្តរសម្បត្តិ សន្ទឹកសន្ធាប់ឯណា ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រើប្រាស់សម្បត្តិទាំងអស់នោះ ព្រោះហេតុនោះទើបទ្រង់បានទទួលការថ្វាយព្រះនាមថា ភគវា ។**

ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានជនដែលភក្តី យ៉ាងដូចម្តេច ? ព្រះអង្គទ្រង់ព្រះនាមថា **ភត្តវា** ព្រោះអត្ថថា ទ្រង់មានជនដែលភក្តី គឺជនដែលមានភក្តីមាំទាំជាច្រើន ។ ជាសេចក្តីពិតថា ព្រះតថាគតទ្រង់ជាបុគ្គលឧត្តមជាងសត្វទាំងពួង ព្រោះភាវៈដែលទ្រង់ជាអ្នកមានចំណែកនៃគុណវិសេស ដែលមានអានុភាពដែលនរណាៗ ប្រមាណមិនបាន រកឧបមាមិនបាន មានព្រះមហាករុណា មានព្រះសព្វញ្ញុតញ្ញាណជាដើម ទើបទ្រង់ជាទីតាំងនៃការស្រឡាញ់ ការភក្តីយ៉ាងក្រៃលែង ព្រោះទ្រង់ជាអ្នកមានឧបការគុណ យ៉ាងក្រៃលែងចំពោះពពួកសត្វ ព្រមទាំងទេវតា និង មនុស្សដោយប្រយោគសម្បត្តិ រកបុគ្គលណាល្អក្រៃលែងជាងមិនបាន ដែលផ្តើមដោយការឲ្យចៀសវាងវត្ថុដែលជាអនត្ថៈ ( ភាពមិនជាប្រយោជន៍ ) ទាំងពួងសំដៅតែនឹងចាត់ចែងប្រយោជន៍សុខ ដោយមិនមានសេសសល់ទុកខាងមុខ ព្រោះទ្រង់ជាអណ្តូងកើតនៃការអើពើ សេចក្តីគោរព ការរាប់អានដ៏ច្រើនអំពីសត្វទាំងឡាយ

ដែលរកប្រមាណមិនបាន ព្រមទាំងទេវតា និងមនុស្សទាំងឡាយ ព្រោះហេតុដែលទ្រង់ជាបុគ្គលដែលគួរជ្រះថ្លាដោយជុំវិញ ដោយទ្រង់ជាហេតុនាំមកនូវសេចក្តីជ្រះថ្លាសូម្បីដោយប្រការទាំងពួង ក្នុងលោកសន្និវាស ដែលមានប្រមាណ ៤ យ៉ាង យ៉ាងនេះ គឺ អ្នកកាន់យករូបជាប្រមាណជ្រះថ្លាក្នុងរូប ១ កាន់យកសំឡេងជាប្រមាណជ្រះថ្លាក្នុងសំឡេង ១ កាន់យកភាពសៅហ្មងជាប្រមាណ ជ្រះថ្លាក្នុងភាពសៅហ្មង ១ កាន់យកធម៌ជាប្រមាណជ្រះថ្លាក្នុងធម៌ ១ ព្រោះភាពដែលទ្រង់មានព្រះរូបកាយប្រដាប់ដោយគ្រឿងប្រដាប់វិសេស ដែលមិនជាសាធារណៈដល់បុគ្គលដទៃ មានព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ មានព្រះអនុព្យញ្ជនៈ ៨០ មានព្រះរស្មីដែលផ្សាយទៅមួយព្យាមជាដើម ព្រោះទ្រង់ជាអ្នកប្រកបព្រមដោយសំឡេងសរសើរដ៏ធំទូលំទូលាយល្អ និងបរិសុទ្ធល្អ ដែលទ្រង់បានទទួលហើយ ដោយព្រះគុណទៅតាមសេចក្តីពិត ផ្សាយទៅក្នុងលោកទាំង ៣ ប្រព្រឹត្តទៅដោយន័យថា **ឥតិបិ សោ ភគវា** ជាដើម ព្រោះភាពដែលទ្រង់តាំងមាំយ៉ាងល្អក្នុងធម៌ មានសេចក្តីប្រាថ្នាតិចភាពសន្តោសជាដើម ដែលដល់នូវភាពជាបារមីដ៏ឧត្តម និងព្រោះភាវៈដែលទ្រង់ជាអ្នកព្រមព្រៀងដោយគុណវិសេសដ៏លើស មានព្រះទសពលញ្ញាណ ចតុវេសារជ្ជ-ញ្ញាណជាដើម ។ ពួកជនណា តាំងមាំក្នុងឱវាទរបស់ព្រះតថាគតអង្គនោះ ជាអ្នកដល់ព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើក ជនទាំងនោះក៏មានភក្តីភាព ដែលនរណាៗដែលជាសមណៈក៏ដោយ ជាព្រាហ្មណ៍ក៏ដោយ ទេវតាក៏ដោយ មារក៏ដោយ ព្រហ្មក៏ដោយ មិនអាចធ្វើឲ្យកម្រើកបានដូច្នេះ ។ ពិតហើយ ជនទាំងនោះ សូម្បីកាលមានការត្រូវលះបង់ជីវិតរបស់ខ្លួន ក៏មិនព្រមលះបង់សេចក្តីជ្រះថ្លា ក្នុងព្រះតថាគតអង្គនោះ ឬថា មិនព្រមលះបង់ពុទ្ធប្បញ្ញត្តិរបស់ព្រះអង្គ ក៏ព្រោះមានភក្តីភាពមាំទាំ ។

ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ទុកថា ៖

បុគ្គលឯណាជាអ្នកកតញ្ញូ កតវេទី ជាអ្នកប្រាជ្ញ ជាកល្យាណមិត្ត និងមានភក្តីភាពមាំទាំ ដូច្នេះជាដើម ។ និងថា ៖

ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រមានការតាំងនៅជាធម្មតា មិនជន់លិចប្រាំងយ៉ាងណា ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយរបស់តថាគត ក៏មិនឈានកន្លងសិក្ខាបទដែលតថាគតបញ្ញត្តហើយដល់សាវកទាំងឡាយ សូម្បីព្រោះហេតុនៃជីវិត យ៉ាងនោះដូចគ្នាដែរ ដូច្នេះ ។

ទ្រង់ព្រះនាមថា ភគវា ព្រោះអត្ថថា ទ្រង់ជា ភត្តវា ( អ្នកមានជនភក្តី ) តាមប្រការដែលពោលមកនេះ ព្រោះធ្វើការលប់ ត អក្សរចេញមួយតួ ហើយធ្វើ ត អក្សរមួយតួទៀតឲ្យជា គ អក្សរ ដោយន័យនិរុត្តិ ។

ព្រោះហេតុដែលព្រះសាស្តា អ្នកស្វែងរកប្រយោជន៍សុខដល់លោក ដែលប្រកបដោយគុណដ៏វិចិត្រ ទ្រង់មានជនភក្តីសន្ធឹកសន្ធាប់ ដូច្នោះ បណ្ឌិត ទើបថ្វាយព្រះនាមព្រះអង្គថា ភគវា ។

ទ្រង់ព្រះនាមថា ភគវា ព្រោះអត្ថថា ទ្រង់ខ្ជាក់ចោលនូវភគៈ ( ទ្រព្យសម្បត្តិ ) យ៉ាងដូចម្តេច ? ព្រោះហេតុដែលព្រះតថាគត សូម្បីថា ទ្រង់នៅជាព្រះពោធិសត្វ កាលទ្រង់ធ្វើព្រះបារមីឲ្យពេញនៅក្នុងជាតិមុនៗ ក៏ទ្រង់ខ្ជាក់ គឺ ទ្រង់ក្អួរចេញហើយនូវសិរី ពោលគឺ សម្បត្តិ ភាពជាធំ និងយស គឺ ទ្រង់ចោលទៅមិនអាឡោះអាល័យដូចជាស្តោះទឹកមាត់ចោល ។ ពិតហើយ ក្នុងកាលយ៉ាងនេះ គឺ ក្នុងកាលដែលព្រះតថាគតអង្គនេះ ទ្រង់ជាសោមនស្សកុមារ ក្នុងកាលដែលទ្រង់ជាហត្ថិបាលកុមារ ក្នុងកាលដែលទ្រង់ជាអយោឃរបណ្ឌិត ក្នុងកាលដែលទ្រង់ជាមូគបក្ខបណ្ឌិត ក្នុងកាល

ដែលទ្រង់ជាចូឡសុត្តសោមដូច្នេះជាដើម អត្ថភាពដែលទ្រង់លះបង់សិរីសម្បត្តិ គឺក្នុងភាពជាព្រះរាជា ដែលដូចភាពជាទេវរាជ ដោយទាក់ទងនឹងការបំពេញនេក្ខម្មបារមីឲ្យបរិបូណ៌រកប្រមាណមិនបាន ។ សូម្បីក្នុងអត្តភាពទីបំផុត ក៏ទ្រង់ជាអ្នកមិនសម្គាល់ មិនអាឡោះអាល័យសូម្បីប៉ុនចុងស្មៅ លះបង់ចក្រពត្តិសិរីសម្បត្តិនៅក្នុងកណ្ដាប់ដៃ គឺ ភាពជាធំក្នុងទ្វីបទាំង ៤ ដែលដូចភាពជាធំក្នុងទេវលោក និង យសដែលរុងរឿងដោយរតនៈទាំង ៧ ដែលមានចក្រពត្តិសម្បត្តិជាទីពឹងអាស្រ័យ ហើយស្ដេចយាងមហាភិនេស្រ្កមណ៍ ត្រាស់ដឹងក្រៃលែងហើយនូវសម្មាសម្ពោធិញ្ញាណដូច្នេះ ទើបទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ក្អែរភគៈ មានសិរីសម្បត្តិជាដើមទាំងនេះ ។ ន័យម្យ៉ាងទៀត ផ្កាយនក្ខត្តៈទាំងឡាយ ឈ្មោះថា **ភ** ធម្មជាតិដែលស្រស់ស្អាតទាំងឡាយ ដែលមានវត្ថុផ្សេងៗ នៃភាជនៈលោក មានភ្នំសិនេរុ ភ្នំយុគន្ធរ ឧត្តរកុរុទ្វីប ភ្នំហិមពាន្តជាដើម ដែលជាទីអាស្រ័យ ដោយភាវៈជាទីពឹង ឬជាទីតាំងនៅបានអស់កប្ប ឈ្មោះថា **ភគ** ព្រោះអត្ថថា **ទៅ** គឺ ប្រព្រឹត្តទៅស្មើគ្នានឹងផ្កាយនក្ខត្តៈ ដែលឈ្មោះថា **ភ** ទាំងនោះ ។ ព្រះមានព្រះភាគ ទ្រង់ក្អែរភគៈទាំងនោះ គឺ ទ្រង់លះបង់បានដោយការឈានកន្លងសត្តាវាស ដែលជាទីអាស្រ័យនៅនៃភគៈទាំងនោះ ដោយការលះឆន្ទរាគៈ ដែលទាក់ទងនឹងភគៈទាំងនោះ ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ខ្ជាក់ចោលភគៈដោយប្រការដូចពោលមកនេះ ។

ព្រោះហេតុដែលព្រះសុគត ទ្រង់លះចក្រពត្តិសិរី យស ភាពជាធំ សេចក្ដីសុខ និងធម្មជាតិដែលវិចិត្រក្នុងលោកបាន ដូច្នោះ បណ្ឌិតទើបថ្វាយព្រះនាមថា **ភគវា** ។

ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ក្អែរភាគៈ ( ចំណែកនៃសភាវធម៌ ) ដូចម្តេច ? ចំណែកនៃសភាវធម៌ទាំងឡាយ ឈ្មោះថា **ភាគ** ចំណែកនៃសភាវធម៌ ដែលឈ្មោះថា ភាគៈទាំងនោះមានច្រើនយ៉ាង ដោយទាក់ទងនឹងខន្ធ អាយតនៈ ធាតុ ជាដើម សូម្បីក្នុងខន្ធជាដើមនោះ ក៏មានច្រើនយ៉ាង ដោយទាក់ទងដោយរូបក្ខន្ធ វេទនាខន្ធជាដើម និងដោយទាក់ទងនឹងកាល មានអតីតជាដើម ក៏ព្រះមានព្រះភាគ កាលទ្រង់កាត់បង់នូវធម៌ ដែលជាគ្រឿងយឺតយូរ ( មានតណ្ហាជាដើម ) ទាំងអស់ យោគៈទាំងអស់ គន្ថៈទាំងអស់ សំយោជនៈទាំងអស់ ហើយទ្រង់សម្រេចអមត-ធាតុ ក៏ឈ្មោះថា ទ្រង់ក្អែរ គឺ ទ្រង់ខ្ជាក់ចោលបាននូវចំណែកនៃសភាវធម៌ ដែលឈ្មោះថា ភាគៈទាំងនោះ មិនអាឡោះអាល័យ ចោលទៅ មិនត្រឡប់កើតទៀត ។ ពិតហើយ ព្រះមានព្រះភាគអង្គនេះ ទ្រង់ក្អែរ គឺ ទ្រង់ខ្ជាក់ចេញដោយមិនមានសល់ គឺ ទ្រង់លោសចោលបាន ដោយទ្រង់លះបង់ចោលបាន មិនមានអាល័យនូវចំណែកនៃធម៌ទាំងអស់នោះឯង សូម្បីដោយអំណាចនៃការចែកធម៌ទៅតាមលំដាប់បទ ដោយន័យថា ទ្រង់ក្អែរនូវបឋវី អាបោ តេជោ វាយោ ដែលមានក្នុងទីទាំងពួងនោះឯង នូវចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយៈ មនៈ នូវរូប សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ ធម្មៈ នូវចក្ខុវិញ្ញាណ ។ល។ មនោវិញ្ញាណ នូវចក្ខុសម្ផស្ស ។ល។ មនោសម្ផស្ស នូវចក្ខុសម្ផស្សវេទនា ។ ល ។ មនោសម្ផស្សវេទនា ។ ល ។ នូវចក្ខុសម្ផស្សសញ្ញា ។ល។ មនោសម្ផស្សសញ្ញា នូវចក្ខុសម្ផស្សចេតនា ។ល។ មនោសម្ផស្សចេតនា នូវរូបតណ្ហា ។ ល ។ ធម្មតណ្ហា នូវរូបវិតក្ក ។ ល ។ ធម្មវិតក្កៈ នូវរូបវិចារៈ ។ ល ។ ធម្មវិចារៈ ដូច្នេះជាដើម សេចក្តីនេះសមដូចដែលទ្រង់ត្រាស់ទុកថា ៖

ម្នាលអានន្ទ វត្ថុដែលតថាគតលះបង់ហើយ ក្អែរបានហើយ ផុតស្រឡះហើយ

លះបង់បានហើយ បន្សាត់បង់បានហើយ នុ៎ះ ឯណា ការដែលតថាគតនឹងត្រឡប់មកកាន់ធម្មជាតិនោះទៀតដូច្នេះ នេះមិនមែនជាឋានៈឡើយ ។

ទ្រង់ព្រះនាមថា ភគវា ព្រោះអត្ថថា ទ្រង់ក្អួរភាគៈ(ចំណែកនៃសភាវធម៌) ស្ទើរបីតាមប្រការដែលពោលមកនេះ ។ ន័យម្យ៉ាងទៀត ពាក្យថា ទ្រង់ក្អួរភាគៈ មានសេចក្តីថា ទ្រង់ក្អួរ គឺ ខ្ជាក់ចេញបានដោយព្រះឱស្ឋ គឺ អរិយមគ្គញ្ញាណ បានដល់ ទ្រង់ជាអ្នកមិនអាឡោះអាល័យ លះបង់បាន លះបាននូវធម៌ទាំងឡាយដែលជាកុសល និង អកុសល មានទោស និង មិនមានទោស ថោកទាប និងប្រណីត មានចំណែកប្រៀបនឹងធម៌ខ្មៅ និងធម៌ស ទាំងអស់ ហើយទ្រង់សម្តែងធម៌ដល់អ្នកដទៃ ដើម្បីការខ្ជាក់ចោលយ៉ាងនោះ ។ សេចក្តីនេះ សមពិត តាមដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ស្ទើរបីធម៌ ពួកអ្នកក៏ត្រូវលះ នឹងចាំបាច់ពោលថ្វីដល់អធម៌នោះ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ដែលមានឧបមាដូចក្បូនដល់ពួកអ្នក ក៏ដើម្បីប្រយោជន៍ដល់ការរលាស់ចេញ ( ចាកទុក្ខ ) មិនមែនដើម្បីប្រយោជន៍ដល់ការប្រកាន់មាំ ដូច្នេះ ។

ទ្រង់ព្រះនាមថា ភគវា ព្រោះអត្ថថា ទ្រង់ក្អួរភាគៈស្ទើរបីតាមប្រការដែលពោលមកនេះ ។

ព្រោះហេតុដែល ព្រះអង្គជាអ្នកស្វែងរកគុណដ៏ធំ ទ្រង់ខ្ជាក់ចោលប្រភេទនៃធម៌ មានខន្ធ អាយតនៈ ធាតុ ជាដើម ដែលមានទាំងចំណែកខ្មៅ និង ចំណែកស ដូច្នេះ បណ្ឌិតទើបថ្វាយព្រះនាមព្រះអង្គថា ភគវា ។

ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបពោលថា ព្រះជិនស្រីជាម្ចាស់ ទ្រង់ព្រះនាមថា

ភគវា ព្រោះអត្ថថា ទ្រង់ជាអ្នកមានចំណែកនៃគុណ ទ្រង់ជាអ្នកមានធម៌ ដែលរក្សាទុកហើយ ទ្រង់គប់រកចំណែកនៃធម៌ និងធម្មសម្បត្តិទាំងឡាយ ទ្រង់មានជនដែលភក្តី ទ្រង់ខ្ចាក់ទ្រព្យសម្បត្តិ ម្យ៉ាងវិញទៀត ទ្រង់ក្អួរចំណែកនៃធម៌ ។

ម្យ៉ាងវិញទៀត ក្នុងបណ្ដាពុទ្ធគុណទាំងនោះ ព្រោះហេតុដែលព្រះពុទ្ធគុណមាន ២ យ៉ាងដោយសង្ខេប គឺ ការដល់ព្រមនៃប្រយោជន៍ខ្លួន និងការបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ក្នុងកាលដែលដល់ព្រមនៃប្រយោជន៍ខ្លួន និងការបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃនោះ ការដល់ព្រមនៃប្រយោជន៍ខ្លួនមាន ២ យ៉ាង ដោយចែកជាបហានសម្បទា ការដល់ព្រមនៃការលះបង់ និងញាណសម្បទា ការដល់ព្រមនៃញាណ , រីឯ អានុភាវសម្បទា ការដល់ព្រមនៃអានុភាពជាដើម ក៏រួមចុះក្នុងបហានសម្បទា និងញាណសម្បទានោះ ព្រោះការមិនវៀរចាកសម្បទាទាំងពីរនោះ, ឯការបដិបត្តិដើម្បីប្រយោជន៍ដល់អ្នកដទៃ ក៏មានពីរយ៉ាង ចែកជា **បយោគ** ( ការព្យាយាម ) និង **អាសយ** ( អជ្ឈាស្រ័យ ) ។ ក្នុងការបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ពីរយ៉ាងនោះ ការប្រកាសធម៌ដែលនាំចេញចាកទុក្ខទាំងពួងនៃព្រះមានព្រះភាគដែលមានចិត្តប្រាសចាកការសម្លឹងអាមិស មានលាភសក្ការៈជាដើម ជាការបដិបត្តិដើម្បីប្រយោជន៍ដល់អ្នកដទៃផ្នែកបយោគៈ ភាពជាអ្នកស្វែងរកប្រយោជន៍ជានិច្ចដើម្បីសត្វទាំងឡាយ សូម្បីអ្នកគិតប្រទូស្ត និង កិច្ច មានការរង់ចាំវេលាញាណចាស់ក្លាជាដើម ជាការបដិបត្តិដើម្បីប្រយោជន៍ដល់អ្នកដទៃ ផ្នែកអាសយៈ ការប្រព្រឹត្តប្រយោជន៍សូម្បីដោយកិច្ច មានការទទួលយកនូវអាមិសជាដើម ក៏ជាការបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ផ្នែកអាសយៈនោះដែរ ។ ដូច្នោះ ទើបគួរជ្រាបដល់ការយល់បទទាំងឡាយ មានបទថា **អរហំ** ជាដើម ក្នុងព្រះបាលីដោយទាក់ទង

នឹងការបើកផ្សាយព្រះគុណពីរយ៉ាងទាំងនោះចុះ ។

ក្នុងបណ្តាព្រះពុទ្ធគុណទាំង ៩ បទនោះ ដោយបទថា **អរហំ** នេះ ជាការបើកផ្សាយនូវការដល់ព្រមនៃប្រយោជន៍ខ្លួន របស់ព្រះមានព្រះភាគ ដោយទាក់ទងនឹងបហានសម្បទា ( ការដល់ព្រមដោយការលះ ) ។ ដោយបទថា **សម្មាសម្ពុទ្ធោ** និងបទថា **លោកវិទូ** ទាំងនេះ ជាការបើកផ្សាយនូវការដល់ព្រមនៃប្រយោជន៍ខ្លួនដោយទាក់ទងនឹងញាណសម្បទា ។ សួរថា ក៏សូម្បីដោយបទថា **លោកវិទូ** នេះ លោកអាចារ្យបើកផ្សាយដល់ភាពជាព្រះសម្មាសម្ពុទ្ធមិនមែនឬ ? ឆ្លើយថា បើកផ្សាយដល់ភាពជាព្រះសម្មាសម្ពុទ្ធពិត សូម្បីយ៉ាងនោះ ក៏នៅមានប្រការដែលពិសេស គឺដោយបទថា **សម្មាសម្ពុទ្ធោ** នេះ ជាការបើកផ្សាយអានុភាពនៃព្រះសព្វញ្ញុតញ្ញាណ , រីឯដោយបទថា **លោកវិទូ** នេះ ជាការបើកផ្សាយនូវអានុភាពនៃអាសយានុសយញ្ញាណជាដើមផងដែរ ។ ដោយបទថា **វិជ្ជាចរណសម្បន្នោ** នេះ ជាការបើកផ្សាយនូវការដល់ព្រមនៃប្រយោជន៍សូម្បីទាំងពួងរបស់ព្រះមានព្រះភាគ ។ ចំណែកដោយបទថា **សុគតោ** នេះ បើកផ្សាយនូវការដល់ព្រមនៃប្រយោជន៍ខ្លួន និងការបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃរបស់ព្រះមានព្រះភាគ ចាប់តាំងអំពីកាលដែលទ្រង់ឧប្បត្តិឡើង ។ ដោយបទថា **អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ** ទាំងនេះ ជាការបើកផ្សាយការបដិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃរបស់ព្រះមានព្រះភាគ ។ ដោយបទថា **ពុទ្ធោ** នេះ ជាការបើកផ្សាយនូវការដល់ព្រមនៃប្រយោជន៍ខ្លួនផង ដោយការបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃផង របស់ព្រះមានព្រះភាគ ។ ក៏ព្រោះធ្វើអធិប្បាយយ៉ាងនេះ ការដែលនឹងពោលថា **សម្មាសម្ពុទ្ធោ** ដូច្នេះហើយ ក៏នៅពោលទៀតថា **ពុទ្ធោ** ទើបជាការប្រើបាន ។ ព្រោះហេតុនោះឯង លោកទើបពោលទុកថា ត្រាស់ដឹងសូម្បី

ដោយព្រះអង្គឯងហើយ ក៏ទ្រង់ញុំាងសត្វពួកដទៃ ឲ្យត្រាស់ដឹងដូច្នេះជាដើម ។ ចំណែកដោយបទថា **ភគវា** នេះ ជាការបើកផ្សាយការដល់ព្រមនៃប្រយោជន៍ខ្លួនផង ការបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃផង គ្រប់យ៉ាងរបស់ព្រះមានព្រះភាគ ចាប់តាំងអំពីកាលដែលទ្រង់ឧប្បត្តិឡើង ។

ន័យម្យ៉ាងទៀត គប្បីជ្រាបថា ព្រះពុទ្ធគុណមាន ៣ យ៉ាង ដោយសង្ខេប ដោយទាក់ទងជាហេតុផល និងការឧបការសត្វ ។ ក្នុងបទទាំងនោះ ដោយបទទាំងឡាយថា **អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ លោកវិទូ** ទាំងនេះ ជាការបើកផ្សាយព្រះពុទ្ធគុណទាំងឡាយ ដោយទាក់ទងនឹងការដល់ព្រមនៃផល ។ ដោយបទទាំងឡាយថា **អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ** ទាំងនេះ ជាការបើកផ្សាយព្រះពុទ្ធគុណទាំងឡាយ ដោយទាក់ទងនឹងការឧបការសត្វ ។ ដោយបទថា **ពុទ្ធោ** នេះ ជាការបើកផ្សាយព្រះពុទ្ធគុណទាំងឡាយ ដោយទាក់ទងនឹងផល និងដោយទាក់ទងនឹងការឧបការសត្វ ។ ចំណែកដោយបទទាំងឡាយថា **សុគតោ ភគវា** ទាំងនេះ ជាការបើកផ្សាយព្រះពុទ្ធគុណទាំងឡាយ ដោយទាក់ទងនឹងហេតុ-ផល និងការឧបការសត្វ ។

( ចប់ មហាដីកា )

# ពុទ្ធានុស្សតិជ្ឈាន

កាលព្រះយោគាវចរនោះ រឭកដល់ព្រះពុទ្ធគុណថា ព្រោះហេតុនេះៗ ព្រះមានព្រះភាគជាម្ចាស់អង្គនោះ **ជាព្រះអរហំ** ។លៗ ព្រោះហេតុនោះៗ ព្រះមានព្រះភាគជាម្ចាស់អង្គនោះ **ជាព្រះភគវា** ដូច្នេះ ក្នុងសម័យនោះ ចិត្តរបស់លោករមែងមិនជាចិត្តដែលរាគៈរួបរិត មិនជាចិត្តដែលទោសៈរួបរិត មិនជាចិត្តដែលមោហៈរួបរិតឡើយ ក្នុងសម័យនោះ ចិត្តរបស់លោករមែងជាចិត្តប្រព្រឹត្តទៅត្រង់ផ្លូវ ប្រារព្ធគុណព្រះតថាគតជាម្ចាស់ , កាលលោកគ្របសង្កត់នីវរណៈបាន ដោយមិនមានបរិយុដ្ឋានកិលេស មានរាគៈជាដើមយ៉ាងនោះ ឈ្មោះថា មានចិត្តប្រព្រឹត្តទៅត្រង់ ព្រោះមានចិត្តបែរចំពោះព្រះកម្មដ្ឋានដូច្នេះ វិតក្កៈនិងវិចារៈដែលបង្អោនទៅក្នុងព្រះពុទ្ធគុណរមែងប្រព្រឹត្តទៅ កាលត្រិះរិះ កាលត្រាច់ទៅក្នុងព្រះពុទ្ធគុណរឿយៗទៅ បីតិរមែងកើតឡើង សេចក្តីក្រវល់ក្រវាយតាមផ្លូវកាយ តាមផ្លូវចិត្តរបស់លោក ដែលមានចិត្តប្រកបដោយបីតិ រមែងស្ងប់រំងាប់ដោយបស្សទ្ធិដែលមានបីតិជាបទដ្ឋាន សុខទាំងផ្លូវកាយ ទាំងផ្លូវចិត្ត រមែងកើតដល់លោក ដែលមានសេចក្តីក្រវល់ក្រវាយស្ងប់រំងាប់ហើយ ចិត្តរបស់លោកដែលមានសុខ ជាចិត្តមានព្រះពុទ្ធគុណជាអារម្មណ៍ រមែងជាសមាធិ អង្គឈានរមែងកើតឡើងដោយលំដាប់ ក្នុងខណៈមួយ ដូចពោលមកដូច្នោះ តែព្រោះព្រះពុទ្ធគុណទាំងឡាយ ជាអារម្មណ៍ជ្រាលជ្រៅ ឬ ព្រោះចិត្តបង្អោនទៅក្នុងកាលរឭកដល់ព្រះពុទ្ធគុណ មានប្រការផ្សេងៗ ឈាននេះ ទើបជាឈានដែលមិនដល់អប្បនា ដល់ត្រឹមតែឧបចារៈប៉ុណ្ណោះ ហើយឈាននេះ ក៏ដល់នូវការរាប់ គឺ បានឈ្មោះថា **ពុទ្ធានុស្សតិ** នោះឯង ព្រោះជាឈានដែលកើតឡើងដោយ

អំណាចការរឭកដល់ព្រះពុទ្ធគុណ ។

# មហាដីកា

បទថា **តស្ស** ( កាលព្រះយោគីនោះ ) បានដល់ ព្រះយោគីដែលចម្រើនពុទ្ធានុស្សតិកម្មដ្ឋាន ។ ពាក្យថា **យ៉ាងនេះ** គឺ តាមប្រការដែលលោកអាចារ្យបានពោលទុកថា តទៅនេះជាន័យក្នុងពុទ្ធានុស្សតិនោះ ដូច្នេះជាដើម ។ ពាក្យថា **ក្នុងសម័យនោះ** គឺ ក្នុងសម័យដែលរឭករឿយ ៗ ដល់ព្រះពុទ្ធគុណ ។ បទថា **រាគបរិយុដ្ឋិតំ** ប្រែថា ត្រូវរាគៈរួបរិត ជាការពោលបានថា ចិត្តដែលប្រព្រឹត្តទៅព្រមជាមួយរាគៈ ដែលដល់ភាពជាបរិយុដ្ឋាន ឈ្មោះថា ត្រូវរាគៈនោះរួបរិត ដូចព្រៃដែលត្រូវពួកចោរគ្រប់គ្រងដូច្នោះ សំដៅយកសេចក្តីថា ចិត្តដែលមានរាគៈរួបរិតហើយ ដោយភាពជាទីតាំងនៃការរុំព័ទ្ធនៃរាគៈនោះ ។ម្យ៉ាងទៀត គប្បីឃើញថា ការរួបរិតនៃរាគៈនោះ ឯណា ការរួបរិតនៃរាគៈនោះ ដែលសត្វចូលទៅសន្សំទុកក្នុងចិត្ត ដែលប្រព្រឹត្តទៅជាមួយរាគៈនោះ ។ ក្នុងចំណែកនេះ ពាក្យថា **ត្រូវរាគៈរួបរិត** ទើបមានន័យថា ត្រូវរាគៈដែលជាហេតុរួបរិត ។ បទថា **ឧជុគតមេវ** គឺ ដល់ នូវភាពត្រង់ប៉ុណ្ណោះ ព្រោះកម្ចាត់ភាពកោងនៃកាយជាដើមបានមុនហើយ និងព្រោះចិត្ត មិនមានឧបក្កិលេស មានមាយាជាដើម ដែលសាងភាពមិនស្មោះត្រង់ ឬ ព្រោះវៀរចាកការបន្ទាបខ្លួន និងការលើកខ្លួន ព្រោះមិនមានការរួបរិតនៃកិលេសមានរាគៈជាដើម ។ ន័យម្យ៉ាងទៀត បទថា **ឧជុគតមេវ** គឺ ដល់នូវភាពត្រង់នោះឯង ដោយការឡើងកាន់សមថនិមិត្ត ដែលជាផ្លូវកណ្តាលបាន ដោយប្រាសចាកការ

រួញរា និង ការរោយរាយ ព្រោះការឈានចុះកាន់វិថីកម្មដ្ឋានបានហើយ ។ ពាក្យថា **ប្រារព្ធព្រះតថាគត** គឺ ធ្វើព្រះគុណទាំងឡាយរបស់ព្រះតថាគត មកជាអារម្មណ៍ ។

បទថា **ឥច្ចស្ស** កាត់ជា **ឥតិ អស្ស** ។ ភ្ជាប់សេចក្តីថា កាលលោកតាមរឭកដល់ព្រះពុទ្ធគុណទាំងឡាយតាមប្រការដែលពោលហើយ ក្នុងខាងដើមដោយន័យថា **សោ ភគវា ឥតិបិ អរហំ** ជាដើម ។ ពាក្យថា **តាមន័យដែលពោលហើយនេះ** គឺ តាមន័យដែលពោលហើយដោយពាក្យថា ក្នុងសម័យនោះ ចិត្តរបស់ព្រះយោគីនេះ គឺ មិនជាចិត្តដែលត្រូវរាគៈរួបរិតដូច្នេះជាដើម ។ បទថា **ពុទ្ធគុណបោណា** គឺ ដែលបង្អោនទៅក្នុងព្រះពុទ្ធគុណទាំងឡាយ ។ ដោយពាក្យថា **វិតក្កៈ និង វិចារៈរមែងប្រព្រឹត្តទៅ** នេះលោកសម្តែងថា ព្រះយោគីរមែងធ្វើកម្មដ្ឋាន ពោលគឺ ព្រះពុទ្ធគុណឲ្យវិតក្កៈពាល់ត្រូវបានអំពីដំបូង ឲ្យវិតក្កៈពាល់ត្រូវទូទៅ និង រមែងធ្វើការតាមប្រកៀករឿយៗ ។ ពាក្យថា **បីតិក៏រមែងកើតឡើង** គឺ បីតិដែលមានកម្លាំង ដែលឲ្យសម្រេចឧបចារជ្ឈាន រមែងកើតឡើងដោយអំណាចនៃភាវនា ។ ពាក្យថា **របស់លោកដែលមានបីតិចិត្ត** គឺ របស់អ្នកដែលមានចិត្តកើតរួមជាមួយបីតិ ដែលមានប្រការដូចពោលមកហើយ ។ ពាក្យថា **ការក្រវល់ក្រវាយនៃកាយនិងចិត្ត** បានដល់កិលេសទាំងឡាយដែលសហគតៈដោយឧទ្ធច្ចៈ ដែលជាបដិបក្ខចំពោះកាយបស្សទ្ធិ និងចិត្តបស្សទ្ធិ មានការតាំងចុះដ៏សុខុម ។ ពាក្យថា **រមែងរំងាប់ទៅ** គឺ រមែងស្ងប់ទៅ ។ ពាក្យថា **ក្នុងខណៈជាមួយគ្នាតាមលំដាប់** មានសេចក្តីថា ក្នុងវេលាណាភាវនាដែលមានព្រះពុទ្ធគុណជាអារម្មណ៍ ប្រព្រឹត្តទៅ នាំមកនូវគុណវិសេសដែលក្រៃលែងៗឡើងទៅ ក្នុងវេលានោះនីវរណៈទាំងឡាយ រមែងស្ងប់រំងាប់ទៅ កិលេសទាំងឡាយក៏ស្ងប់រំងាប់ផងដែរ ឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើម ដែលចាស់ក្លា

ក៏រមែងមានវិតក្កៈនិងវិចារៈ ជាធម្មជាតិ ដែលមានកិច្ចជាក់ច្បាស់ល្អយ៉ាងក្រៃលែង ព្រោះការនាស្មាត់ជំនាញ បីតិដែលមានកម្លាំងរមែងកើតឡើង បស្សទ្ធិដែលមានបីតិជាបទដ្ឋាន ដែលមានភាពពិសេសរមែងកើតឡើង សុខដែលមានសមាធិជាបទដ្ឋាន ជាធម្មជាតិតាំងមាំ រមែងប្រព្រឹត្តទៅដល់អ្នកមានកាយស្ងប់ហើយ ចិត្តដែលមានសុខតាមបម្រើនបន្ថែម រមែងតាំងមាំក្នុងកម្មដ្ឋានដោយប្រពៃ ។ ធម៌ទាំងឡាយមានវិតក្កៈជាដើម ប្រព្រឹត្តទៅដោយការៈដែលជាក់ច្បាស់ ជាក់ច្បាស់ក្រៃលែងៗឡើងទៅ ក្នុងចំណែកខាងដើមតាមលំដាប់ តាមប្រការដែលពោលមកនេះ ហើយជាធម្មជាតិដែលជាក់ច្បាស់បំផុត ព្រោះការនាប្រព្រឹត្តទៅកាន់សមថនិមិត្ត ដែលជាផ្លូវកណ្តាលបាន និងព្រោះឥន្ទ្រិយទាំងឡាយ មានរសតែមួយដូចគ្នា អង្គឈានទាំងឡាយ ក៏រមែងកើតឡើងក្នុងខណៈដូចគ្នា បានដល់ ព្រះតម្រាស់ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកយ៉ាងនេះថា ៖

***ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណាអរិយសាវ័ករឭករឿយៗ ដល់តថាគត ក្នុងសម័យនោះ ចិត្តរបស់គេ មិនជាចិត្តដែលត្រូវរាគៈរួបរិត ។ ល ។ ចិត្តរបស់គេដែលមានសុខ រមែងតាំងមាំជានិច្ច ដូច្នេះ ។***

លោកអាចារ្យធ្វើពាក្យសួរទុកក្នុងចិត្តថា ក៏ព្រោះហេតុអ្វី ឈានក្នុងពុទ្ធានុស្សតិនេះ ទើបមិនជាឈានដែលដល់អប្បនា ដូច្នេះហើយ ទើបពោលថា តែព្រោះព្រះពុទ្ធគុណទាំងឡាយ ជាធម្មជាតិជ្រាលជ្រៅ ដូច្នេះជាដើម ។ ពិតណាស់ ក្នុងអារម្មណ៍ដែលជ្រាលជ្រៅ សមថការនារមែងមិនបានជាទីតាំងមាំ ដូចទូកដែលចែវទៅក្នុងទឹកជ្រៅដូច្នោះ ក៏ដោយពាក្យថា ព្រោះជាធម្មជាតិជ្រាលជ្រៅនេះ រួមយកទាំងភាពជាសភាវធម៌ផង ។ ជាសេចក្តីពិតថា សភាវធម៌ជារបស់មានជម្រៅ បញ្ញត្តិ

មិនជារបស់មានជម្រៅ ចោទសួរថា ក៏ព្រះយោគី រមែងកាន់យកសភាវធម៌ដោយអំណាចបញ្ញត្តិ ដែលអាស្រ័យសភាវធម៌នោះមិនមែនឬ ? ឆ្លើយថា ក្នុងខាងដើម រមែងកាន់យកសភាវធម៌ដោយអំណាចបញ្ញត្តិ ដែលអាស្រ័យសភាវធម៌នោះក៏ពិត តែកាលភាវនាចម្រើនទៅ ចិត្ត រមែងឈានកន្លងបញ្ញត្តិ ហើយតាំងនៅក្នុងសភាវៈប៉ុណ្ណោះ ។ ចោទសួរថា អរូបជ្ឈានទី ២ ( វិញ្ញាណញ្ចាយតនៈ ) ជាដើម រមែងសម្រេចជាអប្បនាក្នុងអារម្មណ៍ សូម្បីដែលជាសភាវធម៌បាន មិនមែនឬ លោកអាចារ្យកាលនឹងសម្ដែងថា រមែងសម្រេចបានក៏ពិត តែថា អរូបជ្ឈាន ទី ២ ជាដើមនោះឯង រមែងសម្រេចបានក្នុងអារម្មណ៍ ដែលមានតែ ១ ប្រការ , តែថា ឈាននេះមានអារម្មណ៍ផ្សេងៗច្រើនប្រការ ដូច្នោះ ទើបពោលថា ព្រោះភាពដែលចិត្តបង្អោនទៅដោយការរឭករឿយៗ ដល់ព្រះពុទ្ធគុណច្រើនប្រការ ដូច្នេះ ។ សូម្បីយ៉ាងនេះ ក៏នៅសួរទៀតថា ប្រៀបឧបមាថា កាលព្រះយោគីធ្វើមនសិការឲ្យប្រព្រឹត្តទៅក្នុងកោដ្ឋាសទាំងឡាយ មានសក់ជាដើមដោយប្រការផ្សេងៗ ភាវនាក៏គង់តាំងចុះបានដោយទាក់ទងជាអប្បនា ក្នុងកោដ្ឋាសមួយប៉ុណ្ណោះ យ៉ាងណា ព្រោះហេតុអ្វី ក្នុងពុទ្ធានុស្សតិកម្មដ្ឋាននេះ ភាវនាទើបមិនដូច្នោះទៅវិញ ? ឆ្លើយថា សេចក្ដីប្រៀបធៀបនេះមិនសមគ្នាទេ ព្រោះថា ក្នុងកម្មដ្ឋាននោះ សូម្បីកាលកោដ្ឋាសទាំងឡាយនឹងមាននៅសន្ទឹកសន្ទាប់ , ភាវនា ក៏រមែងប្រព្រឹត្តទៅក្នុង ១ ប្រការ ប៉ុណ្ណោះ ព្រោះការកាន់យកចំពោះអាការដែលជាបដិកូលប៉ុណ្ណោះ តែក្នុងពុទ្ធានុស្សតិកម្មដ្ឋាននេះ ព្រោះព្រះពុទ្ធគុណមានច្រើនប្រការ ដោយប្រការផ្សេងៗគ្នា ភាវនានេះ ទើបមិនអាចតាំងនៅក្នុងព្រះពុទ្ធគុណ តែម្យ៉ាងប៉ុណ្ណោះបាន ព្រោះសទ្ធា ជាអានិសង្សដែលត្រូវការក្នុងកម្មដ្ឋាននេះ មានកម្លាំងក្នុងកាលព្រះពុទ្ធគុណ ទាំងឡាយប្រាកដ

ដោយប្រចក្ស ដោយកម្លាំងរបស់ភាវនា ។ ក៏ព្រោះហេតុនោះ នោះឯង លោកអាចារ្យទើបពោលថា ព្រោះពេលដែលចិត្តបង្អោនទៅ ( បង្អោនចិត្តជឿ ) ដូច្នេះ ។ លោកអាចារ្យធ្វើពាក្យដេញដោលទុកក្នុងចិត្តថា ប្រសិនបើឈាន ជាឈានដែលដល់ត្រឹមតែឧបចារៈសោត ហៅថា **ពុទ្ធានុស្សតិ** បានដូចម្តេច ដូច្នេះហើយ ទើបពោលថា ឈាននេះនោះ ដូច្នេះជាដើម ។

( ចប់ មហាដីកា )

# អានិសង្សនៃការចម្រើនពុទ្ធានុស្សតិ

*ក៏ឯភិក្ខុដែលប្រកបរឿយៗ នូវពុទ្ធានុស្សតិនេះ រមែងជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែងក្នុងព្រះសាស្តា បានសេចក្តីបរិបូណ៌នៃសទ្ធា សេចក្តីបរិបូណ៌នៃសតិ សេចក្តីបរិបូណ៌នៃបញ្ញា និងសេចក្តីបរិបូណ៌នៃបុណ្យ ជាអ្នកច្រើនទៅដោយបីតិនិងបាមោជ្ជ អត់ធន់ចំពោះសេចក្តីខ្លាច និងសេចក្តីភិតភ័យ អាចអត់ធន់ក្នុងទុក្ខ មានការដឹងថា ដូចបាននៅជាមួយព្រះសាស្តា, ម្យ៉ាងទៀត សូម្បីសរីរៈរបស់លោកដែលពុទ្ធានុស្សតិប្រថាប់នៅ រមែងជាសរីរៈគួរដល់ការបូជាដូចជាព្រះចេតិយ ចិត្តរបស់លោករមែងបង្អោនទៅក្នុងពុទ្ធភូមិ ម្យ៉ាងវិញទៀត ក្នុងកាលមានការជួបនឹងវត្ថុដែលគប្បីកន្លងល្មើស ហិរិឱត្តប្បៈ រមែងប្រាកដដល់លោក បីដូចលោកឃើញព្រះសាស្តានៅចំពោះមុខ ម្យ៉ាងវិញទៀត កាលនៅមិនទាន់សម្រេចគុណដ៏ក្រៃលែងឡើងទៅ លោករមែងមានសុគតិជាទីទៅខាងមុខ ។*

***ព្រោះហេតុនោះឯង អ្នកមានបញ្ញាល្អ គប្បីធ្វើសេចក្តីមិនប្រមាទក្នុងពុទ្ធានុស្សតិ ដែលមានអានុភាពច្រើនយ៉ាងនេះ គ្រប់កាលទៅចុះ ។***

*នេះជាកថាមុខ ( ពាក្យខែសេចក្តីដែលសំខាន់ ) យ៉ាងពិស្តារក្នុងពុទ្ធានុស្សតិជាលំដាប់ដំបូង ។*

## មហាដីកា

*ឈ្មោះថា **រមែងជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែង** ព្រោះព្រះសរីរៈ គឺ ព្រះគុណរបស់ព្រះសាស្តាប្រាកដដោយប្រចក្ស ។ ព្រោះហេតុនោះនោះឯង ទើបឈ្មោះថា **រមែងបានទទួលភាពបរិបូណ៌នៃសទ្ធា** គឺ បានទទួលសទ្ធា*

ដ៏ធំក្រៃលែង ដូចគ្នានឹងការជឿមិនកម្រើករបស់ព្រះអរិយៈទាំងឡាយ ។ ឈ្មោះថា **រមែងបានទទួលភាពសម្បូណ៌នៃសតិ** ព្រោះភាវនាប្រព្រឹត្តទៅដោយទាក់ទងនឹងការរឭករឿយ ៗ ដល់ព្រះពុទ្ធគុណទាំងឡាយ ដែលជាកិច្ចរបស់សតិ ។ ឈ្មោះថា **រមែងបានទទួលការបរិបូណ៌នៃបញ្ញា** ព្រោះព្រះគុណទាំងនោះជ្រាលជ្រៅ ក្រៃលែង និងព្រោះមានច្រើនប្រការ ។ ឈ្មោះថា **រមែងបានទទួលភាពបរិបូណ៌នៃបុណ្យ** ព្រោះព្រះគុណទាំងនោះ ជាខេត្តនៃបុណ្យដ៏ប្រសើរ ។ ឈ្មោះថា **រមែងជាអ្នកច្រើនដោយបីតិ និងបាមោជ្ជ** ព្រោះពុទ្ធានុស្សតិ ជាទីតាំងនៃបីតិសម្មោជ្ជគ្គ ។ ឈ្មោះថា **អត់ធន់ចំពោះសេចក្តីខ្លាចនឹងអារម្មណ៍ដែលគួរខ្លាចបាន** ព្រោះសតិដែលមានព្រះពុទ្ធគុណជាអារម្មណ៍ អាចគ្របសង្កត់ការខ្លាច និង អារម្មណ៍ដែលគួរខ្លាចបាន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ទុកថា ពួកអ្នកគប្បីរឭកដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ចុះ ពួកអ្នកនឹងមិនមានសេចក្តីខ្លាចដូច្នេះ ឈ្មោះថា **អាចអត់ធន់ក្នុងទុក្ខបាន** ព្រោះទុក្ខក្នុងរាងកាយ រំសាយចេញបានដោយពុទ្ធានុស្សតិ ដូចទឹកលើស្លឹកឈូក រមៀលចេញទៅមិនជាប់នៅ ដូច្នោះ ។ បទថា **សំវាសសញ្ញំ** ប្រែថា សេចក្តីសម្គាល់ថានៅរួមគ្នា ។ ឈ្មោះថា **ចិត្តរមែងបង្អោនទៅក្នុងពុទ្ធភូមិ** ព្រោះភាពជាធំក្រៃលែងនៃព្រះពុទ្ធគុណទាំងឡាយ ប្រាកដដោយប្រចក្ស ។ លោកអាចារ្យពោលថា **ដូចឃើញព្រះសាស្តានៅចំពោះមុខ** ព្រោះក្នុងកាលចម្រើនពុទ្ធានុស្សតិព្រះពុទ្ធគុណទាំងឡាយ មានការប្រព្រឹត្តទៅក្នុងចិត្តអស់កាលជានិច្ច ។ ពាក្យថា **កាលនៅមិនទាន់ចាក់ធ្លុះគុណវិសេស ដែលក្រៃលែងឡើងទៅ** គឺ កាលធ្វើភាវនាដែលខ្ពស់ជាងភាវនានេះ ឲ្យជាទីតាំងមាំហើយ ក៏នៅតែចាក់ធ្លុះសច្ចៈទាំងឡាយមិនបាន ។

បទថា **សុគតិបរាយនោ** ប្រែថា មានសុគតិជាទីទៅខាងមុខ ។

ពាក្យថា **សេចក្តីមិនប្រមាទ** បានដល់ ការមិនប្រមាទ គឺ ការប្រកបរឿយៗ យ៉ាងគោរព ។ បទថា **កយិរាថ** បានដល់ **ករេយ្យ** ( គប្បីធ្វើ ) ។ ថា **សុមេធសោ** ប្រែថា លោកអ្នកមានបញ្ញាល្អ ។ ពាក្យថា **ដែលមានអានុភាពច្រើនយ៉ាងនេះ** គឺ ដែលប្រកបព្រមដោយអំណាចដែលធំក្រៃលែង អាចគ្របសង្កត់នីវរណៈជាដើម ជាហេតុនៃការគោរពក្នុងព្រះសាស្តាជាដើម តាមប្រការដែលបានពោលហើយ ។

( ចប់ មហាដីកា - ចប់ ពុទ្ធានុស្សតិ )

# ធម្មានុស្សតិ

សូម្បីព្រះយោគាវចរ ដែលប្រាថ្នានឹងចម្រើនធម្មានុស្សតិ ក៏គប្បីជាអ្នកទៅក្នុងទីស្ងាត់អំពីមនុស្ស សម្ងំនៅក្នុងសេនាសនៈដ៏សមគួរ ហើយរឭកដល់គុណទាំង-ឡាយនៃព្រះបរិយត្តិធម៌ និង ព្រះលោកុត្តរធម៌ ៩ ដោយអនុស្សរណបាឋៈថា ៖

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ
ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ។

## បទថា ស្វាក្ខាតោ

ក៏ក្នុងបទថា **ស្វាក្ខាតោ** នេះ សូម្បីព្រះបរិយត្តិធម៌ក៏សង្គ្រោះចូលដែរ , ក្នុងបទទាំងឡាយក្រៅអំពីនេះ បានដល់ ព្រះលោកុត្តរធម៌តែម្យ៉ាង ក្នុងធម៌ពីរយ៉ាងនោះ ពោលដោយព្រះបរិយត្តិធម៌មុន ។ ព្រះបរិយត្តិធម៌នោះ ឈ្មោះថា **ស្វាក្ខាត** ព្រោះជាធម៌មាន **លំអបទដើម លំអបទកណ្តាល** និង **លំអបទចុង** និងព្រោះជាធម៌ប្រកាសព្រហ្មចរិយៈ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ បរិសុទ្ធបរិបូណ៌អស់ជើង ។

## លំអ បទដើម – កណ្តាល – ចុង

ពិតណាស់ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងព្រះគាថាណា ត្រឹមតែបទមួយ ព្រះគាថានោះ មានលំអបទដើមដោយបាឋដំបូង លំអបទកណ្តាលដោយបាឋទី ២-៣ មានលំអបទចុងដោយបាឋចុងបំផុត ទាំងនេះក៏ព្រោះព្រះធម៌ មានលម្អនៅសព្វអន្លើ , ព្រះសូត្រដែលមានអនុសន្ធិមួយ ក៏មានលំអបទដើម ដោយពាក្យនិទាន មានលំអបទចុងដោយពាក្យនិគម មានលំអបទកណ្តាលដោយពាក្យ

ដ៏សេស , ព្រះសូត្រដែលមានអនុសន្ធិផ្សេងៗ ក៏មានលំអបទដើមដោយអនុសន្ធិដំបូង មានលំអបទចុងដោយអនុសន្ធិខាងចុងបំផុត លំអបទកណ្ដាលដោយអនុសន្ធិដ៏សេស , ម្យ៉ាងទៀត ឈ្មោះថា **មានលំអបទដើម** ព្រោះមានទាំងពាក្យនិទាន និងពាក្យសម្ដែងហេតុកើតឡើងនៃព្រះសូត្រ , ឈ្មោះថា **លំអបទកណ្ដាល** ព្រោះអត្ថន័យមិនវិបរិតទៅ និង ព្រោះប្រកបទៅដោយពាក្យចង្អុលហេតុ និងឧទាហរណ៍តាមសមគួរដល់វេនេយ្យនិករទាំងឡាយ និង ឈ្មោះថា **មានលំអបទចុង** ដោយពាក្យនិគម ដោយញុំាងការបានសទ្ធាឲ្យកើតដល់អ្នកស្ដាប់ទាំងឡាយ ( សូត្រមួយ ឬ រឿងមួយ រមែងមានគោលសេចក្ដីជាកំណាត់កងៗ រៀងតគ្នាទៅ រហូតទាល់តែចប់សូត្រ ឬចប់រឿង តិចកងខ្លះ ច្រើនកងខ្លះ សេចក្ដីមួយកងៗ នោះឯង ហៅថា អនុសន្ធិ ១ , **និទាន** គឺ ពាក្យផ្ដើមព្រះសូត្រ ប្រាប់កាលដែលសម្ដែង ស្ថានទីដែលសម្ដែង អ្នកសម្ដែង និងបរិស័ទ គឺ អ្នកស្ដាប់ជាដើម , **និគម** គឺ ពាក្យចុងបញ្ចប់សូត្រ សំយោគ ឬ សរុបរឿងដែលពោលមក ដើម្បីឲ្យអ្នកស្ដាប់យល់ច្បាស់មុននឹងចប់ ) ។

សាសនធម៌សូម្បីទាំងមូល មានលំអបទដើមដោយសីលដែលជាឫសគល់របស់ខ្លួន មានលំអបទកណ្ដាលដោយសមថវិបស្សនានិងមគ្គផល មានលំអបទចុងដោយព្រះនិព្វាន ដូច្នេះក៏បាន ឬថា មានលំអបទដើមដោយសីលនិងសមាធិ មានលំអបទកណ្ដាលដោយវិបស្សនានិងមគ្គ មានលំអបទចុងដោយ ផលនិងនិព្វាន ឬ មានលំអបទដើម ដោយពុទ្ធសុពោធិតា ( ការត្រាស់ដឹងល្អនៃព្រះពុទ្ធជាម្ចាស់ ) លំអបទកណ្ដាលដោយធម្មសុធម្មតា ( ភាពជាធម៌ល្អនៃព្រះធម៌ ) មានលំអបទចុងដោយសង្ឃសុបដិបត្តិ ( ការបដិបត្តិល្អនៃព្រះសង្ឃ ) ឬ មានលំអបទដើម

ដោយអភិសម្ពោធិ លំអបទកណ្តាលដោយបច្ចេកសម្ពោធិ មានលំអបទចុងដោយសាវកសម្ពោធិ ដែលបុគ្គលអ្នកបានស្តាប់សាសនធម៌នោះហើយ បដិបត្តិដើម្បីភាពជាយ៉ាងនោះ នឹងគប្បីសម្រេចបាន ម្យ៉ាងវិញទៀត សាសនធម៌នោះ កាលបុគ្គលកំពុងស្តាប់ ក៏នាំភាពស្អាតមកឲ្យបានដោយពិត សូម្បីដោយការស្តាប់ ក៏គ្របសង្កត់នីវរណៈបានក្នុងខណៈស្តាប់ ព្រោះហេតុនោះ ទើបឈ្មោះថា **មានលំអបទដើម** , កាលបុគ្គលកំពុងបដិបត្តិ ក៏នាំភាពស្អាតមកឲ្យបាន សូម្បីដោយការបដិបត្តិ ក៏នាំសេចក្តីសុខក្នុងសមថៈ និងសុខក្នុងវិបស្សនាមកឲ្យ ព្រោះហេតុនោះ ទើបឈ្មោះថា **មានលំអបទកណ្តាល** និងកាលបុគ្គលបដិបត្តិហើយយ៉ាងនោះ កាលផលនៃការបដិបត្តិសម្រេចហើយ ក៏រមែងនាំភាពស្អាតមកឲ្យ សូម្បីដោយផលនៃការបដិបត្តិដោយនាំភាពជាតាទិបុគ្គល ( អ្នកមាំទាំមិនញាប់ញ័រ ) មកឲ្យ ព្រោះហេតុនោះទើបឈ្មោះថា **មានលំអបទចុង** ។ **សាសនធម៌** ឈ្មោះថា **ស្វាក្ខាត** ព្រោះជាធម៌ **មានលំអបទដើម មានលំអបទកណ្តាល** និង **មានលំអបទចុង** តាមន័យដូចពោលមកដូច្នេះ ។

## ប្រកាសព្រហ្មចរិយៈ ព្រមទាំងអត្ថ...ព្យញ្ជនៈ

ម្យ៉ាងវិញទៀត ព្រះមានព្រះភាគអង្គនោះ កាលទ្រង់សម្តែងធម៌ ទ្រង់រមែងប្រកាស គឺ ទ្រង់សម្តែងដោយន័យផ្សេងៗ នូវសាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈឯណា សាសនព្រហ្មចរិយៈ និង មគ្គព្រហ្មចរិយៈនោះ ឈ្មោះថា **សាត្ថ** ព្រោះការដល់ព្រមនៃអត្ថ , ឈ្មោះថា **សព្យញ្ជន** ព្រោះការដល់ព្រមនៃព្យញ្ជនៈតាមសមគួរ ។

ឈ្មោះថា **សាត្ថ** ព្រោះប្រកបព្រមទៅដោយអត្ថបទ ( បទសម្តែងអត្ថ ៦ ) គឺ **សង្កាសន** ( សម្តែងសេចក្តីដោយសង្ខេប ) , **បកាសន** ( ផ្តើមសម្តែងជាមាតិកា ) , **វិវរណ** ( ពង្រីកសេចក្តី ) , **វិភជន** ( ចែកសេចក្តី ) , **ឧត្តានីករណ** ( ធ្វើសេចក្តីឲ្យរាក់ ) , **បញ្ញត្តិ** ( តែងសេចក្តីឲ្យយល់ ) ។

ឈ្មោះថា **សព្យញ្ជន** ព្រោះការដល់ព្រមនៃព្យញ្ជនៈ ៦ បទ គឺ **អក្ខរ** ( តួអក្សរ ) , **បទ** ( ពាក្យប្រកបវិភត្តិ ) , **ព្យញ្ជន** ( ពាក្យ ) , **អាការ** ( ការបំបែកពាក្យ ) , **និរុត្តិ** ( វិគ្រោះ ស័ព្ទ ) , **និទ្ទេស** ( ពង្រីកនិរុត្តិឲ្យពិស្តារ ) ។

ឈ្មោះថា **សាត្ថ** ព្រោះជាគុណមានជម្រៅដោយអត្ថ និងជាគុណមានជម្រៅដោយបដិវេធ , ឈ្មោះថា **សព្យញ្ជន** ព្រោះជាគុណមានជម្រៅដោយធម៌ និង ជាគុណមានជម្រៅដោយទេសនា ។

ឈ្មោះថា **សាត្ថ** ព្រោះជាវិស័យនៃអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ឈ្មោះថា **សព្យញ្ជន** ព្រោះជាវិស័យនៃធម្មប្បដិសម្ភិទា និង និរុត្តិប្បដិសម្ភិទា ។

ឈ្មោះថា **សាត្ថ** ហេតុជាគុណញុំាងបរិក្ខជន ( អ្នកមានបញ្ញាស៊ើបសួន ) ឲ្យជ្រះថ្លា ព្រោះជាបណ្ឌិតវេទនីយធម៌ ( សម្រាប់បុគ្គលឈ្លាសវៃ គប្បីដឹងបាន ) , ឈ្មោះថា **សព្យញ្ជន** ហេតុជាគុណញុំាងលោកិយជន ( ជនទូទៅ ) ឲ្យជ្រះថ្លា ព្រោះជាសទ្ធេយ្យធម៌ ( បទដ្ឋាននៃសទ្ធា ) ( មានន័យថា ពួកបុគ្គលឆ្លាតៗ កម្រនឹងជឿ ព្រោះចូលចិត្តប្រើបញ្ញាពិចារណា ធម៌នេះក៏បណ្តុះសេចក្តីជ្រះថ្លាឲ្យកើតដល់ជនពួកនេះបាន ព្រោះធម៌នេះបរិបូណ៌ដោយអត្ថ ដែលកាន់តែពិចារណា ក៏កាន់តែឃើញពិត ចំណែកពួកជនធម្មតា ៗ សូម្បីមិនប្រើបញ្ញា ក៏កើតសេចក្តីជ្រះថ្លាបានដោយព្យញ្ជនសម្បត្តិ គឺ ធម៌នេះ មានព្យញ្ជនៈបរិបូណ៌ល្អមនឹងស្តាប់ឲ្យយល់ចូល

ចិត្ត ជ្រះថ្លា ទាំងដែលមិនចាំបាច់ដឹងសេចក្តី ក៏បាន ) ។

ឈ្មោះថា **សាត្ថ** ព្រោះមានអធិប្បាយ ជ្រាលជ្រៅ , ឈ្មោះថា **សព្យញ្ជន** ព្រោះមានបទរាក់ ( មានសេចក្តីថា បើមានអធិប្បាយរាក់ៗ នឹងសរសើរថា មានអត្ថសម្បត្តិ ដូចម្តេច , ហើយបើមានបទព្យញ្ជនៈជ្រៅ រហូតមិនមាននរណានឹងប្រែចេញ នឹងសរសើរថា មានព្យញ្ជនសម្បត្តិ ដូចម្តេច ) ។

## បរិសុទ្ធបរិបូណ៌អស់ជើង

ឈ្មោះថា **បរិបូណ៌អស់ជើង** ព្រោះជាធម៌ពេញលេញ ដែលមិនមានសេចក្តីនឹងត្រូវបន្ថែមចូល ឈ្មោះថា **បរិសុទ្ធ** ព្រោះជាធម៌រកទោសមិនបាន ដោយមិនមានសេចក្តីដែលនឹងត្រូវកាត់ចេញ ។

## អត្ថន័យមួយន័យទៀត

ន័យម៉្យាងទៀត ឈ្មោះថា **សាត្ថ** ព្រោះមានការប្រសព្វក្នុងអធិគម ( បដិវេធ ) ដោយបដិបត្តិ , ឈ្មោះថា **សព្យញ្ជន** ព្រោះមានការបំភ្លឺក្នុងអាគម ( បរិយត្តិ ) ដោយការរៀនសូត្រ , ឈ្មោះថា **បរិបូណ៌អស់ជើង** ព្រោះប្រកបដោយធម្មក្ខន្ធ ៥ មានសីលក្ខន្ធជាដើម , ឈ្មោះថា **បរិសុទ្ធ** ព្រោះមិនមានឧបក្កិលេស ព្រោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ការចេញចាកវដ្តទុក្ខ និង ព្រោះមិនមានការជាប់ជំពាក់ក្នុងលោកាមិសៈ ដូច្នេះ ។

**បរិយត្តិធម៌** ឈ្មោះថា **ស្វាក្ខាត** ព្រោះប្រកាសព្រហ្មចរិយៈ ព្រមទាំងអត្ថ បរិសុទ្ធបរិបូណ៌អស់ជើង ដោយប្រការដូច្នេះ ។

## បរិយត្តិធម៌ជា ស្វាក្ខាត ន័យម្យ៉ាងទៀត

ឬន័យម្យ៉ាងទៀត បរិយត្តិធម៌នោះ ឈ្មោះថា **ត្រាស់ដោយល្អ** ព្រោះមិនមានអត្ថវិបល្លាស ព្រោះហេតុនោះ ទើបឈ្មោះថា **ស្វាក្ខាត** ( ត្រាស់ដោយល្អ ) , ឯអត្ថន័យនៃធម៌របស់ពួកម្ចាស់លទ្ធិដទៃ ចាត់ថា ដល់នូវភាពវិបល្លាស ព្រោះជាធម៌ដែលគេពោលថា ជាអន្តរាយិកធម៌ទាំងឡាយ មានសភាពជាធម៌ធ្វើអន្តរាយក៏ទេ និងព្រោះជាធម៌ដែលគេពោលថា ជានិយ្យានិកធម៌ទាំងឡាយ នឹងជាធម៌នាំចេញ ( ចាកទុក្ខ ) ក៏ទេ ព្រោះហេតុនោះ ម្ចាស់លទ្ធិដទៃទាំងនោះ ទើបជាអ្នកមានធម៌ជាទុរក្ខាតៈ ( ពោលមិនល្អ ) ពិតយ៉ាងណា អត្ថនៃធម៌របស់ព្រះមានព្រះភាគ ដល់នូវភាពវិបល្លាសក៏ទេ ព្រោះធម៌ដែលព្រះអង្គត្រាស់ថា ធម៌ពួកនេះជាអន្តរាយិកធម៌ ធម៌ពួកនេះជានិយ្យានិកធម៌ ដូច្នេះហើយ នឹងកន្លងភាពជាយ៉ាងនោះទៅមិនមាន ។

ព្រះបរិយត្តិធម៌ជា **ស្វាក្ខាត** ដោយន័យដូចពោលមកដូច្នេះ ចាត់ជាលំដាប់ដំបូង ។

## លោកុត្តរធម៌ជា ស្វាក្ខាត

ចំណែកលោកុត្តរធម៌ ឈ្មោះថា **ស្វាក្ខាត** ព្រោះត្រាស់គោលបដិបត្តិដែលសមគួរដល់ព្រះនិព្វាន និង ព្រះនិព្វានសមគួរដល់គោលបដិបត្តិ ដូចសក្កទេវរាជទ្រង់ពោល ( ក្នុងមហាគោវិន្ទសូត្រ ) ថា ឯបដិបទាដែលឲ្យដល់ព្រះនិព្វាន ព្រះមានព្រះភាគជាម្ចាស់អង្គនោះ ទ្រង់បានបញ្ញត្តទុកល្អហើយ ដល់សាវកទាំងឡាយ ។ **ព្រះនិព្វាន** និង **បដិបទា** រមែងចូលគ្នាបាន ឧបមាដូចទឹកក្នុងទន្លេគង្គា រមែងចូលគ្នា រមែងសមគ្នា ក្នុងទន្លេយមុនា យ៉ាងណាក្តី ឯបដិបទាដែលឲ្យដល់ព្រះនិព្វាន ព្រះមានព្រះភាគជាម្ចាស់អង្គនោះ ទ្រង់បានបញ្ញត្តទុកល្អហើយ ដល់សាវកទាំងឡាយ ។

**ព្រះនិព្វាន** និង **បដិបទា** រមែងចូលគ្នាបានយ៉ាងនោះ ដូច្នេះ , មួយវិញទៀត ក្នុងលោកុត្តរធម៌នោះ អរិយមគ្គដែលជាផ្លូវកណ្ដាល មិនទៅជិតអន្ត: ( ទីបំផុត ) ទាំងពីរនោះឯង ឈ្មោះថា **ស្វាក្ខាត** ព្រោះអរិយមគ្គនោះឯង ទ្រង់ត្រាស់ថា ជាមជ្ឈិមាបដិបទា សាមញ្ញផលទាំងឡាយ ដែលមានកិលេសរំងាប់ហើយនោះឯង ឈ្មោះថា **ស្វាក្ខាត** ព្រោះសាមញ្ញផល ទ្រង់ត្រាស់ថា ជាធម្មជាតិមានកិលេសរំងាប់ហើយ ព្រះនិព្វានដែលមាន សភាពទៀង សភាពមិនស្លាប់ សភាពប្រឆាំង ( នឹងទុក្ខ ) នោះឯង ឈ្មោះថា **ស្វាក្ខាត** ព្រោះព្រះនិព្វាននោះ ទ្រង់ត្រាស់ថា **ទៀង** ជាដើម ដូច្នេះ , សូម្បីលោកុត្តរធម៌ ក៏ជា **ស្វាក្ខាត** ដោយន័យដូចពោលមក ដូច្នេះឯង ។

## មហាដីកា

## អធិប្បាយ ធម្មានុស្សតិ

ក្នុងបទថា **ធម្មានុស្សតិ** នេះ អត្ថនៃបទ និងអត្ថ គឺ សភាវ: លោកបានពោលទុកខាងដើមហើយនោះឯង ព្រោះហេតុនោះ លោកអាចារ្យបំណងសម្ដែងវិធីចម្រើន មិនប៉ះពាល់អត្ថនៃបទ និងអត្ថ គឺ សភាវ:នោះ ទើបផ្ដើមពាក្យថា **ព្រះយោគីសូម្បីប្រាថ្នាចម្រើនធម្មានុស្សតិជាដើម** ។ សួរថា ព្រោះហេតុអ្វី ក្នុងធម្មានុស្សតិនេះ លោកមិនពោលថា អ្នកដល់ព្រមដោយសេចក្ដីជ្រះថ្លាមិនវង្វេស ដូចក្នុងពុទ្ធានុស្សតិផង ។ **អនុស្សតិ ៦** តាមលំដាប់ទាំងនេះ ទ្រង់លើកឡើងកាន់ទេសនា ដោយទាក់ទងនឹងបុគ្គលជាព្រះអរិយសាវកទាំងឡាយ ដែលជាបុគ្គលមានសេចក្ដីជ្រះថ្លា មិនកម្រើក មិនមែនឬ ? ឆ្លើយថា សេចក្ដីដែលពោលមកនេះ ក៏ជាសេចក្ដីពិត សូម្បី

យ៉ាងនេះ តែដើម្បីសម្តែងថា សូម្បីបុថុជ្ជនដែលមានគុណទាំងឡាយ មានសីលជាដើមបរិសុទ្ធ ក៏សម្រេចអនុស្សតិ ៦ បាន ដូច្នេះ លោកទើបមិនពោលពាក្យថា ដែលដល់ព្រមដោយសេចក្តីជ្រះថ្លាមិនកម្រើកទុកក្នុងធម្មានុស្សតិនេះ ចំណែកព្រះអរិយសាវកទាំងឡាយរមែងសម្រេចបានដោយងាយដូច្នេះ ។ ម្យ៉ាងវិញទៀត គប្បីឃើញថា លោកពោលទុកក្នុងពុទ្ធានុស្សតិនេះ ព្រោះមានមកក្នុងព្រះបាលី សូម្បីយ៉ាងនោះ គោលវិចារណ៍នេះនឹងមកដល់ខាងមុខនោះឯង ។

ក្នុងពាក្យថា **សូម្បីព្រះបរិយត្តិធម៌ដោយ បិ ស័ព្ទ** ( ដែលប្រែថា សូម្បី ) លោករួមយកលោកុត្តរធម៌ ។ ពាក្យថា **ក្នុងបទក្រៅអំពីនេះ** គឺ ក្នុងបទថា **សន្ទិដ្ឋិកោ** ជាដើម ។ ពាក្យថា **លោកុត្តរធម៌ប៉ុណ្ណោះ** លោកពោលពាក្យអវធារណៈ ( ពាក្យកំណត់សេចក្តីដែលប្រែថា ប៉ុណ្ណោះ ) សំដៅយកអត្ថនៃបទថា **សន្ទិដ្ឋិកោ** ជាដើម ដោយនិប្បរិយាយ តែបរិយាយអត្ថទាំងនេះ រមែងមានបាន សូម្បីក្នុងព្រះបរិយត្តិនោះឯង ។

ពិតយ៉ាងនោះ **ព្រះបរិយត្តិធម៌** ឈ្មោះថា **សន្ទិដ្ឋិក** ព្រោះអត្ថថា អ្នកមានបញ្ញាជាពហុស្សូត រៀនអាគម ( រៀនបរិយត្តិ ) ដល់ព្រមដោយសតិ និងភាពឈ្លាសវៃដ៏យ៉ាងក្រៃលែង គប្បីឃើញដោយខ្លួនឯង ដោយវិសេសថា មានសភាពជាធម៌ដែលមានលំអបទដើមជាដើម ។ ប្រសិនបើមានពាក្យចោទថា វៀរការអន្ទងជិតអាចារ្យចេញ ព្រះបរិយត្តិធម៌ក៏មិនបាន អត្ថដែលថា ដែលបុគ្គលមានបញ្ញាគប្បីឃើញដោយខ្លួនឯង គឺ មិនរៀនអំពីអាចារ្យមុន ក៏ឃើញមិនបាន ? គប្បីចោទត្រឡប់ទៅវិញថា បើយ៉ាងនោះ ក្នុងព្រះធម៌ សូម្បីដែលជាលោកុត្តរធម៌ ក៏មិនបានអត្ថថា អ្នកមានបញ្ញា គប្បីឃើញដោយខ្លួនឯង ព្រោះសម្រេចបាន ដោយការអាស្រ័យតែ

កល្យាណមិត្តប៉ុណ្ណោះ សូម្បីព្រះសាស្ដា ទ្រង់ឃើញដោយព្រះអង្គឯង ក៏យ៉ាងនោះដូចគ្នា ។ ចំណែកអត្ថថា ឈ្មោះថា **សន្ទិដ្ឋិក** ព្រោះអត្ថថា ឈ្នះដោយ **សន្ទិដ្ឋិ** ( ការឃើញដែលព្រះអរិយៈសរសើរហើយ ) នេះ សម្រាប់ព្រះបរិយត្តិធម៌ រមែងបានព្រោះការញាំញីពួកអន្យតិ្ថយដោយនិប្បរិយាយ រមែងបានព្រោះការឈ្នះកិលេសដោយបរិយាយ ព្រោះជាហេតុបន្តគ្នាទៅ ។ សូម្បីអត្ថដែលថា ឈ្មោះថា **សន្ទិដ្ឋិក** ព្រោះអត្ថថា គួរដល់ **សន្ទិដ្ឋ** ( ការឃើញ ) នេះ ក៏រមែងបានដូចគ្នា ព្រោះព្រះបរិយត្តិធម៌ប្រព្រឹត្តទៅចោះចំពោះយកការលះធម៌ចំណែកសៅហ្មង និងការចម្រើនធម៌ចំណែកផូរផង់ដោយប្រការទាំងពួង ។ ក៏អត្ថនេះ បណ្ឌិតគប្បីជាក់ច្បាស់បានដោយបទព្រះសូត្រទាំងឡាយ មានយ៉ាងនេះថា **ម្នាលនាងគោតមី នាងគប្បីដឹងធម៌ពួកណា ធម៌ពួកនេះប្រព្រឹត្តទៅព្រមដើម្បីមានតម្រេក មិនបានប្រព្រឹត្តទៅព្រមដើម្បីប្រាសចាកតម្រេក ប្រព្រឹត្តទៅដើម្បីការប្រកបទុកក្នុងវដ្ដៈ មិនប្រព្រឹត្តទៅព្រមដើម្បីការប្រាសចាកវដ្ដៈ , ប្រព្រឹត្តទៅព្រមដើម្បីឧបាទាន មិនប្រព្រឹត្តទៅព្រមដើម្បីអស់ឧបាទាន ម្នាលនាងគោតមី នាងគប្បីចាំទុកដោយចំណែកមួយចុះថា នេះមិនមែនធម៌ នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា** ដូច្នេះ និងថា **ម្នាលភិក្ខុទាំងឡាយ សូម្បីធម៌ ពួកអ្នកក៏ត្រូវលះបង់ នឹងពោលទៅថ្វីដល់អធម៌នោះ** ដូច្នេះជាដើម ។ ព្រះបរិយត្តិធម៌ ឈ្មោះថា **អកាលិក** ព្រោះជាឧបាយឲ្យសម្រេចអកាលិកធម៌ ( ព្រះអរិយមគ្គ ) ។ ឈ្មោះថា **ឯហិបស្សិក** ព្រោះអត្ថថា គួរដល់ឯហិបស្សវិធី ការបបួលថា សូមអ្នកទាំងឡាយ ចូរមកមើលចុះ ព្រោះជាធម៌ដែលមានពិត និង ព្រោះជាធម៌ដែលបរិសុទ្ធ ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា **ឱបនយិក** ព្រោះអត្ថថា គួរដល់បុគ្គលដែលត្រូវការចេញចាកទុក្ខ

ក្នុងវជ្ជៈ បង្អោនចូលទៅក្នុងចិត្តរបស់ខ្លួន ឬ បង្អោនចិត្តរបស់ខ្លួនចូលទៅក្នុងព្រះបរិយត្តិធម៌នោះ ។ ឈ្មោះថា **ដែលវិញ្ញូជនទាំងឡាយ** ដែលតាំងក្នុងវិមុត្តាយតនៈ ( ធម៌ជាហេតុនៃការរួចផុតជាប្រធាន ) បានទូវអត្ថវេទ និងធម្មវេទដោយប្រពៃនោះឯង ដោយការសន្សំទុក គប្បីដឹងចំពោះខ្លួន ។ ការធ្វើទុកក្នុងចិត្ត សូម្បីព្រះបរិយត្តិធម៌ ចូលទៅក្នុងបទទាំងឡាយ មានបទថា **សន្ទិដ្ឋិកោជាដើម** តាមប្រការដូចពោលមកនេះ រមែងប្រើបានផងដែរ ។

បទថា **សា** បានដល់ គាថា ។ ពាក្យថា **ព្រោះភាពដែលមានសេចក្តីស្អាតដោយសព្ទអន្ទើ** គឺ ព្រោះមានលំអគ្រប់បទ ។ ពាក្យថា **ព្រះធម៌** បានដល់ ព្រះធម៌ គឺ ពាក្យប្រៀនប្រដៅ ។ ដែលបានឈ្មោះថា បទរួមក្នុងទីនេះ គឺ គាថាអ្វីៗ ដែលក្រៅពីបទរាយ , ក្នុងទីនេះ គឺ **គាថា** រមែងមិនមានដោយបរមត្ថ ក៏ពិត សូម្បីយ៉ាងនោះ ក្នុងបទរាយដែលឃើញបានដោយរូបនៃបទរួមពួកណា មានសមញ្ញាថា **គាថា** លោកអាចារ្យកាលនឹងសម្តែងបទរាយនោះ ដោយលើកឡើងកាន់វោហារនៃបទរួមនោះ ធ្វើឲ្យដូចជារបស់ផ្សេងអំពីបទរាយនោះ ទើបពោលថា **ឈ្មោះថាលំអបទដើម** ដោយបាឋៈដំបូងដូច្នេះជាដើម ។ ពាក្យថា **មានអនុសន្ធិមួយ** នេះ លោកសំដៅយកព្រះសូត្រដែលមានការចែកជាបទ ៗ មិនសូវច្រើន មានអនុសន្ធិមួយ ដោយ **យថានុសន្ធិ** ( ទេសនាតាំងឡើងប្រារព្ធយកធម៌ណាមុនហើយ ទើបប្រព្រឹត្តទៅតាមលំដាប់ពាក្យពោល ដែលមានដោយប្រការនេះ ឈ្មោះថា **យថានុ-សន្ធិ** ) រីឯព្រះសូត្រដែលមានច្រើនអនុសន្ធិក្រៅអំពីនេះ រមែងបានបទទាំងឡាយដែលជាខាងដើម កណ្តាល និងខាងចុង ដោយការចែកជាបទៗ នូវធម៌ដែលគួរសម្តែងនោះ នោះឯងដូច្នេះ ។ ពាក្យថា **ដោយពាក្យនិទាន** គឺ ដោយការចងពាក្យ

និទាន ( ពាក្យពោលសម្តែងហេតុដែលមករបស់ព្រះសូត្រ ) ដែលមានការប្រារព្ធពេលវេលា ស្ថានទី អ្នកសម្តែង បរិស័ទជាដើម ជាលក្ខណៈ ។ ពាក្យថា **ដោយពាក្យនិគម** គឺ ដោយពាក្យថា **ឥទមវោច** ជាដើម ( ពាក្យពោល-ព្រះមានព្រះភាគត្រាស់ព្រះសូត្រនេះហើយ ភិក្ខុទាំងនោះក៏ពេញចិត្តត្រេកអរក្រៃលែងនូវភាសិតរបស់ព្រះមានព្រះភាគ ) ឬដោយសំយោគដល់អត្ថន័យតាមដែលពោលមកហើយ ពាក្យដែលតថាគតពោលហើយឯណា តថាគតពោលពាក្យនេះទុក អាស្រ័យប្រយោជន៍ដូច្នេះ ។

លោកអាចារ្យកាលធ្វើទុកក្នុងចិត្តថា គាថានេះ ( គួរតែជាកថានេះ ) ដោយពិសេសជាការសំវណ្ណនាព្រះសុត្តន្តបិដក ដូច្នេះហើយ ទើបសម្តែងសេចក្តីដែលព្រះធម៌មានលំអបទដើមជាដើម ដោយទាក់ទងនឹងព្រះសុត្តន្តបិដកទុក ឥឡូវនេះបំណងសម្តែងចំពោះព្រះធម៌ដែលមានលំអបទដើមនោះ ដោយទាក់ទងនឹងព្រះសុត្តន្តបិដក និងព្រះវិន័យបិដក ទើបពោលថា ព្រោះជាធម៌ដែលមានទាំងពាក្យនិទាន មានទាំងហេតុឧប្បត្តិ ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ព្រោះជាធម៌ដែលមានទាំងពាក្យនិទាន មានទាំងហេតុឧប្បត្តិ** គឺ ព្រោះជាធម៌ដែលមានពាក្យនិទាន ដោយពាក្យនិទានតាមដែលពោលមកហើយ និង ព្រោះជាធម៌ដែលមានអត្ថន័យ និងហេតុឧប្បត្តិ គឺ មានន័យទាក់ទងនឹងសិក្ខាបទបញ្ញត្តិ និងហេតុឧប្បត្តិនៃសិក្ខាបទបញ្ញត្តិ ។ ពាក្យថា **តាមសមគួរដល់វេនេយ្យសត្វ** គឺ តាមសមគួរដល់វេនេយ្យសត្វ ដែលទ្រង់ប្រោសឲ្យដឹងសិក្ខាបទបញ្ញត្តិ ក្នុងសិក្ខាបទនោះៗ និងដល់វេនេយ្យសត្វ ដែលទ្រង់ប្រកាសព្រះធម៌ទេសនា តាមសមគួរដល់អជ្ឈាស្រ័យនៃវេនេយ្យសត្វ ។ ពាក្យថា **អត្ថ** បានដល់ អត្ថសភាវៈនៃសីលជាដើម ដែលទ្រង់សម្តែង ។

ឈ្មោះថា **ព្រោះប្រកបដោយហេតុ និងឧទាហរណ៍** ព្រោះក្នុងព្រះសូត្រនោះៗ មានការកាន់យកហេតុ និងឧបមាដោយពាក្យថា **តំកិស្ស ហេតុ ?... សេយ្យថាបិ ភិក្ខវេ...** ( សេចក្តីនោះព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជា... ) ដូច្នេះជាដើម ។

លោកអាចារ្យ កាលនឹងសម្តែងភាពដែលព្រះបរិយត្តិធម៌ មានលំអបទដើម កណ្តាល និងបទចុង ទុកដោយទាក់ទងនឹងព្រះសូត្រ និងព្រះវិន័យយ៉ាងនេះហើយ ឥឡូវនេះ បំណងសម្តែងសេចក្តីដែលព្រះបរិយត្តិធម៌ មានលំអបទដើមជាដើមនោះ រួមទាំងបីបិដកចូលជាមួយគ្នា ទើបពោលថា **សកលោបិ** ដូច្នេះជាដើម ក្នុងពាក្យទាំងនោះ ពាក្យថា **សាសនធម៌** បានដល់ ព្រះបរិយត្តិធម៌ ដែលប្រកាសពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ដែលត្រាស់ទុកយ៉ាងនេះថា ៖

**ការមិនធ្វើបាបទាំងពួង ការធ្វើកុសលឲ្យដល់ព្រម ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ដូច្នេះ ។**

ឈ្មោះថា **មានលំអបទដើមដោយសីល** ព្រោះព្រះសាសនាមានសីលជាឫសគល់ ឈ្មោះថា ល្អបទកណ្តាលដោយសមថៈជាដើម ព្រោះសមថៈជាដើមទាំងនោះ ជាបទកណ្តាលនៃព្រះសាសនសម្បត្តិ ។ ឈ្មោះថា **មានលំអបទចុងដោយព្រះនិព្វាន** ព្រោះសម្រេចព្រះនិព្វាននោះហើយ ក៏មិនមានកិច្ចដែលគប្បីធ្វើឲ្យក្រៃលែងឡើងទៀត ។ ដែលបានឈ្មោះថា ការបដិបត្តិត្រូវក្នុងសាសនា រមែងសម្រេចបានដោយបញ្ញា , ឯ សីលនិងសមាធិ ជាឫសគល់នៃបញ្ញានោះ ព្រោះហេតុនោះ លោកទើបពោលថា ឈ្មោះថា មានលំអបទដើមដោយ សីលនិងសមាធិ ដូច្នេះ ។ ចំណែកបញ្ញាមាន ២ យ៉ាង គឺ អនុពោធប្បញ្ញា និង បដិវេធប្បញ្ញា ព្រោះហេតុនោះ

លោកអាចារ្យកាលនឹងកាន់យកបញ្ហា សូម្បីទាំងពីរយ៉ាងនោះ ទើបពោលថា ឈ្មោះថា លំអបទកណ្តាលដោយ វិបស្សនា និង មគ្គ ដូច្នេះ ។ កាលនឹងសម្តែងថា មគ្គនោះមានសេចក្តីសម្រេច គឺ ផល មានកិច្ច គឺ ការធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ តអំពីនោះទៅ ក៏មិនមានកិច្ចដែលត្រូវធ្វើទៀត , ទើបលោកពោលថា ឈ្មោះថា ល្អបទចុងដោយ ផល និង ព្រះនិព្វាន ដូច្នេះ ។ ម្យ៉ាងទៀត ដោយស័ព្ទថា **ផល** លោកពោលដល់សឧបាទិសេសនិព្វាន ដោយស័ព្ទក្រៅអំពីនេះ ( ដោយស័ព្ទថា និព្វាន ) លោកពោលដល់និព្វានក្រៅអំពីនេះ ( អនុបាទិសេសនិព្វាន ) ក៏និព្វាន ទាំងពីរនោះជាទីបំផុតនៃព្រះសាសនសម្បត្តិ ព្រោះហេតុនោះ លោកទើបពោលថា ឈ្មោះថា មានលំអបទចុង ដោយ ផលនិងព្រះនិព្វាន ដូច្នេះ ។

ឈ្មោះថា **ពុទ្ធសុពោធិតា**-ការត្រាស់ដឹងល្អនៃព្រះពុទ្ធជាម្ចាស់ បានដល់ ភាពជាព្រះសម្មាសម្ពុទ្ធ , **សាសនធម៌** ឈ្មោះថា មានលំអបទដើម ដោយពុទ្ធសុពោធិតានោះ ព្រោះមានពុទ្ធសុពោធិតានោះជាដែនកើត ។ ការលះកិលេសបានដោយប្រការទាំងពួង ភាពដូរផង់ និង ភាពបរិបូណ៌ ឈ្មោះថា **ធម្មសុធម្មតា** ( លំអនៃព្រះធម៌ ) ឈ្មោះថា លំអបទកណ្តាលដោយធម្មសុធម្មតានោះ ព្រោះមានធម្មសុធម្មតានោះ ជាសរីរៈ ។ ការបដិបត្តិតាមដែលព្រះសាស្តា ទ្រង់អនុសាសន៍ទុក ឈ្មោះថា **សង្ឃសុបដិបត្តិ** ( ការបដិបត្តិល្អនៃព្រះសង្ឃ ) ឈ្មោះថា លំអបទចុងដោយសង្ឃសុបដិបត្តិនោះ ព្រោះព្រះសាសនា មានការតាំងមាំដោយល្អក្នុងលោកបាន ក៏ដោយសង្ឃសុបដិបត្តិនោះ ។ ពាក្យថា **ព្រះធម៌នោះ** បានដល់ ព្រះធម៌ គឺពាក្យប្រៀនប្រដៅ ។ ពាក្យថា **ដើម្បីភាពជាយ៉ាងនោះ** មានន័យថា ព្រះមានព្រះភាគទ្រង់សម្តែងធម៌ទុក ដើម្បីភាពជាយ៉ាងណា ក៏បដិបត្តិដើម្បីភាពជាយ៉ាងនោះ គឺ

ដើម្បីធ្វើតាមប្រការដែលទ្រង់សម្ដែងនោះ ។ ក៏ពោធិ ( ការត្រាស់ដឹង ) នោះមាន ៣ យ៉ាង គឺ **អភិសម្ពោធិ ១ បច្ចេកពោធិ ១ សាវកពោធិ ១** ដូច្នេះ , ព្រោះការសម្រេចព្រះនិព្វាន ដោយប្រការដទៃអំពីពោធិ ៣ នេះមិនមាន ។ ក្នុងពោធិ ៣ យ៉ាងនោះ លោកពោលដល់ភាពដែលសាសនធម៌ មានលំអបទដើម ទុកដោយពោធិដំបូង ព្រោះជាកំពូលដោយគុណទាំងពួង និងព្រោះជាមូលនៃពោធិ ២ យ៉ាងក្រៅអំពីនេះ លោកពោលដល់ សាសនធម៌ មានលំអបទកណ្ដាលទុកដោយពោធិទី ២ ព្រោះមានភាពជាកណ្ដាលដោយគុណទាំងឡាយ លោកពោលដល់ សាសនធម៌ មានលំអបទចុង ទុកដោយពោធិទី ៣ ព្រោះជាពោធិដែលមានលំដាប់តអំពីពោធិ ទី ២ និង សាសនធម៌មានពោធិទី ៣ នោះ ជាខាងចុង ។

បទថា **ឯសោ** បានដល់ សាសនធម៌ ។ ពាក្យថា **ដោយការសង្កត់នីវរណៈបាន** គឺ ដោយការដែលបុគ្គលតាំងនៅក្នុងវិមុត្តាយតនៈ ( ធម៌ដែលជាហេតុឲ្យរួចផុត ) ជាប្រធានហើយស្ដាប់ព្រះសទ្ធម្ម មានការសង្កត់នីវរណៈទាំងឡាយបាន ។ សេចក្ដីនេះ សមពិតដូចដែលលោកពោលទុកថា ៖

លោកដ៏មានអាយុទាំងឡាយ ព្រះសាស្ដា ឬ សម្ពាញ់ដែលប្រព្រឹត្តព្រហ្មចារ្យ ដែលតាំងនៅក្នុងឋានៈជាគ្រូ រូបណាទីមួយ រមែងសម្ដែងធម៌ដល់ភិក្ខុដោយប្រការណាៗ ភិក្ខុនោះរមែងបានអត្ថវេទ ( សេចក្ដីត្រេកអរដែលអាស្រ័យអត្ថកើតឡើង ) រមែងបានធម្មវេទ ( សេចក្ដីត្រេកអរដែលអាស្រ័យធម៌កើតឡើង ) ក្នុងធម៌នោះ ដោយប្រការនោះៗ ។

ព្រមទាំងទ្រង់ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា សាវករបស់ព្រះពុទ្ធជាម្ចាស់ ដែលជា

ព្រះអរិយៈ ផ្ទៀងសោតៈស្ដាប់ធម៌ ក្នុងសម័យនោះ នីវរណៈ ៥ រមែងត្រូវគេលះបង់បាន ដូច្នេះជាដើម ។

ពាក្យថា ដោយការនាំមកនូវសុខក្នុងសមថៈ និងសុខក្នុងវិបស្សនា គឺដោយការធ្វើសុខក្នុងសមថៈ និងសុខក្នុងវិបស្សនាឲ្យសម្រេច សូម្បីសេចក្ដីនេះក៏សមដូចទ្រង់ត្រាស់ទុកថា ៖

ភិក្ខុនោះស្ងាត់ចាកកាមទាំងឡាយហើយនោះឯង ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយនោះឯង ចូលដល់បឋមជ្ឈានដែលមានវិតក្កៈ មានវិចារៈ មានបីតិ និងសុខដែលកើតអំពីវិវេក ដូច្នេះជាដើម ។

និងទ្រង់ត្រាស់ទុកយ៉ាងនោះដូចគ្នាថា ៖

សព្វៗ កាល កាលដែលភិក្ខុពិចារណាឃើញការកើតឡើង និងការរលត់ទៅនៃខន្ធទាំងឡាយ គេរមែងមានបីតិ និងបាមោជ្ជ ការបានបីតិ និងបាមោជ្ជនោះ ជារបស់អមតៈសម្រាប់ភិក្ខុដែលដឹងច្បាស់ សេចក្ដីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមានដល់ភិក្ខុ ដែលពិចារណាឃើញច្បាស់នូវធម៌ ដោយប្រពៃដូច្នេះ ។

ពាក្យថា ដែលបដិបត្តិហើយដោយប្រការនោះ គឺជាសាសនធម៌ដែលបុគ្គលបដិបត្តិដោយប្រការដែលនាំមកនូវសុខក្នុងសមថៈ និងសុខក្នុងវិបស្សនា ឬដោយប្រការដែលព្រះសាស្ដាទ្រង់អនុសាសន៍ទុក ។ ពាក្យថា ដោយការនាំមកនូវភាពជាបុគ្គលនឹងធឹង គឺដោយការនាំមកនូវភាពជាបុគ្គលនឹងធឹងក្នុងអារម្មណ៍ មានឥដ្ឋារម្មណ៍ជាដើម ដោយអំណាចនៃឆឡង្គុបេក្ខា បានដល់ ការមិនលាបលនទុកដោយលោកធម៌ទាំងឡាយ ។ ប្រកបសេចក្ដីថា ព្រះមានព្រះភាគអង្គនេះ កាលនឹងទ្រង់សម្ដែងធម៌ ដែលមានលំអ ៣ ប្រការ តាមន័យដូចដែលបានពោលមកហើយ គឺ ទ្រង់

ប្រកាសសាសនព្រហ្មចរិយៈ និង មគ្គព្រហ្មចរិយៈណា , ព្រហ្មចរិយៈទាំងពីរនោះ ឈ្មោះថា **សាត្ថ** ព្រោះការដល់ព្រមនៃអត្ថ , ឈ្មោះថា **សព្យញ្ជន** ព្រោះការដល់ព្រមនៃព្យញ្ជនៈតាមសមគួរ ។

ក្នុងពាក្យនោះពោលដោយមិនប្លែកគ្នា សិក្ខា ៣ និងតន្តិធម្ម ( ធម៌ គឺ បែបផែនបរិយត្តិ ) ទាំងមូល ឈ្មោះថា **សាសនព្រហ្មចរិយ** បានដល់ ព្រហ្មចរិយៈដែលព្រះសារីបុត្រសំដៅយក ដូចដែលពោលទុកថា បពិត្រព្រះអង្គដ៏ចម្រើន ព្រហ្មចរិយៈរបស់ព្រះមានព្រះភាគជាម្ចាស់អង្គណា តាំងនៅមិនបានយូរព្រះអង្គ ដូច្នេះជាដើម ។ អរិយមគ្គដែលសង្គ្រោះចូលដោយសិក្ខា ៣ ដែលជាកំពូលនៃសិក្ខាទាំងពួង , ឈ្មោះថា **មគ្គព្រហ្មចារ្យ** បានដល់ ព្រហ្មចារ្យដែលលោកសំដៅយក តាមដែលពោលថា ជាតិអស់ហើយ ព្រហ្មចរិយៈនៅចប់ហើយ កិច្ចដែលគប្បីធ្វើ បានធ្វើហើយដូច្នេះ ។ បទថា **យថានុរូបំ** ប្រែថា តាមសមគួរ ។ ពិតណាស់ សាសន-ព្រហ្មចារ្យដែលមានការសង្គ្រោះបានដោយសិក្ខា ៣ ឈ្មោះថា **សាត្ថ** ព្រោះការដល់ព្រមនៃអត្ថ ។ ក្នុងមគ្គព្រហ្មចរិយៈមិនមានពាក្យដែលត្រូវពោលដល់ឡើយ ។ ពាក្យថា **ព្រោះការដល់ព្រមនៃអត្ថ** គឺ ព្រោះមានអត្ថដែលដល់ព្រម ។ ព្រោះ **សហ** ស័ព្ទក្នុងពាក្យថា **សាត្ថ** ( **សហ + អត្ថ** ) នេះ មានអត្ថថា ដល់ព្រម ។ ឯព្រហ្មចារ្យក្រៅអំពីនេះ ( គឺ ក្នុងលទ្ធិខាងក្រៅ ) ក្នុងកាលមានអត្ថ និង ព្យញ្ជនៈតាមដែលពោលហើយ វិនាសវិញ ក៏មិនឈ្មោះថា **សាត្ថ** និង មិនឈ្មោះថា **សព្យញ្ជន** ។ ចំណែកអាចារ្យពួកណា នឹងពោលចែកក្នុងពាក្យថា **សាត្ថ** និង **សព្យញ្ជន** នេះថា ព្រហ្មចារ្យមានសភាពជាពាក្យពោល , ឈ្មោះថា **សាត្ថ** ( មានអត្ថ ) ដែលមានសភាពជាអត្ថ , ឈ្មោះថា **សព្យញ្ជន** ( មានព្យញ្ជនៈ ) ដូច្នេះ

ពាក្យដែលអាចារ្យទាំងនោះពោលទុកនោះ មិនល្អ ព្រោះព្រះបរិយត្តិធម៌ដែលលោកចែកទុកយ៉ាងនោះមិនមាន ។ ក៏អត្ថនៃស័ព្ទទាំងឡាយ ដល់នូវភាពផ្សេងគ្នាបាន ដូចជាវត្ថុមានរូបដូចគ្នា ។ ពិតហើយ បណ្ឌិតរមែងទទួលបាននូវអត្ថទាំងនោះមិនលាយឡំដោយអត្ថក្នុងផ្លូវលោក ។ ឬ សូម្បីមានសភាពផ្សេងគ្នា ក្នុងពាក្យថា **សព្យញ្ជន** នេះ ប្រសិនបើបំណងយកការប្រកបព្រមគ្នា ( ជាមួយព្យញ្ជនៈ ) ដូចក្នុងប្រយោគថា គេមកព្រមទាំងបុត្រដូច្នេះជាដើម , កាលបើយ៉ាងនេះ ព្រះមានព្រះភាគក៏គួរនឹងទ្រង់សម្តែងដល់ការៈដែលព្រហ្មចារ្យមានអត្ថជាប្រធានថា ម្នាលភិក្ខុទាំងឡាយពួកអ្នកចូរជាអ្នកមានអត្ថជាទីពឹង កុំជាអ្នកមានព្យញ្ជនៈជាទីពឹងឡើយដូច្នេះទុក ។ បើដូច្នោះ **ព្យញ្ជន** ក៏ត្រឹមតែជាវត្ថុដែលប្រកបដោយអត្ថ ដូចក្នុងប្រយោគជាដើមថា **សលោមកោ** ( ដែលមានរោម ) **សបក្ខកោ** ( ដែលមានស្លាប ) ដូច្នោះ ( គឺពោលដល់សត្វជាប្រធាន រោម ឬ ស្លាប ត្រឹមតែជាវត្ថុដែលសត្វមាន ) នៅតែមិនបានកាន់យកការដល់ព្រមនៃព្យញ្ជនៈ ។ ព្រោះដូច្នោះ បណ្ឌិតគប្បីកាន់យកអត្ថន័យតាមន័យដែលលោកពោលទុកក្នុងអដ្ឋកថាប៉ុណ្ណោះចុះ ។

ក្នុងបទថា **សាត្ថំ សព្យញ្ជនំ** នេះ លោកអាចារ្យបំណងសម្តែងអត្ថន័យសូម្បីដោយន័យក្នុងនិទ្ទេសបករណ៍ ទើបពោលថា **សង្កាសន ។ បេ ។ សព្យញ្ជនំ** ដូច្នេះ ។ ក្នុងបទទាំងនោះ ការយល់ព្យញ្ជនៈ និង អត្ថ រមែងសម្រេចបានដោយមានព្យញ្ជនៈជាគន្លង ព្រោះហេតុនោះ ក្នុងនេត្តិបករណ៍ ព្រះមហាកច្ចាយនៈ ទើបលើកព្យញ្ជនបទឡើងសម្តែងមុន ដោយន័យថា អក្ខរបទដូច្នេះជាដើមក៏ពិត សូម្បីដូច្នោះក្នុងវិសុទ្ធិមគ្គនេះ លោកអាចារ្យបំណងសម្តែងអត្ថបទទុំ៖ នោះឯងមុន ព្រោះមកក្នុងព្រះបាលីថា **សាត្ថំ សព្យញ្ជនំ** ដូច្នេះ ទើបពោលថា **សង្កាសន បកាសន** ដូច្នេះ

ជាដើម ។ ក្នុងអត្ថបទទាំងនោះ ការប្រកាស គឺ សម្ដែងដោយបំព្រួញ ឈ្មោះថា **សង្កាសន** ដូចក្នុងប្រយោគថា ម្នាលភិក្ខុទាំងឡាយ **កាលប្រកាន់មាំ ក៏ត្រូវអន្ទាក់របស់មារចងទុក កាលមិនប្រកាន់មាំ ក៏ផុតចាកអន្ទាក់របស់មារ** ដូច្នេះជាដើម ។ ពិតណាស់ ដោយពាក្យពោលត្រឹមប៉ុណ្ណេះ ភិក្ខុនោះ ក៏ចាក់ធ្លុះភាសិតបានហើយ ។ ព្រោះហេតុនោះ ទើបក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គជ្រាបហើយព្រះអង្គ ដូច្នេះជាដើម ។ កាលសម្ដែងជាវារៈដំបូងឈ្មោះថា **បកាសន** ។ ព្រោះថា **ប** ស័ព្ទ ( ក្នុងបទថា **បកាសនា** ) នេះប្រព្រឹត្តទៅក្នុងអត្ថថា ដំបូង ដូចក្នុងពាក្យថា **បញ្ញបេតិ** ( រមែងបញ្ញត្តិ គឺ ឲ្យដឹងជាពាក្យដំបូង ) **បដ្ឋបេតិ** ( រមែងតែងតាំង គឺ តាំងទុកជាវារៈដំបូង ) ជាដើម ។ ក៏ពីរបទនេះ ( គឺ **សង្កាសន** និង **បកាសន** ) ធ្លុះបញ្ចាំងដល់អ្នកដែលមានឥន្ទ្រិយចាស់ក្លា ព្រោះភាពជាឧទ្ទេស ។ ជាសេចក្ដីពិតថា អ្នកដែលមានឥន្ទ្រិយចាស់ក្លា រមែងយល់ក្នុងការបដិបត្តិនៃអត្ថដែលទ្រង់ត្រាស់ទុកដោយសង្ខេប និងជាវារៈដំបូងបាន ពាក្យពោលពង្រីកអត្ថន័យដែលសង្ខេបឲ្យពិស្ដារ និងពាក្យពោលដល់អត្ថន័យដែលបានពោលទៅហើយ មួងទៀត ឈ្មោះថា **វិវរណ** ( បើកផ្សារ ) និង **វិភជន** ( ចែក ) ។ ដូចដែលបានពោលអត្ថន័យដោយសង្ខេប និងតែម្ដងប៉ុណ្ណោះថា ធម៌ដែលជាកុសលមានហើយដូច្នេះហើយ ក៏ពោលដោយទាក់ទងនឹងការបើកផ្សារ និង ដោយទាក់ទងជាមួយការចែកដោយពិស្ដារម្យ៉ាងទៀត ដោយន័យថា ធម៌ដែលជាកុសលដូចម្ដេច ? ក្នុងសម័យណា កាមាវចរកុសលចិត្តកើតឡើងដូច្នេះជាដើម ដូច្នោះ ។ បទទាំងពីរនេះ ( គឺ **វិវរណ** និង **វិភជន** ) សំដៅដល់អ្នកដែលមានឥន្ទ្រិយជាកណ្ដាល ព្រោះជានិទ្ទេស ( ពាក្យអធិប្បាយ ) ។ ការអធិប្បាយអត្ថន័យដែលបានបើកផ្សារហើយ ឲ្យ

ពិស្តារក្រៃលែងឡើង និងការធ្វើឲ្យដឹងដល់ប្រការទាំងឡាយ ក្នុងន័យដែលបានចែកទុកហើយ ដែលជាការធ្វើចិត្តរបស់វេនេយ្យសត្វឲ្យត្រេកអរ ឈ្មោះថា **ឧត្តានីករ-ណា** ( ធ្វើឲ្យរាក់ ) និង **បញ្ញាបនា** ( បញ្ញត្តិ គឺ ធ្វើឲ្យដឹងដោយប្រការទាំងពួង ) ។ ដូចជាកាលដែលបានបើកផ្លូវ និងចែកន័យសេចក្តីដោយន័យថា ផស្សៈរមែងកើតឡើងដូច្នេះជាដើមហើយ ក៏ធ្វើឲ្យរាក់ និងធ្វើឲ្យដឹងដោយប្រការទាំងពួង ដោយន័យថា ផស្សៈក្នុងសម័យនោះ ដូចម្តេច ? ការប៉ះខ្ទប់ កិរិយាដែលខ្ទប់ ភាវៈដែលខ្ទប់ឯណា ក្នុងសម័យនោះ ដូច្នេះជាដើម ។ បទទាំងពីរនេះ ( គឺ **ឧត្តានីករណា** និង **បញ្ញាបនា** ) សំដៅដល់អ្នកដែលមានឥន្ទ្រិយទន់ខ្ចី ព្រោះជាបដិនិទ្ទេស ( អធិប្បាយបទមួយ ៗ ) ។ បាឋៈថា **បញ្ញាបនបដ្ឋបនវិវរណ វិភជន ឧត្តានីករណ បកាសន អត្ថបទ សមាយោគតោ** ដូច្នេះក៏មាន ( ក្នុងវិសុទ្ធិមគ្គជា **សង្កាសន បកាសន វិវរណ វិភជន ឧត្តានីករណ បញ្ញត្តិ អត្ថបទសមាយោគតោ** ) ។

សួរថា ក៏បាឋៈវិកប្បនេះ កើតឡើងបានដូចម្តេច ? ឆ្លើយថា បាឋៈដំបូងកើតឡើងដោយន័យដែលមកក្នុងព្រះបាលីនេត្តិបករណ៍ ។ ពិតណាស់ ក្នុងព្រះបាលីនេត្តិបករណ៍នោះ មានពាក្យពោលមកហើយថា ៖

**អត្ថ** ( ន័យសេចក្តី ) និង **កម្ម** ( ការតាក់តែង ) ទ្រង់សម្តែងខេទុកដោយបទ ៦ ទាំងនេះ គឺ **សង្កាសនា ១ បកាសនា ១ វិវរណា ១ វិភជនា ១ ឧត្តានី-កម្ម ១ បញ្ញត្តិ ១** ។

ដូច្នេះ ក្នុងពាក្យប្រកបសេចក្តីទេសនា ( គោលដឹកនាំទេសនា ) ក៏មានពាក្យពោលមកហើយដោយន័យថា **ឯតស្សេវត្ថស្ស សង្កាសនា បកាសនា** ការសម្តែងដោយបំព្រួញ ការសម្តែងជាវារៈដំបូងនូវអត្ថនេះ នោះឯងដូច្នេះជាដើម ។

ចំណែកបាឋៈក្រោយ កើតឡើងដោយន័យដែលមកក្នុងព្រះសូត្រថា រមែងបញ្ញត្ត រមែងតែងតាំង រមែងបើកផ្សារ រមែងចែក រមែងធ្វើឲ្យរាក់ ពោលថា អ្នកទាំងឡាយចូរពិចារណាមើលចុះដូច្នេះ ។ ក៏បាឋៈទាំងពីរនេះ មានសេចក្ដីផ្សេងគ្នា យ៉ាងនេះក៏ដោយ គ្រាន់តែព្យញ្ជនៈ មិនមែនដោយអត្ថទេ ។ ពិតហើយ ពោលដោយសង្ខេប ការឲ្យដឹងជាពាក្យដំបូង ឈ្មោះថា **បញ្ញាបន** ការតាំងទុកជាវារៈដំបូងនោះ ឯងឈ្មោះថា **បដ្ឋបន** ព្រោះហេតុនោះ បទទាំងឡាយនេះ ទើបមិនផ្សេងគ្នាក្នុងអត្ថ ជាមួយនឹងបទថា **សង្កាសន** និងបទថា **បកាសន** ។ ម្យ៉ាងវិញទៀត អធិប្បាយបានថា បទទី ៦ ក្នុងបាឋៈដំបូង ( តាមព្រះបាលីនេត្តិបករណ៍ ) ដែលលោកហៅថា **បញ្ញាបន** ព្រោះអត្ថថា ធ្វើឲ្យដឹងដោយប្រការទាំងពួង ដូច្នេះ ។ បទទី ៦ នោះមិនបានមានសេចក្ដីផ្សេងពីបទថា **បកាសន** ក្នុងបាឋៈទី ២ ( តាមព្រះសូត្រ ) ព្រោះធ្វើអធិប្បាយថា ជាការប្រកាសទុក ដោយប្រការទាំងពួង ដូច្នេះ ។ ព្រោះហេតុដែលធ្វើឲ្យដឹង និងការប្រកាសមិនឲ្យផ្សេងគ្នា ដោយការបង្ហាញដល់អត្ថ និងការធ្វើចិត្តរបស់វេនេយ្យសត្វទាំងពួងឲ្យត្រេកអរ ការដុសខាត់បញ្ញាឲ្យមុត រមែងកើតបាន ព្រោះឃើញច្បាស់ដល់សភាវៈនៃវត្ថុ ទៅតាមសេចក្ដីពិត ដូច្នេះឯង ។ **ព្រះសាសនា** ឈ្មោះថា **សាត្ថ** ព្រោះអត្ថន័យនៃព្រះបរិយត្តិធម៌ មានរូបជាអត្ថបទ គឺ ព្រោះប្រកបព្រមដោយអត្ថ ៦ បទ តាមដែលពោលហើយនេះ ។

ក្នុងពាក្យថា **ព្រោះការដល់ព្រមនៃ អក្ខរ បទ ព្យញ្ជនៈ អាការ និរុត្តិ និង និទ្ទេស** នេះ មានវិនិច្ឆ័យដូច្នេះ **វណ្ណៈ** ( រូបស័ព្ទ ) ក្នុងបទដែលពោលមិនទាន់ចប់ ក្នុងពេលបន្ទឺសំឡេង ឈ្មោះថា **អក្ខរ** ។ អាចារ្យពួកមួយពោលថា បទដែលមានអក្ខរៈមួយ ក៏ឈ្មោះថា **អក្ខរ** ដូច្នេះ , ដូចជា **អា** អក្សរជាដើម ក៏ក្នុងពាក្យថា

**អា ឯវំ កិរ តំ** ជាដើម ។ អាចារ្យមួយពួកទៀត ពោលថា **ស័ព្ទ** ឈ្មោះថា **អក្ខរ** ព្រោះអាស្រ័យចិត្តរបស់អ្នកដែលមានឋានកបរិសុទ្ធ ក៏ជាហេតុមិនសាបសូន្យ នៃវាចាទេសនា ។ រូបស័ព្ទដែលមានវិភត្តិជាទីបំផុត ឈ្មោះថា **បទ** ព្រោះធ្វើឲ្យដឹងអត្ថ ។ ឈ្មោះថា **ព្យញ្ជនៈ** ព្រោះអត្ថថា ធ្វើអត្ថដែលបានពោលទុកដោយសង្ខេប ដែលបានប្រកបទុកដោយបទ ឲ្យជាក់ច្បាស់ បានដល់ **ពាក្យ** ។ ក៏អាចារ្យច្រើននាក់ពោលថា កិរិយាបទដែលប្រកបដោយ **អព្យយ ស័ព្ទ ការក** និង **វិសេសន** ឈ្មោះថា **ពាក្យ** ដូច្នេះ ។ ការចែកពាក្យដោយប្រការទាំងពួង ឈ្មោះថា **អាការ** ។ ពាក្យខៃសេចក្តីដែលរៀបចំទុកដោយអាការ ឈ្មោះថា **និរុត្តិ** ។ ពាក្យអធិប្បាយពាក្យខៃសេចក្តីដោយពិស្តារ ឈ្មោះថា **និទ្ទេស** ព្រោះជាការចង្អុលបង្ហាញមិនឲ្យសល់ ។ ព្រហ្មចារ្យ ឈ្មោះថា **សព្យញ្ជនៈ** ព្រោះជាការដល់ព្រមដោយសម្បត្តិនៃ **ព្យញ្ជនៈ បទ** មាន **អក្ខរ** ជាដើមទាំងនេះ ។

ក្នុងពាក្យថា **សាត្ថ** និង **សព្យញ្ជនៈ** សេចក្តីប្រកបព្រមដោយអត្ថបទ និងការដល់ព្រមដោយព្យញ្ជនៈនោះ របស់ព្រហ្មចារ្យនេះ រមែងសម្តែងន័យសេចក្តីបំព្រួញដោយអក្ខរៈ រមែងសម្តែងជាវារៈដំបូងដោយបទ រមែងបើកផ្សាយ អធិប្បាយសេចក្តីដោយព្យញ្ជនៈ រមែងចែកដោយអាការ រមែងធ្វើឲ្យវាក់ដោយនិរុត្តិ រមែងបញ្ញត្តដោយនិទ្ទេស , ម្យ៉ាងវិញទៀត រមែងឧទានឡើងដោយអក្ខរៈ ហើយដឹកនាំឧគ្ឃដិតញ្ញូបុគ្គលដោយបទ , រមែងចែកដោយព្យញ្ជនៈ ហើយដឹកនាំវិបចិតញ្ញូបុគ្គលដោយអាការ , រមែងនាំចេញដោយនិរុត្តិ ហើយដឹកនាំនេយ្យបុគ្គលដោយនិទ្ទេស ។ ក៏ព្រះធម៌ដែលទ្រង់ឧទានឡើងយ៉ាងនោះ រមែងដឹកនាំឧគ្ឃដិតញ្ញូបុគ្គល , ដែលត្រូវចែក រមែងដឹកនាំវិបចិតញ្ញូបុគ្គល , ដែលត្រូវនាំចេញ ក៏រមែងដឹកនាំនេយ្យបុគ្គល

បាន ។ ក្នុងអាការទាំងនោះ ការឧទានមានក្នុងខាងដើម ការចែកមានក្នុងកណ្ដាល ការនាំចេញមានក្នុងខាងចុង ។ ព្រះធម៌ដែលទ្រង់សម្ដែងទុកដោយអាការ ៣ ក្នុងកាលទាំង ៣ យ៉ាងនេះ រមែងជាគ្រឿងញ៉ាំញីនូវទោសទាំង ៣ ជាហេតុនាំមកនូវគុណទាំង ៣ ជាគ្រឿងដឹកនាំវេនេយ្យសត្វ ៣ ជំពូកដូច្នេះ ។ ព្រះធម៌ដែលមានលំអ ៣ ប្រការនេះ គប្បីជ្រាបថា ឈ្មោះថា **សាត្ថ សព្យញ្ជន** ព្រោះការបរិបូណ៌នៃអត្ថ និង ព្យញ្ជនៈ និង គប្បីជ្រាបថា ឈ្មោះថា **បរិបូណ៌បរិសុទ្ធ** តាមប្រការដែលពោលមកនេះ ។

ក្នុងពាក្យថា **ការជ្រាលជ្រៅនៃអត្ថ** ជាដើម ឈ្មោះថា **អត្ថ** បានដល់ អត្ថនៃតន្តិ ។ **ព្រះធម៌** ( ព្រះបរិយត្តិធម៌ ) ឈ្មោះថា **តន្តិ** ។ ឈ្មោះថា **បដិវេធ** បានដល់ ការដឹងតាមសេចក្ដីពិតនូវតន្តិ និង អត្ថនៃតន្តិ ។ ឈ្មោះថា **ទេសនា** បានដល់ ការសម្ដែងតន្តិដែលបានកំណត់ទុកហើយដោយចិត្ត ។ ក៏អត្ថជាដើមទាំងនោះ ព្រោះហេតុដែលបុគ្គលមានបញ្ញាទន់ខ្សោយ ឈានចុះកាន់បានដោយលំបាក ដូចមហាសមុទ្រដែលសត្វតូច មានទន្សាយជាដើម ឈានចុះបានដោយលំបាកដូច្នេះ នឹងជាទីតាំង ជាទីពឹង ឬដែលគប្បីពឹង ដែលបុគ្គលមានបញ្ញាទន់ខ្សោយ មិនអាចរកបានដូច្នោះ ទើបឈ្មោះថា **មានជម្រៅ** ។ ន័យម្យ៉ាងទៀត ឈ្មោះថា **អត្ថ** បានដល់ ផលនៃហេតុ ។ ឈ្មោះថា **ធម៌** បានដល់ ហេតុ ។ ឈ្មោះថា **ទេសនា** បានដល់ បញ្ញត្តិ គឺ ការពោលធម៌តាមសមគួរដល់ធម៌ ឬ ការពោលដោយទាក់ទងជាអនុលោម បដិលោម សង្ខេប និង ពិស្ដារជាដើម ។ ឈ្មោះថា **បដិវេធ** បានដល់ ការត្រាស់ដឹង គឺ ការដឹងក្នុងធម៌ទាំងឡាយតាមសមគួរដល់អត្ថ ក្នុងអត្ថទាំងឡាយតាមសមគួរដល់ធម៌ ក្នុងបញ្ញត្តិទាំងឡាយតាមសមគួរដល់បញ្ញត្តិនិងអត្ថ , ម្យ៉ាងទៀត បាន

ដល់ សភាវៈដែលមិនវិបរិត ពោលគឺ លក្ខណៈរបស់ខ្លួនដែលគប្បីចាក់ធ្លុះនៃធម៌ទាំងនោះ ។ ក៏អត្ថដែលសំដៅដល់ផលនៃហេតុជាដើមទាំងនេះ នោះ ព្រោះហេតុដែលបុគ្គលខ្សោយបញ្ញា អ្នកមិនបានសន្សំកុសលសម្ភារៈទុក ដឹងបានដោយលំបាក ដូចមហាសមុទ្រដែលសត្វ មានទន្សាយជាដើម ចុះកាន់បានដោយលំបាកដូច្នោះ នឹងជាទីតាំង ឬទីពឹង ដែលបុគ្គលខ្សោយបញ្ញាមិនអាចរកបាន ដូច្នោះ ទើបឈ្មោះថា **មានជម្រៅ** ។ លោកពោលថា ឈ្មោះថា **សាត្ថ** ព្រោះមានជម្រៅនៃអត្ថ និងជម្រៅនៃបដិវេធដូច្នេះ ព្រោះសូម្បីការចាក់ធ្លុះក្នុងធម៌ទាំងនោះ ក៏ត្រូវអាស្រ័យអត្ថដោយការសម្តែងដល់គុណនៃអត្ថ ។ លោកពោលថា ឈ្មោះថា **សព្យញ្ជន** ព្រោះមានជម្រៅនៃធម៌ និងជម្រៅនៃទេសនា ដូច្នេះទុក ព្រោះធម៌ និងទេសនាទាំងនោះអាស្រ័យព្យញ្ជនៈ ព្រោះធម៌ និង ទេសនាទាំងនោះ សម្តែងអំពីការដល់ព្រមនៃព្យញ្ជនៈ ។

**ញាណ** ដែលបែកធ្លាយក្នុងអត្ថទាំងឡាយ ឈ្មោះថា **អត្ថប្បដិសម្ភិទា** , **ញាណ** ដែលបែកធ្លាយក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និង និរុត្តិប្បដិសម្ភិទា ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ព្រោះហេតុនោះ ព្រោះបដិភាណប្បដិសម្ភិទានេះ ក៏មានអត្ថជាអារម្មណ៍បាន លោកទើបពោលថា ឈ្មោះថា **សាត្ថ** ព្រោះជាអារម្មណ៍របស់អត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ដូច្នេះ ព្រោះកាលមិនមានការដល់ព្រមនៃអត្ថ អត្ថប្បដិសម្ភិទា និង បដិភាណប្បដិសម្ភិទានោះ ក៏មិនមាន ។ **តន្តិ** គឺ ព្រះបរិយត្តិដែលជាបែបផែន ឈ្មោះថា **ធម៌** ។ ពាក្យពោលអធិប្បាយបទទាំងឡាយនៃតន្តិ ឈ្មោះថា **និរុត្តិ** ។ **ញាណ** ដែលបែកធ្លាយក្នុងធម៌ និងនិរុត្តិនោះ ឈ្មោះថា ធម្មប្បដិសម្ភិទា និង និរុត្តិប្បដិសម្ភិទា ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា

ឈ្មោះថា **សព្យញ្ជន** ព្រោះជាអារម្មណ៍របស់ធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិសម្ភិទា នេះ ព្រោះកាលមិនមានការដល់ព្រមនៃព្យញ្ជនៈ ធម្មប្បបដិសម្ភិទា និង និរុត្តិប្ប-ដិសម្ភិទា ក៏មិនមាន ។ **ឥតិ** សព្ទ ក្នុងបទថា **បរិក្ខកជនប្បសាទកន្តិ** នេះ មានអត្ថថា ហេតុ ។ ជាការអនុមានដល់ហេតុ ដោយសារផល ដូចអនុមានដល់ការប្រព្រឹត្តទៅរបស់ភ្លៀងខាងលើ ដោយស្ទឹងដែលពេញប្រៀប ថា ព្រោះហេតុដែលគុណ-ជាតិនាំមកនូវភាពថ្លាដល់ជនដែលមានបញ្ញាស៊ើបសួន គឺ កំពុងស្វែងរកថា អ្វីជាកុសល ដូច្នោះ ទើបឈ្មោះថា **សាត្ថ** គឺ ដល់ព្រមដោយអត្ថដូច្នេះ ។ ក៏ការដល់ព្រមដោយអត្ថនៃព្រហ្មចារ្យនេះ រមែងប្រព្រឹត្តទៅដើម្បីជាវត្ថុដែលបណ្ឌិតគប្បីដឹង , ភាពជាវត្ថុដែលបណ្ឌិតគួរដឹងនោះ គប្បីជ្រាបបាន ព្រោះជាគុណជាតិជ្រាលជ្រៅល្អិតល្អន់ ដ៏យ៉ាងក្រៃលែង ។ សេចក្ដីនេះសមពិត ដូចទ្រង់ត្រាស់ទុកថា **គម្ភីរោ ទុទ្ទសោ** ធម៌ដែលតថាគតសម្រេចហើយនេះ ជ្រាលជ្រៅ ឃើញបានដោយកម្រ ដូច្នេះជាដើម ។ ពាក្យថា **ជាគុណជាតិធ្វើលោកិយជនឲ្យជ្រះថ្លា** ហេតុនោះ ទើបឈ្មោះថា **សព្យញ្ជន** មានសេចក្ដីថា ព្រោះហេតុដែលជាគុណជាតិនាំមកនូវសេចក្ដីជ្រះថ្លាដល់លោកិយជន ដូច្នោះ ទើបឈ្មោះថា **សព្យញ្ជន** ។ ពិតណាស់ លោកិយជន រមែងត្រេកអរបាន ព្រោះការដល់ព្រមនៃព្យញ្ជនៈ សូម្បីក្នុងសេចក្ដីនេះ ក៏ជាការអនុមានដល់ហេតុព្រោះផល ។ ឯការដល់ព្រមដោយព្យញ្ជនៈ នៃព្រហ្មចរិយៈនេះ រមែងប្រព្រឹត្តទៅដើម្បីជាទីតាំងនៃសទ្ធា ភាពជាទីតាំងនៃសទ្ធានោះ គប្បីជ្រាបបានដោយភាពជាគុណជាតិដែលមានលំអបទដើម ជាដើម ។

ន័យម្យ៉ាងទៀត គប្បីឃើញអត្ថន័យ ក្នុងពាក្យថា **សាត្ថ សព្យញ្ជន** សូម្បីយ៉ាងនេះថា ពាក្យថា **ឈ្មោះថា សាត្ថ** ជាវត្ថុដែលបណ្ឌិតគប្បីដឹង លោកពោល

ដល់ភាវៈដែលដល់ព្រមដោយអត្ថ ដោយភាពជាបទដ្ឋាននៃបញ្ញា ព្រោះហេតុដែលដល់ព្រមដោយអត្ថនោះ ទើបជាគុណជាតិធ្វើជនដែលមានបញ្ញាពិចារណាឲ្យជ្រះថ្លា , ពាក្យថា **ឈ្មោះថា សព្យញ្ជន** ដោយជាទីតាំងនៃសទ្ធា លោកពោលដល់ភាវៈដែលដល់ព្រមដោយព្យញ្ជនៈ ដោយភាពជាបទដ្ឋាននៃសទ្ធា ព្រោះហេតុដែលដល់ព្រមដោយព្យញ្ជនៈនោះ ទើបជាគុណជាតិធ្វើលោកិយជនឲ្យជ្រះថ្លាដូច្នេះ ។ ពាក្យថា **ឈ្មោះថា សាត្ថ** ព្រោះមានពាក្យអធិប្បាយជ្រាលជ្រៅ គឺ ដល់ព្រមដោយអត្ថ ព្រោះមិនទាន់ដល់ត្រើយដោយពាក្យអធិប្បាយ ព្រោះបើនឹង កាន់យកសេចក្តីដោយប្រការដទៃ ក្នុងកាលមានពាក្យអធិប្បាយរាក់ ការដល់ព្រមដោយអត្ថនោះ ក៏មិនមាន ។ ពាក្យថា **ឈ្មោះថា សព្យញ្ជន** ព្រោះមានបទរាក់ គឺ ដល់ព្រមដោយព្យញ្ជនៈ ព្រោះមានសព្ទដែលឲ្យដឹងបានងាយ ដោយការធ្វើអត្ថ សូម្បីដ៏ជ្រាលជ្រៅយ៉ាងក្រៃលែង ឲ្យដល់ភាវៈដែលវេនេយ្យសត្វអាចដឹងបានដោយងាយ ។ បណ្ឌិតគប្បីឃើញប្រភេទនៃអត្ថទាំងពីរបទដំបូងនេះ គឺ អត្ថន័យនៃបទថា **សាត្ថ** និងបទថា **សព្យញ្ជន** សូម្បីទាំងអស់ នឹងគប្បីឃើញតាមដែលលោកសម្តែងវណ្ណនាទុកក្នុងទីនោះៗ ។ ពិតហើយ ក្នុងពាក្យថា **សាត្ថំ សព្យញ្ជនំ** នេះ លោកមិនបានកាន់យកស័ព្ទវិកប្ប ( **វា** ស័ព្ទ ) ឬស័ព្ទសមុច្ចយ ( **ច** ស័ព្ទ ) ទុក ។ ពាក្យថា **ធម៌ដែលគប្បីនាំចូលទៅបន្ថែម** គឺ ដោយមិនមានធម៌ចំណែកបរិសុទ្ធ ដែលមិនទាន់បានពោលទុក គប្បីដាក់ចូលទៅ ។ ពាក្យថា **ព្រោះភាវៈដែលបរិបូណ៌អស់ជើង** គឺ ព្រោះភាវៈដែលបរិបូរណ៍ដោយចំណែកទាំងពួង ។ ពាក្យថា **ធម៌ដែលគប្បីលះបង់** បានដល់ ធម៌ចំណែកសៅហ្មង ។

ពាក្យថា **ព្រោះមានការបដិបត្តិ** គឺ ព្រោះមានការបដិបត្តិត្រូវ មានសីល-

វិសុទ្ធិជាដើម បានដល់ ព្រោះមានការបដិបត្តិត្រូវនោះ ជាហេតុ ។ ពាក្យថា **មានការជាក់ច្បាស់ក្នុងអធិគម** គឺ មានការឈ្លាសក្នុងអធិគម ដោយការចាក់ធ្លុះសច្ចៈ ព្រោះធ្វើអធិប្បាយថា ឈ្មោះថា **សាត្ថ** គឺ ដល់ព្រមដោយអត្ថ មិនជាព្រហ្មចារ្យដែលទទេ គ្មានអត្ថដូចលទ្ធិកបិល គឺ លទ្ធិជជុះសំរាមជាដើម ។ ពាក្យថា **ព្រោះមានការរៀនបរិយត្តិ** គឺព្រោះមានការសន្សំព្រះបរិយត្តិធម៌ ។ ពាក្យថា **មានការជាក់ច្បាស់ក្នុងអាគម** មានសេចក្ដីថា ឈ្មោះថា **សព្យញ្ជន** ព្រោះមានការឈ្លាស គឺ ភាពជាពហុស្សូត មិនធ្វើភាពវង្វេងឲ្យកើតឡើង ដូចដែលកើតឡើងដល់បុគ្គលដែលធ្វើការសន្សំក្នុងធម៌ ដែលគេពោលទុកមិនល្អ ។ ពិតណាស់ កាលមានការដល់ព្រមដោយព្យញ្ជនៈ ក៏មានការជាក់ច្បាស់ក្នុងអាគមបាន ។ ពាក្យថា **ព្រោះប្រកបដោយព្រះធម្មក្ខន្ធ ៥ មានសីលជាដើម** គឺ ព្រោះភាពដែលមិនវៀរចាកធម៌ ៥ ចំណែក មានសីលជាដើម ។ ឈ្មោះថា **កេវលបរិបុណ្ណំ** គឺ ពោលប្រៀបដល់ភាពពេញប្រៀបដោយសព្វអន្លើ មិនមានសល់ ។ ពាក្យថា **ព្រោះប្រាសចាកឧបក្កិលេស** គឺ ព្រោះមិនមានឧបក្កិលេស មាន ទិដ្ឋិ មានះ ជាដើម ។ ពាក្យថា **ដើម្បីដកចេញ** គឺ ដើម្បីរលាស់ចេញចាកវដ្ដទុក្ខ ។ ពាក្យថា **ព្រោះមិនមានការសម្លឹងដល់លោកាមិសៈ** គឺ ព្រោះមិនអាស្រ័យនូវទីអាស្រ័យ គឺ តណ្ហា សូម្បីណាៗ ។

លោកអាចារ្យកាលបើកផ្លូវភាពជា **ស្វាក្ខាត** នៃព្រះធម៌ទុកដោយអំណាចនៃវេសារជ្ជញ្ញាណពីរខាងដើមរបស់ព្រះសាស្ដា ដោយការប្រារព្ធដល់ភាពជាធម៌មានលំអបទដើមជាដើមយ៉ាងនេះហើយ ឥឡូវនេះ បំណងសម្ដែងភាពជាស្វាក្ខាតៈនោះ សូម្បីដោយអំណាចនៃវេសារជ្ជញ្ញាណពីរខាងចុង ទើបពោលថា ម្យ៉ាងទៀតព្រះធម៌

ឈ្មោះថា **ស្វាក្ខាត** ព្រោះអត្ថថា ត្រាស់ទុកដោយល្អ ដោយមិនមានការឃៀងឃ្លាតនៃអត្ថដូច្នេះ កាលនឹងបើកផ្លូវអត្ថន័យនោះ ដោយពាក្យផ្ទុយគ្នាជាមុខ ទើបពោលថា **យថាហិ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ដល់នូវភាពឃៀងឃ្លាត** មានសេចក្តីថា ដល់នូវភាពឃៀងឃ្លាត ព្រះធម៌មានវិបាកជាដើម ដែលពួកអន្យតិត្ថិយទាំងនោះពោលទុកថា ជាធម៌ដែលមានអន្តរាយ នឹងមានភាពជាធម៌ដែលមានអន្តរាយក៏ទេ ព្រោះមិនមានភាពជាហេតុចូលដល់អបាយតែម្យ៉ាង ។ ពាក្យថា **ព្រោះមិនមែនជានិយ្យានិកធម៌** គឺ ជាធម៌ដែលវិបរិតតែម្យ៉ាង ព្រោះធម៌មានការធ្វើយញ្ញខ្លះៗ ប្រក្រតី បុរស អន្តរញ្ញាណ ជាដើមដែលពោលថា នាំចេញដោយជា **អត្តម្មយតា** ( ជាបដិបក្ខចំពោះតណ្ហា ) និងនាំចេញចាកសង្សារវដ្ត និងមិនមែនជាធម៌ដែលនាំចេញដោយជាអត្តម្មយតា និងនាំចេញចាកសង្សារវដ្តនោះ ។ ពាក្យថា **ព្រោះហេតុនោះ** គឺ ព្រោះការដល់ភាពឃៀងឃ្លាតនៃអត្ថ ។ ពាក្យថា **អ្នកទាំងនោះ** បានដល់ ពួកអន្យតិត្ថិយ ។ ពាក្យថា **ព្រោះមិនផុតចាកភាពយ៉ាងនោះទៅបាន** គឺ ព្រោះអន្តរាយ ៥ យ៉ាង មានកម្មន្តរាយ ( អន្តរាយ គឺ កម្ម ) ជាដើម មិនផុតចាកភាពជាធម៌ដែលមានអន្តរាយទៅបានឡើយ , រីឯ អរិយមគ្គធម៌ទាំងឡាយ ក៏ជានិយ្យានិកធម៌ គ្រប់កាលទាំងពួង ។

ពាក្យថា **ការបដិបត្តិដ៏សមគួរដល់ព្រះនិព្វាន** ប្រកបសេចក្តីថា ព្រោះត្រាស់ដល់ការបដិបត្តិត្រូវ ព្រមទាំងការបដិបត្តិដែលជាបុព្វភាគ ដែលជាឧបាយរលាស់ចេញចាកសង្ខារទាំងពួង សមគួរដល់ព្រះនិព្វាន ដែលរលាស់ចេញចាកសង្ខតធម៌ទាំងពួង ដែលនឹងគប្បីសម្រេច ។ ពាក្យថា **ដែលសមគួរដល់ការបដិបត្តិ** មានន័យថា ការបដិបត្តិណា ជាការបដិបត្តិដែលនាំចេញចាកទុក្ខទាំងពួង មានភាពជាធម្មជាតិ

ដែលកិលេសទាំងឡាយប្រកាន់ទុកមិនបាន សូម្បីដោយគ្រាន់តែធ្វើឲ្យជាអារម្មណ៍ , លោកុត្តរធម៌ ឈ្មោះថា **ស្វាក្ខាត** ព្រោះត្រាស់ដល់ព្រះនិព្វាន ដែលសមគួរដល់ការបដិបត្តិ ដូច្នេះ ។ ពាក្យថា **ទ្រង់បញ្ញត្តទុកល្អហើយ** គឺ បដិបទាដែលសង្គ្រោះដោយខន្ធ ៣ មានសីលជាដើម មានប្រភេទសម្មាទិដ្ឋិជាដើម ទ្រង់រៀបចំទុកល្អ គឺដោយប្រពៃហើយនោះឯង ជាធម៌ដែលលះមិច្ឆាទិដ្ឋិជាដើមបាន ។ ឈ្មោះថា **ប្រៀបផ្ទឹមគ្នាបាន** គឺ ស្មើដូចគ្នាបានដោយភាវៈដែលបរិសុទ្ធចាកមន្ទិល គឺ កិលេស ។ លោកអាចារ្យកាលសម្ដែងភាវៈដែល មគ្គនិងព្រះនិព្វាន ជា **ស្វាក្ខាតធម៌** ព្រោះសមគួរដល់គ្នានិងគ្នា គឺ ជាការបដិបត្តិ និងជាធម៌ដែលគប្បីទៅដល់យ៉ាងនោះហើយ ឥឡូវនេះបំណង សម្ដែងនូវលោកុត្តរធម៌ទាំង ៣ យ៉ាង ជាស្វាក្ខាតធម៌ តែម្យ៉ាងទើបពោលថា ម្យ៉ាងវិញទៀត ក្នុងបណ្ដាលោកុត្តរធម៌ទាំងនេះ អរិយមគ្គជាដើម ដូច្នេះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ចំណែកទាំងពីរ** បានដល់ ចំណែកទាំងពីរដែលមានប្រភេទយ៉ាងនេះ គឺ សស្សតៈនិងឧច្ឆេទៈ កាមសុខល្លិកានុយោគៈនិងអត្តកិលមថានុយោគៈ ការរួញរានិងការរាយមាយ ការព្រងើយនិងការខ្វល់ខ្វាយ ដូច្នេះ ។ បទថា **អនុបគម្ម** ប្រែថា មិនជាប់ជំពាក់ ឬប្រែថា ព្រោះការមិនជាប់ជំពាក់ជាហេតុ ។ ពាក្យថា **បដិបស្សទ្ធកិលេស** មានកិលេសដែលរំងាប់ហើយ គឺមានកិលេសដែលស្ងប់ដោយល្អហើយ បានដល់ មានទោសលះបង់បានដោយប្រពៃហើយ ដោយអំណាចនៃបដិបស្សទ្ធិប្បហាន ។ ពាក្យថា **ដោយទាក់ទង មានសភាវៈដែលឋិតថេរជាដើម** គឺ ដោយទាក់ទងនឹងព្រះតម្រាស់លើកសរសើរ ដល់ភាពជារបស់ឋិតថេរជាដើម ទុកក្នុងព្រះសូត្រទាំងឡាយនោះៗ ដោយពាក្យថា ៖

**ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងធម៌ដែលឋិតថេរជាអមតៈ ជាទីពឹង**

និងជាទីពួនសម្ងំដល់អ្នកទាំងឡាយ ដូច្នេះជាដើម ។

( ចប់ មហាដីកា )

# បទថា សន្ទិដ្ឋិកោ

ចំណែកវិនិច្ឆ័យក្នុងបទថា **សន្ទិដ្ឋិកោ** នេះ គប្បីជ្រាបដូចតទៅនេះ ៖

## ន័យទី ១ – ឃើញច្បាស់ដោយខ្លួនឯង

**អរិយមគ្គ** ឈ្មោះថា **សន្ទិដ្ឋិកោ** ព្រោះជាធម៌ដែលព្រះអរិយបុគ្គល អ្នកធ្វើភាពមិនមានកិលេស មានរាគៈជាដើម ក្នុងសន្តានរបស់ខ្លួន គប្បីឃើញដោយខ្លួនឯង ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលព្រាហ្មណ៍ បុគ្គលដែលមានតម្រេកហើយ ត្រូវតម្រេកគ្របសង្កត់ហើយ មានចិត្តដែលរាគៈគ្រប់គ្រងទុកដោយជុំវិញហើយនោះឯង រមែងគិតដើម្បីបៀតបៀនខ្លួនខ្លះ រមែងគិតដើម្បីបៀតបៀនអ្នកដទៃខ្លះ រមែងគិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃទាំងពីរចំណែកខ្លះ រមែងបានសោយទុក្ខទោមនស្សតាមផ្លូវចិត្តខ្លះ កាលតម្រេក គេលះបង់បានហើយ គេរមែងមិនគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ មិនគិតដើម្បីបៀតបៀនអ្នកដទៃខ្លះ មិនគិតដើម្បីបៀតបៀនខ្លួនឯង និង អ្នកដទៃទាំងពីរចំណែកខ្លះ គេរមែងមិនបានសោយទុក្ខទោមនស្សតាមផ្លូវចិត្ត ម្នាលព្រាហ្មណ៍ ធម៌ជាសន្ទិដ្ឋិកៈយ៉ាងនេះប្រការមួយ ដូច្នេះ ម្យ៉ាងវិញទៀត សូម្បីលោកុត្តរធម៌ទាំង ៩ ក៏ឈ្មោះថា **សន្ទិដ្ឋិក** ព្រោះជាធម៌ដែលបុគ្គលណា ៗបានសម្រេចហើយ បុគ្គលនោះ ៗ មិនដល់នូវការជឿអ្នកដទៃ ឃើញ

ខ្លួនឯង ដោយបច្ចវេក្ខណញ្ញាណ ។

## ន័យទី២ – ឈ្នះកិលេសដោយសន្ទិដ្ឋិក

ន័យម្យ៉ាងទៀត ទិដ្ឋិ ដែលព្រះអរិយៈជាម្ចាស់សរសើរ ឈ្មោះថា **សន្ទិដ្ឋិ** លោកុត្តរធម៌រមែងឈ្នះកិលេសដោយ **សន្ទិដ្ឋិ** ព្រោះដូច្នោះ ទើបឈ្មោះថា **សន្ទិដ្ឋិក** , ពិតហើយ ក្នុងលោកុត្តរធម៌នោះ **អរិយមគ្គ** រមែងឈ្នះកិលេសទាំងឡាយដោយសន្ទិដ្ឋិដែលសម្បយុត្តជាមួយខ្លួន , **អរិយផល** រមែងឈ្នះកិលេសទាំងឡាយដោយសន្ទិដ្ឋិដែលជាហេតុនៃខ្លួន , **ព្រះនិព្វាន** រមែងឈ្នះកិលេសទាំងឡាយដោយសន្ទិដ្ឋិ ព្រោះជាវិស័យ ជាអារម្មណ៍ , ព្រោះហេតុនោះ លោកុត្តរធម៌ ៩ ទើបឈ្មោះថា **សន្ទិដ្ឋិក** ព្រោះឈ្នះកិលេសដោយសន្ទិដ្ឋិ ប្រៀបដូចអ្នកចម្បាំង បានឈ្មោះថា **រថិក** ព្រោះច្បាំងឈ្នះដោយរថ ដូច្នោះ ។

## ន័យទី ៣ – គួរដល់ការឃើញ

ន័យម្យ៉ាងទៀត ការឃើញហៅថា **ទិដ្ឋ** , **ទិដ្ឋ** នុ៎ះឯងជា **សន្ទិដ្ឋ** ប្រែថា ការឃើញលោកុត្តរធម៌ រមែងគួរដល់សន្ទិដ្ឋ ( ការឃើញ ) ហេតុនោះ ទើបឈ្មោះថា **សន្ទិដ្ឋិក** ព្រោះថា លោកុត្តរធម៌ កាលបុគ្គលឃើញដោយអំណាចភាវនាភិសម័យ និងដោយអំណាចសច្ឆិកិរិយាភិសម័យនោះឯង ទើបញុំាងវដ្តភ័យ ( ភ័យ គឺ វដ្តៈ ) ឲ្យត្រូវឡប់បាន ព្រោះហេតុនោះ លោកុត្តរធម៌នោះទើបឈ្មោះថា **សន្ទិដ្ឋិក** ព្រោះគួរដល់ **សន្ទិដ្ឋ**-ការឃើញ ប្រៀបដូចមនុស្សដែលបានឈ្មោះថា **វត្ថិក** ព្រោះគួរដល់ **វត្ថ** ( សំពត់ ) ដូច្នេះ ( **វត្ថិក** សំដៅដល់ក្មេងធំ ដែលនឹងអាក្រាតកាយ តទៅមិនគួរមើល គួរនឹងប្រើសំពត់បិទបាំងរាងកាយហើយ ដូច្នោះ ទេដឹង ? លោក

ប្រមូលមកពោលដើម្បីប្រៀបធៀបសព្ទប៉ុណ្ណោះថា **សន្ទិដ្ឋិក** អាចនឹងប្រែថា គួរដល់ការឃើញបាន មានសព្ទធៀប គឺ **វត្តិក** ប្រែថា អ្នកគួរដល់សំពត់ ) ។

# មហាដីកា

ដោយពាក្យនេះថា ព្រះអរិយបុគ្គល ដែលធ្វើភាពមិនមាននៃកិលេស មានរាគៈជាដើម គប្បីឃើញដោយខ្លួនឯង មានវិគ្គហៈថា **អរិយមគ្គ** ឈ្មោះថា **សន្ទិដ្ឋិ** ព្រោះអត្ថថា ដែលព្រះអរិយបុគ្គលគប្បីឃើញដោយខ្លួនឯង គឺ ដោយខ្លួនឯង មិនមែនដោយពាក្យដែលអ្នកដទៃណែនាំថា យើងលះកិលេស មានរាគៈជាដើមបានហើយ ដោយអរិយមគ្គ ដូច្នេះ , **សន្ទិដ្ឋិ** នោះឯង ឈ្មោះថា **សន្ទិដ្ឋិក** ។

ឈ្មោះថា **បុគ្គលនោះៗ** បានដល់ ព្រះអរិយសាវក ។ ឈ្មោះថា **បរសទ្ធា** ប្រែថា ដោយការជឿអ្នកដទៃ គឺ ដោយពាក្យសម្តីដែលអ្នកដទៃណែនាំ ។ ឈ្មោះថា លះភាវៈដែលគប្បីដល់ គឺ លះភាវៈដែលអ្នកដទៃគប្បីឲ្យដឹង ។ ឈ្មោះថា **ដោយបច្ចវេក្ខណញ្ញាណ** គឺ ដោយញាណដែលជាគ្រឿងធ្វើឲ្យឃើញ ។ ទិដ្ឋិដែលព្រះអរិយបុគ្គលសរសើរ ឈ្មោះថា **សន្ទិដ្ឋិ** ក៏ដូចជាពាក្យដែលព្រះអរិយបុគ្គលសរសើរ ឈ្មោះថា **សម្មោជ្ជន្ត** ។ ប្រកបសេចក្តីថា **អរិយមគ្គ** រមែងឈ្នះកិលេសដោយសន្ទិដ្ឋិដែលសម្បយុត្តជាមួយខ្លួន , **អរិយផល** រមែងឈ្នះកិលេសដោយសន្ទិដ្ឋិដែលជាហេតុរបស់ខ្លួននោះឯង , **ព្រះនិព្វាន** រមែងឈ្នះកិលេសដោយសន្ទិដ្ឋិ ព្រោះខ្លួនឯងជាវិស័យ ដោយការធ្វើខ្លួនឯងឲ្យជាអារម្មណ៍ ។

លោកុត្តរធម៌ដែលបុគ្គលឃើញដោយអំណាចការត្រាស់ដឹង គឺ ចម្រើន បានដល់ មគ្គធម៌ ។ ដែលបុគ្គលឃើញដោយអំណាចការត្រាស់ដឹង គឺធ្វើឲ្យជាក់ច្បាស់

បានដល់ និព្វានធម៌ ។ សូម្បីផលខាងក្រោម រមែងជាធម្មជាតិដែលគួរពោលថា ផលធម៌ដែលបុគ្គលឃើញ រមែងបញ្ចប់ភ័យក្នុងវដ្ដៈដូច្នេះ បានដោយបរិយាយ ជាឧបនិស្សយប្បច្ច័យដល់ការសម្រេចមគ្គខាងលើ ព្រោះជាបច្ច័យដល់វិបស្សនា របស់ព្រះសកទាគាមី ជាដើម ។

( ចប់មហាដីកា )

## បទថា អកាលិកោ

### ន័យទី ១ – មិនរង់ចាំកាល

ធម៌នោះសំដៅចំពោះការឲ្យផលរបស់ខ្លួន មានកាលក៏ទេ ព្រោះហេតុនោះ ទើបឈ្មោះថា **អកាលោ** , **អកាលិកោ** ជា **អកាលោ** នោះឯង មានអធិប្បាយថា ធម៌នោះ បានរង់ចាំកាលដែលផ្សេងដោយការកំណត់ មានបញ្ចហៈ ( ៥ ថ្ងៃ ) និងសត្តាហៈ ( ៧ ថ្ងៃ ) ជាដើម ទើបឲ្យផលក៏ទេ តែរមែងឲ្យផលជាប់តគ្នាភ្លាម បន្ទាប់ពីការប្រាកដរបស់ខ្លួននោះឯង ។

### ន័យទី២ – មិនមែនធម៌មានកាល

ន័យម្យ៉ាងទៀត កាលក្នុងការឲ្យផលនៃខ្លួនរបស់ធម៌នោះ នៅឆ្ងាយ ក្រនឹងដល់ ( សំដៅយកសេចក្ដីថា ឲ្យផលក្នុងពេលដទៃ ) ហេតុនោះ ធម៌នោះ ទើបឈ្មោះថា **កាលិក** សួរថា ធម៌នោះ គឺអ្វី ? ឆ្លើយថា ធម៌នោះ គឺ កុសលធម៌ដែលជាលោកិយ ចំណែកលោកុត្តរធម៌នេះ មិនមែនកាលិកៈ ព្រោះឲ្យផលបន្ទាប់ពីខ្លួន

ព្រោះហេតុនោះ ទើបឈ្មោះថា **អកាលិក** ។

បទថា **អកាលិកោ** នេះ ត្រាស់សំដៅយកមគ្គប៉ុណ្ណោះ ។

# មហាដីកា

ពាក្យថា **លោកុត្តរកុសលនោះ មិនមានកាល** មានសេចក្តីថា លោកុត្តរ-កុសលនោះ មិនមានកាលដែលត្រូវរង់ចាំ មិនដូចជាលោកិយកុសល មានកាលដែលត្រូវរង់ចាំ ក្នុងការឲ្យផលរបស់ខ្លួន ដោយន័យថា ជាឧបបជ្ជវេទនីយកម្ម និងអបរាបរិយវេទនីយកម្មជាដើម យ៉ាងណា លោកុត្តរកុសលនេះ នឹងមានកាលដែលត្រូវរង់ចាំដូច្នោះក៏ទេ , ព្រោះហេតុនោះ លោកទើបពោលថា ដែលផ្សេងគ្នាមាន ៥ ថ្ងៃ ដូច្នេះជាដើម ។ បទថា **បកដ្ឋោ** គឺ វែងឆ្ងាយ ។ លោកិយកុសលកម្ម ឈ្មោះថា **កាលិក** ព្រោះអត្ថថា មានកាលក្នុងការឲ្យផលយូរ បានដល់ ឲ្យផលក្នុងកាលដទៃ ។ ព្រោះហេតុនោះ លោកទើបពោលថា ក្នុងកាលឲ្យផលរបស់ខ្លួន ដូច្នេះ ។ ពាក្យថា **ដែលនឹងដល់បាន** គឺ ដែលនឹងនាំចូលទៅបាន ។ បទថា **ឥទំ** គឺ បទថា **អកាលិកោ** ។

( ចប់ មហាដីកា )

# បទថា ឯហិបស្សិកោ

ធម៌ ឈ្មោះថា **ឯហិបស្សិក** ព្រោះគួរដល់ឯហិបស្សវិធីដែលប្រព្រឹត្តទៅ ក្នុងសេចក្តីថា អ្នកចូរមកមើលធម៌នេះ ដូច្នេះ , សួរថា ក៏ព្រោះហេតុអ្វី ធម៌នោះ ទើបគួរដល់វិធីនោះ ? ឆ្លើយថា ព្រោះធម៌នោះជាសភាវៈមានប្រាកដផង ព្រោះធម៌នោះជាសភាវៈបរិសុទ្ធផង មែនពិត នរណាៗ សូម្បីនឹងពោលបញ្ឆោតថា ប្រាក់ ឬ មាសមាននៅក្នុងដៃទទេ តែក៏មិនហ៊ានហៅអ្នកដទៃថា ចូរមកមើលប្រាក់ ឬមាសនោះចុះ ព្រោះហេតុអ្វី ព្រោះប្រាក់ឬមាសនោះមិនមាន ទោះជាលាមក ឬមូត្រក៏ដោយ សូម្បីមាន នរណាៗ ក៏មិនអាចហៅអ្នកដទៃថា ចូរមកមើល លាមកឬមូត្រនោះដើម្បីឲ្យរីករាយចិត្តចុះ ព្រោះមិនអាចបង្ហាញថា វាជារបស់គួរចម្រើនចិត្ត ព្រោះហេតុអ្វី ព្រោះលាមក ឬមូត្រនោះជារបស់ស្មោកគ្រោក ចំណែកលោកុត្តរធម៌ទាំង ៩ នេះដោយសភាវៈ ជារបស់មានប្រាកដផង ជារបស់បរិសុទ្ធ ដូចព្រះចន្ទពេញបូណ៌មីក្នុងអាកាសដែលប្រាសចាកពពក និងដូចកែវមណីពិត ដែលគេតម្កល់លើសំពត់កម្ពលពណ៌លឿងដូច្នោះ ព្រោះហេតុនោះ ទើបឈ្មោះថា **ឯហិបស្សិក** ហេតុថាគួរដល់ ឯហិបស្សវិធី ព្រោះជាសភាវៈមានប្រាកដផង និងព្រោះជាសភាវៈបរិសុទ្ធផង ។

# មហាដីកា

ពាក្យថា **វិធី** បានដល់ ការរៀបចំ គឺ ពាក្យពោលចាត់ចែងដែលប្រព្រឹត្តទៅយ៉ាងនេះថា សូមអ្នកមកមើលចុះដូច្នេះ ។ ពាក្យថា **ព្រោះមានពិតប្រាកដ** គឺ ព្រោះមានប្រាកដដោយបរមត្ថ ។ ពាក្យថា **ព្រោះបរិសុទ្ធ** គឺ ព្រោះផូរផង់ដោយប្រការទាំង

ពួង ដោយវៀរចាកមន្ទិល គឺ កិលេស ។ សូម្បីវត្ថុដែលមិនគួររីករាយចិត្ត ក្នុងគ្រាខ្លះ ក៏គប្បីជាវត្ថុដែលត្រូវសម្តែង ដោយទាក់ទងដល់ការមានប្រយោជន៍ ដោយការប្រកាសសភាវៈទៅតាមសេចក្តីពិត ព្រោះហេតុនោះ លោកអាចារ្យកាលនឹងសម្តែងដល់លាមកនិងមូត្រ មិនមានប្រការដែលពោលនោះ ទើបពោលថា ក៏មិនអាចនឹងពោលបានថា ដោយការប្រកាសភាវៈដែលគួររីករាយចិត្តបាន ដូច្នេះ ។

( ចប់ មហាដីកា )

## បទថា ឱបនយិកោ

ធម៌ ឈ្មោះថា **ឱបនយិក** ព្រោះគួរនាំចូលទៅ ក៏ឯសេចក្តីតទៅនេះ ជាការវិនិច្ឆ័យក្នុងបទនេះ គឺ ការនាំចូលទៅ ឈ្មោះថា **ឧបនយ** , ជាធម៌គួរដល់បុគ្គលសូម្បីសំពត់ ឬក្បាលត្រូវភ្លើងឆេះ ក៏ព្រងើយៗ គង់នាំចូលទៅក្នុងចិត្តរបស់ខ្លួនឯងធ្វើឲ្យកើតឡើងទាល់តែបាន ព្រោះហេតុនោះ ធម៌នោះ ទើបឈ្មោះ **ឧបនយិក** , **ឧបនយិក** នោះឯងជា **ឱបនយិក** ពាក្យវិគ្រោះនេះ ប្រើបានក្នុងលោកុត្តរធម៌ដែលជាសង្ខតៈ ចំណែកលោកុត្តរធម៌ដែលជាអសង្ខតៈ វិគ្រោះថា ធម៌នោះ គួរដល់ការនាំចូលទៅដោយចិត្តរបស់ខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា **ឱបនយិក** សំដៅយកសេចក្តីថា គួរដល់ការបង្អោនចូលទៅ ដោយធ្វើឲ្យជាក់ច្បាស់ ឬបើមិនដូច្នោះ **ធម៌** គឺ អរិយមគ្គ ឈ្មោះថា **ឧបនេយ្យ** ព្រោះនាំព្រះអរិយបុគ្គលចូលទៅកាន់ព្រះនិព្វាន **ធម៌** គឺ ផល , **ព្រះនិព្វាន** ឈ្មោះថា **ឧបនេយ្យ** ព្រោះជាធម៌ដែលបុគ្គលត្រូវនាំចូលទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់ , **ឱបនយិក** ជា **ឧបនេយ្យ** នោះឯង ។

# មហាដីកា

លោកអាចារ្យព្រោះបំណាច់យកអត្ថនេះថា ឈ្មោះថា **ឧបនេយ្យ** ព្រោះអត្ថថា គួរនាំចូលទៅ , **ឧបនេយ្យ** នោះឯងជា **ឱបនយិក** ដូច្នេះទើបពោលថា លោកុត្តរធម៌ ទាំង ៩ យ៉ាង ឈ្មោះថា **ឱបនយិក** ព្រោះអត្ថថា គួរនាំចូលទៅ ដូច្នេះ ។

ឈ្មោះថា **ការនាំចូលទៅក្នុងចិត្ត** បានដល់ ការធ្វើឲ្យកើតឡើង ព្រោះហេតុនោះ លោកទើបពោលថា ពាក្យអធិប្បាយដែលពោលនេះ រមែងគួរក្នុងលោកុត្តរ-ធម៌ដែលជាសង្ខត: ដូច្នេះ ។

ពាក្យថា **ការនាំចូលទៅក្នុងចិត្ត** គប្បីប្រើបានសូម្បីក្នុងលោកុត្តរធម៌ ដែលជាអសង្ខត: កាលបំណាច់នាំយកធម៌ដែលជាអារម្មណ៍ចូលទៅកាន់ភាពជាអារម្មណ៍ ពោលបានថា លោកុត្តរធម៌ដែលជាអសង្ខត: ឈ្មោះថា **ឱបនយិក** ព្រោះអត្ថថា រមែងគួរដល់ការនាំចូលទៅ ពោលគឺ ការធ្វើឲ្យជាអារម្មណ៍ ។

ឈ្មោះថា **ការចូលដល់** បានដល់ ការពាល់ត្រូវ ។ ឈ្មោះថា **នាំចូលទៅកាន់ព្រះនិព្វាន** អធិប្បាយថា នាំព្រះអរិយបុគ្គលចូលទៅកាន់ព្រះនិព្វាន ។

( ចប់ មហាដីកា )

# បទថា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ

បទថា ***បច្ចត្តំ វេទិតព្វោ វិញ្ញូហិ*** មានសេចក្តីថា ដែលវិញ្ញូជនទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើមទាំងពួង គួរដឹងដោយខ្លួនឯងថា មគ្គយើងបានចម្រើនហើយ ផលយើងបានសម្រេចហើយ និរោធយើងបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះថា កិលេសទាំងឡាយរបស់សទ្ធិវិហារិក នឹងលះបង់ដោយមគ្គដែលព្រះឧបជ្ឈាយ៍ចម្រើនមិនមាន យើងនឹងនៅជាសុខដោយផលសមាបត្តិរបស់គេ ក៏មិនបាន នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលគេធ្វើឲ្យជាក់ច្បាស់ក៏មិនបាន ព្រោះហេតុនោះទើបមានពាក្យអធិប្បាយថា លោកុត្តរធម៌នោះ បុគ្គលមិនគប្បីឃើញ ដូចជាគ្រឿងប្រដាប់លើសីសៈរបស់អ្នកដទៃ ( ដែលនឹងជួយយកមកប្រដាប់លើសីសៈ របស់ខ្លួនបាន ) តែគប្បីឃើញថា ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តរបស់ខ្លួនឯងប៉ុណ្ណោះ ពិតណាស់ លោកុត្តរធម៌នោះ មិនជាវិស័យរបស់ពួកមនុស្សល្ងង់ឡើយ ។

## មហាដីកា

ពាក្យថា ***ដែលវិញ្ញូជនទាំងឡាយ*** មានន័យថា ដែលអ្នកប្រាជ្ញ គឺ អ្នកដែលចាក់ធ្លុះហើយនូវសច្ចៈទាំងឡាយ ( គប្បីដឹងចំពោះខ្លួនឯង ) ក៏លោកទាំងនោះជាឧគ្ឃដិតញ្ញូបុគ្គលជាដើម តែម្យ៉ាង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា មានឧគ្ឃដិតញ្ញូបុគ្គលជាដើមដូច្នេះ ។ សម្រាប់បទថា ***បច្ចត្តំ*** នេះ គប្បីកាន់យកអត្ថដោយអំណាចនៃសត្តមីវិភត្តិថា ***បត្តិ អត្តនិ*** ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ***អត្តនិ អត្តនិ*** ដូច្នេះ ។ លោកពោលថា ***វេទិតព្វោ*** សួរថា គប្បីដឹងបាន

ដូចម្តេច ? ឆ្លើយថា គប្បីដឹងថា មគ្គយើងបានចម្រើនហើយដូច្នេះជាដើម ។ ក្នុងបទទាំងនោះ លោកអាចារ្យកាលសម្តែងអត្ថន័យដែលពោលទុកដោយបទថា **បច្ចត្តំ** ដែលជាពាក្យបណ្តោយតាមគ្នាជាមួយបទថា **មេ** នេះហើយ បំណងសម្តែង ដែលជាពាក្យបដិសេធទៀត ទើបពោលថា **ន ហិ** ដូច្នេះជាដើម ពាក្យនោះ បណ្ឌិតគប្បីដឹងបានងាយហើយ ។ កាលនឹងសម្តែងថា បទថា **វិញ្ញូហិ** នេះ ជាបទដែលមានអវធារណៈ( ពាក្យកំណត់សេចក្តី ) ទាក់ទងក្នុងខ្លួន ទើបពោលថា **ពាលានប្បន អវិសយោវេស** ( ក៏ព្រះធម៌នេះ មិនមែនវិស័យរបស់ពួកបុគ្គលពាលឡើយ ) ដូច្នេះ ។

( ចប់ មហាដីកា )

## ន័យម្យ៉ាងទៀត

“ ធម្មគុណបទក្រោយៗ ជាហេតុនៃបទមុនៗ ”

ន័យមួយទៀត ធម៌នេះជា **ស្វាក្ខាត** សួរថា ព្រោះហេតុអ្វី( ទើបជាស្វាក្ខាតៈ ) ឆ្លើយថា ព្រោះធម៌នេះជា **សន្ទិដ្ឋិក** , ធម៌នេះបានឈ្មោះថា **សន្ទដ្ឋិក** ក៏ព្រោះជា **អកាលិក** , ធម៌នេះបានឈ្មោះថា **អកាលិក** ក៏ព្រោះជា **ឯហិបស្សិក** , ហើយធម៌ណាបានឈ្មោះថា **ឯហិបស្សិក** ធម៌នោះក៏រមែងជា **ឱបនយិក** ដែរ ដូច្នេះជាដើម ។

## មហាដីកា

លោកអាចារ្យ កាលសម្តែងនូវព្រះធម៌ជាស្វាក្ខាតៈ ដោយទេសនាដែលសម

គួរដល់គ្នានិងគ្នា ព្រោះជាធម៌មានលំអបទដើមជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងថា បទក្រោយ ៗ ជាពាក្យពោលដល់ហេតុនៃបទដើម ៗ ទើបពោលថា ន័យម្យ៉ាងទៀតដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ភាពជាសន្ទិដ្ឋិក** មានសេចក្តីថា ព្រោះព្រះធម៌ ដែលព្រះអរិយបុគ្គលគប្បីឃើញដោយខ្លួនឯង តាមន័យដែលបានពោលមកហើយនេះ រមែងកម្ចាត់កិលេសទាំងឡាយដោយ **សន្ទិដ្ឋិ** ( ទិដ្ឋិដែលព្រះអរិយបុគ្គលជាម្ចាស់ទាំងឡាយសរសើរហើយ ) និងគួរដល់ **សន្ទស្សន** ( **សន្ទិដ្ឋ** ប្រែថា ការឃើញ ) ដូច្នោះ ទើបឈ្មោះថា **ស្វាក្ខាត** ព្រោះប្រការដែលពោលនោះ មិនមានក្នុងធម៌របស់ពួកអន្យតិរ្ថិយ ដែលជា **ទុរក្ខាត** ( ពោលទុកមិនល្អ ) ។ សូម្បីក្នុងបទដ៏សេស គប្បីឃើញអត្ថន័យដោយន័យនេះតាមសមគួរ ។

# ធម្មានុស្សតិជ្ឈាន

កាលព្រះយោគាវចរនោះរឭកដល់ព្រះធម្មគុណទាំងឡាយ ដែលផ្សេងដោយគុណ មានសភាពជាស្វាក្ខាតៈជាដើម ដូចពោលមកដូច្នេះ ក្នុងសម័យនោះ ចិត្តរបស់លោករមែងមិនជាចិត្តដែលរាគៈរុំព័ទ្ធ មិនជាចិត្តដែលទោសៈរុំព័ទ្ធ មិនជាចិត្តដែលមោហៈរុំព័ទ្ធឡើយ ក្នុងសម័យនោះ ចិត្តរបស់លោក រមែងជាចិត្តដំណើរទៅត្រង់គន្លង ប្រារព្ធព្រះធម៌ អង្គឈានទាំងឡាយ រមែងកើតឡើងក្នុងខណៈជាមួយគ្នាដល់អ្នកដែលគ្របសង្កត់នីវរណៈបានហើយ តាមន័យមុន ( ដែលពោលក្នុងពុទ្ធានុស្សតិ ) នោះឯង តែព្រោះភាពដែលធម្មគុណទាំងឡាយ ជាអារម្មណ៍ជ្រាលជ្រៅ ឬ ព្រោះភាពដែលចិត្តបង្អោនទៅ រឭកដល់ព្រះគុណច្រើនយ៉ាង ច្រើនប្រការ ឈាន

នេះ ទើបជាឈានមិនដល់អប្បនា ដល់ត្រឹមតែឧបចារប៉ុណ្ណោះ ហើយឈាននេះក៏ដល់នូវការហៅឈ្មោះថា **ធម្មានុស្សតិនោះឯង** ព្រោះជាឈានដែលកើតឡើងដោយអំណាចការរឭកដល់ធម្មគុណ ។

## អានិសង្សនៃការចម្រើនធម្មានុស្សតិ

ក៏ឯភិក្ខុដែលប្រកបរឿយៗ នូវធម្មានុស្សតិនេះ រមែងជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែងក្នុងព្រះសាស្តា ធ្វើភាពធ្ងន់ចិត្ត និងបង្អោនទៅក្នុងព្រះធម៌ ដោយការរឭកដល់ធម្មគុណដោយន័យ ( សក្កភាសិតក្នុងមហាគោវិន្ទសូត្រ ) ថា យើងពិចារណាមិនឃើញសាស្តាដែលសម្តែងធម៌ ដែលជាឱបនយិកៈយ៉ាងនេះ ដែលប្រកបសូម្បីដោយអង្គនេះក្នុងកាលចំណែកដែលជាអតីតឡើយ ក្នុងកាលឥឡូវនេះសោត យើងក៏ពិចារណាមិនឃើញ វៀរតែព្រះមានព្រះភាគជាម្ចាស់អង្គនោះ ដូច្នេះ រមែងបានភាពសម្បូណ៌នៃគុណ មានសទ្ធាជាដើម ជាអ្នកច្រើនទៅដោយបីតិបាមោជ្ជ អត់ធន់ចំពោះការខ្លាច និងការភ័យ អាចអត់ធន់ចំពោះទុក្ខ មានការដឹងខ្លួនដូចជាបាននៅជាមួយព្រះធម៌ , ម្យ៉ាងវិញទៀត សូម្បីសរីរៈរបស់លោកអ្នកដែលធម្មគុណានុស្សតិ ប្រថាប់នៅ រមែងជាសរីរៈគួរដល់ការបូជា ដូចព្រះចេតិយ , ចិត្តរបស់លោក រមែងបង្អោនទៅក្នុងការសម្រេចបាននូវអនុត្តរធម៌ , ម្យ៉ាងទៀត ក្នុងកាលមានការជួបនឹងវត្ថុដែលនឹងត្រូវកន្លងល្មើស ហិរិឱត្តប្បៈ រមែងប្រាកដដល់លោកដែលរឭកដល់ភាពជាធម៌ល្អនៃព្រះធម៌បាន , ម្យ៉ាងវិញទៀត កាលនៅមិនទាន់សម្រេចគុណដ៏ក្រៃលែងឡើងទៅ លោករមែងជាអ្នកមានសុគតិជាទីទៅ ក្នុងខាងមុខ ។

ព្រោះហេតុនោះឯង អ្នកមានបញ្ញាល្អ គប្បីធ្វើសេចក្តីមិនប្រមាទក្នុងធម្មា-នុស្សតិ ដែលមានអានុភាពច្រើនយ៉ាងនេះ គ្រប់កាលចុះ ។

នេះជាកថាមុខ ( ពាក្យខែសេចក្តីដ៏សំខាន់ ) យ៉ាងពិស្តារក្នុងធម្មានុស្សតិ ។

## មហាដីកា

ក្នុងពាក្យថា កាលព្រះយោគាវចរនោះ......យ៉ាងនេះជាដើម មានពាក្យដែលគួរពោលអធិប្បាយឯណា បណ្ឌិតគប្បីជ្រាបពាក្យនោះ តាមន័យដែលខ្ញុំព្រះករុណាបានពោលអធិប្បាយហើយក្នុងពុទ្ធានុស្សតិនិទ្ទេសនុ៎ះចុះ ។

( ចប់ ធម្មានុស្សតិ )

# សង្ឃានុស្សតិ

*សូម្បីព្រះយោគាវចរ ដែលប្រាថ្នានឹងចម្រើនសង្ឃានុស្សតិ ក៏គប្បីជាអ្នកទៅក្នុងទីស្ងាត់ ពួនសម្ងំនៅ ( ក្នុងសេនាសនៈដែលសមគួរ ) ហើយរឭកដល់គុណព្រះអរិយសង្ឃទាំងឡាយ ( ដោយអនុស្សរណបាឋៈ ) យ៉ាងនេះថា ៖*

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។

## បទថា សុបដិបន្នោ

*ក្នុងបទទាំងនោះ បទថា **សុបដិបន្នោ** ប្រែថា បដិបត្តិល្អ មានពាក្យអធិប្បាយថា បដិបត្តិជាសម្មាបដិបទា ( គឺ ប្រតិបត្តិត្រូវ ) ជាអនិវត្តិបដិបទា ( បដិបត្តិមិនត្រឡប់ ) ជាអនុលោមបដិបទា ( បដិបត្តិសមគួរដល់ព្រះនិព្វាន ) ជាអបច្ចនីកបដិបទា ( បដិបត្តិមិនជាសឹកសត្រូវដល់ធម៌ និងបុគ្គល ) ជាធម្មានុធម្មប្បដិបទា ( បដិបត្តិធម៌សមគួរដល់ធម៌ ) ។*

*បុគ្គលពួកណា ស្តាប់ឱវាទានុសាសនី របស់ព្រះមានព្រះភាគ ដោយគោរពព្រោះហេតុនោះ បុគ្គលទាំងនោះ ទើបឈ្មោះថា **សាវក** ( អ្នកស្តាប់ ) ក្រុមនៃសាវកទាំងឡាយឈ្មោះថា **សង្ឃសាវក** សំដៅយកសេចក្តីថា ជំនុំនៃសាវកដែលដល់នូវភាពជាពពួកក្រុមគ្នា ដោយភាពជាអ្នកស្មើគ្នាដោយសីល និង ទិដ្ឋិ ។*

## បទថា ឧជុ...ញាយ...សាមីចិបដិបន្នោ

***ឧជុ...ញាយ...សាមីចិបដិបន្នោ*** ទាក់ទងនឹង ***សុបដិបន្នោ*** ក៏ព្រោះថា សម្មាបដិបទានោះ ជាបដិបទាត្រង់ គឺ មិនវៀច មិនកោង មិនង , ម្យ៉ាងវិញទៀត បដិបទានោះ លោកហៅថា អរិយញ្ញាណខ្លះ និង ដល់នូវការហៅឈ្មោះបានថា ***សាមីចិ*** ព្រោះជាបដិបទាដែលសមគួរខ្លះ ព្រោះហេតុនោះ ព្រះអរិយសង្ឃដែលធ្វើដំណើរតាមបដិបទានោះ ទើបបានឈ្មោះថា ***ឧជុបដិបន្នោ*** ( បដិបត្តិត្រង់ ) ខ្លះថា ***ញាយបដិបន្នោ*** ( បដិបត្តិជាញាយ ) ខ្លះថា ***សាមីចិបដិបន្នោ*** ( បដិបត្តិគួរ ) ខ្លះ ។

លោកអ្នកតាំងនៅក្នុងផល បានឈ្មោះថា ***សុបដិបន្នោ*** ដូចម្ដេច ?

ក៏ឯក្នុងបទ ***សុបដិបន្នោ*** ជាដើមនោះ បណ្ឌិតគប្បីជ្រាបថា ព្រះអរិយៈពួកណាជាអ្នកតាំងនៅក្នុងមគ្គ ព្រះអរិយៈជាម្ចាស់ទាំងនោះឈ្មោះថា បដិបត្តិល្អ ព្រោះភាពជាបុគ្គលព្រមព្រៀងទៅដោយការបដិបត្តិត្រូវ ព្រះអរិយៈជាម្ចាស់ពួកណាជាអ្នកតាំងនៅក្នុងផល ព្រះអរិយៈជាម្ចាស់ទាំងនោះ ក៏ឈ្មោះថា បដិបត្តិល្អ សំដៅយកការបដិបត្តិដែលកន្លងទៅហើយ ព្រោះលោកទាំងនោះ បានសម្រេចធម៌ដែលគប្បីសម្រេច ក៏ដោយការបដិបត្តិត្រូវនោះឯង ។

## អធិប្បាយ ៤ បទ មួយន័យទៀត

ន័យម្យ៉ាងទៀត ឈ្មោះថា ***សុបដិបន្នោ*** ព្រោះបដិបត្តិទៅតាមអនុសាសនីដែលព្រះសាស្ដា ទ្រង់ប្រៀនប្រដៅទុកក៏បាន ព្រោះបដិបត្តិអបណ្ណកបដិបទា ( គឺបដិបត្តិមិនខុស ) ក៏បាន ចំពោះក្នុងធម្មវិន័យដែលជាស្វាក្ខាតៈ ឈ្មោះថា ***ឧជុបដិបន្នោ*** ព្រោះបដិបត្តិតាមមជ្ឈិមាបដិបទា មិនចូលជិតអន្តៈ ( ទីបំផុត ) ទាំងពីរចំណែក

និងព្រោះបដិបត្តិដើម្បីលះទោស គឺ ការវៀច ការកោង និងកាព-ង តាមផ្លូវកាយ វាចា ចិត្ត ។

*ព្រះនិព្វាន* ទ្រង់ត្រាស់ហៅថា **ញាយ** ព្រោះបដិបត្តិដើម្បីប្រយោជន៍ដល់ព្រះនិព្វាននោះ ទើបឈ្មោះថា **ញាយបដិបន្នោ** ។

បុគ្គលទាំងឡាយ បដិបត្តិដោយប្រការណា ទើបជាអ្នកគួរដល់ សាមីចិកម្ម ព្រោះបដិបត្តិដោយប្រការនោះ ទើបឈ្មោះថា **សាមីចិបដិបន្នោ** ។

## មហាដីកា
## អធិប្បាយ សង្ឃានុស្សតិ

ពាក្យថា *គុណរបស់ព្រះអរិយសង្ឃ* មានសេចក្ដីថា បុគ្គលដែលឈ្មោះថា ព្រះអរិយៈ ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ ( **អារកត្តាកិលេសេហិ** ) ព្រោះមិនប្រព្រឹត្តទៅក្នុងសេចក្ដីវិនាស ( **អនយេ នឥរិយនតោ** ) និងព្រោះប្រព្រឹត្តទៅក្នុងសេចក្ដីចម្រើន ( **អយេ ឥរិយនតោ** ) និងព្រោះលោក ព្រមទាំងទេវលោក គប្បីដល់ ជាសរណៈ ( **សទេវកេន លោកេន សរណន្តិ អរណីយតោ** ) ព្រះអរិយៈនោះជាព្រះសង្ឃផង ទើបឈ្មោះថា ព្រះអរិយសង្ឃ ម្យ៉ាងទៀត ពពួកនៃព្រះអរិយៈទាំងឡាយ ឈ្មោះថា ព្រះអរិយសង្ឃ បានដល់ គុណរបស់ព្រះអរិយសង្ឃនោះ ។

បុគ្គលបដិបត្តិសម្មាបដិបទាណាហើយ បណ្ឌិត ហៅថា ជាអ្នកបដិបត្តិល្អ សម្មាបដិបទានោះ បានដល់ អរិយមគ្គប្បដិបទា ឈ្មោះថា មានការមិនត្រឡប់មក ជា

ធម្មតា សូម្បីយ៉ាងនេះ ព្រោះល្មមនឹងលះធម៌ដែលជាបដិបក្ខ ធ្វើមិនឲ្យវិលត្រឡប់មកបានហើយ ក៏អស់ប្រយោជន៍ទៅ ( ទើបមិនវិលត្រឡប់មកកើតដដែលៗ ដើម្បីលះកិលេសនោះទៀត ) និងឈ្មោះថា អនុលោមចំពោះព្រះនិព្វាន ដែលគប្បីសម្រេចដោយយ៉ាងប្រាកដ ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា មិនជាសឹកសត្រូវ និងឈ្មោះថា ជា **អនុធម្ម** ( ធម៌ដែលសមគួរ ) លោកអាចារ្យបំណងសម្ដែងថា ព្រះ **អរិយសង្ឃ** ហៅថា **សុបដិបន្ន** ព្រោះបដិបត្តិសម្មាបដិបទានោះ ទើបពោលថា ដែលបដិបត្តិល្អ ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ដោយពាក្យថា **អនិវត្តិបដិបទា** ( គោលបដិបត្តិដែលមិនវិលត្រឡប់ ) នេះ លោកសម្ដែង **ឧជុបដិបត្តិ** ( បដិបត្តិត្រង់ ) ។ ព្រោះថា កាលបើមានការវិលត្រឡប់រឿយៗ ក៏មិនមានឧជុបដិបត្តិ ។ ដោយពាក្យថា **អនុលោមបដិបទា អបច្ចនិកបដិបទា** នេះ លោកសម្ដែងដល់ **ញាយ-បដិបទា** ( គោលបដិបត្តិដែលគួរដឹង ) ។ ព្រោះបដិបទានេះគួរដឹង ព្រោះអនុលោមចំពោះព្រះនិព្វាន និង ព្រោះការមិនជាបដិបក្ខចំពោះព្រះនិព្វានដែលគប្បីដល់នោះ ។ ដោយពាក្យថា **ធម្មានុធម្មប្បដិបទា** នេះ លោកសម្ដែងដល់ **សាមីចិបដិបត្តិ** ព្រោះសម្ដែងជាគោលបដិបត្តិដែលសមគួរ ។ ដោយពាក្យថា **បដិបត្តិសម្មាបដិបទាជាដើម** នេះ លោកសម្ដែងថា បទទាំង ៣ ក្រៅអំពីនេះ មានបទថា **ឧជុបដិបន្នោជាដើម** ជាពាក្យនិទ្ទេស ពង្រីកបទដំបូង ( គឺ បទថា **សុបដិបន្នោ** ) ។ ព្រោះហេតុនោះ លោកទើបពោលថា **តែព្រោះហេតុដែល** ដូច្នេះជាដើម ។

ការស្ដាប់ដែលជាហេតុនាំមកនូវភាពជាព្រះអរិយបុគ្គល ដោយការបដិបត្តិតាមដែលទ្រង់អនុសាសន៍ទុក ក៏មានការសម្រេចកិច្ច ឈ្មោះថា **ការស្ដាប់ដោយគោរព** ព្រោះហេតុនោះ លោកទើបពោលថា ឈ្មោះថា **សាវក** ព្រោះអត្ថថា ស្ដាប់ដោយ

គោរព ដូច្នេះ ដោយពាក្យនោះលោកសម្ដែងថា ព្រះអរិយបុគ្គលទាំងឡាយនោះឯង ឈ្មោះថា សាវ័ករបស់ព្រះសាស្ដាដោយនិប្បរិយាយ ( ដោយត្រង់ ) ។ ពាក្យថា ព្រោះការស្មើគ្នានៃសីល និងទិដ្ឋិ គឺ ព្រោះការស្មើគ្នាដោយសីលដែលជារបស់ព្រះអរិយៈ និងដោយទិដ្ឋិដែលជារបស់ព្រះអរិយៈ ។ ពិតណាស់ សម្រាប់ព្រះអរិយ-បុគ្គលទាំងឡាយ នឹងមានការធ្វើសីលនិងទិដ្ឋិ ឲ្យបែកពីគ្នា ដូចជាមាសដែលបែកពាក់កណ្ដាល ក៏ទេ ព្រោះមកហើយដោយមគ្គ ។ ព្រោះហេតុនោះ ព្រះអរិយបុគ្គលទាំងនោះ សូម្បីថា លោកនៅក្នុងទីណាទីមួយ ( ម្នាក់មួយកន្លែង ) ក៏ឈ្មោះ ថា នៅរួមគ្នាដែរ ។ ព្រោះហេតុនោះ លោកទើបពោលថា ដែលដល់នូវការរួមគ្នាបាន ដូច្នេះ ។ **សម្មាបដិបទា** ឈ្មោះថា **ត្រង់** ក៏ដោយការកាត់បាបធម៌ មានមាយាសាឋេយ្យជាដើមបាន ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា **មិនវៀច** ព្រោះមិនមានភាពវៀច ដូចគោមុត្ត ( ស្នាមមូត្រគោ ) ។ ឈ្មោះថា **មិនកោង** ព្រោះមិនមានភាពកោងដូចវង់ព្រះចន្ទ ។ ឈ្មោះថា **មិន-ង** ព្រោះមិនមានភាព-ង ដូចចុងនង្គ័ល ។ ម្យ៉ាងទៀត ឈ្មោះថា **ត្រង់** ព្រោះជាបដិបទាដែលមិនវៀចជាដើម ។ ឈ្មោះថា **អរិយ** ព្រោះអត្ថថា បរិសុទ្ធ ។ ឈ្មោះថា **ញាយ** ព្រោះអត្ថថា ព្រះអរិយបុគ្គល រមែងដឹងដោយភាពជាគោលបដិបត្តិមិនខុស ព្រោះអត្ថថា ឈានទៅកាន់ព្រះនិព្វាន ម្យ៉ាងទៀត ព្រោះអត្ថថា ជាហេតុឲ្យព្រះអរិយបុគ្គលដឹង គឺ ចាក់ធ្លុះព្រះនិព្វាននោះ ។ សម្មាបដិបត្តិដល់នូវការរាប់ គឺ ដែលសមញ្ញាថា **សាមីចិ** ប្រែថា សមគួរ ព្រោះជាបដិបទាដែលសមគួរ គឺ ព្រោះជាបដិបទាដែលសមគួរចំពោះការនាំចេញចាកទុក្ខក្នុងវដ្ដៈ ព្រះអរិយសង្ឃទាំងឡាយ ដែលតាំងនៅក្នុងមគ្គឈ្មោះថា **សុបដិបន្ន** ក៏ព្រោះជាអ្នកព្រមព្រៀងដោយសម្មាបដិបទានោះ ព្រោះធ្វើ

អធិប្បាយថា កំពុងបដិបត្តិដោយប្រពៃ ។ ពិតណាស់ **បដិបន្ន** ស័ព្ទនេះ មាន អត្ថថា កំពុងប្រព្រឹត្តទៅ ដូចជាពាក្យថា **សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ** បុគ្គលកំពុងបដិបត្តិ ដើម្បីធ្វើសោតាបត្តិផលឲ្យជាក់ច្បាស់ ។ ពាក្យថា **គោលបដិបត្តិដែលកន្លងទៅហើយ លោកពោលដល់គោលបដិបត្តិត្រូវ** គឺ មគ្គ តាមដែលពោលមកហើយ ។ ក៏ដោយពាក្យសម្តែងវិធដែលដូចគ្នាទាំងពីរពាក្យ ( គឺ លោកអ្នកតាំងនៅក្នុងមគ្គ ក៏ឈ្មោះថា **សុបដិបន្ន** , លោកអ្នកតាំងនៅក្នុងផល ក៏ឈ្មោះថា **សុបដិបន្ន** ) លោកសម្តែងថា ក្រុមនៃព្រះអរិយបុគ្គលទាំងឡាយដែលកាន់យកហើយដោយឯកសេសន័យ ( ន័យដែលធ្វើឲ្យសល់ត្រឹមតែបទមួយ ) ថា **សុបដិបន្ន** គឺ អ្នកដែលតាំងនៅក្នុងមគ្គផង , **សុបដិបន្ន** គឺ អ្នកដែលតាំងនៅក្នុងផលផង ឈ្មោះថា **សុបដិបន្ន** ដូច្នេះ លោកទើបពោលថា ជាអ្នកបដិបត្តិល្អ ។

លោកអាចារ្យកាលបានពោលអត្ថនៃបទក្រៅអំពីនេះ ( មានបទថា **ឧជុបដិបន្នោ** ជាដើម ) ជាពាក្យសម្តែងវិធអត្ថនៃបទដំបូង គឺ បទថា **សុបដិបន្នោ** យ៉ាងនេះហើយ ឥឡូវនេះ បំណងសម្តែងអត្ថដែលមិនលាយឡំគ្នានៃបទទាំង ៤ ទើបពោលថា **ន័យម្យ៉ាងទៀត** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **តាមដែលទ្រង់អនុសាសន៍ទុក** មានអត្ថន័យថា ព្រោះបដិបត្តិបានសមគួរដល់ព្រះអនុសាសនីតាមដែលព្រះសាស្តាទ្រង់អនុសាសន៍ទុក ។ ពាក្យថា **អបណ្ណកបដិបទា** ប្រែថា បដិបទាដែលមិនខុស មានសេចក្តីថា គោលបដិបត្តិដែលរកទោសមិនបាន ។ ក៏ក្នុងសេចក្តីនេះ គប្បីភ្ជាប់បទយ៉ាងនេះថា **ស្វាក្ខាតេ ធម្មវិនយេ អបណ្ណកបដិបទំ បដិបន្នត្តា** ( ព្រោះបដិបត្តិអបណ្ណកបដិបទាក្នុងធម៌ និង វិន័យដែលត្រាស់ទុកល្អហើយ ) ដូច្នេះចុះ ។ សួរថា កាលមានការភ្ជាប់ ( ពាក្យថា **ស្វាក្ខាតេ ធម្មវិនយេ** )

ចូលជាមួយបទដំបូង ( គឺបទថា **យថានុសិដ្ឋំ បដិបន្នត្តា** ព្រោះបដិបត្តិបានតាមដែលទ្រង់អនុសាសន៍ទុក ) ក៏មិនគួរនឹងត្រូវពោលបទទី ២ គឺ បទថា **អបណ្ណក បដិបទំ បដិបន្នត្តា** ព្រោះបដិបត្តិអបណ្ណកបដិបទា និងសូម្បីកាលមានការភ្ជាប់ចូលជាមួយបទទី ២ ក៏មិនគួរនឹងត្រូវពោលបទដំបូងមិនមែនឬ ? ឆ្លើយថា មិនគួរនឹងត្រូវពោលក៏ទេ ព្រោះលោកសំដៅដល់បទដំបូងនោះមុន ។ តែដើម្បីសម្ដែងថា **អបណ្ណកបដិបទា** របស់សាវកទាំងឡាយនោះជា **យថានុសិដ្ឋបដិបទា** ( គោលបដិបត្តិតាមដែលទ្រង់អនុសាសន៍ទុក ) ដូច្នេះ ទើបត្រូវពោលនូវបទដំបូងថា **យថានុសិដ្ឋំ បដិបន្នត្តា** ដូច្នេះ ។ ម្យ៉ាងទៀត លោកពោលបទទាំងពីរទុក ព្រោះបទទាំងពីរឲ្យសម្រេចភាពជាសុបដិបន្នបុគ្គល ។ សមពិត តាមដែលពាក្យលោកពោលថា ដោយ **បិ** ស័ព្ទ ( ដែលប្រែថា **សូម្បី** ក្នុងពាក្យថា សូម្បីព្រោះបដិបត្តិ ) ជាស័ព្ទ ដែលរួមយកទាំងពីរបទដូច្នេះ ។

ការប្រកាន់ចំណែកទាំងពីរ ( គឺ កាមសុខល្លិកានុយោគ និងអត្តកិលមថានុ-យោគ ) រមែងមានបានដោយអំណាចការវៀចវេរ គឺ កិលេស ព្រោះដូច្នោះ **សម្មាបដិបទា** ដែលលះភាពវៀចវេរ គឺ កិលេសនោះបានដោយប្រការទាំងពួង ទើបជាគោលបដិបត្តិត្រង់ ដែលលះភាពកោងនៃកាយជាដើមបាន ព្រោះហេតុនោះ លោកទើបពោលថា ឈ្មោះថា **ឧជុបដិបន្ន** ។ល។ ព្រោះបដិបត្តិមជ្ឈិមាបដិបទា ដូច្នេះ ។

គោលបដិបត្តិដែលដល់នូវការពាល់ត្រូវព្រះនិព្វាន ឈ្មោះថា **ញាយ** លោកអាចារ្យពោលថា **ព្រះនិព្វាន** ទ្រង់ហៅថា **ញាយ** ព្រោះអត្ថថា ព្រះយោគីត្រូវបដិបត្តិ ( ត្រូវទៅដល់ ) ដូចគ្នា , សូម្បីថា សំពត់ដូតក្បាល ឬ សីសៈត្រូវភ្លើងឆេះក៏ព្រងើយកន្តើយបាន ព្រោះជាធម៌ដែលស្ងប់សង្ខារទាំងពួង ។ ក៏ក្នុងអធិការនេះ

គប្បីឃើញថា លោកពោលដល់និព្វាន ដោយកិរិយាដែលរំលត់កិលេសជាសំខាន់ ម្យ៉ាងទៀត គប្បីជ្រាបអត្ថន័យក្នុងពាក្យថា **ញាយ** នេះ យ៉ាងនេះថា ព្រះនិព្វាន ដែលឈ្មោះថា **ញាយ** ព្រោះអត្ថថា ដែលព្រះអរិយបុគ្គលទាំងឡាយ រមែងដឹង គឺ រមែងចាក់ធ្លុះ និងធ្វើឲ្យជាក់ច្បាស់ដោយមគ្គញ្ញាណជាដើម ។

បុគ្គលឈ្មោះថា **គួរដល់សាមីចិកម្ម** ព្រោះអត្ថថា គួរដល់សាមីចិកម្ម ( ការធ្វើដែលសមគួរ ) មានការក្រោកទទួលជាដើម ដែលបុគ្គលដទៃធ្វើចំពោះ ដោយការសរសើរក្នុងគុណធម៌ ។

( ចប់មហាដីកា )

## បទថា យទិទំ ។បេ។

ពាក្យថា **យទិទំ** ខែជា **យានិ ឥមានិ** ( ប្រែថា ពួកនេះ ) ពាក្យថា **ចត្តារិ បុរិសយុគានិ** មានសេចក្តីថា ដោយរាប់ជាគូនៃបុរស មាន ៤ គូ គឺ ភិក្ខុអ្នកតាំងនៅក្នុងបឋមមគ្គ អ្នកដែលតាំងនៅក្នុងបឋមផល នេះជាគូមួយ ដូច្នេះជាដើម ពាក្យថា **អដ្ឋបុរិសបុគ្គលា** មានសេចក្តីថា បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ដោយន័យនេះ ភិក្ខុដែលតាំងនៅក្នុងបឋមមគ្គ ១ ភិក្ខុដែលតាំងនៅក្នុងបឋមផល ១ ជាដើម ក៏បទថា **បុរសក្តី** បទថា **បុគ្គលក្តី** នេះក្នុងពាក្យថា **អដ្ឋបុរិសបុគ្គលា** នោះ មានអត្ថដូចគ្នា តែបទថា **បុរិសបុគ្គលា** នោះ ទ្រង់ត្រាស់ដោយអំណាចនៃវេយ្យាករណ៍ មានសេចក្តីថា **ឯស ភគវតោ សាវកសង្ឃោ** មានសេចក្តីថា បើរាប់ជាគូនៃបុរសបុគ្គល មាន ៤ គូ បើរាប់ចែកជាអង្គ ៗ បុរសបុគ្គល ៨ ទាំងនេះ គឺ ពពួក

សាវ័ករបស់ព្រះមានព្រះភាគជាម្ចាស់ ។

# មហាដីកា

ពាក្យថា **យទិទំ** ជានិបាតដែលមានប្រភេទនៃលិង្គ និង វចនៈទាក់ទងនៅក្នុងខ្លួន ព្រោះហេតុនោះ លោកអាចារ្យទើបពោលដល់អត្ថនៃពាក្យថា **យទិទំ** នោះ បែកចេញជាពាក្យថា **យានិ ឥមានិ** ដូច្នេះ ។ ពាក្យថា **ឯវំ** ជានិបាត ក្នុងអត្ថថា **ប្រការ** មានអត្ថន័យថា **ឥមិនា បការេន** ( ដោយប្រការនេះ ) ដូច្នេះឯង ។ ដោយពាក្យថា **ឯវំ** នោះ គឺ លោកសម្តែង ៣ គូ ក្រៅអំពីនេះហើយ ព្រោះហេតុនោះ លោកទើបពោលថា ជាគូនៃបុរស មាន ៤ គូ ដោយប្រការនេះ ។ បទថា **ឯតំ** នេះ បានដល់ បទដែលពោលទុក ទាក់ទងនឹងពហុវចនៈថា **បុរិសបុគ្គលា** ។ បុគ្គលទាំងនោះផង ជាបុរសផង ទើបឈ្មោះថា **បុរសបុគ្គល** ។ ម្យ៉ាងទៀត ក្នុងពាក្យថា **បុរសបុគ្គលនោះ** គប្បីជ្រាបអត្ថន័យក្នុងឈ្មោះទាំងពីរនេះ យ៉ាងនេះថា ដោយឈ្មោះដំបូងថា **បុរស** នេះជាការកាន់យកតាមប្រក្រតី រីឯឈ្មោះទី ២ ថា **បុគ្គល** ជាការកាន់យកភាពជាសត្វស្មើគ្នា ។

( ចប់ មហាដីកា )

## បទថា អាហុនេយ្យោ

( ន័យទី ១ )

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងឡាយ មានបទថា **អាហុនេយ្យោ** ជាដើមតទៅ ៖

វត្ថុណាដែលគេនាំមកបូជា ហេតុនោះ វត្ថុនោះ ឈ្មោះថា **អាហុន** សំដៅយកសេចក្ដីថា វត្ថុដែលគេនាំមកអំពីចម្ងាយ ប្រគេនចំពោះលោកដែលមានសីលទាំងឡាយ ។ ពាក្យថា **អាហុន** នោះ ជាឈ្មោះនៃបច្ច័យ ៤ , ព្រះសង្ឃដែលជាអ្នកគួរនឹងទទួលអាហុនៈនោះ ព្រោះធ្វើអាហុនៈនោះឲ្យមានផលច្រើន ហេតុនោះទើបឈ្មោះថា **អហុនេយ្យ** អ្នកគួរទទួលរបស់ដែលគេនាំមកបូជា ។

( ន័យទី ២ )

ន័យម្យ៉ាងទៀត សូម្បីសម្បត្តិទាំងពួងរបស់បុគ្គលមកអំពីចម្ងាយ ក៏គួរតែបូជាចំពោះព្រះសង្ឃនោះ ហេតុនោះ ព្រះសង្ឃនោះ ទើបឈ្មោះថា **អាហវនីយ** ( អ្នកគួរដល់វត្ថុដែលគេបូជា ) ឬថា ព្រះសង្ឃ រមែងគួរដល់ **អាហវនវត្ថុ** សូម្បីជារបស់ទេវតាទាំងឡាយ មានសក្កទេវរាជជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **អាហវនីយ** ( បុគ្គលគួរទទួលរបស់ដែលគេនាំមកបូជា ) ។ ម្យ៉ាងវិញទៀត ភ្លើងដែលបានឈ្មោះថា **អាហវនីយ** របស់ព្រាហ្មណ៍ទាំងឡាយ ដែលលទ្ធិរបស់ពួកគេយល់ថា ជាទីដែលគេបូជាហើយ មានផលច្រើន ប្រសិនបើភ្លើងនោះ ឈ្មោះថា **អាហវនីយ** ព្រោះជាវត្ថុដែលបុគ្គលបូជាហើយ ( ក្នុងភ្លើងនោះ ) មានផលច្រើនសោត ក៏ត្រូវតែជាព្រះសង្ឃនោះឯងជា **អាហវនីយ** ព្រោះវត្ថុដែលបុគ្គលបូជាចំពោះព្រះសង្ឃ ជាវត្ថុដែលមានផលច្រើនពិតៗ ដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

***ក៏ឯជនណា ទោះបីបម្រើភ្លើងនៅក្នុងព្រៃអស់រយឆ្នាំ ចំណែកជនណាបូជាលោកអ្នកដែលបានអប់រំខ្លួនសម្រេចហើយ តែម្នាក់ សូម្បីតែមួង ការបូជានោះឯងប្រសើរជាង ការបូជាភ្លើងអស់រយឆ្នាំ នឹងប្រសើរអ្វីទៅ ។***

បទថា **អាហវនីយ** នេះ ជាពាក្យក្នុងនិកាយដទៃ ដោយអត្ថក៏ជាការដូចគ្នានឹងបទថា **អាហុនេយ្យ** នេះ ក្នុងទីនេះ តែក្នុងពីរបទនេះ ផ្សេងគ្នាបន្តិចដោយព្យញ្ជនៈប៉ុណ្ណោះ , ព្រះសង្ឃជា **អាហុនេយ្យ** ដោយប្រការដូច្នេះ ។

## បទថា បាហុនេយ្យោ

ចំណែកក្នុងបទថា **បាហុនេយ្យោ** ( គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ) **អាគន្តុកទាន** ( របស់ទទួលភ្ញៀវដែលគេរៀបចំទុក ដូចជាគ្រឿងសក្ការៈ គឺ រៀបចំទុកយ៉ាងល្អ ) ដើម្បីប្រយោជន៍ដល់ញាតិ និងមិត្តទាំងឡាយ ដែលជាទីស្រឡាញ់ពេញចិត្ត មកអំពីទិសធំ-តូច ហៅថា **បាហុន** សូម្បីអាគន្តុកទាននោះ វៀរញាតិនិងមិត្តដែលជាទីស្រឡាញ់ជាទីពេញចិត្តទាំងនោះឯង និង ភ្ញៀវដទៃដែលមានឋានៈយ៉ាងនោះចោល ក៏គួរប្រគេនដល់ព្រះសង្ឃប៉ុណ្ណោះ ព្រះសង្ឃប៉ុណ្ណោះគួរទទួលយកអាគន្តុកទាននោះ ព្រោះថា ភ្ញៀវ ( ដែលទ្រទ្រង់គុណ ) ដូចជាព្រះសង្ឃមិនមានពិតយ៉ាងនោះ ព្រះសង្ឃនោះ ចំពោះពុទ្ធន្តរមួយ ទើបនឹងបានជួប លោកប្រកបដោយធម៌ទាំងឡាយ ដែលធ្វើភាពជាទីស្រឡាញ់ ជាទីពេញចិត្តសុទ្ធៗ , ដោយព្រះសង្ឃ ឈ្មោះថា **បាហុនេយ្យ** ព្រោះរបស់ទទួលភ្ញៀវគួរប្រគេនដល់លោក ហើយលោកក៏គួររទទួលរបស់ដែលទទួលភ្ញៀវ ដូច្នេះឯង ។

ចំណែកបាលីរបស់ជនពួកណាថា **បាហវនីយោ** បាលីរបស់ជនពួកនោះមានអធិប្បាយថា ព្រោះហេតុដែលព្រះសង្ឃរមែងគួរដល់បុព្វការ ( ការធ្វើឲ្យមុន ) ព្រោះដូច្នោះ ទានវត្ថុ បុគ្គលគួរនាំមកបូជាចំពោះព្រះសង្ឃមុននរណាៗ ទាំងអស់ ហេតុនោះ ព្រះសង្ឃទើបឈ្មោះថា **បាហវនីយ** ( អ្នកដែលគួរនាំរបស់មកបូជាមុន )

ន័យម្យ៉ាងទៀត ព្រះសង្ឃគួរដល់ **អាហវន** ដោយប្រការទាំងពួង ហេតុនោះទើប ឈ្មោះថា **បាហវនីយ** ( អ្នកគួរទទួលរបស់ដែលគេនាំមកបូជាដោយប្រការទាំងពួង ) ស័ព្ទថា **បាហវនីយ** នេះ នោះក្នុងទីដែលពោលថា **បាហុនេយ្យ** ដោយអត្ថ ដូចគ្នា នោះឯង ។

## បទថា ទក្ខិណេយ្យោ

ចំពោះលោកអ្នក ដែលបុគ្គលជឿបរលោកហើយ ទើបឲ្យ ហៅថា **ទក្ខិណា** ព្រះសង្ឃរមែងគួរដល់ទក្ខិណានោះ ឬថា ចម្រើនដល់ទក្ខិណា ព្រោះថា ធ្វើទក្ខិណា ឲ្យបរិសុទ្ធដោយភាវៈ គឺ ធ្វើទក្ខិណានោះឲ្យមានផលច្រើន ព្រោះហេតុនោះ ព្រះ សង្ឃទើប ឈ្មោះថា **ទក្ខិណេយ្យ** ( អ្នកគួរដល់ទក្ខិណា ឬ អ្នកចម្រើនដល់ ទក្ខិណា ) ។

## បទថា អញ្ជលិករណីយោ

ព្រះសង្ឃរមែងគួរដល់អញ្ជលិកម្ម ដែលមហាជនទាំងពួងផ្គុំហត្ថាទាំងពីរ ផ្គងលើសិរសា ធ្វើអញ្ជលិកម្ម ព្រោះហេតុនោះ ទើបឈ្មោះថា **អញ្ជលិករណីយ** ( បុគ្គលគួរដល់ការធ្វើអញ្ជលិកម្ម ) ។

## មហាដីកា

អត្ថន័យនេះ ប្រាកដច្បាស់តាមរឿងហើយថា បច្ច័យ ៤ ប្រភេទណា ដែល គេគប្បីនាំមកបូជា ដូច្នេះ ។ ម្យ៉ាងទៀត បទថា **ទាតព្វំ**-គប្បីប្រគេន ជាបឋមា- វិភត្តិ ដែលប្រាប់ដល់ បទថា **ចតុន្នំ បច្ចយានំ** ហើយក៏ត្រូវផ្លាស់ទៅជាឆដ្ឋីវិភត្តិ

កាលទឹងកាន់យកសេចក្តីដោយប្រការដទៃ , បច្ច័យ ៤ ឯណានីមួយ ( ដែលសូម្បីមិនបាននាំមកអំពីទីឆ្ងាយ ) ក៏គប្បីមានឈ្មោះថា **អាហុន** បាន ។ ម្យ៉ាងទៀត បុគ្គលណា រមែងគួរដល់វត្ថុដែលគេនាំមកបូជា ហេតុនោះ បុគ្គលនោះ ឈ្មោះថា **អាហុនេយ្យោ** ( បុគ្គលគួរដល់វត្ថុដែលគេនាំមកបូជា ) ។ ពាក្យថា **វត្ថុដែលទេវតាទាំងឡាយ មានសក្កទេវរាជជាដើមនាំមកប្រគេន** គឺ អ្នកដែលទេវតាទាំងឡាយមានសក្កទេវរាជជាដើម ប្រគេន ។ ពាក្យថា **ជាទីដែល វត្ថុដែលគេបូជាមានផលច្រើន** មានន័យថា លទ្ធិរបស់ពួកព្រាហ្មណ៍ទាំងនោះថា ភ្លើងឈ្មោះថា **អាហវនីយគ្គី** ជាទីដែលវត្ថុមានទឹកដោះជូរជាដើម ដែលគេបូជាហើយ មានផលច្រើនជាងវត្ថុដែលគេបូជាក្នុងភ្លើងឈ្មោះថា **អានុណេយ្យគ្គិ គហបតគ្គី** និង **ទក្ខិណេយ្យគ្គិ** ដូច្នេះ ។ ពាក្យថា **វត្ថុដែលគេបូជា** គឺ វត្ថុដែលគេប្រគេន ។ ពាក្យថា **ក្នុងនិកាយដទៃ** គឺ ក្នុងនិកាយសព្វត្ថិកវាទី ។ ពាក្យថា **វៀរលែងពួកញាតិទាំងនោះ** គឺ ដកពួកញាតិមិត្តដែលគួរស្រឡាញ់ គួរពេញចិត្តទាំងនោះចេញទៅហើយ អធិប្បាយថា មិនឲ្យដល់មនុស្សទាំងនោះហើយ ( ក៏គួរនឹងប្រគេនដល់ព្រះសង្ឃ ) ។ បទថា **ឯស** បានដល់ **ឯសោ** មានសេចក្តីថា **ឯកពុទ្ធន្តរេ ច ទិស្សតិ** ប្រែថា នឹងប្រាកដចំពោះកាល ពុទ្ធន្តរមួយកន្លងទៅហើយ ។ ដោយ **ច** ស័ព្ទ លោកសម្តែងថា ក្នុងគ្រាខ្លះនឹងប្រាកដ សូម្បីកាលអសង្ខេយ្យកប្បមួយកន្លងទៅហើយ ។ សេចក្តីថា **អព្យោកិណ្ណំ** ( សុទ្ធៗ ) គឺ មិនលាយឡំដោយធម៌ដែលជាបដិបក្ខ មានសេចក្តីថា **អព្យោកិណ្ណំ** នេះជាពាក្យអធិប្បាយកិរិយា ។ ធម៌ទាំងឡាយមានសីលជាដើម ឈ្មោះថា ធម៌ទាំងឡាយដែលកសាងភាពជាមនុស្សគួរស្រឡាញ់ គួរពេញចិត្ត ធម៌ទាំងនោះតាំងមាំល្អក្នុងព្រះអរិយសង្ឃ ។ ក៏ក្នុងសេចក្តីប្រការនេះមានអធិប្បាយដូច្នេះថា ពួក

ញាតិមិត្តដែលបែកគ្នា រមែងមកជួបគ្នាក្នុងកាលមិនយូរឡើយ តែថា ភាពជាបុគ្គល គួរស្រឡាញ់ គួរពេញចិត្ត មិនបានតាំងចុះក្នុងបុគ្គលទាំងនោះ ព្រះអរិយសង្ឃនឹង ដូចគ្នាយ៉ាងនោះ ក៏ទេ ។ ព្រោះដូច្នោះ ព្រះសង្ឃប៉ុណ្ណោះ ឈ្មោះថា **បាហុនេយ្យ** ដូច្នេះ ។ ពាក្យថា **ការធ្វើឲ្យមុន** គឺ ការធ្វើឲ្យជាកំពូល ។ ពាក្យថា **ដោយប្រការ ទាំងពួង** គឺ ដោយប្រការទាំងពួង មានការអើពើ ការគោរព ការរាប់អានស្និទ្ធ ជាដើម និង មានការធ្វើទេយ្យធម៌យ៉ាងគោរពជាដើម ។ ស័ព្ទថា **បាហវនីយ** នេះ ធ្លាប់ហៅថា **បាហុនេយ្យ** ក៏បាន ព្រោះជាពាក្យបរិយាយ ។

**ទាន** ដែលបុគ្គលគប្បីឲ្យ ព្រោះជឿបរលោក ឈ្មោះថា **ទក្ខិណា** ព្រោះអត្ថ ថា ជាហេតុឲ្យសត្វទាំងឡាយរុងរឿង គឺ ចម្រើនដោយសម្បត្តិតាមបំណង ។ ព្រះ សង្ឃ ឈ្មោះថា គួរដល់ទក្ខិណា ព្រោះធ្វើភាពជាយ៉ាងនោះ ( សេចក្ដីចម្រើន ដោយសម្បត្តិទាំងឡាយ ) ។ **ទាន** ឈ្មោះថា បុគ្គលនោះ ជម្រះឲ្យបរិសុទ្ធបាន ហើយ ក៏ព្រោះការបានផលបរិបូរណ៍ដ៏ធំក្រៃលែង យ៉ាងណា **ទក្ខិណា** ក៏ឈ្មោះថា ព្រះសង្ឃជម្រះឲ្យបរិសុទ្ធបានហើយ ព្រោះមានផលបរិបូណ៌យ៉ាងនោះ ព្រោះហេតុ នោះ លោកទើបពោលថា ព្រោះហេតុដែលជម្រះទក្ខិណានោះ ឲ្យបរិសុទ្ធ ដើម្បីធ្វើ ឲ្យមានផលច្រើន ។

ជនទាំងឡាយដែលត្រូវការបុណ្យ គប្បីធ្វើអញ្ជលីចំពោះព្រះសង្ឃ ព្រោះ ហេតុនោះ ព្រះសង្ឃនោះ ទើបឈ្មោះថា **អញ្ជលិករណីយ** ។

( ចប់ មហាដីកា )

## បទថា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស

បទថា **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** មានសេចក្តីថា ព្រះសង្ឃជាកន្លែងសាបព្រោះ ជាស្រែបុណ្យរបស់សត្វលោកទាំងពួង មិនមានទីស្មើដូច ប្រៀបដូចទីសំណាបស្រូវសាលីក្តី ស្រូវដំណើបក្តីរបស់ព្រះរាជា ឬ របស់អមាត្យក៏ដោយ គេហៅថា **រញ្ញោសាលិក្ខេត្តំ រញ្ញោយវក្ខេត្តំ** ស្រែស្រូវសាលីរបស់ព្រះរាជា ស្រែស្រូវដំណើបរបស់ព្រះរាជាដូច្នេះជាដើម យ៉ាងណា ព្រះសង្ឃក៏ជាស្រែបុណ្យរបស់សត្វលោកទាំងពួងក៏ដូច្នោះ ពិតណាស់ ព្រោះអាស្រ័យព្រះសង្ឃ បុណ្យទាំងឡាយដែលជាគ្រឿងនាំមកនូវប្រយោជន៍ និង សេចក្តីសុខច្រើនប្រការ របស់សត្វលោកទើបបានដុះឡើង ព្រោះហេតុនោះ ព្រះសង្ឃ ទើបជាស្រែបុណ្យរបស់សត្វលោកមិនមានស្រែដទៃក្រៃលែងជាងឡើយ ។

## សង្ឃានុស្សតិជ្ឈាន

កាលព្រះយោគាវចររឭកដល់សង្ឃគុណទាំងឡាយ ដែលមានគុណផ្សេងៗ មានភាពជាអ្នកបដិបត្តិល្អជាដើម ដូចពោលមកដូច្នេះ ក្នុងសម័យនោះ ចិត្តរបស់លោករមែងមិនជាចិត្តដែលរាគៈរួបរិត មិនជាចិត្តដែលទោសៈរួបរិត មិនជាចិត្តដែលមោហៈរួបរិតឡើយ ក្នុងសម័យនោះ ចិត្តរបស់លោករមែងជាចិត្តដំណើរទៅត្រង់គន្លង ប្រារព្ធព្រះសង្ឃ អង្គឈានទាំងឡាយ រមែងកើតឡើង ក្នុងខណៈដូចគ្នាដល់លោកអ្នកគ្របសង្កត់នីវរណៈបានហើយ ដោយន័យមុន ដែលពោលនៅក្នុងពុទ្ធានុស្សតិនោះឯង តែព្រោះសង្ឃគុណទាំងឡាយ ជាអារម្មណ៍ជ្រាលជ្រៅ ឬ ព្រោះចិត្តបង្អោនទៅក្នុងការរឭកដល់ព្រះគុណ មានប្រការផ្សេងៗ ឈានទេះ ទើបជា

ឈានដែលមិនដល់អប្បនា ដល់ត្រឹមតែឧបចារប៉ុណ្ណោះឯង ឈាននេះ ក៏ដល់នូវការហៅឈ្មោះថា **សង្ឃានុស្សតិនោះឯង** ព្រោះជាឈានដែលកើតឡើងដោយអំណាចការរឭកដល់ព្រះសង្ឃគុណ ។

## អានិសង្សនៃការចម្រើនសង្ឃានុស្សតិ

ក៏ឯភិក្ខុដែលប្រកបរឿយៗ នូវសង្ឃានុស្សតិនេះ រមែងជាអ្នកមានការគោរពកោតក្រែងចំពោះព្រះសង្ឃ មានភាពបរិបូណ៌នៃគុណ មានសទ្ធាជាដើម ជាអ្នកច្រើនទៅដោយបីតិ និងបាមោជ្ជ អត់ធន់ចំពោះការខ្លាច និងការភិតភ័យ អាចអត់សង្កត់នូវទុក្ខ មានការដឹងខ្លួនដូចជាបាននៅជាមួយព្រះសង្ឃ ម្យ៉ាងវិញទៀត សូម្បីសរីរៈរបស់លោកដែលសង្ឃគុណានុស្សតិប្រថាប់នៅ រមែងជាសរីរៈគួរដល់ការបូជាដូចរោងឧបោសថដែលមានសង្ឃប្រជុំគ្នាដូច្នោះ ចិត្តរបស់លោករមែងបង្អោនទៅក្នុងការសម្រេចដល់សង្ឃគុណ ម្យ៉ាងវិញទៀត ក្នុងកាលមានការជួបប្រទះវត្ថុដែលគួរកន្លងល្មើស ហិរិឱត្តប្បៈ ក៏រមែងប្រាកដដល់លោក ដែលដឹងខ្លួនហាក់បីដូចឃើញព្រះសង្ឃនៅចំពោះមុខ ម្យ៉ាងវិញទៀត កាលនៅមិនទាន់សម្រេចគុណដែលក្រៃលែងឡើងទៅ លោករមែងជាអ្នកមានសុគតិជាទីទៅខាងមុខ ។

**ព្រោះហេតុនោះឯង អ្នកមានបញ្ញាល្អ មិនគប្បីប្រមាទ ក្នុងសង្ឃានុស្សតិដែលមានអានុភាពច្រើនយ៉ាងនេះ គ្រប់កាលទៅចុះ ។**

នេះជាកថាមុខយ៉ាងពិស្តារ ក្នុងសង្ឃានុស្សតិ ។

# មហាដីកា

សូម្បីក្នុងព្រះបាលីពោលទុកថា **អនុត្តរំ** ។ ក៏ឈ្មោះថា **អនុត្តរំ** ព្រោះអត្ថថា មិនមានស្ថានទីដទៃក្រៃលែងជាង គឺ ពិសេសជាងស្ថានទីនេះដូច្នេះក៏ពិត ។ សូម្បីយ៉ាងនោះ លោកអាចារ្យកាលនឹងសម្តែងថា សូម្បីតែស្ថានទីស្មើគ្នា ក៏គង់មិនមានដូច្នេះ ទើបពោលថា ដែលរកស្ថានទីដទៃស្មើដូចមិនបាន ដូច្នេះ ។ វាលស្រែជាដើម ឈ្មោះថា **ខេត្ត** ព្រោះអត្ថថា រមែងការពារ គឺ រក្សានូវពូជដែលគេព្រោះ គឺ បាចចុះឲ្យសម្រេចបានផលច្រើន ឬព្រោះអត្ថថា ជាទីសំណាប គឺ សាបព្រោះពូជទាំងឡាយ, ព្រះសង្ឃដូចជាស្រែ ទើបឈ្មោះថា **ខេត្ត** , **ខេត្ត** នៃបុណ្យទាំងឡាយ ឈ្មោះថា **បុញ្ញក្ខេត្ត** ។ ពាក្យដ៏សេស ក៏គប្បីជ្រាបតាមទំនងន័យ ដែលខ្ញុំព្រះករុណាបានពោលហើយ ក្នុងពុទ្ធានុស្សតិចុះ ។

( ចប់ សង្ឃានុស្សតិ )

# សីលានុស្សតិ

ចំណែកថា ព្រះយោគាវចរដែលប្រាថ្នានឹងចម្រើនសីលានុស្សតិ គប្បីជាអ្នកទៅក្នុងទីកំបាំងមនុស្ស សម្ងំនៅក្នុងសេនាសនៈដ៏សមគួរហើយ រឭកដល់សីលទាំងឡាយរបស់ខ្លួន ដោយការរឭកដល់គុណសម្បត្តិនៃសីល មានភាពជាសីលមិនដាច់ជាដើម ក្នុងន័យថា ឱ សីលទាំងឡាយរបស់យើងមិនដាច់ហ្ន៎ ឱ សីលទាំងឡាយរបស់យើងមិនធ្លុះហ្ន៎... មិនពពាលហ្ន៎... មិនពព្រុសហ្ន៎... ជាឥស្សរៈហ្ន៎... អ្នកប្រាជ្ញសរសើរហ្ន៎ ... មិនត្រូវបរាមាសៈហ្ន៎ ... ជាផ្លូវសមាធិហ្ន៎ ដូច្នេះ ក៏សីលទាំងនោះ អ្នកដែលជាគ្រហស្ថ គប្បីរឭកដល់សីលដែលជារបស់គ្រហស្ថ បព្វជិតក៏គប្បីរឭកដល់សីលដែលជារបស់បព្វជិត ទោះជាសីលរបស់គ្រហស្ថ ឬសីលរបស់បព្វជិតក៏ដោយ តែសិក្ខាបទសូម្បីមួយខាងដើម ឬក្នុងខាងចុងរបស់សីលពួកណាមិនបែកធ្លាយ សីលទាំងនោះ ឈ្មោះថា **អខណ្ឌ** ព្រោះមិនដាច់ ដូចសំពត់ដាច់ជាយ ។

សិក្ខាបទសូម្បី ១ ក្នុងកណ្ដាលរបស់សីលពួកណាមិនបែកធ្លាយ សីលទាំងនោះ ឈ្មោះថា **អច្ឆិទ្ទ** ព្រោះមិនធ្លុះដូចសំពត់ធ្លុះចំកណ្ដាលផ្ទាំង ។

សិក្ខាបទ ២-៣ តាមលំដាប់របស់សីលពួកណាមិនបែកធ្លាយ សីលពួកនោះ ឈ្មោះថា **អសពល** ព្រោះមិនពពាល-ដាង ដូចមេគោដែលមានខ្នងពណ៌ខ្មៅ ឬ ពណ៌ក្រហមជាដើមឯណានីមួយ មានពណ៌ដែលកាត់ជាមួយពណ៌ខ្លួន មានសណ្ឋានផ្សេងៗ ដូចជាទ្រវែង ឬ មូល ប្រាកដត្រង់ខ្នងខ្លះ ត្រង់ពោះខ្លះ ដូច្នោះ ។

សិក្ខាបទពួកណាមិនបែកធ្លាយក្នុងចន្លោះៗ សីលទាំងនោះ ឈ្មោះថា **អកម្មាស** ព្រោះមិនពពាលដូចមេគោ ដែលលាយចម្រុះទៅដោយចំណុចពណ៌ ដែលធ្លាស់នឹង

ពណ៌ិខ្លួន ។

ន័យម្យ៉ាងទៀត ដោយអត្ថដែលមិនប្លែកគ្នា សីលទាំងពួងឈ្មោះថា មិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ព្រោះមិនត្រូវមេថុនសំយោគ ៧ ប្រការ និង បាបធម៌ទាំងឡាយ មានកោធៈ ឧបនាហៈជាដើម ចូលមកទម្លាយ ។

សីលទាំងនោះឯង ឈ្មោះថា **ភុជិស្ស** ព្រោះផុតចាកភាពជាទាសៈនៃតណ្ហា ហើយធ្វើភាពជាឥស្សរៈបាន ។

ឈ្មោះថា **វិញ្ញូបសត្ថ** ព្រោះជាសីលដែលលោកអ្នកប្រាជ្ញទាំងឡាយ មាន ព្រះពុទ្ធជាដើមសរសើរ ។

ឈ្មោះថា **អបរាមដ្ឋ** ព្រោះជាសីលដែលតណ្ហានិងទិដ្ឋិមិនបរាមាស ( ស្ទាប អង្អែល ) ឬថា ព្រោះជាសីលដែលនរណាៗ មិនអាចតិះដៀលបានថា **នេះជា សេចក្តីវិនាសក្នុងសីលទាំងឡាយរបស់អ្នក** ។

ឈ្មោះថា **សមាធិសំវត្តនិក** ព្រោះញុំាងឧបចារសមាធិ ឬអប្បនាសមាធិឲ្យ សម្រេច ឬមិនដូច្នោះ ញុំាំងមគ្គសមាធិ និងផលសមាធិឲ្យសម្រេចបាន ។

## សីលានុស្សតិដ្ឋាន

កាលព្រះយោគាវចរនោះ រឭកដល់សីលទាំងឡាយរបស់ខ្លួន ដោយគុណ មានសីលមិនដាច់ជាដើមដូច្នេះ ក្នុងសម័យនោះ ចិត្តរបស់លោករមែងមិនជាចិត្ត ដែលរាគៈរួបរឹត មិនជាចិត្តដែលទោសៈរួបរឹត មិនជាចិត្តដែលមោហៈរួបរឹតឡើយ ក្នុងសម័យនោះ ចិត្តរបស់លោក រមែងជាចិត្តដំណើរទៅត្រង់គន្លង ប្រារព្ធសីល ហើយអង្គឈានទាំងឡាយ រមែងកើតឡើងក្នុងខណៈតែមួយ ដល់លោកដែលបាន

គ្រប់សង្កត់នីវរណៈបានហើយ តាមន័យមុន ( ដែលពោលក្នុងពុទ្ធានុស្សតិ ) នោះឯង តែព្រោះសីលគុណទាំងឡាយជាអារម្មណ៍ជ្រាលជ្រៅ ឬ ព្រោះចិត្តបង្អោនទៅក្នុងការរឭកដល់គុណនានា ច្រើនប្រការ ឈាននេះ ទើបជាឈានមិនដល់អប្បនា ដល់ត្រឹមតែឧបចារប៉ុណ្ណោះ ហើយឈាននេះក៏ដល់នូវការហៅឈ្មោះថា **សីលានុស្សតិ** នុ៎ះឯង ព្រោះជាឈានដែលកើតឡើងដោយអំណាចការរឭកដល់សីលគុណ។

## អានិសង្សនៃការចម្រើនសីលានុស្សតិ

ក៏ឯភិក្ខុដែលប្រកបរឿយៗ នូវសីលានុស្សតិនេះ រមែងជាអ្នកមានសេចក្តីគោរពក្នុងសិក្ខា មានការប្រព្រឹត្តសមគួរ មិនប្រមាទក្នុងការបដិសណ្ឋារៈ ប្រាសចាកភ័យ មានអត្តានុវាទភ័យ ( ភ័យ គឺ ខ្លួនតិះដៀលខ្លួនឯង ) ជាដើម ( សំដៅយកភ័យ ៤ គឺ **អត្តានុវាទភ័យ** ( ខ្លួនតិះដៀលខ្លួនឯង ) **បរានុវាទភ័យ** ( អ្នកដទៃតិះដៀល ) **ទណ្ឌភ័យ** ( ត្រូវចាប់ដាក់អាជ្ញា ) **ទុគ្គតិភ័យ** ( ស្លាប់ទៅហើយទៅកាន់ទុគ្គតិ ) មានប្រក្រតីឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច មានភាពបរិបូណ៌នៃគុណ មានសទ្ធាជាដើម ជាអ្នកចម្រើនទៅដោយបីតិ និង បាមោជ្ជ , ម្យ៉ាងវិញទៀត កាលនៅមិនទាន់សម្រេចគុណដែលក្រៃលែងឡើងទៅ លោករមែងជាអ្នកមានសុគតិ ជាទីទៅក្នុងខាងមុខ ។

ព្រោះហេតុនោះ បុគ្គលអ្នកមានបញ្ញាល្អ គប្បីធ្វើសេចក្តីមិនប្រមាទក្នុងសីលានុស្សតិ ដែលមានអានុភាពច្រើននេះ គ្រប់កាលទៅចុះ ។

នេះជាកថាមុខ យ៉ាងពិស្តារក្នុងសីលានុស្សតិ ។

# មហាដីកា

# អធិប្បាយ សីលានុស្សតិ

គប្បីប្រកបពាក្យពោលក្នុងបទទាំងពួងយ៉ាងនេះថា **អហោ វត មេ សីលានិ អខណ្ឌានិ** ( ឱ សីលរបស់យើងមិនដាច់ហ្ន៎ ) ។ **អហោ វត អច្ឆិទ្ទានិ** ( ឱ សីលរបស់យើងមិនធ្លុះហ្ន៎ ) ជាដើម ។ ក្នុងពាក្យថា **អហោ វត** ( ដែលប្រែថា ឱហ្ន៎ ) ជានិបាតស័ព្ទក្នុងអត្ថថា លើកសរសើរ ។ ព្រោះហេតុនោះ លោកទើបពោលថា ដោយអំណាចនៃគុណ មានភាពជាសីលមិនដាច់ជាដើម ដូច្នេះ , មានសេចក្ដីថា ដោយអំណាចនៃសម្បត្តិ មានសភាពជាសីលមិនដាច់ជាដើម ។ សីលរបស់អ្នកដទៃដែលព្រះយោគីតាមរឭកដល់ រមែងជាបទដ្ឋាននៃមេត្តាតែម្យ៉ាង ដោយហេតុនាំមកនូវភាពជាបុគ្គល ដែលគួរស្រឡាញ់ គួរពេញចិត្ត ទើបមិនបានជាកម្មដ្ឋាន ព្រោះហេតុនោះ លោកទើបពោលថា រឭករឿយៗ ដល់សីលរបស់ខ្លួនដូច្នេះ ។ សូម្បីក្នុងចាគានុស្សតិជាដើម ក៏មានន័យដូច្នេះដែរ ។

បទថា **យេសំ** បានដល់ សីល ( សីលពួកណា ) ។ សិក្ខាបទដំបូង និងសិក្ខាបទចុងបញ្ចប់នៃសីល គប្បីជ្រាបបានដោយលំដាប់នៃការសមាទាន ក្នុងគ្រាដែលសមាទានតាមលំដាប់សិក្ខាបទ ដោយលំដាប់ឧទ្ទេស ( មាតិកា ) ក្នុងគ្រាសមាទានព្រមគ្នា ។ បាលីថា **បរិយន្តេ ឆិន្នសាដកោ វិយ** ( ក្នុងវិសុទ្ធិមគ្គ ជា **បរិយន្តឆិន្នសាដកោ វិយ** ) គឺ ដូចជាសំពត់ដែលដាច់ជាយ ឬ ត្រង់រឹមសំពត់ ក៏សេចក្ដីនេះជាឧទាហរណ៍ ប្រៀបជាមួយវត្ថុដែលមិនដូចគ្នា ( គឺ សីលមិនដាច់ តែសំពត់ដាច់ ) ។ សូម្បីឧទាហរណ៍ដ៏សេស ក៏យ៉ាងនេះ ។ សំពត់ដែលដាច់ដោយ

អំណាចផ្ទុះជាប្រហោង ឈ្មោះថា សំពត់ដែលធ្លុះ ។ ភ្ជាប់សេចក្តីថា **វិសភាគវណ្ណេន គាវី វិយ** ។ម្យ៉ាងទៀត សីលដែលវៀរចាកភាពពពាល ឈ្មោះថា **អសពល** ។ **សីល** ឈ្មោះថា **អកម្មស្ស** ( មិនពព្រុស ) ក៏ដោយអាការដូចគ្នានោះ ។ មេថុនសំយោគ ៧ យ៉ាង លោកបានពោលហើយក្នុងសីលកថា ក្នុងខាងដើមនោះឯង ។ បទថា **កោធុបនាហាទីហិ** ( បាបធម៌ទាំងឡាយ មានកោធៈឧបនាហៈជាដើម ) ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) លោកកាន់យកបាបធម៌ទាំងឡាយ មាន មក្ខៈ ( ការលប់គុណ ) បលាសៈ ( ការវាយស្មើ ) ឥស្សា ( ការប្រណែន ) មច្ឆរិយៈ ( សេចក្តីកំណាញ់ ) មាយា ( ការបោកបញ្ឆោត ) សាឋេយ្យ ( អំណួត ) មានះ ( ការលើកតម្កើងខ្លួន ) អតិមានះ ( ការលើកតម្កើងខ្លួនក្រៃលែង ) ជាដើម ។ ឈ្មោះថា **សីលទាំងឡាយនោះឯង** បានដល់សីលដែលមានគុណ គឺ មិនដាច់ជាដើម ។ ឈ្មោះថា **ការដែលសីលធ្វើសត្វឲ្យផុតអំពីភាពជាទាសៈនៃតណ្ហា** បានដល់ ការធ្វើឲ្យដល់ភាពជាឧបនិស្ស័យនៃវិវដ្តៈ ។ ព្រោះហេតុនោះឯង បុគ្គលដែលដល់ព្រមដោយសីលនោះ ទើបជាបុគ្គលមានសិរី គឺ មានអំណាចក្នុងខ្លួនឯង ឈ្មោះថា **ឥស្សរៈ** ។ ព្រោះហេតុនោះ លោកទើបពោលថា ឈ្មោះថា **ភុជិស្ស** ព្រោះសាងឥស្សរភាព ( សីល ឈ្មោះថា អបរាមដ្ឋៈ-មិនត្រូវស្ទាបអង្អែល ) ព្រោះមិនត្រូវតណ្ហានិងទិដ្ឋិស្ទាបអង្អែល ដោយន័យយ៉ាងនេះថា ដោយសីលនេះ សូមឲ្យយើងបានជាទេវៈជាម្ចាស់ ឬទេវតាពួកណានីមួយ ដែលទៀងទាត់ ស្ថិតស្ថិរនៅក្នុងទីនោះ ដូច្នេះ និងថា សេចក្តីបរិសុទ្ធ រមែងមានបានព្រោះសីល ដូច្នេះជាដើម ។ ពាក្យថា **នេះជាការខូចក្នុងសីលរបស់អ្នក** គឺ មិនអាចនឹងត្រូវមើលងាយ គឺ សង្កត់សង្កិនព្រោះឃើញភាពវិបរិត ៤ យ៉ាងឯណា

ទីមួយ ( មានការដាច់ជាដើម ) ។ សីលមានការធ្វើសមាធិឲ្យប្រព្រឹត្តទៅព្រម ជាប្រយោជន៍ ឈ្មោះថា **សមាធិសំវត្តនិក** ។

ពាក្យថា **រមែងជាអ្នកមានសេចក្ដីគោរពក្នុងសិក្ខា** គឺ រមែងជាអ្នកមានសេចក្ដីគោរព មានសេចក្ដីកោតក្រែងក្នុងសិក្ខាយ៉ាងក្រៃលែង ព្រោះអាស្រ័យទ្រព្យ គឺសីល ក៏បានទីតាំងមាំទាំ ។ ពាក្យថា **ប្រព្រឹត្តសមគួរ** គឺ ជាអ្នកមានការប្រព្រឹត្តសមគួរដោយសីល ដែលដល់ព្រម ឬថា ជាអ្នកប្រព្រឹត្តសមគួរក្នុងសិក្ខានោះឯង ។ ព្រោះពោលដោយត្រឡប់គ្នា បុគ្គលណាប្រាសចាកសេចក្ដីគោរពក្នុងសិក្ខា បុគ្គលនោះឈ្មោះថា ជាអ្នកប្រព្រឹត្តមិនសមគួរក្នុងសិក្ខានោះ ។ ការទទួលដោយធម៌ និងអាមិស ដោយប្រការដែលមិនមានចន្លោះទំនេររវាងខ្លួននិងអ្នកដទៃ ឈ្មោះថា បដិសណ្ឋារៈ ។ ភិក្ខុឈ្មោះថា ជាអ្នកមិនប្រមាទក្នុងបដិសណ្ឋារៈនោះ ក៏ព្រោះមានសេចក្ដីគោរពក្នុងសិក្ខានោះឯង ។ ភ័យទាំងឡាយនេះ គឺ អត្តានុវាទភ័យ ( ភ័យព្រោះការតិះដៀលខ្លួនឯង ) បរានុវាទភ័យ ( ភ័យ គឺ ត្រូវអ្នកដទៃតិះដៀល ) ទណ្ឌភ័យ ( ភ័យ គឺ ការត្រូវដាក់ទណ្ឌ ) ទុគ្គតិភ័យ ( ភ័យ គឺ ទុគ្គតិ ) ដូច្នេះជាដើម គឺ ត្រូវភិក្ខុនេះបន្សាត់ទៅឆ្ងាយហើយ ព្រោះហេតុនោះ លោកទើបពោលថា ប្រាសចាកភ័យ មានភ័យ គឺ ការតិះដៀលខ្លួនឯងជាដើម ដូច្នេះ , ពាក្យដ៏សេស គប្បីដឹងបានងាយទាំងអស់ ។

( ចប់ សីលានុស្សតិ )

# ចាគានុស្សតិ

ចំណែកបុគ្គលប្រាថ្នា នឹងចម្រើនចាគានុស្សតិ ត្រូវជាអ្នកមានចិត្តបង្អោនទៅក្នុងចាគៈ មានការឲ្យ និង ការចែករំលែក ( **ទានសំវិភាគ** ធ្លាប់បានឮប្រែរួមៗ ថាចែករំលែកទានក៏មាន តែក្នុងទីនេះលោកចែកជាពីរ ចាត់ចែងរបស់ទុកសម្រាប់អ្នកដទៃ ហៅថា **ទាន** , ចែករំលែកអំពីរបស់ដែលខ្លួនបរិភោគ ហៅថា **សំវិភាគ** ) ប្រព្រឹត្តទៅជានិច្ច ឬបើមិនដូច្នោះ កាលនឹងផ្តើមចម្រើន គប្បីធ្វើការសមាទានថា ឥឡូវនេះ ចាប់ផ្តើមអំពីកាលនេះទៅ កាលបដិគ្គាហកៈមានហើយ យើងកាលមិនបានឲ្យទាន ដោយហោចសូម្បីបាយមួយវែកហើយ នឹងមិនបរិភោគ ដូច្នេះហើយ ឲ្យទានតាមសមគួរដល់សមត្ថភាព ឬ តាមកម្លាំង ចំពោះបដិគ្គាហកៈទាំងឡាយ ដែលវិសេសដោយគុណ ឲ្យបានក្នុងថ្ងៃនោះ ហើយកាន់យកនិមិត្តក្នុងទាននោះ ទៅក្នុងទីស្ងាត់មនុស្ស សម្ងំនៅក្នុងសេនាសនៈដែលសមគួរ ហើយរឭកដល់ចាគៈរបស់ខ្លួនដោយរឭកដល់គុណ មានការប្រាសចាកសេចក្តីកំណាញ់ ដែលជាតួមន្ទិលជាដើមយ៉ាងនេះថា ជាលាភរបស់យើងហ្ន៎ យើងបានល្អហើយហ្ន៎ កាលដែលប្រជា ត្រូវមន្ទិល គឺ សេចក្តីកំណាញ់រួបរឹត យើងបែរជាមានចិត្តប្រាសចាកសេចក្តីកំណាញ់ដែលជាមន្ទិល មានការលះបង់ដាច់ស្រឡះ មិនស្តាយអាល័យ ឬសង្ឃឹមផលតបស្នង មានដៃបានលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ការសូម ពេញចិត្តក្នុងការឲ្យ និងចែករំលែក ។

## អធិប្បាយ អនុស្សរណាចារ

ក្នុងបាឋៈទាំងនោះ ពាក្យថា **លាភា វត មេ** នោះគឺ **មយ្ហំ វត លាភា**

លាភរបស់យើងហ្ន៎ អធិប្បាយថា លាភទាំងឡាយរបស់អ្នកដែលជាទាយក ដែល ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ពណ៌នាទុកច្រើនន័យជាដើមថា ... ក៏ឯអ្នកជាទាយក នោះ កាលឲ្យអាយុហើយ រមែងជាអ្នកមានចំណែកនៃអាយុដែលជារបស់ទិព្វខ្លះ ជារបស់មនុស្សខ្លះ ដូច្នេះជាដើមក្ដី ថា អ្នកឲ្យរមែងជាទីស្រឡាញ់ ជនជាច្រើន រមែងគប់រកគេដូច្នេះក្ដី ថា បុគ្គលកាលប្រព្រឹត្តតាមធម៌របស់សប្បុរសទាំងឡាយ កំពុងឲ្យទាន រមែងជាទីស្រឡាញ់ដូច្នេះក្ដី ទាំងនេះឯង លាភទាំងឡាយទាំងនោះ ជាចំណែករបស់យើងពិតប្រាកដ ។

ពាក្យថា **សុលទ្ធំ វត មេ** យើងបានល្អហើយហ្ន៎ មានសេចក្ដីថា ព្រះ សាសនានេះ ឬថា អត្តភាពមនុស្សនេះដែលយើងបានហើយ ព្រះសាសនា ឬអត្ត ភាពមនុស្សនោះ ឈ្មោះថា យើងបានល្អហើយហ្ន៎ សួរថា ព្រោះហេតុអ្វី ? ឆ្លើយ ថា ព្រោះកាលពពួកសត្វត្រូវមន្ទិល គឺ សេចក្ដីកំណាញ់រួបរឹត យើងបែរមានចិត្ត ប្រាសចាកសេចក្ដីកំណាញ់ជាមន្ទិល ។ល។ ពេញចិត្តក្នុងការឲ្យ ការចែករំលែក ។

ក្នុងបទទាំងនោះ បទថា **មច្ឆេរ មលបរិយុដ្ឋិតាយ** ត្រូវមន្ទិល គឺ សេចក្ដី កំណាញ់រួបរឹត សំដៅយកសេចក្ដីថា ត្រូវមន្ទិល គឺ សេចក្ដីកំណាញ់គ្របសង្កត់ ។ បទថា **បជាយ** កាលប្រជា មានសេចក្ដីថា សត្វទាំងឡាយ លោកហៅថា **បជា** ដោយភាពដែលបានកំណើតមកតាមកម្មរបស់ខ្លួន ព្រោះដូច្នោះ ក្នុងសេចក្ដីនេះ ទើប មានអត្ថន័យដូច្នេះថា កាលសត្វទាំងឡាយត្រូវមន្ទិល គឺ សេចក្ដីកំណាញ់ ដែល មានការទ្រាំមិនបាន ក្នុងសម្បត្តិទាំងឡាយរបស់ខ្លួន ទៅជារបស់សាធារណៈដល់ អ្នកដទៃ ៗ ជាលក្ខណៈ ជាជំពូកធម៌ខ្មៅ ដែលជាគ្រឿងប្រទូសរ៉ាយដល់ភាពជា បភស្សរៈ ( ផូរផង់ ) នៃចិត្តឯណានីមួយ គ្របសង្កត់យកហើយ ។

បទថា **វិគតមល មច្ឆេរេន** មានសេចក្តីថា ឈ្មោះថា ប្រាសចាកមន្ទិល និង សេចក្តីកំណាញ់ ព្រោះមន្ទិលដទៃៗ ដូចជា រាគៈ ទោសៈ និង សេចក្តីកំណាញ់ ប្រាសទៅហើយ ។ ពាក្យថា **ចេតសា វិហរាមិ** មានសេចក្តីថា យើងជាអ្នកមាន ចិត្ត មានប្រការដូចពោលមកហើយ ។ ចំណែកក្នុងព្រះសូត្រទ្រង់ត្រាស់ថា **អគារំ អជ្ឈាវសាមិ** យើង....នៅគ្រប់គ្រងផ្ទះ ព្រោះកាលព្រះបាទមហានាមសក្យៈ ដែលជា ព្រះសោតាបន្នទូលសួរដល់និស្ស័យវិហារ ធម៌ជាទីអាស្រ័យរបស់ព្រះសោតាបន្ន ក៏ ទ្រង់សម្តែងទៅដោយគន្លងនិស្ស័យវិហារធម៌ផងគ្នា ក្នុងសេចក្តីថា **អជ្ឈាវសាមិ** នោះថា **អភិភវិត្វា វសាមិ** - យើងនៅគ្រប់គ្រងផ្ទះ ។

បទថា **មុត្តចាគោ** ប្រែថា មានការលះបង់ដាច់ស្រឡះ ។

បទថា **បយតបាណី** សំដៅយកសេចក្តីថា មានដៃស្អាត មានពាក្យអធិប្បាយ ថា មានដៃដែលលាងទុកគ្រប់កាល ដើម្បីនឹងឲ្យទេយ្យធម៌ដោយដៃខ្លួនដោយគោរព ។

បទថា **វោស្សគ្គរតោ** អធិប្បាយថា ការលះបង់ឈ្មោះថា **វោស្សគ្គ** សេចក្តី ក៏គឺ បរិច្ចាគ ( នោះឯង ) បុគ្គលឈ្មោះថា **វោស្សគ្គរត** ព្រោះត្រេកអរ ដោយ ការប្រកបយ៉ាងក្រៃលែងរឿយៗ ក្នុងវោស្សគ្គៈនោះ ។

បទថា **យាចយោគោ** អធិប្បាយថា ជាអ្នកគួរក្នុងការសុំ ព្រោះមនុស្សដទៃៗ សុំវត្ថុណា ក៏ឲ្យវត្ថុនោះៗ បាឋៈថា **យាជយោគោ** ក៏មាន ប្រែថា ដែលប្រកបដោយ **យាជ** ពោលគឺ ការបូជា ( ការឲ្យ ) ។

បទថា **ទានសំវិភាគរតោ** ប្រែថា ត្រេកអរក្នុងការឲ្យ និងការចែករំលែកផង សេចក្តីថា ព្រះយោគាវចរ ដែលទាយករមែងរឭក ( ក្នុងប្រការនេះ ) យ៉ាងនេះ ថា យើងនេះឯង ឲ្យទានផង ធ្វើការចែករំលែក សូម្បីអំពីរបស់ដែលខ្លួននឹងគប្បី

បរិភោគផង ជាអ្នកត្រេកអរក្នុងការឲ្យ និងការចែករំលែកទាំងពីរយ៉ាងនោះឯងផង ។

# ចាគានុស្សតិជ្ឈាន

កាលព្រះយោគាវចរនោះរឭកដល់ចាគៈរបស់ខ្លួន ដោយ ( រឭកដល់ ) គុណមានភាពជាអ្នកប្រាសចាកសេចក្ដីកំណាញ់ ដែលជាតួមន្ទិលជាដើមយ៉ាងនេះ ក្នុងសម័យនោះ ចិត្ត ( របស់លោក ) រមែងមិនជាចិត្តដែលរាគៈរួបរឹត មិនជាចិត្តដែលទោសៈរួបរឹត មិនជាចិត្តដែលមោហៈរួបរឹតសោះតែម្ដង ក្នុងសម័យនោះ ចិត្តរបស់លោក រមែងជាចិត្តប្រព្រឹត្តទៅត្រង់ផ្លូវប្រារព្ធចាគៈ អង្គឈានទាំងឡាយរមែងកើតឡើងក្នុងខណៈនោះឯង ដល់លោកដែលសង្កត់នីវរណៈបានហើយ ដូចន័យដែលបានពោលទុកនៅក្នុងពុទ្ធានុស្សតិនោះឯង តែព្រោះចាគគុណទាំងឡាយ ជាអារម្មណ៍ជ្រាលជ្រៅ ឬ ព្រោះជាចិត្តដែលបង្អោនទៅក្នុងការរឭកដល់ចាគគុណនានាច្រើនប្រការ ឈាននេះ ទើបជាឈានដែលមិនដល់អប្បនា ដល់ត្រឹមតែឧបចារប៉ុណ្ណោះ ហើយឈាននេះក៏ដល់នូវការរាប់ឈ្មោះថា **ចាគានុស្សតិនោះឯង** ព្រោះជាឈានដែលកើតឡើង ដោយអំណាចការរឭកដល់ចាគគុណ ។

## អានិសង្សនៃការចម្រើនចាគានុស្សតិ

ក៏ឯភិក្ខុដែលប្រកបរឿយៗ នូវចាគានុស្សតិនេះ រមែងជាអ្នកបង្អោនទៅក្នុងការលះបង់ដោយប្រមាណក្រៃលែង គឺ ក្រៃលែងឡើងគ្រប់ពេល មានអធ្យាស្រ័យមិនលោភ ធ្វើសមគួរដល់មេត្តា នៅដោយប្រក្រតី ក្លាហានក្នុងជំនុំជនច្រើន ច្រើនទៅដោយបីតិនិងបាមោជ្ជ ម្យ៉ាងវិញទៀត កាលមិនទាន់សម្រេចគុណវិសេសក្រៃ-

លែងឡើងទៅ លោករមែងជាអ្នកមានសុគតិ ជាទីទៅក្នុងខាងមុខ ។

**ព្រោះហេតុនោះឯង បុគ្គលមានបញ្ញាល្អ គប្បីធ្វើសេចក្តីមិនប្រមាទ ក្នុងចាគានុស្សតិ ដែលមានអានុភាពច្រើន យ៉ាងនេះ គ្រប់កាលចុះ ។**

នេះជាកថាមុខ ( ពាក្យខែបញ្ហាដែលសំខាន់ ) យ៉ាងពិស្តារ ក្នុងចាគានុស្សតិ ។

## មហាដីកា

## អធិប្បាយ ចាគានុស្សតិ

ពាក្យថា **តាមប្រក្រតី** គឺ តាមសភាវៈ ។ ពាក្យថា **មានចិត្តបង្អោនទៅក្នុងការលះ** គឺជាអ្នកប្រកបក្នុងការពេញចិត្តចំពោះការបរិច្ចាគទេយ្យធម៌ ( របស់ដែលគួរឲ្យ ) មានចិត្តទោរទន់ទៅក្នុងការបរិច្ចាគទេយ្យធម៌នោះ ។ ព្រះយោគីបុគ្គលណាមានការឲ្យ និង ការចែករំលែក ប្រព្រឹត្តទៅអស់កាលជានិច្ចគ្រប់កាល ព្រះយោគីបុគ្គលនោះ ឈ្មោះថា **និច្ចប្បវត្ត ទានសំវិភាគោ** បានដល់ ព្រះយោគីបុគ្គលនោះ។ សូម្បីក្នុងពាក្យថា **និច្ចប្បវត្តទានសំវិភាគោ** នេះ ក៏គួរនាំពាក្យថា **បកតិយា** ( តាមប្រក្រតី ) ចូលមកភ្ជាប់ ។ ការដែលឲ្យវត្ថុ ដែលបានត្រៀមទុកដល់អ្នកដទៃឯណានោះ ឈ្មោះថា **ទានំ**-ការឲ្យ ។ ការដែលចែករំលែកអំពីរបស់ដែលខ្លួនគប្បីប្រើប្រាស់ឯណានោះ ឈ្មោះថា **សំវិភាគោ**-ការចែករំលែក ។ ពាក្យថា **ឥឡូវនេះ តាំងអំពីថ្ងៃនេះទៅ** មានសេចក្តីថា ឥឡូវនេះ តាំងអំពីពេលនេះ គឺ ក្នុងថ្ងៃនេះ ធ្វើថ្ងៃនេះឲ្យជាខាងដើម ។ ធ្វើការសមាទានការឲ្យថា យើងមិនបានឲ្យទានទេ នឹងមិនបរិភោគដូច្នេះ ។ ពាក្យថា **ក្នុងថ្ងៃនោះ** គឺ ក្នុងថ្ងៃដែលផ្តើមចម្រើននោះ ។ ពាក្យថា **កាលកាន់យកនិមិត្ត ក្នុងការឲ្យនោះ** បានដល់ កាន់យកនិមិត្តដែលទាក់ទងនឹងការកំណត់

អាការ ដែលប្រព្រឹត្តទៅក្នុងការនោះ គឺក្នុងចេតនាដែលបរិច្ចាគ ។ បទថា **វិគតមលមច្ឆេរតាទិគុណវិសេន** ( ដោយទាក់ទងនឹងគុណ មានភាពជាអ្នកប្រាសចាកមច្ឆរិយៈដែលជាមន្ទិលជាដើម ) មានសេចក្ដីថា មច្ឆរិយៈជាមន្ទិលជាដើម ទៅប្រាសហើយអំពីធម៌នេះ ព្រោះហេតុនោះ ធម៌នេះ ទើបឈ្មោះថា **វិគតមលមច្ឆេរ** បានដល់ ការលះបង់ភាវៈនៃ **វិគតមលមច្ឆេរ** ឈ្មោះថា **វិគតមលមច្ឆេរតា** បានដល់ ដោយទាក់ទងនឹងគុណ គឺសម្បត្តិ ឬអានិសង្ស មានការប្រាសចាកមច្ឆរិយៈដែលជាមន្ទិលនោះជាដើម ។

ឈ្មោះថា **ប្រព្រឹត្តតាមធម៌របស់សប្បុរស** មានសេចក្ដីថា ធ្វើតាម គឺ ការឈានចុះ ឬ បង្អោនចុះកាន់ធម៌ គឺ តាមប្រពៃណីរបស់មនុស្សល្អ ដែលបានដល់ព្រះពោធិសត្វទាំងឡាយ , ឈ្មោះថា **លាភរបស់ទាយកទាំងនេះ** បានដល់ លាភមាន អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណជាដើម និង លាភ មានសភាពជាទីស្រឡាញ់ជាដើម ដែលព្រះមានព្រះភាគទ្រង់ត្រាស់សរសើរ គឺ ទ្រង់លើកតម្កើងហើយ ។ បទថា **មនុស្សត្តំ វា** ( ឬភាពជាមនុស្ស ) **វា** ស័ព្ទ មានអត្ថថា កំណត់វត្ថុដែលមិនទាន់បានពោលទុក ដោយ **វា** ស័ព្ទនោះ គប្បីឃើញថា រួមយកសេចក្ដីផូរផង់នៃឥន្ទ្រិយ និង កម្មស្សកតាញាណជាដើម ។

បទថា **មច្ឆេរមលេន** ប្រែថា មន្ទិល គឺ សេចក្ដីកំណាញ់ ។ ន័យម្យ៉ាងទៀតសេចក្ដីកំណាញ់ផង មន្ទិលផង ឈ្មោះថា **មច្ឆេរមលំ** មានសេចក្ដីថា ត្រូវសេចក្ដីកំណាញ់ និង មន្ទិល មានលោភៈជាដើមនោះរុំព័ទ្ធ ។ ពាក្យថា **ដោយអំណាចនៃការកើតដោយប្រការផ្សេងៗ** គឺ ដោយអំណាចការកើតឡើង ព្រោះកម្មតាមដែលជារបស់ខ្លួន ។ ពាក្យថា **ធម៌ចំណែកខ្មៅ** បានដល់ បាបធម៌ មានលោភៈជាដើម ដែល

ខ្ទៅដោយចំណែកមួយ ។ ពាក្យថា **ព្រោះទៅប្រាសហើយ** គឺ ព្រោះត្រូវលះទៅហើយ ។ បទថា **វិគតមលមច្ឆេរេន ចេតសា** ជាតតិយាវិភត្តិក្នុងឥត្ថម្ភូតលក្ខណៈ ( ប្រែថា មានចិត្តប្រាសចាកសេចក្ដីកំណាញ់ដែលជាមន្ទិល ) ។ ពាក្យថា **ដែលជាព្រះសោតាបន្ន** គឺ ជាព្រះសោតាបន្ននៅគ្រប់គ្រងផ្ទះ ។ បទថា **និស្សយវិហារ** បានដល់ វិហារដែលជាទីអាស្រ័យ មានសេចក្ដីថា កម្មដ្ឋានដែលគប្បីប្រើប្រាស់រៀងរាល់ថ្ងៃ ។ បទថា **អភិភវិត្វា** មានសេចក្ដីថា គ្របសង្កត់ឧបក្កិលេសទាំងឡាយមានរាគៈជាដើម ដែលកើតឡើងដល់បុគ្គលពួកមួយ អ្នកនៅគ្រប់គ្រងផ្ទះ ។

បុគ្គលណា សូម្បីកាលនឹងឲ្យរបស់ខ្លះទៅ រមែងជាអ្នកឲ្យទៅទាំងអាល័យ បុគ្គលនោះមិនឈ្មោះថា ជាអ្នកលះបង់ឲ្យដាច់ ចំណែកព្រះយោគីនេះ នឹងជាដូច្នោះក៏ទេ ព្រោះហេតុនោះ លោកទើបពោលថា **មុត្តចាគោ** លះបង់បានដាច់ស្រឡះ ។ ពាក្យថា **លះបង់បានមិនជាប់ជំពាក់** មានសេចក្ដីថា លះបង់បានមិនមានអាល័យ លោកអាចារ្យកាលនឹងសម្ដែងថា ប្រៀបដូចបុគ្គលដែលច្រើនទៅដោយការសម្លាប់សត្វ គេហៅថា **លោហិតបាណី** ( មានបាតដៃប្រឡាក់ឈាម ) យ៉ាងណា បុគ្គលដែលច្រើនទៅដោយការឲ្យ គេហៅថា **បយតបាណី** ( មានបាតដៃស្អាត ) យ៉ាងនោះ ដូច្នេះ ទើបពោលថា លាងដៃទុកអស់កាលគ្រប់កាល ដើម្បីឲ្យ ដូច្នេះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **អស់កាលគ្រប់កាល** គឺ ជានិច្ច មានសេចក្ដីថា រឿយៗ ។ ពាក្យថា **ការបរិច្ចាគ** បណ្ឌិតរមែងជ្រាបតាមរឿងថា ការបរិច្ចាគទេយ្យធម៌ , ឈ្មោះថា **វត្ថុណាៗ** បានដល់ ទេយ្យធម៌ , ឈ្មោះថា **អ្នកដទៃ** បានដល់ ពួកអ្នកដែលសូម ។ បុគ្គលដែលគួរក្នុងការសូម ឈ្មោះថា **យាចនយោគោ** មានសេចក្ដីថា បុគ្គលអ្នកដែលអ្នកដទៃគួរសូម ។ ពាក្យថា **ប្រកបដោយយាជៈ** គឺ ប្រកបដោយ

ការឲ្យ ដោយមានការបរិច្ចាគគ្រប់កាល ។ ពាក្យថា **ក្នុងការធ្វើទាំងពីរយ៉ាង** គឺ ជាអ្នកត្រេកអរៗ ក្រៃលែងក្នុងការឲ្យ និងការចែករំលែកតាមដែលពោលហើយ ។

លោកអាចារ្យបំណងសម្ដែងថា កាលបុគ្គលដែលមានសីលបរិសុទ្ធល្អ រឭក រឿយៗ ដល់សីលរបស់ខ្លួន ដោយទាក់ទងនឹងគុណ មានភាពជាសីលមិនដាច់ជា ដើម សីលានុស្សតិភាវនា ក៏រមែងសម្រេចបានយ៉ាងណា កាលបុគ្គលមានការ បរិច្ចាគដែលបរិសុទ្ធល្អ និងជំក្រៃលែង រឭករឿយៗ ដល់ការបរិច្ចាគរបស់ខ្លួនដែល មិនសៅហ្មងសោះ ( ចាគានុស្សតិ ) ភាវនា ក៏រមែងសម្រេចបានយ៉ាងនោះ ដូច្នេះ ទើបពោលថា ដោយទាក់ទងនឹងគុណ មានភាពជាអ្នកប្រាសចាកសេចក្ដីកំណាញ់ ដែលជាមន្ទិលជាដើម ដូច្នេះជាដើម ពាក្យនោះមានអត្ថដូចខ្ញុំព្រះករុណាបានពោល ហើយនោះឯង ។ បទថា **ភិយ្យោសោ** គឺ ក្រៃលែងឡើងទៅ ។ ឈ្មោះថា **ដោយ ប្រមាណ** គឺ មានប្រមាណដ៏ច្រើន មានន័យថា ដោយប្រមាណដែលបរិបូណ៌ ។ ពាក្យថា **មានចិត្តបង្អោនទៅក្នុងការលះបង់** គឺ មានចិត្តបង្អោនទៅ បានដល់ មានចិត្ត បង្អោនទៅ ឱនទៅ ឈមទៅក្នុងការបរិច្ចាគ ព្រោះហេតុនោះឯង ទើបឈ្មោះថា មានអធ្យាស្រ័យមិនលោភ គឺ មានចិត្តមិនជាប់ជំពាក់ក្នុងវត្ថុគ្រប់យ៉ាង ។

ការបរិច្ចាគរមែងមានបាន ដោយអំណាចការប្រព្រឹត្តទាក់ទងក្នុងបដិគ្គាហកៈ ទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា មានប្រក្រតីធ្វើអនុលោម គឺ បដិបត្តិ សមគួរចំពោះមេត្តា គឺ ចំពោះការចម្រើនមេត្តា ។ បទថា **វិសារទោ** ប្រែថា ជាអ្នក ក្លៀវក្លា គឺជាអ្នកមិនរួញរា សូម្បីក្នុងទីណាៗ ជាអ្នកគ្របសង្កត់អ្នកដទៃដោយគុណ របស់ខ្លួននោះឯង ។ ពាក្យដ៏សេសគប្បីដឹងបានងាយហើយ ។

( ចប់ ចាគានុស្សតិ )

# ទេវតានុស្សតិ

រីឯ ព្រះយោគាវចរ ដែលប្រាថ្នានឹងចម្រើន **ទេវតានុស្សតិ** ត្រូវជាអ្នកប្រកបដោយគុណទាំងឡាយ មានសទ្ធាជាដើម ដែលកើតឡើងមកយ៉ាងល្អ ដោយអំណាចអរិយមគ្គហើយ តអំពីនោះ គប្បីទៅក្នុងទីស្ងាត់មនុស្ស សម្ងំនៅក្នុងសេនាសនៈដ៏សមគួរ ហើយតាំងទេវតាទុកក្នុងឋានៈនៃសាក្សី រឭកដល់គុណ មានសទ្ធាជាដើមរបស់ខ្លួនយ៉ាងនេះថា ទេវតាពួកចាតុម្មហារាជិកាមាន ទេវតាពួកតាវត្តិង្ស ពួកយាមា ពួកតុសិត ពួកនិម្មានរតី ពួកបរនិម្មិតវសវត្តីក៏មាន ពួកទេវតាជំពូកព្រហ្មក៏មាន ទេវតាជាន់ដែលខ្ពស់ជាងជំពូកព្រហ្មនោះក៏មាន ទេវតាទាំងនោះប្រកបដោយសទ្ធាយ៉ាងណា ចុតិចាកភពនេះហើយទៅកើតក្នុងភពនោះៗ សទ្ធានោះរបស់យើងក៏មាន ទេវតាទាំងនោះប្រកបដោយសីលយ៉ាងណា សុតៈយ៉ាងណា ចាគៈយ៉ាងណា បញ្ញាយ៉ាងណា ចុតិចាកភពនេះហើយ ទៅកើតក្នុងភពនោះ ៗ សីលយ៉ាងនោះ សុតៈយ៉ាងនោះ ចាគៈយ៉ាងនោះ បញ្ញាយ៉ាងនោះ របស់យើងក៏មានដែរ ។ តែក្នុងព្រះសូត្រទ្រង់ត្រាស់ទាំងពីរចំណែកស្មើគ្នាថា **ម្នាលមហានាម ក្នុងសម័យណា អរិយសាវករឭកដល់សទ្ធា សីល សុតៈ ចាគៈ និង បញ្ញារបស់ខ្លួន និងរបស់ទេវតាទាំងនោះផង ក្នុងសម័យនោះ ចិត្តរបស់លោក រមែងមិនជាចិត្តដែលរាគៈរួបរឹតឡើយ** ទ្រង់ត្រាស់ពីរចំណែកស្មើគ្នាដូច្នោះ ក៏ពិត តែដែលពិតបណ្ឌិតគប្បីជ្រាបថា ពាក្យក្នុងព្រះសូត្រនោះ ព្រះមានព្រះភាគ ត្រាស់ដើម្បីសម្ដែងគុណរបស់ទេវតា ដែលគប្បីតាំងទុកក្នុងឋានៈនៃសាក្សីទាំងឡាយ ស្មើគ្នានឹងគុណទាំងឡាយ មានសទ្ធាជាដើមរបស់ខ្លួន ព្រោះក្នុងអដ្ឋកថាខែទុកជាគោលថា តាំងទេវតាទុកក្នុងឋានៈនៃសាក្សី រឭកដល់គុណទាំងឡាយរបស់ខ្លួន ដូច្នេះ ។

## ទេវតានុស្សតិជ្ឈាន

ព្រោះហេតុនោះ កាលព្រះយោគាវចរនោះ សូម្បីរឭកដល់គុណរបស់ទេវតាទាំងឡាយក្នុងខាងដើមហើយ រឭកដល់គុណ មានសទ្ធាជាដើម ដែលខ្លួនមានតាមក្រោយផងដែរ ក្នុងសម័យនោះ ចិត្តរបស់លោកទើបមិនជាចិត្តដែលរាគៈរួបរឹត មិនជាចិត្តដែលទោសៈរួបរឹត មិនជាចិត្តដែលមោហៈរួបរឹតសោះឡើយ ក្នុងសម័យនោះ ចិត្តរបស់លោករមែងដំណើរទៅត្រង់គន្លង ប្រារព្ធទេវតា អង្គឈានទាំងឡាយ រមែងកើតឡើងក្នុងខណៈជាមួយគ្នា ដល់លោកអ្នកគ្របសង្កត់នីវរណៈបាន ដូចន័យមុនដែលពោលទុកក្នុងពុទ្ធានុស្សតិនោះឯង តែព្រោះសទ្ធាទិគុណទាំងឡាយជាអារម្មណ៍ជ្រាលជ្រៅ ឬព្រោះចិត្តបង្អោនទៅក្នុងការរឭកដល់គុណ មានប្រការផ្សេងៗ ឈាននោះ ទើបជាឈានដែលមិនដល់អប្បនា ដល់ត្រឹមតែឧបចារប៉ុណ្ណោះ ហើយឈាននោះ ក៏ដល់នូវការហៅឈ្មោះថា **ទេវតានុស្សតិនោះឯង** ព្រោះជាឈានដែលកើតឡើងដោយអំណាចការរឭកដល់សទ្ធាទិគុណរបស់ខ្លួន ដែលដូចគ្នានឹងគុណរបស់ទេវតាទាំងឡាយ ។

## អានិសង្សនៃការចម្រើនទេវតានុស្សតិ

ក៏ឯភិក្ខុដែលប្រកបរឿយៗ នូវទេវតានុស្សតិនោះ រមែងជាទីស្រឡាញ់ជាទីពេញចិត្តរបស់ទេវតាទាំងឡាយ បានសម្រេចភាពបរិបូណ៌នៃសទ្ធាទិគុណ ដោយប្រមាណក្រៃលែង ជាអ្នកច្រើនទៅដោយបីតិ និងបាមោជ្ជ ម្យ៉ាងវិញទៀត កាលនៅមិនទាន់សម្រេចគុណដែលក្រៃលែងឡើងទៅ លោករមែងជាអ្នកមានសុគតិជាទីទៅក្នុងខាងមុខ ។

ព្រោះហេតុនោះឯង បុគ្គលមានបញ្ញាល្អ គប្បីធ្វើការមិនប្រមាទក្នុងទេវតា-នុស្សតិ ដែលមានអានុភាពច្រើនយ៉ាងនេះ គ្រប់កាលទៅចុះ ។

នេះជាកថាមុខ យ៉ាងពិស្តារ ក្នុង **ទេវតានុស្សតិ** ។

## មហាដីកា

## អធិប្បាយ ទេវតានុស្សតិ

ពាក្យថា **ដោយអំណាចនៃអរិយមគ្គ** គឺ ដោយអំណាចនៃការសម្រេចអរិយ-មគ្គ ។ ពាក្យថា **ដែលតាំងឡើង** គឺ ដែលមកហើយ ក្រោយអំពីការកើតឡើងនៃអរិយមគ្គនោះ ដោយប្រពៃនោះឯង ។ ជាសេចក្តីពិតថា ធម៌ទាំងឡាយ មានសទ្ធាជាដើម សូម្បីដែលជាលោកិយ ក្នុងសន្តានរបស់ព្រះអរិយបុគ្គលទាំងឡាយយ៉ាងណា ធម៌ទាំងឡាយមានសទ្ធាជាដើម ដែលជារបស់បុថុជ្ជន ក៏ជាយ៉ាងនោះដូចគ្នា សូម្បីក្នុងកាលខ្លះ ក៏ទេ ។ ឈ្មោះថា **ទេវា** ( ទេវតា ) ព្រោះអត្ថថា លេង ។ **ទេវតា** ឈ្មោះថា ចាតុម្មហារាជ ព្រោះអត្ថថា មានមហារាជទាំង ៤ , ចតុម្មហារាជនោះឯង ជាចាតុម្មហារាជិកា ។ បុគ្គល ៣៣ នាក់ ដែលធ្វើបុណ្យរួមគ្នា ឧប្បត្តិហើយក្នុងស្ថានទីនោះ ព្រោះហេតុនោះ ស្ថានទីដែលបុគ្គល ៣៣ នាក់នោះត្រាច់ទៅផងគ្នា ទើបឈ្មោះថា ជាន់តាវត្តិង្ស សូម្បីពួកទេវតាដែលអាស្រ័យនៅក្នុងស្ថានទីនោះ ក៏ឈ្មោះថា ទេវតាពួកតាវត្តិង្ស ព្រោះការត្រាច់ទៅរួមគ្នា ក្នុងជាន់តាវត្តិង្សនោះឯង ។ **ទេវតា** ឈ្មោះថា ពួកយាមា ព្រោះអត្ថថា ទៅ គឺ ទៅប្រាសចាកទុក្ខ ។ **ទេវតា** ឈ្មោះ តុសិត ព្រោះអត្ថថា ដល់ គឺ ចូលដល់ហើយដោយសេចក្តីត្រេកអរ គឺ ដោយបីតិ ។ **ទេវតា** ឈ្មោះថា និម្មានរតី ព្រោះអត្ថថា មានសេចក្តីត្រេកអរក្នុង

ការនិម្មិតភោគសម្បត្តិ ។ **ទេវតា** ឈ្មោះថា ពួកបរនិម្មិតវសវត្តី ព្រោះអត្ថថា ធ្វើអំណាចឲ្យប្រព្រឹត្តទៅក្នុងភោគសម្បត្តិទាំងឡាយ ដែលទេវតាពួកដទៃនិម្មិតឲ្យ ។ **កាយ** គឺ ពពួកនៃព្រហ្ម ឈ្មោះថា ព្រហ្មកាយ, **ទេវតា** ឈ្មោះថា ពួកព្រហ្មកាយិក ( ពួកព្រហ្មកាយ ) ព្រោះអត្ថថា មានក្នុងព្រហ្មកាយនោះ ព្រោះជាប់ទាក់ទងនៅក្នុងព្រហ្មកាយនោះ ។ បទថា **តទុត្តរិ** ប្រែថា ទេវតាពួកដែលខ្ពស់ក្រៃលែងជាងពួកព្រហ្មកាយនោះ លោកពោលសំដៅយកទេវតាជាន់ខ្ពស់ឡើងទៅ មានពួកបរិត្តាភាជាដើម ។ ពាក្យថា **តាំងទេវតាទុកក្នុងឋានៈនៃសាក្សី** មានសេចក្តីថា គប្បីរឭករឿយៗ ដល់គុណ មានសទ្ធាជាដើមរបស់ខ្លួន តាំងទេវតា ទុកក្នុងឋានៈនៃសាក្សី គឺ ដូចអញ្ជើញអវតារចុះមកកាន់ភាពជាបន្ទាល់ យ៉ាងនេះថា ទេវតាទាំងនោះដល់ព្រមដោយសទ្ធា ដល់ព្រមដោយសីល ដោយសុតៈ ដោយចាគៈ ដោយបញ្ញា ដែលមកហើយដោយមគ្គបែបណា ទើបបានឃ្លាតចាកភពនេះ ហើយកើតឡើងក្នុងភពនោះ សូម្បីយើងក៏មានសទ្ធា សីល សុតៈ ចាគៈ និងបញ្ញា បែបនោះដែរ ។

លោកអាចារ្យធ្វើពាក្យបញ្ជាក់ទុកក្នុងចិត្តថា ប្រសិនបើជាយ៉ាងនេះ ការរឭករឿយៗ ដល់គុណទាំងពីរចំណែករបស់ខ្លួន និងរបស់ទេវតាព្រមគ្នា ទ្រង់ត្រាស់ទុកក្នុងព្រះសូត្រនោះ ជាយ៉ាងណាវិញ ដូច្នេះហើយ ទើបពោលថា ចំណែកក្នុងព្រះសូត្រដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា ត្រាស់ទុកយ៉ាងនោះក៏ពិត មានសេចក្តីថា ត្រាស់ទុកក្នុងព្រះសូត្រហាក់បីដូចជាទាំងពីរចំណែក ( ចំណែកខ្លួន និងចំណែកទេវតា ) មានធុរៈស្មើគ្នាថា របស់ខ្លួន និងរបស់ទេវតាទាំងនោះ ដូច្នេះក៏ពិត , សូម្បីយ៉ាងនោះឯង ពាក្យថា សទ្ធា សីល របស់ទេវតាជាដើមនោះ ជាពាក្យដែលគប្បីតាំងទុកក្នុងឋានៈនៃបន្ទាល់ គប្បីនាំយកបទថា **វុត្តំ** ប្រែថា ត្រាស់

ទុក មកភ្ជាប់ទុកខាងមុខ ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ក៏ការតាំងទុកក្នុងឋានៈនៃបទទាល់នេះ មានដើម្បីប្រយោជន៍អ្វី ដូច្នេះ , ហើយទើបពោលថា គប្បីជ្រាបថា ដើម្បីសម្តែងគុណរបស់ទេវតាទាំងឡាយ ដែលស្មើនឹងគុណ មានសទ្ធាជាដើមរបស់ខ្លួន ដូច្នេះ ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ក៏ព្រោះហេតុអ្វី ទើបមិនកាន់យកអត្ថ-ន័យដោយអំណាចនៃពាក្យដែលត្រាស់ទុកក្នុងព្រះសូត្រ ត្រឡប់កាន់យកអត្ថន័យយ៉ាងនេះវិញ ដូច្នេះហើយ ទើបពោលថា ពិតណាស់ ក្នុងអដ្ឋកថាដូច្នេះជាដើម ។

ពាក្យថា **ព្រោះដូច្នោះ** មានសេចក្តីថា ព្រោះហេតុដែលក្នុងអដ្ឋកថា លោកពោលដល់ការរឭករឿយៗ ដល់គុណរបស់ខ្លួន តាំងទេវតាទុកក្នុងឋានៈនៃបទទាល់ជាគោលហើយ ការរឭករឿយៗដល់គុណរបស់ខ្លួន , សូម្បីក្នុងទេវតានុស្សតិនេះក៏ដូចគ្នាក្នុងសីលានុស្សតិកម្មដ្ឋាន និង ចាគានុស្សតិកម្មដ្ឋាន ជាហេតុកើតឡើងនៃឈានបានដ៏ប្រពៃហើយ ដូច្នេះ ។ ពាក្យថា **ក្នុងខាងដើម** គឺ ក្នុងគ្រាផ្តើមចម្រើន ។ ពាក្យថា **ក្នុងខាងក្រោយ** គឺ ក្នុងពេលដែលចម្រើន ដោយប្រការដែលឧបចារឈានសម្រេចដល់ព្រះយោគីអ្នកចម្រើន ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ប្រសិនបើក្នុងភាវនាខនេះ ព្រះយោគីគប្បីរឭករឿយៗ ដល់គុណរបស់ខ្លួនឯងសោត ភាវនានេះនឹងឈ្មោះថា ទេវតានុស្សតិបានដូចម្តេច ? ដូច្នេះហើយ ទើបពោលថា ឈាននេះរមែងដល់នូវការរាប់ថា ជាទេវតានុស្សតិនោះឯង ព្រោះកើតឡើងដោយអំណាចការរឭករឿយៗ ដល់គុណ មានសទ្ធាជាដើម ដែលដូចគ្នានឹងគុណរបស់ទេវតាទាំងឡាយ ដូច្នេះ ។ ដោយពាក្យនោះ លោកសម្តែងថា ភាវនានេះ ហៅថា **ទេវតានុស្សតិ** ក៏ដោយការប្រៀបធៀបគ្នា នឹងបានហៅថា **ទេវតានុស្សតិ** ព្រោះជាការរឭករឿយៗដល់ទេវតា ឬ គុណរបស់ទេវតាទាំងនោះក៏ទេ ដូច្នេះ ។ ម្យ៉ាងទៀត គប្បីជ្រាបថា

កាវនានេះ មានសមញ្ញាថា **ទេវតានុស្សតិ** ព្រោះអាស្រ័យការរឭករឿយៗ ដល់គុណរបស់ទេវតា ដែលប្រព្រឹត្តទៅជាខាងដើម ។ ពិតយ៉ាងនោះ លោកនឹងពោលតទៅខាងមុខថា ដោយអំណាចនៃចិត្តដែលប្រព្រឹត្តទៅ ប្រារព្ធទេវតាជាខាងដើម ។ ពាក្យដ៏សេស គប្បីដឹងបានងាយហើយ ។

( ចប់ មហាដីកា )

## បទថា អត្ថវេទំ ជាដើម

( ក្នុងមហានាមសូត្រ )

ការដែលទ្រង់សម្តែងអនុស្សតិទាំងនោះដោយពិស្តារ ព្រះមានព្រះភាគត្រាស់ពាក្យថា ក្នុងសម័យនោះ ចិត្តរបស់លោកជាចិត្តដំណើរទៅត្រង់ផ្លូវ ប្រារព្ធតថាគតដូច្នេះជាដើម ហើយត្រាស់ពុទ្ធវចនៈណាថា ម្នាលមហានាម អរិយសាវកដែលមានចិត្តដំណើរទៅត្រង់ហើយនោះឯង រមែងបានអត្ថរស រមែងបានធម្មរស រមែងបានបាមោជ្ជដែលប្រកបដោយធម៌ កាលបាននូវបាមោជ្ជ បីតិរមែងកើតឡើង , ក្នុងព្រះពុទ្ធវចនៈនោះគប្បីជ្រាបថា ពាក្យថា **បានអត្ថរស** ត្រាស់សំដៅយកសេចក្តីត្រេកអរដែលអាស្រ័យអត្ថនៃអនុស្សរណបាលី មានបទថា **ឥតិបិ សោ ភគវា** ជាដើមកើតឡើង ។ ពាក្យថា **បានរសនៃធម៌** ត្រាស់សំដៅយកសេចក្តីត្រេកអរដែលអាស្រ័យតួបាលីកើតឡើង ។ ពាក្យថា **បានបាមោជ្ជដែលប្រកបដោយធម៌** គឺទ្រង់ត្រាស់សំដៅដល់សេចក្តីត្រេកអរទាំងពីរយ៉ាង ។

ចំណែកពាក្យណា ទ្រង់ត្រាស់ក្នុងទេវតានុស្សតិថា ប្រារព្ធទេវតា ក្នុងពាក្យ

នោះ គប្បីជ្រាបថា ទ្រង់ត្រាស់ដោយសំដៅដល់ចិត្តដែលប្រារព្ធទេវតាប្រព្រឹត្តទៅ ឬ សំដៅដល់ចិត្តដែលប្រារព្ធគុណទាំងឡាយរបស់ខ្លួន ដែលញ៉ាំងភាពជាទេវតា ឲ្យសម្រេច ដែលជាគុណដូចគ្នានឹងគុណរបស់ទេវតា ប្រព្រឹត្តទៅក្នុងខាងដើមនៃការចម្រើនភាវនា ។

## អនុស្សតិ៦
## សម្រេចដល់អរិយសាវ័កប៉ុណ្ណោះ

រីឯ **អនុស្សតិ ៦** នេះ រមែងសម្រេចដល់អរិយសាវ័កទាំងឡាយប៉ុណ្ណោះ ព្រោះគុណរបស់ព្រះពុទ្ធជាម្ចាស់ និង ព្រះធម៌ ព្រះសង្ឃ រមែងប្រាកដច្បាស់ដល់លោក ហើយលោកប្រកបព្រមទៅដោយសីលទាំងឡាយដែលទ្រទ្រង់គុណ មានការមិនដាច់ជាដើម ដោយចាគៈដែលប្រាសចាកសេចក្ដីកំណាញ់ ដែលជាតួមន្ទិល និងដោយគុណទាំងឡាយ មានសទ្ធាជាដើម ដែលស្មើដូចគ្នានឹងគុណរបស់ចមទេព ដែលមានអានុភាពច្រើន ម្យ៉ាងវិញទៀត ក្នុងមហានាមសូត្រ ព្រះមានព្រះភាគជាម្ចាស់ ដែលព្រះបាទមហានាមសក្យៈ ទូលសួរដល់និស្ស័យនៃវិហារធម៌ ដែលគប្បីអាស្រ័យនៅរបស់ព្រះសោតាបន្ន ក៏ត្រាស់អនុស្សតិ ៦ នោះ ដោយពិស្ដារ ដើម្បីទ្រង់សម្ដែងនិស្ស័យវិហារធម៌របស់ព្រះសោតាបន្ននោះឯង សូម្បីក្នុងគេធសូត្រ ក៏ត្រាស់អនុស្សតិ ៦ នោះ ដើម្បីប្រយោជន៍ដល់ការធ្វើចិត្តឲ្យបរិសុទ្ធ ដោយអំណាចអនុស្សតិ ហើយបានសម្រេចបរមត្ថវិសុទ្ធិក្រៃលែងឡើងទៅនៃអរិយសាវ័កយ៉ាងនេះថា **ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងធម្មវិន័យនេះ រមែងរឭកដល់តថាគត** សូម្បីព្រោះហេតុនេះ ព្រះមានព្រះភាគជាម្ចាស់អង្គនោះ ។ល។ ក្នុងសម័យនោះ

ចិត្តរបស់លោករមែងជាចិត្តដំណើរទៅត្រង់ផ្លូវ ជាចិត្តចេញទៅ ផុតទៅ លើកផុតអំពី គេធ (ដោយវិក្ខម្ភនវិមុត្តិ) , ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធ នោះ ជាឈ្មោះនៃ កាមគុណ ៥ ភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ ធ្វើអនុស្សតិដ្ឋាននេះឲ្យជា អារម្មណ៍ហើយ រមែងបរិសុទ្ធបានយ៉ាងនេះប្រការមួយ ដូច្នេះជាដើម ។ សូម្បីក្នុង សម្ពាធោកាសសូត្រដែលព្រះមហាកច្ចាយនៈសម្ដែង ក៏ពោលអនុស្សតិ ៦ នេះ ដែល ជាធម៌ ជាធម្មជាតិបានចន្លោះក្នុងទីចង្អៀត ដើម្បីភាពជាអ្នកមានបរមត្ថវិសុទ្ធិ ជាធម៌ នៃអរិយសាវកនោះឯង យ៉ាងនេះថា ម្នាលអាវុសោ សេចក្ដីនេះជាអស្ចារ្យ ម្នាល អាវុសោ សេចក្ដីនេះមិនធ្លាប់មានមកឡើយ ដែលព្រះមានព្រះភាគជាម្ចាស់ ជាអ្នក ប្រាជ្ញ ជាអ្នកឃើញ ជាព្រះអរហន្តសម្មាសម្ពុទ្ធ បានត្រាស់ដឹងធម៌ ជាធម្មជាតិបាន ចន្លោះក្នុងទីចង្អៀត ដើម្បីសេចក្ដីបរិសុទ្ធនៃសត្វទាំងឡាយ ។ល។ ដើម្បីធ្វើឲ្យជាក់ ច្បាស់នូវព្រះនិព្វានធម៌ ជាធម្មជាតិបានចន្លោះក្នុងទីចង្អៀត នេះគឺអ្វី គឺ អនុស្សតិ-ដ្ឋាន ៦ អនុស្សតិដ្ឋាន ៦ គឺអ្វីខ្លះ ម្នាលអាវុសោ អរិយសាវក ក្នុងធម្មវិន័យនេះ រឭកដល់ ព្រះតថាគត ។ល។ សត្វពួកខ្លះក្នុងលោកនេះ... រមែងជាអ្នកមានវិសុទ្ធិ ជាធម៌ យ៉ាងនេះប្រការមួយ ដូច្នេះជាដើម ។ សូម្បីក្នុងឧបោសថសូត្រ ទ្រង់ត្រាស់ អនុស្សតិ ៦ នេះ ដែលជាកម្មដ្ឋាន ជាគ្រឿងជម្រះចិត្តរបស់អរិយសាវកដែលរក្សា ឧបោសថសីលនោះឯង យ៉ាងនេះថា ម្នាលវិសាខា ក៏អរិយុបោសថដូចម្ដេច ម្នាល វិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់ រមែងមានបានដោយសេចក្ដីព្យាយាម ការធ្វើចិត្តសៅហ្មងឲ្យផូរផង់ រមែងមានបានដោយសេចក្ដីព្យាយាមដូចម្ដេច ម្នាល វិសាខា អរិយសាវកក្នុងធម្មវិន័យនេះ រមែងរឭកដល់តថាគត... ដូច្នេះជាដើម ដើម្បី ទ្រង់សម្ដែងការមានផលច្រើននៃឧបោសថ សូម្បីក្នុងឯកាទសនិបាត អង្គុត្តរនិកាយ

កាលព្រះបាទមហានាមទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គទាំង-ឡាយនោះ នៅជុំគ្នាដោយវិហារធម៌ផ្សេងៗគ្នា ខ្ញុំព្រះអង្គនឹងនៅដោយវិហារធម៌អ្វី ដូច្នេះ ទ្រង់ត្រាស់អនុស្សតិ ៦ ដើម្បីសម្តែងវិហារធម៌នៃអរិយសាវកនោះឯង យ៉ាងនេះថា ម្នាលមហានាម បុគ្គលមានសទ្ធានេះឯង ជាអ្នកធ្វើឲ្យសម្រេចបាន បុគ្គលអ្នកមិនមានសទ្ធា នឹងជាអ្នកធ្វើឲ្យសម្រេចមិនបាន បុគ្គលអ្នកប្រារព្ធនូវសេចក្តីព្យាយាម អ្នកមានសតិតាំងមាំ អ្នកមានចិត្តជាសមាធិ អ្នកមានបញ្ញា ជាអ្នកធ្វើឲ្យសម្រេចបាន បុគ្គលខ្ជិលច្រអូស អ្នកមិនមានសតិ មានចិត្តមិនជាសមាធិ ជាអ្នកទុព្វលបញ្ញា នឹងជាអ្នកធ្វើឲ្យសម្រេចមិនបាន ម្នាលមហានាម អ្នកគប្បីតាំងនៅក្នុងធម៌ ៥ នេះហើយ ចម្រើនធម៌ ៦ តទៅ គឺ ក្នុងការចម្រើនធម៌ ៦ នេះ អ្នកគប្បីរឭកដល់តថាគតថា សូម្បីព្រោះហេតុនេះ ព្រះមានព្រះភាគអង្គនោះដូច្នេះជាដើម ។

## បុថុជ្ជនបំពេញក៏សម្រេចប្រយោជន៍

ទោះជាយ៉ាងនោះ **អនុស្សតិ ៦** នេះ សូម្បីបុថុជ្ជនដែលប្រកបដោយគុណមានសីលបរិសុទ្ធជាដើម ក៏គួរមនសិការបាន ព្រោះថា សូម្បីដោយអំណាចនៃការរឭក ចិត្តរបស់បុគ្គលដែលរឭកដល់គុណរបស់អនុស្សរណវត្ថុ មានព្រះពុទ្ធជាម្ចាស់ជាដើម រមែងកើតសេចក្តីជ្រះថ្លាបានពិត ដោយអានុភាពនៃសេចក្តីជ្រះថ្លានោះសោតព្រះយោគាវចរនឹងគ្របសង្កត់នីវរណៈទាំងឡាយបាន ហើយជាអ្នកមាននូវបាមោជ្ជយ៉ាងខ្លាំង ផ្តើមចម្រើនវិបស្សនា ក៏ធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបានដូចគ្នា ដូចព្រះបុស្សទេវត្ថេរ ដែលនៅក្នុងកដ្ឋអន្ធការវិហារ ។

បានឮថា ព្រះថេរៈអង្គនោះបានឃើញពុទ្ធរូប ដែលមារនិម្មិតហើយ ពិចារណា

ទៅថា មារនេះនៅមានរាគៈ ទោសៈ មោហៈពិតៗ គង់និម្មិតពុទ្ធរូបបានល្អដល់ម្ល៉េះ ព្រះមានព្រះភាគដែលប្រាសចាក រាគៈ ទោសៈ មោហៈ ដោយប្រការទាំងពួងហើយ នឹងល្អបែបណាហ្ន៎ ដូច្នេះហើយ បានបីតិ មានព្រះពុទ្ធជាអារម្មណ៍ ចម្រើនវិបស្សនា ក៏សម្រេចព្រះអរហត្ត ។

## មហាដីកា
## ពណ្ណនា បកិណ្ណកកថា

ពាក្យថា **ក្នុងទេសនាអនុស្សតិទាំងនេះ** គឺ អនុស្សតិ ៦ មានពុទ្ធានុស្សតិជាដើមទាំងនេះ ។ ពាក្យថា **ក្នុងទេសនាដោយពិស្តារ** គឺ ក្នុងទេសនាដែលប្រព្រឹត្តទៅដោយអំណាច ទ្រង់ធ្វើឲ្យពិស្តារ ។ លោកពោលសំដៅយកមហានាមសូត្រ ។ ពាក្យថា អត្ថនៃព្រះបាលី មានបទថា **ឥតិបិ សោ ភគវា** ជាដើម គឺ អត្ថន័យរបស់បទថា **ភគវា** ជាដើម ។ ម្យ៉ាងទៀត ពាក្យថា **អត្ថវេទ** ត្រាស់សំដៅយកសេចក្ដីត្រេកអរដែលអាស្រ័យផលរបស់ហេតុកើតឡើង ។ ពាក្យថា **ធម្មវេទ** ត្រាស់សំដៅយកសេចក្ដីត្រេកអរដែលអាស្រ័យហេតុកើតឡើង ។ ពិតណាស់ កាលព្រះយោគាវចររឭករឿយៗ ថា ទ្រង់ជាព្រះអរហន្ត ព្រោះទ្រង់ជាអ្នកឆ្ងាយអំពីកិលេស ដូច្នេះ ភាពជាអ្នកឆ្ងាយអំពីកិលេសនៃព្រះមានព្រះភាគនោះឯណា នោះ ឈ្មោះថា **ហេតុ** ។ ក៏ក្នុងទីនេះ លោកបំណងយក **ញាបកហេតុ** ( ហេតុឲ្យដឹង ) មិនបំណងយក **ការកហេតុ** ( ហេតុធ្វើផលឲ្យកើត ) ឬ **សម្បាបកហេតុ** ( ហេតុឲ្យដល់ ) ។ ប្រយោជន៍នៃភាពជាអ្នកឆ្ងាយចាកកិលេសណា ដែលព្រះយោគីនេះដឹង នោះឈ្មោះថា **ផល** គប្បីជ្រាបដល់ការចែកហេតុនិងផល ក្នុងបទដ៏សេសដោយន័យនេះចុះ ។

សូម្បីក្នុងធម្មានុស្សតិជាដើម លោកក៏បានធ្វើការបន្តុលហេតុ ទុកក្នុងបទនោះៗហើយ ដោយពាក្យថា ភាពជាធម៌ដែលមានលំអបទដើម បទកណ្តាល និងបទចុងជាដើម ដែលជាការបន្តុលដល់ហេតុឲ្យដឹងថា ព្រះធម៌ជា **ស្វាក្ខាត** ដូចម្តេចជាដើម និង ដោយពាក្យថា តែព្រោះហេតុដែលសម្មាបដិបទានោះ ( ត្រង់ ) ជាដើម ដែលជាការបន្តុលបង្ហាញដល់ហេតុឲ្យដឹងថា **ព្រះសង្ឃ** ឈ្មោះថាជា **សុបដិបន្ន** ដូចម្តេចជាដើម ដូច្នេះឯង ។ ពាក្យថា **ដែលប្រកបដោយធម៌** បានដល់ ប្រកបដោយគុណពោលគឺ ហេតុ និងផលរបស់ហេតុតាមដែលពោលមកហើយ ។ ពាក្យថា **ដោយអំណាចនៃចិត្ត ដែលប្រព្រឹត្តទៅប្រារព្ធយកគុណទាំងឡាយ** គឺ គុណទាំងឡាយរបស់ខ្លួន ។

បទថា **អរិយសាវិកានំ យេវ ឥជ្ឈត្តិ** ( សម្រេចពិតហើយដល់អរិយសាវក ទាំងឡាយ ) គប្បីឃើញថា ជាពាក្យដែលមានអវធារណៈ ក្នុងបទក្រោយយ៉ាងនេះ គឺ **អរិយសាវិកានំ ឥជ្ឈត្តិយេវ** , ក៏ពាក្យអវធារណៈ លោកពោលទុកដើម្បីសម្តែងថា សម្រេចដល់អរិយសាវកទាំងនោះបានដោយងាយ ។ ព្រោះហេតុនោះលោកទើបពោលថា **ព្រោះថា លោកទាំងនោះ** ដូច្នេះជាដើម សម្រាប់អ្នកដែលជាបុថុជ្ជនទាំងឡាយ នឹងសម្រេចបានដោយប្រការទាំងអស់ទាំងពួងក៏ទេ ។ ពិតយ៉ាងនោះ លោកនឹងពោលតទៅថា សូម្បីកាលបើជាយ៉ាងនេះដូច្នេះជាដើម ។ សួរថាប្រសិនបើយ៉ាងនេះ ពោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ប្រើស័ព្ទថា **អរិយសាវក** សូម្បីក្នុងព្រះសូត្រជាច្រើន មានមហានាមសូត្រជាដើមវិញ លោកអាចារ្យច្រើនអង្គឆ្លើយថា ព្រោះជាវិហារធម៌ដែលមានច្រើនចំពោះព្រះអរិយសាវកទាំងនោះ ។

ពាក្យថា **ឈានចេញទៅ** គឺ ចេញទៅ រលាស់ចេញទៅ ។ ពាក្យថា **ផុតទៅ**

គឺ មិនជាប់ជំពាក់ ។ បទថា **វុដ្ឋិតំ** បានដល់ ប្រាសទៅ ។ លោកពោលពាក្យថា ឈានចេញទៅជាដើមទាំងអស់នេះ សំដៅយកការគ្របសង្កត់នោះឯង ។ ពាក្យថា **អំពីគេធ** គឺ អំពីបលិពោធ ( គ្រឿងកង្វល់ ) ។ ពាក្យថា **អនុស្សតិដ្ឋាន** ក្នុងប្រការនេះ លោកពោលដល់ឧបចារជ្ឈាន ដែលព្រះយោគីបាន ដោយអំណាចនៃពុទ្ធានុស្សតិ ។ ពាក្យថា **ធ្វើឲ្យជាអារម្មណ៍** គឺ ធ្វើឲ្យជាបច្ច័យ មានសេចក្ដីថា ធ្វើឲ្យជាបាទ ។ ពាក្យថា **រមែងបរិសុទ្ធ** គឺ សម្រេចបរមត្ថវិសុទ្ធិ ។

ពាក្យថា **ក្នុងទីចង្អៀត** គឺ ក្នុងការនៅគ្រប់គ្រងផ្ទះដែលចង្អៀតចង្អល់ លាយឡំដោយសង្កិលេស គឺ តណ្ហាជាដើម ។ ឈ្មោះថា **ឱកាសាធិគម** គឺ ឱកាសដែលគប្បីបានទទួលដើម្បីបានសម្រេចលោកុត្តរធម៌ ។ អនុស្សតិទាំងឡាយនោះឯងឈ្មោះថា **អនុស្សតិដ្ឋាន** ។ ពាក្យថា **ដែលមានវិសុទ្ធិជាធម្មតា** គឺ ដែលមានភាពបរិសុទ្ធជាសភាវៈ ឬថា ដែលគួរបរិសុទ្ធ ។ បទថា **បរមត្ថវិសុទ្ធិធម្មតាយ** បានដល់ ជាអ្នកគួរចំពោះបរមត្ថវិសុទ្ធិ គឺ ចំពោះព្រះនិព្វាន ។ បទថា **ឧបក្កមេន** ប្រែថា ដោយសេចក្ដីព្យាយាម ។ បទថា **បរិយោទបនា** ប្រែថា ការជម្រះឲ្យបរិសុទ្ធ ។

ពាក្យថា **សូម្បីយ៉ាងនេះ** មានសេចក្ដីថា សូម្បីទ្រង់សម្ដែង **អនុស្សតិ ៦** ទាក់ទងនឹងអរិយសាវកប៉ុណ្ណោះ ក្នុងច្រើនព្រះសូត្រ មានមហានាមសូត្រជាដើមយ៉ាងនេះ ។ ពាក្យថា **ដែលជាសេចក្ដីជ្រះថ្លា** ដែលព្រះយោគី គប្បីប្រើអានុភាព គឺ ដែលជាសេចក្ដីជ្រះថ្លានៃចិត្តដែលព្រះយោគីគប្បីប្រើកម្លាំង ។ ពាក្យថា **បានបីតិ** គឺ ធ្វើបីតិដែលមានព្រះពុទ្ធជាម្ចាស់ ជាអារម្មណ៍ ឲ្យកើតឡើងដោយអំណាចការរឭកដល់ ។

( ចប់ មហាដីកា )

# បរិច្ឆេទទី ៧

## ឈ្មោះ ធអនុស្សតិនិទ្ទេស ក្នុងអធិការនៃសមាធិភាវនា ដែលខ្ញុំម្ចាស់ធ្វើដើម្បីជាប្រយោជន៍ដល់បាមោជ្ជនៃសាធុជន ដូច្នេះឯង ។

# អនុស្សតិកម្មដ្ឋាននិទ្ទេស

------◎------

## មរណស្សតិ

ឥឡូវនេះ ការនាំនិទ្ទេសនៃមរណស្សតិ បន្ទាប់ពីទេវតានុស្សតិ ដល់ហើយតាមលំដាប់ ៖

ការដាច់នៃជីវិតិន្ទ្រិយដែលបន្តនៅក្នុងភពមួយ ឈ្មោះថា **មរណ** ក្នុងពាក្យថា **មរណស្សតិ** នោះ , ឯ **សមុច្ឆេទមរណ** ពោលគឺ ការដាច់ជាសមុច្ឆេទនៃវដ្តទុក្ខរបស់ព្រះអរហន្តទាំងឡាយក្តី , **ខណិកមរណ** បានដល់ ការរលត់ក្នុងខណៈ ៗ នៃសង្ខារទាំងឡាយក្តី , **សម្មុតិមរណ** ក្នុងពាក្យនិយាយរបស់អ្នកស្រុកថា ដើមឈើងាប់ លោហៈងាប់ ជាដើមក្តី ឯណា មរណៈនោះ ទ្រង់មិនបានបំណងយកក្នុង **មរណស្សតិ** នេះទេ ចំណែកមរណៈដែលទ្រង់បំណងយកនោះ មាន ២ យ៉ាង គឺ **កាលមរណ អកាលមរណ** , ក្នុងមរណៈពីរយ៉ាងនោះ **កាលមរណ** រមែងមានព្រោះអស់បុណ្យខ្លះ ព្រោះអស់អាយុខ្លះ ព្រោះអស់ទាំងបុណ្យទាំងអាយុខ្លះ , **អកាលមរណ** រមែងមានដោយអំណាចកម្មចូលទៅកាត់ផ្តាច់ ( ជនកៈ ) កម្ម ។ ក្នុងមរណៈទាំងឡាយនោះ មរណៈណា កាលបច្ច័យដែលជាគ្រឿងញ៉ាំងអាយុឲ្យបន្តទៅ នៅមាន តែមរណៈក៏កើតឡើងបាន ព្រោះកម្មដែលឲ្យបដិសន្ធិ មានវិបាកទុំជាហើយ ឈ្មោះថា មរណៈព្រោះអស់បុណ្យ , មរណៈណា ប្រាកដឡើងដោយអំណាចការអស់អាយុ ដូចអាយុដែលមានប្រមាណ ១០០ ឆ្នាំ របស់មនុស្សសព្វថ្ងៃ ព្រោះការមិនមាន សម្បត្តិ ដូចជា គតិ កាល និង អាហារជាដើម នេះឈ្មោះ

ថា មរណៈ ព្រោះអស់អាយុ ចំណែកមរណៈណា មានដល់បុគ្គលទាំងឡាយ ដែលបច្ច័យជាគ្រឿងបន្ត ( អាយុ ) ត្រូវកម្ម ដែលអាចញុំាងសត្វឲ្យឃ្លាតចាកឋានៈ ( ការរស់នៅ ) ទាន់ហន់ ចូលមកកាត់ផ្តាច់ ដូចបុគ្គលបាបទាំងឡាយ មានទុស្សីមារ និង ស្តេចកលាពុជាដើមក្តី ដល់បុគ្គលទាំងឡាយដែលបច្ច័យជាគ្រឿងបន្ត ( អាយុ ) មកកាត់ផ្តាច់ដោយ **ឧបក្កម** ( ការប្រទូសរ៉ាយ ) មានការប្រើសស្ត្រាជាដើម ដោយអំណាចនៃកម្មដែលបានធ្វើទុកក្នុងកាលមុនក្តី មរណៈនេះឈ្មោះថា **អកាលមរណ** ។ មរណៈទាំងអស់នោះ សង្គ្រោះចូលដោយការដាច់ជីវិតិន្ទ្រិយ មានប្រការដូចពោលហើយ ការរឭកដល់មរណៈ ពោលគឺ ការដាច់នៃជីវិតិន្ទ្រិយ ដូចពោលមកនេះ ឈ្មោះថា **មរណស្សតិ** ។

# វិធីចម្រើនមរណស្សតិ

ព្រះយោគាវចរ មានបំណងចម្រើនមរណស្សតិនោះ គប្បីជាអ្នកចូលទៅកាន់ទីស្ងាត់ ពួនសម្ងំ ( ក្នុងសេនាសនៈដែលសមគួរ ) ហើយញុំាងមនសិការឲ្យប្រព្រឹត្តទៅ ដោយត្រូវទំនងថា **មរណំ ភវិស្សតិ ជីវិតិន្ទ្រិយំ ឧបច្ឆិជ្ជិស្សតិ** - សេចក្តីស្លាប់នឹងមាន ជីវិតិន្ទ្រិយនឹងដាច់ ដូច្នេះ ឬថា **មរណំ មរណំ - ស្លាប់ ស្លាប់** ដូច្នេះក៏បាន ព្រោះកាលមនសិការដោយមិនត្រូវទំនង សេចក្តីសោកនឹងកើតឡើង ព្រោះការរឭកដល់សេចក្តីស្លាប់របស់ឥដ្ឋជន ដូចសេចក្តីសោក កើតដល់មាតាអ្នកឲ្យកំណើត ព្រោះរឭកដល់សេចក្តីស្លាប់របស់បុត្តជាទីស្រឡាញ់ ដូច្នោះ , បាមោជ្ជនឹងកើតឡើង ព្រោះរឭកដល់សេចក្តីស្លាប់របស់អនិដ្ឋជន ដូចការរីករាយកើតឡើងដល់ជនមានពៀរនិងគ្នាទាំងឡាយ ព្រោះកាលរឭកដល់សេចក្តីស្លាប់របស់វេរីជន

ដូច្នោះ , សេចក្តីសង្វេគ រមែងមិនកើតឡើង ព្រោះរឭកដល់សេចក្តីស្លាប់របស់មជ្ឈត្តជន ដូចការតក់ស្លុតមិនមាន ដល់អ្នករកស៊ីធ្វើបុណ្យខ្មោច ព្រោះឃើញសាកសពអ្នកស្លាប់នោះ , សេចក្តីតក់ស្លុត នឹងកើតឡើង ព្រោះរឭកដល់សេចក្តីស្លាប់របស់ខ្លួន ដូចការភ័យខ្លាចកើតឡើងដល់បុគ្គលមានជាតិកំសាក ព្រោះឃើញពេជ្ឈឃាតងាជាវឡើង ដូច្នោះ ។ ការកើតឡើង នៃសេចក្តីសោកទាំងឡាយនោះ រមែងមានដល់បុគ្គលដែលគ្មានសតិ មិនសង្វេគ និង មិនមានញាណ ព្រោះហេតុនោះ ព្រះយោគាវចរគប្បីត្រូវមើលសត្វដែលត្រូវសម្លាប់ និង ដែលស្លាប់ឯង ៗ ក្នុងទីនោះ ៗ ហើយពិចារណាដល់សេចក្តីស្លាប់របស់ពួកសត្វដែលស្លាប់ ដែលវាមានសម្បត្តិ ( គឺ ការដល់ព្រមនៃមូលផ្សេង ៗ ) ដែលខ្លួនធ្លាប់បានឃើញមកប្រកប សតិ សង្វេគ និង ញាណ ចូលទៅមនសិការឲ្យប្រព្រឹត្តទៅ ក្នុងន័យថា **មរណំ ភវិស្សតិ** - សេចក្តីស្លាប់នឹងមាន ដូច្នេះ ជាដើមចុះ ព្រោះថា កាល ( មនសិការ ) ប្រព្រឹត្តទៅយ៉ាងនោះ ចាត់ថា ប្រព្រឹត្តទៅដោយត្រូវទំនង មានន័យថា ឲ្យប្រព្រឹត្តទៅដោយឧបាយ ( ត្រូវផ្លូវ ) ពិតហើយ ចំពោះព្រះយោគាវចររូបខ្លះ ( មានឥន្ទ្រិយចាស់ក្លា ) ញុំាងមនសិការឲ្យប្រព្រឹត្តទៅយ៉ាងនោះប៉ុណ្ណោះ នីវរណៈទាំងឡាយនឹងស្ងប់រម្ងាប់ **សតិមានសេចក្តីស្លាប់ជាអារម្មណ៍** នឹងតាំងមាំ កម្មដ្ឋាននឹង ដល់ឧបចារសមាធិបាន ។

## អ្នកមានឥន្ទ្រិយទន់ខ្សោយ
## គប្បីរឭកដោយអាការ ៨ យ៉ាង

ឯចំពោះព្រះយោគាវចរណា មនសិការត្រឹមប៉ុណ្ណោះ កម្មដ្ឋានមិនកើតឡើង ព្រះយោគាវចរនោះ គប្បីរឭកដល់សេចក្តីស្លាប់ដោយអាការ ៨ នេះ គឺ ៖

១-វធកបច្ចុប្បដ្ឋានតោ ដោយការប្រាកដ ដូចពេជ្ឈឃាត
២-សម្បត្តិវិបត្តិតោ ដោយការវិបត្តិនៃសម្បត្តិ
៣-ឧបសំហរណតោ ដោយការប្រៀបធៀប
៤-កាយពហុសាធារណតោ ដោយរាងកាយជាសាធារណៈដល់សត្វ និង បច្ច័យនៃសេចក្តីស្លាប់ច្រើនប្រភេទ
៥-អាយុទុព្វលតោ ដោយអាយុជារបស់ទុព្វល
៦-អនិមិត្តតោ ដោយជីវិតមិនមាននិមិត្ត
៧-អទ្ធានបរិច្ឆេទតោ ដោយជីវិតមានកាលកំណត់
៨-ខណបរិត្តតោ ដោយជីវិតមានខណៈតិច

## ១-វធកបច្ចុប្បដ្ឋានតោ
( ដោយការប្រាកដដូចពេជ្ឈឃាត )

ក្នុង ៨ បទនោះ បទថា **វធកបច្ចុប្បដ្ឋានតោ** ប្រែថា ដោយការប្រាកដ ( នៃសេចក្តីស្លាប់ ) ដូចពេជ្ឈឃាត មានន័យថា ព្រះយោគាវចរគប្បីរឭកថា ពេជ្ឈឃាតគិតថា នឹងកាត់ក្បាលអ្នកនេះ ដាក់ដាវផ្ទឹបនឹងក ឈរប្រកៀកខ្លួន យ៉ាងណា សូម្បីសេចក្តីស្លាប់ ក៏ប្រាកដដូច្នោះ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះវាមកព្រមជាមួយនឹងការកើត និងព្រោះវាផ្តាច់យកជីវិតទៅ ឧបមាដូចជាផ្សិត រមែងទូលល្អងដីពេលដែលវាដុះឡើងមក យ៉ាងណា សត្វទាំងឡាយក៏នាំយកជរា និងមរណៈមកជាមួយនឹងការកើតក៏យ៉ាងនោះ ពិតហើយ បដិសន្ធិចិត្តរបស់សត្វទាំងឡាយនោះ ក៏ដល់នូវជរា បន្ទាប់ពីការកើតហើយនោះឯង ហើយក៏បែកធ្លាយ ព្រមជាមួយនឹង

សម្បយុត្តខន្ធទាំងឡាយ ដូចដុំសិលាធ្លាក់ចុះពីលើកំពូលភ្នំ បែកទៅដូច្នោះ ( នេះពោលដោយ ) ខណិកមរណៈដែលមកព្រមជាមួយនឹងការកើត តែមរណៈដែលទ្រង់បំណងយកក្នុងមរណស្សតិនេះ ក៏មកព្រមជាមួយការកើតដែរ ព្រោះសត្វដែលកើតមកហើយ ត្រូវស្លាប់ជាប្រាកដ ព្រោះហេតុនោះ សត្វនោះ ចាប់តាំងពីកើតមកហើយ ក៏ឆ្ពោះមុខទៅកាន់សេចក្តីស្លាប់ ទៅដោយមិនត្រឡប់បន្តិចឡើយ ប្រៀបដូចជាព្រះអាទិត្យដែលរះឡើងហើយ រមែងលិចទៅវិញជាធម្មតា មិនបានត្រឡប់ពីទីដែលឆ្ពោះទៅ សូម្បីតែបន្តិចឡើយ ឬមិនដូច្នោះ ដូចខ្សែទឹកហូរចុះពីលើភ្នំ ខ្សែទឹករមែងហូរនាំយកវត្ថុផ្សេងៗ ឲ្យធ្លាក់ចុះទៅតែម្យ៉ាង មិនបានឲ្យត្រឡប់វិញ សូម្បីតែបន្តិចឡើយ ព្រោះដូច្នោះ ព្រះអយោឃរកុមារពោធិសត្វ ទើបពោលថា ៖

**សត្វអំបូរមនុស្ស ចូលទៅនៅក្នុងគភ៌ ក្នុងកណ្តាលរាត្រី ក្នុងខណៈដំបូង ( បដិសន្ធិ ) សត្វដែលកើតឡើង មានខ្លួនហើយ ក៏បែរមុខទៅហើយ ចូលទៅរឿយ ៗ មិនត្រឡប់វិញឡើយ ។**

ម្យ៉ាងទៀត កាលសត្វនោះ ឆ្ពោះទៅយ៉ាងនោះ សេចក្តីស្លាប់រមែងហូរចូលមកពីគ្រប់ទិសទី ដូចជាការហួតហែងទៅនៃដំណក់ទឹកទាំងឡាយ ដែលត្រូវកម្តៅថ្ងៃក្នុងរដូវប្រាំង ដូចជាផ្លែឈើទាំងឡាយដែលត្រូវជ្រុះ ព្រោះទងស្ងួតជាតិទឹកអស់ហើយ ក្នុងពេលព្រឹក ដូចជាការបែកធ្លាយទៅនៃភាជនៈដីទាំងឡាយ ដែលត្រូវគប់ដោយដុំដី និងដូចជាការហួតហែងទៅនៃដំណក់ទឹកសន្សើមទាំងឡាយ ដែលត្រូវរស្មីនៃព្រះអាទិត្យដូច្នោះ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ៖

**ថ្ងៃនឹងយប់កន្លងទៅ ជីវិតកាន់តែអស់ទៅ អាយុរបស់សត្វទាំងឡាយ កាន់តែខ្ចីទៅ ដូចជាប្រឡាយទឹកតូច រីងស្ងួតទៅដូច្នោះ ។**

ភ័យកើតពីសេចក្ដីស្លាប់ រមែងមានយ៉ាងប្រាកដដល់សត្វទាំងឡាយ ដែលកើតមកហើយ ដូចភ័យកើតពីការជ្រុះក្នុងពេលព្រឹក រមែងមានដល់ផ្លែឈើទាំងឡាយ ដែលទុំហើយដូច្នោះ ។

ភាជនៈដីដែលស្មូនផ្ទាំងធ្វើឡើងហើយ ទាំងតូចទាំងធំ ទាំងឆៅទាំងឆ្អិន សុទ្ធតែមានការបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏ដូច្នោះ ។

ទឹកសន្សើមនៅនឹងចុងស្មៅ កាលដែលព្រះអាទិត្យរះឡើងមក ក៏ហួតហែងទៅ យ៉ាងណា អាយុរបស់មនុស្សទាំងឡាយ ក៏ដូច្នោះ សូមម៉ែ កុំហាមខ្ញុំក្នុងការបួសឡើយ ( គាថា ទី ៤ នេះ ជារបស់ព្រះពោធិសត្វ ) ។

**មរណៈ** មកព្រមជាមួយនឹងជាតិ ដូចជាពេជ្ឈឃាតងារដាវឡើង ម្យ៉ាងទៀត មរណៈនោះ រមែងឆក់យកជីវិតទៅ កាលដែលឆក់យកទៅហើយ ក៏មិនបានដោះលែងឲ្យត្រឡប់វិញឡើយ ដូចពេជ្ឈឃាតផ្ទិបដាវជាប់នឹងក ដូច្នោះ ព្រោះហេតុនោះ មរណៈ ទើបឈ្មោះថា ប្រាកដដូចពេជ្ឈឃាតងារដាវឡើង ព្រោះមកព្រមជាមួយនឹងជាតិ និងព្រោះឆក់យកជីវិតទៅ ដោយប្រការ ១ ដូច្នេះ ព្រះយោគាវចរ ទើបគួររឭកដល់សេចក្ដីស្លាប់ ដោយអាការប្រាកដ ដូចជាពេជ្ឈឃាត ដូចដែលពោលមកដូច្នេះចុះ ។

## ២-សម្បត្តិវិបត្តិតោ
## ( ដោយការវិបត្តិនៃសម្បត្តិ )

បទថា **សម្បត្តិវិបត្តិតោ** - ដោយការវិបត្តិនៃសម្បត្តិ មានអធិប្បាយថា សម្បត្តិក្នុងលោកនេះ ស្អាតបានត្រឹមតែមួយរយៈកាល នៅពេលវិបត្តិមិនទាន់គ្រប

សង្កត់ តែថា សម្បត្តិកន្លងផុតវិបត្តិ មិនមាន , ពិតហើយ សូម្បីព្រះបាទអសោក ទ្រង់មានសេចក្តីសុខ បានគ្រប់គ្រងផែនដីទាំងមូល ចំណាយព្រះរាជទ្រព្យ ១០០ កោដិ ( ១ ថ្ងៃ ) ក្នុងទីបំផុត ទ្រង់គ្រប់គ្រងភាពជាធំលើផ្លែកន្ទួតព្រៃ ១ ចំហៀង ប៉ុណ្ណោះ ព្រមទាំងកូនខ្ទមនោះឯង កាលបុណ្យអស់ហើយ ព្រះអង្គក៏បែរព្រះភក្ត្រ ទៅរកមរណភាព ដល់នូវសេចក្តីសោកសៅ ហើយទៅ ។

ម្យ៉ាងទៀត ការមិនមានរោគទាំងពួង រមែងមានជំងឺជាបរិយោសាន ភាពជា កំលោះទាំងពួង រមែងមានជរាជាបរិយោសាន ការរស់នៅ រមែងមានមរណៈជា បរិយោសាន លោកសន្និវាសទាំងមូល ត្រូវជាតិជាប់តាម ត្រូវជរាដេញសង្គ្រប់ ត្រូវព្យាធិរួបរឹត ត្រូវមច្ចុកម្ទាត់ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ៖

ភ្នំថ្មតាន់ខ្ពស់សន្ធឹម រមៀលកិនសត្វ មកពីទិសទាំង ៤ ដោយជុំវិញ ( មិន វៀរនរណា ) យ៉ាងណាក្តី ជរានិងមរណៈ ក៏ដូច្នោះ រមែងគ្របសង្កត់សត្វទាំង-ឡាយ គឺ ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកវេស្សៈ ពួកសូទ្រៈ ពួកចណ្ឌាល និងបុក្កុ-សៈ ( កម្មករចាក់សំរាម ) មិនលើកលែងនរណាៗ កិនកម្ទេចទាំងអស់ , ក្នុងជរា និងមរណៈនោះ ជ័យភូមិ សម្រាប់ពលដំរីក៏មិនមាន សម្រាប់ពលសេះក៏មិនមាន សម្រាប់ពលរថក៏មិនមាន សម្រាប់ពលថ្មើរជើងក៏មិនមាន ទាំងនរណាៗ ក៏មិន អាចយកឈ្នះដោយមន្តយុទ្ធ ( ការប្រើវេទមន្ត ) ឬ ដោយទ្រព្យឡើយ ។ **វិបត្តិ** គឺ មរណៈជាបរិយោសាននៃសម្បត្តិ គឺ ជីវិត មានន័យដូចពោលមកនេះឯង ព្រះ យោគាវចរ គប្បីរឭកដល់ជីវិត ដែលមានមរណៈជាបរិយោសាននោះ រឭកដល់ សេចក្តីស្លាប់ ដោយអាការវិបត្តិនៃសម្បត្តិចុះ ។

## ៣ – ឧបសំហរណតោ

## ( ដោយការប្រៀបធៀប )

បទថា **ឧបសំហរណតោ** គឺ ដោយការប្រៀបធៀបខ្លួនជាមួយនឹងអ្នកដទៃ ៗ ( ដែលស្លាប់ហើយ ) ក្នុងខនោះមានអធិប្បាយថា ព្រះយោគាវចរ គប្បីរឭកដល់សេចក្ដីស្លាប់ មានការប្រៀបធៀបដោយអាការ ៧ យ៉ាង គឺ ៖

១- យសមហត្តតោ ដោយការមានយសជាធំ

២- បុញ្ញមហត្តតោ ដោយការមានបុណ្យច្រើន

៣- ថាមមហត្តតោ ដោយការមានកម្លាំងខ្លាំង

៤- ឥទ្ធិមហត្តតោ ដោយការមានឫទ្ធិច្រើន

៥- បញ្ញាមហត្តតោ ដោយការមានបញ្ញាច្រើន

៦- បច្ចេកពុទ្ធតោ ដោយភាពជាព្រះបច្ចេកពុទ្ធ

៧- សម្មាសម្ពុទ្ធតោ ដោយភាពជាព្រះសម្មាសម្ពុទ្ធ

## យសមហត្តតោ

សួរថា ( ការរលឹកដោយការមានយសជាធំ ) ដូចម្ដេច ?

ឆ្លើយថា គប្បីរឭកដោយការមានយសជាធំ យ៉ាងនេះថា “ សេចក្ដីស្លាប់នេះបានពាល់ត្រូវលោកអ្នកដែលមានយសធំ អ្នកមានបរិវារច្រើន មានទ្រព្យ និងពាហនៈច្រើន ពាល់ត្រូវសូម្បីព្រះបាទមហាសម្មតៈ ព្រះបាទមន្ធាតុ ព្រះបាទមហាសុទស្សនៈ ព្រះបាទទឡ្ហនេមិ មកហើយ ក៏គេចមិនរួច រឿងអ្វីដែលថា វាមិនពាល់ត្រូវយើង ។

លោកអ្នកដែលមានយសធំទាំងឡាយ សូម្បីសកទេវរាជដ៏ប្រសើរ ដូចជាព្រះបាទមហាសម្មតៈ ក៏នៅតែជួបប្រទះអំណាចនៃមច្ចុ ចាំបាច់ពោលថ្វីដល់បុគ្គលដូចជាយើងនេះនោះ ។ ដូច្នេះ ជាបឋម ។

## បុញ្ញមហត្តតោ

( គប្បីរឭក ) ដោយការមានបុណ្យច្រើន ដូចម្ដេច ? គប្បីរឭកដោយការមានបុណ្យច្រើនយ៉ាងនេះថា ៖

សេដ្ឋីទាំងឡាយនេះ គឺ ជោតិយៈ ជដិល ឧគ្គៈ មេណ្ឌកៈ បុណ្ណៈ និងបុគ្គលដទៃ ដែលប្រាកដថា ជាអ្នកមានបុណ្យច្រើនក្នុងលោក ក៏គង់ដល់នូវសេចក្ដីស្លាប់ទាំងអស់ នឹងពោលថ្វីដល់បុគ្គលទាំងឡាយដូចជាយើង ។

## ថាមមហត្តតោ

( គប្បីរឭក ) ដោយការមានកម្លាំងខ្លាំង ដូចម្ដេច ? គប្បីរឭកតាមការដែលមានកម្លាំងខ្លាំង យ៉ាងនេះថា ៖

ព្រះវាសុទេព ព្រះពលទេព ព្រះភីមសេន ព្រះយុធិដ្ឋិលៈ សូម្បី ហនុរៈជាអ្នកបោកចំបាប់ដ៏ធំ ក៏ទៅកាន់អំណាចនៃសេចក្ដីស្លាប់ហើយ សូម្បីបុគ្គលទាំង-ឡាយនោះ ជាអ្នកល្បីឈ្មោះក្នុងលោកថា ជាមនុស្សមានកម្លាំងខ្លាំងក្លាយ៉ាងនេះ ក៏គង់ដល់នូវសេចក្ដីស្លាប់ ចាំបាច់ពោលថ្វីដល់បុគ្គលទាំងឡាយដូចជាយើង ។

## ឥទ្ធិមហត្តតោ

( គប្បីរឭក ) ដោយការមានឫទ្ធិច្រើន ដូចម្ដេច ? គប្បីរឭកដោយការមាន

ឫទ្ធិច្រើន យ៉ាងនេះថា ៖

ព្រះអគ្គសាវកទី ២ អ្នកបានឈ្មោះថា ជាកំពូលនៃអ្នកមានឫទ្ធិទាំងឡាយ អាចញ៉ាំងវេជ្ជយ័ន្តប្រាសាទ ឲ្យញាប់ញ័របានដោយមេជើង ព្រះអគ្គសាវកទី ២ នោះ ក៏ធ្លាក់ចូលទៅកាន់មាត់របស់មច្ចុ ដែលគួរឲ្យភ័យខ្លាច ទៅព្រមជាមួយនឹងឫទ្ធិទាំងឡាយ ដូចម្រឹគចូលមាត់សីហៈ ចាំបាច់ពោលថ្វីដល់មនុស្សទាំងឡាយ ដូចជាយើង ។

## បញ្ញាមហត្តតោ

( គប្បីរឭក ) ដោយការមានបញ្ញាច្រើន ដូចម្ដេច ? គប្បីរឭកដល់អ្នកដែលមានបញ្ញាច្រើន យ៉ាងនេះថា ៖

លើកលែងតែព្រះលោកនាថចេញ សត្វទាំងឡាយដទៃណា មានហើយ សត្វទាំងនោះ ពោលដោយបញ្ញា ក៏នៅមិនដល់ចម្រៀកទី ១៦ នៃព្រះសារីបុត្ត ព្រះអគ្គសាវកទី ១ បានឈ្មោះថា មានបញ្ញាច្រើនយ៉ាងនេះ ក៏គង់ដល់នូវអំណាចនៃសេចក្ដីស្លាប់ ចាំបាច់ពោលថ្វីដល់បុគ្គលទាំងឡាយដូចជាយើង ។

## បច្ចេកពុទ្ធតោ

( គប្បីរឭក ) ដោយភាពជាព្រះបច្ចេកពុទ្ធជាម្ចាស់ ដូចម្ដេច ? គប្បីរឭកចំពោះព្រះបច្ចេកពុទ្ធយ៉ាងនេះថា សូម្បីពុទ្ធបុគ្គលទាំងឡាយ ធ្វើការញាំញីនូវសត្រូវ គឺ សព្វកិលេស ដោយពលៈ គឺ ញាណនិងវីរិយៈ របស់ខ្លួន បានសម្រេចបច្ចេកសម្ពោធិ ជាព្រះសយម្ភូ ( មានចរិយា ) ដូចកុយរមាស សូម្បីពុទ្ធបុគ្គលទាំងឡាយនោះ ក៏មិនបានរួចផុតសេចក្ដីស្លាប់ យើងនឹងផុតយ៉ាងម៉េចទៅ ?

ព្រះមហាឥសីទាំងឡាយណា អាស្រ័យនិមិត្តនោះ ៗ ពិចារណារហូតបាន សម្រេចនូវអាសវក្ខយៈ ដោយកម្លាំងញាណដ៏ខ្លាំងក្លា ជាព្រះសយម្ភូ ប្រៀបដូចជា កុយរមាស ព្រោះត្រាច់ទៅ និង នៅតែមួយអង្គឯង សូម្បីព្រះមហាឥសីទាំងឡាយ នោះ ក៏កន្លងផុតសេចក្ដីស្លាប់មិនបាន ចាំបាច់ពោលថ្វីដល់បុគ្គលដូចជាយើង ។

## សម្មាសម្ពុទ្ធតោ

( គប្បីរឭក ) ដល់ភាពជាព្រះសម្មាសម្ពុទ្ធ ដូចម្ដេច ? គប្បីរឭកដល់ភាព ជាព្រះសម្មាសម្ពុទ្ធ យ៉ាងនេះថា សូម្បីព្រះមានព្រះភាគជាម្ចាស់ មានព្រះរូបកាយ វិចិត្រទៅដោយមហាបុរិសលក្ខណៈ ៣២ ប្រដាប់ដោយអនុព្យញ្ជនៈ ៨០ ប្រការ មានព្រះធម្មកាយសម្រិតដោយព្រះគុណរតនៈ មានសីលក្ខន្ធដ៏បរិសុទ្ធដោយអាការ ទាំងពួងជាដើម ទ្រង់ដល់នូវត្រើយនៃការមានយសធំ មានបុណ្យច្រើន មានកម្លាំង ច្រើន មានឫទ្ធិច្រើន និង មានបញ្ញាច្រើន គ្មានអ្នកស្មើ ទ្រង់ស្មើដោយអ្នកដែលមិន មានអ្នកណាស្មើ រកអ្នកប្រៀបមិនបាន រកបុគ្គលផ្ទឹមមិនបាន ជាព្រះអរហន្តត្រាស់ ដឹងឯងដោយប្រពៃ សូម្បីព្រះមានព្រះភាគអង្គនោះ ក៏ទ្រង់បាត់ទៅយ៉ាងឆាប់រហ័ស ដោយភ្លៀង គឺ មរណៈ ដូចជាគំនរភ្លើងធំរលត់ទៅដោយដំណក់ទឹកភ្លៀងដូច្នោះ ។

សេចក្ដីស្លាប់នោះ ផ្សាយអំណាចមកដល់អង្គព្រះមហាឥសី ដែលទ្រទ្រង់នូវ អានុភាពដ៏ធំយ៉ាងនេះបាន ដោយមិនខ្លាចញញើត រឿងអ្វីដែលថាសេចក្ដីស្លាប់នោះ ដែលគ្មានការក្រែងរអែង បំណងតែនឹងញាំញីសត្វមិនរើសមុខ នឹងមិនគ្របសង្កត់ សត្វដូចជាយើង ។

កាលព្រះយោគាវចរនោះ ប្រៀបធៀបខ្លួនជាមួយនឹងអ្នកដទៃ ៗ អ្នកដែល

ដល់ព្រមដោយភាពជាធំ មានភាពជាអ្នកមានយសធំជាដើម ដោយការៈ គឺ ការមានមរណៈស្មើគ្នាយ៉ាងនេះហើយ រឭកទៅថា **សេចក្តីស្លាប់នឹងត្រូវមានដល់យើងដូចមានដល់អ្នកពិសេសទាំងឡាយនោះ** ដូច្នេះ កម្មដ្ឋាននឹងដល់ឧបចារៈ , ព្រះយោគាវចរគប្បីរឭកដល់សេចក្តីស្លាប់ ដោយការប្រៀបធៀប ដោយប្រការដូច្នេះ ។

## ៤-កាយពហុសាធារណតោ

( ជាសាធារណៈដល់សត្វគ្រប់ប្រភេទ និងបច្ច័យនៃសេចក្តីស្លាប់ )

បទថា **កាយពហុសាធារណតោ** មានអធិប្បាយថា កាយនេះជាសាធារណៈដល់សត្វច្រើនប្រភេទ គឺ ជាដំបូងជាសាធារណៈដល់ពួកកិមិជាតិ(ដង្កូវ) ៨០ ជំពូក ក្នុង កិមិជាតិទាំងឡាយនោះ ជំពូកដែលសត្វអាស្រ័យស្បែកក្រៅ ក៏ស៊ីស្បែកក្រៅ ជំពូកដែលអាស្រ័យស្បែកក្នុង ក៏ស៊ីស្បែកក្នុង ពួកដែលអាស្រ័យសាច់ ក៏ស៊ីសាច់ ពួកដែលអាស្រ័យសរសៃ ក៏ស៊ីសរសៃ ពួកដែលអាស្រ័យឆ្អឹង ក៏ស៊ីឆ្អឹង ពួកដែលអាស្រ័យខួរក្នុងឆ្អឹង ក៏ស៊ីខួរក្នុងឆ្អឹង វា កើត ចាស់ ឈឺ ស្លាប់ បន្ទោបង់ឧច្ចារៈបស្សាវៈ នៅក្នុងទីនោះឯង ហើយរាងកាយ ក៏ចាត់ជា សាលសម្ភព មន្ទីរពេទ្យ ជាព្រៃស្មសានផងដែរ ជាបង្គន់ ជាកន្ធោរនោម របស់ពួកវា ព្រោះថា រាងកាយនេះ កាលបើកិមិជាតិទាំងឡាយនោះកម្រើក ក៏ដល់នូវសេចក្តីស្លាប់ជាប្រាកដ ។

ម្យ៉ាងទៀត កាយនេះជាសាធារណៈដល់កិមិជាតិ ៨០ ជំពូក យ៉ាងណា ក៏ជាសាធារណៈដល់បច្ច័យនៃសេចក្តីស្លាប់ ទាំងដែលជាខាងក្នុង បានដល់ រោគច្រើនរយប្រភេទ ទាំងដែលជាខាងក្រៅ បានដល់ សត្វមានពិស ដូចជាពស់និងខ្ទួយជាដើម ដូច្នោះ ឧបមាដូចអាវុធទាំងឡាយ មានកូនសរ ស្នា លំពែង និង ដុំថ្មជាដើម

ដែលមកពីទិសទាំងពួង មុតចំរង្វង់មូល ដែលគេតាំងទុក នៅត្រង់ផ្លូវបែកជា ៤ យ៉ាងណា សូម្បីឧបទ្រវៈទាំងពួង ក៏ធ្លាក់ចុះមកកាន់រាងកាយ ក៏យ៉ាងនោះ ដែលពោលចំពោះរាងកាយនេះដូច្នោះ ព្រោះការធ្លាក់ចុះនៃឧបទ្រវៈទាំងឡាយនោះ ក៏នឹងដល់នូវសេចក្ដីស្លាប់បានដូចគ្នា ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា :

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ កាលពេលថ្ងៃកន្លងទៅហើយ រាត្រីចូលមកដល់ រមែងពិចារណាឃើញយ៉ាងនេះថា បច្ច័យនៃសេចក្ដីស្លាប់របស់យើងមានច្រើនណាស់ គឺ ពស់អាចខាំយើងក៏បាន ខ្ទួយអាចទិចយើងក៏បាន ក្អែបអាចខាំយើងក៏បាន ព្រោះបច្ច័យមានពស់ខាំជាដើមនោះ កាលកិរិយាអាចមានដល់យើងបាន ការៈ គឺ កាលកិរិយានោះ នឹងជាអន្តរាយដល់យើង យើងអាចរអិលដួលក៏បាន កត្តដែលយើងបរិភោគហើយ អាចកើតជាពិសក៏បាន ទឹកប្រមាត់របស់យើងកម្រើកក៏បាន ស្លេស្មរបស់យើងកម្រើកក៏បាន ខ្យល់សត្ថកៈ ( ផ្ដាច់ជីវិត ) របស់យើងកម្រើកក៏បាន ព្រោះបច្ច័យ មានការរអិលដួលជាដើម កាលកិរិយាអាចមានដល់យើងបាន ការៈ គឺ កាលកិរិយានោះ អាចជាអន្តរាយដល់យើង ដូច្នេះ , ព្រះយោគាវចរ គប្បីរឭកដល់សេចក្ដីស្លាប់ ដោយរាងកាយជាសាធារណៈដល់សត្វនិងបច្ច័យនៃសេចក្ដីស្លាប់ ច្រើនប្រភេទ ដូចពោលមកនេះឯង ។

## ៥–អាយុទុព្វលតោ

( អាយុជារបស់ទុព្វល )

បទថា **អាយុទុព្វលតោ** អធិប្បាយថា អាយុនោះមិនរឹងមាំ ទន់ខ្សោយ ពិតហើយ អាយុរបស់សត្វទាំងឡាយជាប់ជាមួយនឹងខ្យល់ដង្ហើមចូលចេញ ១ ជាប់នឹង

ឥរិយាបថ ១ ដាច់នឹងក្តៅ-ត្រជាក់ ១ ដាច់នឹងមហាភូត ១ ដាច់នឹងអាហារ ១ ។

ជីវិតនេះនោះ មានការប្រព្រឹត្តទៅស្មើនៃខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញប៉ុណ្ណោះ ទើបប្រព្រឹត្តទៅបាន តែកាលខ្យល់ដង្ហើមចេញទៅក្រៅហើយ មិនចូលក្នុងវិញក្តី ចូលក្នុងហើយ មិនចេញក្រៅក្តី បុគ្គល ក៏បានឈ្មោះថា ស្លាប់ ។

ម្យ៉ាងទៀត ជីវិតនោះ មានការប្រព្រឹត្តទៅស្មើនៃឥរិយាបថ ៤ ប៉ុណ្ណោះ ទើបប្រព្រឹត្តទៅបាន បើឥរិយាបថណាមួយលើសប្រមាណ ដោយប្រការណាមួយ អាយុសង្ខារ ក៏ត្រូវដាច់ ។

ម្យ៉ាងទៀត ជីវិតនោះ បានការប្រព្រឹត្តទៅសមល្មមនៃភាពក្តៅ និងត្រជាក់ប៉ុណ្ណោះ ទើបប្រព្រឹត្តទៅបាន តែកាលបើបុគ្គលត្រូវត្រជាក់ហួសប្រមាណក្តី ក្តៅហួសប្រមាណក្តី គ្របសង្កត់ ក៏រមែងវិបត្តិទៅ ។

ម្យ៉ាងទៀត ជីវិតនោះ បានការប្រព្រឹត្តទៅស្មើនៃមហាភូតរូបទាំងឡាយប៉ុណ្ណោះ ទើបប្រព្រឹត្តទៅបាន តែព្រោះបឋវីធាតុ ឬធាតុដ៏សេស មានអាបោធាតុជាដើម យ៉ាងណាមួយ កម្រើកហើយ បុគ្គលសូម្បីសម្បូរណ៍ដោយកម្លាំង ក៏ទៅជាបុគ្គលមានកាយរឹងខ្លះ មានកាយស្អុយសៅហ្មង ដោយអំណាចនៃរោគរាគមួលជាដើមខ្លះ មានការក្តៅសន្ធំខ្លះ ដាច់សរសៃខ្លះ ក៏ដល់នូវការអស់ជីវិតទៅ ។

ម្យ៉ាងទៀត កាលបុគ្គលបានកវឡិង្ការាហារ ក្នុងកាលដែលសមគួរប៉ុណ្ណោះ ជីវិត ទើបប្រព្រឹត្តទៅបាន តែកាលបើមិនបានអាហារ វាក៏វិនាសដូចគ្នា ។

ព្រះយោគាវចរ គប្បីរឭកដល់សេចក្តីស្លាប់ ដោយអាយុជារបស់ទុព្វលតាមន័យដូច្នេះចុះ ។

# ៦-អនិមិត្តតោ

( ជីវិតមិនមាននិមិត្ត )

បទថា **អនិមិត្តតោ** គឺ មិនមានការកំណត់ មានន័យថា ព្រោះមិនមានព្រំដែន ។

ពិតហើយ ធម៌ ៥ ប្រការ គឺ ជីវិត ព្យាធិ កាល ទីកន្លែងដាក់ចុះសាកសព និង គតិ របស់សត្វទាំងឡាយក្នុងជីវលោក មិនមាននិមិត្ត ដឹងមិនបាន ។

ក្នុងធម៌ ៥ ប្រការនោះ **ជីវិត** ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានការកំណត់ថា នឹងរស់នៅត្រឹមប៉ុណ្ណោះ មិនរស់នៅបន្ទាប់ពីនេះទៅ ព្រោះថា សត្វទាំងឡាយរមែងស្លាប់ក្នុងកាលនៅជាកលលៈក៏មាន ក្នុងកាលនៅជាអព្ពុទៈក៏មាន ជាបេសិ ជាឃនៈ នៅក្នុងគភ៌ បាន១ខែ បាន២ខែ បាន៣ខែ បាន៤ខែ បាន៥ខែ បាន១០ខែ ក៏មាន ក្នុងសម័យដែលចេញចាកផ្ទៃក៏មាន បន្ទាប់ពីនោះ ស្លាប់ក្នុងរវាង ១០០ ឆ្នាំ ក៏មាន ជាង ១០០ ឆ្នាំ ក៏មាន ដូចគ្នា ។

**ព្យាធិ** ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានការកំណត់ថា សត្វទាំងឡាយត្រូវស្លាប់ដោយជំងឺនេះប៉ុណ្ណោះ មិនស្លាប់ដោយជំងឺដទៃ ព្រោះថា សត្វទាំងឡាយស្លាប់ដោយរោគភ្នែកក៏មាន ដោយរោគក្រៅពីនោះ មានរោគត្រចៀកជាដើម យ៉ាងណាមួយក៏មាន ។

**កាល** ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានការកំណត់យ៉ាងនេះថា ត្រូវស្លាប់ក្នុងកាលនេះប៉ុណ្ណោះ មិនស្លាប់ក្នុងកាលដទៃ ព្រោះថា សត្វទាំងឡាយរមែងស្លាប់ ក្នុងពេលព្រឹកក៏មាន ក្នុងពេលដទៃ មានថ្ងៃត្រង់ជាដើម ក្នុងពេលណាមួយក៏មាន ។

**ទីកន្លែងដាក់ចុះសាកសព** ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានការកំណត់យ៉ាងនេះថា សត្វទាំងឡាយត្រូវតែស្លាប់ក្នុងទីនេះប៉ុណ្ណោះ មិនស្លាប់ក្នុងទីដទៃ , ព្រោះថា រាងកាយរបស់បុគ្គលទាំងឡាយ កើតក្នុងស្រុក ស្លាប់ក្រៅស្រុកក៏មាន រាងកាយរបស់បុគ្គលកើតក្រៅស្រុក ស្លាប់ក្នុងស្រុកក៏មាន ដោយន័យដូចគ្នាដែរ បណ្ឌិតអធិប្បាយឲ្យពិស្តារគ្រប់ប្រការ ជាដើមថា រាងកាយរបស់សត្វទាំងឡាយកើតលើគោក អាចស្លាប់ក្នុងទឹក ឬថា កើតក្នុងទឹក អាចស្លាប់លើគោក.... ។

**គតិ** ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានការកំណត់យ៉ាងនេះថា សត្វដែលចុតិចាកគតិនេះ នឹងកើតក្នុងគតិនេះ ព្រោះថា សត្វទាំងឡាយដែលចុតិចាកទេវលោក កើតក្នុងមនុស្សលោកក៏មាន ចុតិចាកមនុស្សលោក កើតក្នុងលោកដទៃមានទេវលោកជាដើម ទីណាមួយក៏មាន ព្រោះយ៉ាងនេះ លោកទើបវិលទៅក្នុងគតិ ៥ ដូចគោដែលគេចងនឹងបង្គោលស្នឹង ក៏ដើរវិលជុំវិញទៅ ។

ព្រះយោគាវចរ គប្បីរឭកដល់សេចក្តីស្លាប់ ព្រោះជីវិតមិនមាននិមិត្ត ដូចពោលមកដូច្នេះចុះ ។

## ៧ – អទ្ធានបរិច្ឆេទតោ

( ជីវិតមានកាលកំណត់ )

បទថា **អទ្ធានបរិច្ឆេទតោ** អធិប្បាយថា កាលនៃជីវិតរបស់មនុស្សទាំងឡាយក្នុងសម័យនេះ អ្នកដែលរស់នៅបានយូរ អ្នកនោះក៏រស់នៅ ១ឬ ១០០ ឆ្នាំ លើសនោះទៅ ក៏មានខ្លះ តែតិចតួចទេ , ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ អាយុរបស់មនុស្សមានប្រមាណតិច សម្បរាយភពនឹងត្រូវ**

ទៅ ទើបគួរធ្វើកុសល ប្រព្រឹត្តព្រហ្មចារ្យ ការមិនស្លាប់នៃសត្វដែលកើតហើយ មិនមានទេ ម្នាលភិក្ខុទាំងឡាយ អ្នកណាដែលរស់នៅបានយូរ អ្នកនោះ ក៏រស់នៅ ខ្ទង់ ១០០ ឆ្នាំ ច្រើនជាងនោះ ក៏មានខ្លះ តែតិចទេ ។

## និគមគាថា

អាយុរបស់មនុស្សទាំងឡាយតិច បុគ្គលល្អមិនគប្បីប្រមាទ ចូរប្រព្រឹត្តដូចមនុស្សត្រូវភ្លើងឆេះលើសីសៈ គ្មានទីណាមួយដែលមច្ចុមិនមកឡើយ ។

ទ្រង់ត្រាស់ទុកក្នុងសូត្រមួយទៀតថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយ មានសាស្តា ឈ្មោះ អារកៈ ដូច្នេះជាដើម , ព្រះសូត្រប្រកបដោយឧបមា ៧ យ៉ាង បណ្ឌិតគប្បីនាំមកឲ្យពិស្តារចុះ ។

ទ្រង់ត្រាស់ទុកក្នុងទីដទៃទៀតថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនមរណស្សតិយ៉ាងនេះថា “ ឱហ្ន៎ យើងអាចរស់នៅបានរយៈពេល ១ យប់ ១ ថ្ងៃ ដូច្នោះយើងប្រញាប់ធ្វើទុកក្នុងចិត្ត ដល់ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ សេចក្តីនោះជាឧបការៈដល់យើង ” ដូច្នេះក្តី , ភិក្ខុចម្រើនមរណស្សតិយ៉ាងនេះថា “ ឱហ្ន៎ យើងអាចរស់នៅបានកន្លះថ្ងៃ យើងគួរធ្វើទុកក្នុងចិត្តដល់ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ សេចក្តីនោះជាឧបការដល់យើងហ្ន៎ ” ក្តី , ភិក្ខុចម្រើនមរណស្សតិយ៉ាងនេះថា “ ឱហ្ន៎ យើងអាចរស់បានក្នុងរយៈពេលត្រឹមឆាន់បិណ្ឌបាត ១ ពេល ដូច្នោះយើងគួរធ្វើទុកក្នុងចិត្តចំពោះពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ សេចក្តីនោះជាឧបការដល់យើងហ្ន៎ ” ក្តី , ភិក្ខុចម្រើនមរណស្សតិ យ៉ាងនេះថា យើងអាចរស់នៅបានត្រឹមរយៈពេលទំពាអាហារលេបបាន ៤-៥ ដុំ ដូច្នោះយើងគួរធ្វើទុកក្នុង

ចិត្តដល់ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគចុះ សេចក្តីនោះ ជាឧបការៈដល់យើងហ្ន៎ ” ដូច្នេះក្តី , ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ គឺថាគតពោលថា នៅជាអ្នកប្រមាទនៅឡើយ ចម្រើនមរណស្សតិនៅយឺតយូរ ដើម្បីនឹងអស់អាសវៈ , ម្នាលភិក្ខុទាំងឡាយ រីឯភិក្ខុចម្រើនមរណស្សតិយ៉ាងនេះថា “ ឱហ្ន៎ ! យើងអាចរស់នៅបានត្រឹមរយៈនៃការលេបអាហារមួយដុំ យើងគួរប្រញាប់ធ្វើទុកក្នុងចិត្តដល់ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគចុះ សេចក្តីនោះនឹងជាឧបការដល់យើងច្រើនហ្ន៎ ” ដូច្នេះក្តី , ភិក្ខុចម្រើនមរណស្សតិយ៉ាងនេះថា “ ឱហ្ន៎ ! យើងអាចរស់នៅបានត្រឹមរយៈនៃការដកដង្ហើមចូលហើយចេញ ឬ ដកដង្ហើមចេញហើយចូល ដូច្នោះយើងគួរធ្វើទុកក្នុងចិត្ត ដល់ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគចុះ សេចក្តីនោះជាឧបការដល់យើងច្រើនហ្ន៎ ” ដូច្នេះក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតពោលថា ជាអ្នកមិនប្រមាទ ចម្រើនមរណស្សតិប្រញាប់ដើម្បីអស់អាសវៈ ។

ជីវិតមានរយៈខ្លី មិនគួរនឹងដាក់ចិត្ត ដល់ទៅក្នុងរយៈទំពាអាហារ ៤-៥ ដុំ ដូច្នេះឡើយ ព្រះយោគាវចរ គប្បីរឭកដល់សេចក្តីស្លាប់ ដោយជីវិតមានកាលកំណត់ តាមន័យដូច្នេះចុះ ។

## ៨ – ខណបរិត្តតោ

( ជីវិតមានខណៈតិច )

បទថា **ខណបរិត្តតោ** មានន័យថា ពោលដោយបរមត្ថ ខណៈនៃជីវិតរបស់សត្វទាំងឡាយខ្លីបំផុត ត្រឹមតែរយៈនៃការប្រព្រឹត្តនៃចិត្ត ១ ដួង ប៉ុណ្ណោះឯង ឧបមាដូចកង់រថ កាលវិលទៅ ក៏វិលទៅដោយដុំដែលជាផ្នែកមួយនៃកង់ កាលឈប់ ក៏

ឈប់ដោយដុំដែលជាផ្នែកមួយនៃកង់ដែរ យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏ជាវត្ថុដែលប្រព្រឹត្តទៅដោយខណៈចិត្ត ១ ក៏ដូច្នោះ ដូចគ្នា ពេលចិត្តដួងនោះរលត់ទៅ សត្វក៏ឈ្មោះថា រលត់ ( ស្លាប់ ) ដូចព្រះបាលីថា ក្នុងខណៈចិត្តជាអតីត សត្វឈ្មោះថា កើតហើយ មិនមែនកំពុងកើត មិនមែននឹងកើត , ក្នុងខណៈចិត្តដែលជាអនាគត សត្វមិនមែនបានកើតហើយ មិនមែនកំពុងកើត ( តែ ) នឹងកើត , ក្នុងខណៈចិត្តដែលជាបច្ចុប្បន្ន សត្វក៏មិនមែនបានកើតហើយ (តែ) ឈ្មោះថា កំពុងកើត មិនឈ្មោះថា នឹងកើត ។

ជីវិត អត្តភាព និង សុខទុក្ខ ទាំងមូលរស់នៅដោយចិត្តដួង១ ខណៈ ( នៃជីវិតជាដើមនោះ ) រមែងប្រព្រឹត្តទៅយ៉ាងរហ័ស ខន្ធទាំងឡាយណារបស់បុគ្គលដែលស្លាប់ហើយ ឬ របស់បុគ្គលដែលរស់នៅក្នុងបវត្តិកាលក៏ដោយ ដែលរលត់ហើយ ខន្ធទាំងឡាយទាំងពួងនោះ ក៏ដូចគ្នា គឺ រលត់ទៅដោយមិនជាប់តគ្នា , **លោក** ( គឺ សត្វ ) **មិនកើត** ព្រោះចិត្តមិនកើត , ឈ្មោះថា **កើត** ព្រោះចិត្តកើតឡើង ឈ្មោះថា **ស្លាប់** ព្រោះ **ចិត្តរលត់** នេះបញ្ញត្តិ តាមរយៈបរមត្ថ ។

## មរណស្សតិជ្ឈាន

កាលព្រះយោគាវចរ រឭកដោយអាការទាំង ៨ នេះ យ៉ាងណាមួយ ដូច្នេះដោយអំណាចការធ្វើទុកក្នុងចិត្តរឿយ ៗ ចិត្តរមែងបានអាសេវនា សតិមានសេចក្ដីស្លាប់ជាអារម្មណ៍ រមែងតាំងមាំ នីវរណធម៌ទាំងឡាយក៏ស្ងប់រម្ងាប់ទៅ អង្គឈានទាំងឡាយក៏ប្រាកដឡើង ព្រោះអារម្មណ៍នៃ ( ឈាននេះ ) ជាសភាវធម៌ និងព្រោះអារម្មណ៍នេះ ជាទីតាំងនៃសេចក្ដីសង្វេគ ឈាននេះ ទើបជាឈានមិនដល់

អប្បនា ដល់ត្រឹមឧបចារប៉ុណ្ណោះ ។ ចំណែកលោកុត្តរជ្ឈាន និងអរូបជ្ឈានទី ២ ទី ៤ ដល់អប្បនាបាន សូម្បីក្នុងសភាវធម៌ ព្រោះជាភាវនាពិសេស , ពិតហើយ លោកុត្តរជ្ឈានដល់អប្បនាបានដោយអំណាច ( ការប្រព្រឹត្តទៅតាម ) លំដាប់នៃ វិសុទ្ធិភាវនា , អរូបជ្ឈានដល់អប្បនាបាន ព្រោះជាភាវនាដែលឈានកន្លងអារម្មណ៍ ព្រោះក្នុងអរូបជ្ឈាននោះ មានតែការឈានកន្លងអារម្មណ៍នៃឈានដែលដល់អប្បនា ហើយប៉ុណ្ណោះ តែក្នុងមរណស្សតិនេះ ( វិសុទ្ធិភាវនានុក្រម និង អារម្មណសមតិក្កមៈ ) ទាំង ២ នោះមិនមាន ព្រោះដូច្នោះ ទើបជាឈានដល់ត្រឹមឧបចារ ឈាន នេះ ក៏ហៅថា **មរណស្សតិ** ព្រោះកើតឡើងដោយកំលាំងនៃការរលឹកដល់សេចក្ដី ស្លាប់ ។

## អានិសង្សនៃការចម្រើនមរណស្សតិ

ភិក្ខុដែលប្រកបរឿយៗ នូវមរណស្សតិនេះ រមែងជាអ្នកមិនប្រមាទជានិច្ច បានអនភិរតិសញ្ញា ( ការសម្គាល់ថា មិនគួរឲ្យរីករាយ ) ក្នុងភពទាំងពួង លះបង់ សេចក្ដីត្រេកអរក្នុងជីវិត ជាអ្នកតិះដៀលបាប មិនច្រើនទៅដោយការសន្សំ ប្រាស ចាកមន្ទិល គឺ សេចក្ដីកំណាញ់ក្នុងបរិក្ខារទាំងឡាយ លោកក៏ដល់នូវការជំនាញ ក្នុងអនិច្ចសញ្ញា ម្យ៉ាងទៀត ទុក្ខសញ្ញា និង អនត្តសញ្ញា ក៏ប្រាកដទៅតាមគន្លងនៃ អនិច្ចសញ្ញានោះដែរ សត្វទាំងឡាយដែលមិនបានអប់រំរឿងស្លាប់ ពេលស្លាប់រមែង ដល់នូវការតក់ស្លុត ភ័យខ្លាច វង្វេង ដូចបុគ្គលត្រូវសត្វសាហាវ យក្ស ពស់ ចោរ និងអ្នកសម្លាប់មនុស្ស វាយប្រហារ ( ភ្លាមៗ ) យ៉ាងណា លោកក៏មិនដល់នូវ សភាពដូច្នោះ ជាអ្នកមិនខ្លាច មិនវង្វេង ក្នុងការធ្វើកាលកិរិយា បើនៅមិនទាន់បាន

សម្រេចនូវអមតៈក្នុងទិដ្ឋធម៌ កាលកាយបែកធ្លាយហើយ រមែងជាអ្នកមានសុគតិជាទីប្រព្រឹត្តទៅខាងមុខ ព្រោះហេតុនោះ **អ្នកមានបញ្ញាល្អ គប្បីធ្វើសេចក្ដីមិនប្រមាទក្នុងមរណស្សតិ ដែលមានអានុភាពច្រើនយ៉ាងនេះ គ្រប់ពេលចុះ ។**

នេះជាកថាមុខ ដោយពិស្ដារក្នុងមរណស្សតិនេះ ។

## មហាដីកា

## អធិប្បាយ មរណស្សតិ

ពាក្យថា **បន្ទាប់ពីអនុស្សតិ៦នេះ** គឺ បន្ទាប់ពីទេវតានុស្សតិ , ព្រោះក្នុងបណ្ដាអនុស្សតិ ៦ ទេវតានុស្សតិនេះ នៅចុងក្រោយ និងឃើញបានប្រចក្ស ព្រោះលោកសម្ដែងទុកចុងក្រោយគេ ។ ពាក្យថា **បន្ទាប់ពី** លោកពោលទុក ព្រោះលោកលើកមរណស្សតិឡើងសម្ដែង ក្នុងលំដាប់នៃទេវតានុស្សតិនោះ ។ ការរឭកដល់សេចក្ដីស្លាប់ ឈ្មោះថា **មរណស្សតិ** ព្រោះហេតុនោះ លោកអាចារ្យបំណាងសម្ដែងមរណៈមុន ទើបពោលថា “ ក្នុងពាក្យថា **មរណស្សតិនោះ** ឈ្មោះថា **មរណៈ** ” ដូច្នេះជាដើម ។ ក្នុងពាក្យថា **មរណៈនេះ** គួរនឹងពោលថា ការបែកធ្លាយនៃខន្ធទាំងឡាយ គឺ ការឃ្លាត ការវិនាសទៅនៃខន្ធទាំងឡាយ ឈ្មោះថា **មរណៈ** ព្រោះមានព្រះពុទ្ធវចនៈថា **ជរា មរណំ ទ្វីហិ ខន្ធេហិ សង្គហិតំ** ប្រែថា ជរានិងមរណៈសង្គ្រោះដោយខន្ធ ២ ក៏ពិតហើយ , សូម្បីដូច្នោះ ដោយពិសេសមរណៈនោះនឹងប្រាកដដល់ព្រះយោគីដែលបំពេញកម្មដ្ឋាន ដោយការវិនាសទៅនៃជីវិតិន្ទ្រិយ ព្រោះហេតុនោះ លោកទើបពោលថា បានដល់ **ការដាច់នៃជីវិតិន្ទ្រិយ** ។

ព្រោះហេតុនោះឯង ក្នុងពាក្យនិទ្ទេស ទើបទ្រង់ត្រាស់ថា ការដាក់ចុះសាកសព

ការដាច់នៃជីវិតិន្ទ្រិយ ( ឈ្មោះថា មរណៈ ) ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ទាក់ទងក្នុងភព ១** គឺ កំណត់ទុកដោយភព ១ ។ ពាក្យថា **ការដាច់នៃជីវិតិន្ទ្រិយ** គឺ ការដាច់ខ្សែនៃការបន្តគ្នារបស់ជីវិតិន្ទ្រិយ បានដល់ ការសូន្យទៅ ទាក់ទងនឹងការអស់អាយុជាដើម ។ ពាក្យថា **សមុច្ឆេទមរណ** បានដល់ ការស្លាប់ដោយដាច់ខាតដោយប្រការទាំងពួងនៃវដ្តទុក្ខសន្តានរបស់ព្រះអរហន្ត ។ ពាក្យថា **បានដល់ ការរលត់ក្នុងខណៈៗនៃសង្ខារទាំងឡាយ** គឺ ការដល់នូវការរាប់ថាជាកង្គៈ គឺ ការរលត់ទៅនៃខណៈដែលប្រព្រឹត្តទៅ ដែលកំណត់ទុកដោយការកើតឡើង និង ការរលត់ទៅនៃសង្ខតធម៌ទាំងឡាយ ។ ពាក្យថា **ខណិកមរណ** បានដល់ សេចក្តីស្លាប់ជាខណៈតាម ដែលពោលហើយ ដែលនឹងមាននៅក្នុងខណៈនោះឯង ។ បញ្ញត្តិថា ដើមឈើជាដើម អាស្រ័យការបន្តគ្នានៃវដ្តទុក្ខយ៉ាងណា , កាលការបន្តគ្នានៃវដ្តទុក្ខនោះនៅមិនទាន់ដាច់ **វោហារ** ថា **ស្លាប់** ព្រោះអាស្រ័យការដល់ទីបំផុតហើយជាដើម ឈ្មោះថា **សម្មតិមរណ** ។ ពាក្យថា **សមុច្ឆេទមរណៈជាដើមនោះ មិនបានបំណងយកក្នុងទីនេះ** គឺ **សមុច្ឆេទមរណ ខណិកមរណ** និង **សម្មតិមរណ** មិនបានបំណងយកក្នុងមរណស្សតិនេះ អធិប្បាយថា ព្រោះ **សមុច្ឆេទមរណ** មិនមានច្រើន ( គឺ មានចំពោះតែព្រះអរហន្ត ) , **ខណិកមរណ** មិនប្រាកដច្បាស់ , **សម្មតិមរណ** មិនបានជាទីតាំងនៃសេចក្តីសង្វេគ ។

ពាក្យថា **មរណៈដែលបំណងយក** គឺ មរណៈដែលបំណងយកដោយភាពជាអារម្មណ៍នៃសតិ ។ សេចក្តីស្លាប់ក្នុងកាលដែលអាយុជាដើមអស់ទៅ ឈ្មោះថា **កាលមរណ** ។ សេចក្តីស្លាប់ក្នុងកាលដែលអាយុជាដើម នៅមិនទាន់អស់ ឈ្មោះថា **អកាលមរណ** ។ ពាក្យថា **កាលមរណៈរមែងមានព្រោះអស់បុណ្យ** គឺ លោក

ពោលដោយទាក់ទងតាមគតិសម្បត្តិ តាមសមគួរដល់បុញ្ញាធិការ , តែបើទាក់ទងដល់គតិវិបត្តិ ក៏គួរពោលថា **រមែងមានព្រោះអស់បាប** ។

ពាក្យថា **ការដល់ព្រមនៃបច្ច័យដែលធ្វើអាយុឲ្យបន្តទៅ** គឺ ការដល់ព្រមនៃបច្ច័យ មានអាហារជាដើម ដែលធ្វើឲ្យអាយុប្រព្រឹត្តទៅបាន ។ ពាក្យថា **ព្រោះកម្មមានវិបាកទុំហើយ** គឺ ព្រោះឲ្យវិបាកតាមសមគួរដល់កម្លាំងរបស់ខ្លួនហើយ ។ ពាក្យថា **ព្រោះមិនមានការដល់ព្រមនៃគតិ កាល អាហារជាដើម** គឺ ព្រោះមិនមានគតិសម្បត្តិ ដូចគតិសម្បត្តិរបស់ពួកទេវតាទាំងឡាយ , ព្រោះមិនមានកាលសម្បត្តិ ដូចកាលសម្បត្តិរបស់មនុស្ស ដែលរស់នៅក្នុងបឋមកប្ប និងព្រោះមិនមានអាហារសម្បត្តិ ដូចអាហារសម្បត្តិរបស់មនុស្សឧត្តរកុរុទ្វីបជាដើម ។ ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) លោកកំណត់យក ឧតុ ទឹកសុក្កៈ និង ឈាមជាដើម ។

**វិយ** ស័ព្ទ ក្នុងពាក្យថា **អជ្ជតនកាលបុរិសានំ វិយ** តាំងនៅខុសទី , បានសេចក្ដីថា ដោយអំណាចការអស់អាយុ ដូចអាយុដែលមានប្រមាណ ខ្ទង់ ១០០ ឆ្នាំ របស់មនុស្សក្នុងកាលសព្វថ្ងៃនេះ ។ ព្រោះថា កាលមានការប្រកបសេចក្ដីយ៉ាងនេះ ជាការបានធ្វើការសង្គ្រោះអាយុ ដែលមានតិចតួច សូម្បីក្នុងអនាគត , ចំណែកក្នុងអតីត ព្រោះមានការដល់ព្រមនៃកាល អាហារជាដើម ដូចគ្នានឹងការដល់ព្រមនៃគតិ អាយុទើបមានប្រមាណច្រើនពាន់ឆ្នាំ ។ បណ្ឌិតគប្បីឃើញថា ការចែកបែបនេះ ពោលទុកទាក់ទងនឹងអន្តរកប្ប ដែលកំពុងប្រព្រឹត្តទៅ ( អន្តរកប្បបច្ចុប្បន្ននេះ ) ។ ពាក្យថា **ព្រះបាទកលាពុជាដើម** ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) គប្បីជ្រាបដោយការសង្គ្រោះយកបុគ្គលទាំងឡាយ មាននន្ទយក្ស នន្ទមាណពជាដើម ។ ពាក្យថា **មរណៈនោះ ទាំងអស់** គឺ មរណៈដែលមាន

ប្រភេទដូចពោលហើយថា **កាលមរណ អកាលមរណ** ក្នុងមរណៈទាំងពីរនោះ ជាមរណៈព្រោះអស់បុណ្យ មរណៈព្រោះអស់អាយុ មរណៈព្រោះអស់ទាំងពីរយ៉ាង មរណៈព្រោះសេចក្តីព្យាយាម យ៉ាងណា បានដល់ មរណៈនោះ ទាំងអស់ ។

បទថា **យោនិសោ** បានដល់ ដោយត្រូវឧបាយ ។ បទថា **មនសិការេ** បានដល់ ការធ្វើទុកក្នុងចិត្ត ដែលមានសេចក្តីស្លាប់ជាអារម្មណ៍ ។ ព្រះយោគាវចរគប្បីធ្វើមនសិការឲ្យប្រព្រឹត្តទៅដោយឧបាយណា ដើម្បីសម្តែងឧបាយនោះ ដោយមាតិកាន័យផ្ទុយគ្នា លោកអាចារ្យទើបពោលថា **កាលធ្វើមនសិការឲ្យប្រព្រឹត្តទៅដោយមិនត្រូវឧបាយ** ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **កាលធ្វើមនសិការឲ្យប្រព្រឹត្តទៅដោយមិនត្រូវឧបាយ** គឺ ពេលរឭកដល់សេចក្តីស្លាប់ក្នុងន័យដែលមិនត្រូវឧបាយ គឺ មិនចូលទៅតម្កល់ សតិ សង្វេគ និងញាណ ។ ពាក្យថា សេចក្តីសោកជាដើម ទាំងអស់ គឺ ការធ្វើសេចក្តីសោក និងការរីករាយចិត្តឲ្យកើតឡើង , ការមិនធ្វើសង្វេគឲ្យកើតឡើង និងការធ្វើសេចក្តីតក់ស្លុតឲ្យកើតឡើង រមែងមានដល់បុគ្គលដែលប្រាសចាកសតិ សង្វេគ និងញាណ តាមលំដាប់ ។ ពិតហើយ បុគ្គលណារឭកដល់ពាក្យរបស់បណ្ឌិតថា " **សេចក្តីស្លាប់នេះ ជារបស់មានប្រាកដសម្រាប់បុគ្គលដែលកើតឡើងមកហើយ** " រមែងជាអ្នកមានសេចក្តីសង្វេគ និងសម្បជញ្ញៈ ដោយសារពាក្យរបស់បណ្ឌិតនោះ , ទោសទាំងឡាយ មានសេចក្តីសោកជាដើម ព្រោះហេតុនៃសេចក្តីស្លាប់របស់ជនជាទីស្រឡាញ់ជាដើម គ្មានឱកាសសម្រាប់បុគ្គលនោះឡើយ ។ ពាក្យថា **ព្រោះដូច្នោះ** មានន័យថា ព្រោះកាលធ្វើមនសិការឲ្យប្រព្រឹត្តទៅមិនត្រូវឧបាយ ទើបមានទោសទាំងនេះ ។ ពាក្យថា **ក្នុងទីកន្លែងនោះៗ** គឺ ក្នុងស្ថានទីទាំងឡាយ មានព្រៃ និង ព្រៃខ្មោចជាដើម ។ ពាក្យថា

**សត្វត្រូវសម្លាប់ និងស្លាប់ដោយខ្លួនឯង** គឺ សត្វទាំងឡាយដែលត្រូវចោរជាដើម សម្លាប់ និង អ្នកដែលស្លាប់តាមសភាពរបស់ខ្លួន ។ សត្វទាំងឡាយណា មាន សម្បត្តិ ដែលខ្លួនធ្លាប់ឃើញ សត្វទាំងឡាយនោះ ឈ្មោះថា **ទិដ្ឋបុព្វសម្បត្តី** បាន ដល់ របស់សត្វទាំងឡាយអ្នកមានសម្បត្តិ ដែលខ្លួនធ្លាប់បានឃើញ ទាំងនោះ ។ ពាក្យថា **ប្រកប** ( សតិ សង្វេគ ញាណ ) គឺ ចូលទៅតម្កល់ទុក ។ ពាក្យថា **សម្រាប់ព្រះយោគាវចររូបខ្លះ** គឺ សម្រាប់ព្រះយោគាវចរដែលមានឥន្ទ្រិយចាស់ក្លា និងក្រាស់ដោយញាណ ។

ពាក្យថា **ដោយការចូលទៅចំពោះមុខ ដូចនាយពេជ្ឈឃាត** គឺ ដោយការចូល ទៅប្រាកដចំពោះមុខ ដូចអ្នកសម្លាប់ គឺ មាននៅជិត ។ ពាក្យថា **ដោយការវិបត្តិ នៃសម្បត្តិ** គឺ ដោយការវិនាសនៃសម្បត្តិ គឺ ជីវិត ដូចគ្មានឹងសម្បត្តិទាំងឡាយ មានការមិនមានរោគជាដើម ។ ពាក្យថា **ដោយការប្រៀបធៀប** គឺ ដោយការអាង លើសេចក្តីស្លាប់របស់អ្នកដទៃ ប្រៀបធៀបជាមួយនឹងសេចក្តីស្លាប់របស់ខ្លួន ។

បទថា **កាយពហុសាធារណតោ** ប្រែថា រាងកាយជារបស់សាធារណៈ ដល់សត្វ និងបច្ច័យនៃសេចក្តីស្លាប់ច្រើនប្រការ ។ ពាក្យថា **អាយុជារបស់ទុព្វល** គឺ ជីវិតជារបស់មានកម្លាំងខ្សោយ ។ ពាក្យថា **ជាវត្ថុគ្មាននិមិត្ត** គឺ សេចក្តីស្លាប់ មិនមាននិមិត្ត ដែលអាចនឹងកំណត់បាន ។ ពាក្យថា **មានកាលកំណត់** គឺ ដោយ កាល មានការកំណត់ទុកហើយ ។ ពាក្យថា **ជីវិតមានខណៈខ្លី** គឺ ភាវៈដែលជា ខណៈនៃជីវិតមានតិចតួច ។

លោកអាចារ្យកាលនឹងសម្តែងថា **វិយ** សព្ទ ( ប្រែថា ដូច ) ក្នុងបទថា **វធកបច្ចុបដ្ឋានតោ** នេះ ជាសព្ទដែលបានសម្តែងអធិប្បាយហើយ លុបចេញ ទើប

ពោលថា **ដោយការចូលទៅប្រាកដចំពោះមុខ ដូចនាយពេជ្ឈឃាត** , កាលនឹងបើកផ្ទារខ្ទឹមសារនោះ ទើបពោលថា **យថា ហិ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **ហរាយមានោ** ប្រែថា ដាក់ផ្គឹបទឹងក គឺ ធ្វើអាការប្រហារ ។ ឈ្មោះថា **ចូលទៅឈរប្រាកដចំពោះមុខ** គឺ ចូលទៅឈរនៅក្នុងទីជិត ។ ពាក្យថា **សត្វទាំងឡាយពេលកើតឡើង ក៏នាំយកជរា និងមរណៈមកផងដែរ** មានន័យថា ឧបមាមានហើយ ដោយអត្ថត្រឹមប៉ុណ្ណេះថា ប្រៀបដូចផ្សិតដុះឡើង នឹងវៀរចាកធូលី មិនមាន យ៉ាងណា សត្វទាំងឡាយដែលកើតឡើងហើយ នឹងផុតចាកជរានិងមរណៈក៏មិនមាន ដូច្នោះដែរ ។ ផ្សិតគង់ជាវត្ថុដែលមិនជាប់ធូលីបានក្នុងកាលខ្លះ ក្នុងស្ថានទីខ្លះ , តែថា សត្វទាំងឡាយ មិនជាអ្នកផុតចាកជរា និង មរណៈឡើយ ។ ដើម្បីនឹងសម្តែងខណិកមរណៈជាឧបមាសិន ហើយទើបសម្តែងមរណៈដែលបំណងយកក្នុងទីនេះ លោកអាចារ្យទើបពោលថា **តថា ហិ** ដូច្នេះជាដើម ។

ម្យ៉ាងទៀត លោកអាចារ្យសំដៅយកពាក្យសួរថា បើសត្វទាំងឡាយនេះកើតឡើងហើយ កាន់យកជរានិងមរណៈមកផងដែរ គេគួរតែស្លាប់បន្ទាប់ពីការកើតនេះឯង ដូច្នេះ ទើបពោលថា **តថា ហិ** ជាដើម ។ សេចក្តីថា **ឯវស្សំ មរណតោ** ប្រែថា ព្រោះបុគ្គលដែលកើតឡើងហើយត្រូវស្លាប់ជាប្រាកដ , ឬប្រែថា ព្រោះបុគ្គលដែលកើតឡើងមកហើយ មានសេចក្តីស្លាប់ជាសភាវៈ យ៉ាងប្រាកដ ។

បទថា **បព្វតេយ្យា** ប្រែថា ចុះពីភ្នំ ។ បទថា **ហារហារិនី** គឺ មានប្រក្រតីហូរនាំទៅទាំងអស់ នូវវត្ថុដែលគប្បីនាំទៅបាន មានស្មៅ ស្លឹកឈើជាដើម ដែលជ្រុះទៅក្នុងក្រសែទឹក ។ បទថា **សន្ទតេវ** ប្រែថា ហូរទៅហើយ ។ ពាក្យថា **ធ្លោះទៅហើយ** គឺ ធ្លោះទៅហើយ មិនឈប់ ព្រោះជាក្រសែទឹក ។

បទថា **យាមេករត្តិំ** ប្រែថា ក្នុងរាត្រីមួយ គប្បីឃើញថាជា ទុតិយាវិកត្តិក្នុង អត្ថនៃសត្តមីវិភត្តិ , ឬ ក្នុងអត្ថនៃអច្ចន្តសំយោគៈ ( គឺ ប្រែថា អស់ ១ រាត្រីក៏បាន ) ។ ពាក្យថា **ជាគ្រាដំបូង** គឺ មុន បានដល់ ក្នុងបដិសន្ធិខណៈ ។ ពាក្យថា **ក្នុងគភ៌** គឺ ក្នុងផ្ទៃមាតា ។ បទថា **មាណវោ** ប្រែថា សត្វ ។ សត្វទាំងឡាយ ដោយច្រើនកាន់យកបដិសន្ធិក្នុងពេលរាត្រី ព្រោះហេតុនោះ លោកទើបប្រើស័ព្ទថា **រាត្រី** ។ បទថា **អព្ភុដ្ឋិតោវ** ប្រែថា ដូចក្បៀងដែលបង្អុរឡើង ឬមានអធិប្បាយថា ក្បៀងធ្លាក់ , ដោយភាវៈបែរមុខឆ្ពោះទៅរកសេចក្ដីស្លាប់តែម្យ៉ាង ។ សេចក្ដីថា **សោ យាតិ** មានន័យថា សត្វនោះកើតឡើង បែរមុខទៅ គឺ ទៅតែម្យ៉ាង តាំងពីខណៈដំបូង ។ ពាក្យថា **គេ កាលទៅក៏មិនត្រឡប់** មានន័យថា សត្វនោះកាលទៅយ៉ាងនេះ រមែងមិនវិលត្រឡប់សូម្បីតែមួយខណៈឡើយ , គឺ រមែងចូលទៅរកសេចក្ដីស្លាប់នោះ យ៉ាងពិតប្រាកដ ។ ពាក្យថា **ជាទឹកតូច** គឺ ខ្សែទឹកដែលហូរចុះពីកំពូលភ្នំ ។ ពាក្យថា **ទងត្រូវរសអាបោជ្រាបចូលហើយក្នុងពេលព្រឹក** គឺ ត្រូវរសអាបោជ្រួតជ្រាបហើយក្នុងពេលព្រឹក មានសេចក្ដីថា ជាទងសើមព្រោះរសអាបោជ្រាបចូលទៅខាងក្នុង ដល់ថ្ងៃត្រង់ក៏ត្រូវកម្ដៅថ្ងៃ ហើយជ្រាបចូលដល់គល់ទងក្នុងពេលយប់ទៀត ក្នុងថ្ងៃមុន ។

បទថា **អច្ចយន្តិ** ប្រែថា រមែងកន្លងទៅ ។ បទថា **ឧបរុជ្ឈតិ** ប្រែថា រមែងរលត់ទៅ ។ **ឧទកំ** នោះឯងជា **ឱទកំ** ប្រែថា ទឹក ឬ បានដល់ **ឧទកោឈំ** ប្រែថា ប្រឡាយ ។ សេចក្ដីថា ព្រោះហេតុដែលថ្ងៃ និងយប់ រមែងកន្លងទៅ , ដូច្នោះ ជីវិតរមែងរលត់ទៅ , ព្រោះហេតុដែលជីវិតរលត់ទៅនោះ ដូច្នោះអាយុរបស់សត្វទាំងឡាយរមែងអស់ទៅ ។ ពាក្យថា **ភ័យព្រោះការជ្រុះ** មានន័យថា ភ័យកើតពី

ការជ្រុះ កាលអ្នកដែលជាម្ចាស់របស់ ប្រាថ្នានឹងកាត់ដើមឈើដើម្បីប្រកបការងារ ឬ ចូលទៅក្រោមដើម ។ ពាក្យថា **ឧគ្គមនំ បតិ** ស្មើនិង **ឧគ្គមននិមិត្តំ** ប្រែថា ស្ងួតហួតហែង ព្រោះព្រះអាទិត្យរះឡើង អធិប្បាយថា **អ្នកម្ដាយ** កុំហាមខ្ញុំក្នុងការបួសឡើយ ។

កាលនឹងសម្ដែងថា សត្រូវមានមុខដូចជាមិត្តពួកខ្លះ ដែលស្វែងរកឱកាសដើម្បីសម្លាប់ សូម្បីថា រស់នៅជាមួយគ្នា ក៏មិនអាចសម្លាប់បាន តែថា នាយពេជ្ឈឃាត ( សេចក្ដីស្លាប់ ) នេះ រមែងសម្លាប់បានយ៉ាងប្រាកដ ដូច្នេះ លោកអាចារ្យទើបពោលថា **ព្រោះមកព្រមជាមួយនឹងការកើត** ហើយទើបពោលថា **ព្រោះឆក់យកជីវិតទៅ** ។

បទថា នំ បានដល់ សម្បត្តិ ។ ពាក្យថា **អ្នកមានសុខ** គឺ អ្នកប្រកបព្រមដោយសេចក្ដីសុខព្រោះទ្រព្យសម្បត្តិ និងភាពជាធំ ដូចភាពជាធំនៃទេវតា ។ បទថា **ទេហពន្ធេន** ប្រែថា ខ្ញុម ។ ពាក្យថា **ព្រះបាទអសោក** គឺ ព្រះបាទអសោកមហារាជ ។ ពាក្យថា **ដល់ហើយនូវសេចក្ដីសោក** គឺ ដល់ហើយនូវការៈ ដែលគប្បីសោយសោក ។

ការៈ ដែលមិនមានរោគ គឺ មានរោគជាទីបំផុត , ភាពជាកំលោះក្រមុំ មានជរាជាទីបំផុត លោកនាំមកហើយដោយទាក់ទងជាឧទាហរណ៍ នៃការៈដែលជីវិតមានសេចក្ដីស្លាប់ជាទីផុត , ឬ ទាក់ទងនឹងការបែកបច្ច័យ ។ **លោក** នោះឯង ឈ្មោះថា **លោកសន្និវាស** ដូច **សត្វ** នោះឯង ឈ្មោះថា **សត្តាវាស** ដូច្នោះ , ម្យ៉ាងទៀត **ពួកសត្វ** ឈ្មោះថា លោកសន្និវាស ព្រោះទីដែលសត្វអាស្រ័យ ។ ឈ្មោះថា ត្រូវ ( ជាតិ ) ជាប់តាម ដូចត្រូវសត្រូវជាប់តាម ។ ត្រូវជរារួបរឹត ដូច

ត្រូវថ្នាំពិស ដ៏ពន្លឹកជ្រាបចូលទៅ ។ ឈ្មោះថា ត្រូវ ( ព្យាធិ ) គ្របសង្កត់ ក៏ដូចជាដីរសង្កត់ ពីលើ រួបរឹតយកទៅ ។ ឈ្មោះថា ត្រូវ ( មរណៈ ) កម្ចាត់ដូចជាត្រូវកូតទាំងឡាយប្រទូសរ៉ាយ ។

ពាក្យថា **ភ្នំថ្ម** គឺ ភ្នំដែលសម្រេចដោយថ្ម មិនមែនសម្រេចដោយលំអងដីជាដើម ។ បទថា **វិបុលា** ប្រែថា ធំ គឺ វែង និងទទឹងច្រើនយោជន៍ ។ ពាក្យថា **ខ្ពស់សន្ធឹម** គឺ ព្រោះធំនោះឯង ទើបខ្ពស់សន្ធឹម លាតសន្ធឹងទៅកាន់ទិសទាំងពួង ។ បទថា **អនុបរិយេយ្យុំ** ប្រែថា រមៀលមក ។ ពាក្យថា **កិនកម្ទេច** គឺ ប្រើខ្ទេចវានោះឯង ធ្វើឲ្យខ្ទេចជាផង់ធូលី ។ ពាក្យថា **រមែងរួបរឹត** គឺ រមែងគ្របសង្កត់ ។ ក្នុងបណ្តាបុគ្គលជាន់ខ្ពស់ មានក្សត្រជាដើម ឈ្មោះថា មិនលើកលែងសូម្បីតែម្នាក់ ដោយការលើកលែងថា គេជាបុគ្គលប្រសើរដោយជាតិត្រកូលខ្លះ ដោយរូបខ្លះ ដោយសីលខ្លះ ដោយសុតៈខ្លះ ដោយធម៌ មានសទ្ធាជាដើមខ្លះ ។ ក្នុងបណ្តាបុគ្គលថ្នាក់ទាប មានពួកសូទ្រៈជាដើម ឈ្មោះថា មិនលើកលែងសូម្បីតែម្នាក់ ដោយការមើលងាយថា គេថោកទាបជាងបុគ្គលជាន់ខ្ពស់ទាំងនោះ រមែងកិនកម្ទេច គឺ ញាំញីគ្រប់គ្នា តែម្នាក់ ក៏មិនសល់ ។

លោកអាចារ្យបំណានសម្តែងថា ក្នុងជរានិងមរណៈនោះ ឧបាយយកឈ្នះសត្រូវទាំងឡាយ មានការវាយលុកជាដើម មិនមែនជាវិស័យឡើយ ដូច្នេះ ទើបពោលថា ក្នុងជរានិងមរណៈនោះ ( ជ័យ )ភូមិសម្រាប់ពលដំរីមិនមាន ជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **ដោយមន្តយុទ្ធ** គឺ ដោយវិធីវេទអាថ៌កំបាំង បានដល់ ការធ្វើសង្គ្រាមដោយមន្ត ។ ពាក្យថា **ដោយទ្រព្យ** គឺ ដោយការឲ្យទ្រព្យ ។ **វា** សព្ទ ( ប្រែថា ឬ ) មានអត្ថថា កំណត់យកវិធីដែលមិនទាន់បានពោលផងដែរ ។

ដោយ វា ស័ព្ទ នោះ លោករួមយក សាមវេទ ឫគវេទ និង យជុរវេទផង ។

ពាក្យថា **ដោយការប្រៀបខ្លួនជាមួយនឹងអ្នកដទៃៗ** គឺ ដោយការប្រៀបធៀបសេចក្ដីស្លាប់របស់ខ្លួនជាមួយនឹងអ្នកដទៃ ដែលស្លាប់ទៅហើយថា **អ្នកទាំងឡាយនោះ បានស្លាប់ទៅហើយ នឹងពោលថ្វីដល់បុគ្គលដូចជាយើង** ។ ពាក្យថា **ជាអ្នកមានយសធំ** គឺ ព្រោះជាអ្នកមានបរិវារច្រើន និងជាអ្នកមានទ្រព្យច្រើន ។ បទថា **បុញ្ញមហត្តតោ** ប្រែថា ជាអ្នកមានបុណ្យច្រើន ។ ពាក្យថា **ជាអ្នកមានកម្លាំងខ្លាំង-ក្លា** គឺ ជាអ្នកមានសេចក្ដីព្យាយាម និងកម្លាំងច្រើន ។ នាយយុទ្ធិដ្ឋិលៈ គឺ នាយធម្មបុត្ត ។ នាយហនុរៈ គឺ ជាអ្នកដែលត្រូវនាយពលទេពវាយឲ្យសន្ធប់ ហើយក៏ស្លាប់ទៅ ។ ពាក្យថា **ព្រមដោយឫទ្ធិទាំងឡាយ** គឺ ចូលទៅកាន់មាត់នៃមច្ចុ ព្រមជាមួយឫទ្ធិទាំងឡាយរបស់ខ្លួន ដែលមានអានុភាពប្រាកដហើយក្នុងកាលធ្វើវេជយន្តប្រាសាទឲ្យញ័រ ឬ ក្នុងកាលទូន្មាននន្ទោបនន្ទនាគរាជជាដើម ។

ពាក្យថា **មិនដល់នូវចំណែកទី ១៦** គឺ មិនដល់ចំណែកនៃចំណែកទី ១៦ , មានអធិប្បាយថា បែងបញ្ញារបស់ព្រះសារីបុត្តត្ថេរជា ១៦ ចំណែក បញ្ញារបស់សត្វដទៃ លើកលែងព្រះសម្មាសម្ពុទ្ធចេញ ឈ្មោះថា មិនបានដល់ចំណែកមួយដែលយកមកពីចំណែកទី ១៦ ហើយបែងជា ១៦ ចំណែកទៀត ។

ការកើចកន្ទ្រាក់នូវធម៌ដែលជាចំណែកនៃសង្កិលេសទាំងពួង រមែងមានដល់អ្នកដែលប្រារព្ធនូវសេចក្ដីព្យាយាមដោយញាណ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ដោយកម្លាំង គឺ ញាណ និង វីរិយៈ** ។ កាលសម្មាទិដ្ឋិ និងសម្មា-វាយាមៈសម្រេចហើយ ព្រះអរិយមគ្គមានអង្គ ៨ ក៏សម្រេចហើយដូចគ្នា ។ ឈ្មោះថា **ប្រៀបដូចកុយរមាស** ព្រោះជាអ្នកនៅម្នាក់ឯង ។ ឈ្មោះថា **សយម្ភូ** ព្រោះអត្ត

ថា កើត គឺ ចាក់ធ្លុះធម៌ដែលមិនកម្រើក ( អរហត្តផល ) ដោយព្រះអង្គឯង មិនមានការប្រាប់ពីអ្នកដទៃ ។

ឈ្មោះថា **អាស្រ័យនិមិត្ត** គឺ ហេតុនោះៗ មានយ៉ាងនេះថា គឺ ការទន្ទិចគ្នានៃកងដៃមាស ភាវៈដែលទំពាំងឫស្សីនៅក្នុងទីណាៗ ក៏មិនមែនជាសត្វ ដូច្នេះជាដើម ។ ពាក្យថា **ពិចារណា** គឺ ត្រិះរិះដល់ការប្រព្រឹត្តទៅ និងការឈប់នៅ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ឈ្មោះថា **មហេសី** - អ្នកស្វែងរកនូវគុណដ៏ធំ ដោយន័យថា ស្វែងរកនូវគុណ មានសីលក្ខន្ធជាដើម ដ៏ធំ ។ ពាក្យថា **ដោយការត្រាច់ទៅ និង ស្នាក់នៅតែមួយអង្គឯង** គឺ ត្រាច់ទៅ និង នៅតែមួយអង្គឯង , មិនមែនដោយធម៌ មានសីលក្ខន្ធជាដើម ។ បុរសដែលមានឧបមាដូចកុយរមាស ឬថាមានកុយរមាសជាឧបមាស្មើគ្នា ឈ្មោះថា **ខគ្គសិង្គសមូបមា** ។

ឈ្មោះថា **ទ្រង់មានព្រះរូបកាយដែលវិចិត្រ...៨០ ប្រការ** ព្រោះអត្ថថា ទ្រង់មានព្រះរូបកាយជារបស់អស្ចារ្យ វិចិត្រដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការមាន ភាពដែលព្រះបាទទាំង ២ តាំងស៊ប់ ស្មើល្អជាដើម ដែលប្រដាប់ហើយដោយអនុព្យញ្ជនៈ ៨០ ប្រការ មានព្រះនខាក្រហម មានព្រះនខាវែងជាដើម ។ ឈ្មោះថា **ទ្រង់មានព្រះធម្មកាយ... ដោយអាការទាំងពួង** ព្រោះអត្ថថា ទ្រង់មានព្រះធម្មកាយដែលសម្រិតដោយគុណរតនៈ មានសីលក្ខន្ធជាដើម ដែលបរិសុទ្ធដោយប្រការទាំងពួង ព្រោះទ្រង់លះបង់កិលេសទាំងពួង ព្រមទាំងវាសនាបានហើយ ។

បទថា **ឃនសោ - ភ្លាម** គឺ ខណៈនោះឯង ។

ពាក្យថា **ទ្រង់មានព្រះអានុភាពច្រើនយ៉ាងនេះ** គឺ ទ្រង់មានព្រះអានុភាពច្រើនមិនអាចប្រមាណបាន ដែលបុគ្គលដឹងបាននូវព្រះរូបកាយសម្បត្តិ តាមដែលបាន

ពោលហើយ និង ព្រះធម្មកាយសម្បត្តិយ៉ាងនេះ , អធិប្បាយថា សេចក្តីស្លាប់ផ្សាយអំណាចទៅដល់ ក៏ដោយទាក់ទងនឹងការទៅដល់តាមសមគួរ ។

បុគ្គល ឈ្មោះថា **មរណសាមញ្ញ** ព្រោះអត្ថថា មានសេចក្តីស្លាប់ស្មើគ្នា , ភាវៈនៃមរណសាមញ្ញនោះ ឈ្មោះថា **មរណសាមញ្ញតា** - អ្នកមានសេចក្តីស្លាប់ស្មើគ្នា បានដល់ ភាពជាអ្នកមានសេចក្តីស្លាប់ស្មើគ្នានោះឯង ។

បទថា **កិមិកុលានំ** ប្រែថា ជារបស់សាធារណៈ ដល់ពួកដង្កូវ ឬ ដល់ពួកកិមិជាតិទាំងឡាយ ។ ពាក្យថា **ចាស់ - ជិយ្យន្តិ** គឺ ដល់ភាពគ្រាំគ្រា ។

បទថា **និក្ខន្តេ** ប្រែថា ( ពេលថ្ងៃត្រង់ ) កន្លងទៅ ។ បទថា **បដិហិតាយ** ស្មើគ្នានិង **បច្ចាទុគតាយ** ប្រែថា ចូលមក ។ ពាក្យថា **ខនេះចាត់ជាអន្តរាយសម្រាប់យើង** មានន័យថា កាលកិរិយាតាមដែលពោលហើយនោះ មិនមែនជាអន្តរាយតែម្យ៉ាងប៉ុណ្ណោះទេ តែថា អាចមាន គឺ មានអន្តរាយដល់យើងដែលជាអ្នកបានខណៈរកបានដោយកម្រ ( គឺ ការបានបព្វជ្ជាឧបសម្បទក្នុងព្រះពុទ្ធសាសនា ) ជាអ្នកបង្អោនចិត្តទៅក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ។ បទថា **ព្យាបជ្ជេយ្យ** ប្រែថា អាចដល់នូវសេចក្តីវិបត្តិ ។ ខ្យល់ដែលកាត់អវយវៈតូចធំទាំងឡាយ ដូចត្រូវបុគ្គលដែលមានសស្រ្តាចាក់ទម្លាយ គឺ ខ្យល់កាត់ផ្តាច់សរសៃ ក្នុងវេលាជិតស្លាប់ ឈ្មោះថា ខ្យល់សត្ថកៈ ។

បទថា **អពលំ** - គ្មានកម្លាំង គឺ អស់កម្លាំង ។ បទថា **ទុព្វលំ** - ទុព្វលក៏ជាវេវចនៈនឹងពាក្យថា **អពលំ** នោះឯង ។ ព្រោះថា ទុ ស័ព្ទ ( ក្នុងបទថា **ទុព្វលំ** នេះ ) មានអត្ថថា **គ្មាន** ដូចក្នុងពាក្យថា **ទុស្សីលោ** - មនុស្សគ្មានសីល **ទុប្បញ្ញោ** - មនុស្សគ្មានបញ្ញា ជាដើម ។ ឈ្មោះថា **តទេតំ** បានដល់ អាយុ ។

ឈ្មោះថា **ការប្រព្រឹត្តទៅស្មើគ្នានៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ** បានដល់ ការចូលទៅ និងការចេញមក ជាប់តគ្នានោះឯង ។ ពាក្យថា **ពេលខ្យល់ចេញតាមរន្ធច្រមុះទៅខាងក្រៅ ហើយមិនត្រឡប់ចូលមកខាងក្នុងវិញ ឬចូលទៅហើយ មិនចេញមកវិញ** លោកពោលសំដៅសេចក្ដីថា ខ្យល់ដង្ហើមតែមួយនោះឯង មានទាំងការចូល និងការចេញ , ពាក្យនោះ គប្បីឃើញថា លោកពោលទុកក្នុងន័យផ្សេងគ្នា តែក៏ជាខ្យល់តាមរន្ធច្រមុះដូចគ្នា ។ ឈ្មោះថា **ព្រោះឥរិយាបថយ៉ាងណាមួយលើសប្រមាណ** គឺ ព្រោះអង្គុយច្រើនហួស ឈរច្រើនហួសជាដើម ។ ការមិនមាននៃការអង្គុយច្រើនហួសជាដើមនោះ ឈ្មោះថា ការប្រព្រឹត្តទៅស្មើគ្នានៃឥរិយាបថទាំងឡាយ ។

សេចក្ដីវិបត្តិនៃរាងកាយ ដែលត្រូវភាពត្រជាក់ហួសគ្របសង្កត់ បណ្ឌិតគប្បីសម្ដែងបានតាមរដូវកាល ដែលមានព្រិលធ្លាក់ជាដើម នៅដែនមហិសៈជាដើម ។ ពិតហើយ សត្វទាំងឡាយនៅដែនមហិសៈជាដើមនោះ រាងកាយត្រូវភាពត្រជាក់ទម្លាយហើយ ក៏ដល់នូវការអស់ជីវិតទៅ ។ សេចក្ដីវិបត្តិនៃរាងកាយដែលក្ដៅហួសប្រមាណគ្របសង្កត់ បណ្ឌិតគប្បីសម្ដែងរឿងស្ត្រីឈរជាន់លើបន្ទិចខោអាវ និងបុត្តដែលដាក់លើបន្ទិច ហើយស្លាប់ទៅ ដោយកម្ដៅដុតរោល ក្នុងសមុទ្រខ្សាច់ ។

ឈ្មោះថា **ការប្រព្រឹត្តទៅស្មើគ្នានៃមហាភូតរូបទាំងឡាយ** បានដល់ ការមិនមានការកម្រើក ។ រឿងរាងកាយដល់នូវភាពពិការ ព្រោះការកម្រើកនៃបឋវីធាតុជាដើម នឹងមានមកដល់ក្នុងកថា ពោលដោយធាតុកម្មដ្ឋានខាងមុខ ។ ពាក្យថា **ក្នុងកាលគួរ** គឺ ក្នុងពេលដែលគួរនឹងបរិភោគ បានដល់ ក្នុងពេលដែលត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ។

ពាក្យថា **រកការកំណត់មិនបាន** គឺ មិនមានការកំណត់ដែលទាក់ទងនឹងពេលវេលាជាដើម ។ ក្នុងពាក្យថា **វវត្ថានំ** - កំណត់ នេះ លោកបំណងយកការចែកពេល មិនបានបំណងយកការកំណត់ដែលមិនលាយគ្នា ( គឺ កំណត់ផ្សេងៗ ដូចជាការកំណត់ធាតុ ៤ ) និងមិនបានបំណងយកការសម្រេចចិត្ត ព្រោះហេតុនោះទើបលោកពោលថា មិនមានការចែកពេល ដូច្នេះ ។ **បទថា ន នាយរេ** ប្រែថា ដឹងមិនបាន ។

ក្នុងពាក្យថា **ក្នុងកាលបន្ទាប់ពីនេះទៅ** មានអធិប្បាយថា បទថា **បរំ** បាន ដល់ ក្នុងកាលដទៃ គឺ ដទៃទៀត ។ បទថា **បរំ** នោះ ជាការសម្រេចការសង្គ្រោះយកទាំងកាលដែលតិចជាង ។ កាលដែលតិចជាងអាយុនោះ លោកបំណងយកក្នុងទីនេះថា **កាលដទៃ** ព្រោះសត្វទាំងឡាយមិនអាចរស់នៅបានយូរជាងនោះ ។ ពាក្យថា **ព្រោះមិនមានការកំណត់បាន** គឺ មិនអាចនឹងពោលបាន ។ ក្នុងពាក្យថា **អព្ទុទបេសិ** ជាដើម គប្បីប្រកប **កាល** ស័ព្ទ ចូលជាតែបទមួយ ក្នុងន័យថា **អព្ទុទកាលេ** - ក្នុងកាលជាអព្ទុទៈ , **បេសិកាលេ** - ក្នុងកាលជាបេសិ ជាដើម ។ បទថា **កាល** ក្នុងពាក្យថា សូម្បីកាលទាំងនោះ ក៏ជាវត្ថុគ្មាននិមិត្ត លោកបំណងយកពេលវេលា មានពេលព្រឹកជាដើម , ព្រោះហេតុនោះ លោកទើបពោលថា ពិតហើយ សត្វទាំងឡាយរមែងស្លាប់ក្នុងពេលព្រឹកក៏បាន ដូច្នេះជាដើម ។ ភ្ជាប់សេចក្តីថា **ឥធេវ ទេហេន បតិតព្វំ** - មានរាងកាយដាក់ចុះនៅទីនេះ ។

ពាក្យថា **ច្រើនប្រការ** គឺ ច្រើនប្រការ ក្នុងន័យថា អត្តភាពរបស់សត្វដែលកើតនៅក្នុងក្រុង បែរជាដាក់ចុះនៅជនបទ , អត្តភាពរបស់សត្វដែលកើតនៅជនបទបែរជាដាក់ចុះនៅក្នុងក្រុង , អត្តភាពរបស់សត្វដែលកើតនៅក្នុងព្រៃ បែរជាដាក់ចុះ

នៅជនបទ , អត្តភាពរបស់សត្វដែលកើតនៅជនបទ ែបរជាធ្លាក់ចុះនៅក្នុងព្រៃ ដូច្នេះជាដើម ។ បទថា **ឥតោ ចុតេន** ប្រែថា សត្វដែលឃ្លាតចាកពីគតិនេះ ។ **ឥធ** ស្មើនឹង **ឥមិស្សំ យោគ គតិយំ** ប្រែថា ក្នុងគតិនេះ ។ ពាក្យថា ដូចគោដែលគេចងនឹងបង្គោលស្នឹង ជាឧបមាដោយន័យត្រឹមប៉ុណ្ណេះថា គោដែលគេចងជាប់នឹងបង្គោលស្នឹង នឹងដើរផុតពីបង្គោលស្នឹងទៅមិនបាន យ៉ាងណា , សត្វលោក នឹងផុតពីគតិ ៥ ក៏មិនមាន ដូច្នោះដែរ ។

ពាក្យថា **ច្រើនជាង ឬ តិចជាង** មានន័យថា ឬរស់នៅបានច្រើនជាង ១០០ ឆ្នាំ ឬ តិចជាង មិនដល់ ១០០ ឆ្នាំ ទី២ ក្នុងន័យថា ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ជាដើម ។ បទថា **គមនីយោ** បានដល់ ត្រូវទៅដោយអំណាចនៃឧប្បត្តិ ។ បទថា **សម្បរាយនោ** គឺ លោកខាងមុខ ។ បទថា **ហីឡេយ្យ** ប្រែថា គប្បីមើលងាយ គឺ មិនលើកសរសើរ ។ បទថា **នំ** ប្រែថា អាយុនោះ ។ បទថា **សុបោរិសោ** ប្រែថា មនុស្សល្អ គឺ មនុស្សមានបញ្ញា ។ ពាក្យថា **គប្បីប្រព្រឹត្ត** គឺ គប្បីប្រព្រឹត្តសុចរិត ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ដូចមនុស្សដែលមានសីសៈត្រូវភ្លើងឆេះ ។

ពាក្យថា **ដោយឧបមា ៧** បានដល់ ប្រដាប់ដោយឧបមា ៧ យ៉ាង ដែលមកហើយ យ៉ាងនេះថា ៖

ម្នាលព្រាហ្មណ៍ ទឹកសន្សើមដែលជាប់នៅលើចុងស្មៅ កាលព្រះអាទិត្យរះឡើង រមែងហួតហែងទៅដោយរហ័ស តាំងនៅមិនបានយូរ យ៉ាងណា , ម្នាលព្រាហ្មណ៍ ជីវិតរបស់មនុស្សទាំងឡាយ ក៏មានឧបមាដូចដំណក់ទឹកសន្សើមដូចគ្នា ជារបស់តិចតួច រហ័ស មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន គប្បីពាល់

ត្រូវបានដោយបញ្ញា ទើបគួរធ្វើកុសល ប្រព្រឹត្តព្រហ្មចារ្យ បុគ្គលដែលកើតមក ហើយ មិនស្លាប់ មិនមានឡើយ ។

ម្នាលព្រាហ្មណ៍ ដំណក់ទឹកភ្លៀងដែលធ្លាក់មកហើយ ពពុះទឹកប៉ោងឡើង ហើយក៏បែកទៅវិញភ្លាម តាំងនៅមិនបានយូរ យ៉ាងណា , ម្នាលព្រាហ្មណ៍ ជីវិត របស់មនុស្សទាំងឡាយ ក៏មានឧបមាដូចពពុះទឹក ដូច្នោះដែរ ។ ល ។

ម្នាលព្រាហ្មណ៍ ស្នាមគំនូសឈើនៅលើផ្ទៃទឹក រមែងរលុបទៅដោយរហ័ស តាំងនៅមិនបានយូរ យ៉ាងណា , ម្នាលព្រាហ្មណ៍ ជីវិតរបស់មនុស្សទាំងឡាយ ក៏ មានឧបមាដូចគំនូសលើទឹក ដូច្នោះដែរ ។ ល ។

ម្នាលព្រាហ្មណ៍ ទឹកដែលហូរមកពីលើកំពូលភ្នំ មានក្រសែហូរត្របាញ់ ហូរ នាំយកនូវវត្ថុដែលអាចហូរនាំទៅបាន ខ្សែទឹកនោះ នឹងថា ឈប់មួយខណៈ មួយ គ្រា មួយភ្លែត មិនមានឡើយ ដោយពិត ខ្សែទឹកនោះ រមែងសំដៅទៅ ស្រុតទៅ តែម្យ៉ាង ហូរត្របាញ់ទៅតែម្យ៉ាង យ៉ាងណា , ម្នាលព្រាហ្មណ៍ ជីវិតរបស់មនុស្ស ទាំងឡាយ ក៏មានឧបមាដូចទឹកហូរធ្លាក់មកពីលើកំពូលភ្នំ ដូច្នោះដូចគ្នា ។ ល ។

ម្នាលព្រាហ្មណ៍ បុរសដែលមានកម្លាំង ប្រមូលទឹកមាត់ផ្ដុំនៅចុងអណ្ដាត ហើយ ក៏ស្ដោះចោលដោយមិនលំបាកឡើយ យ៉ាងណា , ម្នាលព្រាហ្មណ៍ ជីវិត របស់មនុស្សទាំងឡាយ ក៏មានឧបមាដូចដំណក់ទឹកមាត់ ដូច្នោះដូចគ្នា ។ ល ។

ម្នាលព្រាហ្មណ៍ បន្ទះសាច់ដែលគេទុកនៅលើបន្ទះដែកដ៏ក្ដៅ ដែលដុតរហូត ពេញមួយថ្ងៃ រមែងវិនាសទៅយ៉ាងរហ័ស តាំងនៅមិនបានយូរ យ៉ាងណា , ម្នាល ព្រាហ្មណ៍ ជីវិតរបស់មនុស្សទាំងឡាយ ក៏មានឧបមាដូចបន្ទះសាច់ដូច្នោះ ។ ល ។

ម្នាលព្រាហ្មណ៍ មេគោដែលត្រូវសម្លាប់ ដែលគេនាំទៅកាន់ទីពិឃាត រមែង

ឈានដើងចូលទៅជិតទីពិឃាត ជិតសេចក្តីស្លាប់ យ៉ាងណា , ម្នាលព្រាហ្មណ៍ ជីវិតរបស់មនុស្សទាំងឡាយ ក៏មានឧបមាដូចមេគោដែលត្រូវសម្លាប់ ដូច្នោះដូចគ្នា ជារបស់តិចតួច រហ័ស មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន គប្បីពាល់ត្រូវបានដោយបញ្ញា ទើបគួរធ្វើកុសល ប្រព្រឹត្តព្រហ្មចារ្យ បុគ្គលដែលកើតមកហើយ មិនស្លាប់ មិនមានឡើយ ។

បទថា **រត្តិន្ទិវំ** ប្រែថា ពេលយប់ និង ពេលថ្ងៃ ។ ពាក្យថា **ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ** គឺ ព្រះឱវាទរបស់ព្រះសាស្តា ជាហេតុនាំមកនូវការសម្រេចព្រះអរិយមគ្គ ។ ពាក្យថា **យើងបានធ្វើកិច្ចទុកច្រើនហើយហ្ន៎** គឺ យើងបានធ្វើកិច្ចរបស់បព្វជិត ដែលជាប្រយោជន៍ដល់ខ្លួនទុកច្រើនហើយហ្ន៎ ។ បទថា **តទន្តរំ** គឺ ខណៈនោះ បានដល់ វេលាត្រឹមប៉ុណ្ណោះ ( មានវេលាដែលបរិភោគបិណ្ឌបាតមួយពេលជាដើម ) ។ ពាក្យថា **បិណ្ឌបាតមួយពេល** គឺ ( ពេលដែលបរិភោគបិណ្ឌបាត ) ល្មមតែនឹងញុំាងជីវិតិន្ទ្រិយឲ្យរស់នៅបានមួយថ្ងៃ ។ បទថា **ទន្ធំ** ប្រែថា យូរ គឺ ដោយពេលយូរ ។ បទថា **អវិស្សាសិយោ** ប្រែថា មិនគួរដាក់ចិត្ត ។ កាលចិត្តនៅមានប៉ុណ្ណោះ សត្វទាំងឡាយបានវោហារថា រស់នៅ , ខណៈនៃចិត្តនេះមានតិចតួច ព្រោះប្រែប្រួលយ៉ាងរហ័ស , ដូចដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ តថាគត រកមើលមិនឃើញធម៌ យ៉ាងដទៃ សូម្បីតែមួយដែលប្រែប្រួលរហ័សដូចជាចិត្តនេះឡើយ ។**

ព្រោះដូច្នោះ លោកអាចារ្យកាលនឹងសម្តែងថា ជីវិតរបស់សត្វទាំងឡាយរហ័ស មានតិចតួច ព្រោះត្រឹមមួយខណៈចិត្ត ទើបពោលថា **ដោយបរមត្ថ** ដូច្នេះជាដើម ។

ក្នុងពាក្យទាំងឡាយនោះ មានសេចក្តីថា ការប្រព្រឹត្តទៅនៃជីវិតរបស់សត្វទាំងឡាយ ដែលទ្រង់ត្រាស់ទុកដោយន័យថា អ្នកដែលរស់នៅបានយូរ អ្នកនោះរមែងរស់នៅបានខ្ទង់ ១០០ ឆ្នាំ ដូច្នេះជាដើម , ការប្រព្រឹត្តទៅនៃជីវិតនោះ ទ្រង់ត្រាស់ទុកដោយអំណាចបញ្ញត្តិ ព្រោះមានការបន្តគ្នា( នៃខន្ធ )ជាវិស័យ ព្រោះហេតុនោះ លោកអាចារ្យ ទើបបដិសេធការប្រព្រឹត្តទៅនៃជីវិត ដោយពាក្យថា **ដោយបរមត្ថ** ដូច្នេះ ។ ដោយពាក្យថា **តិចតួច** នេះ លោកអាចារ្យបដិសេធខណៈតិចតួចមិនងាយស្ងួម្បីឧបមា ដែលទ្រង់ត្រាស់ទុកថា **ម្នាលភិក្ខុទាំងឡាយ នាយខ្មាន់ធ្នូដែលមានការសិក្សាស្ទាត់ជំនាញ បានសិក្សា មានដៃស្ទាត់ជំនាញក្នុងការបាញ់ធ្នូ ៤ នាក់ ឈរនៅផ្លូវទិសទាំង ៤ , លំដាប់នោះ មានបុរសម្នាក់មកពោលថា យើងអាចចាប់យកព្រួញ ដែលនាយខ្មាន់ធ្នូ ។ ល ។ ជំនាញក្នុងការបាញ់ធ្នូ ៤ នាក់ បាញ់មកហើយពីទិសទាំង ៤ មិនឲ្យធ្លាក់ដល់ដី ។ ល ។ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ កាពរហ័ស របស់បុរសនោះយ៉ាងណាក្តី កាពរហ័សរបស់ព្រះចន្ទ និងព្រះអាទិត្យយ៉ាងណាក្តី កាពរហ័សរបស់ទេវតាដែលស្ទុះទៅខាងមុខព្រះចន្ទ និងព្រះអាទិត្យ យ៉ាងណាក្តី អាយុសង្ខារ រមែងវិនាសទៅរហ័សជាងកាពរហ័សរបស់ទេវតាទាំងឡាយនោះ ។**

ពិតហើយ ក្នុងព្រះពុទ្ធវចនៈនោះ ទ្រង់ត្រាស់ដល់ខណៈនៃរូបជីវិតិន្ទ្រិយ មានតិច សូម្បីខ្សែដែលមុតដូចកាំបិតកោ ចងជាប់សីសៈ ឬ ជើងរបស់ពួកទេវបុត្តដែលជាអ្នកមានសេចក្តីត្រេកអរ ក្នុងការដើរផ្លូវ ឬ ស្ទុះទៅខាងមុខ ទៅទទឹង និងទៅលើ តែជាខណៈនៃចិត្តនៅតិចជាងណាស់ , ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ចិត្តនេះប្រែប្រួលរហ័សយ៉ាងណា , សូម្បីឧបមាក៏មិនអាចធ្វើបានងាយឡើយ ។

ពាក្យថា **ខណៈនៃជីវិត** គឺ ខណៈនៃការរស់នៅ ។ ឈ្មោះថា ត្រឹមតែខណៈប្រព្រឹត្តទៅនៃចិត្តមួយដួងប៉ុណ្ណោះ ព្រោះខណៈនៃការរស់នៅ ដោយបរមត្ថនៃសត្វទាំងឡាយកំណត់ទុក ត្រឹមតែការប្រព្រឹត្តទៅនៃចិត្តមួយដួងប៉ុណ្ណោះ ។

ឥឡូវនេះ លោកអាចារ្យកាលនឹងប្រកាសខ្លឹមសារនោះ ដោយឧបមា ទើបពោលថា **យថា នាម** ដូច្នេះជាដើម ។ ក្នុងបទទាំងឡាយនោះ បទថា **បវត្តមានំ** ប្រែថា កាលនឹងវិលទៅ ។ ពាក្យថា **មួយខណៈចិត្ត** គឺ មានត្រឹមមួយខណៈចិត្តៗ ពាក្យថា **កាលចិត្តដួងនោះរលត់ទៅហើយ** មានន័យថា សត្វបានរស់នៅហើយដោយខណៈចិត្តដួងណាប្រព្រឹត្តទៅ , សូម្បីចិត្តដួងនោះ ដល់នូវការរលត់ទៅហើយ គឺ បែកធ្លាយហើយ ក៏ពោលដល់សត្វដែលព្រមព្រៀងដោយខណៈចិត្តដួងនោះថា រលត់ហើយ គឺ ស្លាប់ហើយ ។ កាលនឹងបើកផ្លូវខ្លឹមសារដែលបានពោលហើយនោះឯង ដោយព្រះបាលី លោកអាចារ្យទើបពោលថា **ដូចដែលព្រះសារីបុត្តត្ថេរបានពោលទុក** ដូច្នេះជាដើម ។ ដោយពាក្យនោះ លោកសម្ដែងថា ឈ្មោះថា ការរស់នៅ ដោយបរមត្ថ របស់សត្វទាំងឡាយក្នុងកាលទាំង ៣ រមែងប្រព្រឹត្តទៅទាក់ទងនឹងខណៈចិត្តនោះឯង ។

ពាក្យថា **ជីវិត** បានដល់ ជីវិតិន្ទ្រិយ ។ ពាក្យថា **សុខនិងទុក្ខ** បានដល់ សុខវេទនា និងទុក្ខវេទនា តែថា សូម្បីឧបេក្ខាវេទនា ក៏ទាក់ទងនឹងសុខវេទនានិងទុក្ខវេទនានោះដែរ ព្រោះជាវេទនាដែលគួរប្រាថ្នានិងមិនគួរប្រាថ្នា ។ ពាក្យថា **អត្តភាព** លោកពោលដល់ធម៌ដ៏សេស លើកលែង ជីវិត វេទនា និង វិញ្ញាណ ។ ពាក្យថា **សុទ្ធ** គឺ មិនលាយជាមួយនឹងខ្លួន ឬថា មិនលាយជាមួយនឹងវត្ថុដែលទៀងជាដើម ។ ពាក្យថា **ប្រកបទុកក្នុងចិត្តដួងមួយ** គឺ ប្រព្រឹត្តទៅព្រមជាមួយចិត្តមួយ

ដួង ។ ពាក្យថា **ខណៈរមែងប្រព្រឹត្តទៅយ៉ាងរហ័ស** គឺ ខណៈនៃជីវិតជាដើម ដែលមានតិច រមែងប្រព្រឹត្តទៅយ៉ាងរហ័ស ព្រោះមានត្រឹមខណៈនៃចិត្តមួយដួង ដូចដែលបានពោលហើយ ។

ពាក្យថា **ខន្ធទាំងឡាយដែលរលត់ទៅហើយ របស់សត្វដែលស្លាប់ហើយ** មានន័យថា ខន្ធទាំងឡាយណាដែលអាចពោលបានថា **រលត់ទៅហើយ** បន្ទាប់ពីចុតិ របស់សត្វដែលចុតិ ។ ពាក្យថា **របស់សត្វដែលនៅរស់ក៏ដោយ ក្នុងបវត្តិ-កាលនេះ** គឺ ខន្ធដែលរលត់ទៅហើយ ព្រោះដល់នូវការបែកធ្លាយ របស់សត្វដែលនៅរស់ គឺ នៅប្រព្រឹត្តទៅក្នុងបវត្តិកាលនេះ ។ ពាក្យថា **ខន្ធទាំងឡាយនោះ ដូចគ្នាទាំងអស់** គឺ ខន្ធទាំងឡាយនោះទាំងអស់ ដូចគ្នាតែម្យ៉ាង ។ តើយ៉ាងណា ? គឺ ទៅហើយមិនត្រឡប់មកបន្តវិញ បានដល់ ទៅប្រាសហើយ ដោយមិនមានការវិលត្រឡប់មកបន្តវិញទៀត , អធិប្បាយថា ដូចជា ខន្ធទាំងឡាយដែលឃ្លាតចាកហើយ រមែងមិនវិលត្រឡប់ យ៉ាងណា , ខន្ធក្នុងកាលមុនៗ ក៏មិនវិលត្រឡប់មក ដូច្នោះដែរ , ព្រោះហេតុនោះ ជីវិតរបស់សត្វទាំងឡាយទើបមានត្រឹមមួយខណៈចិត្ត ។

ពាក្យថា **សត្វលោកមិនឈ្មោះថា កើត ក៏ព្រោះចិត្តមិនទាន់កើត** គឺ សត្វលោកមិនឈ្មោះថា ជាអ្នកកើតហើយ គឺ ជាអ្នកឈ្មោះថា មិនទាន់កើត ក៏ព្រោះចិត្តមិនទាន់កើតឡើង ។ ឈ្មោះថា **កើតហើយ** គឺ ជាអ្នកមានជីវិតហើយ ព្រោះចិត្តកើតឡើងចំពោះមុខ គឺ កំពុងប្រព្រឹត្តទៅ ។ ពាក្យថា **សត្វលោក** ឈ្មោះថា ស្លាប់ ក៏ព្រោះការរលត់ទៅនៃចិត្ត មានន័យថា សត្វលោកនេះ នឹងបានឈ្មោះថា ស្លាប់ដោយបរមត្ថ ព្រោះការរលត់ទៅនៃចិត្តនោះគ្រប់ដួង ដូចនឹងចុតិចិត្ត ព្រោះចិត្តដែលរលត់ទៅហើយ មិនបានត្រឡប់មកបន្តវិញទេ ។ សូម្បីយ៉ាងនេះ ក៏ឈ្មោះថា

ជាបញ្ញត្តិអាស្រ័យបរមត្ថ មានន័យថា **សន្តានបញ្ញត្តិ** ( បញ្ញត្តិអាស្រ័យការបន្តគ្នា ) ដែលជាវិស័យ នៃការប្រព្រឹត្តទៅនៃពាក្យនិយាយថា **នាយតិស្សៈរស់នៅ នាយបុស្សៈរស់នៅ** ដូច្នេះជាដើម អាស្រ័យចិត្តដែលតាំងនៅនោះយ៉ាងណា សន្តានបញ្ញត្តិ ឈ្មោះថា ជា **បរមត្ថិយា** គឺ មានដោយបរមត្ថ ។ ពិតហើយ មនុស្សទាំងឡាយតែងនិយាយគ្នាថា ឈ្មោះ និង គោត្ត រមែងមិនចាស់ ។

**អញ្ញតរញ្ញតរេន** ប្រែថា ដោយអាការ ( ៨ ) អាការណាមួយ ។ ពាក្យថា ចិត្ត បានដល់ ចិត្តដែលមានកម្មដ្ឋានជាអារម្មណ៍ ។ ពាក្យថា **សេវតស្ស** គឺ រមែងបានភាវនាសេវនៈ ( ការសេព គឺ ចម្រើន ) ទើបជាចិត្តដែលមានតែមរណៈជាអារម្មណ៍ប៉ុណ្ណោះ ដោយទាក់ទងជាមួយនឹងសេចក្តីរាយមាយទៅខាងក្រៅ ហើយមានអារម្មណ៍តែមួយគត់ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **សតិមានមរណៈជាអារម្មណ៍ រមែងតាំងមាំ** ។ ការបែកធ្លាយរបស់សភាវធម៌ទាំងឡាយ ក៏មានគតិជាសភាវធម៌នោះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **តែព្រោះអារម្មណ៍ជាសភាវធម៌** ។

ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ ជរា-មរណៈមិនទៀង ជាសង្ខតៈ អាស្រ័យបច្ច័យកើតឡើង** ដូច្នេះជាដើម ។ ពាក្យថា **ព្រោះអារម្មណ៍ជាទីតាំងនៃសេចក្តីសង្វេគ** គឺ ព្រោះធ្វើការសង្វេគចិត្តឲ្យកើតឡើង មានន័យថា មរណៈដែលរឭកដល់ហើយ រមែងនាំមកនូវសេចក្តីសង្វេគដ៏ក្រៃលែងឡើង ៗ ដូចភាពវិការជាច្រើនដែលជាប់តាមមហាភូតទាំងឡាយ ( ក្នុងពេលដែលភ្លើងឆេះកប្ប ទឹកជំនន់ជាដើម ឬ ធាតុ ៤ ក្នុងរាងកាយ ណាមួយកម្រើក ) ព្រោះហេតុនោះ ក្នុងអារម្មណ៍នោះ ភាវនាចិត្តទើបមិនអាចដល់អប្បនាបាន ។ សួរថា បើ

ឈានមិនដល់អប្បនា ព្រោះអារម្មណ៍ជាសភាវធម៌សោត , លោកុត្តរឈាន និង អរូបជ្ឈានពួកខ្លះ ( ក៏មានអារម្មណ៍ជាសភាវធម៌ ) ដល់អប្បនាបានដូចម្ដេចទៅ ? លោកអាចារ្យឆ្លើយថា ចំណែកលោកុត្តរជ្ឈានដូច្នេះជាដើម ។

ពាក្យថា **ទាក់ទងក្នុងលំដាប់នៃការចម្រើនវិសុទ្ធិ** មានន័យថា លោកុត្តរជ្ឈាន កើតឡើងដល់អប្បនាបាន ទាក់ទងនឹងលំដាប់នៃការចម្រើនវិសុទ្ធិ យ៉ាងនេះ គឺ ដោយ អានុភាពនៃវិសុទ្ធិជាន់ទាបៗ បាបធម៌ទាំងឡាយ ដែលជាបដិបក្ខដល់ការចម្រើន បដិបទាញាណទស្សនវិសុទ្ធិ ដែលមិនប្រាសចាកនូវអំណាច , និងអប្បនា ( ដែល មានក្នុងខណៈនៃញាណទស្សនវិសុទ្ធិ ) ដែលបង្អោនទៅក្នុងធម៌ ដែលប្រាសចាក សង្ខារទាំងពួង ព្រោះសេចក្ដីនឿយណាយ ប្រាសចាកតម្រេកជាដើម ( ឈានក៏ កើតឡើងដល់អប្បនាបាន ) ។ ពាក្យថា **ក្នុងអរូបជ្ឈាននោះ មានត្រឹមតែការឈាន កន្លងអារម្មណ៍** មានន័យថា អរូបកម្មដ្ឋាន ក៏ដូចគ្នានឹងកម្មដ្ឋានដែលមានសភាវធម៌ ជាអារម្មណ៍ ផ្សេងៗទៀត មិនមានការព្យាយាមក្នុងការធ្វើចិត្តឲ្យតាំងមាំ , តែថា មានកិច្ចដែលគួរធ្វើក្នុងភាវនា ត្រឹមតែជាការឈានកន្លងអារម្មណ៍ ដោយចិត្តតាម ដែលតាំងមាំហើយប៉ុណ្ណោះ ព្រោះដូច្នោះ អរូបជ្ឈានក៏ដល់អប្បនាបាន សូម្បីក្នុង សភាវធម៌ ។

ឈ្មោះថា **រមែងជាអ្នកមិនប្រមាទជានិច្ច** ព្រោះជាអ្នកច្រើនដោយការសង្វេគ ព្រោះហេតុនោះឯង ភិក្ខុនោះ ទើបមានការសម្គាល់នៅក្នុងភពទាំងពួងថា មិនគួរឲ្យ រីករាយ ។ ឈ្មោះថា **លះបង់នូវសេចក្ដីប្រាថ្នាក្នុងជីវិត** ព្រោះឃើញមរណៈនឹងត្រូវ មានយ៉ាងប្រាកដ ។ ឈ្មោះថា **ជាអ្នកតិះដៀលបាប** ព្រោះការបានអនិច្ចសញ្ញា , ព្រោះហេតុនោះ ទើបជាអ្នកមិនច្រើនដោយការសន្សំ និងប្រាសចាកសេចក្ដីកំណាញ់

ដែលជាមន្ទិល ។ ពាក្យថា **តាមគន្លងនៃអនិច្ចសញ្ញានោះ** គឺ តាមគន្លងដែលស្មាត់ជំនាញនៃអនិច្ចសញ្ញានោះ ។ ពាក្យថា **ដែលមិនបានអប់រំរឿងស្លាប់** គឺ ដែលមិនបានចម្រើនការរឭករឿយៗ ដល់សេចក្ដីស្លាប់ ។ ឈ្មោះថា **រមែងជាអ្នកមិនភ័យមិនវង្វេងក្នុងការស្លាប់** ក៏ព្រោះមានមរណសញ្ញាតាំងមាំល្អស្រេចហើយ ។

( ចប់ មរណស្សតិ )

# កាយគតាសតិ

កាយគតាសតិកម្មដ្ឋាននោះ មិនធ្លាប់ប្រព្រឹត្តទៅក្រៅពុទ្ធុប្បាទកាលឡើយ មិនមែនជាវិស័យនៃតិរ្ថិយទាំងពួង ដែលព្រះមានព្រះភាគ ទ្រង់សរសើរទុកក្នុងព្រះ-សូត្រនោះ ៗ ដោយអាការច្រើនយ៉ាងថា ម្នាលភិក្ខុទាំងឡាយ ធម៌ឯក បុគ្គលចម្រើន ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីសង្វេគ ដើម្បីជាប្រយោជន៍ ដើម្បីសតិសម្បជញ្ញៈ ដើម្បីបាននូវញាណទស្សនៈ ប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងទិដ្ឋធម៌ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវ **វិជ្ជា វិមុត្តិ** និង **ផល** ធម៌ឯកគឺអ្វី ធម៌ឯក គឺកាយគតាសតិ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាបរិភោគកាយគតាសតិ បុគ្គលនោះឈ្មោះថា បរិភោគនូវអមតៈ បុគ្គលណាមិនបរិភោគកាយគតាសតិ បុគ្គលនោះឈ្មោះថា មិនបរិភោគនូវអមតៈ កាយគតាសតិដែលបុគ្គលណាបានបរិភោគហើយ អមតៈ ក៏ឈ្មោះថា បុគ្គលនោះបានបរិភោគហើយដែរ កាយគតាសតិដែលបុគ្គលណាមិនបានបរិភោគ អមតៈក៏បុគ្គលនោះមិនបានបរិភោគ កាយគតាសតិរបស់បុគ្គលណាវិនាសហើយ អមតៈរបស់បុគ្គលនោះក៏វិនាសដែរ កាយគតាសតិរបស់បុគ្គលណាមិនវិនាស អមតៈរបស់បុគ្គលនោះក៏មិនវិនាស កាយគតាសតិរបស់បុគ្គលណាខកហើយ អមតៈរបស់បុគ្គលនោះក៏ខក កាយគតាសតិរបស់បុគ្គលណាបានសម្រេច អមតៈរបស់បុគ្គលនោះក៏បានសម្រេច ដូច្នេះជាដើម ។

ទ្រង់និទ្ទេសទុក ១៤ បព្វៈ គឺ ៖

១ - អានាបានបព្វៈ

២ - ឥរិយាបថបព្វៈ

៣ - ចតុសម្បជញ្ញបព្វៈ

៤ - បដិកូលមនសិការបព្វៈ

៥ - ធាតុមនសិការបព្វៈ ៦ - សិវថ្ថិកាបព្វៈ ៩

ក្នុងន័យថា ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ បុគ្គលគួរចម្រើនដូចម្ដេច ធ្វើឲ្យច្រើនដូចម្ដេច ទើបមានផល មានអានិសង្សច្រើន ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ទៅកាន់ព្រៃក្ដី ដូច្នេះជាដើម ឥឡូវនេះ និទ្ទេសនៃការចម្រើននូវកាយគតាសតិនោះ ដល់ហើយតាមលំដាប់ ៖

## កាយគតាសតិដែលបំណងក្នុងទីនេះ

ក្នុង ១៤ បព្វៈនោះ ព្រោះហេតុដែល ៣ បព្វៈ គឺ ឥរិយាបថបព្វៈ ចតុសម្បជញ្ញបព្វៈ ធាតុមនសិការបព្វៈ ព្រះមានព្រះភាគត្រាស់ជា **វិបស្សនា** , សិវថ្ថិកាបព្វៈ ៩ ត្រាស់ជាអាទីនវានុបស្សនា ( គឺ អាទីនវញ្ញាណ ) ក្នុងវិបស្សនាញាណទាំងឡាយនោះឯង ។ ម្យ៉ាងទៀត **សូម្បីសមាធិភាវនាណា** គប្បីសម្រេចបានក្នុងអសុភកម្មដ្ឋានទាំងឡាយ មានឧទ្ធុមាតកអសុភជាដើម ក្នុងសិវថ្ថិកាបព្វៈទាំងឡាយនោះ សមាធិភាវនានោះ មានច្បាស់លាស់ហើយក្នុងអសុភនិទ្ទេស ។ ចំណែក **២** បព្វៈនេះ គឺ អានាបានបព្វៈ និង បដិកូលមនសិការបព្វៈ ទ្រង់ត្រាស់ជាសមាធិក្នុងអនុស្សតិនិទ្ទេស , ក្នុង **២** បព្វៈនោះ **អានាបានបព្វ** ជាកម្មដ្ឋានបទមួយផ្សេង ជាអានាបានស្សតិ រីឯ **ទ្វត្តឹង្សាការកម្មដ្ឋាននោះ** ទ្រង់សម្ដែងជា **បដិកូលមនសិការបព្វៈ** សង្គ្រោះយកខួរក្បាលចូលជាមួយខួរឆ្អឹង យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីដទៃនៅមានទៀត ភិក្ខុពិចារណាឃើញកាយនេះឯង តាំងពីបាតជើងឡើងទៅ តាំងពីចុងសក់ចុះមក ព័ទ្ធជុំវិញដោយស្បែក ពេញទៅដោយរបស់មិនស្អាតមានប្រការផ្សេងៗ គឺ សក់ទាំងឡាយមានក្នុងកាយនេះ រោមទាំងឡាយមានក្នុងកាយ

នេះ ក្រចកទាំងឡាយមានក្នុងកាយនេះ ធ្មេញទាំងឡាយមានក្នុងកាយនេះ ស្បែក មានក្នុងកាយនេះ សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ មានទៅក្នុងកាយនេះ ដូច្នេះ ទ្វត្តឹង្សាការកម្មដ្ឋាននេះ បំណង យកជា **កាយគតាសតិ** ក្នុងអនុស្សតិនិទ្ទេសនេះ ។

## អធិប្បាយ បាលី កាយគតាសតិ

តទៅនេះ ជាការសម្តែងនូវការបំពេញក្នុងកាយគតាសតិកម្មដ្ឋាន ដែលមាន ពាក្យអធិប្បាយបាលីនាំមុខ ៖

បាឋៈថា **ឥមមេវ កាយំ** មានន័យថា នូវកាយស្អុយដែលជាទីអាស្រ័យនៃ មហាភូតរូប ៤ នេះ ។ បាឋថា **ឧទ្ធំ បាទតលា** ប្រែថា តាំងពីបាតជើងឡើងទៅ , បាឋថា **អធោ កេសមត្ថកា** ប្រែថា តាំងពីចុងសក់ចុះមក ។ បទថា **តចបរិយន្តំ** មានន័យថា មានស្បែកហ៊ុំព័ទ្ធដោយជុំវិញ ។ បាឋថា **បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ** គឺ ឃើញថា កាយនេះ ពេញទៅដោយវត្ថុមិនស្អាត មានសក់ជាដើម មានប្រការផ្សេងៗ សួរថា តើដូចម្តេច ? ឆ្លើយថា គឺ **អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ។ បេ ។ មុត្តំ** ក្នុងបទទាំងឡាយនោះ ។ បទថា **អត្ថិ** គឺ **សំវិជ្ជន្តិ** ប្រែថា មានហើយ ។ បទថា **ឥមស្មឹ** គឺ ក្នុងកាយដែលទ្រង់ត្រាស់ថា តាំងពីបាតជើងឡើងទៅ តាំងពីចុងសក់ចុះមក ហ៊ុំព័ទ្ធដោយស្បែក ពេញដោយវត្ថុ មិនស្អាត មានប្រការផ្សេងៗ ។ បទថា **កាយេ** គឺ ក្នុងសរីរៈ អធិប្បាយថា សរីរៈ

ហៅថា **កាយ** ព្រោះជាទីកើតនៃកោដ្ឋាសទាំងឡាយ មានសក់ជាដើម និងនៃរោគរាប់រយ មានរោគភ្នែកជាដើម , ឈ្មោះថា **ជារបស់គួរខ្ពើម** ព្រោះកើតមកពីវត្ថុមិនស្អាត ។ បទទាំងឡាយថា **កេសា លោមា** ជាដើមទាំងឡាយនោះ គឺ អាការ ៣២ មានសក់ជាអាការដើម បណ្ឌិតគប្បីជ្រាបសម្ព័ន្ធក្នុងបទបាលីនោះ ដោយការប្រកប **អត្ថិ ឥមស្មឹ កាយេ** គ្រប់បទចុះ យ៉ាងនេះថា **អត្ថិ ឥមស្មឹ កាយេ កេសា , អត្ថិ ឥមស្មឹ កាយេ លោមា** - សក់ទាំងឡាយមានក្នុងកាយនេះ រោមទាំង-ឡាយមានក្នុងកាយនេះ ដូច្នេះជាដើម ។

ពិតហើយ នរណាម្នាក់ កាលសម្លឹងមើលក្នុងរាងកាយនេះ ដែលមានប្រវែងប្រមាណ ១ ព្យាម យ៉ាងនេះគឺ ពីបាតជើងឡើងទៅ តាំងពីចុងសក់ចុះមក មានស្បែកព័ទ្ធជុំវិញ ដោយអាការគ្រប់យ៉ាង នឹងបានជួបនូវរបស់មានតម្លៃណា ៗ ដូចជា គជ់ កែវមណី កែវពៃទូរ្យ ក្រឹស្នា ការបូរ របស់ដទៃ មានខ្លឹមច័ន្ទជាដើមក្តី សូម្បីតែបន្តិចបន្តួច ក៏មិនមាន ដែលពិតជួបតែរបស់មិនស្អាតច្រើនប្រការ ដោយកោដ្ឋាស មានសក់ និងរោមជាដើម មានក្លិនស្អុយ និងគួរខ្ពើម មិនមែនជារបស់គួរស្រឡាញ់ឡើយ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **អត្ថិ ឥមស្មឹ កាយេ កេសា លោមា ។ បេ ។ មុត្តំ** - សក់ទាំងឡាយមាននៅក្នុងកាយនេះ រោមទាំង-ឡាយមាននៅក្នុងកាយនេះ ។ ល ។ មូត្រមាននៅក្នុងកាយនេះ ។ នេះជាពាក្យពោលអធិប្បាយ បទសម្ព័ន្ធក្នុងបាលីនោះ ។

## ការធានិទ្ទេសនៃកាយគតាសតិ

ឯអាទិកម្មិកបុគ្គល ដែលប្រាថ្នាចម្រើនកម្មដ្ឋាននេះ គប្បីចូលទៅរកកល្យាណ

មិត្ត មានប្រការដូចពោលហើយ កាន់យកកម្មដ្ឋានចុះ ចំណែកកល្យាណមិត ( អាចារ្យ ) កាលពោលកម្មដ្ឋានដល់គេ គប្បីប្រាប់ **ឧគ្គហកោសល្យ** ( ភាពច្លាតក្នុងការកាន់យកកម្មដ្ឋាន ) **៧** វិធី និង **មនសិការកោសល្យ** ( ភាពច្លាតក្នុងការមនសិការកម្មដ្ឋាន ) **១០** វិធី ។

## ឧគ្គហកោសល្យ

ក្នុងកោសល្យ ២ យ៉ាងនោះ អាចារ្យគប្បីប្រាប់ឧគ្គហកោសល្យ **៧** វិធី យ៉ាងនេះ គឺ ដោយវាចា ដោយចិត្ត ដោយពណ៌ ដោយសណ្ឋាន ដោយទិស ដោយឱកាស-ទីអាស្រ័យ ដោយបរិច្ឆេទ-ការប្រកាសទីបំផុត ។

### ដោយវាចា

ក្នុងកម្មដ្ឋានដែលត្រូវមនសិការវត្ថុបដិកូលនេះ ព្រះយោគាវចរ សូម្បីជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ក៏ត្រូវធ្វើការស្វាធ្យាយដោយវាចាមុន ក្នុងកាលមនសិការ ព្រោះថា កាលព្រះយោគាវចររូបខ្លះធ្វើការស្វាធ្យាយទៅ កម្មដ្ឋានរមែងប្រាកដបាន ដូចកម្មដ្ឋានប្រាកដដល់ព្រះថេរៈ ២ រូប អ្នករៀនកម្មដ្ឋានក្នុងសម្នាក់ព្រះមហាទេវត្ថេរ អ្នកស្រុកមលយ បានឮថា ព្រះថេរៈ កាលលោកទាំង ២ សុំកម្មដ្ឋានហើយ ក៏ឲ្យព្រះបាលីក្នុងទ្វត្តឹង្សាការ ប្រាប់ថា **អ្នកទាំង ២ ត្រូវស្វាធ្យាយរយៈពេល ៤ ខែ** លោកទាំង ២ នោះ ជំនាញ ២-៣ និកាយក៏ពិត តែថា ព្រោះលោកជាអ្នកទទួលឱវាទដោយគោរពជាប្រក្រតី លោកទើបស្វាធ្យាយទ្វត្តឹង្សាការអស់រយៈពេល ៤ ខែ បានជាព្រះសោតាបន្ន ព្រោះដូច្នោះ អាចារ្យអ្នកពោលកម្មដ្ឋាន ទើបគួរប្រាប់អន្តេវា-

សិកថា ដំបូងចូរស្វាធ្យាយដោយវាចាមុន ។

## វិធីស្វាធ្យាយ

កាលទីងធ្វើ គប្បីកំណត់ជាវគ្គៗ មានវគ្គ **តចបញ្ចកៈ** ( ៥ ទាំង **ស្បែក** ) ជាដើមហើយ ស្វាធ្យាយដោយអនុលោម និង បដិលោម , គប្បីពោលថា **កេសា លោមា នខា ទន្តា តចោ** - សក់ រោម ក្រចក ធ្មេញ ស្បែក ហើយទើបពោលបដិលោមថា **តចោ ទន្តា នខា លោមា កេសា** - ស្បែក ធ្មេញ ក្រចក រោម សក់ ។

បន្ទាប់មក គប្បីពោលក្នុង **វក្កបញ្ចកៈ** ( ៥ ទាំង **តម្រងបស្សាវៈ** ) ថា **មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ** = សាច់ សរសៃ ឆ្អឹង ខួរឆ្អឹង តម្រងបស្សាវៈ ហើយពោលដោយបដិលោមទៀតថា **វក្កំ អដ្ឋិមិញ្ជំ អដ្ឋី នហារូ មំសំ តចោ ទន្តា នខា លោមា កេសា** = តម្រងបស្សាវៈ ខួរឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់ ។

បន្ទាប់ពីនោះ ពោលក្នុង **បប្ផាសបញ្ចកៈ** ( ៥ ទាំង **សួត** ) ថា **ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ** = បេះដូង ថ្លើម វាវ ក្រពះ សួត ហើយពោលដោយបដិលោមថា **បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ វក្កំ អដ្ឋិមិញ្ជំ អដ្ឋី នហារូ មំសំ តចោ ទន្តា នខា លោមា កេសា** = សួត ក្រពះ វាវ ថ្លើម បេះដូង តម្រងបស្សាវៈ ខួរឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់ ។

បន្ទាប់ពីនោះ ពោលក្នុង **មត្ថលុង្គបញ្ចកៈ** ( ៥ ទាំង **ខួរក្បាល** ) ថា **អន្តំ អន្តគុណំ ឧទរិយំ ករីសំ មត្ថលុង្គំ** = ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារ

ចាស់ ខួរក្បាល ហើយពោលដោយបដិលោមទៀតថា **មត្ថលុង្គំ ករីសំ ឧទរិយំ អន្តគុណំ អន្តំ បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ វក្កំ អដ្ឋិមិញ្ជំ អដ្ឋី នហារូ មំសំ តចោ ទន្តា នខា លោមា កេសា** = ខួរក្បាល អាហារចាស់ អាហារថ្មី ពោះវៀនតូច ពោះវៀនធំ សួត ក្រពះ វាវ ថ្លើម បេះដូង តម្រងបស្សាវៈ ខួរឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់ ។

បន្ទាប់មកពោលក្នុង **មេទឆក្កៈ** ( ៦ ទាំង **ខ្លាញ់ខាប់** ) ថា **បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ** = ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ហើយពោលដោយបដិលោមថា **មេទោ សេទោ លោហិតំ បុព្វោ សេម្ហំ បិត្តំ មត្ថលុង្គំ ករីសំ ឧទរិយំ អន្តគុណំ អន្តំ បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ វក្កំ អដ្ឋិមិញ្ជំ អដ្ឋី នហារូ មំសំ តចោ ទន្តា នខា លោមា កេសា** = ខ្លាញ់ខាប់ ញើស ឈាម ខ្ទុះ ស្លេស្ម ប្រមាត់ ខួរក្បាល អាហារចាស់ អាហារថ្មី ពោះវៀនតូច ពោះវៀនធំ សួត ក្រពះ វាវ ថ្លើម បេះដូង តម្រងបស្សាវៈ ខួរឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់ ។

បន្ទាប់មកពោលក្នុង **មុត្តឆក្កៈ** ( ៦ ទាំង **ទឹកមុត្រ** ) ថា **អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តំ** = ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ហើយពោលបដិលោមទៀតថា **មុត្តំ លសិកា សិង្ឃាណិកា ខេឡោ វសា អស្សុ មេទោ សេទោ លោហិតំ បុព្វោ សេម្ហំ បិត្តំ មត្ថលុង្គំ ករីសំ ឧទរិយំ អន្តគុណំ អន្តំ បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ វក្កំ អដ្ឋិមិញ្ជំ អដ្ឋី នហារូ មំសំ តចោ ទន្តា នខា លោមា កេសា** = ទឹកមូត្រ ទឹករំអិល ទឹកសំបោរ ទឹកមាត់ ខ្លាញ់រាវ ទឹកភ្នែក ខ្លាញ់ខាប់ ញើស ឈាម ខ្ទុះ ស្លេស្ម

ប្រមាត់ ខួរក្បាល អាហារចាស់ អាហារថ្មី ពោះវៀនតូច ពោះវៀនធំ សួត ក្រពះ វាវ ថ្លើម បេះដូង តម្រងបស្សាវៈ ខួរឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់ ។

គប្បីធ្វើការស្វាធ្យាយដោយវាចា យ៉ាងនេះ ១០០ ដង ១.០០០ ដង ឬដល់ទៅ ១០.០០០ ដងក្តី ព្រោះថាការស្វាធ្យាយដោយមាត់ ប្រព័ន្ធកម្មដ្ឋាន រមែងជាការងាយ ចិត្តមិនស្ទុះទៅខាងនេះខាងនោះ កោដ្ឋាសទាំងឡាយនឹងប្រាកដ គឺ ច្បាស់ដូចជួរម្រាមដៃ និងដូចជាជួរបង្គោលរបងដូច្នោះ ។

## ដោយ ចិត្ត ពណ៌ សណ្ឋាន ទិស ឱកាស បរិច្ឆេទ

ដោយវាចា ធ្វើការស្វាធ្យាយយ៉ាងណា សូម្បីដោយចិត្ត ក៏គប្បីធ្វើការស្វាធ្យាយ យ៉ាងនោះដែរ ព្រោះការស្វាធ្យាយដោយវាចា ជាបច្ច័យនៃការស្វាធ្យាយដោយចិត្ត ការស្វាធ្យាយដោយចិត្តជាបច្ច័យនៃការចាក់ធ្លុះនូវលក្ខណៈ ។

ពាក្យថា **ដោយពណ៌** គឺ គប្បីកំណត់ដោយពណ៌របស់កោដ្ឋាសទាំងឡាយមានសក់ជាដើម ។

ពាក្យថា **ដោយសណ្ឋាន** គឺ គប្បីកំណត់ដោយសណ្ឋានរបស់កោដ្ឋាសទាំងឡាយនោះ ។

ពាក្យថា **ដោយទិស** អធិប្បាយថា ក្នុងសរីរៈនេះ តាំងពីផ្ចិតឡើងទៅជាទិសខាងលើ តាំងអំពីផ្ចិតចុះមកជាទិសខាងក្រោម ហេតុនោះ គប្បីកំណត់ទិសថា កោដ្ឋាសនេះ នៅក្នុងទិសនេះ ។

ពាក្យថា **ដោយឱកាស** មានន័យថា គប្បីកំណត់ឱកាសរបស់កោដ្ឋាសនោះ

យ៉ាងនេះថា កោដ្ឋាសនេះឋិតនៅត្រង់នេះ ។

ពាក្យថា **ដោយបរិច្ឆេទ** មានអធិប្បាយថា បរិច្ឆេទមាន ២ គឺ **សភាគបរិច្ឆេទ** ការប្រកាសទីបំផុតនៃខ្លួនឯង , **វិសភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយភាពផ្សេងពីខ្លួនឯង , ក្នុង ២ យ៉ាងនោះ ការប្រកាសទីបំផុតនៃខ្លួន គប្បីជ្រាបយ៉ាងនេះថា កោដ្ឋាសនេះ មានទីបំផុតដោយចំណែកឈ្មោះនេះ ទាំងខាងក្រោម ខាងលើ និងទទឹង , ឯការប្រកាសទីបំផុតដែលផ្សេងពីខ្លួនឯង គប្បីជ្រាបដោយការមិនច្រឡំគ្នា យ៉ាងនេះថា សក់ គឺ វត្ថុដែលមិនមែនរោម រោមទាំងឡាយ ក៏មិនមែនជាសក់ដូច្នេះ ជាឧទាហរណ៍ ។

## ប្រការគួរជ្រាប មុននឹងប្រាប់ឧគ្គហកោសល្យ

ឯអាចារ្យកាលនឹងប្រាប់ឧគ្គហកោសល្យ ៧ វិធី ដូចពោលមកនេះ គួរដឹងថា កម្មដ្ឋាននេះ ទ្រង់ត្រាស់ក្នុងព្រះសូត្រនោះ ជាវត្ថុបដិកូល ក្នុងសូត្រនោះ ជាធាតុដូច្នេះហើយ ទើបប្រាប់ , ពិតហើយ កម្មដ្ឋាននេះ ក្នុងមហាសតិប្បដ្ឋានសូត្រ ទ្រង់ត្រាស់ជាវត្ថុបដិកូល , ក្នុងមហាហត្ថិបទោបមសូត្រ មហារាហុលោវាទសូត្រ និងធាតុវិភង្គសូត្រ ទ្រង់ត្រាស់ជាធាតុ , រីឯ ក្នុងកាយគតាសតិសូត្រ ទ្រង់ចែកឈាន ៤ សំដៅដល់បុគ្គលដែលកោដ្ឋាស មានសក់ជាដើមប្រាកដជាវណ្ណ , ក្នុងកម្មដ្ឋាន ២ ផ្នែកនោះ ដែលទ្រង់ត្រាស់ជាធាតុ ជាវិបស្សនាកម្មដ្ឋាន ដែលទ្រង់ត្រាស់ជាវត្ថុបដិកូលជាសមថកម្មដ្ឋាន , កម្មដ្ឋានក្នុងបដិកូលមនសិការបព្វៈនេះ ជាសមថកម្មដ្ឋាន ។

ឧគ្គហកោសល្យ ៧ វិធី អាចារ្យគប្បីប្រាប់តាមន័យដូចពោលមកដូច្នេះចុះ ។

## មនសិការកោសល្យ

អាចារ្យគប្បីប្រាប់មនសិការកោសល្យ ១០ វិធី យ៉ាងនេះ គឺ តាមលំដាប់ ដោយមិនលឿនពេក ដោយមិនយឺតពេក ដោយការពារការរាយមាយ ដោយការកន្លងនូវបញ្ញត្តិ ដោយការកន្លងលំដាប់ ដោយអប្បនា និង សុត្តន្ត ៣ ។

## មនសិការតាមលំដាប់

ក្នុងមនសិការកោសល្យ ១០ នោះ ឈ្មោះថា ដោយលំដាប់ អធិប្បាយថា កម្មដ្ឋាននេះ តាំងពីផ្ដើមស្វាធ្យាយ ត្រូវមនសិការរៀងតាមលំដាប់ ( បទទួតីង្សាការ ) កុំមនសិការដោយការកន្លងបទ ១ ( ហួសទៅបទ ១ ផ្សេង ) ព្រោះបើព្រះយោគីមនសិការដោយការកន្លងបទ ១ នឹងនឿយចិត្ត នឹងប្រាសចាកការបាននូវអស្សាទៈដែលត្រូវបានដោយអំណាចការដល់ព្រមនៃភាវនា មិនញុំាងភាវនាឲ្យសម្រេចបាន ប្រៀបដូចបុគ្គលមិនឆ្លាត ឡើងជណ្ដើរ ៣២ កាំ ឡើងរំលង ១ កាំ ៗ ក៏នាំឲ្យអស់កម្លាំងកាយ មិនអាចឡើងឲ្យសម្រេចបាន ។

## មនសិការកុំលឿនពេក

សូម្បីមនសិការតាមលំដាប់ គប្បីមនសិការ កុំលឿនពេក ព្រោះកាលមនសិការលឿនពេក កម្មដ្ឋានគង់ដល់ទីបំផុតក៏ពិត តែថា មិនប្រាកដច្បាស់ មិនអាចនាំមកនូវគុណវិសេស ប្រៀបដូចបុរសដើរផ្លូវប្រមាណ ៣ យោជន៍ មិនបានចំណាំផ្លូវដែលគួរដើរ និងផ្លូវដែលគួរវៀរ ធ្វើដំណើរដោយជំហានជើងយ៉ាងរហ័ស , ទៅមក ៗ ៧ ដង , ទៅដល់ក៏ពិត តែ ( គេចាំផ្លូវមិនបាន ) ត្រូវសួរគេរាល់ដង

ព្រោះដូច្នោះ ព្រះយោគាវចរ កុំមនសិការលឿនពេក ។

## មនសិការកុំយឺតពេក

ម្យ៉ាងទៀត កុំមនសិការយឺតពេក ដូចគ្នានឹងមនសិការកុំលឿនពេក ព្រោះពេលមនសិការយឺតពេក កម្មដ្ឋានមិនដល់ទីបំផុត មិនជាបច្ច័យនៃការបានគុណវិសេស ដូចបុគ្គលដែលមានបំណងធ្វើដំណើរចម្ងាយ ៣ យោជន៍ ក្នុងមួយថ្ងៃ វល់តែយឺតយ៉ាវនៅតាមកន្លែងផ្សេងៗ ដូចជាដើមឈើ ភ្នំ និង បឹង ក្នុងរវាងផ្លូវ ក៏ទៅមិនដល់ទីដៅ , ២ - ៣ ថ្ងៃ ទើបដើរដល់ ។

## មនសិការការពារភាពរាយមាយ

សេចក្តីថា **ដោយការពារភាពរាយមាយ** មានន័យថា ការដែលចិត្តរំលងកម្មដ្ឋាន ហើយរាយមាយទៅក្នុងអារម្មណ៍ទាំងឡាយខាងក្រៅ ព្រះយោគាវចរត្រូវការពារ ព្រោះបើមិនការពារ កាលសេចក្តីរាយមាយទៅខាងក្រៅ មានហើយ កម្មដ្ឋាន រមែងវិនាសទៅ ប្រៀបដូចបុរសដើរលើផ្លូវអែបមាត់ជ្រោះ ជាផ្លូវមួយជាន មិនមើលជាន ជាន់ឲ្យចំ វល់ងាកទៅខាងនេះខាងនោះ ឈានជើងខុស ក៏ត្រូវធ្លាក់ពីផ្លូវនោះ ចុះទៅក្នុងជ្រោះដែលមានជម្រៅ ១០០ ជួរបុរស ព្រោះហេតុនោះ ព្រះយោគាវចរ គួរធ្វើមនសិការការពារភាពរាយមាយ ។

## មនសិការកន្លងនូវបញ្ញត្តិ

សេចក្តីថា **ដោយកន្លងនូវបញ្ញត្តិ** មានន័យថា បញ្ញត្តិថា **កេសា លោមា** ជាដើម ព្រះយោគាវចរ គប្បីឈានកន្លងនូវបញ្ញត្តិនោះហើយ ទើបតម្កល់ចិត្តនៅក្នុង

“ **បដិកូល** ” ដូចជា ក្នុងកាលដែលទឹករកបានដោយលំបាក មនុស្សទាំងឡាយជួប ត្រពាំងទឹកនៅក្នុងព្រៃហើយ ចងវត្ថុចំណាំ មានស្លឹកត្នោតជាដើម ទុកក្នុងទីនោះៗ ហើយក៏មកតាមគ្រឿងចំណាំនោះ ងូតទឹក និង ផឹកទឹកបាន តែកាលណាធ្វើដំណើរ ទៅរឿយៗ នៃមនុស្សទាំងឡាយនោះ គន្លងផ្លូវនៃមនុស្សដែលទៅមក រមែងប្រាកដ ពេលនោះ កិច្ចដោយគ្រឿងសម្គាល់រមែងមិនមាន មនុស្សទាំងឡាយរមែងទៅងូត ទឹក និង ផឹកទឹកបាន គ្រប់ពេលដែលត្រូវការ យ៉ាងណា កាលព្រះយោគាវចរ មនសិការទៅតាមបញ្ញត្តិថា **កេសា លោមា** - ជាខាងដើម , រហូតភាពជាបដិកូល ប្រាកដ បន្ទាប់មកទើបលើកបញ្ញត្តិដែលថា **កេសា លោមា** ចេញ , តម្កល់ចិត្តតែ ក្នុងភាពជាបដិកូល តែម្យ៉ាងចុះ ។

## មនសិការរំលងលំដាប់

សេចក្តីថា **ដោយរំលងលំដាប់** មានអត្ថាធិប្បាយថា កោដ្ឋាសណាមិនប្រាកដ ព្រះយោគាវចរ គប្បីរំលងកោដ្ឋាសនោះចេញ មនសិការតទៅ ឈ្មោះថា **មនសិ-ការរំលងលំដាប់** ពេលព្រះអាទិកម្មិកៈមនសិការ ( ដោយអនុលោម ) ថា **កេសា** មនសិការក៏ប្រព្រឹត្តទៅរហូតដល់កោដ្ឋាសចុង គឺ **មុត្តំ** , ហើយពេលមនសិការ ( ដោយបដិលោម ) ថា **មុត្តំ** មនសិការក៏ប្រព្រឹត្តទៅរហូតដល់កោដ្ឋាសដើម គឺ **កេសា** ដូចគ្នា កាលមនសិការទៅ កោដ្ឋាសខ្លះក៏ប្រាកដ កោដ្ឋាសខ្លះក៏មិនប្រាកដ កោដ្ឋាសទាំងឡាយណាប្រាកដ គប្បីមនសិការកោដ្ឋាសទាំងឡាយនោះ រហូតកាល កោដ្ឋាសប្រាកដត្រឹមតែ ២ , ហើយក្នុង ២ នោះ មានមួយ រមែងប្រាកដល្អជាង ដូច្នោះ ព្រះអាទិកម្មិកៈ គប្បីមនសិការកោដ្ឋាសដែលប្រាកដ ( ល្អជាងមួយទៀត )

នោះ យ៉ាងនោះដដែល ៗ នឹងញ៉ាំងអប្បនាឲ្យកើតឡើងបានជាប្រាកដ ។

នេះជាឧបមាក្នុងសេចក្ដីនោះ ដូចជាព្រានប្រាថ្នានឹងចាប់ស្វា នៅក្នុងព្រៃត្នោត ដែលមានដើមត្នោត ៣២ ដើម ក៏ប្រើសរបាញ់ស្លឹកត្នោត ដើមដែលឈរនៅដើមគេ ហើយធ្វើសំឡេងបណ្ដេញចេញ ស្វានោះ ក៏លោតទៅដើមត្នោតនោះៗ តាមលំដាប់ រហូតដល់ដើមចុងក្រោយគេ បន្ទាប់មក ព្រានក៏ធ្វើដូចគ្នានោះដដែល ចូលទៅដើម ចុងគេនោះ វាក៏លោតមកតាមកាយវិការនោះ រហូតដល់ដើម ខាងដើមវិញ វា លោតទៅតាមលំដាប់ដើមរឿយៗ យ៉ាងនោះ និងលោតផ្លោះឡើងតែត្រង់ទីដែល ព្រាន ធ្វើសំឡេងដេញប៉ុណ្ណោះ ( បើមិនធ្វើសំឡេងដេញក៏មិនប្រាកដ ) ហើយ ទៅបាត់ត្រង់ដើមត្នោតមួយ តោងចុងផ្កាត្នោតដ៏ស្អាត ត្រង់កណ្ដាលដើម វាទុកជា មូលដ្ឋាន ទោះត្រូវបាញ់ វាក៏មិនលោតឡើងយ៉ាងណា ពាក្យឧបមេយ្យនេះ ក៏គប្បី ឃើញដូច្នោះ ។

នេះជាពាក្យប្រៀបធៀបឧបមេយ្យ ជាមួយនឹងឧបមា , កោដ្ឋាស ៣២ ក្នុង កាយនេះ ប្រៀបដូចនឹងដើមត្នោត ៣២ ដើម ក្នុងព្រៃត្នោត ចិត្តដូចសត្វស្វា ព្រះ យោគាវចរដូចជាព្រាន ការដែលចិត្តរបស់ព្រះយោគាវចរប្រព្រឹត្តទៅក្នុងកាយដែល មានកោដ្ឋាស ៣២ ជាអារម្មណ៍ ដូចសត្វស្វានៅក្នុងព្រៃត្នោត ដែលមានដើមត្នោត ៣២ ដើម កាលព្រះយោគាវចរផ្ដើមមនសិការថា **កេសា** , ចិត្តប្រព្រឹត្តទៅរហូត ដល់កោដ្ឋាសខាងចុង ដូចពេលព្រានប្រើសរបាញ់ស្លឹកត្នោត ដើមខាងដើម ហើយ ធ្វើសំឡេងដេញចេញ ស្វាក៏លោតទៅដើមត្នោតនោះៗ រហូតដល់ដើមចុងក្រោយ សូម្បីក្នុងពេលត្រឡប់មកវិញ ក៏មានន័យដូចគ្នាដែរ កាលព្រះយោគាវរមនសិការ រឿយ ៗ កាលកោដ្ឋាសខ្លះមិនប្រាកដ ខ្លះប្រាកដ ក៏រំលងកោដ្ឋាសទាំងឡាយដែល

មិនប្រាកដចេញ ធ្វើបរិកម្មក្នុងកោដ្ឋាសទាំងឡាយដែលប្រាកដ ដូចស្វាដែលលោតទៅតាមលំដាប់ដើមរឿយៗ លោតឡើងតែក្នុងទីដែលព្រានធ្វើសំឡេងបណ្តេញចេញ ( បើមិនធ្វើសំឡេងបណ្តេញក៏មិនលោត ) ទីបំផុតកោដ្ឋាសប្រាកដ ២ , ក្នុងកោដ្ឋាស ២ នោះ កោដ្ឋាសណាប្រាកដល្អជាង ព្រះយោគាវចរមនសិការកោដ្ឋាសនោះរឿយៗ ញុំាងអប្បនាឲ្យកើត ដូចស្វាដែលលោតទៅសម្ងំនៅនឹងដើមត្នោតមួយដើម តោងចុងផ្កាត្នោតដ៏ស្អាត ត្រង់កណ្តាលដើម វាទុកជាមូលដ្ឋាន សូម្បីត្រូវបាញ់ក៏មិនលោតដែរ ។

ឧបមាមួយទៀត ដូចបិណ្ឌបាតិកភិក្ខុអាស្រ័យនៅក្នុងស្រុកដែលមានមនុស្ស ៣២ ត្រកូល ទៅបិណ្ឌបាត បើបានភិក្ខា ២ កន្លែង នៅផ្ទះខ្ទងដំបូងរួចហើយ ក៏លះបង់ផ្ទះក្រោយ ១ ចោល , ស្អែកឡើង បើថាទៅ ៣ កន្លែង បើបានក្នុងផ្ទះដំបូងហើយ ក៏លះបង់ផ្ទះ ២ ខ្ទងខាងមុខចោល , ក្នុងថ្ងៃទី ៣ បើថាបានភិក្ខាពេញបាត្រ ក្នុងផ្ទះខាងដើមស្រេចហើយ ( ក៏មិនទៅបិណ្ឌបាត ) ទៅរោងឆាន់ ឆាន់តែម្តង យ៉ាងណា ពាក្យឧបមេយ្យនេះ ក៏គប្បីឃើញដូច្នោះ អាការ ៣២ ដូចស្រុកដែលមានត្រកូល ៣២ ត្រកូល ព្រះយោគាវចរដូចបិណ្ឌបាតិកភិក្ខុ ការដែលព្រះយោគាវចរធ្វើបរិកម្មក្នុងអាការ ៣២ ដូចបិណ្ឌបាតិកភិក្ខុនោះ អាស្រ័យស្រុកនោះ ( ជាទីគោចរបិណ្ឌបាត ) កាលព្រះយោគាវចរមនសិការរឿយៗ លះបង់កោដ្ឋាសទាំងឡាយដែលមិនប្រាកដចោល ធ្វើបរិកម្មក្នុងកោដ្ឋាសទាំងឡាយដែលប្រាកដ រហូតសល់តែ ២ កោដ្ឋាស ក៏ដូចបិណ្ឌបាតិកភិក្ខុ បានភិក្ខា ២ កន្លែង ក្នុងផ្ទះដំបូងហើយ លះបង់ផ្ទះមួយខាងមុខចោល និងដូចក្នុងថ្ងៃទី ២ បាន ១ កន្លែង ក៏លះបង់ផ្ទះ ២ ខាងមុខចោល , ក្នុងកោដ្ឋាស ២ បើកោដ្ឋាសណាប្រាកដច្បាស់ជាង ព្រះ

យោគាវចរគប្បីមនសិការកោដ្ឋាសនោះរឿយៗ ញុំាងអប្បនាឲ្យកើតឡើង ដូចក្នុងថ្ងៃទី ៣ បានពេញបាត្រក្នុងផ្ទះដំបូងហើយ ទៅអង្គុយឆាន់ក្នុងរោងឆាន់ដូច្នោះ ។

## មនសិការដោយអប្បនា

សេចក្ដីថា **ដោយអប្បនា** គឺ ដោយកោដ្ឋាសដែលឲ្យកើតអប្បនា នេះជាអធិប្បាយក្នុងសេចក្ដីនោះ គឺ បណ្ឌិតគប្បីជ្រាបថា ក្នុងកោដ្ឋាសទាំងឡាយ មានសក់ជាដើម អប្បនា រមែងសម្រេចបានក្នុងកោដ្ឋាសមួយ ៗ ។

## ដោយសុត្តន្តៈ៣

នេះជាអធិប្បាយក្នុងសេចក្ដីថា **ដោយសុត្តន្តៈ ៣** នោះថា សុត្តន្តៈ ៣ គឺ **អធិចិត្តសូត្រ សីតិភាវសូត្រ ពោជ្ឈង្គកោសល្លសូត្រ** ព្រះយោគាវចរ គប្បីជ្រាបដើម្បីប្រកបនូវវីរិយសមាធិ ។

## អធិចិត្តសូត្រ

ក្នុង ៣ សូត្រនោះ សូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបអធិចិត្ត ត្រូវមនសិការនិមិត្ត ៣ តាមកាលដែលគួរ គឺ ត្រូវមនសិការសមាធិនិមិត្តតាមកាលដែលគួរ ត្រូវមនសិការបគ្គហនិមិត្តតាមកាលដែលគួរ ត្រូវមនសិការឧបេក្ខានិមិត្តតាមកាលដែលគួរ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបអធិចិត្ត មនសិការសមាធិនិមិត្តតែម្យ៉ាងប៉ុណ្ណោះ រមែងមានចិត្តប្រព្រឹត្តទៅក្នុងកោសជ្ជ បើភិក្ខុប្រកបអធិចិត្ត មនសិការបគ្គហនិមិត្តតែម្យ៉ាង រមែងមានចិត្តប្រព្រឹត្តទៅក្នុងឧទ្ធច្ចៈ បើភិក្ខុប្រកបអធិចិត្ត មនសិការឧបេក្ខានិមិត្តតែម្យ៉ាង រមែងមានចិត្តមិនតាំងមាំត្រូវផ្លូវ ដើម្បីអស់អាសវៈ

ទាំងឡាយឡើយ តែកាលភិក្ខុប្រកបអធិចិត្ត មនសិការសមាធិនិមិត្ត បគ្គហនិមិត្ត ឧបេក្ខានិមិត្ត ចិត្តទើបជាចិត្តទន់ភ្លន់ គួរដល់ការងារ ជាចិត្តផូរផង់ និងមិនរាយមាយ តាំងមាំត្រូវផ្លូវដើម្បីអស់អាសវៈទាំងឡាយ ឧបមាដូចជាងទង ឬកូនសិស្សជាងទង បង្កាត់ភ្លើងក្នុងឡ កាលបង្កាត់ហើយ ក៏ដុតឡ ពេលដែលដុតឡហើយ ក៏យកដង្កាប់ចាប់មាសដាក់ចូលក្នុងឡ ហើយសប់ខ្យល់ក្នុងកាលដែលគួរ ប្រោះទឹកក្នុងកាលដែលគួរ នៅព្រងើយៗតាមកាលដែលគួរ , ម្នាលភិក្ខុទាំងឡាយ បើជាងទងក្តី កូនសិស្សនៃជាងទងក្តី សប់ខ្យល់ចូលតែម្យ៉ាង មាសនោះនឹងរលាយទៅ បើជាងទងក្តី កូនសិស្សនៃជាងទងក្តី ប្រោះទឹកចូលទៅតែម្យ៉ាង មាសនោះនឹងត្រជាក់ បើជាងទងក្តី កូនសិស្សនៃជាងទងក្តី មើលដោយព្រងើយៗតែម្យ៉ាង នឹងឆ្អិនមិនល្អ តែកាលបើជាងទងក្តី កូនសិស្សនៃជាងទងក្តី សប់ខ្យល់តាមកាលគួរ ប្រោះទឹកតាមកាលដែលគួរ មើលមាសនោះព្រងើយៗតាមកាលដែលគួរ មាសនោះទើបទន់ល្អ គួរដល់ការងារ ជាមាសសុទ្ធល្អ និងមិនប្រេះ ប្រើការបានល្អ បើជាងទងបំណងនឹងធ្វើគ្រឿងប្រដាប់ប្រភេទណាៗ ជាខ្សែក្រវាត់ក្តី ជាទំហ៊ូក្តី ជាគ្រឿងប្រដាប់កក្តី ជាខ្សែសង្វារក្តី វត្ថុដែលបំណងនោះ រមែងសម្រេចដល់គេ យ៉ាងណា ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុដែលប្រកបអធិចិត្ត ( ត្រូវមនសិការនិមិត្ត ៣ តាមកាលគួរ ។ល។ ) ( ចិត្តរបស់គេ ) ទើបតាំងមាំ ត្រូវផ្លូវដើម្បីអស់អាសវៈទាំងឡាយ បើគេបង្អោនចិត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ប្រពៃ នូវធម៌ដែលជាអភិញ្ញាសច្ឆិករ-ណីយៈណាៗ ពេលបានហេតុដែលគួរ គេនឹងជាអ្នកអាចក្នុងការធ្វើឲ្យប្រចក្សបានក្នុងអភិញ្ញាសច្ឆិករណីយធម៌នោះៗ ជាប្រាកដ ។ នេះឈ្មោះថា **អធិចិត្តសូត្រ** ។

## សីតិភាវសូត្រ

សូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៦ ប្រការ ជាអ្នកអាចដើម្បីធ្វើឲ្យជាក់ច្បាស់នូវ សីតិភាវៈ ( ការរលត់ត្រជាក់ ) ដ៏ប្រពៃ ធម៌ ៦ ប្រការ គឺ អ្វីខ្លះ ? គឺ ភិក្ខុក្នុងធម្មវិន័យនេះ គ្របសង្កត់ចិត្តក្នុងសម័យដែលចិត្តគួរគ្រប ១ លើកចិត្តក្នុងសម័យដែលចិត្តគួរលើក ១ ធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលគួរធ្វើចិត្តឲ្យរីករាយ ១ សម្លឹងមើលចិត្តព្រងើយៗ ក្នុងសម័យដែលគួរសម្លឹងមើលចិត្តដោយព្រងើយៗ ១ ជាអ្នកមានអធិមុត្តិ ( អធ្យាស្រ័យ ) ប្រណីត ១ ត្រេកអរក្នុងព្រះនិព្វាន ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ ប្រការនេះ ជាអ្នកអាចធ្វើឲ្យជាក់ច្បាស់នូវសីតិភាវៈដ៏កំពូល ។ នេះឈ្មោះថា សីតិភាវសូត្រ ។

## ពោជ្ឈង្គកោសល្យសូត្រ

ចំណែកសត្តពោជ្ឈង្គកោសល្យ បានសម្តែងមកហើយក្នុងអប្បនាកោសល្យកថា យ៉ាងនេះ **ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណាចិត្តរួញរា ក្នុងសម័យនោះមិនមែនជាកាលនៃការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ** ដូច្នេះជាដើម ។

ព្រះយោគាវចរនោះ ធ្វើឧគ្គហកោសល្យ ៧ វិធីនេះ ឲ្យជាការកាន់យកដោយល្អ និង កំណត់មនសិការកោសល្យ ១០ វិធី នេះដោយល្អផង តាមន័យដែលពោលមកនេះហើយ នឹងជាអ្នកកាន់យកកម្មដ្ឋានបានដោយល្អ ដោយអំណាចកោសល្យទាំង ២ នោះ ។

## មុននឹងផ្ដើមកម្មដ្ឋាន

បើព្រះយោគាវចរ មានសេចក្ដីសុខនៅក្នុងវិហារជាមួយព្រះអាចារ្យ លោកក៏មិនចាំបាច់ឲ្យអាចារ្យប្រាប់ដោយពិស្ដារយ៉ាងនេះឡើយ ប្រកបកម្មដ្ឋាន បានគុណវិសេសហើយ ចាំឲ្យលោកប្រាប់ថ្នាក់ខ្ពស់ឡើងទៅ បើព្រះយោគាវចរបំណងនឹងទៅកាន់កន្លែងដទៃ គប្បីឲ្យអាចារ្យប្រាប់ដោយពិស្ដារ តាមវិធីដែលពោលហើយ សាចុះឡើងដដែលៗ ( ឲ្យចាំមាត់ និង ចិត្ត ) ជម្រះន័យដែលមិនយល់ឲ្យអស់ លះបង់សេនាសនៈដែលមិនសមគួរ ហើយនៅក្នុងសេនាសនៈដែលសមគួរ លះបង់បលិពោធតូចតាច តាមន័យដែលពោលហើយក្នុងបឋវីកសិណនិទ្ទេសនោះហើយ ទើបធ្វើបរិកម្មដោយបដិកូលមនសិការចុះ ។

កាលនឹងធ្វើ គប្បីកាន់យកនិមិត្តក្នុងសក់ទាំងឡាយជាលំដាប់ដំបូង , សួរថា កាន់យកនិមិត្តក្នុងសក់ទាំងឡាយ ដូចម្ដេច ? ឆ្លើយថា គប្បីដកសក់ ១ ឬ ២ សរសៃ ដាក់នៅលើបាតដៃ ហើយកំណត់ពណ៌ជាមុន បើនឹងមើលសក់ទាំងឡាយនៅត្រង់កន្លែងគេកាត់សក់ ក៏គួរ ឬសូម្បីមើលសក់ទាំងឡាយជ្រុះក្នុងទឹក ឬ ក្នុងយាគូ ក៏គួរដូចគ្នា ឃើញក្នុងពេលពណ៌វានៅខ្មៅ គប្បីមនសិការថា **វាខ្មៅ** ឃើញក្នុងកាលដែលវា ស គប្បីមនសិការថា វា ស តែបើកាលណាមានពណ៌លាយគ្នា គប្បីមនសិការពណ៌ដែលក្រាស់ជាង , ក្នុងសក់ទាំងឡាយយ៉ាងណា ក្នុងកោដ្ឋាសតចបញ្ចកៈទាំងអស់ក៏ដូច្នោះ កាលបានឃើញច្បាស់ហើយ គប្បីកាន់យកនិមិត្ត , កាលកាន់យកនិមិត្តយ៉ាងនេះហើយ គប្បីកំណត់លក្ខណៈកោដ្ឋាសទាំងពួង ដោយ ពណ៌ សណ្ឋាន ទិស ឱកាស-ទីតាំង និង បរិច្ឆេទ-ទីជុំវិញ ហើយទើបកំណត់ជាបដិកូល ៥ ប្រការ ដោយ ពណ៌ សណ្ឋាន ក្លិន ទីអាស្រ័យ និង ឱកាស ។

# មហាដីកា

# អធិប្បាយ កាយគតាសតិ

ឈ្មោះថា **ពុទ្ធុប្បាទ** ព្រោះអត្ថថា ពេលដែលព្រះពុទ្ធជាម្ចាស់ទាំងឡាយទ្រង់ឧប្បត្តិ បានដល់ កាលឧប្បត្តិនៃព្រះពុទ្ធជាម្ចាស់ទាំងឡាយ វៀរចាកពុទ្ធុប្បាទនោះ, អធិប្បាយថា វៀរនូវពុទ្ធុប្បាទនោះ គឺ ក្នុងកាលដទៃ ។ បទថា **នប្បវត្តបុព្វំ** ប្រែថា មិនធ្លាប់ប្រព្រឹត្តទៅ ។ ព្រោះហេតុនោះឯង ទើបមិនជាវិស័យនៃពួកតិត្ថិយទាំងពួង ។ សួរថា ក៏សាស្តាទាំងឡាយ មានព្រះសុនេត្រជាដើម និងពួកតាបសបរិព្វាជកទាំងឡាយដទៃ ក៏ដឹងរាងកាយថា មិនស្អាត មិនមែនឬ ? ពិតហើយ សុមេធតាបសជាអ្នករង្កៀសនឹងសរីរៈ បានពោលថា **យើងគប្បីជាអ្នកមិនអាល័យ មិនត្រូវការ លះបង់នូវកាយស្អុយដែលពេញទៅដោយសាកសពផ្សេងៗ នេះចោល** ដូច្នេះជាដើម ។

ឆ្លើយថា ព្រះពោធិសត្វទាំងឡាយ និងបុគ្គលទាំងឡាយដទៃ មានតាបសជាដើម រមែងដឹងរាងកាយថា មិនស្អាតក៏ពិត តែមិនមែនដឹងដោយភាពជាកម្មដ្ឋាន ។

ព្រោះហេតុនោះឯង លោកអាចារ្យទើបពោលថា **វៀរចាកពុទ្ធុប្បាទចេញ** ដូច្នេះជាដើម ។ ពាក្យថា **រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្វេគ** ព្រោះធ្វើឲ្យដឹងសភាពរបស់រាងកាយតាមសេចក្តីពិត ។ ពាក្យថា **ដើម្បីប្រយោជន៍** គឺ ដើម្បីប្រយោជន៍ដែលជាទិដ្ឋធម្មិកៈជាដើម ។ ពាក្យថា **ដើម្បីក្សេមចាកយោគៈ** គឺ ដើម្បីក្សេមចាកយោគៈ ៤ ។ ពាក្យថា **ដើម្បីសតិនិងសម្បជញ្ញៈ** គឺ ដើម្បីការមិនប្រាសចាកសតិ និងសម្បជញ្ញៈ ដែលគួរដល់ឋានៈនៃសតិនិងសម្បជញ្ញៈក្នុងទីទាំងពួង ។

ពាក្យថា **ដើម្បីការបានមកនូវញាណទស្សនៈ** គឺ ដើម្បីការបានសម្រេចនូវវិបស្សនាញាណ ។ ពាក្យថា **ដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា វិមុត្តិ និង ផល** គឺ ដើម្បីការធ្វើឲ្យឃើញច្បាស់នូវធម៌ទាំងឡាយនេះ គឺ វិជ្ជា ៣ អធិមុត្តិនៃចិត្ត គឺ ព្រះនិព្វាន សាមញ្ញផល ៤ ។ ទ្រង់ត្រាស់ដល់កាយគតាសតិថា **អមត** ព្រោះជាហេតុនៃការសម្រេចអមតៈ គឺ ព្រះនិព្វាន និង ព្រោះការប្រព្រឹត្តទៅរួមជាមួយនឹងសេចក្តីសុខ មិនក្តៅក្រហាយ ដូចព្រះនិព្វានដែលជាអមតៈ ។ ពាក្យថា **បរិភោគ** គឺ ប្រើប្រាស ដោយការចូលឈាន ។ បទថា **បរិហីនំ** ប្រែថា វិនាសហើយ ។ ពាក្យថា ខកហើយ គឺ **ខកហើយ** ក៏ព្រោះការមិនបានសម្រេច ។ បទថា **អារទ្ធំ** ប្រែថា សម្រេចហើយ គឺ ធ្វើឲ្យកើតឡើងបានហើយ ។

ក្លាប់សេចក្តីថា កាយគតាសតិកម្មដ្ឋាននោះ ព្រះមានព្រះភាគ ទ្រង់សរសើរហើយ ដោយអនេកបរិយាយ ហើយទ្រង់សម្តែងទុកក្នុងព្រះសូត្រនោះៗ ។ ទ្រង់សម្តែងទុកក្នុងទីណាខ្លះ ? ឆ្លើយថា ក្នុងកាយគតាសតិសូត្រ ។ ពិតហើយ ក្នុងកាយ-គតាសតិសូត្រនោះ ទេសនានេះ មកហើយដោយពាក្យថា **ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលភិក្ខុចម្រើនហើយ** ដូចម្តេច ? ដូច្នេះជាដើម ។ តទៅនេះ ជាសេចក្តីសង្ខេប ក្នុងបាឋៈនៃកាយគតាសតិសូត្រនោះថា ម្នាលភិក្ខុទាំងឡាយ កាយគតាសតិភាវនា ភិក្ខុចម្រើនហើយដោយប្រការដូចម្តេច និងការធ្វើរឿយៗ ដោយប្រការដូចម្តេច ទើបមានផលច្រើន ដែលនាំឲ្យអានាបានស្សតិជាដើមកើតបាន និងមានអានិសង្សច្រើន ក្នុងធម៌ទាំងឡាយដែលគួរដឹងដ៏ក្រៃលែង និង គួរធ្វើឲ្យជាក់ច្បាស់ ជាផ្នែកនៃវិជ្ជាទាំងឡាយនោះៗ និង គុណទាំងឡាយ មានសេចក្តីអត់ធន់ចំពោះការប្រទូសរ៉ាយជាដើម ឲ្យសម្រេចបាន ។

ពាក្យថា **អានាបានបព្វ** គឺ អានាបានកម្មដ្ឋាន ។ សូម្បីក្នុងបព្វៈដ៏សេស ក៏មានន័យដូច្នេះដែរ ។

ដោយធាតុមនសិការកម្មដ្ឋាន ព្រះយោគាវចរ រមែងសម្រេចឧបចារសមាធិ ក៏ពិត សូម្បីដូច្នោះ ក្នុងធាតុមនសិការកម្មដ្ឋាននោះ វារៈនៃការពិចារណា ( ជាអនត្តា ) ប្រពៃជាង ព្រោះហេតុនោះ ធាតុមនសិការបព្វៈ លោកអាចារ្យពោលថា **ទ្រង់ត្រាស់ទុកទាក់ទងនឹងវិបស្សនា** ដូច្នេះ ។ លោកអាចារ្យពោលថា សិវថិកា ៩ បព្វៈ ។ ល ។ ទ្រង់ត្រាស់ទុកទាក់ទងនឹង អទីនវានុបស្សនា ដូច្នេះ ព្រោះព្រះទេសនាមកហើយ ទាក់ទងនឹងការបើកផ្សាយដល់ **អាទីនព្វ**( ទោស )ក្នុងកាយ ព្រមជាមួយនឹងភាពមិនស្អាត មិនទៀងជាដើម ក្នុងបព្វៈនោះៗថា កាយនេះមានសភាពដូចជាសាកសព នឹងក្លាយជាសាកសព មិនកន្លងសភាពជាយ៉ាងនោះឡើយ ។ ពាក្យថា **ក្នុងសាកសពហើមប៉ោងជាដើម ក្នុងបណ្តាសិវថិកាបព្វៈទាំងឡាយនេះ** មានន័យថា ក្នុងសពដែលហើមប៉ោងជាដើម ដែលមកហើយក្នុងសិវថិកាបព្វៈទាំងឡាយនេះ ។ ពាក្យថា **ទាក់ទងនឹងអានាបានស្សតិ** គឺ ទាក់ទងនឹងការបម្រើនអានាបានស្សតិ ។ លោកអាចារ្យកាលនឹងសម្តែងថា កោដ្ឋាស គឺ ខួរក្បាល លោកកាន់យក “ **អាហារចាស់ ខួរក្បាល** ” ដូច្នេះខាងដើម , ក្នុងព្រះបាលីក្នុងធអនុស្សតិនិទ្ទេសនេះ ទេសនាមកហើយ សង្គ្រោះយកកោដ្ឋាស គឺ ខួរក្បាលនោះ ចូលនឹងខួរឆ្អឹងនោះឯង ដូច្នេះទើបពោលថា សង្គ្រោះ យកខួរក្បាលចូលនឹងខួរឆ្អឹង ដូច្នេះ ។ ពាក្យថា **ក្នុងទីនេះ** គឺ ក្នុងអនុស្សតិនិទ្ទេសនេះ ។ ប្រកបសេចក្តីថា ទូតីយព្រាការកម្មដ្ឋាននេះ បំណងយកសតិជាប្រធាន សតិមានក្នុងកាយ ឬ ប្រព្រឹត្តទៅក្នុងកាយ ឈ្មោះថា **កាយ-គតាសតិ** ។

ដែលប្រកបដោយមហាភូតរូប៤ គឺ ដែលមានមហាភូតរូប៤ ជាទីអាស្រ័យ។ ពាក្យថា **កាយស្អុយ** បានដល់ កាយដែលជារបស់ស្អុយ មានក្លិនស្អុយដ៏ពន្លឹក ។ ទ្រង់ត្រាស់ថា **តាំងពីបាតជើងឡើងទៅ** ទ្រង់សំដៅយកសរីរៈដែលកំណត់ទុកដោយការឈរ ការដើរជាដើម , ឬ ព្រោះអត្ថថា ក្នុងបណ្តាអវយវៈទាំងឡាយនៃសរីរៈនោះ បាតជើងជាអវយវៈនៅក្រោមបំផុតនៃអវយវៈទាំងអស់ ។ ក្នុងពាក្យថា **ហ៊ុំព័ទ្ធដោយស្បែក** នេះ , សួរថា សក់ រោម ក្រចក និង ស្បែក គឺជា កោដ្ឋាសដែលមិនមានស្បែករុំព័ទ្ធ មិនមែនឬ ? ជាកោដ្ឋាសដែលមិនមានស្បែករុំព័ទ្ធ ក៏ពិតតែថា រាងកាយ ឈ្មោះថា ជាធម្មជាតិដែលមានស្បែករុំព័ទ្ធ ព្រោះកោដ្ឋាសភាគច្រើនមានស្បែករុំព័ទ្ធ ព្រោះហេតុនោះ ទើបលោកពោលទុកយ៉ាងនេះ ។ ម្យ៉ាងទៀត ពាក្យថា **កាយ** ឈ្មោះថា **តចបរិយន្ត** ព្រោះអត្ថថា មានស្បែកជាទីបំផុតដោយជុំវិញ ។ នេះជាការកាន់យកស្បែក ដែលជាចំណែកមួយនៃកាយ , រីឯកោដ្ឋាសទាំងឡាយ មានសក់ជាដើម ជាវត្ថុជាប់ទាក់ទងនឹងស្បែកនោះ មានគល់ដោតចូលទៅក្នុងស្បែកនោះ ទើបឈ្មោះថា មានស្បែកព័ទ្ធជុំវិញ ព្រោះហេតុនោះគប្បីជ្រាប ថា ប្រជុំនៃអាការ ៣២ គឺ កាយទាំងអស់ ហៅថា **តចបរិយន្ត** មានស្បែកជាទីបំផុត ដោយជុំវិញ ។

បទថា **អត្ថិ** ប្រែថា **មាន** ទ្រង់ត្រាស់ទុកជា វចនវិបល្លាស ឬថា បទនេះជាបទនិបាត , ព្រោះដូច្នោះ ក្នុងវចនៈទាំង ៣ គឺ ឯកវចនៈ ទ្វិវចនៈ និង ពហុវចនៈ គួរមានរូបជា **អត្ថិ** នេះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **សំវិជ្ជន្តិ** ប្រែថា **មាន** ។ លោកអាចារ្យកាលនឹងសម្តែងថា អាចារ្យអ្នកគិតអក្សរទាំងឡាយ កាលនឹងពណ៌នាសព្ទថា **កាយ** ទុកក្នុងន័យថា ជាសរីរៈ គប្បីសំដៅ

យកកាយដែលជាទីប្រជុំនៃវត្ថុមិនស្អាតនោះឯង ទើបពោលថា **ព្រោះជាទីសន្សំវត្ថុមិនស្អាត** ដូច្នេះហើយ កាលសម្ដែងកាយនោះ ជានិរុត្តិន័យទៀត ទើបពោលថា ( ព្រោះជាទីមក... ដែលគួរខ្ពើម ) ដូច្នេះជាដើម ។

ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **ព្រោះជាទីមក** គឺ ព្រោះជាស្ថានទីឧប្បត្តិ. លោកអាចារ្យធ្វើទុកក្នុងចិត្តថា ប្រការទាំងឡាយនោះ ដូចម្ដេច ? ដែលជាហេតុឲ្យទ្រង់ត្រាស់វត្ថុមិនស្អាត មានប្រការផ្សេងៗថា “ ពេញទៅដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ” ដូច្នេះហើយ កាលនឹងសម្ដែងខ្លឹមសារ នេះថា ទ្រង់បំណងសម្ដែងប្រការទាំងឡាយ មានសក់ជាដើមទាំងឡាយនោះ ទើបទ្រង់ត្រាស់ទុកក្នុងព្រះបាលីថា **កេសា លោមា** ជាដើម ទើបពោលថា បានដល់ អាការ ៣២ មានសក់ជាដើមនេះ ។ ពិតហើយ ពាក្យថា **អាការ ប្រការ** មានខ្លឹមសារតែមួយដូចគ្នា ។ ពាក្យថា ( គប្បីជ្រាប ) **សម្ពន្ធយ៉ាងនេះ** គឺ គប្បីជ្រាប សេចក្ដីសម្ពន្ធជាមួយនឹងបទទាំង ៣ គឺ **អត្ថិ ឥមស្មឹ កាយេ** ក្នុងកោដ្ឋាសទាំងពួង ដោយន័យថា **អត្ថិ ឥមស្មឹ កាយេ នខា** ក្នុងកាយនេះមានក្រចក ដូច្នេះជាដើម ។

បទថា **បរិតោ** ប្រែថា ខាងទទឹង ឬ ប្រែថា ដោយជុំវិញ ព្រោះបាតជើងនិងគល់សក់ ក៏មានស្បែក ។ ពាក្យថា **ជារបស់ស្អាត** គឺ ការមាននូវវត្ថុស្អាត ឬរបស់ស្អាតនោះឯង ។

ព្រះយោគាវចរ ជាអ្នកឆ្លាតក្នុងឧគ្គហៈ ( ការរៀនយក ) បានដោយវិធីណា វិធីនោះមាន ៧ យ៉ាង ហៅថា **ឧគ្គហកោសល្ល** , មយ៉ាងទៀត ការដឹងដែលបានមកដោយការរៀននោះ ហៅថា **ឧគ្គហកោសល្ល** ។ សូម្បីក្នុងមនសិការកោសល្ល ក៏មានន័យដូច្នេះ ។

ពាក្យថា **គប្បីស្វាធ្យាយ** គឺ គប្បីធ្វើការស្វាធ្យាយ ។ បានឮមកថា កាល លោកទាំង ២ នោះ ស្វាធ្យាយរហូតដល់ទៅ ៤ ខែ ក៏ចាំកោដ្ឋាសទាំងឡាយ តាម គន្ធដែលស្វាធ្យាយនោះឯង អាការ ៣២ ជាធម្មជាតិប្រាកដច្បាស់ក្រៃលែង ទៅ តាមលំដាប់ , លោកសម្រេចឈានក្នុងនិមិត្តដែលតាំងឡើង ដោយបដិកូលសញ្ញា នោះហើយ ក៏ចម្រើនវិបស្សនាដែលមានឈានជាបាទ បានចាក់ធ្លុះនូវទស្សនមគ្គ ( សោតាបត្តិមគ្គ ) ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **គប្បីស្វាធ្យាយ បានសម្រេចជាព្រះសោតាបន្ន** ។

ពាក្យថា **កំណត់** ( ជាពួក ៗ ) គឺ ធ្វើការកំណត់ដោយទាក់ទងជាពួក មាន តចបញ្ចកៈ ( ពួក ៥ ទាំងស្បែក ) ជាដើម ។ លោកពោលដល់មត្ថលុង្គៈ ( ខួរ ក្បាល ) ឲ្យមានការលើកឡើងកាន់ព្រះបាលី ជាខាងចុងបន្ទាប់ពីករីសៈ ( អាហារ ចាស់ ) ក៏ព្រោះមានបឋវីធាតុច្រើន ។ ក្នុងអាការទាំងឡាយនេះ ព្រះយោគាវចរ ស្វាធ្យាយក្នុងវក្កបញ្ចកៈ ( ពួក ៥ ទាំងទាច ) ជាដើម ដោយអនុលោមហើយ ក៏ ស្វាធ្យាយដោយបដិលោម ឲ្យមានការជាប់តគ្នាជាមួយពួកមុនៗ យ៉ាងនេះថា សាច់ សរសៃ ឆ្អឹង ខួរឆ្អឹង ទាច , ទាច ខួរឆ្អឹង ឆ្អឹង សរសៃ សាច់ , ស្បែក ធ្មេញ ក្រចក រោម សក់ ដូច្នេះ ។

ការស្វាធ្យាយនោះ ក្នុងសម្មោហវិនោទនី លោកពោលដល់ការស្វាធ្យាយ រយៈពេល ៣០ ថ្ងៃ ថា គប្បីធ្វើការស្វាធ្យាយកោដ្ឋាសមួយពួក ១៥ ថ្ងៃ ( ដោយ អនុលោម ៥ ថ្ងៃ , បដិលោម ៥ ថ្ងៃ , ទាំងអនុលោម ទាំងបដិលោម ៥ ថ្ងៃ ) គប្បីធ្វើការស្វាធ្យាយ ១៥ ថ្ងៃ ព្រមជាមួយនឹងពួកដំបូងៗ ដូច្នេះ ក្នុងសម្មោហវិ- នោទនីនោះ គប្បីឃើញថា លោកពោលដល់ការស្វាធ្យាយ ទាក់ទងនឹង ការសម្តែង

ខាងដើម និង ខាងចុងនៃការស្វាធ្យាយ ព្រោះក្នុងការស្វាធ្យាយ ទាំង អនុលោម ទាំងបដិលោម , ការស្វាធ្យាយដោយបដិលោម គឺជាការស្វាធ្យាយខាង ចុង , គប្បីជ្រាបថា ពាក្យពោលក្នុងសម្មោហវិនោទនីនេះ ជាការស្វាធ្យាយប្រការមួយទៀត ។

លោកពោលដល់ជួរម្រាមដៃថា **ហត្ថសន្ធលិកា** ។

លោកពោលដល់ ការនឹកគិតដោយចិត្ត ថា ការស្វាធ្យាយផ្លូវចិត្ត បាន ដល់ ចិត្តដែលហៅថា **ជប្បនំ** ( ការពោល គឺ ការគិត ) ន័យម្យ៉ាងទៀត ឈ្មោះថា **សជ្ឈាយ** ( ការស្វាធ្យាយ ) ព្រោះអត្ថថា ជាការសូត្រដោយប្រពៃនោះឯង , មានន័យថា ជាការគិត ។ របៀបកម្មដ្ឋានដែលជាធម្មជាតិស្ទាត់ជំនាញ ដោយការធ្វើឲ្យប្រព្រឹត្តទៅយ៉ាងល្អ អស់កាលដ៏យូរ ក្នុងទីណាៗ ក៏រមែងប្រាកដបាន ជាប់តគ្នាមិនដាច់ឡើយ តាំងពីដើមរហូតដល់ចប់ ដល់ព្រះយោគីដែលមនសិការ , សូម្បីសភាពនៃកម្មដ្ឋាននោះ ក៏ប្រាកដជាធម្មជាតិផ្សេងៗប្លែកគ្នា តាមទំនងនៃការមន-សិការនោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ការស្វាធ្យាយផ្លូវវាចា... ។ល។ ជាបច្ច័យនៃការចាក់ធ្លុះលក្ខណៈ** ។ ពាក្យថា **ដល់ការចាក់ធ្លុះលក្ខណៈ** គឺ ដល់ការ ចាក់ធ្លុះលក្ខណៈដែលមិនស្អាត ។

លោកអាចារ្យកាលសម្តែង ខ្លឹមសារថា សម្រាប់ព្រះយោគាវចរ ដែលមានការកំណត់សភាវៈជាបដិកូលរូបខ្លះ កោដ្ឋាសទាំងឡាយ ក៏កំណត់ដោយការកាន់យកពណ៌ជាសំខាន់ , រូបខ្លះកាន់យកដោយសណ្ឋានជាសំខាន់ , រូបខ្លះកាន់យកតាមទិសជាសំខាន់ , រូបខ្លះកាន់យកតាមឱកាសទីតាំងជាសំខាន់ រូបខ្លះកាន់យកដោយប្រការទាំងពួងជាសំខាន់ ព្រោះហេតុនោះ ការកំណត់ដោយពណ៌ជាដើម ទើប

ពោលបានថា ជាហេតុនាំមកនូវភាពជាអ្នកឆ្លាតក្នុងការរៀនយក ដូច្នោះ ទើបពោលថា គប្បីកំណត់ពណ៌របស់កោដ្ឋាសទាំងឡាយ មានសក់ជាដើម ដូច្នេះជាដើម ។

ចំណែករបស់ខ្លួន ឈ្មោះថា **សភាគ** , ការប្រកាសទីបំផុតដោយសភាគៈ ឈ្មោះថា **សភាគបរិច្ឆេទ** មានន័យថា ការប្រកាសទីបំផុតដោយចំណែកខាងក្រោម ខាងលើ ខាងទទឹង និងដោយសរសៃសក់ដទៃ ដែលរួមកោដ្ឋាសគ្នាជាដើម ។ ពាក្យថា **ទាក់ទងនឹងកោដ្ឋាសដែលមិនច្រឡំគ្នា** គឺ ដោយទាក់ទងនឹងកោដ្ឋាសដែលមិនលាយជាមួយនឹងកោដ្ឋាសដទៃៗ , ព្រោះលោកអាចារ្យសង្គ្រោះយក **អសភាគ** ( មិនមែនចំណែករបស់ខ្លួន ) ថាជា **វិសភាគ** ក្នុងទីនេះ , មិនបានបំណងយក **វិរុទ្ធសភាគ** ( មានចំណែកខុសគ្នា ) ថាជា **វិសភាគ** , ឯសេចក្តីនេះ រមែងបានដោយសព្ទថា **កេសា** ជាដើមនោះឯង , គឺថា សព្ទរមែងប្រកាសដល់អត្ថ ដោយអំណាចការធ្វើឲ្យផ្សេងពីអត្ថនៃសព្ទនោះ ព្រោះហេតុនោះ កាលពោលថា **កេសា** រមែងប្រាកដអត្ថថា ជាកោដ្ឋាសដែលមិនមែនកេសា ក៏មិនបាន , សួរថា កោដ្ឋាសដែលមិនមែនកេសាទាំងឡាយនោះ គឺអ្វី ? ឆ្លើយថា បានដល់ កោដ្ឋាសទាំងឡាយមានរោមជាដើម , ម្យ៉ាងទៀត ទោះនៅរួមគ្នា ក៏មិនច្រឡំជាមួយសក់ដែរ ព្រោះកោដ្ឋាសទាំងឡាយ មានលោមាជាដើមទាំងឡាយនោះ លោកហាមទុកហើយដោយបករណ៍នោះឯង ( ថា សក់មិនមែនរោម , រោមក៏មិនមែនសក់ជាដើម ) ។

ក្នុងមហាសតិប្បដ្ឋានសូត្រ ឈ្មោះថា ត្រាស់ទុកទាក់ទងនឹងបដិកូលនោះឯង ព្រោះមិនបានកាន់យកការចែកធាតុ សូម្បីជាកោដ្ឋាសស្មើគ្នា ( ជាធាតុ ) , ព្រោះក្នុងមហាសតិប្បដ្ឋានសូត្រនោះ ទ្រង់ត្រាស់ធាតុកម្មដ្ឋាន ជាកម្មដ្ឋានផ្សេងមួយទៀត ( មិនបានទាក់ទងនឹងកោដ្ឋាសទាំងឡាយនេះទេ ) បុក្កុសាតិសូត្រ និង ព្រះបាលីធាតុវិភង្គ

ក្នុងវិគ្គហករណ៍ ជាការចែកធាតុ ( គឺ ចែកកោដ្ឋាសទាំងឡាយជាធាតុ ៤ ) ។ សម្រាប់ព្រះយោគាវចរណា កោដ្ឋាសមានសក់ជាដើម ប្រាកដដោយពណ៌ ទ្រង់សំដៅយកព្រះយោគីនោះ ក៏ចែកឈាន មានវណ្ណកសិណក្នុងកោដ្ឋាស មានសក់ជាដើមជាអារម្មណ៍ ។ ពាក្យដែលលោកពោលថា **គួរជ្រាបហើយ ចូរប្រាប់ចុះ** មានន័យណា ដើម្បីសម្ដែងន័យនោះ ទើបពោលថា **ក្នុងសូត្រទាំងឡាយនោះ កម្មដ្ឋាននេះ ពោលទុកទាក់ទងនឹងធាតុ** ដូច្នេះជាដើម ។ បទថា **ឥធ** ប្រែថា ក្នុងបដិកូលមនសិការបព្វៈនេះ ។ ព្រោះលោកអាចារ្យកាន់យកបដិកូលមនសិការបព្វៈ ក្នុងកាយគតាសតិសូត្រ មកសម្ដែងអធិប្បាយក្នុងការចម្រើនកាយគតាសតិ ទុកក្នុងវិសុទ្ធិមគ្គនេះ ។

ពាក្យថា **ន ឯកន្តរិកាយ** អធិប្បាយថា មិនគប្បីមនសិការរំលងកោដ្ឋាសណាមួយ ចាំបាច់ពោលថ្វីដល់ទៅរំលង ២ កោដ្ឋាសជាដើមនោះ ។ សម្ព័ន្ធសេចក្ដីថា ធ្វើការនាឲ្យសម្រេចមិនបាន , គឺ មិនសម្រេចការចាក់ចុះលក្ខណៈ កាលមនសិការដោយការវៀរកោដ្ឋាសណាមួយ ។

បទថា **ឧក្កមនវិស្សជ្ជនំ** ប្រែថា ផ្លូវដែលគួរដើរ និង គួរលះបង់ ។ ឈ្មោះថា ត្រូវសួរគេរាល់ដង ទើបទៅបាន ក៏ព្រោះការមិនបានចំណាំស្ថានទី ដែលគួរកាន់យក និងមិនគួរកាន់យក ។ ពាក្យថា **កម្មដ្ឋាននឹងដល់ទីបញ្ចប់** អធិប្បាយថា នឹងមានការមនសិការទៅ តាំងពីដើមដល់ចប់បាន ។ ឈ្មោះថា តែថាជាធម្មជាតិមិនប្រាកដច្បាស់ ព្រោះមិនបានកំណត់ទុកឲ្យល្អ នូវអាការដែលជាបដិកូល , ព្រោះហេតុនោះ ទើបឈ្មោះថា មិននាំមកនូវគុណវិសេស ។

ពាក្យថា **កម្មដ្ឋាននឹងមិនដល់នូវទីបំផុត** មានន័យថា កាលមនសិការកោដ្ឋាស

ទាំងពួងទៅតាមលំដាប់តែម្យ៉ាង កោដ្ឋាសទាំងឡាយ ក៏គង់ប្រាកដច្បាស់បាន ។ កាលមនសិការកោដ្ឋាសទាំងឡាយនោះ ជាបដិកូលដ៏ក្រៃលែងហើយ កម្មដ្ឋាន ក៏អាចដល់ទីបំផុតបាន , តែកាលព្រះយោគីនោះមនសិការយឺតពេក ការប្រាកដ មកប្រាកដច្បាស់ ក៏មិនមាន , ការតាំងមាំជារបស់បដិកូលនឹងមានម្ដេចបាន ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **មិនជាបច្ច័យនៃការសម្រេចគុណ-វិសេស** ដូច្នេះ ។

ពាក្យថា **ក្នុងអារម្មណ៍មានសភាវៈច្រើនក្នុងខាងក្រៅ** មានន័យថា សូម្បីកោដ្ឋាសទាំងឡាយ មានសក់ជាដើម ដែលបុគ្គលប្រកាន់ថា ជារបស់ស្អាតជាដើម វៀរចាកការតាមពិចារណាឃើញថា មិនស្អាត ដែលគួរធ្វើឲ្យប្រព្រឹត្តទៅក្នុងកោដ្ឋាសទាំងឡាយ មានសក់ជាដើម ក្នុងន័យថា **មិនស្អាត ជាបដិកូល** ដូច្នេះ ក្នុងទីនេះគួរជ្រាបថា អារម្មណ៍ដែលជាសភាវៈច្រើន ក្នុងខាងក្រៅនោះឯង ។ ធម៌ទាំងឡាយមានរូបជាដើម , ឈ្មោះថា **អារម្មណ៍ជាសភាវៈច្រើន** ព្រោះមានសភាវៈច្រើនដោយទាក់ទងនឹងពណ៌ខៀវជាដើម បានដល់ អារម្មណ៍ផ្សេងៗ ។ ការមិនតាំងមាំដោយប្រពៃនៃចិត្ត ឈ្មោះថា **វិក្ខេប-សេចក្ដីរាយមាយ** ព្រោះអត្ថថា ជាការរាយ-មាយចាកពីរូប ។ **វិក្ខេប-ការរាយមាយ** នោះ ព្រះយោគាវចរ ដែលញ៉ាំងសតិចូលទៅតាំងមាំល្អហើយ មនសិការកម្មដ្ឋានដោយគោរព អាចការពារបាន ។ បទថា **បរិហាយតិ** រមែងវិនាស ។ ពាក្យថា **រមែងឆ្ងាយបាន** គឺ រមែងវិនាសបាន ។

ឈ្មោះថា បញ្ញត្តិថា **កេសា លោមា** ជាដើម បានដល់ បញ្ញត្តិដែលប្រព្រឹត្តទៅតាមការសម្គាល់របស់អ្នកស្រុក ។ ពាក្យថា **បញ្ញត្តិ** បានដល់ បញ្ញត្តិអាស្រ័យអាស្រ័យធម៌ ៨ យ៉ាង ។ ព្រះយោគាវចរឈានកន្លងបញ្ញត្តិ មានសក់ជាដើម ។

ពាក្យថា **ឈានកន្លង** បានដល់ ឈានកន្លង គឺ ដកចេញដោយបដិកូលភាវនា ។ កាលកោដ្ឋាសនោះ ៗ ប្រាកដជាបដិកូល ព្រោះព្រះយោគីដកចេញនូវបញ្ញត្តិនោះហើយ ក៏តាំងចិត្តទុកថា ជាបដិកូលចុះ ។ លោកអាចារ្យកាលបើកផ្ទាវខ្លឹមសារនោះដោយឧបមា ទើបពោលថា **យថា ហិ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះសេចក្តីប្រៀបឧបមា មានដូចតទៅនេះ ៖

ព្រះយោគាវចរប្រៀបដូចជាមនុស្សទាំងឡាយ , កោដ្ឋាសទាំងឡាយប្រៀបដូចត្រពាំងទឹក , បញ្ញត្តិថា សក់ជាដើម ប្រៀបដូចគ្រឿងសម្គាល់ មានស្លឹកត្នោតជាដើម ។

ការមនសិការជាខាងដើម ដោយអំណាចបញ្ញត្តិថា **កេសា លោមា** ជាដើមនៃព្រះយោគាវចរ ប្រៀបដូច ការងូត ការផឹកជាដើម នៅត្រង់ត្រពាំងទឹកនៃជនទាំងឡាយ តាមគ្រឿងសម្គាល់នោះ ។ កាលព្រះយោគាវចរ ឈានកន្លងបញ្ញត្តិដោយកម្លាំងនៃមនសិការ ហើយតាំងចិត្តទុកក្នុងភាពជាបដិកូលតែម្យ៉ាង បំពេញភាវនាទៅ ប្រៀបដូចមនុស្សទាំងឡាយធ្វើកិច្ចនៅត្រង់ត្រពាំងទឹក ដោយការវៀរចាកគ្រឿងសម្គាល់បាន ព្រោះមានការសញ្ចរទៅរឿយៗ ។

ពាក្យថា **កាលព្រះយោគី... ប្រាកដហើយ** ។ល។ ជាខាងដើម មានន័យថា កាលព្រះយោគីបំពេញភាវនាទៅក្នុងន័យថា **កេសា លោមា** ជាដើម , កាលបញ្ញត្តិថា **កេសា** ជាដើមនៅប្រាកដ ភាពជាបដិកូលនៃកោដ្ឋាសទាំងឡាយ ក៏ប្រាកដបណ្តើរៗជាខាងដើម ។ ពាក្យថា **លំដាប់នោះ** គឺ បន្ទាប់ពី បានដល់ ក្នុងវេលាដែលភាវនាប្រព្រឹត្តទៅតាមវិធីហើយ ។ ពាក្យថា **គួរតាំងចិត្តទុកក្នុងភាពជាបដិកូលតែម្យ៉ាង** គឺ ការបំពេញភាវនាចិត្តក្នុងអាការដែលជាបដិកូលនៃកោដ្ឋាសទាំងឡាយ

ប៉ុណ្ណោះ ។

ការប្រព្រឹត្តទៅតាមលំដាប់ ឈ្មោះថា **អនុបុព្វមុញ្ចនំ** មានន័យថា ការប្រព្រឹត្តតាមកោដ្ឋាស តែលះបង់កោដ្ឋាសដែលមិនប្រាកដ ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា កោដ្ឋាសទាំងឡាយមានការមិនប្រាកដយ៉ាងណា ដូច្នេះ ហើយទើបពោលថា ពិតហើយ **សម្រាប់ព្រះយោគីដែលជាអាទិកម្មិកៈ** ដូច្នេះជាដើម ។ ពាក្យថា រហូតដល់កោដ្ឋាសចុងក្រោយ ហើយឈប់ ដូច្នេះ លោកអធិប្បាយថា ការមនសិការកម្មដ្ឋាន រមែងប្រព្រឹត្តទៅពីខាងដើម តាមទំនងថា នោះជាកម្មដ្ឋាន ។ ពិតហើយ សម្រាប់ព្រះយោគីជាអាទិកម្មិកៈ មនសិការរមែងប្រព្រឹត្តទៅ ធ្វើកោដ្ឋាសទាំងឡាយនោះ ៗ ឲ្យជាការកាន់យកបានហើយ ដូចការស្វាធ្យាយដោយចិត្ត , មិនមែនប្រព្រឹត្តទៅដោយការកំណត់លក្ខណៈនោះទេ , តែក្នុងពេលណា ព្រះយោគីមនសិការ ពិចារណាកោដ្ឋាសទាំងឡាយនោះ យ៉ាងល្អហើយ ទាក់ទងនឹងការកំណត់លក្ខណៈ , ក្នុងវេលានោះកោដ្ឋាសខ្លះនឹងប្រាកដ កោដ្ឋាសខ្លះមិនប្រាកដ ។ លោកអាចារ្យកាលសម្ដែងវិធីបដិបត្តិ ក្នុងកោដ្ឋាសដែលប្រាកដ និងមិនប្រាកដទាំងឡាយនោះ ទើបពោលថា **អថស្ស** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា ( គួរធ្វើ ) **កម្ម** បានដល់ គួរធ្វើកម្ម គឺ មនសិការមុន ៗ គួរធ្វើយូរប៉ុណ្ណា ? ឆ្លើយថា គួរធ្វើរហូតដល់កោដ្ឋាស ២ ប្រាកដ , សូម្បីកោដ្ឋាស ២ នោះ មានកោដ្ឋាសមួយប្រាកដច្បាស់ជាង ។

ពាក្យថា **លោតឡើងត្រង់គ្រប់ៗ កន្លែងដែលស្រែកដេញប៉ុណ្ណោះ** បានដល់ ពួនហើយ លោតឡើងទៅដើមត្នោតគ្រប់ដើមតាមលំដាប់ ព្រោះសំឡេងស្រែកដែលព្រានធ្វើឡើងនៅត្រង់ដើមត្នោតមួយដើម ៗ ដូចដើមត្នោតខាងដើម រហូតដល់

ដើមត្នោតចុងក្រោយ ហើយត្រឡប់មកដើមត្នោតខាងដើមវិញ ហើយលោតឡើង ត្រង់ដើមត្នោតខាងដើមនោះ ព្រោះសំឡេងស្រែកដេញដែលព្រានធ្វើឡើង នៅត្រង់ដើមត្នោតនោះៗឯង ។

ពាក្យថា **ភិក្ខុ ២** គឺ ភិក្ខុដែលបានត្រង់ផ្លូវ ២ ខ្នង ។

បទថា **ដោយអប្បនា** គឺ ដោយអាការ ( ដែលជាទីកើតឡើង ) នៃអប្បនា ។ ក្នុងវិចារដែលថា **អប្បនា** រមែងកើតឡើងក្នុងអាការ ៣២ ។ រមែងកើតឡើងក្នុងកោដ្ឋាស តែមួយកោដ្ឋាស ឬ ដោយប្រការដទៃ ដូច្នេះ លោកអាចារ្យពោលថា គឺ ដោយកោដ្ឋាសដែលជាទីកើតឡើងនៃអប្បនា ដូច្នេះ , មានន័យថា ដោយកោដ្ឋាស តែមួយកោដ្ឋាស ( ដែលជាទីកើតឡើងនៃអប្បនា ) ។ ព្រោះហេតុនោះ លោកទើបពោលថា ( គប្បីជ្រាបថា ) ក្នុងកោដ្ឋាសទាំងឡាយ មានសក់ជាដើម ដូច្នេះជាដើម ។

ពាក្យថា **អធិចិត្ត** បានដល់ សមថចិត្ត និង វិបស្សនាចិត្ត ។

បទថា **អនុយុត្តេន** ប្រែថា អ្នកប្រកបត្រូវ មានន័យថា អ្នកចម្រើន ។ ពាក្យថា **តាមកាលដែលគួរ** គឺ ក្នុងកាលតែមួយកាល ។ ឈ្មោះថា **សមាធិនិមិត្ត** បានដល់ សមាធិដែលភិក្ខុកំណត់អាការតាំងមាំដោយប្រពៃបានហើយនោះឯង ។ ពាក្យថា **គប្បីមនសិការ** គឺ គប្បីធ្វើទុកក្នុងចិត្ត មានន័យថា គប្បីធ្វើឲ្យកើតឡើងៗ ម្យ៉ាងទៀត អារម្មណ៍ដែលជាហេតុនៃសមាធិ ឈ្មោះថា **សមាធិនិមិត្ត** មានន័យថា គប្បីនឹកដល់អារម្មណ៍ ដែលជាហេតុនៃសមាធិនោះ ។ សូម្បីក្នុងបគ្គហនិមិត្ត និង ឧបេក្ខានិមិត្ត ក៏មានន័យដូច្នេះដែរ ។ នៅមានពាក្យនិយាយទៀតថា **ឋានំ អត្ថិ** គឺ ( បាលី ប្រាកដត្រឹម **ឋានន្តំ** , ពាក្យពេញជា **ឋានំ អត្ថិ តំ** ) ។ សេចក្តីថា

ការនាចិត្តនោះ នឹងប្រព្រឹត្តទៅដើម្បីកោសជ្ជៈ , **ឋានៈ** គឺ ហេតុនៃការប្រព្រឹត្តទៅនេះ មានហើយ ។ ម្យ៉ាងវិញទៀត មានសេចក្ដីថា មនសិការចិត្តនោះ នឹងប្រព្រឹត្តទៅដើម្បីកោសជ្ជៈ , **ឋានៈ** គឺ ហេតុនៃការប្រព្រឹត្តទៅនេះ មានហើយ ។ ពាក្យថា ( **រមែងជាចិត្តដែល** ) **ទន់ភ្លន់** គឺ ជាធម្មជាតិដែលទន់ភ្លន់ ព្រោះបានអប់រំល្អហើយ មានន័យថា ជាចិត្តដែលដល់នូវភាពជាវសី ។ ព្រោះភាពទន់ភ្លន់នោះឯង ទើបជា **កម្មញ្ញ** គឺ គួរដល់ការងារ សមគួរដល់ការងារ ។ ពាក្យថា **ផូរផង់** គឺ បរិសុទ្ធ ព្រោះប្រាសចាកឧបក្កិលេស មានន័យថា សដោយជុំវិញ ។ ពាក្យថា **នឹងមិនបែក** គឺ មិនមានការរឹងត្អឹង ជាសភាវៈ ព្រោះចូលដល់ភាពជាចិត្តគួរដល់ការងារ បានដល់ គួរដល់ការងារ ដូចមាសដែលដុតល្អហើយ ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា រមែងតាំងមាំដោយប្រពៃ ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ ។

ពាក្យថា **រមែងបង្កាត់ភ្លើង** គឺ រមែងធ្វើឡូឲ្យសម្រេច ។ ពាក្យថា **រមែងសប់** គឺ រមែងផ្លុំភ្លើងឲ្យឆេះឡើង ។ បទថា **តញ្ច** មានន័យថា វត្ថុដែលត្រូវការ គឺ ប្រយោជន៍ ពោលគឺ ការធ្វើគ្រឿងប្រដាប់នោះ គេរមែងបានទទួល គឺ អាចសម្រេចដល់ជាងទងនេះ ម្យ៉ាងទៀត ជាងទងរមែងបានទទួល គឺ សម្រេចបានវត្ថុដែលជាប្រយោជន៍របស់មាស ។

ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយ អភិញ្ញា គឺ ដោយញាណ មានឥទ្ធិវិធ-ញាណជាដើម ដែលមានការសម្ដែងឫទ្ធិបានជាផល ដែលបានទទួលតបមកវិញជាដើម ឈ្មោះថា **អភិញ្ញាសច្ឆិករណីយ** ។ បុគ្គលណា មានការធ្វើឲ្យឃើញប្រចក្ស បុគ្គលនោះ ឈ្មោះថា **សក្ខី** ។ សេចក្ដីថា **អ្នកសមគួរជាសក្ខីបុគ្គល** ឈ្មោះថា **សក្ខិភព្វតា** , មានអធិប្បាយថា បានដល់ ការបានជាសក្ខីបុគ្គល ។

ន័យម្យ៉ាងទៀត **បុគ្គល** ឈ្មោះថា **សក្ខិភព្វ** ព្រោះអត្ថថា ទាំងជាសក្ខីបុគ្គល និង ភព្វបុគ្គល ។ បុគ្គលនេះជាអ្នកសមគួរដល់ការសម្ដែងឫទ្ធិបាទជាដើម , និងជាអ្នក មានការធ្វើឲ្យឃើញប្រចក្ស ក្នុងការសម្ដែងឫទ្ធិជាដើមនោះ ព្រោះហេតុនោះ ទើប ឈ្មោះថា **សក្ខិភព្វបុគ្គល** , ភាពជាសក្ខិភព្វបុគ្គលនោះ ឈ្មោះថា **សក្ខិភព្វតា** , លោករមែងបានសម្រេចភាពជាសក្ខិភព្វបុគ្គលនោះ ។ ពាក្យថា **ក្នុងកាលហេតុ នោះៗ មានហើយ** គឺ ក្នុងកាលហេតុ មានហេតុក្នុងភពមុនជាដើម មានហើយ ។

ពាក្យថា **សីតិភាវ** បានដល់ ព្រះនិព្វាន , ឬបានដល់ គុណជាតិដែលចូល ទៅស្ងប់សេចក្ដីក្រហល់ក្រហាយ គឺ កិលេស ។ ពាក្យថា **រមែងគ្រប់សង្កត់** គឺ រមែងគ្រប់សង្កត់ចិត្តដែលរាយមាយ ដោយការរក្សាមិនឲ្យធ្លាក់ទៅក្នុងឧទ្ធច្ចៈ ។

ពាក្យថា **រមែងលើក** គឺ រមែងលើកចិត្តដែលរួញរា ទាក់ទងនឹងការរក្សា មិនឲ្យធ្លាក់ទៅក្នុងកោសជ្ជៈ ។ ពាក្យថា **រមែងធ្វើឲ្យរីករាយ** គឺ រមែងប្រើបញ្ញា ដែលមានការប្រព្រឹត្តទៅយ៉ាងនោះ ធ្វើចិត្តឲ្យប្រព្រឹត្តទៅស្មើល្អហើយ ឲ្យត្រេកអរ ( ក្នុងភាវនា ) បានដល់ ជំរុញ ។ ម្យ៉ាងទៀត កាលណាចិត្តប្រាសចាកសេចក្ដី រីករាយ មិនស្ទុះទៅក្នុងភាវនា , ក្នុងវេលានោះ ភិក្ខុគួរពិចារណាសង្វេគវត្ថុ មាន ជាតិជាដើម ធ្វើឲ្យរីករាយ គឺ ជំរុញដោយប្រពៃ ។

ពាក្យថា **រមែងព្រងើយ** មានន័យថា រីឯក្នុងវេលាណា ដែលចិត្តមិនរួញរា មិនរាយមាយ ជាធម្មជាតិដែលឈានចុះកាន់ភាវនាវិថី ដោយប្រពៃហើយ ក្នុងវេលា នោះ ភិក្ខុមិនគួរធ្វើសេចក្ដីព្យាយាមណាៗ ក្នុងការលើក ការគ្រប់សង្កត់ និងការធ្វើ ឲ្យរីករាយ រមែងព្រងើយ គឺ ជាអ្នកព្រងើយតែម្យ៉ាង ដូចនាយសារថីព្រងើយ ក្នុង សេះដែលទឹមក្នុងរថ ដែលរត់ទៅស្មើល្អហើយដូច្នោះ ។ ពាក្យថា **ជាអ្នកមានអធិ-**

**មុត្តិដ៏ប្រណីត** បានដល់ ជាអ្នកបង្អោន គឺ ផ្អៀងទៅ ឱនទៅ ទោរទៅ ក្នុងមគ្គនិងផលដ៏ប្រណីត គឺ ឧត្តម ។

ពាក្យថា **ធ្វើការកាន់យក ឲ្យជាការកាន់យកដោយល្អ** គឺ ការធ្វើវិធី ដែលហៅថា ឧគ្គហកោសល្យ តាមដែលពោលហើយ ឲ្យជាការរៀនយកដោយល្អ គឺ ឲ្យជាការកាន់យកដោយល្អ ដោយការរៀនជាដើម ។ ពាក្យថា **កំណត់ទុកដោយល្អ** គឺ ចងចាំទុកដោយល្អ ដោយអំណាចការកំណត់វិធី ដែលហៅថា **មនសិការកោសល្យ** ដោយប្រពៃ ។ ពាក្យថា **គុណវិសេស** គឺ គុណវិសេសនៃការទាជាប់តគ្នាទៅ ។ ពាក្យថា **សាចុះឡើង ដដែលៗ** មានន័យថា ធ្វើរបៀបកម្មដ្ឋានឲ្យដល់ភាពស្ទាត់ជំនាញ សាចុះឡើងតាមផ្លូវវាចា និង ផ្លូវចិត្តឲ្យក្រៃលែងឡើងទៅ ។

ពាក្យថា **ឋានៈដែលជាក្រម៉** មានន័យថា ជារបស់ដែលជម្រះបានដោយលំបាកនៃដើមឈើ ឬដែលជាព្រៃចាក់ស្រែះ ក៏គេហៅថា **គណ្ឋិដ្ឋាន** ( ក្រម៉ ) យ៉ាងណា , រីឯ ភាពស្មុគស្មាញលំបាកដោយអត្ថ ឬភាពសាំញ៉ាំនៃរបៀបកម្មដ្ឋាន លោកក៏ហៅថា **គណ្ឋិដ្ឋាន** ដូច្នោះដែរ ។ ព្រះយោគីប្រើពូថៅ គឺ បញ្ញាដែលបានដោយការសាកសួរជាដើម ជម្រះឋានៈដែលជាក្រម៉នោះចេញ ។

ពាក្យថា **និមិត្ត** បានដល់ និមិត្តនៃកម្មដ្ឋាន គឺ អាការដែលមិនស្អាត ។ លោកអាចារ្យពោលពាក្យថា “ ដកសក់ ” ដើម្បីសម្តែងថា សូម្បីការដក ព្រោះប្រយោជន៍នេះ មិនមានទោសទេ ( មិនត្រូវអាបត្តិ ) ។ ពាក្យថា **នៅកន្លែងកាត់សក់** គឺ នៅកន្លែងកោរសក់ ។ ឈ្មោះថា **ប្រើបានដូចគ្នា** ព្រោះជាការមើល ដោយមានអជ្ឈាស្រ័យក្នុងធម៌ ចេញចាកទុក្ខ ។ ពាក្យថា **ដោយអំណាចនៃពណ៌ដែលច្រើន** គឺ ដោយអំណាចនៃសក់មិនសូវមានស្កូវច្រើន ឬសក់ដែលស្កូវច្រើន ។

ឈ្មោះថា **ព្រះយោគីត្រូវឃើញហើយ ទើបកាន់យកនិមិត្តបាន** ព្រោះតចបញ្ចកៈ ជាកម្មដ្ឋានដែលសមគួរសម្រាប់ការមើល , ក្នុងកម្មដ្ឋានក្រៅពីនេះ ត្រូវស្តាប់ ហើយយល់ ទើបកាន់យកនិមិត្តបាន ។

( ចប់ មហាដីកា )

# ការកំណត់កោដ្ឋាស

( តទៅនេះ ) ជាអនុបុព្វិកថា ក្នុងការកំណត់ ( លក្ខណៈ និង ភាពជាបដិកូល ) ក្នុងកោដ្ឋាសទាំងពួង ៖

## កេសា – សក់

ជាបឋម **កេសា** – សក់ទាំងឡាយ , **ដោយពណ៌ប្រក្រតី** ជាពណ៌ខ្មៅ ដូចពណ៌ផ្លែផ្កាំស្រស់ៗ **ដោយសណ្ឋាន** វែង មូល ដូចសណ្ឋានជញ្ជីង , **ដោយទិស** កើតក្នុងទិសខាងលើ ( នៃរាងកាយ ) , **ដោយឱកាស** ( ទីតាំង ) ប្រតិស្ឋាននៅត្រង់ស្បែកព័ទ្ធលលាដ៏ក្បាល ផ្នែកសងខាងកំណត់ត្រឹមគុម្ពត្រចៀក ផ្នែកខាងមុខត្រឹមថ្ងាស ផ្នែកខាងក្រោយត្រឹមកញ្ចឹងក ជាឱកាសនៃសក់ទាំងឡាយ , **ដោយបរិច្ឆេទ** សក់ទាំងឡាយ ខាងក្រោមមានទីបំផុតត្រឹមឫសរបស់ខ្លួន ដែលដុះចាក់ចូលទៅក្នុងស្បែកក្បាលមួយចុងគ្រាប់ស្រូវ ខាងលើមានទីបំផុតដោយអាកាសខាងៗមានទីបំផុត ដោយសក់គ្នាឯង ការកំណត់ទីបំផុតក្នុងន័យថា “ សក់ ២ សរសៃមិនជាប់គ្នា ” នេះជា **សភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយចំពោះខ្លួនឯង , សក់ទាំងឡាយនោះ ធម្មតា មកមិនបានប្រឡំជាមួយកោដ្ឋាសដ៏សេស ៣០ ទៀតក្នុងន័យថា **សក់មិនមែនរោម រោមក៏មិនមែនសក់** ដូច្នេះ ការកំណត់ទីបំផុតថាកោដ្ឋាសនោះជាផ្នែកមួយផ្សេង នេះជា **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដែលផ្សេងពីខ្លួនឯង នេះជា ការកំណត់ទីបំផុតដោយលក្ខណៈ មានពណ៌ជាដើមនៃសក់ទាំងឡាយ ។

តទៅនេះ ជាការកំណត់ដោយភាពជាបដិកូល ៥ យ៉ាង តាមប្រការ មាន

ពណ៌ជាដើមនៃសក់ទាំងឡាយនោះ ៖

សក់នោះ ដោយពណ៌ក៏បដិកូល ទាំងដោយសណ្ឋាន ដោយក្លិន ដោយទីអាស្រ័យ ដោយឱកាស ក៏បដិកូល អធិប្បាយថា បុគ្គលទាំងឡាយឃើញវត្ថុណាៗដែលមានពណ៌ស្រដៀងសក់ ក្នុងភាជន៍បាយ ឬ ភាជន៍បបរ ក៏ដោយ សូម្បីជារបស់គាប់ចិត្ត ក៏ទៅជាគួរខ្ពើម នឹងប្រាប់ថា **វាលាយសក់ យកវាចេញទៅ** សក់ទាំងឡាយជារបស់បដិកូល ដោយពណ៌ យ៉ាងនេះ ។

ម្យ៉ាងទៀត បុគ្គលទាំងឡាយបរិភោគអាហារកណ្ដាលយប់ កាលបើប៉ះត្រូវសរសៃផ្ចិត ឬ សរសៃព្រលដែលមានសណ្ឋានដូចសក់ ក៏មានការខ្ពើមកើតឡើងដូចគ្នា សក់បដិកូលដោយសណ្ឋាន យ៉ាងនេះឯង ។

ម្យ៉ាងទៀត ក្លិនរបស់សក់ដែលវៀរចាកការតុបតែង មានលាបប្រេង និងអប់ផ្កាឈើជាដើម រមែងគួរខ្ពើមក្រៃពេក ក្លិនរបស់សក់ដែលត្រូវភ្លើងឆេះ ស្អុយជាងនោះទៅទៀត ពិតហើយ សក់ទាំងឡាយ ដោយពណ៌និងសណ្ឋានអាចមិនជាបដិកូលបាន តែបើ ដោយក្លិនហើយ បដិកូលតែម្យ៉ាង ឧបមាដូចជាឧច្ចារៈរបស់ទារកដែលមានពណ៌ដូចល្មៀត សូម្បីសណ្ឋាន ក៏មានសណ្ឋានដូចខ្ទែងល្មៀត និងសាកសពសុនខខ្មៅដែលហើមហើយ គេបោះចោលនៅកន្លែងចោលសំរាម ដោយពណ៌ ពណ៌វាដូចពណ៌ផ្លែត្នោតទុំ ដោយសណ្ឋាន មានសណ្ឋានដូចស្គរដែលគេរមៀល ចង្កូមរបស់វា មានសណ្ឋានដូចផ្កាម្លិះក្រពុំ ព្រោះដូច្នេះហើយ ឧច្ចារៈទារកនិង សាកសពសុនខខ្មៅ ទាំង ២ យ៉ាង ដោយពណ៌និងសណ្ឋាន គង់មិនបដិកូលក៏បាន តែដោយក្លិនបដិកូលជាប្រាកដ យ៉ាងណា សូម្បីសក់ក៏ដូច្នោះ ដោយពណ៌និង សណ្ឋាន គង់មិនបដិកូលក៏បាន តែពោលដោយក្លិនហើយ បដិកូលយ៉ាងពិត

ប្រាកដ ។

ម្យ៉ាងទៀត បន្លែសម្រាប់ស្ល ដែលដុះនៅក្នុងទីកខ្វក់ដោយទឹកជ្រាំ ដែលហូរទៅពីក្នុងភូមិ រមែងជារបស់គួរខ្ពើម មិនគួរបរិភោគសម្រាប់អ្នកក្រុង យ៉ាងណា សូម្បីសក់ក៏ដូច្នោះ ឈ្មោះថា គួរខ្ពើម ព្រោះដុះដោយទឹក ដែលហូរចេញមកពីកោដ្ឋាស មានខ្ទុះ ឈាម មូត្រ ករីសៈ ទឹកប្រមាត់ និង ស្លេស្មជាដើម នេះឯងជាភាពបដិកូល ដោយទីអាស្រ័យនៃសក់ទាំងឡាយនោះ ។

ម្យ៉ាងទៀត សក់ទាំងឡាយនេះ ដុះក្នុងគំនរកោដ្ឋាស ៣១ ដូចបន្លែដែលដុះក្នុងគំនរលាមក វាជារបស់គួរខ្ពើមក្រៃលែង ព្រោះកើតក្នុងទីមិនស្អាត ដូចបន្លែដែលដែលដុះក្នុងទីកខ្វក់ទាំងឡាយ មានព្រៃខ្មោច និងកន្លែងចោលសំរាមជាដើម និងដូចផ្កាឈើ មានផ្កាឈូក និងព្រលិតជាដើម ដែលដុះក្នុងទីមិនស្អាតទាំងឡាយ មានស្នាមក្ដោះជាដើម នេះជាភាពបដិកូលដោយឱកាសនៃសក់ទាំងឡាយនោះ ។

ព្រះយោគាវចរ គប្បីកំណត់ភាពបដិកូល ៥ យ៉ាង ដោយពណ៌ សណ្ឋាន ក្លិន ទីអាស្រ័យ និង ឱកាស នៃកោដ្ឋាសទាំងពួង ដូចការកំណត់បដិកូលនៃសក់ទាំងឡាយដូច្នេះចុះ តែបើពោលដោយលក្ខណៈ គឺ ពណ៌ សណ្ឋាន ទិស ឱកាស និង បរិច្ឆេទ ត្រូវកំណត់ផ្សេងៗពីគ្នា គ្រប់កោដ្ឋាស ។

## លោមា-រោម

ក្នុងកោដ្ឋាសទាំងឡាយនោះ គប្បីកំណត់ **លោមា - រោមទាំងឡាយ** រោមតាមប្រក្រតី មានប្រមាណ ៩០.០០០ រណ្ដៅ **ដោយពណ៌ប្រក្រតី** មិនខ្មៅដូចសក់ទេ តែខ្មៅលាយលឿង , **ដោយសណ្ឋាន** មានចុង-ង សណ្ឋានដូចឫសត្នោត ,

**ដោយទិស** កើតក្នុងទិសទាំង ២ , **ដោយឱកាស** វៀរឱកាសដែលសក់ដុះ និង បាតដៃបាតជើង កើតនៅតាមស្បែកដែលស្រោបសរីរៈខាងក្រៅ ដោយច្រើន , **ដោយបរិច្ឆេទ** ខាងក្រោមមានទីបំផុតត្រឹមឫសរបស់ខ្លួន ដែលដុះចាក់ចូលទៅក្នុងស្បែកហ៊ុំសរីរៈ ប្រមាណ ១ លិក្ខា ខាងលើមានទីបំផុតដោយអាកាស ខាងៗមានទីបំផុតដោយរោមគ្នាឯង ការកំណត់ទីបំផុតក្នុងន័យថា រោម ២ សរសៃមិនជាប់គ្នាជាសរសៃ ១ នេះជា **សភាគបរិច្ឆេទ** គឺ ការប្រកាសទីបំផុតក្នុងចំណែករបស់ខ្លួននៃរោមទាំងឡាយនោះ , រីឯ **វិសភាគបរិច្ឆេទ** ការប្រកាសទីបំផុតក្នុងចំណែកដែលផ្សេងគ្នា ក៏ដូចគ្នានឹងសក់នោះដែរ ។

## នខា – ក្រចក

ពាក្យថា **នខា** – ក្រចកទាំងឡាយ ជាឈ្មោះនៃស្លឹកក្រចក ២០ , ក្រចកទាំងពួងនោះ **ដោយពណ៌** ជាពណ៌ស , **ដោយសណ្ឋាន** មានសណ្ឋានដូចស្រកាត្រី , **ដោយទិស** កើតក្នុងទិសទាំង ២ គឺ ក្រចកជើងកើតក្នុងទិសខាងក្រោម ក្រចកដៃកើតក្នុងទិសខាងលើ , **ដោយឱកាស** តាំងនៅលើខ្នងចុងម្រាមទាំងឡាយ , **ដោយបរិច្ឆេទ** ក្នុងទិសទាំង ២ កំណត់ទីបំផុតដោយសាច់ចុងម្រាម ខាងក្នុងកំណត់ទីបំផុតដោយសាច់ខ្នងម្រាម ខាងក្រៅនិងចុងកំណត់ទីបំផុតដោយអាកាស ខាងទទឹងកំណត់ដោយក្រចកគ្នាឯង , ការកំណត់ទីបំផុតក្នុងន័យថា " ក្រចក ២ សន្លឹក មិនជាប់គ្នាតែមួយ " នេះជា **សភាគបរិច្ឆេទ** គឺ ការប្រកាសទីបំផុតដោយចំណែករបស់ខ្លួននៃក្រចកទាំងឡាយនោះ , រីឯ **វិសភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយភាពផ្សេងគ្នា ក៏ដូចជាការកំណត់សក់នោះដែរ ។

## ទន្តា – ធ្មេញ

ពាក្យថា **ទន្តា – ធ្មេញទាំងឡាយ** គឺ ឆ្អឹងធ្មេញ ៣២ សម្រាប់អ្នកមានធ្មេញគ្រប់បរិបូរ សូម្បីធ្មេញទាំងឡាយនោះ **ដោយពណ៌** មានពណ៌ស , **ដោយសណ្ឋាន** មានសណ្ឋានច្រើនយ៉ាង , ពិតហើយ បណ្តាធ្មេញទាំងឡាយនោះ ធ្មេញ ៤ គ្រាប់កណ្តាលជួរធ្មេញខាងក្រោម មានសណ្ឋានដូចគ្រាប់ឃ្លោក ដែលគេដោតជាជួរនៅលើដីឥដ្ឋ , ២ សងខាងធ្មេញ ៤ នោះ ធ្មេញមួយមានឫសមួយ ចុងក៏មានមួយ សណ្ឋានដូចផ្កាម្លិះក្រពុំ , បន្ទាប់ពីនោះទៅ ធ្មេញមួយៗ មានឫស ២ ចុងក៏មាន ២ មានសណ្ឋានដូចជន្ទល់រទេះ , បន្ទាប់ពីនោះទៅ ធ្មេញខាង ២ មួយៗ មានឫស ៣ ចុងក៏មាន ៣ , បន្ទាប់ពីនោះទៅ ធ្មេញខាង ២ មួយៗ មានឫស ៤ ចុងក៏មាន ៤ សូម្បីជួរលើក៏មានន័យដូចគ្នា , **ដោយទិស** ធ្មេញនោះកើតក្នុងទិសខាងលើ , ដោយឱកាសតាំងនៅក្នុងឆ្អឹងថ្គាមទាំង ២ , **ដោយបរិច្ឆេទ** ខាងក្រោមមានទីបំផុតត្រឹមឫសរបស់ខ្លួន តាំងនៅក្នុងឆ្អឹងថ្គាម ខាងលើមានទីបំផុតដោយអាកាស ខាងទទឹងមានទីបំផុតដោយធ្មេញគ្នាឯង ការកំណត់ទីបំផុតក្នុងន័យថា " ធ្មេញ ២ មិនជាប់គ្នាតែមួយ " នេះជា **សភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយចំណែករបស់ខ្លួននៃធ្មេញទាំងឡាយនោះ , រីឯ **វិសភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយភាពផ្សេងគ្នា ក៏ដូចគ្នានឹងការកំណត់សក់ដែរ ។

## តចោ – ស្បែក

ពាក្យថា **តចោ – ស្បែក** គឺ ស្បែកដែលស្រោបរាងកាយទាំងមូល ស្បែកនោះ ក៏មានវត្ថុដែលឈ្មោះថា ឆវី – ពណ៌ មានពណ៌ផ្សេងៗ ដូចជា ខ្មៅ លាយ

លឿង បើបកចេញពីរាងកាយឲ្យអស់ ( រមូរជាដុំ ) មានប្រមាណ ប៉ុនផ្លែពុទ្រា តែស្បែក **ដោយពណ៌** ក៏មានពណ៌សប៉ុណ្ណោះ , តែពណ៌សនោះនឹងប្រាកដ កាលដែលឆវីរលាត់ ដោយហេតុ មានអណ្តាតភ្លើង និងត្រូវគ្រឿងប្រហារជាដើម , **ដោយសណ្ឋាន** មានសណ្ឋានដូចរាងកាយនោះឯង នេះជាសេចក្តីសង្ខេបក្នុងន័យថា ដោយសណ្ឋាន ។

## សណ្ឋានស្បែកផ្សេងៗ

រីឯ ដោយពិស្តារ **ស្បែកម្រាមជើង** មានសណ្ឋានដូចសំបុកដង្កូវនាង , **ស្បែកខ្នងជើង** មានសណ្ឋានដូចស្បែកជើងក្រវ៉ាត់កែង , **ស្បែកស្មងជើង** មានសណ្ឋានដូចស្លឹកត្នោតខ្ចប់បាយ , **ស្បែកភ្លៅ** មានសណ្ឋានដូចទែប្រកអង្ករ , **ស្បែកត្រគាក** មានសណ្ឋានដូចសំពត់ត្រងទឹកដែលពេញដោយទឹក , **ស្បែកខ្នង** មានសណ្ឋានដូចស្បែកស្រោបខែល , **ស្បែកពោះ** មានសណ្ឋានដូចស្បែកស្រោបស្នូកពិណ , **ស្បែកទ្រូង** ដោយច្រើន មានសណ្ឋានដូចសំពត់បួនជ្រុង , **ស្បែកកដៃទាំងពីរ** មានសណ្ឋានដូចស្បែកស្រោបបំពង់ព្ធួ , **ស្បែកខ្នងដៃ** មានសណ្ឋានដូចស្រោមកាំបិត ឬ ដូចស្រោមខែល , **ស្បែកម្រាមដៃ** មានសណ្ឋានដូចស្រោមកូនសោ , **ស្បែក ក** មានសណ្ឋានដូចអាវបិទក , **ស្បែកមុខ** មានរន្ធធំតូច មានសណ្ឋានដូចសំបុកកណ្តូប , **ស្បែកក្បាល** មានសណ្ឋានដូចស្លោកបាត្រ ។

## វិធីកំណត់ស្បែក

ព្រះយោគាវចរ កំណត់ស្បែកជា ( អារម្មណ៍ ) គប្បីបញ្ជូនញាណទៅខាងមុខ តាំងពីរីមបបូរមាត់លើ ឡើងទៅ ហើយកំណត់ស្បែកស្រោបមុខជាមុន បន្ទាប់

ពីនោះ ទើបកំណត់ស្បែកស្រោបឆ្អឹងថ្ពាស បន្ទាប់មកទើបបញ្ជូនញាណទៅចន្លោះលលាដ៏ក្បាល និង ស្បែកក្បាល ដូចស៊កដៃចូលទៅចន្លោះបាត្រដែលមានស្នោក ដូច្នោះ ដោយញែកស្បែកដែលជាប់គ្នានិងលលាដ៏ក្បាលចេញពីគ្នា កំណត់តែស្បែកក្បាល បន្ទាប់ពីនោះកំណត់ស្បែកក បន្ទាប់មកកំណត់ស្បែកដៃខាងស្តាំ ដោយអនុលោមនិងបដិលោម រួចហើយ កំណត់ដៃឆ្វេងក្នុងន័យដូចគ្នា បន្ទាប់មកកំណត់ស្បែកខ្នង កាលកំណត់ស្បែកខ្នងនោះហើយ ទើបកំណត់ស្បែកជើងស្តាំ ដោយអនុលោមនិងបដិលោម ហើយក៏កំណត់ស្បែកជើងឆ្វេងក្នុងន័យដូចគ្នា បន្ទាប់ពីនោះកំណត់ស្បែកពោះតូច ស្បែកពោះខាងមុខ ស្បែកទ្រូង ស្បែកក តាមលំដាប់ ហើយកំណត់ស្បែកក្រោមថ្គាម ពីស្បែកកឡើងទៅរហូតដល់រឹមបបូរមាត់ក្រោម ជាទីបំផុត ទើបចប់ ។ កាលព្រះយោគាវចរកំណត់ស្បែកធំៗ បានយ៉ាងនេះហើយ សូម្បីស្បែកតូចៗ ក៏រមែងប្រាកដដែរ , **ដោយទិស** ស្បែកកើតក្នុងទិសទាំង ២ , **ដោយឱកាស** វាស្រោបរាងកាយទាំងមូល , **ដោយបរិច្ឆេទ** ខាងក្រោមកំណត់ដោយផ្ទៃដែលវាតាំងនៅ ខាងលើកំណត់ដោយអាកាស នេះឯងជា **សភាគបរិច្ឆេទ** ការកំណត់បរិច្ឆេទដោយចំណែករបស់ខ្លួន , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដែលផ្សេងគ្នា ក៏មានន័យដូចសក់នោះឯង ។

## មំសំ – សាច់

ពាក្យថា **មំសំ - សាច់** គឺ សាច់ ៩០០ ដុំ , **ដោយពណ៌** មានពណ៌ក្រហមដូចផ្កាចា , **ដោយសណ្ឋាន សាច់កំភួនជើង** មានសណ្ឋានដូចបាយខ្ចប់ដោយស្លឹកត្នោត , **សាច់ភ្លៅ** មានសណ្ឋានដូចអង្រែថ្មុ , **សាច់ត្រគាក** មានសណ្ឋានដូច

ជុំចង្កេះ , **សាច់ខ្នង** មានសណ្ឋានដូចផែនត្នោត , **សាច់ឆ្អឹងជំនីទាំង ២ ខាង** មានសណ្ឋានដូចជញ្ជាំងជង្រុកស្រូវដែលបូកដោយដីឥដ្ឋស្តើងៗ , **សាច់ដោះទាំង ២** មានសណ្ឋានដូចដីឥដ្ឋដែលគេលុញ ហើយវាជក់ចុះ , **សាច់ដើមដៃទាំង ២** មានសណ្ឋានដូចកណ្ដុរប្រែង ដែលគេបកស្បែក ធ្វើទុកជា ២ ចំណែក , កាលព្រះយោគាវចរកំណត់សាច់ធំៗបានយ៉ាងនេះហើយ សូម្បីសាច់តូចៗក៏នឹងប្រាកដដែរ , **ដោយទិស** សាច់នោះកើតក្នុងទិសទាំង ២ , **ដោយឱកាស** វាជាប់នៅតាមឆ្អឹង ៣០០ កំណាត់ , **ដោយបរិច្ឆេទ** ខាងក្រោម មានទីបំផុតត្រឹមទីតាំងគ្រោងឆ្អឹង ខាងលើមានទីបំផុតត្រឹមស្បែក ខាងទទឹងមានទីបំផុតដោយសាច់គ្នាឯង នេះជា **សភាគបរិច្ឆេទ** គឺ ទីបំផុតដោយចំណែកនៃសាច់ខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ទីបំផុតដែលផ្សេងពីខ្លួន ក៏ដូចគ្នានឹងសក់នោះឯង ។

## ៩ហារូ – សរសៃ

បទថា **នហារូ - សរសៃទាំងឡាយ** គឺ សរសៃ ៩០០ សរសៃ , **ដោយពណ៌** សរសៃទាំងពួង មានពណ៌ស , **ដោយសណ្ឋាន** មានសណ្ឋានផ្សេងៗ ពិតហើយក្នុងសរសៃទាំងឡាយ សរសៃធំចងសរីរៈចាប់ពីលើ ត្រឹមកចុះទៅ ផ្នែកខាងមុខ ៥ សរសៃ , ខាងក្រោយ ៥ សរសៃ , ខាងស្ដាំ ៥ សរសៃ , ខាងឆ្វេង ៥ សរសៃ , សូម្បីចងរឹតដៃស្ដាំ ខាងមុខដៃ ៥ សរសៃ , ខាងក្រោយដៃ ៥ សរសៃ ចងរឹតដៃឆ្វេងក៏ដូចគ្នា , ចងរឹតជើងស្ដាំ ខាងមុខជើង ៥ សរសៃ ខាងក្រោយជើង ៥ សរសៃ សូម្បីជើងឆ្វេង ក៏យ៉ាងនោះដូចគ្នា , ហើយសរសៃធំ ៦០ សរសៃនេះ បានឈ្មោះថា **សរីរធារកា** ( សរសៃទ្រទ្រង់រាងកាយ ) ចងទប់កាយឲ្យមាំ

ឬ លោកហៅថា **កណ្ឌរា** សរសៃពួរខ្វះ ។ សរសៃទាំងឡាយទាំងពួងនោះ មានសណ្ឋានដូចលំពង់ដើមគុណ្ឌលមកុល ចំណែកសរសៃពួកដទៃ ចងចំណែកនោះៗហើយតាំងនៅ , ដែលតូចជាងសរសៃ សរីរធារកានោះ មានសណ្ឋានដូចសរសៃអំបោះ , សរសៃពួកដទៃដែលតូចជាងនោះ មានសណ្ឋានដូចវល្លិផោម , សរសៃពួកដទៃដែលតូចជាងនោះទៀត មានសណ្ឋានដូចខ្សែពិណធំ , សរសៃពួកដទៃទៀត មានសណ្ឋានដូចអំបោះរីកៗ , សរសៃខ្នងដៃនិងជើង មានសណ្ឋានដូចជើងបក្សី , សរសៃក្បាល មានសណ្ឋានដូចសំណាញ់គ្របក្បាលទារក , សរសៃខ្នងមានសណ្ឋានដូចអួនសើម ដែលគេសន្ធឹងហាលថ្ងៃ , សរសៃនៅ តាមអង្គាវយវៈធំតូចនោះដ៏សេស មានសណ្ឋានដូចអាវសំណាញ់ដែលពាក់ពីក្រៅ , **ដោយទិស** សរសៃកើតក្នុងទិសទាំង ២ , **ដោយឱកាស** វាតោងជាប់ឆ្អឹងក្នុងរាងកាយទាំងអស់ , **ដោយបរិច្ឆេទ** ខាងក្រោមមានទីបំផុតស្ថិតនៅលើឆ្អឹង ៣០០ កំណាត់ ខាងលើកំណត់ដោយប្រទេសដែលតាំងនៅទល់សាច់និងស្បែក ខាងទទឹង មានទីបំផុតដោយសរសៃគ្នាឯង នេះជា **សភាគបរិច្ឆេទ** ការប្រកាសទីបំផុតដែលជាចំណែកនៃសរសៃខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយចំណែកផ្សេងគ្នា ដូចគ្នានឹងសក់នោះឯង ។

## អដ្ឋិ – ឆ្អឹង

ពាក្យថា **អដ្ឋី** – ឆ្អឹងទាំងឡាយ គឺ លើកលែងឆ្អឹងធ្មេញ ៣២ ចេញ ដ៏សេសជាឆ្អឹងប្រមាណ ៣០០ កំណាត់ គឺ ៖

| | | | |
|---|---|---|---|
| ១-ឆ្អឹងប្រអប់ដៃ | ៦៤ | ២-ឆ្អឹងប្រអប់ជើង | ៦៤ |

| | | | |
|---|---|---|---|
| ៣-ធ្អឹងខ្ទីជាប់សាច់ | ៦៤ | ៤-ធ្អឹងកែងជើង | ២ |
| ៥-ធ្អឹងកជើង(ភ្នែកគោរ) | ៤ | ៦-ធ្អឹងស្មងជើង | ៤ |
| ៧-ធ្អឹងជង្គង់ | ២ | ៨-ធ្អឹងភ្លៅ | ២ |
| ៩-ធ្អឹងចង្កេះ | ២ | ១០-ធ្អឹងខ្នង | ១៨ |
| ១១-ធ្អឹងជំនី | ២៤ | ១២-ធ្អឹងទ្រូង | ១៤ |
| ១៣-ធ្អឹងប៉ាំងបេះដូង | ១ | ១៤-ធ្អឹងដងកាំបិត | ២ |
| ១៥-ធ្អឹងស្មាបប្រចៀវ | ២ | ១៦-ធ្អឹងដើមដៃ | ២ |
| ១៧-ធ្អឹងកំភួនដៃ | ៤ | ១៨-ធ្អឹងក | ៧ |
| ១៩-ធ្អឹងចង្កា | ២ | ២០-ធ្អឹងច្រមុះ | ១ |
| ២១-ធ្អឹងប្រឡង់ភ្នែក | ២ | ២២-ធ្អឹងត្រចៀក | ២ |
| ២៣-ធ្អឹងថ្ពាស | ១ | ២៤-ធ្អឹងបង្ហើយ | ១ |
| ២៥-ធ្អឹងលលាដ៍ក្បាល | ៩ | | |

ធ្អឹងទាំងពួងនោះ **ដោយពណ៌** មានពណ៌ស , **ដោយសណ្ឋាន** មានសណ្ឋានផ្សេងៗ , ពិតហើយ ធ្អឹងទាំងឡាយនោះ ធ្អឹងម្រាមជើងផ្នែកខាងចុង មានសណ្ឋានដូចគ្រាប់ផ្លែជីប៉ី ធ្អឹងកណ្តាលបន្ទាប់ពីចុង មានសណ្ឋានដូចគ្រាប់ខ្នុរ ធ្អឹងខាងគល់ មានសណ្ឋានដូចស្គរមុខ ២ របស់ពួកព្រាហ្មណ៍ , ធ្អឹងខ្នងជើង មានសណ្ឋានដូចបាច់នៃគល់វល្លិ ដែលគេដំហើយ , ធ្អឹងកែងជើង មានសណ្ឋានដូចកំពឹងត្នោតក្នុងប្រឡង់មួយ , ធ្អឹងកជើង មានសណ្ឋានដូចគ្រាប់អង្គញ់ផ្តោបគ្នា , ធ្អឹងស្មងជើង ដែលនៅពីលើ-កជើង មានសណ្ឋានដូចលំពង់ឈើដែលបកសម្បកចេញ , ធ្អឹងស្មងកំណាត់តូច មានសណ្ឋានដូចធ្នូ , ធ្អឹងស្មងកំណាត់ធំ មានសណ្ឋានដូចខ្នងពស់

ក្រៀមៗ , ឆ្អឹងជង្គង់ មានសណ្ឋានដូចព្រួចទឹកដែលផតទៅម្ខាង , ឆ្អឹងស្មងដែល ទល់នឹងជង្គង់ មានសណ្ឋានដូចស្នែងគោចុងទាល , ឆ្អឹងភ្លៅ មានសណ្ឋានដូចដង កាំបិតព្រា ឬ ដងពូថៅដែលគគ្រាត , ឆ្អឹងភ្លៅដែលទល់នឹងឆ្អឹងចង្កេះ មានសណ្ឋាន ដូចផ្លែអង្គញ់ , ឆ្អឹងចង្កេះដែលទល់នឹងឆ្អឹងភ្លៅនោះ មានសណ្ឋានដូចផ្លែបុស្សនាគធំ ស្រួចចុង , ឆ្អឹងចង្កេះទាំង ២ កំណាត់ តែជាប់គ្នា មានសណ្ឋានដូចចង្ក្រានរបស់ ជាងផ្ទាំង បើបែកតែមួយៗ មានសណ្ឋានដូចដង្កាប់របស់ជាងមាស , ឆ្អឹងត្រគាក ផ្នែកខាងចុង មានសណ្ឋានដូចពពារពស់ដែលគេចាប់ឲ្យផ្កាប់មុខ មានប្រហោងតូច ធំ ៧-៨ កន្លែង , ឆ្អឹងខ្នងខាងក្នុង មានសណ្ឋានដូចក្រវិលសំណដែលដាក់តម្រួត គ្នា , ឆ្អឹងខ្នងខាងក្រៅ មានសណ្ឋានដូចគ្រាប់អង្កាំ ក្នុងចន្លោះនៃឆ្អឹងខ្នងនោះៗ មាន បន្លួញ ២-៣ ដែលដូចធ្មេញរណា , បណ្តាឆ្អឹងជំនី ២៤ កំណាត់ ដែលមិនពេញ ( ខ្លី ) មានសណ្ឋានដូចផ្លែកណ្តៀវត្រកង , ដែលពេញ ( វែងទល់គ្នា ) មាន សណ្ឋានដូចផ្លែកណ្តៀវត្រកាត់ ទាំងអស់មានសណ្ឋានដូចស្លាប.នរបស់មាន់សំឡី , ឆ្អឹងទ្រូង ១៤ កំណាត់ មានសណ្ឋានដូចរបាំគ្រែស្នែងដែលចាស់ , ឆ្អឹងបាំងបេះដូង មាន សណ្ឋានដូចវែក , ឆ្អឹងដងកាំបិត មានសណ្ឋានដូចដងកាំបិតលោហៈតូច , ឆ្អឹងស្លាបប្រចៀវ មានសណ្ឋានដូចចបអ្នកស្រុកសីហឡៈដែលរិលទៅម្ខាង , ឆ្អឹង ដើមដៃ មានសណ្ឋានដូចដងវែនតា ផ្នែកខាងចុងមានសណ្ឋានដូចឫសត្នោតក្មេះ , ឆ្អឹងកដៃ មានសណ្ឋានដូចកងបន្ទះសំណដែលគេត្រួតគ្នា , ឆ្អឹងខ្នងដៃ មានសណ្ឋាន ដូចបាច់នៃគល់រលិដែលគេជំហើយ , ឆ្អឹងម្រាមដៃត្រង់គល់ មានសណ្ឋានដូចស្គរ មុខ ២ របស់ពួកព្រាហ្មណ៍ , ឆ្អឹងម្រាមកណ្តាល មានសណ្ឋានដូចគ្រាប់ខ្នុរស្ទើ , ឆ្អឹង ម្រាមកំណាត់ខាងចុង មានសណ្ឋានដូចគ្រាប់ផ្លែដីប៉ី , ឆ្អឹងក ៧ កំណាត់ មាន

សណ្ឋានដូចកំណាត់ទំពាំង ដែលគេប្រើឈើដោតជាចង្កាក់ , ឆ្អឹងថ្គាមក្រោម មានសណ្ឋានដូចដង្កាប់ដែករបស់ជាងលោហៈ ខាងលើ មានសណ្ឋានដូចដែកខ្ទោះ , ឆ្អឹងរន្ធភ្នែក និងឆ្អឹងរន្ធច្រមុះ មានសណ្ឋានដូចប្រឡង់គ្រាប់ត្នោតខ្ចីដែលខ្វេះសាច់ចេញហើយ , ឆ្អឹងថ្ងាស មានសណ្ឋានដូចសម្បកស័ង្ខដែលផ្កាប់មុខ , ឆ្អឹងត្រចៀក មានសណ្ឋានដូចស្រោមកាំបិតកោររបស់ជាងកាត់សក់ , ឆ្អឹងដែលតាំងនៅជាប់គ្នាជាផ្ទាំងផ្នែកខាងលើឆ្អឹងថ្ងាសនិងឆ្អឹងត្រចៀក មានសណ្ឋានដូចសំពត់ជ្រួញ ដែលត្រាំទៅដោយទឹកដោះស្រស់ , ឆ្អឹងបង្ហើយ មានសណ្ឋានដូចបំណែកត្រឡោកដូងដែលគេកាត់ទទឹងពីខាងមុខ , ឆ្អឹងលលាដ៏ក្បាល មានសណ្ឋានដូចត្រឡោកឃ្លោកចាស់ដែលគេដេរភ្ជាប់គ្នា , **ដោយទិស** ឆ្អឹងកើតក្នុងទិសទាំង ២ , **ដោយឱកាស** មិនខុសគ្នា វាស្ថិតនៅទូទាំងរាងកាយ តែបើខុសគ្នា ក្នុងឆ្អឹងទាំងឡាយនោះ ឆ្អឹងក្បាលតាំងនៅលើឆ្អឹងក ឆ្អឹងកតាំងនៅលើឆ្អឹងខ្នង ឆ្អឹងខ្នងតាំងនៅលើឆ្អឹងចង្កេះ ឆ្អឹងចង្កេះតាំងនៅលើឆ្អឹងភ្លៅខ្ចី ឆ្អឹងភ្លៅខ្ចីតាំងនៅលើឆ្អឹងជង្គង់ ឆ្អឹងជង្គង់តាំងនៅលើឆ្អឹងស្មងឆ្អឹងស្មងតាំងនៅលើឆ្អឹងកជើង ឆ្អឹងកជើងតាំងនៅលើឆ្អឹងខ្នងជើង , **ដោយបរិច្ឆេទ** ខាងក្នុងមានទីបំផុតត្រឹមខួរឆ្អឹង ខាងក្រៅមានទីបំផុតត្រឹមសាច់ ខាងចុងនិងគល់មានទីបំផុតត្រឹមឆ្អឹងគ្នាឯង នេះជា **សភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយចំណែកនៃឆ្អឹងខ្លួនឯងទាំងឡាយនោះ , រីឯ **វិសភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយភាពខុសគ្នា ក៏ដូចសក់នោះដែរ ។

## អដ្ឋិមិញ្ជំ - ខួរឆ្អឹង

ពាក្យថា **អដ្ឋិមិញ្ជំ - ខួរក្នុងឆ្អឹង** គឺ ខួរដែលនៅដោយចំពោះក្នុងឆ្អឹងទាំង-

ឡាយនោះ ។ ខួរក្នុងឆ្អឹងនោះ **ដោយពណ៌** មានពណ៌ស , **ដោយសណ្ឋាន** ខួរដែលនៅក្នុងឆ្អឹងកំណាត់ធំ ៗ មានសណ្ឋានដូចចុងផ្តៅធំ ដែលគេរោលភ្លើងស៊ីកទុកក្នុងបំពង់ឫស្សី ខួរដែលនៅក្នុងឆ្អឹងកំណាត់តូចៗ មានសណ្ឋានដូចចុងផ្តៅតូចៗ ដែលគេរោលភ្លើងហើយស៊ីកទុកក្នុងបំពង់ដើមបបុស , **ដោយទិស** កើតក្នុងទិសទាំង ២, **ដោយឱកាស** តាំងនៅក្នុងឆ្អឹង , **ដោយបរិច្ឆេទ** មានទីបំផុតដោយផ្ទៃខាងក្នុងនៃឆ្អឹងទាំងឡាយ នេះជា **សភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយចំណែកខ្លួនឯងនៃខួរឆ្អឹងទាំងឡាយនោះ , រីឯ **វិសភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយភាពផ្សេងគ្នា ក៏ដូចគ្នានឹងសក់ទាំងឡាយដែរ ។

## វក្កំ–ទាច (តម្រងបស្សាវៈ)

ពាក្យថា **វក្កំ - ទាច** បានដល់ ដុំសាច់ ២ ដុំ មានទងតែមួយ ទាចនោះ **ដោយពណ៌** មានពណ៌ក្រហមព្រឿងដូចពណ៌គ្រាប់រលួសបាយ , **ដោយសណ្ឋាន** មានសណ្ឋានដូចផ្លែអង្គញ់ក្មេងរបស់ក្មេងៗ , ឬ មានសណ្ឋានដូចផ្លែស្វាយ២ មានទងជាមួយគ្នា , **ដោយទិស** កើតក្នុងទិសខាងលើ , **ដោយឱកាស** វាជាដុំសាច់ដែលជាប់នឹងសរសៃធំ មានគល់សរសៃតែមួយ ដែលបែកចេញពីបំពង់កទៅបន្តិចហើយបែកជា ២ សរសៃ រុំព័ទ្ធបេះដូង , **ដោយបរិច្ឆេទ** ទាចក៏កំណត់ទីបំផុតដោយចំណែកនៃខ្លួន នេះជា **សភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយចំណែកខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នា ដូចគ្នានឹងសក់នោះឯង ។

## ហទយំ – បេះដូង

ពាក្យថា **ហទយំ** គឺ **សាច់បេះដូង** , បេះដូងនោះ **ដោយពណ៌** មានពណ៌ក្រហមដូចពណ៌ខាងខ្នងនៃត្របកផ្កាឈូក , **ដោយសណ្ឋាន** មានសណ្ឋានដូចផ្កាឈូកក្រពុំ ដែលគេបកត្របកខាងក្រៅចេញ ហើយព្យួរចុងចុះក្រោម ខាងក្រៅរាបស្មើរលោង ខាងក្នុងដូចជាខាងក្នុងនៃផ្លែននោងព្រៃ របស់អ្នកមានបញ្ញា រីកបន្តិច របស់អ្នកបញ្ញាអន់ ក្រពុំធម្មតា ម្យ៉ាងទៀត ក្នុងបេះដូងនោះ មានប្រហោងអាចបញ្ចុះផ្លែបុស្សនាគបាន ជាកន្លែងផ្ទុកលោហិតប្រមាណកន្លះទូកដៃ ដែលមនោធាតុ និងមនោវិញ្ញាណធាតុអាស្រ័យកើតឡើង ឯលោហិតនោះ របស់បុគ្គលរាគចរិត មានពណ៌ក្រហម , របស់បុគ្គលទោសចរិត មានពណ៌ខ្មៅ , របស់បុគ្គលមោហចរិត មានពណ៌ដូចទឹកលាងសាច់ , របស់បុគ្គលវិតក្កចរិត មានពណ៌ដូចទឹកស្ងោរពពាយ , របស់មនុស្សសទ្ធាចរិត មានពណ៌ដូចផ្កាកណ្ណិកា , របស់មនុស្សពុទ្ធិចរិត មានពណ៌ថ្លាយង់ មិនល្អក់ សបរិសុទ្ធ ប្រាកដមានពណ៌ដូចកែវមណីដែលគេច្នៃហើយ , **ដោយទិស** កើតក្នុងទិសខាងលើ , **ដោយឱកាស** តាំងនៅត្រង់កណ្តាលនៃដោះទាំងពីរ ខាងក្នុងសរីរៈ , **ដោយបរិច្ឆេទ** បេះដូងមានទីបំផុតដោយចំណែកខ្លួនឯងនេះជា **សភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយចំណែកនៃបេះដូងខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយភាពខុសគ្នា ដូចគ្នានឹងសក់នោះឯង ។

## យកនំ – ថ្លើម

ពាក្យថា **យកនំ - ថ្លើម** បានដល់ បន្ទះដុំសាច់ដែលចែកជាពីរ ថ្លើមនោះ **ដោយពណ៌** មានពណ៌ក្រហមលាយលឿង មិនក្រហមសុទ្ធដូចត្របកផ្កាឈូក

ក្រហមនោះទេ , **ដោយសណ្ឋាន** មានគល់ជាបន្ទះដុំសាច់មួយ ខាងចុងចែកជាពីរ មានសណ្ឋានដូចស្លឹករលួសផ្អុង , ម្យ៉ាងទៀត ថ្លើមនោះ របស់បុគ្គលល្ងង់ ជាបន្ទះដុំសាច់តែមួយដុំ របស់អ្នកមានបញ្ញា រមែងមាន ២ ឬ ៣ បន្ទះក៏មាន , **ដោយទិស** វាកើតក្នុងទិសខាងលើ , **ដោយឱកាស** តាំងនៅត្រង់ចន្លោះដោះទាំង ២ ផ្អៀងទៅនៅខាងស្តាំ , **ដោយបរិច្ឆេទ** ថ្លើមមានទីបំផុតដោយចំណែករបស់ខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃថ្លើមខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយភាពខុសគ្នា ក៏ ដូចសក់នោះឯង ។

## កិលោមកំ-វាវ

ពាក្យថា **កិលោមកំ - វាវ** បានដល់ សាច់សម្រាប់ស្រោប មាន ២ ប្រភេទ ដោយចែកជា វាវប្រាកដឲ្យឃើញ និង វាវមិនប្រាកដឲ្យឃើញ វាវទាំង ២ នោះ **ដោយពណ៌** មានពណ៌សដូចពណ៌សំពត់ទុកូលចាស់ , **ដោយសណ្ឋាន** មានសណ្ឋានតាមឱកាស ( ទីអាស្រ័យ ) របស់ខ្លួន , **ដោយទិស** វាវប្រភេទ **បដិច្ឆន្ន** ( មិនប្រាកដឲ្យឃើញ ) កើតក្នុងទិសខាងលើ , វាវប្រភេទ **អបដិច្ឆន្ន** ( ប្រាកដឲ្យឃើញ ) កើតក្នុងទិសទាំង ២ , **ដោយឱកាស** វាវបដិច្ឆន្នៈតាំងនៅស្រោបបេះដូងនិងទាច , វាវអបដិច្ឆន្នៈ ពាសនៅលើសាច់ ក្រោមស្បែកក្នុងសរីរៈទាំងអស់ , **ដោយបរិច្ឆេទ** ខាងក្រោមកំណត់ត្រឹមសាច់ ខាងលើកំណត់ត្រឹមស្បែក ខាងទទឹងកំណត់ដោយវាវគ្នាឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃវាវខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយភាពខុសគ្នា ក៏ដូចគ្នានឹងសក់នោះឯង ។

## បិហកំ–ក្រពះ

ពាក្យថា **បិហកំ - ក្រពះ** បានដល់ សាច់មានសណ្ឋានដូចអណ្តាត នៅក្នុងពោះ ក្រពះនោះ **ដោយពណ៌** មានពណ៌ដូចពណ៌ម៉ៃ ( ខៀវចាស់ ) ដូចពណ៌ផ្កាគន្ទិស , **ដោយសណ្ឋាន** មានសណ្ឋានតាមឱកាស វាតាំងនៅលើផ្ទៃពោះចំហៀងខាងឆ្វេងនៃបេះដូង កាលវានោះចេញមកខាងក្រៅ ព្រោះត្រូវគេប្រហារដោយសស្ត្រា សត្វទាំងឡាយក៏នឹងត្រូវអស់ជីវិត , **ដោយបរិច្ឆេទ** ក្រពះនោះមានទីបំផុតដោយចំណែកនៃខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នា ដូចគ្នានឹងសក់នោះឯង ។

## បប្ផាសំ–សួត

ពាក្យថា **បប្ផាសំ - សួត** បានដល់ សាច់សួតជាសាច់តូច ៗ ៣២ ដុំ សួតនោះ **ដោយពណ៌** មានពណ៌ក្រហមដូចផ្លែល្វាស្រគាល , **ដោយសណ្ឋាន** មានសណ្ឋានដូចដុំនំក្រាស់ៗ ដែលគេកាត់មិនស្មើ សួតនោះ វាជាសាច់ដែលស្ងួកស្ងាំង ដូចកម្ទេចស្លឹកឈើដែលមនុស្សទំពាហើយ ព្រោះវាត្រូវកម្តៅដែលកើតពីកម្មដុតរោលហើយ ព្រោះក្នុងសួតនោះមិនមានវត្ថុដែលបរិភោគចូលទៅ ឬផឹកចូលទៅឡើយ , **ដោយទិស** វាកើតក្នុងទិសខាងលើ , **ដោយឱកាស** វាគ្របដណ្តប់បេះដូង និងថ្លើម ព្យួរជាប់នៅរវាងដោះទាំង ២ ខាងក្នុងរាងកាយ , **ដោយបរិច្ឆេទ** វាមានទីបំផុតដោយចំណែកខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតនៃចំណែកខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នា ក៏ដូចសក់នោះឯង ។

## អន្តំ - ពោះវៀនធំ

ពាក្យថា **អន្តំ - ពោះវៀនធំ** បានដល់ របស់មនុស្សប្រុសប្រវែង ៣២ ហត្ថ របស់មនុស្សស្រីប្រវែង ២៨ ហត្ថ បត់ជាក្នាត់ ២១ ក្នាត់ ពោះវៀនធំនោះ **ដោយពណ៌** មានពណ៌សដូចដុំក្រួស(ស) ឬ កំបោរ-ស , **ដោយសណ្ឋាន** មានសណ្ឋានដូចពស់ដែលត្រូវគេកាត់ក្បាល ធ្លាយទុកក្នុងស្នូកឈាម , **ដោយទិស** កើតក្នុងទិសទាំង ២ , **ដោយឱកាស** តាំងនៅក្នុងរាងកាយ មានចុងម្ខាងជាប់នឹងក ចុងម្ខាងទៀតជាប់នឹងទ្វារធំ ព្រោះផ្នែកខាងលើ វាជាប់នឹងបំពង់ក ផ្នែកខាងក្រោមជាប់នឹងទ្វារធំ , **ដោយបរិច្ឆេទ** មានការកំណត់ទីបំផុតដោយពោះវៀនធំខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការមានទីបំផុតដោយភាពខុសគ្នា ក៏ដូចនឹងសក់នោះឯង ។

## អន្តគុណំ - ពោះវៀនតូច

ពាក្យថា **អន្តគុណំ - ពោះវៀនតូច** គឺជា ពោះវៀនដែលព័ទ្ធនៅតាមក្នាត់នៃពោះវៀនធំ ពោះវៀនតូចនោះ **ដោយពណ៌** មានពណ៌ស ដូចក្រអៅឈូក , **ដោយសណ្ឋាន** មានសណ្ឋានដូចក្រអៅឈូកនោះឯង , **ដោយទិស** កើតក្នុងទិសទាំង ២ , **ដោយឱកាស** វាតោងជាប់ជាមួយពោះវៀនធំ ដូចជាខ្សែដែលរុំក្ដាប់កង់រុំខ្សែ ក្នុងពេលដែលពួកជាងធ្វើការឆ្លាក់ផ្សេងៗ មានការឆ្លាក់ជីកចោះជាដើម វានៅក្នុងក្នាត់ពោះវៀនធំ ២១ ក្នាត់ ដូចជាខ្សែដែលដេរធ្លាក់ក្នុងរវាងនៃខ្សែសម្រាប់ជូតជើងដូច្នោះ , **ដោយបរិច្ឆេទ** មានទីបំផុតដោយចំណែកនៃពោះវៀនតូចខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដែលជាចំណែកនៃខ្លួនឯង , រីឯ **វិសភាគ-**

បរិច្ឆេទ ការកំណត់ទីបំផុតដោយភាពខុសពីខ្លួន គឺ ដូចគ្នានឹងសក់នោះឯង ។

## ឧទរិយំ -អាហារថ្មី

វត្ថុដែលមាននៅក្នុងឧទរ ឈ្មោះថា **ឧទរិយំ - អាហារថ្មី** សំដៅយកវត្ថុដែលបរិភោគ ផឹក ទំពា លិត ភ្លក់ ចូលទៅ ឧទរិយៈនោះ **ដោយពណ៌** មានពណ៌ដូចអាហារដែលលេបចូលទៅ , **ដោយសណ្ឋាន** មានសណ្ឋានដូចអង្ករដែលប្រេកធូរៗនៅក្នុងថង់ក្រណាត់ , **ដោយទិស** កើតក្នុងទិសខាងលើ , **ដោយឱកាស** តាំងនៅក្នុងឧទរ ( ក្រពះអាហារ ) ជាអវយវៈដែលហ៊ុំពោះវៀន ស្រដៀងសំពត់សើមដែលប៉ោងត្រង់កណ្ដាល ដោយសារគេចងជាយទាំង ២ ខាង ឈ្មោះថា **ឧទរ** ខាងក្រៅរលោង ខាងក្នុងដូចសំពត់ជូតឈាមរដូវដែលប្រឡាក់ ហើយគេយកខ្ចប់សាច់វាអាចពោលថា ខាងក្នុងឧទរនោះ ដូចខាងក្នុងនៃផ្លែខ្នុរបាយស្រោ ដូច្នេះក៏គួរ , វាជាទីអាស្រ័យនៃពួកដង្កូវ មានប្រភេទផ្សេងគ្នាដល់ទៅ ៣២ ត្រកូល មានប្រភេទតក្កោជកៈ( ព្រូនទំពក់ ), ប្រភេទកណ្ឌុប្បាទកៈ( ព្រូនខ្ជួនមូល ), ប្រភេទតាលហីរកៈ( ព្រូនចង្កឹះ ) , ប្រភេទសូចិមុក្ខៈ( ព្រូនមាត់ស្រួច ) , ប្រភេទបដតន្តុ( ព្រូនសំប៉ែត=តេនញ៉ា ) , ប្រភេទសុត្តកៈ( ព្រូនអំបោះ=អៀន ) យ៉ាងនេះជាដើមអាស្រ័យនៅប្រជ្រៀតគ្នាជាសំណុំៗ ពេលរបស់បរិភោគ មានទឹក និងបាយជាដើមមិនមាន វាក៏ច្រេច្រាឡើងឲ្យរងំ នាំគ្នាចូលទៅខាំសាច់បេះដូង ពេលបរិភោគអាហារមានទឹកនិងបាយជាដើមចូលទៅ វានាំគ្នាងើយមាត់ឡើងម្នីម្នាចូលទៅដណ្ដើមអាហារដែលបរិភោគចូលទៅជាដំបូង ២-៣ ដុំ , ឧទរដែលពោលនេះ ដូចជាបន្ទប់សម្រាលកូន វច្ចកុដិ រោងព្យាបាល និង ព្រៃស្មសានរបស់ដង្កូវទាំងឡាយនោះ បើនិយាយ

ក្នុងឧទរនោះ របស់បរិភោគមានទឹកនិងបាយជាដើម មានប្រការផ្សេងៗ ដែលបុកឲ្យខ្ទេចដោយអង្រែ គឺ ធ្មេញ កៀសត្រឡប់ទៅមកដោយដៃ គឺ អណ្តាត ប្រឡាក់ដោយទឹករំលាយ គឺ ទឹកមាត់ , ខណៈនោះឯង វាជារបស់ដល់នូវការប្រាសចាកការដល់ព្រមនៃពណ៌ ក្លិន និងរសជាដើម មើលទៅដូចជាបាយជ្រលក់អំបោះរបស់ជាងតម្បាញ និង កម្អួតសុនខ , ចូលទៅហើយ ទឹកប្រមាត់ ស្លេស្ម និងខ្យល់ផុរឡើង ប្រឡាក់ដោយកម្លាំងដុតកម្តៅនៃភ្លើងក្នុងឧទរ ប៉ប្រិទៅដោយពួកដង្កូវបញ្ចេញពពុះ និង ទឹកមាត់មកខាងលើ ដល់នូវភាពជាវត្ថុស្មោកគ្រោក ជារបស់ស្អុយ និង គួរខ្ពើមដ៏ពន្លឹក តាំងនៅក្នុងពោះនោះ ដូចជាភ្លៀងធំធ្លាក់នារដូវប្រាំងហូរនាំសាកសពផ្សេង តាំងពីមូត្រ លាមក កំណាត់ស្បែក ឆ្អឹង សរសៃ ទឹកមាត់ ទឹកសំបោរនិងឈាម មកផ្តុំក្នុងទីទំនាបស្មោកគ្រោក ជិតទ្វារផ្ទះរបស់ពួកចណ្ឌាលលាយចូលគ្នាជាមួយទឹកជ្រាំ ២ - ៣ ថ្ងៃ ក៏មានដង្កូវកើតឡើង កើតចំហាយឡើងដោយកម្លាំងនៃកម្តៅថ្ងៃ បញ្ចេញពពុះនិងទឹកមាត់ឡើងលើព្រួច ៗ មានពណ៌ខៀវចាស់ គួរខ្ពើមពន្លឹក ដល់នូវភាពជារូបមិនគួរចូលជិត មិនគួរមើល នឹងពោលថ្វីថានឹងគួរហិត គួរលិតនោះ ដូច្នោះ សូម្បីត្រឹមបានស្តាប់រឿងឧទរដែលពោលនោះ ភាពជាវត្ថុដែលមិនគួរពេញចិត្តក្នុងរបស់បរិភោគទាំងឡាយ មានទឹកនិងបាយជាដើម ក៏មានបាន ចាំបាច់ពោលថ្វីដល់ការមិនគួរពេញចិត្តក្នុងរបស់បរិភោគ ដែលកើតឡើងព្រោះបានពិចារណាដោយបញ្ញាចក្ខុហើយនោះ ម្យ៉ាងទៀត ក្នុងឧទរដែលពោលនោះ របស់បរិភោគ មានទឹកនិងបាយជាដើម ដែលធ្លាក់ចូលទៅ រមែងបែកបានជា ៥ ចំណែក គឺ ដង្កូវបរិភោគមួយចំណែក , ភ្លើងក្នុងឧទរដុតបំផ្លាញមួយចំណែក , ជាបស្សាវៈមួយចំណែក , ជាឧច្ចារៈមួយចំណែក , មួយចំណែកទៀតបានជា ឱជា

ទៅឧបត្ថម្ភកោដ្ឋាសនៃរាងកាយ មានឈាម និង សាច់ជាដើម , **ដោយបរិច្ឆេទ** ឧទរិយៈនោះ មានទីបំផុតដោយក្រពេញឧទរនិងដោយចំណែកនៃឧទរិយៈខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកឧទរិយៈខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ដោយចំណែកដែលផ្សេងពីខ្លួន គឺ ដូចគ្នានឹងសក់នោះឯង ។

## ករីសំ – អាហារចាស់

ពាក្យថា **ករីសំ - អាហារចាស់** បានដល់ ឧច្ចារៈ , ករីសៈនោះ **ដោយពណ៌** មានពណ៌ដូចអាហារដែលបរិភោគចូលទៅនេះឯង ដោយច្រើន , **ដោយសណ្ឋាន** មានសណ្ឋានតាមឱកាស( ទីអាស្រ័យ ) , **ដោយទិស** កើតក្នុងទិសខាងក្រោម , **ដោយឱកាស** តាំងនៅក្នុង **បក្កាសយ**( ក្រពះឧច្ចារៈ ) , **បក្កាសយ** នោះ ដូចបំពង់ឫស្សី កម្ពស់ប្រមាណ ៨ អង្គុលី នៅខាងចុងពោះវៀនធំ ក្នុងចន្លោះផ្ចិតនិងក្រោមគល់ឆ្អឹងខ្នង ដែលជាទីអាស្រ័យនៃរបស់បរិភោគ មានទឹកនិងបាយជាដើម កាលធ្លាក់ចូលទៅក្នុង **អាមាសយ** ( ក្រពះអាហារ ) ហើយដុតឲ្យពុះ ដោយភ្លើងធាតុក្នុងឧទរ ឆ្អិនរហូតរលួយ ដូចកិនដោយត្បាល់ថ្ម ហើយហូរចុះទៅ តាមពោះវៀនធំធ្លាក់ទៅប្រមូលផ្តុំគ្នា ស្រដៀងដីពណ៌លឿង ដែលគេញាត់ចូលទៅក្នុង បំពង់ឫស្សីឧបមាដូចទឹកភ្លៀងធ្លាក់នៅភូមិភាគខ្ពង់រាប ហូរចុះទៅបំពេញរាលទំនាប ឲ្យពេញដូច្នោះ , **ដោយបរិច្ឆេទ** ករីសៈនោះ មានទីបំផុតត្រឹមក្រពេញក្រពះឧច្ចារៈ នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃករីសៈនោះ , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដែលផ្សេងពីខ្លួនឯង ដូចសក់នោះឯង ។

## មត្ថលុង្គំ - ខួរក្បាល

ពាក្យថា **មត្ថលុង្គំ - ខួរក្នុងក្បាល** គឺ គំនរជាលិកា ដែលតាំងនៅក្នុងលលាដ៍ក្បាល , ខួរក្បាលនោះ **ដោយពណ៌** មានពណ៌សដូចពណ៌ផ្សិត អាចពោលថា មានពណ៌ដូចពណ៌ទឹកដោះមិនទាន់ចម្រាញ់ នៅជាទឹកដោះស្រស់ ក៏គួរ , **ដោយសណ្ឋាន** មានសណ្ឋានតាមឱកាស ( ទីអាស្រ័យ ) , **ដោយទិស** វាកើតក្នុងទិសខាងលើ , **ដោយឱកាស** វាតាំងនៅតម្រៀបលើក្រោមផ្គុំគ្នា ៤ ប្រអប់ ប្រជុំគ្នានៅក្នុងលលាដ៍ក្បាល ស្រដៀងដុំម្សៅ ៤ ដុំ ដែលមនុស្សដាក់ប្រជុំគ្នា ដូច្នោះ , **ដោយបរិច្ឆេទ** មានទីបំផុតត្រឹមផ្ទៃខាងក្នុងលលាដ៍ក្បាល និង ខួរក្បាលគ្នាឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកខួរក្បាលខ្លួនឯង , រីឯ **វិសភាគ-បរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពផ្សេងគ្នានឹងខ្លួនឯង ដូចសក់នោះឯង ។

## បិត្តំ - ទឹកប្រមាត់

ពាក្យថា **បិត្តំ - ទឹកប្រមាត់** គប្បីអធិប្បាយថា ប្រមាត់មាន ២ គឺ ប្រមាត់ដែលនៅក្នុងថង់ ១ និងប្រមាត់ដែលមិននៅក្នុងថង់ ១ ក្នុង ២ យ៉ាងនោះ ប្រមាត់ដែលនៅក្នុងថង់ **ដោយពណ៌** មានពណ៌ ( ខៀវ ) ដូចប្រេងស្រគំខាប់ៗ , ប្រមាត់ដែលមិននៅក្នុងថង់ មានពណ៌ ( លឿង ) ដូចផ្កាពិកុលក្រៀម , **ដោយសណ្ឋាន** ប្រមាត់ទាំង ២ យ៉ាង មានសណ្ឋានតាមឱកាស ( ទីអាស្រ័យរបស់ខ្លួន ) , **ដោយទិស** ប្រមាត់ក្នុងថង់ កើតក្នុងទិសខាងលើ ប្រមាត់មួយទៀត កើតក្នុងទិសទាំង ២ , **ដោយឱកាស** ប្រមាត់មិននៅក្នុងថង់ វៀរចាកកន្លែងដែលផុតពីសាច់នៃសក់ រោម ធ្មេញ ក្រចកនិងស្បែកដែលរឹង ដែលក្រិនចេញ វាជ្រួតជ្រាបទៅទូទាំងរាងកាយ

ដ៏សេស ដូចជាដំណក់ប្រេងជ្រួតជ្រាបទៅក្នុងទឹកដូច្នោះ នៅពេលដែលវាកម្រើក កែវភ្នែករបស់សត្វទាំងឡាយនឹងទៅជាលឿង ខ្ទួនក៏ហើមជាកន្ទួលរមាស់ , ប្រមាត់នៅក្នុងថង់ ឋិតនៅក្នុងថង់ទឹកប្រមាត់ ស្រដៀងនឹងកន្សោមននោងធំ នៅជាប់នឹងសាច់ក្រោមចន្លោះបេះដូងនិងសួត កាលវាកម្រើក សត្វទាំងឡាយនឹងទៅជាឆ្កួតចិត្តនឹងវិបល្លាស មិនអើពើនឹងហិរិឱត្តប្បៈ មិនគួរធ្វើ ក៏ធ្វើបាន មិនគួរនិយាយ ក៏និយាយបាន មិនគួរគិត ក៏គិតទៅបាន , **ដោយបរិច្ឆេទ** មានទីបំផុតដោយចំណែកនៃប្រមាត់ខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយប្រមាត់ខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពផ្សេងគ្នា ដូចសក់នោះឯង ។

## សេម្ហំ – ស្លេស្ម

ពាក្យថា **សេម្ហំ** - ស្លេស្ម គឺ មានប្រមាណពេញមួយបាត្រ នៅខាងក្នុងរាងកាយ ស្លេស្មនោះ **ដោយពណ៌** ពណ៌សដូចទឹកស្លឹកត្រសក់ , **ដោយសណ្ឋាន** មាន សណ្ឋានតាមឱកាស( ទីអាស្រ័យ ) , **ដោយទិស** កើតក្នុងទិសខាងលើ , **ដោយឱកាស** តាំងនៅក្នុងក្រពេញឧទរ ក្នុងពេលដែលលេបអាហារ មានទឹកនិងបាយជាដើម កាលទឹកនិងបាយធ្លាក់ចូលទៅ វាញែកចេញពីគ្នាជា ២ ផ្នែក ហើយរួមចូលដូចដើមវិញ ដូចចកក្នុងទឹក កាលឈើ ឬ ក្បឿងធ្លាក់ចុះទៅ ក៏នឹងញែកចេញពីគ្នាជា ២ ផ្នែក ហើយរួមចូលដូចដើមវិញ , ម្យ៉ាងទៀត កាលស្លេស្មនោះ មានតិចឧទរនឹងកាយក្លិនសាកសពគួរខ្ពើមពន្លឹក ដូចបូសធ្លាយ និងដូចពងមាន់ស្អុយ មានក្លិនស្អុយគួរខ្ពើមយ៉ាងនោះ ព្រោះក្លិនដែលកើចេញមកពីឧទរនោះ សូម្បីក្លិនដែលកាយចេញពីមាត់ ក៏ស្អុយដូចក្លិនខ្មោចសត្វស្អុយដូច្នោះដែរ ហើយបុគ្គលនោះ នឹង

ត្រូវគេដេញចេញថា “ ចេញទៅ ឯងក្លិនស្អុយ ” តែកាលស្លេស្មនោះចម្រើនឡើង បានក្រាសហើយ ក៏បិទបាំងក្លិនខ្មោចសត្វទុកនៅខាងក្នុងក្រពេញឧទរបាន ដូចបន្ទះក្តារបិទវច្ចកុដិ ដូច្នោះ , **ដោយបរិច្ឆេទ** មានទីបំផុតដោយចំណែកនៃស្លេស្មខ្លួនឯងនេះជា **សភាគបរិច្ឆេទ** ការប្រកាសទីបំផុតដោយចំណែកនៃស្លេស្មខ្លួនឯង , រីឯ វិសភាគបរិច្ឆេទ ការកំណត់ទីបំផុតដែលផ្សេងគ្នា ដូចនឹងសក់នោះឯង ។

## បុព្វោ – ខ្ទុះ

ពាក្យថា **បុព្វោ** - ខ្ទុះ មានអធិប្បាយថា បុព្វោនោះ **ដោយពណ៌ប្រក្រតី** មានពណ៌លឿងខ្ចី ដូចពណ៌ស្លឹកឈើទុំ តែក្នុងរាងកាយមនុស្សស្លាប់ មានពណ៌សដូចពណ៌ទឹកបាយផ្អូមខាប់ៗ , **ដោយសណ្ឋាន** មានសណ្ឋានតាមឱកាស , **ដោយទិស** កើតក្នុងទិសទាំង ២ , **ដោយឱកាស** ( ទីអាស្រ័យ ) ពោលដោយឱកាសរបស់បុព្វោ វាមានជាប្រចាំក៏ទេ តែបើផ្នែកនៃរាងកាយត្រង់ណា ត្រូវប៉ះទង្គិចដោយ មុតបន្លា គ្រឿងប្រហារ និង រលាកភ្លើងជាដើម ឈាមក៏បាញ់ចេញ ឬថាកើតបូស ពងបែក ខ្ទុះក៏កើតត្រង់នោះៗ , **ដោយបរិច្ឆេទ** មានការកំណត់ទីបំផុតដោយខ្ទុះខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃខ្ទុះនោះ , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពផ្សេងគ្នា ដូចសក់នោះឯង ។

## លោហិតំ – ឈាម

ពាក្យថា **លោហិតំ** - ឈាម មានអធិប្បាយថា លោហិតមាន ២ យ៉ាង គឺ **សន្និចិតលោហិត** ( លោហិតដែលខាប់ ) ១ **សំសរណលោហិត** ( លោហិតដែលរាវ ) ១ ក្នុងលោហិត ២ យ៉ាងនោះ , សន្និចិតលោហិត **ដោយពណ៌** មាន

ពណ៌ដូចអាចម៍ល័ក្ខខាប់ដែលចាស់ភ្លើង ( ក្រហមក្រម៉ៅ ) , សំសរណលោហិត **ដោយពណ៌** មានពណ៌ដូចអាចម៍ល័ក្ខថ្លា ( ក្រហមស្រស់ ) , **ដោយសណ្ឋាន** លោហិតទាំង ២ យ៉ាង មានសណ្ឋានតាមឱកាស ( ទីអាស្រ័យ ) , **ដោយទិស** សន្និចិតលោហិត កើតក្នុងទិសខាងលើ លោហិតមួយទៀត កើតក្នុងទិសទាំង ២ , **ដោយឱកាស** សំសរណលោហិត ជ្រៀតចូលក្នុងសាច់នៃ សក់ រោម ធ្មេញ ក្រចក និងស្បែករឹងៗ-ស្បែកងាប់ វាជ្រួតជ្រាបទូទាំងរាងកាយដែលមានចិត្តគ្រប់-គ្រងទាំងអស់ តាមសរសៃខ្វាត់ខ្វែង មានជានិច្ច , សន្និចិតលោហិត ឋិតនៅពេញក្នុងផ្នែកខាងក្រោមដែលជាទីតាំងនៃថ្លើម មានប្រមាណពេញមួយបាត្រ វាជ្រាបសើមតិចៗ ទៅផ្សើម ទាច បេះដូង ថ្លើម និងសួត ធ្វើទាច បេះដូង ថ្លើម និងសួតឲ្យសើមជានិច្ច ព្រោះថា បើវាមិនធ្វើ ទាច បេះដូង ជាដើម ឲ្យសើមទេ សត្វទាំងឡាយនឹងដល់នូវសេចក្តីក្តៅក្រហល់ក្រហាយ, **ដោយបរិច្ឆេទ** មានទីបំផុតដោយចំណែកនៃឈាមខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃឈាមខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នា ដូចនឹងសក់នោះឯង ។

## សេទោ – ញើស

ពាក្យថា **សេទោ - ញើស** បានដល់ អាបោធាតុដែលហូរចេញតាមរន្ធនៃរាងកាយ មានរន្ធរណ្តៅរោមជាដើម សេទោនោះ **ដោយពណ៌** មានពណ៌ដូចប្រេងល្ងថ្លា , **ដោយសណ្ឋាន** មានសណ្ឋានតាមឱកាស( ទីអាស្រ័យ ) , **ដោយទិស** កើតក្នុងទិសទាំង ២ , **ដោយឱកាស** ឈ្មោះថា ឱកាសប្រចាំរបស់សេទោ ដែល

ជាកន្ទែង វាគប្បីតាំងនៅគ្រប់ពេលដូច ( សន្និចិត )លោហិត មិនមាន តែកាលណាពងកាយក្តៅឡើងដោយហេតុផ្សេងៗ មានកម្តៅភ្លើង កម្តៅថ្ងៃ និងការប្រែប្រួលនៃធាតុ កាលនោះវាទឹងហូរចេញចាករន្ធសក់និងរោមទាំងពួង ដូចជាទងឈូកដែលគេដកឡើងផុតពីទឹក មានពន្លកនិងឫសដាច់មិនស្មើគ្នា ( ទឹកក៏ហូរចេញមិនស្មើគ្នា ) ដូច្នោះ ព្រោះដូច្នោះ សូម្បីសណ្ឋានរបស់សេទោនោះ ក៏គប្បីយល់ថា មានតាមរន្ធសក់និងរោមនោះឯង ព្រះយោគីដែលកំណត់នូវសេទោ ( ជាអារម្មណ៍ ) គប្បីមនសិការនូវសេទោ តាមដែលវាឋិតនៅតាមរណ្តៅសក់និងរោមដូចគ្នា , **ដោយបរិច្ឆេទ** មានទីបំផុតដោយចំណែកនៃសេទោខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃសេទោខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នា ដូចសក់នោះឯង ។

## មេទោ – ខ្លាញ់ខាប់

ពាក្យថា **មេទោ** - ខ្លាញ់ខាប់ , ខ្លាញ់ខាប់នោះ **ដោយពណ៌** មានពណ៌ដូចពន្លកល្មៀត ( លឿងខ្ចី ) , **ដោយសណ្ឋាន** ពោលសម្រាប់មនុស្សធាត់មុន មានសណ្ឋានដូចសំពត់ទុកូលចាស់ពណ៌ល្មៀត ឋិតនៅជ្រៀតក្នុងចន្លោះស្បែកនិងសាច់ , សម្រាប់មនុស្សស្គម មានសណ្ឋានដូចសំពត់ទុកូលចាស់ពណ៌ល្មៀត ត្រួតលើគ្នា ២-៣ ជាន់ តៀកជាប់នឹងសាច់ទាំងឡាយនេះ គឺ សាច់ស្មង សាច់ភ្លៅ សាច់ខ្នងដែលជាប់នឹងឆ្អឹងខ្នង សាច់ក្រពះ , **ដោយទិស** វាកើតក្នុងទិសទាំង ២ , **ដោយឱកាស** សម្រាប់មនុស្សធាត់ វាផ្សាយទៅទូទាំងរាងកាយ សម្រាប់មនុស្សស្គម វាជាប់នៅតាមសាច់ផ្សេង ៗ ដូចជាសាច់កំភួនជើង សូម្បីធាត់ថា ជាប្រេង តែដោយ

វាជារបស់គួរខ្ពើមពន្លឹក មនុស្សទាំងឡាយទើបមិនយកវាប្រើជាប្រេងលាបក្បាល មិនយកប្រើជាប្រេងផ្សេង ៗ មានប្រេងបន្តក់ច្រមុះជាដើម , **ដោយបរិច្ឆេទ** ខាងក្រោមមានទីបំផុតត្រឹមសាច់ ខាងលើមានទីបំផុតត្រឹមស្បែក ខាងទទឹងមានទីបំផុតដោយខ្លាញ់ខាប់គ្នាឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃខ្លាញ់ខាប់ខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នា ដូចសក់នោះឯង ។

## អស្សុ – ទឹកភ្នែក

ពាក្យថា **អស្សុ** - ទឹកភ្នែក បានដល់ អាបោធាតុដែលហូរចេញពីរន្ធភ្នែក ទឹកភ្នែកនោះ **ដោយពណ៌** មានពណ៌ដូចប្រេងល្ងថ្លា , **ដោយសណ្ឋាន** មានសណ្ឋានតាមឱកាស ( ទីអាស្រ័យ ) , **ដោយទិស** វាកើតក្នុងទិសខាងលើ , **ដោយឱកាស** មាននៅក្នុងរន្ធភ្នែក តែថា វាមិនបានឋិតនៅគ្រប់ពេលក្នុងរន្ធភ្នែក ដូចទឹកប្រមាត់នៅក្នុងថង់ប្រមាត់ដូច្នោះទេ ដល់ពេលណា សត្វទាំងឡាយមានការសប្បាយចិត្ត សើចខ្លាំង មានសេចក្តីខូចចិត្តយំកន្ទក់កន្ទេញ ឬថា បរិភោគអាហារទាស់ យ៉ាងនេះចូលទៅ ម្យ៉ាងទៀត កាលណាភ្នែករបស់សត្វទាំងឡាយនោះ ប៉ះនឹងវត្ថុដែលធ្វើឲ្យទឹកភ្នែកហូរ មានផ្សែង លំអង និងធូលីជាដើម ប៉ះត្រូវក្តី ពេលនោះ វានោះទើបកើតឡើង ព្រោះការសប្បាយចិត្ត ការខូចចិត្ត អាហារ និង វត្ថុដែលទាស់ ទាំងឡាយនោះ ណាមួយ ហើយដក់នៅពេញរន្ធភ្នែកខ្លះ ហូរចេញក្រៅខ្លះ ព្រះយោគីដែលកំណត់ទឹកភ្នែក ( ជាអារម្មណ៍ ) គប្បីកំណត់តាមដែលវានៅពេញរន្ធភ្នែកនោះឯង , **ដោយបរិច្ឆេទ** មានទីបំផុតដោយទឹកភ្នែកខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់

ទីបំផុត ដោយចំណែកទឹកភ្នែកខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុត ដោយភាពខុសគ្នា ដូចសក់នោះឯង ។

## វសា – ខ្លាញ់រាវ

ពាក្យថា **វសា** ប្រែថា **ខ្លាញ់រាវ** , ខ្លាញ់រាវនោះ **ដោយពណ៌** ដូចពណ៌ប្រេងដូង សូម្បីពោលថា មានពណ៌ដូចពណ៌ប្រេងប្រួចទៅក្នុងទឹកបាយក៏គួរ , **ដោយសណ្ឋាន** មានសណ្ឋានដូចដំណក់ប្រេង ដែលអណ្តែតត្រានៅលើទឹកដែលថ្លា ក្នុងពេលលាង ( ប្រេង ) , **ដោយទិស** វាកើតក្នុងទិសទាំង ២ , **ដោយឱកាស** វាឋិតនៅត្រង់បាតដៃ ខ្នងដៃ បាតជើង ខ្នងជើង ចុងច្រមុះ ថ្ងាស និង ចន្លុយស្មាដោយច្រើន តែវារលាយនៅក្នុងឱកាសទាំងឡាយនេះគ្រប់ពេល ក៏ទេ ពេលណាកន្លែងទាំងឡាយនោះក្តៅឡើងព្រោះ កម្តៅភ្លើង កម្តៅថ្ងៃ ឧតុវិសភាគៈ និង ធាតុ-វិសភាគៈ ពេលនោះ វាទើបរលាយទៅខាងនេះខាងនោះ ក្នុងទីទាំងឡាយនោះ ដូចដំណក់ប្រេងដែលអណ្តែតត្រានៅពេលលាង ដូច្នោះ , **ដោយបរិច្ឆេទ** មានទីបំផុតដោយចំណែកនៃខ្លាញ់រាវខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដែលជាចំណែកនៃខ្លាញ់រាវខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នា ដូចសក់នោះឯង ។

## ខេឡោ – ទឹកមាត់

ពាក្យថា **ខេឡោ** - ទឹកមាត់ គឺ អាបោធាតុដែលផ្សំឡើងជាពពុះខាងក្នុងមាត់ ទឹកមាត់នោះ **ដោយពណ៌** ពណ៌សដូចពណ៌ពពុះទឹក , **ដោយសណ្ឋាន** មានសណ្ឋានតាមឱកាស ( ទីអាស្រ័យ ) អាចថា មានសណ្ឋានដូចពពុះទឹកក៏បាន ,

**ដោយទិស** កើតក្នុងទិសខាងលើ , **ដោយឱកាស** វាជ្រាបចេញពីក្រពេញថ្ពាល់ទាំង ២ ខាង មកនៅលើអណ្តាត តែថា វាមិនបានឋិតនៅទីនោះគ្រប់ពេលទេ ពេលណា សត្វទាំងឡាយឃើញ ឬនឹកដល់អាហារយ៉ាងនោះ ( គឺ ប្រភេទដែលធ្វើឲ្យចេញទឹកមាត់ ) ដាក់អាហារមានរសក្តៅ ល្វីង ហឹរ ប្រៃ ជូរ ណាៗ ចូលទៅក្នុងមាត់ក្តី ឬថា ពេលណា បេះដូងរបស់សត្វទាំងឡាយនោះខ្សោយក្តី ការខ្ពើមរអើមកើតឡើងក្នុងរបស់អ្វី ៗ ពោលនោះ ទឹកមាត់ក៏កើតពីក្រពេញថ្ពាល់ទាំង ២ ខាង មកនៅត្រង់អណ្តាត ម្យ៉ាងទៀត ទឹកមាត់នោះនៅចុងអណ្តាតមានតិច នៅត្រង់គល់អណ្តាតមានច្រើន ហើយវាមិនចេះអស់ទៅឡើយ ដូចទឹកក្នុងអណ្តូងដែលគេជីកនៅតាមឆ្នេរខ្សាច់ មិនចេះអស់ដូច្នោះ អាចនឹងញ៉ាំងអំបុក ឬ បាយ ឬ របស់គួរទំពាស៊ី អ្វីៗក៏ដោយ ដែលដាក់ចូលទៅក្នុងមាត់ឲ្យសើមបាន , **ដោយបរិច្ឆេទ** មានទីបំផុតដោយទឹកមាត់ខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃទឹកមាត់ខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នា ដូចសក់នោះឯង ។

## សិង្ឃាណិកា – ទឹកសំបោរ

ពាក្យថា **សិង្ឃាណិកា** - ទឹកសំបោរ បានដល់ ទឹកមិនស្អាតដែលហូរចេញចាកខួរក្បាល សំបោរនោះ **ដោយពណ៌** មានពណ៌ដូចទឹកក្នុងគ្រាប់ត្នោតខ្ចី , **ដោយសណ្ឋាន** មានសណ្ឋានតាមឱកាស , **ដោយទិស** កើតក្នុងទិសខាងលើ , **ដោយឱកាស** វានៅពេញរន្ធច្រមុះ តែថា វាមិនបានឋិតនៅក្នុងទីនោះគ្រប់ពេលទេ ដោយពិត កាលណា សត្វទាំងឡាយយំក្តី ជាអ្នកមានការកម្រើកនៃធាតុក្តី ដែលកើត

ឡើងដោយអំណាចនៃអាហារទាស់ និងរដូវប្រែប្រួលក្តី ពេលនោះ ខួរក្បាលក៏ក្លាយជាស្ងួស្ង ហើយហូរចេញចាកក្បាល ហូរចេញតាមប្រហោងពិតានលើរហូតពេញរន្ធច្រមុះខ្លះ ហូរចេញក្រៅខ្លះ ប្រៀបដូចជាបុគ្គលខ្ចប់ទឹកដោះជូរទុកក្នុងស្លឹកឈូក ហើយប្រើបន្លាចាក់ទម្លុះខាងក្រោម ទឹកថ្លានៃទឹកដោះជូរ ក៏ស្រក់ចេញមកតាមរន្ធនោះ ធ្លាក់ទៅខាងក្រៅដូច្នោះ ឯព្រះយោគីដែលកំណត់ទឹកសំបោរ ( ជាអារម្មណ៍ ) គប្បីកំណត់តាមដែលវានៅពេញរន្ធច្រមុះនោះឯង , ដោយបរិច្ឆេទ មានទីបំផុតដោយទឹកសំបោរខ្លួនឯង នេះជា សភាគបរិច្ឆេទ ការកំណត់ទីបំផុតដោយចំណែកនៃទឹកសំបោរខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នាដូចនឹងសក់នោះឯង ។

## លសិកា – ទឹករំអិល

ពាក្យថា **លសិកា – ទឹករំអិល** បានដល់ ខ្លាញ់ដែលមានក្លិនស្អុយដូចសពដែលទុកយូរហើយ ឋិតនៅក្នុងសន្ទាក់ក្នុងរាងកាយ ទឹករំអិលនោះ **ដោយពណ៌** មានពណ៌ដូចជ័រផ្កាកណ្ណិកា , **ដោយសណ្ឋាន** មានសណ្ឋានតាមឱកាស , **ដោយទិស** កើតក្នុងទិសទាំង ២ , **ដោយឱកាស** វាឋិតនៅក្នុងសន្ទាក់ឆ្អឹង ១០៨ កន្លែង មាននាទីចាំលាបលទសន្ទាក់ឆ្អឹងទាំងឡាយ ឯខ្លាញ់នោះ អ្នកណាមានតិច ពេលអ្នកនោះក្រោកឡើង អង្គុយ ឈានទៅមុខ ថយក្រោយ បត់ចូល លាចេញ ឆ្អឹងទាំង-ឡាយនឹងលាន់ឮ ស្រោះ ៗ ដូចបុគ្គលធ្វើសំឡេងផ្ទាត់ម្រាមដៃដូច្នោះ កាលគេដើរផ្លូវត្រឹមតែ ១ យោជន៍ ២ យោជន៍ វាយោធាតុនឹងកម្រើក ខ្លួននឹងឈឺចុកចាប់ តែបើអ្នកណាមានច្រើន ឆ្អឹងទាំងឡាយរបស់អ្នកនោះនឹងមិនលាន់ឮ ស្រោះ ៗ ព្រោះការ

កម្រើក មានការក្រោកឡើង អន្ទ្រយចុះជាដើម កាលគេដើរផ្លូវឆ្ងាយ វាយោធាតុក៏មិនកម្រើក ខ្លួនក៏មិនឈឺចាប់ , **ដោយបរិច្ឆេទ** មានទីបំផុតដោយចំណែកនៃទឹករំអិលខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃទឹករំអិលខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នា ដូចគ្នានឹងសក់នោះឯង ។

## មុត្តំ – មូត្រ

ពាក្យថា **មុត្តំ - មូត្រ** , មូត្រនោះ ដោយពណ៌ មានពណ៌ដូចទឹកក្បុងសណ្តែកសៀង , **ដោយសណ្ឋាន** មានសណ្ឋានដូចទឹកនៅក្នុងថ្នាំងដែលគេបិទមាត់ទុក , **ដោយទិស** កើតក្នុងទិសខាងក្រោម , **ដោយឱកាស** វាឋិតនៅត្រង់ក្បាលពោះវៀន , ប្លោកនោម លោកហៅឈ្មោះថា ក្បាលពោះវៀន ជាកន្លែងនាំទឹកនោមចេញពីសរីរៈ តែជាផ្លូវទឹកនោមដែលចូលទៅមិនប្រាកដ ប្រាកដតែផ្លូវចេញ ដូចទឹកជ្រាំជ្រាបចូលទៅក្នុងថ្នាំងសាច់គ្រើម ដែលបិទជិត ដែលគេទុកវានៅក្នុងថ្លុកទឹកជ្រាំ តែផ្លូវចូលរបស់វាមិនប្រាកដ ម្យ៉ាងទៀត កាលប្លោកនោមពេញដោយទឹកនោមហើយ សេចក្តីខ្វាយខ្វល់ថា យើងនឹងបន្ទោបង់បស្សាវៈ រមែងមានដល់សត្វទាំង-ឡាយ , **ដោយបរិច្ឆេទ** មានការកំណត់ទីបំផុតដោយទំរង់របស់ប្លោកនោម និងដោយចំណែក នៃទឹកនោមខ្លួនឯង នេះជា **សភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយចំណែកនៃទឹកនោមខ្លួនឯង , រីឯ **វិសភាគបរិច្ឆេទ** ការកំណត់ទីបំផុតដោយភាពខុសគ្នា ដូចនឹងសក់នោះឯង ។

# សរុប

ឯព្រះយោគាវចរកំណត់កោដ្ឋាសទាំងឡាយ មានសក់ជាដើម **ដោយពណ៌ សណ្ឋាន ទិស ឱកាស** និង **បរិច្ឆេទ** យ៉ាងនេះហើយ មនសិការថា **បដិកូល** ៗ ដោយអាការ ៥ ផ្លូវ មាន **ពណ៌ សណ្ឋាន ក្លិន ទីអាស្រ័យ** និង **ឱកាស** តាមន័យ ( មនសិការកោសល្យវិធី ) មានតាមលំដាប់ ដោយមិនលឿនពេកជាដើម ក្នុងទីបំផុតនៃមនសិការ កាលឈានកន្លងបញ្ញត្តិហើយ ពិចារណាមើលកាយនេះថា : **អត្ថិ ឥមស្មឹ កាយេ កេសា** ... សក់ទាំងឡាយ មាននៅក្នុងកាយនេះជាដើម ធម៌ទាំងឡាយទាំងពួងនោះ រមែងប្រាកដមិនមុនមិនក្រោយគ្នា ប្រៀបដូចបុរសមានចក្ខុល្អ មើលកួងមាលាដែលក្រងដោយផ្កាឈើ ៣២ ពណ៌ ដោយខ្សែតែមួយ ផ្កាឈើទាំងពួង រមែងប្រាកដ ដូចជាមិនមុនមិនក្រោយ ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបពោលទុកជាខាងដើមថា ដោយមនសិការកោសល្យថា " កាលព្រះអាទិកម្មិកៈមនសិការ ( អនុលោម ) ផ្ដើមថា **កេសា** ... មនសិការក៏ដំណើរទៅដល់ទីបំផុតនៃកោដ្ឋាសខាងចុង គឺ **មុត្តំ** នេះតែម្យ៉ាង " ប្រសិនបើព្រះយោគាវចរនោះ នឹងនាំ ( បដិកូល ) មនសិការចេញទៅក្រៅខ្លួនខ្លះសោត កាលកោដ្ឋាសទាំងពួងប្រាកដច្បាស់យ៉ាងនេះហើយ ទោះសត្វទាំងឡាយ មានមនុស្សនិងតិរច្ឆានជាដើម ដែលដើរទៅមក ក៏នឹងលះបង់អាការនៃសត្វដែលប្រាកដដល់លោក គ្រាន់តែជាគំនរនៃកោដ្ឋាសទាំងអស់ , អាហារ មានទឹកនិងបាយជាដើម ដែលសត្វទាំងឡាយនោះបរិភោគចូលទៅ ក៏ប្រាកដដូចជារបស់ដែលធ្លាក់ចូលទៅក្នុងគំនរកោដ្ឋាសប៉ុណ្ណោះ ។

## និមិត្ត និង អប្បនា

ក្នុងលំដាប់នោះ កាលលោកមនសិការរឿយៗថា **បដិកូលៗ** តាមមនសិការកោសល្យវិធីតទៅ មានវិធីរៀងតាមលំដាប់ជាដើម អប្បនានឹងកើតឡើងជាលំដាប់ ក្នុងការកើតឡើងនៃអប្បនានោះ បណ្ឌិតគប្បីជ្រាបថា ការប្រាកដនៃកោដ្ឋាស មានសក់ជាដើម ដោយអំណាចនៃ ពណ៌ សណ្ឋាន ទិស ឱកាស និង បរិច្ឆេទ ជា **ឧគ្គហ-និមិត្ត** , ការប្រាកដដោយអំណាចភាពជាបដិកូល ក្នុងអាការទាំងពួង ជា **បដិភាគ-និមិត្ត** កាលសេពធ្វើឲ្យច្រើននូវបដិភាគនិមិត្តនោះទៅ អប្បនានឹងកើតឡើងដោយអំណាចនៃបឋមជ្ឈាន ( បានត្រឹមបឋមជ្ឈាន ) ដូចអប្បនាក្នុងអសុភកម្មដ្ឋាន តាមន័យដែលពោលហើយ , ព្រះយោគាវចរណា មានកោដ្ឋាសប្រាកដតែម្យ៉ាង ឬថា ព្រះយោគាវចរណា បានសម្រេចអប្បនាក្នុងកោដ្ឋាសមួយហើយ មិនធ្វើសេចក្ដីព្យាយាមក្នុងកោដ្ឋាសដទៃតទៅទៀតក្ដី អប្បនានោះក៏រមែងកើតឡើងដល់ព្រះយោគីនោះតែមួយនោះឯង រីឯព្រះយោគីណាមានកោដ្ឋាសច្រើនយ៉ាង ប្រាកដ ឬថា ព្រះយោគីណាបានសម្រេចឈានក្នុងកោដ្ឋាសមួយហើយ ធ្វើសេចក្ដីព្យាយាមក្នុងកោដ្ឋាសដទៃតទៅទៀតក្ដី បឋមជ្ឈានច្រើនដួង តាមចំនួនកោដ្ឋាស រមែងកើតដល់ព្រះយោគីនោះបាន ដូចបឋមជ្ឈានច្រើនដួង កើតឡើងដល់ព្រះមាលកត្ថេរដូច្នោះ ។

បានឮថា ព្រះថេរៈអង្គនោះ ចាប់តាំងពីព្រះអភ័យត្ថេរដែលជាទីឃភាណ-កាចារ្យ ពោលថា “ អាវុសោ ពីពេលនេះតទៅ អ្នកចូររៀនបញ្ហានេះមុនចុះ ” ហើយប្រាប់ថា “ ព្រះថេរៈដែលចាស់ ( ១ រូប ) ជាអ្នកបានបឋមជ្ឈាន ៣២ ដួងក្នុងកោដ្ឋាស ៣២ យ៉ាង បើចូលពេលយប់ឈាន ១ ពេលថ្ងៃឈាន ១ លោកត្រូវបន្តឈាននោះរយៈពេលកន្លះខែជាង តែបើចូលក្នុង ១ថ្ងៃ ១ឈាន លោកត្រូវ

បន្តឈានទោះក្នុងពេលជាង ១ ខែ ។

## ហេតុដែលហៅថា កាយគតាសតិ

កម្មដ្ឋាននេះ សូម្បីសម្រេចបានត្រឹមបឋមជ្ឈាន តែព្រោះហេតុដែលសម្រេចដោយភាពខ្លាំងក្លានៃសតិ ក្នុងកោដ្ឋាសទាំងឡាយ ដែលមានលក្ខណៈផ្សេងៗ មានពណ៌និងសណ្ឋានជាដើម ទើបហៅថា **កាយគតាសតិ** ។

## អានិសង្សនៃការចម្រើនកាយគតាសតិ

ភិក្ខុដែលប្រកបតាមសមគួរនូវកាយគតាសតិនេះហើយ ៖

១- រមែងជាអ្នកគ្របសង្កត់បាន ទាំងសេចក្ដីមិនរីករាយនិងសេចក្ដីរីករាយ សេចក្ដីមិនរីករាយគ្របសង្កត់លោកមិនបាន តែលោកគ្របសង្កត់បាននូវសេចក្ដីមិនរីករាយដែលកើតឡើង ។

២- ជាអ្នកគ្របសង្កត់នូវការភ័យខ្លាចបាន ការភ័យខ្លាចមិនអាចគ្របសង្កត់លោកបាន លោកគ្របសង្កត់នូវការភ័យខ្លាចដែលកើតឡើងបាន ។

៣- ជាអ្នកអត់ធន់ចំពោះភាពរងា-ក្ដៅ ។ ល ។

៤- ជាប្រភេទបុគ្គលអត់ធន់ចំពោះទុក្ខវេទនាខ្លាំងក្លា... ថ្នាក់អស់ជីវិតបាន ។

៥- បានអាស្រ័យពណ៌ផ្សេងៗ នៃកោដ្ឋាសទាំងឡាយ មានសក់ជាដើម នឹងជាអ្នកបានឈានទាំង ៤ រហូតបានដល់អភិញ្ញា ៦ ។

ព្រោះហេតុនោះ ភិក្ខុអ្នកមានបញ្ញាគប្បីជាអ្នកមិនប្រមាទ បំពេញនូវកាយគតាសតិនេះ ដែលមានអានិសង្សច្រើនប្រការ ដូចពោលមកដូច្នេះចុះ ។

នេះជាកថាមុខដោយពិស្តារ ក្នុងកាយគតាសតិ ។

## មហាដីកា

## អធិប្បាយ ការកំណត់កោដ្ឋាស

ពាក្យថា **ដូចពណ៌ផ្លែផ្កាំស្រស់** ៗ គឺ ដូចពណ៌ផ្លែផ្កាំដែលទើបបេះថ្មីៗ ។ ពាក្យថា **ត្រឹមគុម្ពត្រចៀក** លោកពោលសំដៅយកផ្នែកខាងក្រោយខាងលើស្លឹកត្រចៀក ។ ខាងទទឹងមានទីបំផុតត្រឹមសរសៃសក់គ្នាឯង គឺ ដូចម្ដេច ? គឺ មានទីបំផុតដោយសក់ ២ សរសៃ មិនមែនជាប់ជា ១ សរសៃនោះទេ ។

ពាក្យថា **ដែលជាទីអាស្រ័យ** មានន័យថា ជាទីអាស្រ័យ គឺជាបច្ច័យ ។

បទថា **អសម្ភិន្នកាឡកា** ប្រែថា មានពណ៌ខ្មៅ មិនលាយដោយពណ៌ដទៃ ។

ក្រចកនោះឯង ឈ្មោះថា ស្លឹកក្រចក ព្រោះវាដូចជាស្លឹកឈើ ។ ពាក្យថា ក្រចកទាំងឡាយ **ខាងទទឹងកំណត់ដោយក្រចកគ្នាឯង** លោកពោលសំដៅយកការកំណត់បែងចែកស្លឹកក្រចកមួយៗ ។ ពិតហើយ លោកពោលថា ក្រចក ២ សន្លឹក មិនជាប់គ្នាតែមួយ គឺ មិនរួមគ្នាជា ១ សន្លឹក ដូច្នេះ ក៏ដើម្បីសម្ដែងសេចក្ដីនោះៗឯង ។

បទថា **ទន្តបាឡិយោ** ប្រែថា ជួរធ្មេញ ។ ពាក្យថា **ជន្ទល់រទេះ** គឺ ឈើទល់ទល់រទេះនៅត្រង់នឹម ។ ឆ្អឹងដែលទ្រធ្មេញទាំងឡាយ ឈ្មោះថា ឆ្អឹងថ្គាម ។

ពាក្យថា **ពេលបកចេញ** ( ចាកសរីរៈទាំងអស់ ) គឺ ពេលរួមចូលគ្នា ។

ឈ្មោះថា **កោសការកកោសោ** ប្រែថា សំបុកដង្កូវនាង , សំបុកដង្កូវនាងអាចហៅថា **កោសេយ្យផលំ** ដូច្នេះក៏មាន ។ ឈ្មោះថា **ស្បែកជើងក្រវាត់កែង**

បានដល់ ស្បែកជើងដែលស្រោបជិតកែងជើងទាំងអស់ ។ ឈ្មោះថា **អានិសទំ** បានដល់ អវយវៈដែលប្រើដើម្បីអង្គុយ ( ត្រគាក ) ។ ឈ្មោះថា **តូណិរោ** ប្រែថា បំពង់ធ្នូ ។ ឈ្មោះថា **គលកញ្ចុកំ** ប្រែថា អាវបិទក ។ ឈ្មោះថា **កីជកុលាវកំ** បានដល់ សំបុកកណ្តូប ។

ក្នុងពាក្យថា **ទាំងដោយអនុលោម និងបដិលោម** នេះ មានសេចក្តីថា ការកំណត់តាំងពីបរិវេណចង្កួយស្មាដេញចុះទៅរហូតដល់ខ្នងដៃ ចាត់ជាអនុលោម ការកំណត់តាំងពីកដៃដេញឡើងមកដល់ដើមដៃ ចាត់ជាបដិលោម ។ ពាក្យថា **ដោយន័យនោះឯង** គឺ ក្នុងន័យដែលបានពោលហើយនៃដៃស្តាំ មានន័យថា ដោយអនុលោមនិងបដិលោម ។ ពាក្យថា **ស្បែកដែលល្អិត** បានដល់ ស្បែកដែលល្អិតជាងស្បែកធំៗ តាមដែលបានពោលហើយ ។ ន័យម្យ៉ាងទៀត ក្នុងកោដ្ឋាសទាំង-ឡាយ មានស្បែកក្នុងមាត់ជាដើម ស្បែកដែលព្រះយោគីកំណត់បានដោយលំបាកព្រោះ ( ត្រូវ ) ស្បែកធំបិទបាំង ហៅថា ស្បែកតូច ។ ពិតហើយ ស្បែកតូចនោះ នឹងប្រាកដបាន កាលព្រះយោគីប្រើញាណបើកស្បែកធំ ពិចារណាតាមន័យដែលបានពោលហើយ ។ ក្នុងទីនេះ សូម្បីធាតុក៏មានគតិជាស្បែកផងដែរ ព្រោះហេតុនោះ ទើបលោកពោលថា ស្បែកក្រៅមានទីបំផុតត្រឹមអាកាស ដូច្នេះ ។ **និសទបោតោ** ប្រែថា អង្រែថ្ម ។ ពាក្យថា **ដុំចង្ក្រាន** បានដល់ ដុំចង្ក្រានដែលគេធ្វើដោយដីឥដ្ឋ ។ ឈ្មោះថា **ផែនត្នោត** បានដល់ សាច់ត្នោតទុំ គឺ គេយកត្នោតទុំមកកោសយកសាច់ពាសលើស្លឹកត្នោត ឬ ផ្ទាំងសំពត់ជាដើម ហាលឲ្យស្ងួតហើយបកចេញជាបន្ទះ ៗ ( ដូចផែនស្វាយ ) ។ ពាក្យថា **សាច់តូចៗ** បានដល់ សាច់តូចៗ ជាងសាច់តាមដែលពោលហើយ ។ លោកពោលថា ខាងទទឹងមានទី

បំផុតដោយសាច់គ្នាឯង ដូច្នេះ ព្រោះត្រង់សាច់ដែលប៉ោង មានសាច់កែងជើងជា-ដើម នៃសរីរៈទាំងមូលរបស់មនុស្សស្គម ដោយច្រើនត្រូវសាច់បិទបាំង ( គឺ មិនមានខ្វាញ់ជ្រៀត ) ។ អាវដែលមានអាការដូចសំណាញ់ ឈ្មោះថា អាវសំណាញ់ ។ សរសៃទាំងឡាយ ឈ្មោះថា ខាងទទឹងមានទីបំផុតដោយសរសៃគ្នាឯង គឺ ព្រះយោគីត្រូវកំណត់ចែកសរសៃមួយៗនោះឯង ។ លោកអាចារ្យពោលថា លើកលែងឆ្អឹងធ្មេញ ៣២ ដូច្នេះ ព្រោះកាន់យកធ្មេញទាំងឡាយ ជាកោដ្ឋាសផ្សេងដោយឡែកមួយទៀត ។ ពាក្យថា ឆ្អឹងជង្គង់ ១ កំណាត់ , ឆ្អឹងភ្លៅ ១ កំណាត់ ( ជំនួសពាក្យថា ២ កំណាត់ ) ព្រោះពោលច្បាស់លាស់ហើយថា " ជើងតែម្ខាង " ។ ស័ព្ទថា ប្រមាណយ៉ាងនេះ ថា ប្រមាណ ៣០០ កំណាត់ យ៉ាងនេះគឺ គប្បីជ្រាបថា លោកសម្ដែងឆ្អឹងដ៏សេស មានឆ្អឹងត្រគាកជាដើម ដែលមិនបានពោលទុកក្នុងទីនេះ ។ ព្រោះបានធ្វើការអធិប្បាយទុកយ៉ាងនេះ ពាក្យថា ជាគំនរឆ្អឹងជាង ៣០០ កំណាត់ ទើបគួរប្រើបាន ។

ពាក្យថា **ផ្លែអន្ទាញ់** គឺ ផ្លែអន្ទាញ់មូលដែលគេប្រើដើម្បីលេង ដោយប្រើខ្សែព្រាលចងផ្អោបគ្នា ។ ពាក្យថា **ជង្គង់** គឺ ដុំតូចៗ របស់ក្មេងលេង ។ ពាក្យថា **ឆ្អឹងស្មងដែលទល់នឹងឆ្អឹងជង្គង់នោះ** មានអធិប្បាយថា នៅត្រង់ឆ្អឹងស្មងដែលស៊កចូលក្នុងឆ្អឹងជង្គង់ ។ ត្រង់កន្លែងឆ្អឹងភ្លៅទល់នឹងឆ្អឹងចង្កេះ មានសណ្ឋានដូចផ្លែបុស្សនាគធំ ស្រួចចុង ។ ចង្ក្រានដែលជាងផ្ទាំងអ្នកធ្វើ ឈ្មោះថា ឡរបស់ជាងផ្ទាំង ។ ឈ្មោះថា **ក្រវិលបន្ទះសំណ** បានដល់ បន្ទះដែលធ្វើដោយសំណដែលគេក្រងទុក។ គ្រាប់មូលៗ ដែលគេបោះហើយ ប្រើអំបោះដោតក្រងរៀងគ្នា ឈ្មោះថា **គ្រាប់អង្កាំ** ជួរនៃគ្រាប់អង្កាំទាំងឡាយ ឈ្មោះថា **វដ្ដនាវឡី** ។

ទំពាំងដែលគេកាត់ជាកង់ៗ ដោយអាការមូល ឈ្មោះថា **កំណាត់ទំពាំង** ។

ឈ្មោះថា **គាំបិតព្រា** បានដល់ គាំបិតសម្រាប់សកសម្បកអំពៅ ។

ពាក្យថា **មានទីបំផុតដោយចំណែកនៃទាចខ្ទួនឯង** គឺ មានទីបំផុតដែលជាចំណែកជុំវិញទាចនោះ ។ សូម្បីកោដ្ឋាសដទៃក្រៅអំពីទាចនេះ ក៏មានលក្ខណៈយ៉ាងនេះ មានន័យយ៉ាងនេះ ។

ពាក្យថា **ដែល ( មនោធាតុ និង មនោវិញ្ញាណធាតុ ) អាស្រ័យ** គឺ ដែលជាលោហិត ជាកន្លែង ( មនោធាតុ និង មនោវិញ្ញាណធាតុ ) អាស្រ័យ , សូម្បីទីអាស្រ័យ ( គឺ លោហិត ) នៃទីអាស្រ័យ ( របស់មនោធាតុ និងមនោវិញ្ញាណ-ធាតុ គឺ ហទយវត្ថុ ) ក៏ហៅថា ទីអាស្រ័យ ផងដែរ ។ ព្រោះថា បញ្ញត្តិថា ហេតុ រមែងមានបាន សូម្បីក្នុងហេតុនៃហេតុ ដូចពាក្យថា " ផ្ទះឆេះព្រោះពួកចោរ " ដូច្នេះ " គឺ ផ្ទះឆេះព្រោះហេតុ គឺ ភ្លើង តែពួកចោរជាហេតុនៃភ្លើង " ទើបពោលកាត់ថា " ផ្ទះឆេះព្រោះពួកចោរ " ។ ន័យម្យ៉ាងទៀត ហទយវត្ថុ អាស្រ័យនៅក្នុងរូបកលាបៈណា រូបកលាបៈនោះ តាំងនៅជាធម្មជាតិដែលមានគតិជាលោហិតនោះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ជាលោហិតដែល ( មនោធាតុ និង មនោវិញ្ញាណធាតុ ) អាស្រ័យ ។

បទថា **បណ្ឌុធាតុកំ** កែជា **បណ្ឌុកសការំ** - មានពណ៌លឿង ជាបន្ទះ ។

ពាក្យថា **សាច់សម្រាប់ស្រោប** គឺ សាច់សម្រាប់បិទជុំវិញ ។

ពាក្យថា **សាច់មានសណ្ឋានដូចអណ្ដាត** គឺ សាច់ដែលតាំងនៅផ្នែកខាងលើនៃពោះ ដែលមានសណ្ឋានដូចអណ្ដាត ។ លោកពោលថា **មានពណ៌នីលំ** ឈ្មោះថា ពណ៌និល ( ខៀវចាស់ ) មានច្រើនបែប ព្រោះហេតុនោះ លោកទើបពោល

ថា មានពណ៌ដូចផ្កាគន្ធិស ដូច្នេះ ។

ពាក្យថា **សាច់ស្ងួត** បានដល់ សាច់ដែលសំយុងចុះមូល តូចបន្តិច ដូចដែលពោលហើយនោះឯង ។ បទថា **នីរសំ** កែជា **និហីនរសំ** ( អស់រស គឺ ស្ងាំង ) បទថា **និរោជំ** កែជា **និប្បកំ** ឬ **ឱជារហិតំ** ( មិនស្រស់ថ្លា ឬ ប្រាសចាកឱជា គឺ ស្ងួកស្ងាំង ) ។

ពាក្យថា **បត់ជាក្នាត់** គឺ តាំងបត់ជាក្នាត់ ។ បទថា **សក្ខរសុធាវណ្ណំ** ប្រែថា មានពណ៌ដូចកំបោ.ស ដែលធ្វើពីក្រួស ។ បាឋៈថា **សេតសក្ខរសុធាវណ្ណំ** ដូច្នេះ ក៏មាន មានន័យថា មានពណ៌ដូចដុំក្រួស.ស និង មានពណ៌ដូចកំបោ.ស ។

លោកអាចារ្យកាលនឹងសម្ដែងថា រីឯ ទីតាំងដែលបត់ជាក្នាត់ទៅមក នៃពោះវៀនធំ ឈ្មោះថា **ក្នាត់ពោះវៀនធំ** ។ អវយវៈដែលចងភ្ជាប់រមូរនឹងពោះវៀនធំនោះ ឈ្មោះថា **អន្តគុណំ** - ពោះវៀនតូច ដូច្នេះ ទើបពោលថា បទថា **អន្តគុណំ** បានដល់ អវយវៈដែលរុំភ្ជាប់រមូរជាមួយពោះវៀនធំ ។ រុំព័ទ្ធរមូរពោះវៀនធំ ឲ្យជាប់គ្នាតែមួយ ដូចអ្វី ដូចខ្សែយន្តចងដុំយន្ត នៃអ្នកធ្វើការងារ មានការជីក និង ចោះជាដើម ។ ឋិតនៅក្នុងរវាងក្នាត់នៃពោះវៀនធំនោះ ។ ល ។ សម្រាប់ជូតជើង ។ ក្នុងពាក្យទាំងឡាយនេះ បណ្ឌិតគប្បីឃើញថា ( ពាក្យឧបមាដំបូង ដូចខ្សែរុំភ្ជាប់នឹងដុំយន្ត ) នេះជានិទស្សនៈសម្ដែងដល់ការរុំព័ទ្ធ , ពាក្យឧបមាទី ២ ( ដូចខ្សែដែលដេរធ្លាក់ ។ ល ។ ) ជានិទស្សនៈសម្ដែងដល់អាការជាទីតាំង ។

ឈ្មោះថា **អសិតំ** - របស់ស៊ី បានដល់ បាយជាដើមសម្រាប់បរិភោគ ។ ឈ្មោះថា **បិតំ** - របស់ផឹក បានដល់ ទឹកបានៈជាដើមលេបចូលដោយការផឹក ។ ឈ្មោះថា **ខាយិតំ** - របស់ទំពា បានដល់ របស់គួរទំពា មានសំបកឈើ ឫសឈើ

ផ្លែឈើជាដើម ដែលបានមកខាំទំពា ។ ឈ្មោះថា **សាយិតំ** - របស់លិត បាន ដល់ ផ្លែស្វាយទុំ ទឹកឃ្មុំ ទឹកអំពៅជាដើមដែលធ្វើឲ្យធ្លាញ់បាន ។

បទថា **យត្ថ** ស្មើនឹង **យស្មឹ ឧទរេ** និង បទថា **យំ** លោកបំណងយកឧទរ នោះឯង ។ ក្នុងសេចក្ដីថា ជាកន្លែងផ្ទុករបស់ផឹក របស់ស៊ីជាដើម ដែលធ្លាក់ចុះ ទៅហើយ តាំងនៅ ។ ឈ្មោះថា **កម្ពុតសុនខ** បានដល់ វត្ថុដែលសុនខក្អួតចេញ ។ បទថា **វិវេកំ** ស្មើគ្នានឹង **វិភាគំ** ( ចំណែក ) ។

ពាក្យថា **ក្នុងចន្លោះផ្ចិត និងក្រោមគល់ឆ្អឹងខ្នង** គឺ ចំកណ្ដាលបរិវេណក្រោម ផ្ចិត រហូតដល់ផ្នែកខាងមុខ ( នៃក្រពះអាហាចាស់ ) និង ឆ្អឹងខ្នងខាងក្រោម ផ្នែកខាងក្រោយ “ ទាក់ទងឆ្អឹងខ្នងនិងក្រពះអាហារចាស់ ” អធិប្បាយថា ជា ផ្នែកមួយដូចបំពង់ឫស្សី ។

ពាក្យថា **រួមចូល** គឺ ផ្សំគ្នា ។

ពងមាន់ដែលដល់នូវភាពស្អុយ ឈ្មោះថា ពងមាន់ស្អុយ ។ ឈ្មោះថា **ឧទ្ទេកោ** - ខ្យល់កើ បានដល់ ខ្យល់ដែលផុសឡើងមកលើសុទ្ធៗ ប្រាសចាកទឹក ប្រមាត់ជាដើម ។

ឈ្មោះថា **អាចាម** - ពពុះទឹកបាយ បានដល់ ចំណែកទឹកបាយដែលគេចាក់ ចោល ។

ក្នុងពាក្យថា **ផ្សើម ទាច បេះដូង ថ្លើម និង សួត ឲ្យសើម** នេះ គប្បី ឃើញថា ធ្វើថ្លើមឲ្យសើម ក៏ដោយការធ្វើចំណែកខាងក្រោមឲ្យពេញផងដែរ ធ្វើ អវយវៈក្រៅពីនេះឲ្យសើម ក៏ដោយបង្ហូរតិចៗទៅលើអវយវៈទាំងនោះ ។

ឈ្មោះថា **ការប្រែប្រួលនៃរដូវ** បានដល់ ឧតុប្រែប្រួល មានការក្ដៅខ្លាំង

ក្លៀនធ្លាក់ខ្លាំងជាដើម ជាហេតុ ។ លោកប្រើស័ព្ទថា **ដាច់មិនស្មើគ្នា** ដើម្បីសម្តែង ពន្ទកឈូកជាដើមដែលដាច់មិនស្មើគ្នា ទឹករមែងហូរចេញមកមិនស្មើគ្នា យ៉ាងណា សរីរៈ ( ក៏មានញើស ) ហូរចេញពីរន្ធរោម-សក់ជាដើម ផ្សេងគ្នា មិនស្មើគ្នាទាំង ខាងលើ ទាំងខាងក្រោម និង ជុំវិញខ្លួន ដូច្នោះ ។

ពាក្យថា **អាហារដែលទាស់** គឺ អាហារដែលជាអសប្បាយ ដោយការ កំណត់យកសរីរៈដែលប្រព្រឹត្តទៅក្នុងពេលនោះ ឬថា បានដល់ អាហារដែលជា វិសភាគៈ មានម្ទេសច្រើនពេក ក្តៅខ្លាំងពេកជាដើម ។ រីឯ ក្នុងសម្មោហវិនោទនី លោកពោលទុកខ្លី ៗថា “ **វិសភាគាហារំ** - អាហារដែលជាវិសភាគៈ ” ព្រោះជា វិសភាគៈចំពោះធាតុទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងពេលនោះ ។

ពាក្យថា **នៅពេលលាង** នេះ លោកពោលទុកដើម្បីសម្តែងសភាពនៃប្រេង អណ្តែតលើទឹក ។ បទថា **បរិព្ភមន្តសិនេហពិន្ទុវិសដ្ឋសណ្ឋានា** ប្រែថា មាន សណ្ឋានដូចដំណក់ប្រេងដែលអណ្តែតត្រា ( លើទឹក ) ។ **ឧតុវិសភាគ** មានហេតុ ខាងក្រៅជាសមុដ្ឋាន ។ **ធាតុវិសភាគ** មានហេតុខាងក្នុងជាសមុដ្ឋាន ។ ពាក្យថា **បរិវេណទាំងឡាយនោះ** បានដល់ បរិវេណបាតដៃជាដើមទាំងនោះ ។

ពាក្យថា ( **រសក្តៅ ។ ល ។ រសជូរ** ) **ណាៗ** គឺ វត្ថុដែលជាអាហារមាន រសក្តៅជាដើម យ៉ាងណាមួយ ។ បទថា **នេសំ** គឺ របស់សត្វទាំងឡាយនោះ ។ ២ បទថា **ហទយំ អាគិលាយតិ** គឺ បរិវេណបេះដូងរមួល ព្រោះអាស្រ័យអាហារ ដែលជាវិសភាគៈជាដើម ។

ទឹកថ្លា ៗ នៃទឹកដោះជូរដែលហូរចេញ ឈ្មោះថា **ទធិដ្ឋំ** ។ បទថា **គឡិត្វា** ប្រែថា ដំណក់ ។ ពាក្យថា **ហូរចុះមកតាមពិតានក្បាល** គឺ វាហូរចុះមកតាម

ប្រហោងក្បាល ហើយហូរចុះមកតាមពិតានមាត់ខាងលើ ។

**ទឹករំអិល** ឈ្មោះថា ធ្វើកិច្ច គឺ ការរំអិលសន្លាក់នៃឆ្អឹងទាំងឡាយ ឲ្យសម្រេច ក៏ដូចជាប្រេងធ្វើកិច្ច គឺ ការរំអិលភ្លៅដែលនៅក្នុងជុំនៃរទេះឲ្យសម្រេច ។ ពាក្យថា **នឹងលាន់ឮ ព្រោះ ៗ** គឺ នឹងលាន់សំឡេងឮ **ព្រោះ ៗ** , ពាក្យថា **ព្រោះៗ** នេះជាការស្តែងសំឡេងថ្ងូរ ។ បទថា **ទុក្ខន្តិ** កែជា **ទុក្ខិតានិ** គឺ កើតទុក្ខ ( មានការឈឺចាប់ ) ។

ទឹកដែលគេស្ងោរសណ្តែកសៀង ព្រមទាំងឫស ហើយចាក់ផេះចូលទៅ ឈ្មោះថា **ទឹកក្បួសសណ្តែកសៀង** ។ ស្ថានទីដែលគេចោលទឹកស្អោកគ្រោក មានមន្ទិលគិកជាដើម ឈ្មោះថា **ថ្លុកទឹកជ្រាំ** ។ ឈ្មោះថា **ឆ្នាំងសាច់គ្រើម** តាមប្រក្រតីជាឆ្នាំងមិនមានមាត់ឡើយ ។ ឆ្នាំងសាច់គ្រើមណា មិនមានមាត់ដែលទឹកជ្រាបចូលបាន សូម្បីត្រឹមមួយចុងម្ជុល , លោកអាចារ្យពោលថា **ក្នុងឆ្នាំងសាច់គ្រើម ដែលបិទមាត់** ក៏ដើម្បីសម្តែងឆ្នាំងសាច់គ្រើមនោះឯង ។ ពាក្យថា **សេចក្តីខ្វាយខ្វល់** គឺ ការត្រិះរិះ ។

ពាក្យថា **ឯវណ្ហិ** ... “ រីឯ.... យ៉ាងនេះហើយ ” ជាដើម ជាពាក្យពោលបញ្ជាក់ដល់ឧបដិបត្តិក្នុងឧគ្គហកោសល្យ តាមដែលពោលហើយ ។ ឥឡូវនេះលោកអាចារ្យបំណងនឹងកាន់យក ទាំងឧបដិបត្តិក្នុងមនសិការកោសល្យ តាមដែលលោកបានពោលទុក ទាក់ទងនឹងពាក្យពោលបញ្ជាក់សេចក្តី ហើយសម្តែងកម្មដ្ឋានឲ្យដល់កំពូល ទើបផ្តើមពាក្យថា **តាមលំដាប់** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **ក្នុងទីបំផុតនៃការឈានកន្លងបញ្ញត្តិ** គឺ ក្នុងទីបំផុតនៃភាវនាដែលប្រព្រឹត្តទៅ ទាក់ទងនឹងការឈានកន្លងបញ្ញត្តិ ថា **សក់** ជាដើម ។ ពាក្យថា **ដូច**

**ជាមិនមុនមិនក្រោយ** គឺ ដូចជាព្រមគ្នា ។ **ឥតិ** ស័ព្ទ ក្នុងបទថា **កេសាតិ** មាន អត្ថថា ជាដើម , ឬមានអត្ថថា ប្រការ , មានន័យថា ( កំពុងមើលនូវកាយនេះ ) តាមន័យយ៉ាងនេះថា ក្នុងកាយនេះ មានសក់ជាដើម , ឬដោយប្រការនេះថា ក្នុងកាយនេះ មានសក់ ។ ពាក្យថា **ធម៌ទាំងឡាយនោះ** បានដល់ ធម៌ គឺ កោដ្ឋាសទាំងឡាយដែលព្រះយោគីកំណត់ ដោយទាក់ទងនឹងពណ៌ជាដើម ដែលប្រាកដដោយអាការជាបដិកូល ។

ពាក្យថា **ខាងក្រៅខ្លួនខ្លះ** គឺ ខាងក្រៅខន្ធសន្តានរបស់ខ្លួនខ្លះ មានន័យថា ក្នុងកាយដែលជាខន្ធសន្តានរបស់អ្នកដទៃ ។ ពាក្យថា **នឹងបង្អោនមនសិការ** គឺ នឹងបង្អោនមនសិការថា ជាបដិកូលតាមដែលពោលហើយថា នេះយ៉ាងណា នោះក៏ដូច្នោះ ។ ពាក្យថា **ក្នុងពេលកោដ្ឋាសទាំងពួង ជាធម្មជាតិប្រាកដច្បាស់ហើយយ៉ាងនេះ** មានន័យថា ក្នុងពេលកោដ្ឋាស មានសក់ជាដើមទាំងពួងប្រាកដហើយដោយភាវៈដែលជាក់ច្បាស់ ដោយអំណាចភាពជាបដិកូល ក្នុងកាយរបស់ខ្លួនយ៉ាងណា សូម្បីក្នុងកាយរបស់អ្នកដទៃក៏ដូច្នោះ ។ សេចក្តីនេះ ជាការនាំវិសេសរបស់ព្រះយោគី ដូចជាការពង្រីកនិមិត្តក្នុងកសិណទាំងឡាយ ដែលលោកបានសម្តែងទុកក្នុងកាយគតាសតិនេះ ។

ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) ក្នុងពាក្យថា **ការធ្វើទៅតាមលំដាប់ជាដើម** លោកកាន់យកការប្រកបភាពស្មើគ្នានៃសេចក្តីព្យាយាម ដែលព្រះយោគីអប់រំហើយ តាមន័យនៃព្រះសូត្រ ។ ពាក្យថា **មនសិការដដែលៗ** គឺ មនសិការឲ្យប្រព្រឹត្តទៅរឿយៗ " **ជាបដិកូល ជាបដិកូល** " ក្នុងកាយ គឺ ក្នុងសក់ជាដើមរបស់ខ្លួន តាមន័យដូចពោលហើយ ។ ក្នុងវេលាណាឥន្ទ្រិយទាំងឡាយ មានសទ្ធា

ជាដើម បានទូវភាពស្មើគ្នា ជាធម្មជាតិចាស់ក្លា ប្រព្រឹត្តទៅ , ក្នុងវេលានោះ អង្គឈានទាំងឡាយ មានវិតក្កៈជាដើម ដែលបានការឧបត្ថម្ភពីព្រះសទ្ធម្ម ៧ បានទទួលកម្លាំងដ៏វិសេស ព្រោះព្រះយោគីជាអ្នកឆ្ងាយចាកអសទ្ធិយៈ ( អ្នកមិនមានសទ្ធា ) ជាដើម រមែងប្រាកដជាធម្មជាតិចាស់ក្លា ។ នីវរណធម៌ទាំងឡាយ ដែលជាសត្រូវដោយត្រង់នៃអង្គឈានទាំងឡាយនោះ ក៏ត្រូវគ្របសង្កត់ ព្រមជាមួយនឹងបាបធម៌ទាំងឡាយ ដែលតាំងនៅក្នុងចិត្តប្បាទជាមួយនឹងនីវរណៈនោះ ។ ចិត្តរមែងតាំងមាំដោយឧបចារសមាធិ , ព្រះយោគីនោះ កាលសេព ចម្រើន ធ្វើឲ្យច្រើននូវនិមិត្តនោះហើយ រមែងសម្រេចអប្បនាបាន ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា អប្បនានឹងកើតឡើងតាមលំដាប់ ។ ពាក្យថា **ដោយអាការទាំងពួង** គឺ ដោយអាការទាំង ៥ យ៉ាង ទាក់ទងនឹងពណ៌ជាដើម ។ បទថា **សា** បានដល់ អប្បនា ។

លោកអាចារ្យធ្វើពាក្យសួរទុកក្នុងចិត្តថា ប្រសិនបើកម្មដ្ឋាននេះ សម្រេចបានត្រឹមបឋមជ្ឈាន ដូចនឹងអសុភកម្មដ្ឋានដែលគ្មានវិញ្ញាណ , បើដូច្នោះ ហេតុអ្វី ទើបហៅថា **កាយគតាសតិទៅវិញ** ដូច្នេះហើយ ទើបពោលថា “ **សម្រេចបានត្រឹមតែបឋមជ្ឈានយ៉ាងនេះ** ” ជាដើម ។ ក្នុងកម្មដ្ឋាននេះ កិច្ចរបស់សតិប្រព្រឹត្តទៅក្នុងកោដ្ឋាស ៣២ ដែលមាន ពណ៌ សណ្ឋាន ជាដើមផ្សេងៗគ្នា ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ព្រោះសម្រេចដោយកម្លាំងសតិ** ដូច្នេះ ។

ព្រះយោគីឈ្មោះថា **ជាអ្នកគ្របសង្កត់សេចក្តីមិនរីករាយ-រីករាយបាន** ក៏ព្រោះអត្ថថា ញាំញី គឺ គ្របសង្កត់ការមិនរីករាយ ( ភាពអោ ការនឿយណាយ ) ក្នុងសេនាសនៈដែលស្ងាត់ និង ក្នុងអធិកុសលទាំងឡាយ ព្រមទាំងសេចក្តីត្រេកអរ

ក្នុងកាមគុណទាំងឡាយបាន ព្រោះសេចក្ដីមិនរីករាយ-រីករាយ ត្រូវលោកដែលគិតដល់សភាពនៃរាងកាយ លះបង់បានហើយ ។ យ៉ាងនោះដូចគ្នា ព្រោះស្នេហាក្នុងខ្លួនអស់ទៅហើយ ដោយការចម្រើនកោដ្ឋាស លោកទើបគ្របសង្កត់នូវការភ័យខ្លាច និងអារម្មណ៍ដែលគួរភ័យខ្លាចបាន , ជាប្រភេទមនុស្សដែលអត់ធន់ចំពោះអន្តរាយមានភាពរងាជាដើម ។ ពិតហើយ ការភ័យខ្លាច និងអារម្មណ៍ដែលគួរខ្លាច ព្រមទាំងការមិនអត់ធន់ចំពោះទុក្ខ នឹងមានដល់យើងបាន ក៏ព្រោះសេចក្ដីស្នេហាក្នុងខ្លួន។ លោកអាចារ្យ កាលនឹងសម្ដែងថា សម្រាប់ភិក្ខុដែលតាមប្រកបនូវកោដ្ឋាសភាវនានេះ នឹងសម្រេចត្រឹមបឋមជ្ឈានតែម្យ៉ាង ក៏ទេ រមែងសម្រេចបាននូវការចាក់ធ្លុះក្នុងគុណវិសេសក្រៃលែងឡើងទៅ ទើបពោលថា “ **អាស្រ័យពណ៌ មានសក់ជាដើម** ” ដូច្នេះជាដើម ។

( ចប់ មហាដីកា )

( ចប់ កាយគតាសតិកម្មដ្ឋាន )

( សមាធិនិទ្ទេស **ភាគ ២** ចប់ ត្រឹមប៉ុណ្ណេះ... មានបន្ត **ភាគ ៣** )

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៤

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

# ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានកុំព្យូទ័រជាដើម ក្នុងកិច្ចការខាងដោជនូវ

※ឧបាសិកា ហម យិម

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បូ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ ស៊ីថូ ឧបាសិកា ថៃ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បូ ចន្ថា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បូ ដាវី កញ្ញា អ៊ឹង មុយហៀក

※លោកម្ចាស់ សោម ហួន

លោកគ្រូជម្ទាចារ្យ អៀ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យឹម សំណាង ឧបាសិកា យឹម ច័ន្ទបូ(LAURA) +បុត្រធីតា

ឧបាសិកា លីប៉ុលីន ស៊ីមប៉ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនជានេត

លោកអាចារ្យ ផាត សារឿយ ឧបាសិកា វ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មូនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ឆាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ( SABOREAK SOK )

ឧបាសក យក់ ស៊ីមូរ៉ា ឧបាសិកា តាន់ រ៉ាណា

ឧបាសក អ៊ឹង រិទ្ធី ឧបាសិកា ជូជារី

ឧបាសក មាស សារ៉េត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គីមអេង

❋ឧបាសក ឈុំ គីម គីមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន យឹម) ឧបាសិកា ណៃ គីមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❋ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ងួន សុធីរ

ឧបាសិកា ស្ងួន កល្យាណ

ឧបាសិកា ស្ងួន ចរណៃ

ឧបាសិកា ស្ងួន កញ្ញារ័ត្ន

❋ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គីមចៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គីមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងនិម និងស្វាមី ព្រមទាំងកូនចៅ

❋ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ដុះ ចំណាន

ឧបាសិកា វិញ ពូន

❋ឧបាសក ឡាំ ជៀន ឧបាសិកា សឺន ចន្ទា

ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុភី

ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា

ឧបាសក ឡាំ ដាវណ្ណ ឧបាសិកា ឡាំ ចាន់វារី

❋ឧបាសក ជុំ ឈាង ឧបាសិកា ចៀម អ៊ូន ព្រមទាំងបុត្រ

ញោម ឥម្មុន្ទីនិងជូ ញោម ហាន ញោម រ៉ែន ញោម ភ័ណ្ឌ ញោម

សុមនា ញោម ជោត ញោម មាស សុភា ញោម ឡៃ លី កញ្ញា

នា ញោម ឆាង ញោម ជីង ឡេង ញោម អៀម ញោម ភួង

ញោម អុំភា ញោម សុភា ញោម វល័ក្ខ ញោម ឆាលី លីណា

ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម

ស៊ិន ញោម គាព សារឿន ញោម ហ៊ន ញោម ប៊ូ សៀកលីវ

ញោម យក់ វ៉ាន់ថា ។

❋ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុន សេរី

លោក ដេង រស្មី និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ

❋ឧបាសក អ៊ឹង ហេ្គចឡេង ឧបាសិកា តាំង ប៉េជីង ព្រមទាំងបុត្រ

លោក ឆៃ ហេង អ្នកស្រី អ៊ឹង ស៊ីវគៀង ព្រមទាំងបុត្រ

លោក ភួ ពុយ អ្នកស្រី អ៊ឹង ណងពិន ព្រមទាំងបុត្រ

លោក អ៊ឹង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ

លោក ប៊ុ ទី អ្នកស្រី តាំង ប៉ោគិម ព្រមទាំងបុត្រ

ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្ដាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុភនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អៀន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ុ ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ប៉ែ អេង+គឹម ធី+ខៀវ វ៉ន+ គឹម

ញោម នឿង+យាយ ធឹង+គួង ភាង+សើន គា+សឿង+គឹម អាង

ញោម សេង ឆេង+ផាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាក់ឡៃន+ ហ៊ុង+ ប៉ែ ង៉ា+ រី វុត្ថ

ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណេរ អ៊ុំ វីរៈ

ញោមប៉ែ ង៉ាថ្មគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈឿត

ញោម ហ៊ុង+នាង មឿន+អូន ប៉ុច+ ឡាត វ៉ាន់ឃិន+ ម៉ម សុខហេង

ញោម គឹម ឡេង+តាំង វេន+ យុន+ យាយ ធុច + យាយ យន
ញោម ហ៊ន ស៊ម ញោម អឿន គី+វ៉ាន់ ស៊ុនឡាយ+ផល្ល៊ី+សវ៉ាមី
ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លឹម+សេង ទូច+ស៊ីវ ទី
ញោម ណោ ហ្គេចណៃ+វ៉ាន់ សុផានី+សា វឿន+សំ គី+ចាន់ ណាក់
ញោម ធាក់+យឿត និងស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី
ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គឹម អ៊ី
ញោម អៀប សានួន+ យាយ ហឿន+យាយ ឡាំ+កេន សេងមុំ
ស ខាន់ថង+ស៊ី ណាត+យឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

# នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា
# ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន
លោកគ្រូធម្មបណ្ឌិត ( ទក្ខប្បញ្ញោ ) អឿ សៅ

| | |
|---|---|
| ឧបាសិកា ធីក ស្រ៊ន | ព្រមទាំងកូនប្រុស អ៊ឹង រិទ្ធី និងភរិយា |
| ឧបាសក ប៊ូហោ នាង | ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា |
| ឧបាសក យេម សំណាង | ឧបាសិកា យេម ឡូរ៉ា ព្រមទាំងបុត្រ |
| ឧបាសក សៅ ហ៊ាន | ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ |
| ឧបាសក ឈៀង សាវឿន | ឧបាសិកា ឈុំ ឆដា ព្រមទាំងបុត្រធីតា |
| ឧបាសក ម៉ៅ វង្ស | ឧបាសិកា ឆាន់ កាន់ជួង ព្រមទាំងបុត្រ |

ឧបាសក និន ហាក់ ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ
ឧបាសិកា មុី ចាន់រ៉ាវី ព្រមទាំងបុត្រធីតា
ឧបាសិកា យ៉ក់ សុីមូរ៉ា ព្រមទាំងបុត្រ
ឧបាសិកា វ៉ាន់ចាន់ ព្រមទាំងបុត្រធីតា
ឧបាសិកា ខៀវ ណាត ព្រមទាំងបុត្រធីតា

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឆាយ អុីវស៊ាង ឧបាសិកា ហុង គីមសែ កូន+ចៅ
ឧបាសិកា យូ ស៊ាងទន្ទលី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ប៊ុន ហេង ឧបាសិកា ជុំ សុខុម
ឧបាសិកា ហេង ស្រីជា ឧបាសិកា ហេង ស្រីចន្ទ
ឧបាសិកា ហេង គន្ធា ឧបាសក ហេង សុកត្រ័

## នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឈុំ គីមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ

ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ ព្រមទាំងកូន

ឧបាសក អ៊ឹង ហ្គិចឡេង ឧបាសិកា តាំង ប៉ោងជឹង ព្រមទាំងកូនចៅ

ឧបាសក វៀម ឈើន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ

ឧបាសក ញ៉ែម មឿន ឧបាសិកា វៀម ចុល ព្រមទាំងកូនចៅ

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក នាង រ៉ា ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ

ឧបាសក សៅ ស៊ុន្ទរា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ

ឧបាសក ណូ ស្វែង ឧបាសិកា សោម គីមលួន ព្រមទាំងកូនចៅ

ឧបាសិកា ងិន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ

ឧបាសិកា សោម គីមលៀម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា គីម ធវី និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ទាវ គីមយក់ ឧបាសិកា អ៊ុម គីមជីវ

ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី

ឧបាសិកា ហួត អេង ឧបាសិកា ឡោ សាយហ្គិច

ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ

ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ

ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ

ឧបាសិកា សឿង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទនៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ចេង ស៊ីម ព្រមទាំងបុត្រ ធីតា និងចៅ

លោក លី ហុង អ្នកស្រី ជាណារី ព្រមទាំងបុត្រ ធីតា

លោក ផូ ចាន់ថន អ្នកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក លីម ចាន់ឌី អ្នកស្រី ទេព ចិន្តា ព្រមទាំងបុត្រ ធីតា

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា អ្នកស្រី លីម ចាន់មុនីរ័ត្ន ព្រមទាំងបុត្រ

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉េត

លោក ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហេងគង់ ឧបាសិកា ទូច សារុន ព្រមទាំងកូនចៅ

ឧបាសិកា ធុយ ឈីវអួន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គីមហ៊ាន ព្រមទាំងកូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា អ្នកស្រី មុំ ដាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័ត អ្នកស្រី មុំ ដា ព្រមទាំងបុត្រ ធីតា

ឧបាសិកា ប៉ោ យេកលៀង ព្រមទាំងបុត្រ ធីតា និងចៅ

លោក រស់ ប៊ុនឡេង អ្នកស្រី ឡេង ស៊ីនី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្វាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀង នីម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ិន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គីម សេង ព្រមទាំងកូនចៅ

ឧបាសិកា ហួយ ជន ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

អ្នកស្រី ជុន បូណាំមី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ជា ព្រមទាំងកូនចៅ

ឧបាសិកា គីម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និងកុមារី សុជាតា

ឧបាសិកា ជា រួបទៀង ព្រមទាំងកូនចៅ

ឧបាសក ជី សុខអៀម ឧបាសិកា តាំង ស៊ូអេង ព្រមទាំងកូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជី ញ៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុជី ហៅ អ៊ំម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា ផាវ ហ៊ិន ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសិកា គី ប៊ួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ារិទ្ធ អ្នកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ

ឧបាសិកា យន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ចាន់ថា ព្រមទាំងកូនចៅ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា ស៊ិន ឡាច ព្រមទាំងកូនចៅ

ឧបាសក ប៊ុន បួន ឧបាសិកា យុត សួរ ព្រមទាំងកូនចៅ

លោក ផាន សុបិន អ្នកស្រី សំ សុវណ្ណមល្លិកា ព្រមទាំងបុត្រ

បងស្រី ណៅ សុភី និងប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឹន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី អ្នកស្រី អួន សារ៉េត ព្រមទាំងបុត្រ

លោក ឱម ឡូត អ្នកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រ

លោក ម៉ាន់ សារឿន អ្នកស្រី ម៉ម សុជា ព្រមទាំងបុត្រ

លោក ស៊ឹម សារ៉ាន់ អ្នកស្រី លី សុខរ៉េត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហេងវណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គឹមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូ ប៉ុក ព្រមទាំងកូនចៅ

ឧបាសិកា ប៉េ សារ៉ា ឧបាសក ម៉ើ ធារី

ឧបាសិកា ម៉ៅ ណារី ព្រមទាំងកូនចៅ

ឧបាសក ប៉ែ ស៊ីថា ឧបាសិកា ឈួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូច សាមុត ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង វ៉េត ព្រមទាំងកូនចៅ

ឧបាសិកា សេក ម៉ាន ព្រមទាំងកូនចៅ

ឧបាសិកា ច័ន្ទ សោភ័ណ្ឌ

ឧបាសក ជូ បូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

ឧបាសក ឃ្លោក ម៉ាន ឧបាសិកា ផូ ឡា ព្រមទាំងកូនចៅ

ឧបាសក ហាន គង់ ឧបាសិកា តេង លីគាង ព្រមទាំងកូនចៅ

ឧបាសិកា ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសិកា ម៉ៅ សុផានី ព្រមទាំងកូនចៅ

លោក លឹម លី អ្នកស្រី ជាវ ប៊ួយ ព្រមទាំងបុត្រ

ឧបាសិកា សោម សូត្រ ព្រមទាំងកូនចៅ

ឧបាសិកា អ៊ុយ សុខុន និងកូន ឈុន ពុធធារី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅភ្នំពេញមានសទ្ធាជ្រះថ្លា
## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ ព្រមទាំងកូនចៅ

ឧបាសិកា យិន មួយឡាង ឧបាសិកា យិន មួយហួ ព្រមទាំងកូនចៅ

ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ធីតា ព្រមទាំងកូនចៅ

ឧបាសិកា កាំង ប៉ោទៀង និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា យ៉ា សុខគឹម ព្រមទាំងកូនចៅ

ឧបាសិកា តឹក អេងគី ព្រមទាំងកូនចៅ

ឧបាសិកា ទី សុធី +បុត្រ ហែម តុលា

## នាមពុទ្ធបរិស័ទនៅស្រុកថ្មគោលមានសទ្ធាជ្រះថ្លា
## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក តាំង ម៉េង ឧបាសិកា លី ហ៊ុយស៊ីម ព្រមទាំងកូនចៅ

ឧបាសក លី ប៊ុនយូរ ឧបាសិកា យ៉ាន ស៊ី ព្រមទាំងកូនចៅ

លោក លី ប៊ុនហាក់ អ្នកស្រី តាំង ស៊ីវទៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈក្នុងការទានធម្មទាន

១- ឧបាសក ប៉េង តាំងហៃ ឧបាសិកា ហ៊ួ គឹមហៀក

| | |
|---|---|
| ២- ឧបាសក ស្រេង ស្រ៊ាង | ឧបាសិកា គិម ចន្ថា |
| ៣- ឧបាសក ឡាយ សុខុម | ឧបាសិកា គី គីមហាប់ |
| ៤- ឧបាសិកា បូ ម៉ាឡា | ឧបាសក បញ្ញា |
| ៥- ឧបាសិកា ង៉ែង យូអេង | ឧបាសិកា មាស ម៉ូនីកា |
| ៦- ឧបាសក លឹម ខូង | ឧបាសិកា កែវ អុន |
| ៧- ឧបាសិកា កែវ កល្យាណ | ឧបាសិកា ឡឹក ពេញចិត្ត |
| ៨- ឧបាសិកា ស៊ីន ចន្ថា | លោក ឡាំ ដាវណ្ណ |
| ៩- ឧបាសិកា គួ ប៊ុនគាង | ឧបាសិកា ឈុំ គីមហួយ |
| ១០- ឧបាសិកា នេត្រ នរិន្ទ | ឧបាសិកា តាំង ប៉ោងជីង |
| ១១-ឧបាសិកា ឱម លក្ខណា | ឧបាសិកា ហេង ច័ន្ទបុញ្ញវត្តី |
| ១២-ឧបាសិកា គី យក់បួយ | ឧបាសិកា ឈុន ណាត |
| ១៣-ឧបាសិកា អ៊ឹង រិទ្ធារី | ឧបាសិកា សៀក ឆាយគីម |
| ១៤-ឧបាសិកា វៀម ជុល | ឧបាសិកា ម៉ៅ នី |
| ១៥-ឧបាសិកា សន ឈៀត | ឧបាសក ឡាន សុខុម |
| ១៦-ឧបាសិកា គី វណ្ណហាក់ | ឧបាសិកា ប៉ាន ណម |
| ១៧-ឧបាសិកា ស្ងួន កល្យាណ | ឧបាសិកា ភួង កក្តី |
| ១៨-ឧបាសក អ៊ឹង រ៉ែយ៉ា | ឧបាសក កុយ សាមន |
| ១៩-ឧបាសក ហុង សុវណ្ណារិទ្ធ | ឧបាសក ហុង សុវណ្ណារ៉េត |

តម្លៃបោះពុម្ពក្នុង ១ ក្បាល ២$ × ១០០០ ក្បាល = ២០០០ $

ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខ

ទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ព សៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ ០៧៧ ៦៦ ៦៦ ៣៨, ០៨៨៨ ៧៧ ៩៩ ៦៦, ០១២ ៣០៥ ៧៦៦ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

-**ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ ទៀត តែប៉ុណ្ណោះ ។

-**វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរ ហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៨៣៣ ទំព័រ ។

-**គម្ពីរអភិធម្មត្ថសង្គហៈ** និង **វិភាវិនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរ ហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៦៥០ ទំព័រជាង ។

-**អភិធម្មត្ថសង្គហៈ** និង **បរមត្ថទីបនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរ ហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៩៨៩ ទំព័រជាង ។

-**គម្ពីរអភិធម្មាវតារ** សព្វថ្ងៃនេះបានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

-**មិលិន្ទបញ្ហា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

-**ខ្ញុំព្រះករុណា អាត្មាភាព** មានបំណងនឹងរាបចំធ្វើ **គម្ពីរព្រះត្រៃបិដក** និង**គម្ពីរព្រះអដ្ឋកថា** បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាង

ក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

**-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយ កុំព្យូទ័រចប់ហើយ** ( ០១. ០៥. ២០១០, ២៧. ០៣. ២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ ដែលធ្វើសម្រេចជាស្ថាពរនោះ មានដូចខាងក្រោមនេះ គឺ

**-គម្ពីរវិន័យបិដក បានធ្វើរួចជាស្រេចហើយ មានចំនួន ១៤ ភាគ**

**-គម្ពីរទីឃនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៦ ភាគ**

**-គម្ពីរមជ្ឈិមនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៩ ភាគ**

**-គម្ពីរសំយុត្តនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១១ ភាគ**

**-គម្ពីរអង្គុត្តរនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១៣ ភាគ**

**-គម្ពីរខុទ្ទកនិកាយ ប្រែបាន ៣៧ ភាគហើយ**

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ សព្វថ្ងៃនេះបានចំនួន ៩០ ក្បាលជាងហើយ ។

# សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ
# ខ្ញុំព្រះករុណា អាត្មាភាព
# ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះអសីតិមហាសាវក **មាន ៤ ភាគ** ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-ជីវប្រវត្តិព្រះពុទ្ធឧបាសក **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-រឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាន **មាន ៥ ភាគ** ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មាន ១ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស មាន ៣ ភាគ

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ភាគ ១-២

-ធម៌សូធ្យនមស្ការបែបសម័យទំនើប

-គម្ពីរសារត្ថសង្គហៈ ភាគ ១

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-ពុទ្ធប្បវត្តិ

សូមអនុមោទនាធម្មទាន !!!

សីល សមាធិ បញ្ញា